# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ២៨

បាលីប្រែ ៥២ - ៥៣ - ៥៤

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មនោរថបូរណី អដ្ឋកថា

## សេចក្ដីប្រែជាភាសាខ្មែរ

# អង្គុត្តរនិកាយ

# ចតុក្កនិបាត តតិយ-ចតុត្ថភាគ

# បញ្ចកនិបាត បញ្ចមភាគ

# ២៨

## បាលីប្រែ ៤២-៤៣-៤៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ២៨

# សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# តតិយ-ចតុត្ថភាគ

*សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## ទុតិយបណ្ណាសក

## បុញ្ញាភិសន្ទវគ្គ

### បឋមបុញ្ញាភិសន្ទសូត្រទី ១

[ ៥២ ] *ម្នាលភិក្ខុទាំងឡាយ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌នេះ មាន ៤ យ៉ាង រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល មាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលប្រើប្រាស់ចីវររបស់ទាយកណា ចូលកាន់ចេតោសមាធិ ជាធម៌ប្រមាណមិនបាន អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលរបស់ទាយកនោះ ក៏រមែងប្រមាណមិនបាន ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ*

កាលបរិភោគបិណ្ឌបាតរបស់ទាយកណា ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលប្រើប្រាស់សេនាសនៈរបស់ទាយកណា ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបរិភោគភេសជ្ជបរិក្ខារជាបច្ច័យ ដល់អ្នកជំងឺរបស់ទាយកណា ចូលកាន់ចេតោសមាធិ ជាធម៌ប្រមាណមិនបាន អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលរបស់ទាយកនោះ ក៏រមែងប្រមាណមិនបាន ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ៤ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត កាលបើអរិយសាវកដែលប្រកបដោយអានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទាំង ៤ នេះហើយ បុគ្គលមិនងាយនឹងរាប់នូវប្រមាណនៃបុណ្យថា អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌មានប្រមាណប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថា ជាគំនរបុណ្យយ៉ាងធំដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយរាប់នូវប្រមាណនៃទឹកក្នុងមហាសមុទ្រថា ទឹកមានប៉ុណ្ណេះអាឡ្ហក ទឹកមានប៉ុណ្ណេះរយអាឡ្ហក ទឹកមានប៉ុណ្ណេះពាន់អាឡ្ហក ទឹកមានប៉ុណ្ណេះសែនអាឡ្ហកបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថា គំនរទឹកធំ ដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវកដែលប្រកបដោយអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទាំង ៤ យ៉ាងនេះឯងហើយ បុគ្គលមិនងាយនឹងរាប់នូវប្រមាណនៃបុណ្យថា អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌មានប្រមាណប៉ុណ្ណេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថា ជាគំនរបុណ្យយ៉ាងធំដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់ ក៏យ៉ាងនោះដែរ ។

ទន្លេទាំងឡាយដែលមានពួកត្រីនៅអាស្រ័យ ច្រើនតែហូរចុះទៅ
កាន់សាគរ មានអន្លង់ទឹកធំដែលបុគ្គលរាប់មិនបាន ជាស្រះធំ
ប្រកបដោយអារម្មណ៍គួរស្ញប់ស្ញែងដ៏ច្រើន ជាទីកើតនៃរតនវត្ថុ
ទាំងឡាយ យ៉ាងណាមិញ ។ ធារនៃបុណ្យរមែងប្រព្រឹត្តហូរ
ទៅកាន់នរជន ដែលជាបណ្ឌិត អ្នកឲ្យនូវបាយទឹក និងសំពត់
អ្នកឲ្យនូវទីដេក ទីអង្គុយ និងគ្រឿងកម្រាល ដូចជាទន្លេ ស៊ឹង
ដែលហូរទៅកាន់សាគរ យ៉ាងនោះដែរ ។

# អដ្ឋកថា

# ទុតិយបណ្ណាសក

## បឋមបុញ្ញាភិសន្ទវគ្គទី ១

### បឋមបុញ្ញាភិសន្ទសូត្រ

[ ៥២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបុញ្ញាភិសន្ទសូត្រទី ១ នៃទុតិយ-បណ្ណាសកទី ២ ដូចតទៅនេះ បទថា* **បុញ្ញាភិសន្ទា** *បានដល់ ការហូរមកនៃបុណ្យ អធិប្បាយថា ការកើតឡើងនៃបុណ្យ ។ បទថា* **កុសលាភិសន្ទា** *នោះ ជាវេវចនៈនៃបទថា* **បុញ្ញាភិសន្ទា** *នោះឯង ។ ឈ្មោះថា* **សុខស្សាហារា** *ព្រោះថា ការហូរមកនៃបុណ្យទាំងនេះ នាំមកនូវសេចក្ដីសុខមកឲ្យ ។ ឈ្មោះថា* **សោវគ្គិកា** *ព្រោះថា ឲ្យអារម្មណ៍ មានរូបជាដើមដោយល្អ ។ ឈ្មោះថា* **សុខវិបាកា** *ព្រោះបុណ្យទាំងនោះមានសេចក្ដីសុខជាវិបាក ។ ឈ្មោះថា* **សគ្គសំវត្តនិកា** *ព្រោះប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។*

*បទថា* **ចីវរំ បរិភុញ្ជមានោ** *សេចក្ដីថា ភិក្ខុបានសំពត់ដើម្បីធ្វើចីវរ ព្រោះម្លូល និងអំបោះជាដើមមិនមាន ទើបរក្សាទុកឯងខ្លះ ធ្វើឯងខ្លះ ឲ្យអ្នកដទៃធ្វើខ្លះ ដណ្ដប់ឯងខ្លះនូវសំពត់នោះ ក្នុងវេលាសំពត់ចាស់ ធ្វើជាសំពត់ក្រាលដេកខ្លះ មិនអាចធ្វើជាសំពត់ក្រាលដេកបាន ក៏ធ្វើជាសំពត់ក្រាលផែនដីខ្លះ ហែកសំពត់ដែលមិនសមនឹងក្រាលផែនដីធ្វើជាសំពត់ជូតជើងខ្លះ ក៏ហៅថា បរិភោគ ។ តែកាលណាគិតថា សំពត់នេះ បុគ្គលណាមិនអាចធ្វើជា*

សំពត់ជូតជើងបាន ក៏បោះចោលទៅ កាលនោះឈ្មោះថា មិនបរិភោគ ។ បទថា **អប្បមាណំ ចេតោសមាធឹ** គឺអរហត្តផលសមាធិ ។ បទថា **អប្បមាណោ តស្ស បុញ្ញាភិសន្ទោ** នេះ ត្រាស់ដល់បុញ្ញចេតនារបស់ទាយក រាប់ប្រមាណមិនបាន ដ្បិតថា បុញ្ញចេតនារបស់ទាយកនោះ ដែលប្រព្រឹត្តទៅហើយ ដោយអំណាចការរឭកដល់រឿយៗ ថា ភិក្ខុដែលជាទីណាស្រឡាញ់ បរិភោគចីវររបស់អាត្មាអញ ដូច្នេះ ឈ្មោះថា រាប់ប្រមាណមិនបាន ពាក្យនេះ ត្រាស់សំដៅដល់សេចក្ដីនោះ ។ ឯក្នុងបិណ្ឌបាតជាដើម ភិក្ខុណាបរិភោគបិណ្ឌបាត តាំងជីវិតនៅបាន ដោយបិណ្ឌបាតនោះឯង បាន ៧ ថ្ងៃ មិនបរិភោគបិណ្ឌបាតដទៃ ។ ភិក្ខុនោះ ឈ្មោះថា បរិភោគនូវបិណ្ឌបាតនោះឯង តាំងនៅបាន ៧ ថ្ងៃ ។ ក្នុងសេនាសនៈ ១ កន្លែង ភិក្ខុចង្ក្រមក្ដី អង្គុយក្ដី ក្នុងលំនៅពេលយប់ និងពេលថ្ងៃជាដើម ឈ្មោះថា បរិភោគដរាបទល់នឹងមិនទាន់លះបង់សេនាសនៈដែលបានហើយ ទៅកាន់យកសេនាសនៈដទៃ ។ កាលជំងឺតម្កាត់ស្ងប់រម្ងាប់ដោយថ្នាំមួយមុខ លោក ឈ្មោះថា បរិភោគដរាបទល់គ្នានឹងមិនទាន់បរិភោគថ្នាំមុខដទៃ ។

បទថា **ពហុភេរវំ** បានដល់ ប្រកបដោយអារម្មណ៍ដែលគួរខ្លាចច្រើន ។ បទថា **រតនគណានំ** បានដល់ នៃរតនៈដែលប្រសើរ ៧ យ៉ាង ។ បទថា **អាលយំ** បានដល់ ទីនៅអាស្រ័យ ។ បទថា **បុថូ សវន្តិ** បានដល់ ស្ទឹងដ៏ច្រើនហូរទៅ ។ បទដ៏សេស ក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយ ។៚

**អដ្ឋកថាបឋមបុញ្ញាភិសន្ទសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយបុញ្ញាភិសន្ទសូត្រទី ២

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល នាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌នេះមាន ៤ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោកទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់កពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ១ ដែលនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក

ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនវលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ២ ដែលនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ព្រះសង្ឃជាសាវកនៃព្រះដ៏មាន ព្រះភាគ ប្រតិបត្តិដោយត្រង់ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិសមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ព្រះសង្ឃអង្គណា បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកបូជា គួរទទួលនូវអគ្គនកទាន គួរទទួលនូវទក្ខិណាទាន

គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ៣ ដែលនាំមកនូវសេចក្ដីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវកជាអ្នកប្រកបដោយសីលទាំងឡាយ ជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលវិញ្ញូជន តែងសរសើរ ជាសីលមិនប៉ះពាល់ដោយតណ្ហាទិដ្ឋិ ប្រព្រឹត្តទៅដើម្បីបាននូវសមាធិ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ៤ ដែលនាំមកនូវសេចក្ដីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលមាន ៤ យ៉ាងនេះឯង ជាទីនាំមកនូវសេចក្ដីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។

សេចក្ដីជឿក្នុងព្រះតថាគតរបស់បុគ្គលណា មិនបានញាប់ញ័រ
បានតម្កល់ហើយដោយប្រពៃ សីលរបស់បុគ្គលណា ជាសីល

ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈសរសើរ ហើយ ។ សេចក្តីជ្រះថ្លាក្នុងព្រះសង្ឃ និងការឃើញដោយត្រង់ពិត របស់បុគ្គលណា អ្នកប្រាជ្ញទាំងឡាយ ពោលនូវបុគ្គលនោះថា ជាអ្នកមិនទ័លក្រ ទាំងជីវិតរបស់បុគ្គលនោះមិនបានសូន្យឡើយ ។ ព្រោះហេតុនោះ អ្នកប្រាជ្ញ កាលរឭកឃើញពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរប្រកបទុកនូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវការឃើញធម៌ផង ។

# អដ្ឋកថា

## ទុតិយបុញ្ញាភិសន្ទសូត្រ

[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយបុញ្ញាភិសន្ទសូត្រទី ២ ដូចតទៅ បទថា **អរិយកន្តេហិ** គឺដោយសីលសម្បយុត្តដោយមគ្គ និងផល។ សីលទាំងនោះ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្តរបស់ព្រះអរិយៈទាំងឡាយ ។ ពាក្យដែលគប្បីពោលក្នុងសូត្រនោះ បានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **សទ្ធា** សេចក្តីថា លោកបំណងយកសទ្ធារបស់សោតាបន្នបុគ្គល ។ សូម្បីសីលក៏ជាសីលនៃសោតា-

បន្ទបុគ្គលនោះឯង ។ បទថា **ឧជុភូតញ្ច ទស្សនំ** សេចក្តីថា ការឃើញរបស់បុគ្គលដែលអស់អាសវៈ ឈ្មោះថា ជាការឃើញត្រង់ ព្រោះលោកមិនមានការវៀចវេរ ផ្លូវកាយជាដើម ។ បទថា **អាហុ** ប្រែថា ពោល ។ បទថា **បសាទំ** គឺនូវការជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **ធម្មទស្សនំ** គឺឃើញធម៌ ។៚

## អដ្ឋកថា ទុតិយបុញ្ញាភិសន្ទសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមសង្វាសសូត្រទី ៣

[ ៥៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះស្រុកមធុរា និងចន្លោះស្រុកវេរញ្ជា ។ មានពួកគហបតី និងពួកគហបតានីជាច្រើននាក់ ដើរទៅកាន់ផ្លូវឆ្ងាយក្នុងចន្លោះស្រុកមធុរា និងចន្លោះស្រុកវេរញ្ជាដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គេចចេញចាកផ្លូវហើយ ទ្រង់គង់ក្រោមម្លប់ឈើមួយ ។ ពួកគហបតី និងគហបតានីទាំងនោះ បានឃើញព្រះដ៏មានព្រះភាគ ស្តេចគង់ក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកគហបតី និងគហតានី

ទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាល គហបតី និងគហបតានីទាំងឡាយ សង្វាស ( ការនៅរួមគ្នាជាមួយនឹងស្វាមីភរិយា ) នេះមាន ៤ យ៉ាង ។ សង្វាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ខ្មោចប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ។ ម្នាលគហបតីទាំងឡាយ ចុះខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ប្រព្រឹត្តនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់ស្វាមីនោះ ក៏ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ប្រព្រឹត្តធ្វើនូវអទិន្នាទាន ប្រព្រឹត្តធ្វើនូវកាមេសុមិច្ឆាចារ ពោលនូវពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលគហបតីទាំងឡាយ ចុះខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោក

នេះ ជាអ្នកធ្វើនូវបាណាតិបាត ។បេ។ ក្រេបផឹកនូវសុរា និងមេរ័យដែល ជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវ មន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួក សមណព្រាហ្មណ៍ ប៉ុន្តែ កិរិយារបស់ស្វាមីនោះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ ជាអ្នកវៀរ ចាកការក្រេបផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តី ប្រមាទ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តី កំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរ ប្រទេច ពួកសមណព្រាហ្មណ៍ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជា មួយនឹងទេវតាស្រី ។ ម្នាលគហបតីទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជា មួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ មានសីល មានធម៌ល្អ មានចិត្តប្រាសចាក មន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួក សមណព្រាហ្មណ៍ ទើបឯកិរិយារបស់ស្វាមីនោះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណា- តិបាត ។បេ។ ក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃ សេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិល គឺ សេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណ-

ព្រាហ្មណ៍ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ទេវតាប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលគហបតីទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមី ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកការក្រេបផឹកនូវ ទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមាន សីល មានធម៌ដ៏ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់ គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់ស្វាមី នោះ ក៏ជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកការក្រេបផឹកនូវទឹក ស្រវឹង គឺសុរានិង មេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមានសីល មានធម៌ដ៏ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាល គហបតីទាំងឡាយ សង្វាស ( ការនៅរួមគ្នា ) មាន ៤ យ៉ាងនេះឯង ។

ជនទាំងពីរនាក់ ជាអ្នកទ្រុស្តសីល ជាអ្នកកំណាញ់ស្វិតស្វាញ
ជេរប្រទេច ( នូវសមណព្រាហ្មណ៍ ) ប្រពន្ធ និងប្តីទាំងពីរនាក់
នោះ ឈ្មោះថា ខ្មោចមកនៅរួមគ្នា ។ ស្វាមីជាអ្នកទ្រុស្តសីល
មានសេចក្តីកំណាញ់ស្វិតស្វាញ ជេរប្រទេច ( នូវសមណ-
ព្រាហ្មណ៍ ) ភរិយាជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួក
ស្មូម មានសេចក្តីកំណាញ់ប្រាសចេញហើយ ភរិយានោះឯង

ឈ្មោះថា ទេវតាស្រីនៅរួមគ្នាជាមួយនឹងប្តីខ្មោច ។ ស្វាមីជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកមានសេចក្តីកំណាញ់ប្រាសចេញហើយ ករិយាជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញស្វិតស្វាញ ជេរប្រទេច ( នូវសមណ-ព្រាហ្មណ៍ ) ករិយានោះឯង ឈ្មោះថា ស្រីខ្មោចនៅរួមគ្នាជាមួយនឹងប្តីទេវតា ។ ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកសង្រួម ( ក្នុងសីល ) ជាអ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធ និងប្តីទាំងពីរនាក់នោះពោលពាក្យផ្អែមល្ហែមទៅរកគ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏ចម្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា ពួកសត្រូវរមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់មានសីល និងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ បើនូវមានចំណង់ក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយក្នុងទេវលោកបាន ។

# អដ្ឋកថា

## បឋមសង្វាសសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសង្វាសសូត្រទី ៣ ដូចតទៅនេះ បទថា **សម្ពហុលាបិ ខោ គហបតី ច គហបតានិយោ ច** សេចក្តីថា គហបតី និងគហបតានីជាច្រើន កាលទៅធ្វើអាវាហមង្គល ឬវិវាហមង្គល ក៏បានដើរផ្លូវនោះដូចគ្នា ។ បទថា **សំវាសា** សេចក្តីថា ការនៅរួមគ្នា ការនៅរួមតែមួយ ។ បទថា **ឆវោ ឆវាយ** សេចក្តីថា ឈ្មោះថា ខ្មោចប្រុស ព្រោះស្លាប់ដោយការស្លាប់នៃគុណ នៅរួមជាមួយខ្មោចស្រី ព្រោះស្លាប់ដោយការស្លាប់នៃគុណដូចគ្នា ។ បទថា **ទេវិយា សទ្ធឹ** សេចក្តីថា ខ្មោចប្រុសនៅរួមនឹងទេវតាស្រី ដោយគុណទាំងឡាយ ។ បទថា **ទុស្សីលោ** គឺស្វាមីជាបុគ្គលមិនមានសីល ។ បទថា **បាបធម្មោ** គឺមានធម៌លាមក ។ បទថា **អក្កោសកបរិភាសកោ** សេចក្តីថា ជេរដោយរឿងសម្រាប់ជេរ ១០ យ៉ាង ដោយសម្តែងភ័យគំរាម ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបទទាំងពួងយ៉ាងនេះ ។

បទថា **កទរិយា** បានដល់ កំណាញ់ស្វិតស្វាញ ។ បទថា **ជានិបតយោ** ប្រែថា ភរិយាស្វាមី ។ បទថា **វទញ្ញូ** បានដល់ ដឹងនូវអត្ថនៃពាក្យរបស់យាចក ។ បទថា **សញ្ញតា** បានដល់ ប្រកបដោយសេចក្តីសង្រួមក្នុងសីល ។ បទថា **ធម្មជីវិនោ** បានដល់ ឈ្មោះថា **ធម្មជីវី** ព្រោះតាំងនៅក្នុងធម៌ចិញ្ចឹមជីវិត ។ បទថា **អត្ថា សម្បចុរា ហោន្តិ** សេចក្តីថា មនុស្សទាំងនោះ រមែងបានប្រយោជន៍ ពោល គឺការចម្រើនដ៏ច្រើន ។ បទ

ថា **ជាសុកំ ឧបជាយតិ** សេចក្តីថា កើតជាមួយគ្នាយ៉ាងផាសុក ។ បទថា **កាមកាមិនោ** បានដល់ បុគ្គលនៅមានការប្រាថ្នាក្នុងកាម ។៚

## អដ្ឋកថាបឋមសង្វាសសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ទុតិយសង្វាសសូត្រទី ៤

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ សង្វាស ( ការនៅរួមគ្នាជាមួយនឹងស្វាមីភរិយា ) នេះ មាន ៤ យ៉ាង ។ សង្វាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយទេវតាស្រី ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នទាន ធ្វើនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យរោយរាយ មានអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយើញខុស ទ្រុស្តសីល មានធម៌លាមក មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់របរឹត នៅគ្រប់

គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងកិរិយារបស់បុរសនោះ ក៏ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ធ្វើនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យរោយរាយ មានអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីឃើញខុស ទ្រុស្តសីល មានធម៌លាមក មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលភិក្ខុទាំង-ឡាយ ចុះខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ធ្វើអទិន្នាទាន ។បេ។ មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ ប៉ុន្តែកិរិយារបស់បុរសនោះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្ប-លាបៈ មិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ ឃើញត្រូវ មានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំង-

ឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ មានសេចក្ដីឃើញត្រូវ មានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទើបឯកិរិយារបស់បុរសនោះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ។បេ។ មានចិត្តត្រូវមន្ទិល គឺសេចក្ដីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណ-ព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងកិរិយារបស់បុរសនោះ ក៏ជាអ្នកវៀរចាកបាណាតិបាត ។បេ។ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថាទេវតាប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលភិក្ខុទាំងឡាយ សង្វាសមាន ៤ យ៉ាងនេះឯង ។

ជនទាំងពីរនាក់ ជាអ្នកទ្រុស្តសីល ជាអ្នកកំណាញ់ស្វិតស្វាញ

ជេរប្រទេច ( សមណព្រាហ្មណ៍ ) ប្រពន្ធ និងប្ដីទាំងពីរនាក់

នោះ ឈ្មោះថា ខ្មោចនៅរួមជាមួយគ្នា ។ ស្វាមីជាអ្នកទ្រុស្ត-សីល មានសេចក្តីកំណាញ់ស្វិតស្វាញ ជេរប្រទេច (សមណ-ព្រាហ្មណ៍) ភរិយា ជាអ្នកមានសីល ជាអ្នកដឹងនូវពាក្យពេចន៍នៃពួកស្មូម មានសេចក្តីកំណាញ់ប្រាសចេញហើយ ភរិយានោះឯង ឈ្មោះថា ទេវតាស្រីនៅរួមគ្នាជាមួយនឹងប្តីខ្មោច ។ ស្វាមីជាអ្នកមានសីស ដឹងនូវពាក្យពេចន៍នៃពួកស្មូម មានសេចក្តីកំណាញ់ប្រាសចេញហើយ ភរិយាជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញ់ស្វិតស្វាញ ជេរប្រទេច ( សមណព្រាហ្មណ៍ ) ភរិយានោះឯង ឈ្មោះថា ស្រីខ្មោចនៅរួមគ្នាជាមួយនឹងប្តីទេវតា ។ ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា អ្នកដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកសង្រួម ( ក្នុងសីល ) អ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធ និងប្តីទាំងនោះ ពោលពាក្យផ្អែមល្ហែមទៅរកគ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា ពួកសត្រូវរមែងអាក់អន់ចិត្តចំពោះជនទាំងពីរ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់មានសីល និងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ( បើ ) មានចំណង់ក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយក្នុងទេវលោកបាន ។

# អដ្ឋកថា

## ទុតិយសង្ខាសសូត្រ

[ ៥៥ ] ទុតិយសង្វាសសូត្រទី ៤ ទ្រង់ត្រាស់កំណត់ទេសនាដោយអំណាចកម្មបថ ។ បទដ៏សេសក៏ដូចឈ្មោះដូចគ្នា ។ ក្នុងព្រះសូត្រទាំង ២ នេះ ត្រាស់បដិបទាសម្រាប់បុគ្គលដែលនៅគ្រប់គ្រងផ្ទះផង គួរដល់គ្រហស្ថដែលជាសោតាបន្ន និងសកទាគាមីផង ៕

### អដ្ឋកថា ទុតិយសង្ខាសសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមសមជីវិសូត្រទី ៥

[ ៥៦ ] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងភេសកឡាវ័នជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុង្សុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ស្ដេចចូលទៅកាន់និវេសន៍របស់គហបតី ឈ្មោះនកុលបិតា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ នកុលបិតាគហបតី និងនកុលមាតាគហបតានី បាននាំគ្នាចូលទៅគាល់ព្រះដ៏មាន

ព្រះភាគ លុះចូលទៅដល់ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំព្រះអង្គបានប្រសព្វគ្នានឹងនកុលមាតាគហបតានី តាំងពីកំលោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលមាតាគហបតានី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។ ចំណែកនកុល-មាតាគហបតានី ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះដែរថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំម្ចាស់បានប្រសព្វគ្នានឹងនកុលបិតាគហបតី តាំងអំពីកំលោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលបិតាគហបតី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី និងគហបតានីទាំងឡាយ បើជនទាំងពីរនាក់ប្តីប្រពន្ធ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជួបគ្នាក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។

ជនទាំងពីរនាក់ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យពេចន៍នៃ
ស្មូម ជាអ្នកសង្រួម ( ក្នុងសីល ) អ្នកចិញ្ចឹមជីវិតតាមគន្លង

ធម៌ ប្រពន្ធ និងប្ដីទាំងនោះ ពោលពាក្យផ្អែមល្ហែមរកគ្នានិង គ្នា រមែងមានសេចក្ដីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា ពួកសត្រូវរមែងអាក់អន់ចិត្ត ចំពោះ ជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់មាន សីល និងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ បើ មានចំណង់ក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយ ក្នុង ទេវលោកបាន ។

# អដ្ឋកថា

## បឋមសមជីវិសូត្រ

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសមជីវិសូត្រទី ៥ ដូចតទៅនេះ បទថា **តេនុបសង្កមិ** សេចក្ដីថា សួរថា ព្រះមានព្រះភាគទ្រង់ចូលទៅរក ដើម្បីអ្វី ឆ្លើយថា ដើម្បីទ្រង់អនុគ្រោះ ។ ពិតហើយ ព្រះតថាគតកាលទ្រង់ ទៅកាន់ដែននោះ រមែងយាងទៅដើម្បីទ្រង់សង្គ្រោះមនុស្សទាំង ២ នេះ ប៉ុណ្ណោះ ។ បានឮថា នកុលបិតា បានជាបិតារបស់ព្រះតថាគតមកហើយ ៥០០ ជាតិ ជាជីតា ៥០០ ជាតិ ជាឪពុកមា ៥០០ ជាតិ សូម្បីនកុលមាតា ក៏បានជាមាតា ៥០០ ជាតិ ជាជីដូន ៥០០ ជាតិ ជាមីង ៥០០ ជាតិ ជន ទាំងនោះ បាននូវសេចក្ដីស្រឡាញ់ដូចកូន តាំងអំពីកាលខ្លួនឃើញព្រះសាស្ដា

ទើបចូលទៅរកហើយ គាត់ទាំង ២ បានជាសោតាបន្ន ដោយបឋមទស្សនៈ ដូចមេគោឃើញកូនគោហើយ ជាប់ចិត្តក្នុងកូនគោ ស្រែករកថា **ហន្ទាត ហន្ទាត** ដូច្នេះ ។ ក្នុងនិវេសន៍ ទើបបុគ្គលនោះបានរៀបចំអាសនៈប្រគេនដល់ភិក្ខុ ៥០០ រូបជានិច្ចកាល ទើបព្រះមានព្រះភាគ យាងចូលទៅរកដើម្បីអនុគ្រោះមនុស្សទាំងនោះ ដោយប្រការដូច្នេះ ។ បទថា **អតិចរិតា** បានដល់ ប្រព្រឹត្តក្រៅចិត្ត ។ បទថា **អភិសម្បរាយញ្ច** បានដល់ ក្នុងលោកខាងមុខ ។ បទថា **សមសទ្ធា** បានដល់ ជាបុគ្គលស្មើ គឺស្មើគ្នាដោយសទ្ធា ។ ក្នុងសីលជាដើម ក៏មានន័យនេះដូចគ្នា ។

**អដ្ឋកថា បឋមសមជីវិសូត្រទី ៥ ចប់**

# សុត្តន្តបិដក
## ទុតិយសមជីវិសូត្រទី ៦

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ បើប្តី និងប្រពន្ធទាំងពីរនាក់ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជនទាំងនោះ ជួបគ្នាក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។

ជនទាំងពីរនាក់ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យពេចន៍នៃ
ស្មូម ជាអ្នកសង្រួម ( ក្នុងសីល ) ជាអ្នកចិញ្ចឹមជីវិតតាម
គន្លងធម៌ ប្រពន្ធ និងប្តីទាំងនោះ ពោលពាក្យផ្អែមល្ហែមរក
គ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏ច្រើន ទាំងមានការនៅជា
សុខ កើតឡើងដល់គ្នានិងគ្នា ពួកសត្រូវរមែងអាក់អន់ចិត្ត
ចំពោះជនទាំងពីរដែលមានសីលស្មើគ្នា ជនទាំងពីរនាក់មាន
សីល និងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ
( បើ ) មានចំណង់ក្នុងកាម រមែងជាអ្នកត្រេកអររីករាយ
ក្នុងទេវលោកបាន ។

# អដ្ឋកថា

## ទុតិយសមជីវិសូត្រ

[ ៥៧ ] ទុតិយសមជីវិសូត្រទី ៦ ទ្រង់សម្តែងដល់ភិក្ខុទាំងឡាយ
តែម្យ៉ាង ។ បទដ៏សេសក្នុងទីទាំងពួងក៏ដូច្នោះ ។

**អដ្ឋកថា ទុតិយសមជីវិសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សុប្បវាសសូត្រទី ៧

[ ៥៨ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគមឈ្មោះ បជ្ជនេលៈ របស់ពួកកោលិយរាជត្រកូល ក្នុងដែនកោលិយៈ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្ដេចចូលទៅកាន់និវេសន៍របស់នាងសុប្បវាសា ជាធីតានៃស្ដេចកោឡិយៈ លុះស្ដេចចូលទៅដល់ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ វេលានោះ នាងសុប្បវាសាជាធីតានៃស្ដេចកោឡិយៈ បានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះព្រះដ៏មានព្រះភាគឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់ព្រះអង្គប្រកែកលែងទទួលទៀត ។ លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្ដទៅក្នុងបាត្រហើយ ទើបនាងសុប្បវាសាអង្គុយក្នុងទីសមគួរ ។ លុះនាងសុប្បវាសាជាកោឡិយៈធីតាអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសុប្បវាសា អរិយសាវិកាឲ្យភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកទាំងឡាយ ។ ឋានៈ ៤ យ៉ាង តើដូចម្ដេច ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខ ១ ឲ្យពល ១ ។ លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវអាយុដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវវណ្ណៈ ដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យសុខហើយ រមែងជាអ្នកមានចំណែក គឺបាន

ទទួលយកនូវសុខដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យពលហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវពលដែលជារបស់ទិព្វ ឬជារបស់មនុស្ស ។ ម្នាលសុប្បវាសា អរិយសាវិកាឲ្យភោជនាហារ ឈ្មោះថាឲ្យឋានៈទាំង ៤ យ៉ាងនេះដល់បដិគ្គាហកទាំងឡាយ ។

បុគ្គលឲ្យភោជនដែលខ្លួនតាក់តែងស្អាត ឆ្ងាញ់ពិសាបរិបូណ៌ដោយរស ( ដល់បដិគ្គាហក ) ទក្ខិណាទាននោះ ដែលបុគ្គលឲ្យហើយដល់ព្រះខីណាស្រពទាំងឡាយ មានដំណើរត្រង់ប្រកបដោយចរណៈ ដល់នូវភាពដ៏ប្រសើរ ជាទីរួបរួមមកនូវបុណ្យ ដោយបុណ្យ ព្រះលោកវិទូទ្រង់សរសើរ ( នូវទក្ខិណាទាននោះ ) ថា ជាទានមានផលច្រើន ជនទាំងឡាយណា រឭកឃើញនូវយញ្ញ ដូច្នោះ កើតមានសេចក្តីត្រេកអរ កម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫសក្នុងលោក ជនទាំងនោះឥតមានគេនិន្ទា តែងចូលទៅកាន់ស្ថានសួគ៌បាន ។

# អដ្ឋកថា

## សុប្បវាសសូត្រ

[ ៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុប្បវាសសូត្រទី ៧ ដូចតទៅនេះ ពាក្យថា **បជ្ជនេល** ជាឈ្មោះនិគមរបស់បុគ្គលណា ។ បទថា **កោលិយានំ** បានដល់ របស់កោលិយរាជត្រកូល ។ បទថា **អាយុំ ខោ បន ទត្វា** បានដល់ កាលឲ្យអាយុទានហើយ ។ បទថា **អាយុស្ស ភាគិនី ហោតិ** បានដល់ ជាស្រីបានលាភ គឺអាយុ ឬជាបុគ្គលដែលកើតមានអាយុ អធិប្បាយថា ជាអ្នកបានអាយុ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **រសសា ឧបេតំ** បានដល់ ភោជនីយាហារដែលប្រកបដោយរស គឺ ដល់ព្រមដោយរស ។ បទថា **ឧជ្ជុគតេសុ** សេចក្តីថា ក្នុងព្រះខីណាស្រពដែលទៅត្រង់ ព្រោះវៀរការវៀចកាយជាដើមហើយ ។ បទថា **ចរណូ បបន្នេសុ** សេចក្តីថា ជាអ្នកប្រកបដោយចរណធម៌ ១៥ ។ បទថា **មហគ្គតេសុ** គឺជាអ្នកដល់នូវភូមិនៃធម៌ជាន់ខ្ពស់ ។ បទនោះជាឈ្មោះរបស់ព្រះខីណាស្រព ។ បទថា **បុញ្ញេន បុញ្ញំ សំសន្ទមានា** ប្រែថា ការបន្តបុណ្យដោយបុណ្យ ។ បទថា **មហប្ផលា លោកវិទូន វណ្ណិតា** សេចក្តីថា ទក្ខិណាពោល គឺទានបែបនេះ ព្រះពុទ្ធទាំងឡាយ ទ្រង់ដឹងច្បាស់នូវលោក ត្រាស់សរសើរហើយ អធិប្បាយថា ព្រះពុទ្ធទាំងឡាយទ្រង់សរសើរហើយ ព្រោះទ្រង់ធ្វើលោក ៣ ឲ្យជាក់ច្បាស់ហើយ ។ បទថា **យញ្ញមនុស្សរន្តា** បានដល់ រឭកដល់យញ្ញ គឺទាន ។ បទថា **វេទជាតា** ប្រែថា កើតនូវការត្រេកអរ

ហើយ ។ ៧

## អដ្ឋកថា សុប្បវាសសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សុទត្តសូត្រទី ៨

[ ៥៩ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី អរិយសាវកកាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកទាំងឡាយ ។ ឋានៈ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខ ១ ឲ្យពល ១ ។ លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវអាយុដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ ... លុះឲ្យសុខហើយ ... លុះឲ្យពលហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវពលដែលជារបស់ទិព្វ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវក កាលឲ្យភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាងនេះ ដល់បដិគ្គាហកទាំងឡាយ ។

*បុគ្គលណាឲ្យនូវភោជនាហារ ដល់ពួកភិក្ខុដែលសង្រួម ( ក្នុងសីល ) ជាអ្នកបរិភោគភោជនដែលបុគ្គលដទៃឲ្យដោយគោរពតាមកាល បុគ្គលនោះ រមែងបានទទួលនូវឋានៈទាំង ៤ យ៉ាង គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ ។ ជនអ្នកឲ្យអាយុ ឲ្យពល ឲ្យសុខ ឲ្យវណ្ណៈ កើតក្នុងភពណាៗ រមែងជាអ្នកមានអាយុវែង មានយសបរិវារក្នុងភពនោះៗ ។*

# អដ្ឋកថា

## សុទត្តសូត្រ

*[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុទត្តសូត្រទី ៨ ដូចតទៅនេះ បទថា* **សញ្ញតានំ** *បានដល់ បដិគ្គាហកដែលជាអ្នកសង្រួមតាមកាយ និងវាចា ។ បទថា* **បរទត្តភោជិនំ** *សេចក្តីថា ជាអ្នកបរិភោគរបស់ដែលអ្នកដទៃឲ្យហើយ ទើបញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ បទថា* **កាលេន** *បានដល់ តាមកាលដ៏គួរ ។ បទថា* **សក្កច្ច ទទាតិ** *សេចក្តីថា ធ្វើសក្ការៈ ហើយឲ្យដោយដៃរបស់ខ្លួន ។ បទថា* **ចត្តារិ ឋានានិ អនុប្បវេច្ឆតិ** *សេចក្តីថា រមែងហូរចុះ គឺឲ្យនូវហេតុ ៤ ។ បទថា* **យសវា ហោតិ** *បានដល់ មានបរិវារច្រើន ។ល។*

# សុត្តន្តបិដក

## ភោជនសូត្រទី ៩

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកទាំងឡាយ ។ ឋានៈ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខ ១ ឲ្យពល ១ ។ លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលនូវអាយុជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ ... លុះឲ្យសុខហើយ ... លុះឲ្យពលហើយ រមែងជាអ្នកមានចំណែក គឺបានទទួលនូវពលជារបស់ទិព្វ ឬជារបស់មនុស្ស ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាងនេះដល់បដិគ្គាហកទាំងឡាយ ។

បុគ្គលណាឲ្យនូវភោជនាហារ ដល់ពួកភិក្ខុដែលជាអ្នកសង្រួម ( ក្នុងសីល ) ជាអ្នកបរិភោគនូវភោជន ដែលអ្នកដទៃឲ្យ ដោយគោរព តាមកាល បុគ្គលនោះ រមែងបានទទួលនូវឋានៈទាំង ៤ យ៉ាង គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ ។ ជនអ្នកឲ្យអាយុ ឲ្យពល ឲ្យសុខ ឲ្យវណ្ណៈ កើតក្នុងភពណាៗ រមែងជាអ្នកមានអាយុវែង មានយសបរិវារ ក្នុងភពនោះៗ ។

# អដ្ឋកថា

## ភោជនសូត្រ

[ ៦០ ] ភោជនសូត្រទី ៩ ទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយតែម្យ៉ាង ។ បទដ៏សេសក្នុងព្រះសូត្រនេះ ក៏ដូច្នោះ ។៚

### អដ្ឋកថាភោជនសូត្រទី ៩ ចប់

# សុត្តន្តបិដក

## គិហិសាមិចិសូត្រទី ១០

[ ៦១ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី អរិយសាវកប្រកបដោយធម៌ ៤ យ៉ាង ប្រតិបត្តិនូវបដិបទាដ៏សមគួរដល់គ្រហស្ថ មានប្រក្រតីបាននូវយសប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។ អរិយសាវកប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ ទំនុកបម្រុងភិក្ខុសង្ឃដោយចីវរ ១ ទំនុកបម្រុងភិក្ខុសង្ឃដោយបិណ្ឌបាត ១ ទំនុកបម្រុងភិក្ខុសង្ឃដោយសេនាសនៈ ១ ទំនុកបម្រុងភិក្ខុសង្ឃ ដោយភេសជ្ជបរិក្ខារជា

បច្ច័យដល់មនុស្សមានជំងឺ ១ ។ ម្នាលគហបតី អរិយសាវកប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង ឈ្មោះថា ប្រតិបត្តិនូវបដិបទាដ៏សមគួររបស់គ្រហស្ថ មានប្រក្រតីបាននូវយស ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។

បណ្ឌិតទាំងឡាយ តែងប្រតិបត្តិនូវបដិបទាដ៏សមគួរ របស់គ្រហស្ថ គឺទំនុកបម្រុងភិក្ខុដែលមានសីល ជាអ្នកព្រមព្រៀងគ្នាដោយចីវរ ដោយបិណ្ឌបាត ដោយសេនាសនៈ និងគិលានប្បច្ច័យ បុណ្យតែងចម្រើនដល់បណ្ឌិតទាំងឡាយនោះសព្វៗ កាល ទាំងយប់ទាំងថ្ងៃ លុះធ្វើកម្មដ៏ចម្រើនហើយរមែងទៅកាន់ស្ថានសួគ៌ ។

**បុញ្ញាភិសន្ទវគ្គទី ១ ចប់**

## ឧទ្ទាននៃបុញ្ញាភិសន្ទវគ្គនោះ គឺ

និយាយពីអានិសង្សនៃបុណ្យ ២ លើក និយាយពីសង្វាស ២ លើក និយាយពីការចិញ្ចឹមជីវិតតាមគន្លងធម៌ ២ លើក និយាយពីរឿងនាងសុប្បវាសា ១ និយាយពីការឲ្យទានដោយប្រពៃ ១ និយាយពីការឲ្យភោជន ១ និយាយពីអរិយសាវកប្រតិបត្តិដ៏សមគួររបស់គ្រហស្ថ ១ ។

# អដ្ឋកថា

## គិហិសាមិចិសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគិហិសាមិចិសូត្រទី ១០ ដូចតទៅនេះ បទថា **គិហិសាមិចិប្បដិបទំ** បានដល់ នូវបដិបទាដ៏សមគួរដល់គ្រហស្ថ ។ បទថា **បច្ចុប្បដ្ឋិតោ ហោតិ** សេចក្ដីថា តាំងសតិមាំ ព្រោះលោកបំណង នឹងនាំទៅថ្វាយ អធិប្បាយថា ចូលទៅថ្វាយចីវរដល់ភិក្ខុសង្ឃ ។

បទថា **ឧបដ្ឋិតា** ប្រែថា ជាអ្នកទំនុកបម្រុង ។ បទថា **តេសំ ទិវា ច រត្តោ ច** សេចក្ដីថា បណ្ឌិតពួកណា រមែងទំនុកបម្រុងដោយបច្ច័យ ៤ យ៉ាង នេះ បុណ្យរមែងចម្រើនដល់បណ្ឌិតទាំងនោះគ្រប់កាល ទាំងពេលថ្ងៃ ទាំងពេលយប់ ដោយអំណាចការបរិច្ចាគ និងការរឭកដល់ ។ បទថា **សគ្គញ្ច កមតិដ្ឋានំ** សេចក្ដីថា បណ្ឌិតដែលមានសភាពបែបនោះ កាលធ្វើកម្មដ៏ចម្រើនហើយ រមែងទៅកាន់សគ្គស្ថាន ក្នុងព្រះសូត្រទាំង ៤ នេះ ត្រាស់បដិបទាសម្រាប់អ្នកគ្រប់គ្រងផ្ទះ រមែងគួរដល់គ្រហស្ថដែលជាសោតាបន្ន និងសកទាគាមីផងដែរ ។l៚

**អដ្ឋកថា គិហិសាមិចិសូត្រទី ១០ ចប់**

**បុញ្ញាភិសន្ទវគ្គទី ១ ចប់**

# សុត្តន្តបិដក

# បត្តកម្មវគ្គទី ២

## បត្តកម្មសូត្រទី ១

[ ៦២ ] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ធម៌ ៤ ប្រការនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ បំណងថា ភោគៈទាំងឡាយចូរកើតដល់អាត្មាអញ ដែលប្រកបដោយធម៌ នេះជាធម៌ទី ១ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ បំណងថា កាលបើអាត្មាអញបានទូវភោគៈដោយកម្ម ប្រកបដោយធម៌ហើយ សូមឲ្យយសរបស់អាត្មាអញ ល្បីខ្ចរខ្ចាយឡើង ព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ គឺមិត្តសម្លាញ់ទាំងឡាយ នេះជាធម៌ទី ២ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ បំណងថា កាលបើអាត្មាអញបានភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញ ព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ នឹងចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង នេះជាធម៌ទី ៣ ជាទីប្រាថ្នា ជាទីត្រេកអរ

ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ បំណងថា កាលបើអាត្មាអញបាននូវភោគៈ ដោយកម្ម ប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញ ព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ បានចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែងហើយ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ សូមឲ្យបានទៅកើតក្នុងសុគតិសួគ៌ ទេវលោក នេះជាធម៌ទី ៤ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ម្នាលគហបតី ធម៌ ៤ ប្រការនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ម្នាលគហបតី ធម៌ ៤ ប្រការប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវធម៌ ៤ ប្រការ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោកនេះ ។ ធម៌ ៤ ប្រការដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលគហបតី ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ មានសទ្ធាជឿសេចក្តីត្រាស់ដឹងព្រះតថាគតថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវលោក ឥតមានបុគ្គលដទៃស្មើ ទូន្មានបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលគហបតី នេះហៅថា សទ្ធាសម្បទា ។ ម្នាល

គហបតី ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ វៀរចាកបាណាតិបាត ។បេ។ វៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ម្នាលគហបតី នេះហៅថា សីលសម្បទា ។ ម្នាលគហបតី ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល មានការបរិច្ចាគហើយ មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ គួរដល់សូម ត្រេកអរក្នុងទាន និងការចែកចាយ នៅគ្រប់គ្រងផ្ទះ ម្នាលគហបតី នេះហៅថា ចាគសម្បទា ។ ម្នាលគហបតី ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលគហបតី បុគ្គលកាលមានចិត្ត ត្រូវអភិជ្ឈាវិសមលោភៈគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្តីសុខ ម្នាលគហបតី បុគ្គលកាលមានចិត្តត្រូវព្យាបាទគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្តីសុខ ម្នាលគហបតី បុគ្គលកាលមានចិត្ត ត្រូវថីនមិទ្ធៈគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្តីសុខ ម្នាល

គហបតី បុគ្គលកាលមានចិត្ត ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្តីសុខ ម្នាលគហបតី បុគ្គលកាលមានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្តីសុខ ។ ម្នាលគហបតី អរិយសាវកនោះឯង ដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា ព្យាបាទជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់ព្យាបាទជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា ថីនមិទ្ធៈជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់ថីនមិទ្ធៈជាឧបក្កិ-លេសនៃចិត្តចេញ ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់ឧទ្ធច្ចកុក្កុច្ចៈជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា វិចិកិច្ឆាជាឧប-ក្កិលេសនៃចិត្តហើយ ក៏លះបង់វិចិកិច្ឆាជាឧបក្កិលេសនៃចិត្តចេញ ។ ម្នាលគហបតី កាលណាអរិយសាវកដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈជាឧបក្កិ-លេសនៃចិត្តហើយ ក៏បានលះបង់អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញ ព្យាបាទជាឧបក្កិលេសនៃចិត្ត ... ថីនមិទ្ធៈជាឧបក្កិលេសនៃចិត្ត ... ឧទ្ធច្ចកុក្កុច្ចៈជាឧបក្កិលេសនៃចិត្តហើយ .... ដឹងច្បាស់ថា វិចិកិច្ឆាជាឧប-ក្កិលេសនៃចិត្តហើយ ក៏បានលះបង់វិចិកិច្ឆាជាឧបក្កិលេសនៃចិត្តចេញ ។ ម្នាល

គហបតី អរិយសាវកនេះ ហៅថាជាអ្នកមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ ជាអ្នកយល់សេចក្តីតាមគន្លងនៃពាក្យ បរិបូណ៌ដោយប្រាជ្ញា ។ ម្នាលគហបតី នេះហៅថា បញ្ញាសម្បទា ។ ម្នាលគហបតី ធម៌ទាំង ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវធម៌ទាំង ៤ ប្រការនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ម្នាលគហបតី អរិយសាវកនោះ ជាអ្នកធ្វើកម្មដ៏សមគួរ ៤ ប្រការ ដោយភោគៈទាំងឡាយ ដែលអរិយសាវកបានដោយសេចក្តីព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ កម្មដ៏សមគួរ ៤ ប្រការដូចម្តេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ ញុំាងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមាតាបិតាឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងកូនប្រពន្ធ និងបុរសជាទាសកម្មករឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមិត្តអាមាត្យឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ដោយភោគៈទាំងឡាយ ដែលបានមកដោយសេចក្តីព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង សន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ១ ដែលអរិយសាវកនោះបានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ប្រការមួយទៀត សេចក្តីអន្តរាយណា ដែលកើតអំពីភ្លើងក្តី អំពីទឹក

ក្តី អំពីស្តេចក្តី អំពីចោរក្តី អំពីបុគ្គលមិនជាទីស្រឡាញ់ក្តី អំពីអ្នកទទួលមត៌កក្តី អរិយសាវកក៏ការពារទប់ទល់ ចំពោះអន្តរាយមានសភាពដូច្នោះបាន ដោយភោគៈទាំងឡាយ ធ្វើខ្លួនឲ្យដល់នូវសួស្តីបាន ក៏ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ២ ដែលអរិយសាវកនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ម្នាលគហបតី ប្រការមួយទៀត អរិយសាវក ធ្វើពលីទាំង ៥ គឺញាតិពលិ ១ អតិថិពលិ ១ បុព្វបេតពលិ ១ រាជពលី ១ ទេវតាពលិ ១ ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៣ ដែលអរិយសាវកនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ប្រការមួយទៀត ពួកសមណព្រាហ្មណ៍ណា វៀរចាកសេចក្តីវង្វេង និងសេចក្តីប្រមាទ ស្ថិតនៅក្នុងខន្តិ និងសោរច្ចៈ ទូន្មានតែខ្លួនមួយ រម្ងាប់កិលេសចំពោះខ្លួនមួយ ញ៉ាំងតែខ្លួនមួយឲ្យបរិនិព្វាន អរិយសាវករមែងញ៉ាំងទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ នាំឲ្យទៅកើតក្នុងស្ថានសួគ៌ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ឲ្យប្រតិស្ឋាននៅក្នុងពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ

បានដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៤ ដែលអរិយសាវកនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ ម្នាលគហបតី អរិយសាវកនោះឯង ជាអ្នកធ្វើកម្មដ៏សមគួរទាំង ៤ ប្រការនេះ បានដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណាមួយ តែវៀរលែងចាកកម្មដ៏សមគួរទាំង ៤ ប្រការចេញហើយ រមែងដល់នូវការអស់ទៅ ម្នាលគហបតី ភោគៈទាំងឡាយនេះ ហៅថា មិនដល់នូវហេតុដ៏សមគួរ មិនបានសម្រេច មិនបានបរិភោគដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណាមួយអស់ទៅដោយកម្មដ៏សមគួរទាំង ៤ នេះ ម្នាលគហបតី ភោគៈទាំងឡាយនេះហៅថា ដល់នូវហេតុដ៏សមគួរ បានសម្រេច បានបរិភោគដោយទំនងដ៏សមគួរ ។

ភោគៈទាំងឡាយ អាត្មាអញបរិភោគហើយ មិត្ត អាមាត្យ
អាត្មាអញចិញ្ចឹមហើយ អាត្មាអញឆ្លងអន្តរាយទាំងឡាយបាន
ហើយ ទក្ខិណាទានមានផលដ៏ខ្ពស់ប្រសើរ អាត្មាអញបានឲ្យ

ហើយ ឯពលីទាំង ៥ អាត្មាអញបានធ្វើហើយ អ្នកមាន សីល មានសេចក្តីសង្រួម មានព្រហ្មចរិយធម៌ អាត្មាអញ បានទំនុកបម្រុងហើយ បណ្ឌិតកាលនៅគ្រប់គ្រងផ្ទះ គប្បីប្រាថ្នាភោគៈ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ អាត្មាអញបានសម្រេចហើយ កម្មដែលមិននាំឲ្យកើតសេចក្តីក្តៅក្រហាយ អាត្មាអញបានធ្វើហើយ ជនអ្នកមានសេចក្តីស្លាប់ជាធម្មតា កាលរឭកឃើញនូវប្រយោជន៍នុ៎ះ រមែងស្ថិតនៅក្នុងអរិយធម៌ បណ្ឌិតទាំងឡាយ រមែងសរសើរជននោះក្នុងលោកនេះដោយពិត ជននោះ លុះលះលោកនេះទៅ រមែងត្រេកអរក្នុងស្ថានសួគ៌ ។

# អដ្ឋកថា

# បត្តកម្មវគ្គទី ២

## បត្តកម្មសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបត្តកម្មសូត្រទី ១ នៃបត្តកម្មវគ្គទី ២ ដូចតទៅនេះ ឈ្មោះថា **ឥដ្ឋា** ព្រោះបដិសេធធម៌ដែលមិនគួរប្រាថ្នា ។ ឈ្មោះថា **កន្តា** ព្រោះឈានចូលទៅក្នុងចិត្ត ។ ឈ្មោះថា **មនាបា** ព្រោះធ្វើឲ្យបីតិចម្រើន ។ បទថា **ទុល្លភា** បានដល់ បានដោយលំបាកក្រៃលែង ។ បទថា **ភោគា** បានដល់ អារម្មណ៍ មានរូបជាដើមដែលបុគ្គលគប្បីបរិភោគ ។ បទថា **សហ ធម្មេន** សេចក្ដីថា សូមភោគសម្បត្តិកើតឡើងដោយធម៌ កុំចូលទៅកម្ចាត់ធម៌ ហើយកើតឡើង ដោយអធម៌ឡើយ ។ម្យ៉ាងទៀត បទថា **សហ ធម្មេន** ប្រែថា មានហេតុ អធិប្បាយថា ភោគសម្បត្តិ ចូរកើតឡើង ដោយការណ៍ គឺ តំណែង មានតំណែងសេនាបតី និងសេដ្ឋីជាដើមនោះ ។ បទថា **យសោ** បានដល់ បរិវារសម្បត្តិ ។ បទថា **សហ ញាតីភិ** បានដល់ មួយអន្លើដោយពួកញាតិ ។ បទថា **សហ ឧបជ្ឈាយេហិ** បានដល់ មួយអន្លើដោយសម្លាញ់ដែលធ្លាប់ឃើញ ធ្លាប់ជួប ដែលហៅថា ឧបជ្ឈាយ៍ ព្រោះជាអ្នកជួយសម្លឹងក្នុងរឿងសុខ និងទុក្ខ ។ បទថា **អកិច្ចំ ករោតិ** សេចក្ដីថា ធ្វើនូវការដែលមិនគួរធ្វើ ។ បទថា **កិច្ចំ អបរាធេតិ** សេចក្ដីថា កាលមិនធ្វើកិច្ចដែលគួរធ្វើ ឈ្មោះថា លះបង់នូវកិច្ច

នោះ ។ បទថា **ធំសតិ** បានដល់ រមែងធ្លាក់ទៅ គឺរមែងវិនាស ។

បទថា **អភិជ្ឈាវិសមលោភំ** បានដល់ អភិជ្ឈាវិសមលោភ ។ បទថា **បជហាតិ** បានដល់ បន្ទោបង់ គឺនាំចេញទៅ ។

បទថា **មហាបញ្ញោ** បានដល់ ជាអ្នកមានបញ្ញាច្រើន ។ បទថា **បុថុប្បញ្ញោ** បានដល់ មានបញ្ញាក្រាស់ ។ បទថា **អត្ថទ្ទសោ** សេចក្តីថា បុគ្គលនោះឃើញអត្ថនោះ តាំងនៅក្នុងគន្លងធម៌ រមែងមកកាន់គន្លងដែលជាអត្ថដ៏សុខុមនៃធម៌នោះ ។ បទថា **ឧដ្ឋានវីរិយាធិគតេហិ** បានដល់ ដែលបានមកដោយសេចក្តីព្យាយាម ពោល គឺការឧស្សាហ៍ ។ បទថា **ពាហា-ពលបរិចិតេហិ** បានដល់ ដែលសន្សំឲ្យច្រើនឡើង ដោយកម្លាំងស្មង ។ បទថា **សេទាវក្ខិត្តេហិ** គឺញើសហូរ ។ អធិប្បាយថា ដោយការព្យាយាមធ្វើការងារហូតហូរញើស ។ បទថា **ធម្មិកេហិ** បានដល់ ប្រកបដោយធម៌ ។ បទថា **ធម្មលទ្ធេហិ** គឺមិនល្មើសក្នុងកុសលកម្មបថ ១០ បានហើយ ។ បទថា **បត្តកម្មានិ** បានដល់ កម្មដែលសម កម្មដែលសមគួរ ។ បទថា **សុខេតិ** បានដល់ ធ្វើបុគ្គលនោះឲ្យមានសេចក្តីសុខ ។ បទថា **បីណេតិ** បានដល់ រមែងធ្វើឲ្យឆ្អែតសម្បូរដោយកម្លាំង ។ បទថា **ឋានំ គតំ ហោតិ** បានដល់ជាហេតុ សួរថា ហេតុនោះដូចម្តេច ។ ឆ្លើយថា ការងារដែលគប្បីធ្វើដោយភោគៈទាំងឡាយ ជាកម្មណាមួយក្នុងបត្តកម្ម ៤ ជាឋានៈ ដែលកើតអំពីភោគទ្រព្យនោះឯង ។ បទថា **បត្តគតំ** បានដល់ ជាឋានៈដែលគួរដល់

ហើយ ។ បទថា **អាយតនសោ បរិភុត្តំ** បានដល់ បរិភោគហើយដោយហេតុនោះឯង ដែលកើត អំពីភោគទ្រព្យ ។ បទថា **បរិយោធាយ វត្តតិ** បានដល់ រមែងបិទ ។ អរិយសាវកបរិច្ចាគទ្រព្យដើម្បីប្រយោជន៍ដល់ការរលត់ភ្លើងដែលឆេះផ្ទះជាដើម រមែងរកាំងផ្លូវនៃអន្តរាយទាំងនោះ ដូចកាលដែលអន្តរាយទាំងឡាយកើតឡើងអំពីភ្លើងជាដើម ដូច្នោះ ។ បទថា **សោត្ថឹ អត្តានំ ករោតិ** សេចក្តីថា រមែងធ្វើខ្លួនឲ្យផុតភ័យ មិនមានអន្តរាយ ។ បទថា **ញាតិពលឹ** គឺសង្គ្រោះញាតិ ។ បទថា **អតិថិពលឹ** គឺទទួលភ្ញៀវ ។ បទថា **បុព្វបេតពលឹ** គឺធ្វើបុណ្យឧទ្ទិសឲ្យញាតិដែលស្លាប់ ។ បទថា **រាជពលឹ** គឺចំណែកដែលគួរធ្វើដល់ព្រះរាជា ។ បទថា **ទេវតាពលឹ** គឺធ្វើបុណ្យឧទ្ទិសឲ្យទេវតា ។ បទថា **ញាតិពលឹ** ជាដើម ជាឈ្មោះរបស់ទានដែលគប្បីឲ្យតាមសមគួរដល់បុគ្គលនោះៗ ។

បទថា **ខន្តិសោរច្ចេ និវិដ្ឋា** សេចក្តីថា តាំងមាំនៅក្នុងអធិវាសនខន្តីនិងក្នុងភាពជាអ្នកមានសីលល្អ ។ បទថា **ឯកមត្តានំ ទមេន្តិ** សេចក្តីថា រមែងទូន្មានអត្តភាពរបស់ខ្លួនតែម្យ៉ាង ដោយការទូន្មានឥន្ទ្រិយ ។ បទថា **សមេន្តិ** សេចក្តីថា រមែងស្ងប់ចិត្តរបស់ខ្លួន ដោយការស្ងប់កិលេស ។ បទថា **បរិនិព្វាបេន្តិ** សេចក្តីថា រមែងរម្ងត់ដោយការរម្ងត់កិលេស ។ ក្នុងបទថា **ឧទ្ធគ្គិកំ** ជាដើម ទក្ខិណា ឈ្មោះថា **ឧទ្ធគ្គិកា** ព្រោះមានផលខាងដើម ដោយអំណាចឲ្យផលក្នុងភូមិ ជាន់ខ្ពស់ឡើងទៅ ។ ទក្ខិណាជាប្រយោជន៍

ដល់សួគ៌ ព្រោះហេតុនោះ ទើបឈ្មោះថា **សោវគ្គិកា** ព្រោះឲ្យកើតក្នុងស្ថានសួគ៌នោះ ។ ឈ្មោះថា **សុខវិបាកា** ព្រោះមានសុខជាវិបាកក្នុងទីដែលកើតហើយ ។ ឈ្មោះថា **សគ្គសំវត្តនិកា** ព្រោះធ្វើអារម្មណ៍ដែលល្អគឺរបស់ពិសេស ១០ មានពណ៌សម្បុរទិព្វជាដើមឲ្យកើត អធិប្បាយថា រមែងតាំងទក្ខិណាដូច្នោះ ។

បទថា **អរិយធម្មេ ឋិតោ** គឺតាំងនៅក្នុងបញ្ចសីល បញ្ចធម៌ ។ បទថា **បេច្ច សគ្គេ បមោទតិ** សេចក្តីថា នរជននោះទៅបរលោក បដិសន្ធិហើយ រមែងត្រេកអរក្នុងស្ថានសួគ៌ ។ គ្រហស្ថ ទោះជាសោតាបន្ន និងសកទាគាមី ឬអនាគាមីក្តី បដិបទានេះ រមែងបានដូចគ្នាគ្រប់បុគ្គលនោះឯង ។

**អដ្ឋកថា បត្តកម្មសូត្រទី ១ ចប់**

# សុត្តន្តបិដក
# អនណសូត្រទី ២

[ ៦៣ ] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរ ។ ព្រះដ៏

មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី គិហិសុខ ( សុខរបស់គ្រហស្ថ ) នេះមាន ៤ យ៉ាង ដែលគ្រហស្ថអ្នកបរិភោគកាម អាស្រ័យនូវកាលតាមកាល នូវសម័យតាមសម័យ គប្បីបានសម្រេច ។ សេចក្តីសុខ ៤ ប្រការដូចម្តេចខ្លះ ។ គឺអត្ថិសុខ ( សុខព្រោះចេះតែមាន ) ១ ភោគសុខ ( សុខព្រោះចេះប្រើប្រាស់ ) ១ អនណសុខ ( សុខព្រោះមិនជំពាក់បំណុលគេ ) ១ អនវជ្ជសុខ ( សុខព្រោះមិនមានទោស ) ១ ។ ម្នាលគហបតី ចុះអត្ថិសុខតើដូចម្តេច ។ ម្នាលគហបតី កុលបុត្តក្នុងលោកនេះ មានភោគៈដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្តនោះរមែងបានសុខ រមែងបានសោមនស្សថា ភោគៈទាំងឡាយដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ របស់អាត្មាអញមាន ។ ម្នាលគហបតី នេះ ហៅថា អត្ថិសុខ ។ ម្នាលគហបតី ចុះភោគសុខ តើដូចម្តេច ។ ម្នាលគហបតី កុលបុត្តក្នុងលោកនេះ ប្រើប្រាស់នូវភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផង ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្តនោះ រមែងបានសុខ បានសោមនស្សដូច្នេះថា

អាត្មាអញប្រើប្រាស់ភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផង ដោយភោគៈទាំងឡាយដែលបានមកដោយព្យាយាម ពោល គឺសេចក្ដីខ្នះខ្នែងដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតីនេះហៅថា ភោគសុខ ។ ម្នាលគហបតី ចុះអនណសុខ តើដូចម្ដេច ។ ម្នាលគហបតី កុលបុត្តក្នុងលោកនេះ មិនជំពាក់បំណុលអ្វីមួយ តិចក្ដី ច្រើនក្ដី របស់បុគ្គលណាមួយ កុលបុត្តនោះរមែងបានសេចក្ដីសុខ បានសោមនស្សដូច្នេះថា អាត្មាអញមិនជំពាក់បំណុលអ្វីមួយ តិចក្ដី ច្រើនក្ដី របស់បុគ្គលណាមួយទេ ។ ម្នាលគហបតី នេះហៅថា អនណសុខ ។ ម្នាលគហបតី ចុះអនវជ្ជសុខ តើដូចម្ដេច ។ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ អ្នកប្រកបដោយកាយកម្មឥតមានទោស ប្រកបដោយវចីកម្មឥតមានទោស ប្រកបដោយមនោកម្មឥតមានទោស អរិយសាវកនោះ រមែងបានសុខ បានសោមនស្សដូច្នេះថា អាត្មាអញប្រកបដោយកាយកម្មឥតមានទោសទេ ប្រកបដោយវចីកម្មឥតមានទោសទេ ប្រកបដោយមនោកម្មឥតមានទោសទេ ។ ម្នាលគហបតី នេះ ហៅថា អនវជ្ជសុខ ។ ម្នាលគហបតី សេចក្ដីសុខ ៤ យ៉ាងនេះឯង ដែលគ្រហស្ថអ្នកបរិភោគកាម អាស្រ័យនូវកាលតាមកាល នូវសម័យតាមសម័យហើយ គប្បីបានសម្រេចដោយប្រការដូច្នេះ ។

បុគ្គលដឹងនូវសុខដែលមិនមានបំណុលក្ដី រឭកឃើញនូវសុខ

ដែលមានភោគៈក្តី ពិចារណាឃើញនូវសុខ ដែលកំពុង ប្រើប្រាស់នូវភោគៈដោយប្រាជ្ញាក្តី កាលពិចារណាឃើញ ច្បាស់ រមែងដឹងនូវចំណែកទាំងពីរ ដោយប្រាជ្ញាដ៏ប្រពៃថា សុខ ( ទាំង ៣ ) នុ៎ះ មិនដល់នូវចំណែកមួយ ក្នុងចំណែក ទី ១៦ របស់អនវជ្ជសុខឡើយ ฯ

# អដ្ឋកថា

## អនណសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនណសូត្រទី ២ ដូចតទៅនេះ បទថា **អធិគមនីយានិ** គឺគប្បីដល់ ฯ បទថា **កាមភោគិនា** គឺអ្នកបរិភោគ វត្ថុកាម និងកិលេសកាម បណ្តាសុខ មានអត្ថិសុខជាដើម សុខដែលកើត ឡើងថា ភោគទ្រព្យមាន ឈ្មោះថា **អត្ថិសុខ** សុខកើតអំពីមានទ្រព្យ ฯ សុខ ដែលកើតឡើងដល់បុគ្គលអ្នកចាយភោគទ្រព្យ ឈ្មោះថា **ភោគសុខ** ฯ សុខ ដែលកើតឡើងថា អាត្មាអញមិនជំពាក់បំណុល ឈ្មោះថា **អណណសុខ** ฯ សុខ ដែលកើតឡើងថា អញប្រាសចាកទោស មិនជាទោស ឈ្មោះថា **អនវជ្ជ-សុខ** ฯ បទថា **ភុញ្ជំ** ប្រែថា កាលបរិភោគ ฯ បទថា **បញ្ញាវិបស្សតិ** ប្រែថា រមែងពិចារណាឃើញដោយបញ្ញា ฯ បទថា **ឧភោ ភាគេ** ប្រែថា ២

ចំណែក អធិប្បាយថា ពិចារណាឃើញដោយបញ្ញាយ៉ាងនេះថា សេចក្តីសុខ ៣ ខាងដើម ចាត់ជា ១ ចំណែក ។ សុខកើតអំពីការប្រកបការងារដែលមិនមានទោសចាត់ជា ១ ចំណែក ឈ្មោះថា ដឹង ២ ចំណែក ។ បទថា **អនវជ្ជសុខស្សេតំ** សេចក្តីថា សុខ ៣ យ៉ាងនោះ រមែងមិនដល់ចម្រៀកទី ១៦ នៃសុខដែលកើតអំពីការប្រកបការងារ មិនមានទោស ដូច្នេះ ។៚

**អដ្ឋកថា អនណាជសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សព្រហ្មសូត្រទី ៣

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកកុលបុត្តណា បូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះ ឈ្មោះថា ប្រកបដោយឋានៈជាព្រហ្ម ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកកុលបុត្តណា បូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះ ឈ្មោះថា ប្រកបដោយឋានៈជាបុព្វាចារ្យ ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកកុលបុត្តណា បូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះ ឈ្មោះថា ប្រកបដោយឋានៈជាបុព្វទេព ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកកុលបុត្តណា បូជាហើយ

ក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយឋានៈជាអាហុនេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មន៌ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យន៌ះ ជាឈ្មោះរបស់មាតាបិតាទាំង-ឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេពន៌ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យបុគ្គលន៌ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតាបិតាទាំងឡាយ មានឧបការៈច្រើន ជាអ្នករក្សា ជាអ្នកចិញ្ចឹម ជាអ្នកបង្ហាញនូវលោកនេះ ដល់បុត្តទាំងឡាយ ។

> មាតាបិតាទាំងឡាយ ជាអ្នកអនុគ្រោះដល់ពួកបុត្ត ហៅថា ជាព្រហ្មផង ហៅថាជាបុព្វាចារ្យផង ជាអហុនេយ្យបុគ្គលផង របស់បុត្តទាំងឡាយ ។ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ ទីដេក ការដុសជម្រះ ការផ្ងូតទឹក ការលាងជើង និងការបម្រើ ចំពោះមាតាបិតាទាំងឡាយនោះ បណ្ឌិតទាំងឡាយ តែងសរសើរបុគ្គលនោះ ក្នុងលោកនេះដោយពិត លុះលះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

# អដ្ឋកថា

## សព្រហ្មសូត្រ

[ ៦៤ ] ក្នុងសព្រហ្មសូត្រទី ៣ បានពណ៌នាហើយក្នុងតិកនិបាត ។ ត្រឹមតែបទថា **សុបុព្វទេវតានិ** នេះឯងដែលប្លែកក្នុងសូត្រនេះ ។

អដ្ឋកថា សព្រហ្មសូត្រទី ៣ ចប់

# សុត្តន្តបិដក

## និរយសូត្រទី៤

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងធ្លាក់ប្រុងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ការសម្លាប់សត្វ ១ ការកាន់យករបស់ដែលគេមិនបានឲ្យ
១ ការពោលមុសា ១ ការប្រព្រឹត្តិខុសក្នុងប្រពន្ធបុគ្គល
ដទៃ ១ បណ្ឌិតទាំងឡាយ រមែងមិនសរសើរទេ ។

# អដ្ឋកថា

## និរយសូត្រ

[ ៦៥ ] និរយសូត្រទី ៤ មានអត្ថងាយយល់គ្រប់បទហើយ ។

អដ្ឋកថានិរយសូត្រទី ៤ ចប់

# សុត្តន្តបិដក

## រូបសូត្រទី ៥

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកដូចម្តេចខ្លះ ។ គឺបុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថា រូបប្បមាណ ១ ជ្រះថ្លាក្នុងសំឡេង ឈ្មោះថា ឃោសប្បមាណ ១ ជ្រះថ្លាក្នុងវត្ថុសៅហ្មង ឈ្មោះថា លូខប្បមាណ ១ ជ្រះថ្លាក្នុងធម៌ ឈ្មោះថា ធម្មប្បមាណ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

ជនទាំងឡាយណា រាប់អានដោយរូប និយមទៅតាមសំឡេង
លុះក្នុងអំណាចនៃឆន្ទរាគ ជនទាំងនោះ ឈ្មោះថា មិនដឹង
( តាមពិត ) បុគ្គលពាល អ្នកមានធម៌ជាគ្រឿងរារាំងដោយ
ជុំវិញ រមែងមិនដឹងនូវគុណខាងក្នុង ទាំងមិនឃើញសេចក្តី
ប្រតិបត្តិខាងក្រៅ បុគ្គលពាលនោះ រមែងអណ្តែត ( ចិត្ត )

ទៅតាមសំឡេង ។ មួយទៀត បុគ្គលពាលមិនដឹងនូវគុណ ខាងក្នុង តែឃើញច្បាស់នូវសេចក្ដីប្រតិបត្តិខាងក្រៅ បុគ្គល ពាលនោះ ឈ្មោះថា ជាអ្នកឃើញផលខាងក្រៅជាប្រក្រតី រមែងអណ្ដែត ( ចិត្ត ) ទៅតាមសំឡេង ។ ឯជនដឹងច្បាស់ នូវគុណខាងក្នុង ទាំងឃើញច្បាស់នូវសេចក្ដីប្រតិបត្តិជាខាង ក្រៅ ជននោះ ឈ្មោះថា ជាអ្នកឃើញធម៌ ជាគ្រឿងប្រាស ចាកនីវរណៈជាប្រក្រតី រមែងមិនអណ្ដែត ( ចិត្ត ) ទៅតាម សំឡេងឡើយ ។

# អដ្ឋកថា

## រូបសូត្រ

[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរូបសូត្រទី ៥ ដូចតទៅនេះថា បុគ្គល កាន់យកប្រមាណក្នុងរូប ហើយជ្រះថ្លា ឈ្មោះថា **រូបប្បមាណោ** ។ បទថា **រូបប្បសន្នោ** ជាវេវចនៈនៃបទថា **រូបប្បមាណោ** នោះ ។ បុគ្គលកាន់យក ប្រមាណក្នុងសំឡេងកងរំពង ហើយជ្រះថ្លា ឈ្មោះថា **ឃោសប្បមាណោ** ។ បុគ្គលកាន់យកប្រមាណក្នុងភាពសៅហ្មងរបស់ចីវរ និងបាត្រ ហើយជ្រះថ្លា ឈ្មោះថា **លូខប្បមាណោ**។ បុគ្គលកាន់យកប្រមាណក្នុងធម៌ ហើយជ្រះថ្លា

ឈ្មោះថា **ធម្មប្បមាណា** ។ បទក្រៅអំពីនេះ ជាវេវចនៈនៃបទទាំងនោះឯង ព្រោះបែងចែកសត្វជា ៣ ចំណែក ពីរចំណែកកាន់យករូបជាប្រមាណ មួយចំណែក មិនកាន់យករូបជាប្រមាណ ។ ព្រោះចែកសត្វជា ៥ ចំណែក ៤ ចំណែកកាន់យកសំឡេងឃោសនាជាប្រមាណ ១ ចំណែក មិនកាន់យកសំឡេងឃោសនាជាប្រមាណ ។ ព្រោះចែកសត្វជា ១០ ចំណែក ៩ ចំណែក កាន់យកភាពសៅហ្មងជាប្រមាណ ១ ចំណែកមិនកាន់យកភាពសៅហ្មងជាប្រមាណ ។ តែការចែកសត្វចេញជាមួយសែនចំណែក ១ ចំណែកប៉ុណ្ណោះ កាន់យកធម៌ជាប្រមាណ សត្វដ៏សេសមិនកាន់យកធម៌ជាប្រមាណឡើយ ដូច្នេះ ។ បទថា **រូបេន ចាមីសុ** សេចក្តីថា បុគ្គលពួកណាឃើញរូបហើយជ្រះថ្លា បុគ្គលទាំងនោះ ឈ្មោះថា កាន់យករូបជាប្រមាណ អធិប្បាយថា រាប់អានហើយ ។ បទថា **ឃោសេន អន្វគូ** សេចក្តីថា បុគ្គលពួកណាហូរទៅតាមសំឡេងឃោសនា អធិប្បាយថា បុគ្គលទាំងនោះ កាន់យកឃោសប្បមាណ ហើយជ្រះថ្លា ។ បទថា **ឆន្ទរាគវសូបេតា** បានដល់ ធ្លាក់នៅក្នុងអំណាចនៃការពេញចិត្ត និងស្រឡាញ់ហើយ ។ បទថា **អជ្ឈត្តញ្ច ន ជានាតិ** សេចក្តីថា បុគ្គលល្ងង់ រមែងមិនស្គាល់គុណខាងក្នុងរបស់បុគ្គលនោះ ។ បទថា **ពហិទ្ធា ច ន បស្សតិ** សេចក្តីថា រមែងមិនឃើញបដិបទាខាងក្រៅរបស់បុគ្គលនោះ ។ បទថា **សមន្តាវរណោ** បានដល់ ត្រូវសំឡេងបិទបាំងដោយជុំវិញ ។ ម្យ៉ាងទៀត ឈ្មោះថា **សមន្តា-**

*វរណា ព្រោះសំឡេងរាំងដោយជុំវិញ ។ បទថា* **ឃោសេន វុយ្ហតិ** *សេចក្ដីថា បុគ្គលល្ងង់នោះ ទើបត្រូវសំឡេងឃោសនានាំទៅ មិនមែនត្រូវគុណនាំទៅឡើយ ។ បទថា* **អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច វិបស្សតិ** *សេចក្ដីថា បុគ្គលមិនដឹងគុណខាងក្នុង តែឃើញបដិបត្តិខាងក្រៅរបស់បុគ្គលនោះ ។ បទថា* **ពហិទ្ធា ផលទស្សាវី** *សេចក្ដីថា ឃើញផលសក្ការៈខាងក្រៅដែលបុគ្គលដទៃធ្វើដល់បុគ្គលនោះ ។ បទថា* **វិនីវរណាទស្សាវី** *សេចក្ដីថា ឃើញដោយមិនមានអ្វីបិទបាំង ។ បទថា* **ន សោ ឃោសេន វុយ្ហតិ** *សេចក្ដីថា បុគ្គលនោះមិនត្រូវសំឡេងឃោសនានាំទៅឡើយ ។ល។*

**អដ្ឋកថា រូបសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សរាគសូត្រទី ៦

*[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្ដេចខ្លះ ។ គឺបុគ្គលប្រកបដោយរាគៈ ១ ប្រកបដោយទោសៈ ១ ប្រកបដោយមោហៈ ១ ប្រកបដោយមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។*

ពួកសត្វឥតមានធម៌ ប្រកបដោយសេចក្តីត្រេកអរក្នុងអារម្មណ៍គួរត្រេកត្រអាលរីករាយ ក្នុងរូបជាទីស្រឡាញ់ ជាប់ដោយមោហៈ ញ៉ាំងចំណង ( នៃមារ ) ឲ្យចម្រើន ។ ពួកសត្វអ្នកមិនដឹងនូវហេតុដែលកើតអំពីរាគៈ កើតអំពីទោសៈ កើតអំពីមោហៈ រមែងធ្វើអកុសលកម្មប្រកបដោយទុក្ខ មានទុក្ខជាកម្រៃ ពួកសត្វត្រូវអវិជ្ជារួបរឹត ដូចជាខ្វាក់ឥតចក្ខុ គឺបញ្ញា ទើបមិនសម្គាល់នូវអកុសលកម្មនោះថា យើងទាំងឡាយនឹងមានសភាពប្រព្រឹត្តទៅតាមធម៌ទាំងឡាយ យ៉ាងនេះមិនខាន ។

# អដ្ឋកថា

## សរាគសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសរាគសូត្រទី ៦ ដូចតទៅនេះ បទថា **មោហជំ វាបិ អវិទ្ទសុ** សេចក្តីថា បុគ្គលល្ងង់ខ្លៅ គឺមិនមែនបណ្ឌិតធ្វើអកុសលកម្មដែលកើតព្រោះមោហៈក៏មាន ។ បទថា **សវិឃាតំ** គឺប្រព្រឹត្តទៅដោយទុក្ខ ។ បទថា **ទុក្ខុទ្រយំ** គឺបន្ថែមនូវទុក្ខឲ្យតទៅ ។ បទថា **អចក្ខុកា** គឺវៀរចាកបញ្ញាចក្ខុ ។ បទថា **យថា ធម្មា តថា សន្តា** សេចក្តីថា ធម៌ មានរាគៈជាដើម តាំងនៅយ៉ាងណាមួយ ។ បុគ្គលល្ងង់ខ្លៅទាំងនោះ

ក៏មានសភាពយ៉ាងនោះ ។ បទថា **ន តស្សេវន្តិ មញ្ញរេ** សេចក្តីថា បុគ្គល នោះ រមែងមិនសម្គាល់ រមែងមិនឮកថាអញយ៉ាងនោះ មានសភាពយ៉ាង នោះផងដែរ ។ ក្នុងសូត្រនេះក្តី ក្នុងព្រះគាថាក្តី ត្រាស់វដ្តៈតែម្យ៉ាង ៕

**អដ្ឋកថា សរាគសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## អហិសូត្រទី ៧

[ ៦៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ក្រុងសាវត្ថី មានភិក្ខុមួយរូប ត្រូវពស់ចឹកធ្វើមរណកាលទៅ ។ លំដាប់នោះ ភិក្ខុជាច្រើន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏ មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏ សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងសាវត្ថីនេះ មានភិក្ខុមួយរូបត្រូវពស់ចឹក ធ្វើ មរណកាលទៅ ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះ មិនផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួក ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ ផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួក

ម្នាលភិក្ខុទាំងឡាយ ពស់មិនគប្បីចឹកភិក្ខុនោះ ឲ្យស្លាប់ទៅទេ ។ ត្រកូលស្តេចពស់ ៤ ពួក ដូចម្តេចខ្លះ ។ គឺត្រកូលស្តេចពស់ ឈ្មោះវិរូបក្ខៈ ១ ត្រកូលស្តេចពស់ ឈ្មោះឯរាបថៈ ១ ត្រកូលស្តេចពស់ ឈ្មោះឆព្យាបុត្តៈ ១ ត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមកៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះមិនផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ពស់មិនហ៊ានចឹកភិក្ខុនោះឲ្យស្លាប់ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ដើម្បីគ្រប់គ្រងខ្លួន រក្សាខ្លួន ការពារខ្លួន ។

ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះវិរូបក្ខៈទាំងឡាយផង ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះឯរាបថៈទាំងឡាយផង ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះឆព្យាបុត្តៈទាំងឡាយផង ភាវៈជាមិត្តរបស់អញ ( ចូរមាន ) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងសត្វឥតជើង ទាំងឡាយផង ភាវៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹង

សត្វ មានជើងពីរទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងសត្វជើង ៤ ទាំងឡាយផង ការៈជាមិត្តរបស់អាត្មាអញ ( ចូរមាន ) ជាមួយនឹងសត្វមានជើងច្រើនទាំងឡាយផង ។ សត្វឥតជើងកុំបៀតបៀនអាត្មាអញ សត្វជើងពីរកុំបៀតបៀនអាត្មាអញ សត្វជើង ៤ កុំបៀតបៀនអាត្មាអញ សត្វជើងច្រើនកុំបៀតបៀនអាត្មាអញឡើយ ។ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា សត្វទាំងអស់ ( នោះ ) ចូរប្រទះនូវសេចក្តីចម្រើនទាំងឡាយ សេចក្តីអាក្រក់បន្តិចបន្តួច កុំមកឡើយ ។

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្យួយ ក្អែប ពីងពាង តុកកែ កណ្តុរ សុទ្ធតែមានប្រមាណ ( រាប់បាន ) គឺថា មិនច្រើនដូចគុណព្រះរតនត្រ័យទេ ។ កិរិយារក្សា ខ្ញុំបានធ្វើហើយ កិរិយាការពារ ខ្ញុំបានធ្វើហើយ ពួកសត្វចូរចៀសចេញទៅ ខ្ញុំសូមនមស្ការចំពោះព្រះដ៏មានព្រះភាគ សូមនមស្ការព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ ។

# អដ្ឋកថា

## អហិសូត្រ

[ ៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអហិសូត្រទី ៧ ដូចតទៅនេះ បទថា **ឥមានិ ចត្តារិ អហិរាជកុលានិ** នេះ ត្រាស់សំដៅដល់ពិសដែលត្រូវពស់ចឹក ពិសដែលត្រូវពស់ពួកណាមួយចឹក ពិសទាំងអស់នោះ នៅខាងក្នុងត្រកូលស្តេចពស់ទាំង ៤ នេះ ។ បទថា **អត្តគុត្តិយា** គឺដើម្បីគ្រប់គ្រងខ្លួន ។ បទថា **អត្តរក្ខាយ** គឺដើម្បីរក្សាខ្លួន ។ បទថា **អត្តបរិត្តាយ** គឺដើម្បីការពារខ្លួន អធិប្បាយថា តថាគតអនុញ្ញាតព្រះបរិត្ត ដូច្នេះ ។

ឥឡូវនេះ ភិក្ខុគប្បីធ្វើបរិត្តនោះដោយវិធីណា កាលទ្រង់សម្តែងវិធីនោះ ទើបត្រាស់ថា **វិរូបក្ខេហិ មេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **វិរូបក្ខេហិ** បានដល់ មានមេត្តាចិត្តជាមួយពស់ត្រកូលវិរូបក្ខៈ ។ ក្នុងត្រកូលពស់ដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **អបាទកេហិ** បានដល់ មានមេត្តាចិត្តជាមួយសត្វដែលមិនមានជើងទាំងឡាយ ។ ក្នុងសត្វដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សព្វេ សត្តា** សេចក្តីថា មុនអំពីនេះ ភិក្ខុពោលមេត្តាចំពោះដោយឋានៈប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ទើបផ្តើមពាក្យនេះដើម្បីពោលមេត្តាមិនចំពោះ ។ ក្នុងបទទាំងនោះ បទថា **សត្វា បាណា ភូត** ទាំងនេះ ជាបទពោលដល់បុគ្គលប៉ុណ្ណោះ ។ បទថា **ភទ្រានិ បស្សន្តុ** សេចក្តីថា ចូរឃើញតែអារម្មណ៍ដែលត្រេកអរចុះ ។ បទថា **មា កញ្ចិ បាបមាគមា** សេចក្តីថា សត្វណាមួយកុំជួបនូវវត្ថុដែលជាបាបលាមកឡើយ ។

*ក្នុងបទថា* **អប្បមាណោ ពុទ្ធោ** *នេះ គប្បីជ្រាបពុទ្ធគុណថា* **ពុទ្ធោ** *ពិត ហើយ ពុទ្ធគុណទាំងនោះ ឈ្មោះថា មិនអាចប្រមាណបាន ។ ក្នុង ២ បទ ដ៏សេសក៏មានន័យនេះឯង ។ បទថា* **បមាណវន្តានិ** *បានដល់ ប្រកប ហើយដោយប្រមាណនៃព្រះគុណ ។ បទថា* **ឧណ្ណានាភី** *បានដល់ ពីងពាង ដែលមានរោមត្រង់ពោះ ។ បទថា* **សរព្វូ** *បានដល់ តុកកែក្នុងផ្ទះ ។ បទថា* **កតា មេ រក្ខា កតា មេ បរិត្តា** *សេចក្តីថា ការរក្សា និងការការពារ ខ្ញុំបានធ្វើហើយ ដល់ជនប្រមាណប៉ុណ្ណោះ ។ បទថា* **បដិក្កមន្តុ ភូតានិ** *សេចក្តីថា សត្វទាំងអស់ដែលខ្ញុំធ្វើការការពារហើយ ចូរចៀសចេញទៅ អធិប្បាយថា កុំបៀតបៀនខ្ញុំឡើយ ដូច្នេះ ។ល។*

**អដ្ឋកថា អហិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទេវទត្តសូត្រទី ៨

[ ៦៩ ] *សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ កាលទេវទត្តភិក្ខុចេញទៅមិនយូរប៉ុន្មាន ។ ក្នុងទីនោះ ព្រះ ដ៏មានព្រះភាគ ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំង-*

ឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្តដើម្បីសេចក្តីវិនាស ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមចេកតែបញ្ចេញផ្លែមកដើម្បីសម្លាប់ដើម តែបញ្ចេញផ្លែមកដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាសក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឫស្សីបញ្ចេញផ្លែមក ដើម្បីសម្លាប់ដើម បញ្ចេញផ្លែមក ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្តដើម្បីសេចក្តីវិនាសក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមបបុសបញ្ចេញផ្លែមក ដើម្បីសម្លាប់ដើម បញ្ចេញផ្លែមក ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាសក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាមេសេះអស្សតរ តែចាប់មានផ្ទៃឡើង ដើម្បីសម្លាប់ខ្លួន តែចាប់មានផ្ទៃឡើងដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភ-សក្ការៈ និងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភ-

សក្ការៈ និងសេចក្ដីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្ដីវិនាស ក៏ដូចគ្នាដែរ ។

ផ្លែចេក រមែងសម្លាប់ដើមចេក ផ្លែឫស្សី រមែងសម្លាប់ដើមឫស្សី ផ្លែបបុស រមែងសម្លាប់ដើមបបុស សក្ការៈ រមែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌រមែងសម្លាប់មេសេះអស្សតរ ។

# អដ្ឋកថា

## ទេវទត្តសូត្រ

[ ៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទេវទត្តសូត្រទី ៨ ដូចតទៅនេះ បទថា **អចិរបក្កន្តេ ទេវទត្តេ** សេចក្ដីថា កាលទេវទត្តធ្វើសង្ឃភេទ ហើយចៀសចេញទៅមិនយូរ ។ បទថា **បរាភវាយ** បានដល់ ដើម្បីអន្តរាយ ដើម្បីសេចក្ដីវិនាស ។ បទថា **អស្សតរី** សេចក្ដីថា សេះអស្សតរកើតក្នុងពោះរបស់មេលា ។ បទថា **អត្តវធាយ គព្ភំ គណ្ហាតិ** សេចក្ដីថា មនុស្សទាំងឡាយផ្សំផ្គុំមេលានោះ និងបាសេះ សូម្បីសេះអស្សតរនោះតាំងគភ៌ហើយ កាលដល់ពេលកើតកូន ក៏កើតមិនបាន យកជើងទាំង ២ កកាយផែនដី កាលបើដូច្នោះ ទើបគេចងជើងទាំង ៤ របស់មេលាត្រង់បង្គោលទាំង ៤ វះពោះយកកូនចេញ ទើបមេលានោះស្លាប់ក្នុងទីនោះឯង ដោយហេតុ

នោះ ទើបត្រាស់ដល់មេរបស់សេះអស្សតរនោះ ។ ១៩៦

## អដ្ឋកថា ធេវទត្តសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បធានសូត្រទី ៩

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ បធាន ( សេចក្តីព្យាយាម ) នេះមាន ៤ យ៉ាង ។ បធាន ៤ យ៉ាង ដូចម្តេចខ្លះ ។ សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសំវ-រប្បធាន តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សំវរប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះបហានប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីលះបង់អកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បហានប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះភាវនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាវនាបធាន ។ ម្នាលភិក្ខុទាំងឡាយ អនុរក្ខនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ដើម្បីឲ្យស្ថិតនៅ មិនឲ្យភ្លេចភ្លាំងទៅ ឲ្យចម្រើនពេញលេញ ធំទូលាយក្រៃលែងឡើង ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា អនុរក្ខនាបធាន ។ ម្នាលភិក្ខុទាំងឡាយ បធានមាន ៤ យ៉ាងនេះឯង ។

សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១
អនុរក្ខនាបធាន ១ បធានទាំង ៤ នុ៎ះ ព្រះពុទ្ធជា
ផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ជាហេតុឲ្យ
ភិក្ខុក្នុងសាសនានេះ ជាអ្នកមានព្យាយាម ជាគ្រឿងដុត
កម្តៅកិលេស គប្បីដល់នូវការអស់ទៅនៃទុក្ខបាន ។

# អដ្ឋកថា

## បធានសូត្រ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបធានសូត្រទី ៩ ដូចតទៅនេះ សេចក្តីព្យាយាមដើម្បីរាំងនូវកិលេស គឺដើម្បីបិទផ្លូវចូលរបស់កិលេស ឈ្មោះថា **សំវរប្បធាន** ព្យាយាមដើម្បីលះ ឈ្មោះថា **បហានប្បធាន** ព្យាយាមដើម្បីចម្រើនកុសលធម៌ ឈ្មោះថា **ភាវនាបធាន** ព្យាយាមដើម្បីរក្សាកុសលធម៌ទាំងនោះ ឈ្មោះថា **អនុរក្ខនាបធាន** ។

អដ្ឋកថា បធានសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ធម្មិកសូត្រទី ១០

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ សម័យណាពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការក៏មិនប្រកបដោយធម៌ដែរ ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការមិនប្រកបដោយធម៌ សម័យនោះ ពួកព្រាហ្មណ៍ និងគហបតីក៏មិនប្រកបដោយធម៌ដែរ កាលពួកព្រាហ្មណ៍ និងគហបតីមិនប្រកបដោយធម៌ហើយ សម័យនោះ ពួកអ្នកនិគម និងអ្នកជនបទ ក៏មិនប្រកបដោយធម៌ដែរ កាលអ្នកនិគម និងអ្នកជនបទ មិនប្រកបដោយធម៌ ព្រះចន្ទ

និងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ កាលព្រះចន្ទ និងព្រះអាទិត្យគោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្សក៏គោចរទៅមិនស្មើដែរ កាលពួកផ្កាយនក្ខត្តឫក្សគោចរទៅមិនស្មើ យប់ និងថ្ងៃក៏ប្រព្រឹត្តទៅមិនស្មើដែរ កាល យប់ និងថ្ងៃប្រព្រឹត្តទៅមិនស្មើ ខែ និងកន្លះខែក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលខែ និងកន្លះខែប្រព្រឹត្តទៅមិនស្មើ រដូវ និងឆ្នាំក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលរដូវ និងឆ្នាំប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិនស្មើដែរ កាលខ្យល់បក់មិនស្មើ ខ្យល់បក់ខុសផ្លូវទាំងឡាយ ក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលខ្យល់បក់ខុសផ្លូវទាំងឡាយ ប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយខឹងសម្បា កាលទេវតាទាំងឡាយខឹងសម្បា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ កាលភ្លៀងមិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយក៏ឲ្យផលមិនស្មើល្អ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស កាលបរិភោគស្រូវឲ្យផលមិនស្មើ រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន ។ ម្នាលភិក្ខុទាំងឡាយ សម័យណាពួកព្រះរាជាប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការក៏ប្រកបដោយធម៌ដែរ កាលបើពួកខ្ញុំរាជការប្រកបដោយធម៌ ក្នុងសម័យនោះ ពួកព្រាហ្មណ៍ និងគហបតីក៏ប្រកបដោយធម៌ដែរ កាលពួកព្រាហ្មណ៍ និងគហបតីប្រកបដោយធម៌ ក្នុងសម័យនោះ ពួកអ្នកនិគម និងអ្នកជនបទក៏ប្រកបដោយធម៌ដែរ កាលបើពួកអ្នកនិគម និងអ្នកជនបទប្រកបដោយធម៌ ព្រះចន្ទ និងព្រះអាទិត្យក៏គោចរទៅស្មើដែរ កាលព្រះចន្ទ និងព្រះអាទិត្យគោចរទៅស្មើ ពួកផ្កាយនក្ខត្តឫក្សក៏គោចរទៅស្មើដែរ កាលពួក

ផ្កាយនក្ខត្តឫក្ស គោចរទៅស្មើ យប់ និងថ្ងៃក៏ប្រព្រឹត្តទៅស្មើដែរ កាលយប់និងថ្ងៃប្រព្រឹត្តទៅស្មើ ខែ និងកន្លះខែក៏ប្រព្រឹត្តទៅស្មើដែរ កាលខែ និងកន្លះខែប្រព្រឹត្តទៅស្មើ រដូវ និងឆ្នាំក៏ប្រព្រឹត្តទៅស្មើដែរ កាលរដូវ និងឆ្នាំប្រព្រឹត្តទៅស្មើ ខ្យល់ក៏បក់ស្មើដែរ កាលខ្យល់បក់ទៅស្មើ ផ្លូវខ្យល់ទាំងឡាយក៏ប្រព្រឹត្តទៅបានស្មើ កាលបើផ្លូវខ្យល់ទាំងឡាយស្មើ ពួកទេវតាក៏មិនខឹងសម្បា កាលពួកទេវតាមិនខឹងសម្បា ភ្លៀងក៏បង្អុរទឹកភ្លៀងចុះមកដោយប្រពៃ កាលភ្លៀងបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវក៏ឲ្យផលស្មើល្អ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយ កាលបរិភោគស្រូវដែលមានផលស្មើល្អ រមែងមានអាយុវែង មានសម្បុរល្អ មានកម្លាំង ព្រមទាំងមានអាពាធតិច ។

បើគោទាំងឡាយ កំពុងឆ្លងទៅ គោមេហ្វូងនាំទៅកាន់ផ្លូវខុសកំពង់ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវខុសកំពង់ ពួកគោទាំងអស់នោះ ក៏នាំគ្នាទៅកាន់ផ្លូវខុសកំពង់ដែរ មានឧបមាយ៉ាងណា ក្នុងពួកមនុស្ស ក៏ដូច្នោះដែរ អ្នកណាដែលគេសន្មតថា ប្រសើរជាងគេ បើអ្នកនោះប្រព្រឹត្តមិនត្រូវតាមធម៌ នឹងបាច់និយាយទៅថ្វីដល់ប្រជាជនដទៃឡើយ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែងដេកកើតទុក្ខ ។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ គោទាំងអស់នោះ រមែងទៅកាន់ផ្លូវត្រង់ដែរ មានឧបមា

*យ៉ាងណា ក្នុងពួកមនុស្ស ក៏ដូច្នោះដែរ អ្នកណាដែលគេសន្មត ជាប្រសើរជាងគេ បើអ្នកនោះប្រព្រឹត្តតាមធម៌ នឹងបាច់និយាយទៅថ្វីដល់ប្រជាជនដទៃ បើព្រះរាជាប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែងដេកនៅជាសុខ ។*

*បត្តកម្មវគ្គទី ២ ចប់*

## *ឧទ្ទាននៃបត្តកម្មវគ្គនោះ គឺ*

*និយាយអំពីកម្មដ៏គួរ ១ អំពីសេចក្តីសុខ មានការមិនជំពាក់បំណុលជាដើម ១ អំពីត្រកូលប្រកបដោយឋានៈជាព្រហ្មជាដើម ១ អំពីបុគ្គលធ្លាក់ទៅក្នុងនរក ១ អំពីរូបប្បមាណបុគ្គលជាដើមជាគម្រប់បួន ១ អំពីបុគ្គលប្រកបដោយរាគៈជាដើម ១ អំពីពស់ចឹកកិក្កុ ១ អំពីទេវទត្ត ១ អំពីបធានបួន ១ អំពីអធម្មិករាជ ១ ។*

# អដ្ឋកថា

## ធម្មិកសូត្រ

[ ៧១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មិកសូត្រទី ១០ ដូចតទៅនេះ បទថា* **អធម្មិកា ហោន្តិ** *សេចក្តីថា ព្រះរាជាទាំងឡាយប្រព្រឹត្តមិនប្រកបដោយធម៌*

ដោយមិនរក្សាសួយ ១០ ចំណែក និងមិនដាក់ទោសតាមសមគួរដល់កំហុស ដែលបុរាណរាជាទ្រទ្រង់ហើយ រក្សាសួយច្រើនជាងកំណត់ និងដាក់ទោសលើសកំណត់ ។

បទថា **រាជយុត្តា** បានដល់ ខ្ញុំរាជការដែលធ្វើការក្នុងជនបទរបស់ព្រះរាជា ។ បទថា **ព្រាហ្មណគហបតិកា** បានដល់ ព្រាហ្មណ៍ និងគហបតីទាំងឡាយដែលនៅខាងក្នុងក្រុង ។ បទថា **នេគមជានបទា** បានដល់ អ្នកនិគម និងអ្នកជនបទ ។ បទថា **វិសមំ** សេចក្តីថា ខ្យល់ក៏ប្រែប្រួលទៅមិនត្រូវតាមរដូវ ។ បទថា **វិសមា** សេចក្តីថា ខ្យល់ផាត់មិនស្មើ បក់ខ្លាំងពេកខ្លះ បក់តិចពេកខ្លះ ។ បទថា **អបញ្ញសា** បានដល់ ខ្យល់ក្រៅផ្លូវ បក់ចេញខាងក្រៅផ្លូវ ។ បទថា **ទេវតា បរិកុបិតា ភវន្តិ** សេចក្តីថា ព្រោះថាកាលខ្យល់ក្រៅគន្លងបក់មិនស្មើ ដើមឈើទាំងឡាយក៏បាក់ វិមានក៏បែកខ្ទាត់ខ្ទាយ ព្រោះដូច្នោះ ពួកទេវតាក៏ខឹងសម្បា ។ ទើបទេវតាទាំងនោះ មិនព្រមឲ្យភ្លៀងធ្លាក់តាមរដូវកាល ដោយហេតុនោះ ទើបត្រាស់ថា ភ្លៀងក៏មិនធ្លាក់តាមរដូវកាល ។ បទថា **វិសមបាកីនិ សស្សានិ ភវន្តិ** សេចក្តីថា សម្ទូងទាំងឡាយ ក៏ទុំមិនស្មើ យ៉ាងនេះ គឺក្នុងទីខ្លះផើម ក្នុងទីខ្លះដាក់ទឹកដោះក្នុងទីខ្លះទុំ ដូច្នេះ ។

បទថា **សមំ នក្ខត្តានិ តារករូបានិ បរិវត្តន្តិ** សេចក្តីថា ផ្កាយនក្ខត្តឫក្សទាំងឡាយ រមែងវិលស្មើ ដូចថ្ងៃពេញបូណ៌មីនោះ បាននក្ខត្តឫក្សនោះៗ

*ក្នុងខែនោះ យ៉ាងនេះថា ថ្ងៃ ១៥ កើត ខែកត្តិក បាននក្ខត្តឫក្សក្នុងខែកត្តិកប៉ុណ្ណោះ ថ្ងៃ ១៥ កើត ខែមិគសិរ បាននក្ខត្តឫក្សក្នុងខែមិគសិរប៉ុណ្ណោះ ។ បទថា* **សមំ វាតា វាយន្តិ** *សេចក្តីថា ខ្យល់ទាំងឡាយមិនមែនបក់មិនស្មើបក់ក្នុងរដូវកាលប៉ុណ្ណោះ រមែងបក់ក្នុងរដូវដែលសមគួរដល់ជនបទនោះៗ យ៉ាងនេះ គឺខ្យល់ទិសខាងជើង បក់ ៦ ខែ ខ្យល់ទិសខាងត្បូងបក់ ៦ ខែ ។ បទថា* **សមា** *សេចក្តីថា ខ្យល់បក់ស្មើ មិនខ្លាំងពេក មិនតិចពេក ។ បទថា* **បញ្ចសា** *បានដល់ ខ្យល់ដែលបក់ក្នុងផ្លូវ រមែងបក់តាមផ្លូវនោះឯង មិនមែនបក់ដោយមិនមែនផ្លូវឡើយ ។*

*បទថា* **ជិម្ហំ គច្ឆតិ** *ប្រែថា ដើរទៅមិនត្រង់ គឺរមែងកាន់យកតែទីដែលមិនមែនជាកំពង់ ។ បទថា* **នេត្តេ ជិម្ហំ គតេ សតិ** *បានដល់ គោឈ្មោះថា* **នេត្តា** *ព្រោះនាំទៅ ។ អធិប្បាយថា កាលគោនាំដើរទៅមិនត្រង់ កាន់យកតែទីមិនមែនជាកំពង់ គោក្រៅអំពីនេះ រមែងកាន់យកតែទីមិនមែនកំពង់តាមគ្នាទៅ ។ បាឋៈថា* **នេន្តេ** *ដូច្នេះក៏មាន ។ បទថា* **ទុក្ខំ សេតិ** *ប្រែថា រមែងដេកជាទុក្ខ អធិប្បាយថា ជួបនូវទុក្ខហើយ ។*

**អដ្ឋកថាធម្មិកសូត្រទី ១០ ចប់**

**បត្តកម្មវគ្គទី ២ ចប់**

**ព្រះសូត្រដែលលាយនឹងគាថា ចប់បរិបូណ៌**

# សុត្តន្តបិដក

## អបណ្ណកវគ្គ

### បធានសូត្រទី ១

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ជាអ្នកប្រតិបត្តិចំពោះអបណ្ណកប្បដិបទា គឺប្រតិបត្តិមិនខុសផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល ១ ជាអ្នកចេះដឹងច្រើន ១ ជាអ្នកមានព្យាយាមប្រារព្ធ ១ ជាអ្នកមានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថា ប្រតិបត្តិអបណ្ណកប្បដិបទាផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

# អបណ្ណកវគ្គទី ៣

## អដ្ឋកថា

### បធានសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបធានសូត្រទី ១ នៃអបណ្ណកវគ្គទី ៣ ដូចតទៅនេះ បទថា **អបណ្ណកប្បដិបទំ** គឺបដិបទាមិនខុស ។ បទថា **យោនិ ចស្ស អារទ្ធា ហោតិ** សេចក្ដីថា ហេតុនៃការអស់អាសវៈនៃភិក្ខុនោះ ឈ្មោះថា បរិបូណ៌ហើយ ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីអរហត្ត ។l៚

**អដ្ឋកថា បធានសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ឥន្ទ្រិយសូត្រទី ២

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការឈ្មោះថា ប្រតិបត្តិនូវអបណ្ណកប្បដិបទាផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្ដេចខ្លះ ។ គឺ សេចក្ដីត្រិះរិះក្នុងការចេញចាកកាម ១ សេចក្ដីត្រិះរិះក្នុងការមិនព្យាបាទ ១

សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ១ សេចក្តីឃើញត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថា ជាអ្នកប្រតិបត្តិនូវអបណ្ណកបដិបទាផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

# អដ្ឋកថា

## ទិដ្ឋិសូត្រ

ទិដ្ឋិសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទិដ្ឋិសូត្រទី ២ ចប់

# សុត្តន្តបិដក

## សប្បុរិសសូត្រទី ៣

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ អ្នកប្រាជ្ញគប្បីដឹងថាជាអសប្បុរស ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ រឿងណាជាទោសរបស់បុគ្គលដទៃ អសប្បុរសក្នុងលោកនេះ ទុកជាគេមិនសួរ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់

រឿងដែលគេសួរ ។ តែថាអសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់បុគ្គលដទៃ ដោយពិស្តារពេញទី មិនចេះអស់មិនចេះហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាគុណរបស់បុគ្គលដទៃ អសប្បុរសទុកជាមានគេសាកសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេមិនសួរ ។ តែថា អសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់បុគ្គលដទៃ ដោយសេចក្ដីមិនពិស្តារ មិនពេញលេញ ឲ្យធាប់អស់ធាប់ហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាទោសរបស់ខ្លួន អសប្បុរសទុកជាមានគេសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេមិនសួរ ។ តែថាអសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់ខ្លួនមិនដោយសេចក្ដីពិស្តារ មិនពេញលេញ ឲ្យធាប់អស់ឲ្យធាប់ហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាគុណរបស់ខ្លួន អសប្បុរសទុកជាមិនមានគេសួររឿងនោះ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វី ដល់រឿងដែលគេសួរ ។ តែថាអសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់ខ្លួនឲ្យ

ពិស្តារ ឲ្យពេញលេញ មិនឲ្យអស់ មិនឲ្យហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ អ្នកប្រាជ្ញគប្បីដឹងថាជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ ( ដោយឡែកទៀត ) អ្នកប្រាជ្ញគប្បីដឹងថាជាសប្បុរស ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ រឿងណាជាទោសរបស់បុគ្គលដទៃ សប្បុរសក្នុងលោកនេះ បើទុកជាមានគេសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងពោលទៅថ្វីដល់រឿងដែលគេមិនសួរ ។ ចំណែកខាងសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់បុគ្គលដទៃ ដោយមិនពិស្តារ មិនពេញលេញ ឲ្យធាប់អស់ ឲ្យធាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាដែលជាគុណរបស់បុគ្គលដទៃ សប្បុរសទុកជាគេមិនសួរ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេសួរ ។ ចំណែកខាងសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់បុគ្គលដទៃឲ្យពិស្តារ ឲ្យពេញលេញ មិនចេះអស់ មិនចេះហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាទោសរបស់ខ្លួន សប្បុរសទុកជាគេមិនសួរ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេ

សួរ ។ មួយទៀត សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់ខ្លួន ឲ្យពិស្តារ ឲ្យពេញលេញ មិនចេះអស់ មិនចេះហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងជំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងឯរឿងណាជាគុណរបស់ខ្លួន សប្បុរសទុកជាគេសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេមិនសួរ ។ មួយវិញទៀត សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់ខ្លួនដោយសេចក្តីមិនពិស្តារ មិនឲ្យពេញលេញ ឲ្យដាច់អស់ ឲ្យដាច់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងជំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ អ្នកប្រាជ្ញគប្បីដឹងថាជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រីមានគូស្រករដែលគេនាំមកក្នុងវេលាយប់ណា ឬថ្ងៃណា វេលានោះ ស្ត្រីនោះ ក៏តាំងហិរិ និងឱត្តប្បៈដ៏មាំមួនទៅរកម្តាយក្មេកផង ឪពុកក្មេកផង ប្តីផង ដោយហោចទៅ សូម្បីចំពោះពួកបុរសជាទាសកម្មករ សម័យក្រោយមក ស្ត្រីនោះ អាស្រ័យការនៅរួមសង្វាសហើយ និយាយយ៉ាងនេះនឹងម្តាយក្មេក ឪពុកក្មេក និងប្តីថា សូមអ្នកទាំងឡាយចៀសចេញទៅ សូមអ្នកទាំងឡាយដឹងការងារអ្វីៗ ចុះ មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះក្នុងសាសនានេះ ក៏មានឧបមេយ្យដូច្នោះដែរ គឺបានចេញចាកផ្ទះចូលកាន់ផ្នួសក្នុងវេលាយប់ ឬថ្ងៃណាហើយ វេលានោះ

ភិក្ខុនោះតាំងហិរិ និងឱត្តប្បៈដ៏មាំមួនទៅរកពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដោយហោចទៅសូម្បីពួកអារាមិកជន គឺអ្នកធ្វើការក្នុងអារាម និងសមណុទ្ទេស ( សាមណេរ ) សម័យក្រោយមក ភិក្ខុនោះ អាស្រ័យការនៅរួបរួមគ្នា ទើបនិយាយយ៉ាងនេះនឹងអាចារ្យខ្លះ ឧបជ្ឈាយ៍ខ្លះថា សូមលោកទាំងឡាយ ចៀសចេញទៅ សូមលោកទាំងឡាយដឹងការងារអ្វីៗ ចុះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងមានចិត្តស្មើ ដូចជាស្ត្រីមានគូស្រករដែលទើបមកដល់ថ្មី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

## សប្បុរិសសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសប្បុរិសសូត្រទី ៣ ដូចតទៅនេះ បទថា **អវណ្ណោ** បានដល់ មិនមែនគុណ ។ បទថា **ធាតុករោតិ** បានដល់ ប្រាប់ធ្វើឲ្យប្រាកដ ។ បទថា **បញ្ហាភិនីតោ** បានដល់ ត្រូវនាំមកសាកសួរ ។ បទថា **អហាបេត្វា អលម្ពេត្វា** បានដល់ ធ្វើមិនឲ្យស្រកចុះ ធ្វើមិនឲ្យតិចចុះនោះឯង ។ មួយវិញទៀត ក្នុងសេចក្តីនេះ អសប្បុរសមែងបិទបាំងនូវការវិនាសរបស់ខ្លួន ។ ព្រោះជាអ្នកប្រាថ្នាលាភមក សប្បុរសមែងបិទបាំង

កិត្តិគុណរបស់ខ្លួន ព្រោះជាអ្នកខ្មាស ។ ព្រោះហេតុដែលអសប្បុរសជាប់នូវហិរិឱត្តប្បៈ នៅរួមគ្នាក៏មើលងាយ ឯសប្បុរសប្រកបដោយហិរិឱត្តប្បៈ នៅរួមគ្នាក៏មិនមើលងាយ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងសាធក ភាពជាសប្បុរស ប្រៀបដូចកូនប្រសាថ្មី ទើបត្រាស់ថា **សេយ្យថាបិ ភិក្ខវេ វធុកា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **វធុកា** បានដល់ កូនប្រសាស្រី ។ បទថា **តិព្វំ** គឺច្រើន ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា សប្បុរិសសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បឋមអគ្គសូត្រទី ៤

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ ការប្រសើរនេះមាន ៤ ប្រការ ។ ការប្រសើរមាន ៤ ប្រការ ដូចម្តេចខ្លះ ។ គឺសីលប្រសើរ ១ សមាធិប្រសើរ ១ បញ្ញាប្រសើរ ១ វិមុត្តិប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រសើរមាន ៤ ប្រការនេះឯង ។

# អដ្ឋកថា

## បឋមអគ្គសូត្រ

[ ៧៥ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអគ្គសូត្រទី ៤ ដូចតទៅនេះ បទថា* **សីលគ្គំ** *គឺសីលដ៏ប្រសើរ ។ ក្នុងបទទាំងពួងក៏មានន័យដូច្នេះ ។៚*

**អដ្ឋកថា បឋមអគ្គសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ទុតិយអគ្គសូត្រទី ៥

[ ៧៦ ] *ម្នាលភិក្ខុទាំងឡាយ ការប្រសើរនេះមាន ៤ ប្រការ ។ ការប្រសើរមាន ៤ ប្រការ ដូចម្តេចខ្លះ ។ គឺរូបប្រសើរ ១ វេទនាប្រសើរ ១ សញ្ញាប្រសើរ ១ ភពប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រសើរ ៤ យ៉ាងនេះឯង ។*

# អដ្ឋកថា

## ទុតិយអគ្គសូត្រ

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអគ្គសូត្រទី ៥ ដូចតទៅនេះ បទថា **រូបគ្គំ** សេចក្ដីថា បុគ្គលពិចារណាឃើញរូបណាហើយ រមែងសម្រេចអរហត្ត រូបនេះ ឈ្មោះថា រូបដ៏ប្រសើរ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។ ឯក្នុងបទថា **ភវគ្គំ** នេះ បុគ្គលតាំងនៅក្នុងអត្តភាពណា រមែងសម្រេចអរហត្តក្នុងអត្តភាពនោះ ឈ្មោះថា ភពដ៏ប្រសើរ ដូច្នេះ ៕

**អដ្ឋកថា ទុតិយអគ្គសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## កុសិនារាសូត្រទី ៦

[ ៧៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្ដេចគង់នៅនាចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវន នៃស្ដេចមល្លៈទាំងឡាយ ជាទីបត់ចូលទៅក្នុងក្រុង ជិតនគរកុសិនារា ក្នុងសម័យជិតបរិនិព្វាន ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទូលព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីសង្ស័យ ឬសេចក្ដីវង្វេស

ចិត្តក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តីមានដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសួរមកចុះ កុំឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយថា ព្រះសាស្តារបស់យើងគង់នៅក្នុងទីចំពោះមុខ ពួកយើងមិនបានទូលសួរព្រះដ៏មានព្រះភាគ ចំពោះព្រះភក្ត្រសោះ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកភិក្ខុទាំងនោះក៏នៅស្ងៀម ។ ព្រះដ៏មានព្រះភាគត្រាស់នឹងពួកភិក្ខុជាគម្រប់ពីរដងទៀត ... ព្រះដ៏មានព្រះភាគត្រាស់នឹងពួកភិក្ខុជាគម្រប់បីដងទៀតថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យ ឬសេចក្តីវង្វេងសចិត្ត ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តី មានដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសួរមកចុះ កុំមានសេចក្តីក្តៅក្រហាយស្តាយក្រោយថា ព្រះសាស្តារបស់យើងគង់នៅក្នុងទីចំពោះមុខ ពួកយើងមិនបានទូលសួរព្រះដ៏មានព្រះភាគ ចំពោះព្រះភក្ត្រសោះ ។ ពួកភិក្ខុទាំងនោះ នៅស្ងៀមអស់វារៈ ៣ ដងទៀត ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំង-ឡាយ បើអ្នកទាំងឡាយមិនហ៊ានសួរ ព្រោះមានសេចក្តីគោរពក្នុងព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុជាសម្លាញ់ ចូរប្រាប់ភិក្ខុជាសម្លាញ់ផងគ្នាចុះ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកភិក្ខុទាំងនោះក៏នៅស្ងៀម ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា អស្ចារ្យណាស់ព្រះអង្គ ចម្លែកណាស់ព្រះអង្គ បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីជ្រះថ្លា ក្នុងពួកភិក្ខុនេះដោយប្រការយ៉ាងនេះ ។ សេចក្ដីសង្ស័យ ឬសេចក្ដីវង្វេងសចិត្ត ក្នុងព្រះពុទ្ធក្ដី ព្រះធម៌ក្ដី ព្រះសង្ឃក្ដី មគ្គក្ដី បដិបទាក្ដី ក្នុងពួកភិក្ខុទាំងនេះ មិនមានដល់ភិក្ខុមួយរូបឡើយ ។ ម្នាលអានន្ទ អ្នកពោលតាមសេចក្ដីជ្រះថ្លាពិត ម្នាលអានន្ទ តថាគតក៏មានសេចក្ដីដឹងក្នុងដំណើរនោះដែរថា សេចក្ដីសង្ស័យ ឬវង្វេងសចិត្តក្នុងព្រះពុទ្ធក្ដី ព្រះធម៌ក្ដី ព្រះសង្ឃក្ដី មគ្គក្ដី បដិបទាក្ដី ក្នុងពួកភិក្ខុទាំងនេះ មិនមានដល់ភិក្ខុមួយរូបឡើយ ។ ម្នាលអានន្ទ ព្រោះថា បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុណាដែលមានគុណជាន់ទាបជាងគេ ភិក្ខុនោះ គង់ជាសោតាបន្ន មិនធ្លាក់ទៅក្នុងអបាយទេ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

# អដ្ឋកថា

## កុសិនារាសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុសិនារាសូត្រទី ៦ ដូចតទៅនេះ បទថា **ឧបវត្តនេ** បានដល់ ក្នុងទីកណ្ដាលនៃជួររាំងភ្នំដែលនៅទិសខាងកើត ដុះរៀងគ្នាព័ទ្ធទៅទិសខាងជើង ។ បទថា **អន្តរេ យមកសាលានំ** បានដល់ ក្នុងរវាងដើមរាំងភ្នំ ២ ដើម ។ បទថា **កង្ខា** បានដល់ ការងឿងឆ្ងល់ ។ បទ

ថា **វិមតិ** គឺមិនអាចសម្រេចបាន ។ សេចក្ដីសង្ខេបក្នុងសេចក្ដីនេះ មាន ដូច្នេះថា ភិក្ខុរូបណា គប្បីកើតសេចក្ដីសង្ស័យថា ព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធ ព្រះធម៌ ឬមិនមែនព្រះធម៌ ព្រះសង្ឃ ឬមិនមែនសង្ឃ មគ្គ ឬមិនមែនមគ្គ បដិបទា ឬមិនមែនបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរសួរចុះ តថាគតនឹងប្រាប់សេចក្ដីនោះ ដល់ភិក្ខុរូបនោះ ដូច្នេះ ។

បទថា **សត្ថុគារវេនបិ ន បុច្ឆេយ្យាថ** សេចក្ដីថា បើពួកអ្នកមិនសួរ ព្រោះគោរពក្នុងព្រះសាស្ដាយ៉ាងនេះថា ពួកយើងបួសក្នុងសម្នាក់របស់ព្រះសាស្ដា សូម្បីបច្ច័យ ៤ ជារបស់ព្រះសាស្ដានៃពួកយើង ពួកយើងទាំងនោះ មិនសង្ស័យមកអស់កាលមានប្រមាណប៉ុណ្ណោះហើយ ក៏មិនគួរធ្វើសេចក្ដីសង្ស័យក្នុងថ្ងៃនេះ ដែលជាបច្ឆិមកាល ។ ដោយបទថា **សហាយកោបិ ភិក្ខវេ សហាយកស្ស អារោចេតុ** ទ្រង់សម្ដែងថា បណ្ដាពួកអ្នក ភិក្ខុណា ជាសម្លាញ់ ឃើញសម្លាញ់ស្និទ្ធស្នាលរបស់ភិក្ខុណា ភិក្ខុនោះចូរប្រាប់ដល់ភិក្ខុនោះ តថាគតនឹងប្រាប់ដល់ភិក្ខុមួយរូប ពួកអ្នកគប្បីស្ដាប់ពាក្យរបស់ភិក្ខុនោះ ហើយក៏នឹងនាំគ្នាអស់នូវសេចក្ដីសង្ស័យ ។ បទថា **ឯវំ បសន្នោ** សេចក្ដីថា ខ្ញុំព្រះអង្គជឿយ៉ាងនេះ ។ បទថា **ញាណមេវ** សេចក្ដីថា ញាណដែលធ្វើឲ្យប្រចក្សដល់ភាវៈដែលភិក្ខុមិនមានសេចក្ដីសង្ស័យ មិនមែនត្រឹមតែការជឿរបស់តថាគតក្នុងសេចក្ដីនេះ ។ បទថា **ឥមេសំ ហិ អានន្ទ** សេចក្ដីថា បណ្ដាភិក្ខុប្រមាណ ៥០០ រូបនេះ ដែលអង្គុយខាងក្នុងវាំងនន ។

បទថា **យោ បច្ឆិមកោ** សេចក្តីថា ត្រាស់ដល់ព្រះអានន្ទត្ថេរដែលជាភិក្ខុមានគុណទាបបំផុត ។ ៚

## អដ្ឋកថា កុសិនារាសូត្រទី ៦ ចប់

# អចិន្តេយ្យសូត្រទី ៧

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ អចិន្រ្តៃយ៍ ( ហេតុដែលមិនគួរគិត ) នេះមាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាក ។ អចិន្រ្តៃយ៍ ៤ ប្រការ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវិស័យរបស់ព្រះពុទ្ធទាំងឡាយ ជាអចិន្រ្តៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយ ឈានវិស័យរបស់បុគ្គលអ្នកបានឈាន ជាអចិន្រ្តៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្ម ជាអចិន្រ្តៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយ លោកចិន្តា ( ការគិតអំពីលោក ) ជាអចិន្រ្តៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត

និងសេចក្ដីលំបាកទទេ ១ ។ ម្នាលភិក្ខុទាំងឡាយ អចិន្ដេយ្យ មាន ៤ ប្រការប៉ុណ្ណេះ ដែលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួត និងសេចក្ដីលំបាកទទេៗ ។

# អដ្ឋកថា

## អចិន្ដេយ្យសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអចិន្ដេយ្យសូត្រទី ៧ ដូចតទៅនេះ បទថា **អចិន្តេយ្យានិ** បានដល់ មិនគួរគិត ។ បទថា **ន ចិន្តេតព្វានិ** សេចក្ដីថា បុគ្គលមិនគួរគិត ព្រោះជាអចិន្ដេយ្យនោះឯង ។ បទថា **យានិ ចិន្តេន្តោ** គឺ គិតវត្ថុដែលមិនមានហេតុពួកណា ។ បទថា **ឧម្មាទស្ស** បានដល់ ភាពជាមនុស្សឆ្កួត ។ បទថា **វិឃាតស្ស** គឺជាទុក្ខ ។ បទថា **ពុទ្ធវិសយោ** ប្រែថា វិស័យរបស់ព្រះពុទ្ធទាំងឡាយ គឺប្រព្រឹត្តទៅ និងអានុភាពរបស់ពុទ្ធគុណមានសព្វញ្ញុតញ្ញាណជាដើម ។ បទថា **ឈានវិសយោ** បានដល់ ឈានវិស័យក្នុងអភិញ្ញា ។ បទថា **កម្មវិបាកោ** បានដល់ វិបាករបស់កម្ម មានកម្មដែលគប្បីសោយផលក្នុងបច្ចុប្បន្នជាដើម ។ បទថា **លោកចិន្តា** សេចក្ដីថា លោកចិន្ដា គឺការគិតរឿងលោក ដូចជាគិតថា អ្នកណាហ្ន៎ សាងព្រះចន្ទ និងព្រះអាទិត្យ អ្នកណាហ្ន៎ សាងមហាប្រឹថពី អ្នកណាហ្ន៎ សាងមហាសមុទ្រ

អ្នកណាហ្ន៎ សាងសត្វឲ្យកើត អ្នកណាសាងភ្នំ អ្នកណាហ្ន៎ សាងដើមស្វាយ ដើមត្នោត និងដើមដូងជាដើម ដូច្នេះ ។ល។

## អដ្ឋកថា អចិន្តេយ្យសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទក្ខិណាសូត្រទី ៨

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិ ( សេចក្តីបរិសុទ្ធនៃទក្ខិណាទាន ) នេះមាន ៤ ប្រការ ។ ទក្ខិណាវិសុទ្ធិ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកក៏មាន ១ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយកក៏មាន ១ ទក្ខិណាមិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហកក៏មាន ១ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយកផង បរិសុទ្ធអំពីបដិគ្គាហកផងក៏មាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ មានសីល មានកល្យាណធម៌ តែបដិគ្គាហកជាអ្នកទ្រុស្តសីល មានបាបធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា

ទក្ខិណាបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ តែបដិគ្គាហកជាអ្នកមានសីល មានកល្យាណធម៌ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា ទក្ខិណាបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាមិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ ទាំងបដិគ្គាហកក៏ជាអ្នកទ្រុស្តសីល មានបាបធម៌ដែរ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា ទក្ខិណាមិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហក ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ទាយកក្នុងសាសនានេះ ជាអ្នកមានសីល មានកល្យាណធម៌ បដិគ្គាហកក៏ជាអ្នកមានសីល មានកល្យាណធម៌ដូចគ្នា ។ ម្នាលភិក្ខុទាំង-ឡាយ យ៉ាងនេះ ឈ្មោះថា ទក្ខិណាបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង ។ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិមាន ៤ ប្រការប៉ុណ្ណេះឯង ។

# អដ្ឋកថា

## ទក្ខិណាសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទក្ខិណាសូត្រទី ៨ ដូចតទៅនេះ បទថា **ទក្ខិណាវិសុទ្ធិយោ** បានដល់ ហេតុទាំងឡាយនៃសេចក្ដីបរិសុទ្ធ នៃទក្ខិណា គឺទាន ។ បទថា **ទាយកតោ វិសុជ្ឈតិ** សេចក្ដីថា រមែងបរិសុទ្ធដោយការមានផលច្រើន ។ បទថា **កល្យាណធម្មោ** គឺជាអ្នកមានធម៌ស្អាត ។ បទថា **បាបធម្មោ** គឺជាអ្នកមានបាបធម៌ ។ ក្នុងបទថា **ទាយកតោ វិសុជ្ឈតិ** នេះ គួរពោលដល់វេស្សន្ដរមហារាជ ។ បានឮថា វេស្សន្ដរមហារាជនោះឲ្យទារកដល់ព្រាហ្មណ៍ឈ្មោះជូជក ធ្វើមហាប្រឹថពីឲ្យញាប់ញ័រហើយ ក្នុងបទថា **បដិគ្គាហកតោ វិសុជ្ឈតិ** នេះ គួរពោលដល់អ្នកប្រមង់ ដែលនៅត្រង់មាត់ស្ទឹងកល្យាណី ។ បានឮថា អ្នកប្រមង់នោះបានប្រគេនបិណ្ឌបាត ៣ ដង ដល់ព្រះទីឃសុមនត្ថេរ ដេកលើគ្រែមរណៈ ពោលថា បិណ្ឌបាតដែលបានប្រគេនដល់លោកម្ចាស់ ទីឃសុមនត្ថេរលើកខ្ញុំឡើងបាន ។ ក្នុងបទថា **នេវ ទាយកតោ** នេះ គួរពោលដល់នាយព្រានក្នុងស្រុកវឌ្ឍមាន បានឮថា ព្រាននោះ កាលធ្វើបុណ្យ ឧទ្ទិសដើម្បីអ្នកស្លាប់ហើយ ទើបបានឲ្យដល់បដិគ្គាហកជាអ្នកទ្រុស្ដសីលតែម្នាក់អស់ ៣ ដង ។ ក្នុងគ្រាទី ៣ អមនុស្ស គឺអ្នកស្លាប់ទៅកើតជាប្រេតស្រែកថា បដិគ្គាហកទ្រុស្ដសីលប្លន់ខ្ញុំ ដូច្នេះ ។ ទក្ខិណាដែលអាចដល់បុគ្គលអ្នកស្លាប់នោះ ក្នុងកាលទក្ខិណាដែលបុគ្គលនោះថ្វាយដល់ភិក្ខុដែលមានសីលមួយរូបហើយ ។ ក្នុងបទថា **ទាយកតោ**

ចេវ វិសុជ្ឈំ បដិគ្គាហកតោ ច នេះ បណ្ឌិតគួរពោលអសទិសទាននោះ ឯង ។ ១៨៨

## អដ្ឋកថា ទក្ខិណាសូត្រទី ៨ ចប់

# សុត្តន្តបិដក

## វណិជសូត្រទី ៩

[ ៨០ ] គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រដ៏មានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានតែខាតទុនជាប្រក្រតី បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មិនបានចំណេញដូចបំណង បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួន

ប្រកបទៅហើយ មានចំណេញដូចបំណង បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ បានចំណេញលើសបំណង ។ ម្នាលសារីបុត្រ បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ ( សូម ) ដោយបច្ច័យចុះ បុគ្គលនោះបវារណាដោយបច្ច័យណាមែន តែមិនឲ្យបច្ច័យនោះទេ បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ មកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងខាតទុនទៅជាប្រក្រតី ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះបវារណាដោយបច្ច័យណាមែន តែឲ្យបច្ច័យនោះមិនតាមបំណងទេ បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ មកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ មិនបានចំណេញដូចបំណង ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណា ក៏ឲ្យបច្ច័យនោះតាមបំណងមែន បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបជំនួញណា ជំនួញរបស់បុគ្គល

នោះ រមែងមានចំណេញដូចបំណង ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណា ក៏ឲ្យបច្ច័យនោះលើសបវារណា បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងមានចំណេញលើសបំណង ។ ម្នាលសារីបុត្រ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានតែខាតទុនជាប្រក្រតី ១ ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មិនមានចំណេញដូចបំណង ១ ម្នាលសារីបុត្រ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ បានចំណេញដូចបំណង ១ ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានចំណេញលើសបំណង ១ ។

# អដ្ឋកថា

## វណិជសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវណិជសូត្រទី ៩ ដូចតទៅនេះ បទថា **តាទិសាវ** សេចក្តីថា ការលក់ដូរដូចគ្នានោះ គឺស្រដៀងគ្នានោះ ។ បទថា **ឆេទគាមិនី ហោតិ** គឺមិនចំណេញ អធិប្បាយថា ផលចំណេញ ដែលប្រាថ្នាសាបសូន្យអស់ ។ បទថា **ន យថាធិប្បាយា ហោតិ** សេចក្តីថា បានដល់ផលកម្រៃមិនសមតាមប្រាថ្នា ។ បទថា **បរាធិប្បាយា ហោតិ** សេចក្តីថា បានផលកម្រៃលើស គឺច្រើនជាងដែលខ្លួនប្រាថ្នា ។ ក្នុងបទថា **សមណំ វា ព្រាហ្មណំ វា** នេះ គប្បីជ្រាបថា ជាសមណៈ ឬព្រាហ្មណ៍ ព្រោះមានបាបស្ងប់ហើយ មានបាបដែលបន្សាត់ចោលហើយ ។ បទថា **វទ ភន្តេ បច្ចយេន** សេចក្តីថា រមែងបវារណា គឺនិមន្តយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ គប្បីសូមបច្ច័យ ៤ មានចីវរជាដើមបាន ។ បទថា **យេន បវារេតិ** សេចក្តីថា បុគ្គលនោះ រមែងបវារណាកំណត់ដោយបច្ច័យណា ។ បទថា **តំ ន ទេតិ** សេចក្តីថា បុគ្គលនោះមិនប្រគេនបច្ច័យនោះគ្រប់ប្រការ ។ បទថា **តំ ន យថាធិប្បាយំ ទេតិ** សេចក្តីថា បុគ្គលនោះរមែងមិនអាចប្រគេនបច្ច័យនោះតាមដែលសមណព្រាហ្មណ៍នោះ បំណង គឺប្រគេនបន្ថយចុះ ។ បទថា **យថាធិប្បាយំ ទេតិ** សេចក្តីថា សមណព្រាហ្មណ៍នោះរមែងប្រាថ្នាបច្ច័យប៉ុនណា ក៏ប្រគេនបច្ច័យប៉ុណ្ណោះ ។ បទថា **បរាធិប្បាយំ ទេតិ** សេចក្តីថា បុគ្គលនោះ បវារណាបច្ច័យទុកតិចតួច តែប្រគេនច្រើន

ជាងនោះ ។ល។

អដ្ឋកថា វណិជសូត្រទី ៩ ចប់

# សុត្តន្តបិដក

## កម្ពោជសូត្រទី ១០

[ ៨១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្ដេចគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យមាតុគ្រាមមិនបានអង្គុយក្នុងសភា មិនបានប្រកបការងារ ( ធំៗ ) មិនសម្រេចនូវភោគសម្បត្តិដែលកើតអំពីការងារបាន ។ ម្នាលអានន្ទ មាតុគ្រាមហៃក្រោធ ម្នាលអានន្ទមាតុគ្រាមហៃឫស្យា ម្នាលអានន្ទ មាតុគ្រាមហៃកំណាញ់ ម្នាលអានន្ទមាតុគ្រាមអប្បប្រាជ្ញា ។ ម្នាលអានន្ទ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមមិនបានចូលទៅអង្គុយក្នុងសភា មិនបានប្រកបការងារ ( ធំៗ )

មិនសម្រេចនូវភោគសម្បត្តិ ដែលកើតអំពីការងារបាន ។

អបណ្ណកវគ្គទី ៣ ចប់

## ឧទ្ទាននៃអបណ្ណកវគ្គនោះ គឺ

ពោលអំពីអបណ្ណកប្បដិបទា មានសេចក្ដីព្យាយាមជាដើម ១ អំពីអបណ្ណកប្បដិបទា មានសម្មាទិដ្ឋិជាដើម ១ អំពីអសប្បុរស ១ អំពីសប្បុរស ១ អំពីកិក្ខុមានហិរិឱតប្បៈ មានសេចក្ដីប្រៀបដូចស្ត្រីមានគូស្រករ ១ អំពីការប្រសើរមានពីរលើក ១ អំពីព្រះដ៏មានព្រះភាគ គង់ទៀបក្រុងកុសិនារា ១ អំពីអចិន្ត្រៃយ៍ ១ អំពីទក្ខិណាវិសុទ្ធិ ១ អំពីជំនួញ ១ អំពីមាតុគ្រាមមិនសម្រេចនូវភោគសម្បត្តិ ដែលកើតអំពីការងារជាដើម ១ ទើបហៅថា អបណ្ណកវគ្គ ។

# អដ្ឋកថា

## កម្ពោជសូត្រ

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកម្ពោជសូត្រទី ១០ ដូចតទៅនេះ បទថា **នេវ សភាយំ និសីទតិ** សេចក្ដីថា មាតុគ្រាមរមែងមិនអង្គុយក្នុងសភា

*វិនិច្ឆ័យ ដើម្បីធ្វើការវិនិច្ឆ័យ ។ បទថា* **ន កម្មន្តំ បយោជេតិ** *សេចក្តីថា មិនប្រកបការងារធំ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។ បទថា* **ន ករម្ពាជំ គច្ឆតិ** *សេចក្តីថា មិនទៅកាន់ដែនកម្ពោជដើម្បីប្រមូលភោគទ្រព្យ ។ ពាក្យនោះ ត្រឹមតែជាមាតិកាប៉ុណ្ណោះ អធិប្បាយថា មិនទៅខាងក្រៅដែនណាមួយ ។ ក្នុងបទជាដើមថា* **កោធនោ** *សេចក្តីថា មាតុគ្រាមត្រូវសេចក្តីក្រោធចោមរោមហើយ ឈ្មោះថា មិនស្គាល់ប្រយោជន៍ និងមិនជាប្រយោជន៍ ព្រោះសេចក្តីក្រោធ ។ ឈ្មោះថា មិនអត់ធន់ក្នុងសម្បត្តិរបស់អ្នកដទៃ ព្រោះច្រើនដោយសេចក្តីច្រណែន ។ ឈ្មោះថា មិនអាចនឹងឲ្យទ្រព្យទៅធ្វើកិច្ចដែលគួរធ្វើបាន ព្រោះច្រើនដោយសេចក្តីកំណាញ់ ឈ្មោះថា មិនអាចធ្វើកិច្ចដែលគួរធ្វើបាន ព្រោះមិនមានបញ្ញា ព្រោះដូច្នោះ ទើបមាតុគ្រាមមិនធ្វើការអង្គុយក្នុងសភាជាដើម ដូច្នេះ ។*

**អដ្ឋកថាកម្ពោជសូត្រទី ១០ ចប់**

**អបណ្ណកវគ្គទី ៣ ចប់**

# សុត្តន្តបិដក
# មចលវគ្គទី ៤

## ចាណាតិចាតសូត្រទី ១

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែង ធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺជាអ្នកសម្លាប់សត្វមានជីវិត ១ កាន់យកទ្រព្យដែលគេ មិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយពាក្យកុហក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ប្រុងទៅ ក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងទៅកើតក្នុង ស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

# មចលវគ្គទី ៤

## បាណាតិបាតសូត្រ

[ ៨២ ] បាណាតិបាតសូត្រទី ១ នៃមចលវគ្គទី ៤ មានអត្ថាយយល់ហើយ ។

អដ្ឋកថាបាណាតិបាតសូត្រទី ១ ចប់

# សុត្តន្តបិដក

## មុសាសូត្រទី ២

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកនិយាយពាក្យកុហក ១ និយាយពាក្យញុះញង់ ១ និយាយពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងធ្លាក់ប្រុងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា

១ វៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

## មុសាសូត្រ

[ ៨៣ ] មុសាសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាមុសាសូត្រទី ២ ចប់

# សុត្តន្តបិដក

## វណ្ណាសូត្រទី ៣

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយពោលសរសើរបុគ្គលដែលគួរតិះដៀល ១ មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយពោលតិះដៀលបុគ្គលដែលគួរសរសើរ ១ មិន

ពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយបណ្ដុះសេចក្ដីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយបណ្ដុះសេចក្ដីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ប្រូងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបុគ្គលបានពិនិត្យមើល បានស្ទង់មើល រួចហើយទើបពោលទោសចំពោះបុគ្គលដែលប្រកបដោយទោស ១ បានពិនិត្យមើល បានស្ទង់មើល រួចហើយ ទើបពោលគុណចំពោះបុគ្គលដែលប្រកបដោយគុណ ១ បានពិនិត្យមើល បានស្ទង់មើល រួចហើយ ទើបបណ្ដុះសេចក្ដីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ បានពិនិត្យមើល បានស្ទង់មើល រួចហើយ ទើបបណ្ដុះសេចក្ដីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

## វណ្ណាសូត្រ

[ ៨៤ ] វណ្ណសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវណ្ណសូត្រទី ៣ ចប់

# សុត្តន្តបិដក

## កោធសូត្រទី ៤

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ជាអ្នកធ្ងន់ក្នុងព្រះ

សទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

## កោធសូត្រ

[ ៨៥ ] កោធសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាកោធសូត្រទី ៤ ចប់

# សុត្តន្តបិដក

## តមសូត្រទី ៥

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលងងឹត មានងងឹតទៅខាងមុខទៀត ១ បុគ្គលងងឹត មានពន្លឺទៅខាងមុខ ១ បុគ្គលភ្លឺ មានងងឹតទៅខាងមុខវិញ ១ បុគ្គលភ្លឺ មានពន្លឺទៅខាងមុខទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងងឹត មានងងឹតទៅខាងមុខទៀត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុង លោកនេះ កើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល

ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកនេសាទ ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកបោចសំរាម ឬត្រកូលកម្សត់ ដែលមានបាយ ទឹក និងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ដែលជាត្រកូលរកអាហារសម្រាប់បរិភោគ និងសំពត់សម្រាប់បិទបាំងបានដោយក្រជាបក្រដួស ។ បុគ្គលនោះ ជាអ្នកមានសម្បុរអាក្រក់ មានរូបឆោមអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ងែង ខ្វក់ ខ្វិន ជាអ្នកមិនសូវបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ។ បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុង អបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងងឹត មានងងឹតទៅខាងមុខទៀត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងងឹត តែមានពន្លឺទៅខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកនេសាទ ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកបោចសំរាម ឬត្រកូលកម្សត់ ដែលមានបាយ ទឹក និងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ជាត្រកូលរកអាហារសម្រាប់បរិភោគ និងសំពត់សម្រាប់បិទបាំងបានដោយក្រជាបក្រដួស ។ បុគ្គលនោះ ជាអ្នកមានសម្បុរ

អាក្រក់ មានរូបឆោមអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ញែង ខ្វក ឬខ្វិន ជាអ្នកមិនសូវបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងងឹតតែមានពន្លឺទៅខាងមុខ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលភ្លឺតែមានងងឹតទៅខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល និងត្រកូលគហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានមាស ប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានស្រូវជាទ្រព្យច្រើន បុគ្គលនោះរមែងមានរូបល្អ គួរពិតពិលរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយរូបឆោមល្អក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីបជាប្រក្រតី ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត

ដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលភ្លឺ តែមានងងឹតទៅខាងមុខ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលភ្លឺ មានពន្លឺទៅខាងមុខទៀត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល និងត្រកូលគហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានស្រូវជាទ្រព្យច្រើន បុគ្គលនោះជាអ្នកមានរូបល្អ គួរពិតពិលរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយរូបឆោមល្អក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូបគ្រឿងលាបផ្សេងៗ ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីបជាប្រក្រតី ។ បុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលភ្លឺ មានពន្លឺទៅខាងមុខទៀត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាដកក្នុងលោក ។

# អដ្ឋកថា

## តមសូត្រ

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតមសូត្រទី ៥ ដូចតទៅនេះ បុគ្គល ប្រកបដោយការងងឹត មានពាក្យជាដើមថា **នីចកុលេ បច្ចាជាតោ** ប្រែថា កើតក្នុងត្រកូលទាបដូច្នេះ ឈ្មោះថា **តម** គឺមកងងឹត ។ បុគ្គល ឈ្មោះថា ងងឹតទៅខាងមុខ ព្រោះចូលដល់ការងងឹត គឺនរកទៀត ដោយកាយទុច្ចរិត ជាដើម ដោយបទទាំង ២ ដូចពោល ឈ្មោះថា ត្រាស់ដល់ការងងឹត នៃ ខន្ធប៉ុណ្ណោះ ។ បុគ្គល ឈ្មោះថា មកភ្លឺ ព្រោះប្រកបដោយពន្លឺ មានពាក្យ ជាដើមថា **អឌ្ឍកុលេ បច្ចាជាតោ** គឺជាអ្នកកើតក្នុងត្រកូលស្តុកស្តម្ភ ។ អធិប្បាយថា ជាអ្នកភ្លឺ ដូច្នេះ ។ បុគ្គល ឈ្មោះថា មានពន្លឺទៅខាងមុខ ព្រោះចូលដល់នូវការភ្លឺ ដោយការចូលដល់ស្ថានសួគ៌ទៀត ដោយកាយ សុចរិតជាដើម ។ គប្បីជ្រាប ២ បទក្រៅអំពីនេះ ដោយន័យនេះ ។

បទថា **វេណកុលេ** បានដល់ ក្នុងត្រកូលជាងផែង ។ បទថា **នេសាទ-កុលេ** បានដល់ ក្នុងត្រកូលព្រានម្រឹគជាដើម ។ បទថា **រថការកុលេ** បាន ដល់ ក្នុងត្រកូលជាងស្បែក ។ បទថា **បុក្កុសកុលេ** បានដល់ ក្នុងត្រកូល អ្នកស៊ីឈ្នួលចាក់សំរាម ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងត្រកូលវិបត្តិ ដោយហេតុប្រមាណប៉ុណ្ណោះហើយ ព្រោះហេតុដែលបុគ្គលពួកខ្លះដល់នូវការ កើតក្នុងត្រកូលអ្នកស៊ីឈ្នួលចាក់សំរាម ក៏ស្តុកស្តម្ភ មានទ្រព្យច្រើនបាន តែបុគ្គលនេះ មិនមែនដូច្នោះឡើយ ដូច្នេះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងភោគ-

វិបត្តិរបស់បុគ្គលនោះ ទើបត្រាស់ថា **ទលិទ្ទេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ទលិទ្ទេ** បានដល់ ប្រកបដោយភាពក្រីក្រ មានបាយទឹក និងរបស់បរិភោគតិច ។ បទថា **កសិរវុត្តិកេ** បានដល់ ជាអ្នកនៅដោយសេចក្តីទុក្ខ ។ អធិប្បាយថា ឲ្យចូលដល់ត្រកូលដែលមនុស្សទាំងឡាយ ឲ្យគេត្រេកអរដោយសេចក្តីព្យាយាម ។ បទថា **យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ** សេចក្តីថា បុគ្គលនោះបានបបរ បាយ និងអាហារ ឬគ្រឿងស្លៀកដណ្តប់ល្មមតែបិទបាំងអវយវៈដោយសេចក្តីលំបាក ក្នុងត្រកូលណា ។

ព្រោះហេតុដែលបុគ្គលកើតក្នុងត្រកូលនេះ ជាអ្នកដល់ព្រមដោយឧបធិ-សម្បត្តិ តាំងនៅក្នុងសេចក្តីសម្រេចនៃអត្តភាព តែបុគ្គលនេះ មិនមែនដូច្នោះឡើយ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិបត្តិរាងកាយរបស់បុគ្គលនោះ ទើបត្រាស់ថា **សោ ច ហោតិ ទុព្វណ្ណោ** ជាដើម ។ ក្នុងបទទាំងនេះ បទថា **ទុព្វណ្ណោ** សេចក្តីថា ជាបុគ្គលមានពណ៌សម្បុរដូចជន្លត់ភ្លើងឆេះ ដូចបិសាចប្រឡាក់ធូលី ។ បទថា **ទុទ្ទសិកោ** សេចក្តីថា សូម្បីមាតាបង្កើតឃើញអ្នកនោះ ក៏មិនពេញចិត្ត ។ បទថា **ឱកោដិមកោ** បានដល់ ជាមនុស្សទាបតឿ ។ បទថា **កាណោ** បានដល់ ខ្វាក់ម្ខាងក្តី ខ្វាក់សងខាងក្តី ។ បទថា **កុណី** បានដល់ មានដៃពិការម្ខាងក្តី មានដៃពិការទាំងសងខាងក្តី ។ បទថា **ខញ្ជោ** បានដល់ មានជើងខ្វិកម្ខាងក្តី ខ្វិកទាំងសងខាងក្តី ។ បទថា **បក្ខហតោ** បានដល់ ខ្វិនមួយចំហៀងខ្លួន ។ បទថា **បទីបេយ្យស្ស** បាន

ដល់ គ្រឿងឧបករណ៍របស់ប្រទីប មានប្រេង និងភាជនៈជាដើម ។ ក្នុងបទថា **ឯវំ ខោ ភិក្ខវេ** នេះ បុគ្គលម្នាក់មិនទាន់ឃើញពន្លឺខាងក្រៅ ស្លាប់ក្នុងគភ៌របស់មាតា ហើយកើតក្នុងអបាយ អន្ទោលទៅមកអស់កប្ប បុគ្គលនោះ ក៏ឈ្មោះថា មកងងឹត ហើយមានងងឹតទៅខាងមុខ ។ បុគ្គលនោះគប្បីជាបុគ្គលបោកបញ្ឆោត អធិប្បាយថា ព្រោះថា បុគ្គលបោកបញ្ឆោត បានទទួលផលសម្រេចបែបនេះ ដូច្នេះ ។ ក្នុងបទទាំងនេះ ទ្រង់សម្តែងដល់វិបត្តិនៃការមកនិងបច្ច័យក្នុងបច្ចុប្បន្នវិបត្តិ ដោយបទថា **នីចេ កុលេ** ជាដើម ។ ទ្រង់សម្តែងបច្ច័យដែលប្រព្រឹត្តទៅហើយ វិបត្តិ ដោយបទថា **ទលិទ្ទេ** ជាដើម ។ ទ្រង់សម្តែងឧបាយចិញ្ចឹមជីវិតវិបត្តិ ដោយបទថា **កសិរវុត្តិកេ** ជាដើម ។ ទ្រង់សម្តែងអត្តភាពវិបត្តិ ដោយបទថា **ទុព្វណ្ណោ** ជាដើម ។ ទ្រង់សម្តែងហេតុនៃទុក្ខដែលបុគ្គលនោះត្រូវជួប ដោយបទថា **ពហ្វាពាធោ** ជាដើម ។ ទ្រង់សម្តែងហេតុនៃសុខវិបត្តិ និងគ្រឿងឧបភោគវិបត្តិ ដោយបទថា **ន លាភី** ជាដើម ។ ទ្រង់សម្តែងហេតុនៃភាពជាអ្នកងងឹតទៅខាងមុខ ដែលបុគ្គលនោះត្រូវជួប ដោយបទថា **កាយេន ទុច្ចរិតំ** ជាដើម ។ ទ្រង់សម្តែងការចូលដល់នូវភាពងងឹតក្នុងសម្បរាយភព ដោយបទថា **កាយស្ស ភេទា** ជាដើម ។ សុក្កបក្ខ គប្បីជ្រាបដោយន័យដែលផ្ទុយគ្នា តាមដែលពោលមកហើយ ។ល។

## អដ្ឋកថា តមសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ឱណតសូត្រទី ៦

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ គឺបុគ្គលទាបកាន់តែទាបទៅ ១ បុគ្គលទាប ត្រឡប់ទៅជាខ្ពស់វិញ ១ បុគ្គលខ្ពស់ ត្រឡប់មកជាទាបវិញ ១ បុគ្គលខ្ពស់ កាន់តែខ្ពស់ឡើង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាប កាន់តែទាបទៅ តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ បុគ្គលនោះ តែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាប កាន់តែទាបទៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាប ត្រឡប់ទៅជាខ្ពស់វិញ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាបត្រឡប់ជាខ្ពស់វិញ យ៉ាងនេះ

ឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ពស់ត្រឡប់មកជាទាបវិញ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ។បេ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំឡាយ បុគ្គលខ្ពស់ ត្រឡប់មកជាទាបវិញ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ពស់ កាន់តែខ្ពស់ឡើង តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយ-មហាសាល ។បេ។ បុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ពស់ កាន់តែខ្ពស់ឡើង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## ឱណាតសូត្រ

[ ៨៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឱណាតសូត្រទី ៦ ដូចតទៅនេះ បទថា **ឱណតោណតោ** សេចក្ដីថា បុគ្គលមកទាបក្នុងបច្ចុប្បន្ន និងទាបទៅក្នុងអនាគត ។ បទថា **ឱណតុណ្ណតោ** សេចក្ដីថា បុគ្គលមកទាបក្នុងបច្ចុប្បន្នទៅខ្ពស់ក្នុងអនាគត ។ បទថា **ឧណ្ណតោណតោ** សេចក្ដីថា បុគ្គលមកខ្ពស់ក្នុងបច្ចុប្បន្ន និងទៅទាបក្នុងអនាគត ។ បទថា **ឧណ្ណតុណ្ណតោ** សេចក្ដីថា បុគ្គលមកខ្ពស់ក្នុងបច្ចុប្បន្ន និងទៅខ្ពស់ក្នុងអនាគត ។ សេចក្ដីពិស្ដារនៃអត្ថទាំងនោះ គប្បីជ្រាបដោយន័យដែលបានពោលមកហើយ ។

**អដ្ឋកថា ឱណាតសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បុត្តសូត្រទី ៧

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ គឺសមណៈមិនរំកើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំកើប តើដូច

ម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសេក្ខៈ អ្នកប្រតិបត្តិ ប្រាថ្នានូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចព្រះរាជបុត្រច្បងរបស់ខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារគួរនឹងអភិសេក តែមិនទាន់អភិសេកនៅឡើយ តែងដល់នូវសេចក្ដីមិនរំភើប ( ចំពោះការអភិសេក ) យ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាសេក្ខៈអ្នកប្រតិបត្តិប្រាថ្នានូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំភើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន តែមិនទាន់ពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទៀតផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុ

ទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយសុខ ក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើទាយកអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់បិណ្ឌបាតច្រើន បើគេមិនអង្វរទេ ក៏ឆាន់តិច បើទាយកអង្វរ ទើបប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរទេ ក៏ឆាន់តិច ។ បើភិក្ខុនោះ នៅជាមួយនឹងសព្រហ្មចារីបុគ្គលទាំងឡាយណា សព្រហ្មចារីបុគ្គលទាំងនោះ តែងប្រព្រឹត្តកិច្ចការច្រើនដោយកាយកម្ម ជាទីគាប់ចិត្តនៃភិក្ខុនោះ ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយវចីកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយមនោកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រគេននូវគ្រឿងបូជាច្រើន ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច ។ មួយទៀត វេទនាទាំងឡាយណា កើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីសន្និបាត គឺការកម្រើកប្រមាត់ ស្លេស្ម និងខ្យល់ប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីការផ្លាស់ប្តូរឥរិយាបថ មិនស្មើគ្នាក្តី កើតអំពីសេចក្តីព្យាយាម ( របស់អ្នកឯទៀត មានការចាប់ចងវាយ កាប់ជាដើម ) ក្តី កើតអំពីវិបាកនៃកម្មក្តី វេទនាទាំងអស់នោះ មិនកើតឡើងច្រើនដល់ភិក្ខុនោះៗ ជាអ្នកមានអាពាធតិច ជាអ្នកបានមិនបាច់ប្រាថ្នា បានមិនលំបាក បានមិនត្រដាបត្រដួស នូវ

ឈានទាំង ៤ ដែលកើតអំពីអធិចិត្ត ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន តែង ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមាន អាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ ចម្រើនដោយសុខ ក្នុងពួកសមណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកផងពោលសរសើរបុគ្គល ណាថាជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯង ថាជា សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ ថា តថាគត បើទាយកអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់បិណ្ឌបាតច្រើន បើគេមិនអង្វរទេ ក៏ ឆាន់តិច បើទាយកអង្វរ ទើបប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនបានអង្វរទេ ក៏ឆាន់តិច បើតថាគតនៅជាមួយនឹងភិក្ខុទាំងឡាយណា ភិក្ខុទាំងនោះ តែងប្រព្រឹត្តកិច្ចការច្រើន ដោយកាយកម្ម ជាទីគាប់ចិត្តនៃ តថាគត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយវចីកម្ម ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយ មនោកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រគេននូវគ្រឿងបូជា ច្រើន ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច ។ មួយទៀត វេទនាទាំង-

ឡាយណា កើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីសន្និបាត គឺការកម្រើកប្រមាត់ ស្លេស្ម និងខ្យល់ប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នាក្តី កើតអំពីសេចក្តីព្យាយាម ( របស់អ្នកឯទៀត មានការចាប់ចង វាយ កាប់ជាដើម ) ក្តី កើតអំពីវិបាកនៃកម្មក្តី វេទនាទាំងអស់នោះ មិនកើតឡើងច្រើនដល់តថាគតឡើយ តថាគតជាអ្នកមានអាពាធតិច ជាអ្នកបានមិនបាច់ប្រាថ្នា បានមិនលំបាក បានមិនត្រដាបត្រដួសនូវឈាន ៤ ដែលកើតអំពីអធិចិត្ត ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកផងពោលសរសើរបុគ្គលណាថាជាសមណៈចម្រើន ដោយសុខក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលគេពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯង ជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## បុត្តសូត្រ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុត្តសូត្រទី ៧ ដូចតទៅនេះ បទថា **សមណមចលោ** បានដល់ សមណៈមិនញាប់ញ័រ ។ ម អក្ខរៈ ធ្វើបទសន្ធិ គឺតនូវបទ ។ អធិប្បាយថា និច្ចលសមណៈ ។ ទ្រង់សំដែងព្រះសេក្ខៈ ៧ ពួក ដោយបទនេះ ។ ព្រះសេក្ខៈនោះ ឈ្មោះថា មិនញាប់ញ័រ ព្រោះលោកតាំងមាំដោយសទ្ធា ដែលជាមូលក្នុងព្រះសាសនា ។ បទថា **សមណបុណ្ឌរីកោ** បានដល់ សមណៈដូចឈូកស ។ ធម្មតាឈូកសកើតក្នុងស្រះ មានត្របក ៩៩ ត្របក ។ ទ្រង់សំដែងព្រះខីណាស្រពសុក្ខវិបស្សក ដែលបំពេញវិបស្សនាដោយបទនេះ ។ ព្រោះថា ព្រះខីណាស្រពសុក្ខវិបស្សកនោះ ឈ្មោះថា សមណៈដូចឈូកស ព្រោះលោកមានគុណមិនទាន់បរិបូណ៌ ដ្បិតឈាន និងអភិញ្ញាមិនមាន ។ បទថា **សមណបទុមោ** បានដល់ សមណៈដូចឈូកក្រហម ។ ធម្មតាឈូកក្រហមកើតក្នុងស្រះ មានត្របក ១០០ ទ្រង់សំដែងព្រះខីណាស្រព ដែលជាឧភតោភាគវិមុត្តិ ដោយបទនេះ ដ្បិតថា ព្រះខីណាស្រពដែលជាឧភតោភាគវិមុត្តិនោះ ឈ្មោះថា សមណៈដូចឈូកក្រហម ព្រោះលោកមានគុណបរិបូណ៌ ព្រោះមានឈាន និងអភិញ្ញា ។ បទថា **សមណេសុ សមណសុខុមាលោ** សេចក្ដីថា បណ្ដាសមណៈទាំងអស់នោះ សមណសុខុមាល ដែលជាអ្នកមានកាយ និងចិត្តទន់ភ្លន់ វៀរនូវសេចក្ដីទុក្ខផ្លូវកាយ និងផ្លូវចិត្ត ជាអ្នកមានសុខដោយ

ចំណែកមួយ ។ ទ្រង់សម្តែងព្រះអង្គ និងសមណសុខុមាលដូចគ្នានឹងព្រះអង្គ ដោយបទថា **សុខុមាលសមណោ** នោះ ។

កាលទ្រង់តាំងមាតិកាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ចែកទៅតាមលំដាប់ ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សេក្ខោ** បានដល់ ព្រះសេក្ខៈ ៧ ពួក ។ បទថា **បដិបន្នោ** បានដល់ ជាអ្នកនៅប្រតិបត្តិបន្ត ។ បទថា **អនុត្តរំ យោគក្ខេមំ បត្ថយ-មានោ វិហរតិ** សេចក្តីថា កំពុងប្រាថ្នាអរហត្ត ។ បទថា **មុទ្ធាភិសិត្តស្ស** សេចក្តីថា ជាអ្នកបានទទួលទឹកស្រោចលើព្រះសិរសា គឺជាក្សត្រដែលបានមុទ្ធាភិសេក អធិប្បាយថា ទ្រង់បានមុទ្ធាភិសេកហើយ ។ បទថា **អាភិ-សេកោ** បានដល់ ជាអ្នកគួរធ្វើការអភិសេក ។ បទថា **អនភិសិត្តោ** បានដល់ ជាអ្នកមិនបានអភិសេកមុន ។ បទថា **មចលប្បត្តោ** បានដល់ដល់នូវភាវៈដូចតំណែងព្រះយុវរាជ មានការប្រាថ្នាមាំទាំ មិនយ្វេងយ្វោង ដើម្បីជាប្រយោជន៍ដល់ការអភិសេក ព្រោះជាឱរសរបស់ព្រះរាជា ដែលជាក្សត្រមុទ្ធាភិសេក ។ ព្រោះជាជេដ្ឋោរស បណ្តាព្រះឱរសទាំងឡាយ និងព្រោះមិនទាន់បាន អភិសេកមុន ។ **ម** អក្ខរៈ ត្រឹមតែជានិបាត ។ បទថា **កាយេន ផុសិត្វា** សេចក្តីថា ពាល់ត្រូវហើយ ដោយនាមកាយ ។ បទថា **យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជតិ** សេចក្តីថា សមណសុខុមាលដោយច្រើន បរិភោគចីវរដែលទាយកបង្អោនចូលទៅថ្វាយ ដោយអង្វរយ៉ាង

នេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បរិភោគចីវរនេះ ដូច្នេះហើយ ចំពោះចីវរដែលគេមិនអង្វរក៏តិច ដូចព្រះពកុលត្ថេរ ចំពោះបិណ្ឌបាត ដូចព្រះសីវលិត្ថេរ តាមផ្លូវទៅកាន់ព្រៃគិរី ដូច្នោះ ចំពោះសេនាសនៈ ដូចព្រះអានន្ទត្ថេរ ក្នុងអដ្ឋកនាគសូត្រ ចំពោះគិលានប្បច្ច័យ ដូចព្រះបិលិន្ទ-វច្ឆត្ថេរ ។ បទថា **ត្យស្ស** កាត់បទជា **តេ អស្ស** ។ បទថា **មនាបេនេវ** បានដល់ ដែលជាទីត្រូវចិត្ត ។ បទថា **សមុទាចរន្តិ** សេចក្តីថា ធ្វើ ឬប្រព្រឹត្តកិច្ចដែលគួរធ្វើ ។ បទថា **ឧបហារំ ឧបហរន្តិ** សេចក្តីថា មិត្ត-ព្រហ្មចារីទាំងឡាយ រមែងនាំចូលទៅ គឺបង្អោនចូលទៅនូវវត្ថុដែលពេញចិត្តតាមផ្លូវកាយ និងចិត្ត ។ បទថា **សន្និបាតិកានិ** សេចក្តីថា ដែលកើតព្រោះការប្រជុំគ្នានៃសមុដ្ឋានទាំង ៣ ។ បទថា **ឧតុបរិណាមជានិ** សេចក្តីថា កើតអំពីការផ្លាស់ប្តូរនៃឧតុ គឺអំពីឧតុដែលរងាពេក ឬក្តៅពេក ។ បទថា **វិសមបរិហារជានិ** សេចក្តីថា កើតអំពីការបរិហារមិនស្មើ មានអង្គុយយូរ ឬឈរយូរជាដើម ។ បទថា **ឱបក្កមិកានិ** សេចក្តីថា កើតព្រោះត្រូវប្រទូស្ត មានការសម្លាប់ និងការចងជាដើម ។ បទថា **កម្មវិបាកជានិ** សេចក្តីថា កើតដោយអំណាចនៃវិបាករបស់កម្មដែលធ្វើហើយ ក្នុងកាលមុននោះឯង ។ សូម្បីវៀរចាកហេតុទាំងនេះ ក្នុងបទថា **ចតុន្នំ ឈានានំ** នេះ លោកបំណងយកកិរិយាឈានប៉ុណ្ណោះ ។ របស់ព្រះខីណាស្រពផង របស់ព្រះពុទ្ធទាំងឡាយផង ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថាបុត្តសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សំយោជនសូត្រទី ៨

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ គឺសមណៈមិនរំភើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំភើប តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសោតាបន្នបុគ្គល មិនបានធ្លាក់ចុះក្នុងអបាយជាធម្មតា ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំភើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសកទាគាមិបុគ្គល ព្រោះអស់សញ្ញោជនៈ ៣ ទាំងមានរាគៈ ទោសៈ មោហៈស្រាលស្តើង មកកាន់លោកនេះម្ដងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកកំណើត រលត់កិលេសក្នុងទីនោះ មិនបានត្រឡប់ចាកលោកនោះមកវិញទេ ព្រោះអស់ឱរម្ភាគិយ-សញ្ញោជនៈទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយ

សុខក្នុងពួកសមណៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## សំយោជនសូត្រ

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំយោជនសូត្រទី ៨ ដូចតទៅនេះ ព្រះសោតាបន្ន ហៅថា សមណៈមិនញាប់ញ័រ ព្រោះបាននូវសទ្ធា តាំងមាំហើយក្នុងព្រះសាសនា ។ ព្រះសកទាគាមី ហៅថា សមណៈដូចឈូកស ប្រៀបដូចឈូកសកើតក្នុងស្រះ មានស្រទាប់មិនច្រើន ព្រោះលោកជាបុគ្គលមានគុណមិនច្រើន ។ ព្រះអនាគាមី ហៅថា សមណៈឈូកក្រហម ប្រៀបដូចឈូកក្រហម មានស្រទាប់ ១០០ កើតក្នុងស្រះ ព្រោះលោកមានគុណច្រើនជាងនោះ ។ ព្រះខីណាស្រពដល់នូវការទន់ភ្លន់ ហៅថា សមណៈសុខុមាល ព្រោះកិលេសដែលធ្វើនូវការរឹងត្អឹង លោកដកបានហើយ ដោយ

ប្រការទាំងពួង ។

### អដ្ឋកថា សំយោជនសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ទិដ្ឋិសូត្រទី ៩

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺសមណៈមិនរំកើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំកើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីយល់ឃើញត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានព្យាយាមត្រូវ មានស្មារតីត្រូវ មានការតម្កល់ចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំកើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីយល់ត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានព្យាយាមត្រូវ

មានស្មារតីត្រូវ មានការតម្កល់ចិត្តត្រូវ មានការដឹងត្រូវ មានការរួចចាកកិលេសត្រូវ តែមិនទាន់បានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្ដីយល់ត្រូវ ។បេ។ មានការដឹងត្រូវ មានការរួចចាកកិលេសត្រូវ ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកផង កាលបើពោលសរសើរបុគ្គលណាថាជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផង ដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯងថាជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាតថាគត បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។បេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

# ទិដ្ឋិសូត្រ

[ ៩០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិសូត្រទី ៩ ដូចតទៅនេះ ដោយបទជាដើមថា **សម្មាទិដ្ឋិកោ** ទ្រង់សំដៅដល់ព្រះសេក្ខៈ ៧ ពួក ដូចក្នុងសូត្រដំបូង ដោយអំណាចមគ្គមានអង្គ ៨ ។ វារៈទី ២ ទ្រង់ត្រាស់ព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលបំពេញវិបស្សនាសុទ្ធ មួយអន្លើដោយអរហត្តផលញ្ញាណ និងអរហត្តផលវិមុត្តិ ដោយអំណាចនៃមគ្គមានអង្គ ១០ ឬដោយអំណាចនៃមគ្គមានអង្គ ៨ ។ ក្នុងវារៈទី ៣ ត្រាស់ព្រះខីណាស្រពដែលជាឧភតោភាគវិមុត្តិ ។ វារៈទី ៤ ត្រាស់ដល់ព្រះតថាគត និងព្រះខីណាស្រពដូចគ្នា និងព្រះតថាគតយ៉ាងនេះ ។ ដូច្នោះ ព្រះសូត្រនេះត្រាស់ដោយអំណាចបុគ្គលដែលពោលក្នុងសូត្រដំបូង តែក្នុងព្រះសូត្រនេះផ្សេងគ្នា ត្រឹមតែទេសនាប៉ុណ្ណោះ ៕

**អដ្ឋកថា ទិដ្ឋិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ខគ្គសូត្រទី ១០

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺសមណៈមិនរំកើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំកើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសេក្ខបុគ្គល ជាអ្នកមានសេចក្តីប្រាថ្នាក្នុងចិត្ត មិនទាន់បានសម្រេច រមែងប្រាថ្នានូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ គឺព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំកើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងពិចារណាឃើញនូវការកើតឡើង និងការវិនាសទៅវិញ ក្នុងឧបាទានក្ខន្ធ ៥ ថា រូបដូច្នេះ ហេតុជាទីកើតនៃរូបដូច្នេះ ការវិនាសទៅនៃរូបដូច្នេះ វេទនាដូច្នេះ ... សញ្ញាដូច្នេះ ... សង្ខារដូច្នេះ ... វិញ្ញាណដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណដូច្នេះ ការវិនាសទៅនៃវិញ្ញាណដូច្នេះ តែមិនបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងពិចារណានូវការកើត និងការវិនាសទៅក្នុងឧបាទានក្ខន្ធ ៥ ថា រូបដូច្នេះ ហេតុជាទីកើតនៃរូបដូច្នេះ ការ

រលត់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ... សញ្ញាដូច្នេះ ... សង្ខារដូច្នេះ ... វិញ្ញាណដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណដូច្នេះ ការរលត់នៃវិញ្ញាណដូច្នេះ ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកផងពោលសរសើរបុគ្គលណាថាជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផង ដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯងថាជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាតថាគត បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់ចីវរតិច ។បេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

**មចលវគ្គទី ៤ ចប់**

## ឧទ្ទាននៃមចលវគ្គនោះ គឺ

និយាយអំពីបាណាតិបាតជាដើម ១ អំពីមុសាវាទជាដើម ១
អំពីបុគ្គលពោលសរសើរគុណ ១ អំពីបុគ្គលផ្ងន់ក្នុងសេចក្តី
ក្រោធ ១ អំពីបុគ្គលងងឹត ១ អំពីបុគ្គលទាប ១ អំពី

សេក្ខភិក្ខុប្រៀបដោយព្រះរាជបុត្រ ១ អំពីសញ្ញោជនៈ ១ អំពីភិក្ខុជាអ្នកយល់ត្រូវជាដើម ១ អំពីភិក្ខុជាអ្នកពិចារណាក្នុងឧបាទានក្ខន្ធ ១ រួមទាំងអស់នោះត្រូវជា ១០ ។

# អដ្ឋកថា

## ខន្ធសូត្រ

[ ៩១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខន្ធសូត្រទី ១០ ដូចតទៅនេះ វារៈទី ១ ត្រាស់ព្រះសេក្ខបុគ្គល ដែលមិនទាន់ផ្ដើមសេចក្ដីព្យាយាម ដើម្បីអរហត្តតាំងនៅដោយសេចក្ដីប្រមាទ ។ វារៈទី ២ ត្រាស់ព្រះសេក្ខបុគ្គលដែលមិនទាន់បានឈាន តែផ្ដើមវិបស្សនាដោយមិនប្រមាទ ។ វារៈទី ៣ ត្រាស់ព្រះសេក្ខបុគ្គល ដែលផ្ដើមវិបស្សនាដោយការមិនប្រមាទ បានវិមោក្ខ ៨ ។ វារៈទី ៤ ត្រាស់ព្រះខីណាស្រពដែលជាសុខុមាលដ៏ក្រៃលែង ៕

**អដ្ឋកថា ខន្ធសូត្រទី ១០ ចប់**

**មចលវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## អសុរវគ្គ

### អសុរសូត្រទី ១

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺអសុរមានអសុរជាបរិវារ ១ អសុរមានទេវតាជាបរិវារ ១ ទេវតាមានអសុរជាបរិវារ ១ ទេវតាមានទេវតាជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអសុរមានអសុរជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ទាំងបរិស័ទនៃបុគ្គលនោះ ក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសុរ មានអសុរជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអសុរ មានទេវតាជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ប៉ុន្តែឯបរិស័ទនៃបុគ្គលនោះ ជាអ្នកមានសីល មានធម៌ល្អ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសុរមានទេវតាជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាទេវតា មានអសុរជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ប៉ុន្តែបរិស័ទនៃបុគ្គលនោះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាទេវតាមានអសុរជាបរិវារ

យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាទេវតា មានទេវតាជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិស័ទនៃបុគ្គលនោះ ក៏ជាអ្នកមានសីលមានធម៌ល្អដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាទេវតា មានទេវតាជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

# អសុរវគ្គទី ៥

## អសុរសូត្រ

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសុរសូត្រទី ១ នៃអសុរវគ្គទី ៥ ដូចតទៅនេះ បទថា **អសុរោ** បានដល់ បុគ្គលគួរខ្ពើម ដូចគ្នានឹងអសុរ ។ បទថា **ទេវោ** បានដល់ បុគ្គលស្អាតដោយគុណដែលធ្វើឲ្យកើតសេចក្ដីផូរផង់ ដូចគ្នានឹងទេវតា ។ល។

អដ្ឋកថា អសុរសូត្រទី ១ ចប់

# សុត្តន្តបិដក

## បឋមសមាធិសូត្រទី ២

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈខាងក្នុងសន្ដាន មិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្ដាន ១

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានទូវចេតោសមថៈ ខាងក្នុងសន្តានផង មិនបានទូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានទូវចេតោសមថៈខាងក្នុង សន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## បឋមសមាធិសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសមាធិសូត្រទី ២ ដូចតទៅនេះ បទថា **អជ្ឈត្តំ ចេតោសមថស្ស** បានដល់ អប្បនាចិត្តសមាធិខាងក្នុងរបស់ខ្លួន ។ បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** សេចក្តីថា វិបស្សនាញាណ ដែលកំណត់សង្ខារជាអារម្មណ៍ ។ ដែលពិត វិបស្សនាញាណនោះ រាប់ថាជា អធិប្បញ្ញា និងជាវិបស្សនាក្នុងធម៌ទាំងឡាយ ពោល គឺបញ្ចក្ខន្ធ ព្រោះដូច្នោះ ទើបត្រាស់ថា **អធិប្បញ្ញាធម្មវិបស្សនា** ។

**អដ្ឋកថា បឋមសមាធិសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទុតិយសមាធិសូត្រទី ៣

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្តាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាននូវចេតោសមថៈខាងក្នុងសន្តានផង មិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាដែលបាននូវចេតោសមថៈខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនាទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅក្នុងចេតោសមថៈខាងក្នុងសន្តាន ហើយធ្វើសេចក្តីព្យាយាម ក្នុងអធិប្បញ្ញាធម្មវិបស្សនា លុះសម័យខាងក្រោយមក បុគ្គលនោះរមែងបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្តានទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះគប្បីតាំងនៅក្នុង

អធិប្បញ្ញាធម្មវិបស្សនា ហើយធ្វើសេចក្តីព្យាយាម ក្នុងចេតោសមថៈខាងក្នុងសន្តាន លុះសម័យខាងក្រោយមក បុគ្គលនោះ រមែងបាននូវអធិប្បញ្ញាធម្មវិបស្សនាផង បាននូវចេតោសមថៈខាងក្នុងសន្តានផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនបាននូវចេតោសមថៈខាងក្នុងសន្តានផង មិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីធ្វើសេចក្តីប៉ុនប៉ង សេចក្តីព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង សេចក្តីមិនរួញរា សតិ និងសម្បជញ្ញៈដ៏ក្រៃលែង ដើម្បីឲ្យបានសម្រេចនូវកុសលធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលមានភ្លើងឆេះសំពត់ ឬមានភ្លើងឆេះក្បាល គប្បីធ្វើសេចក្តីប៉ុនប៉ង សេចក្តីព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង សេចក្តីមិនរួញរា សតិ និងសម្បជញ្ញៈដ៏ក្រៃលែង ដើម្បីលត់នូវសំពត់ ឬក្បាលនោះៗ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីធ្វើសេចក្តីប៉ុនប៉ង សេចក្តីព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង សេចក្តីមិនរួញរា សតិ និងសម្បជញ្ញៈដ៏ក្រៃលែង ដើម្បីឲ្យបានសម្រេចនូវកុសលធម៌ទាំងនោះ ក៏ដូច្នោះដែរ លុះសម័យខាងក្រោយមក បុគ្គលនោះរមែងបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គល ៤ ពួកនោះ បុគ្គលណាបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះគប្បីតាំងនៅ

ស៊ប់ក្នុងកុសលធម៌ទាំងនោះ ហើយធ្វើសេចក្ដីព្យាយាម ដើម្បីឲ្យអស់ទៅនៃអាសវៈតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## ទុតិយសមាធិសូត្រ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសមាធិសូត្រទី ៣ ដូចតទៅនេះ បទថា **យោគោ ករណីយោ** សេចក្ដីថា គប្បីធ្វើការប្រកបនូវសេចក្ដីខ្វល់ខ្វាយ ។ បទថា **ឆន្ទោ** គឺកត្តុកម្យតាឆន្ទៈ គឺការពេញចិត្តប្រាថ្នានឹងធ្វើ ។ បទថា **វាយាមោ** គឺសេចក្ដីព្យាយាម ។ បទថា **ឧស្សាហោ** គឺសេចក្ដីព្យាយាមជាងព្យាយាមនោះ ។ បទថា **ឧស្សោឡ្ហី** សេចក្ដីថា សេចក្ដីព្យាយាមច្រើន ដូចលើករទេះដែលជាប់ភក់ ។ បទថា **អប្បដិវានី** មិនថយក្រោយ ៕

**អដ្ឋកថា ទុតិយសមាធិសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## តតិយសមាធិសូត្រទី ៤

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្តាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាននូវចេតោសមថៈខាងក្នុងសន្តាន ទាំងមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវចេតោសមថៈខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីចូលទៅរកបុគ្គលដែលបាននូវអធិប្បញ្ញាធម្មវិបស្សនា ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ សង្ខារទាំងឡាយ គេត្រូវឃើញដូចម្តេច សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងណា សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់ដោយហេតុដូចម្តេច ។ ភិក្ខុនោះក៏ដោះស្រាយតាមដែលខ្លួនធ្លាប់យល់ តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ សង្ខារទាំងឡាយ គេត្រូវឃើញយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងនេះ សង្ខារទាំងឡាយ

គេត្រូវឃើញច្បាស់យ៉ាងនេះ ឯភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្តាន ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីចូលទៅរកបុគ្គលដែលបាននូវចេតោសមថៈខាងក្នុងសន្តាន ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់ដូចម្តេច ចិត្តគេត្រូវពត់ដូចម្តេច ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកដូចម្តេច ចិត្តគេត្រូវតាំងឲ្យនឹងធឹងដូចម្តេច ។ ភិក្ខុនោះក៏ដោះស្រាយតាមដែលខ្លួនធ្លាប់យល់ តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់យ៉ាងនេះ ចិត្តគេត្រូវពត់យ៉ាងនេះ ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកយ៉ាងនេះ ចិត្តគេត្រូវតាំងឲ្យនឹងធឹងយ៉ាងនេះ ឯភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវអធិប្បញ្ញាធម្មវិបស្សនាផង បាននូវចេតោ-សមថៈខាងក្នុងសន្តានផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនបាននូវចេតោសមថៈខាងក្នុងសន្តានផង ទាំងមិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីចូលទៅរកបុគ្គលដែលបាននូវចេតោសមថៈខាងក្នុងសន្តាន ទាំងបាននូវអធិប្ប-ញ្ញាធម្មវិបស្សនា ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់ដូចម្តេច ចិត្តគេត្រូវពត់ដូចម្តេច ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកដូច

ម្ដេច ចិត្តគេត្រូវតាំងឲ្យនឹងធឹងដូចម្ដេច សង្ខារទាំងឡាយ គេត្រូវឃើញដូចម្ដេច សង្ខារទាំងឡាយ គេត្រូវពិចារណាដូចម្ដេច សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់ដូចម្ដេច ។ ភិក្ខុនោះក៏ដោះស្រាយតាមដែលខ្លួនធ្លាប់យល់ តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់យ៉ាងនេះ ចិត្តគេត្រូវពត់យ៉ាងនេះ ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកយ៉ាងនេះ ចិត្តគេត្រូវតាំងឲ្យនឹងធឹងយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវឃើញយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់យ៉ាងនេះ ភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវចេតោសមថៈខាងក្នុងសន្ដានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវចេតោសមថៈខាងក្នុងសន្ដានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅក្នុងធម៌ជាកុសលទាំងនោះ ហើយធ្វើសេចក្ដីព្យាយាម ដើម្បីឲ្យអស់អាសវៈតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## តតិយសមាធិសូត្រ

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយសមាធិសូត្រទី ៤ ដូចតទៅនេះ បទថា **ឯវំ ខោ អាវុសោ សង្ខារា ទដ្ឋព្វា** ជាដើម គប្បីឃើញអត្ថយ៉ាងនេះថា អាវុសោទាំងឡាយ ធម្មតាសង្ខារទាំងឡាយគប្បីពិចារណាដោយភាពជារបស់មិនទៀង គប្បីកំណត់ដោយការមិនទៀង គប្បីឃើញច្បាស់ដោយការមិនទៀង ដោយភាពជាទុក្ខ ដោយភាពជាអនត្តាក៏យ៉ាងនោះ ដូច្នេះ ។ ក្នុងបទថា **ឯវំ ខោ អាវុសោ ចិត្តំ សណ្ឋាបេតព្វំ** ជាដើម គប្បីឃើញអត្ថយ៉ាងនេះថា អាវុសោទាំងឡាយ ចិត្តគប្បីតាំងនៅបានដោយអំណាចបឋមជ្ឈាន គប្បីបង្អោនចិត្តទៅដោយអំណាចបឋមជ្ឈាន គប្បីធ្វើអារម្មណ៍ឲ្យជាឯកគ្គតាដោយអំណាចបឋមជ្ឈាន គប្បីឲ្យជាសមាធិដោយបឋមជ្ឈាន ចិត្តគប្បីតាំងនៅបានដោយអំណាចទុតិយជ្ឈានជាដើម ក៏យ៉ាងនេះ ដូច្នេះ ។ ក្នុងព្រះសូត្រទាំង ៣ នេះ ទ្រង់ត្រាស់សមថៈ និងវិបស្សនាជាលោកិយ និងលោកុត្តរតែម្យ៉ាង ៕

**អដ្ឋកថា តតិយសមាធិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ឆវាលាតសូត្រទី ៥

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអង្កត់ឧសដុតខ្មោច ដែលភ្លើងឆេះរន្ទាលទាំងសងខាង មានលាមកប្រឡាក់ត្រង់កណ្តាល រមែងមិនសម្រេចជាឧសក្នុងស្រុកបាន ទាំងមិនសម្រេចជាឧសក្នុងព្រៃបាន មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាជាអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន បណ្តាបុគ្គលទាំងពីរនេះ បុគ្គលនេះចាត់ថា ល្អជាង ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ បណ្តាបុគ្គលទាំងបីនេះ បុគ្គលនេះចាត់ថាល្អជាង ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ បណ្តា

*បុគ្គលទាំង ៤ ពួកនោះ បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះចាត់ថាជាអ្នកលើសលុប ជាចម្បង ជាប្រធាន ឧត្តម ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចទឹកដោះស្រស់ចេញមកអំពីមេគោ ទឹកដោះជូរក្លាយមកអំពីទឹកដោះស្រស់ ទឹកដោះខាប់ក្លាយមកអំពីទឹកដោះជូរ ទឹកដោះថ្លាក្លាយមកអំពីទឹកដោះខាប់ ជុំនៃទឹកដោះថ្លាក្លាយមកអំពីទឹកដោះថ្លា បណ្តាទឹកដោះទាំងនោះ ជុំនៃទឹកដោះថ្លា ប្រាកដជាប្រសើរជាង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះ ចាត់ថាជាអ្នកលើសលុប ជាចម្បង ជាប្រធាន ឧត្តម ប្រសើរយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាន នៅក្នុងលោក ។*

# អដ្ឋកថា

## ឆវាលាតសូត្រ

*[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឆវាលាតសូត្រទី ៥ ដូចតទៅនេះ បទថា* **ឆវាលាតំ** *បានដល់ ឧសដែលដុតសពក្នុងព្រៃខ្មោច ។ បទថា* **មជ្ឈេ-គូថគតំ** *បានដល់ ត្រង់កណ្តាល ក៏ប្រឡាក់លាមក ។ បទថា* **នេវ គាមេ**

**កដ្ឋត្ថំ ផរតិ** សេចក្ដីថា មិនសម្រេចប្រយោជន៍ដែលជាគ្រឿងឈើក្នុងផ្ទះ ព្រោះមិនគួរនាំចូលទៅដើម្បីជាប្រយោជន៍ដល់ទព្វសម្ភារៈ មានធ្នឹម បង្គន់ ដំបូល សសរ និងជណ្ដើរជាដើម មិនសម្រេចប្រយោជន៍ ដែលប្រើជាគ្រឿងឈើក្នុងព្រៃ ព្រោះមិនគួរនាំចូលទៅធ្វើទ្រនល់ខ្ទមក្នុងស្រែ ឬជើងគ្រែ កាលចាប់ត្រង់ចុង ២ ក៏រមែងធេះដៃ ចាប់ត្រង់កណ្ដាលក៏ប្រឡាក់លាមក ។ បទថា **តថូបមំ** សេចក្ដីថា បុគ្គលនោះក៏សមគ្នា ។ បទថា **អភិក្កន្តតរោ** គឺល្អជាង ។ បទថា **បណីតតរោ** គឺឧត្តមជាង ។ បទថា **គវា ខីរំ** បាន ដល់ ទឹកដោះដែលកើតអំពីមេគោ ។ បទថា **ខីរម្ហា ទធិ** ជាដើម សេចក្ដីថា តែរបស់ទីមួយៗ ប្រសើរជាងមុនៗ ។ ចំណែកសប្បិមណ្ឌជាកំពូលក្នុងទឹកដោះជាដើមនោះ ។ ក្នុងបទថា **អគ្គោ** ជាដើម គប្បីជ្រាបថា ជាបុគ្គលប្រសើរលើស ជាប្រមុខ ដ៏ឧត្តមដោយគុណទាំងឡាយ ។ បុគ្គលដែលទ្រុស្តសីល ត្រាស់ប្រៀបដូចខសដែលដុតសព តែគប្បីជ្រាបថា ត្រាស់បុគ្គលដែលមានសុតៈតិច និងលះការងារប្រៀបដូចគោ ដូច្នេះ ៕

## អដ្ឋកថា ឆវាលាតសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ភាគស្វ្រទី ៦

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួន តែមិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់រាគៈ ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួន តែមិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់ទោសៈ ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួន មិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនប្រតិបត្តិដើម្បីកម្ចាត់រាគៈចំពោះខ្លួន

តែបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់រាគៈ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួន តែបបួលបុគ្គលដទៃ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់ទោសៈ មិនប្រតិបត្តិដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួន តែបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនប្រតិបត្តិដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួន ទាំងមិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់រាគៈ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួន ទាំងមិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់ទោសៈ ជាអ្នកមិនប្រតិបត្តិដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួន ទាំងមិនបបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួនផង បបួលអ្នកដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់រាគៈផង ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួនផង បបួលអ្នកដទៃ ( ឲ្យ

ប្រតិបត្តិ ) ដើម្បីកម្ចាត់បង់ទោសៈផង ជាអ្នកប្រតិបត្តិដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួនផង បបួលបុគ្គលដទៃ ( ឲ្យប្រតិបត្តិ ) ដើម្បីកម្ចាត់បង់មោហៈផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## រាគសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងរាគសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថារាគសូត្រទី ៦ ចប់

# សុត្តន្តបិដក

## និសន្តិសូត្រទី ៧

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បី

ប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ អាចដឹងឆាប់ក្នុងកុសលធម៌ទាំងឡាយ ជាអ្នកចងចាំនូវធម៌ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យមិនពីរោះ មិនបញ្ចេញនូវពាក្យដែលពីរោះ មិនប្រកបដោយពាក្យអ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យដែលប្រាសចាកសេចក្តីវង្វេស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអាចដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយផង ជាអ្នកមិនចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកមិនត្រិះរិះសេចក្តីនៃធម៌ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា

មិនដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយពាក្យអ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំង-ឡាយ ដោយពាក្យដែលប្រាសចាកសេចក្ដីរង្កៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្ដី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអាចដឹងឆាប់ក្នុងកុសលធម៌ផង ជាអ្នកមិនអាចចងចាំនូវធម៌ដែលខ្លួនបានស្ដាប់មកផង ជាអ្នកមិនត្រិះរិះនូវសេចក្ដីនៃធម៌ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា មិនដឹងនូវបាលី ហើយមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងជាអ្នកមិនមានពាក្យពីរោះ មិនបញ្ចេញនូវពាក្យពីរោះ មិនប្រកបដោយពាក្យរបស់អ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំង-ឡាយ ដោយពាក្យប្រាសចាកសេចក្ដីរង្កៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្ដី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បី

ប្រយោជន៍អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអាចដឹងឆាប់ក្នុងកុសលធម៌ផង ជាអ្នកចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយពាក្យរបស់អ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យប្រាសចាកសេចក្តីរង្កៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## និសន្តិសូត្រ

[ ៩៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិសន្តិសូត្រទី ៧ ដូចតទៅនេះ បទថា **ខិប្បនិសន្តិ** សេចក្តីថា បុគ្គលតាំងចិត្តស្តាប់ អាចដឹងបានរហ័ស ។ បទថា **ធតានញ្ច ធម្មានំ** សេចក្តីថា ធម៌ដែលជាបាលីមានបែបផែន ទ្រទ្រង់ចាំបានស្ទាត់ជំនាញហើយ ។ បទថា **អត្ថុបបរិក្ខី** សេចក្តីថា ជាបុគ្គល

ពិចារណាអត្ថ ។ បទថា **អត្ថមញ្ញាយ ធម្មមញ្ញាយ** សេចក្តីថា ដឹងដល់អដ្ឋកថា និងបាលី ។ បទថា **ធម្មានុធម្មប្បដិបន្នោ ហោតិ** សេចក្តីថា ជាអ្នកបដិបត្តិបដិបទាដែលជាចំណែកខាងដើម មួយអន្លើដោយសីល ជាធម៌ដែលសមគួរដល់លោកុត្តរធម៌ ៩ ។ បទថា **នោ ច កល្យាណវាចោ ហោតិ** សេចក្តីថា តែជាអ្នកពោលមិនល្អ ។ បទថា **ន កល្យាណវាក្ករណោ** សេចក្តីថា ជាអ្នកមានសំឡេងមិនពីរោះ ។ **នោ** អក្ខរៈ គួរប្រកបជាមួយបទថា **ចោរិយា** ជាដើម សេចក្តីថា មិនជាអ្នកប្រកបដោយវាចា ដែលអាចចន្លុលបង្ហាញឲ្យបុគ្គលយល់អត្ថ ដោយបទ និងព្យញ្ជនៈ ដែលមិនបាននៅក្នុង-ក ពេញដោយគុណ មិនត្រដិត មិនមានទោស ។ បទទាំងពួង គប្បីជ្រាបអត្ថដោយឧបាយនេះ ។ល។

**អដ្ឋកថា និសន្តិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អត្តហិតសូត្រទី ៨

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បី

ប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមានទៅក្នុងលោក ។

# អដ្ឋកថា

## អត្តហិតសូត្រ

[ ៩៩ ] អត្តហិតសូត្រទី ៨ ត្រាស់ដោយអំណាចអធ្យាស្រ័យនៃបុគ្គលខ្លះ ដោយការស្អាតនៃទេសនាញាណរបស់ព្រះទសពលខ្លះ ។

**អដ្ឋកថា អត្តហិតសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សិក្ខាសូត្រទី ៩

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ តើដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍

ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតចំពោះខ្លួន តែមិនបបួលអ្នកដទៃឲ្យវៀរចាកបាណាតិបាត ជាអ្នកវៀរចាកអទិន្នាទានចំពោះខ្លួន តែមិនបបួលអ្នកដទៃឲ្យវៀរចាកអទិន្នាទាន ជាអ្នកវៀរចាកកាមេសុមិច្ឆាចារចំពោះខ្លួន តែមិនបបួលអ្នកដទៃឲ្យវៀរចាកកាមេសុមិច្ឆាចារ ជាអ្នកវៀរចាកមុសាវាទចំពោះខ្លួន តែមិនបបួលអ្នកដទៃឲ្យវៀរចាកមុសាវាទ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យចំពោះខ្លួន តែមិនបបួលអ្នកដទៃឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនវៀរចាកបាណាតិបាតចំពោះខ្លួន តែបបួលអ្នក

ដទៃឲ្យវៀរចាកបាណាតិបាត ។បេ។ ជាអ្នកមិនវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យចំពោះខ្លួន តែបបួលអ្នកដទៃឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនវៀរចាកបាណាតិបាតចំពោះខ្លួន ទាំងមិនបបួលអ្នកដទៃឲ្យវៀរចាកបាណាតិបាត ។បេ។ ជាអ្នកមិនវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យចំពោះខ្លួន ទាំងមិនបបួលអ្នកដទៃឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតចំពោះខ្លួនផង បបួលអ្នកដទៃឲ្យវៀរចាកបាណាតិបាតផង វៀរចាកអទិន្នាទានចំពោះខ្លួនផង បបួលអ្នកដទៃឲ្យវៀរចាកអទិន្នាទានផង វៀរចាកកាមេសុមិច្ឆាចារចំពោះខ្លួនផង បបួល

បុគ្គលដទៃឲ្យវៀរចាកកាមេសុមិច្ឆាចារផង វៀរចាកមុសាវាទចំពោះខ្លួនផង បបួល បុគ្គលដទៃឲ្យវៀរចាកមុសាវាទផង វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យចំពោះខ្លួនផង បបួលអ្នកដទៃឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## សិក្ខាសូត្រ

[ ១០០ ] សិក្ខាសូត្រទី ៩ ត្រាស់ដោយអំណាចបពា្ចវេក ។

### អដ្ឋកថា សិក្ខាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ពោតលិយសូត្រទី ១០

[ ១០១ ] គ្រានោះឯង ពោតលិយបរិព្វាជក បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ កាលពោតលិយបរិព្វាជក អង្គុយក្នុងទីសមគួរស៊ប់ហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលពោតលិយៈ បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួកនេះ តើដូចម្តេចខ្លះ ។ ម្នាលពោតលិយៈ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ ម្នាលពោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ ម្នាលពោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ១ ម្នាលពោតលិយៈ បុគ្គលពួកខ្លះ ក្នុង

លោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ១ ។ ម្នាលបោតលិយៈ បុគ្គលទាំង ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ ម្នាលបោតលិយៈ បណ្ដាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលដូចម្ដេចដែលល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់អ្នក ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គល ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ១

បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណាមិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះឧបេក្ខានោះជាគុណជាតិដ៏ល្អ ។ ម្នាលបោតលិយៈ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។បេ។ ម្នាលបោតលិយៈ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលបោតលិយៈ បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណាពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាង

ផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលពោតលិយៈ ព្រោះថា ការដឹងនូវកាលដ៏សមគួរក្នុងហេតុនោះៗ នោះចាត់ថាជាការល្អ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គលទាំង ៤ ពួក តើដូចម្តេចខ្លះ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលសរសើរចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលតិះដៀលចំពោះបុគ្គល ដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនពោលនូវពាក្យតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះរមែងមានទៅក្នុងលោក ។

បពិត្រព្រះគោតមដ៏ចម្រើន បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណាពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរផង បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះចាត់ថាល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា ការដឹងកាលដ៏សមគួរក្នុងហេតុនោះៗ ទុំះចាត់ថាជាការល្អ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន សម្ដែងដោយអនេកបរិយាយយ៉ាងនេះ ភ្លឺច្បាស់ណាស់ ឧបមាដូចបុគ្គលផ្ងារនូវរបស់ដែលគេផ្កាប់ ឬបើកនូវរបស់ដែលកំបាំង ឬបង្ហាញផ្លូវដល់បុគ្គលអ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹតដោយបំណងថា អ្នកមានភ្នែកភ្លឺ រមែងមើលឃើញនូវរូបទាំងឡាយបាន ។ ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមទៅ ។

## អសុរវគ្គទី ៥ ចប់

## ឧទ្ទាននៃអសុរវគ្គនោះ គឺ

បុគ្គលជាអសុរ មានអសុរជាបរិវារជាដើម ១ បុគ្គលបាននូវចេតោសមថៈជាដើមមាន ៣ លើក បុគ្គល ៤ ពួក មានសេចក្តីប្រៀបដោយអង្កត់ឧសជាគម្រប់ប្រាំ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីកម្ចាត់រាគៈជាដើម ១ បុគ្គលអាចដឹងឆាប់ក្នុងកុសលធម៌ជាដើម ១ អ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម ១ បុគ្គលអ្នកប្រតិបត្តិតាមសិក្ខាបទ ៥ ជាដើម ១ បោតលិយបរិព្វាជក ១ ។

បណ្ណាសកទី ២ ចប់

# អដ្ឋកថា

## ចោតលិយសូត្រ

[ ១០១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចោតលិយសូត្រទី ១០ ដូចតទៅនេះ បទថា **កាលេន** សេចក្តីថា តាមកាលដ៏សមគួរ ។ បទថា **ឲមតិ** គឺ ពេញចិត្ត ។ បទថា **យថិទំ តត្រ តត្រ កាលញ្ញុតា** សេចក្តីថា ការដឹងច្បាស់ក្នុងទីនោះ លោកសម្តែងថា ការដឹងកាលនោះៗ ហើយពោលតិះដៀលបុគ្គលដែលគួរតិះដៀល និងពោលសរសើរបុគ្គលដែលគួរសរសើរជាប្រក្រតីរបស់បណ្ឌិតទាំងឡាយ ។ល។

**អដ្ឋកថា ចោតលិយសូត្រទី ១០ ចប់**

**អសុរវគ្គទី ៥ ចប់**

**ទុតិយបណ្ណាសក ចប់**

# សុត្តន្តបិដក

# តតិយបណ្ណាសក

# វលាហកវគ្គទី ១

## បឋមវលាហកសូត្រទី១

[ ១០២ ] *សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មេឃនេះមាន ៤ យ៉ាង ។ មេឃ ៤ យ៉ាង ដូចម្តេចខ្លះ ។ គឺមេឃគ្រហឹមឥតភ្លៀង ១ មេឃបង្អុរភ្លៀងឥតគ្រហឹម ១ មេឃទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ មេឃគ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ មេឃមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដែលឧបមាដោយមេឃនេះមាន ៤ ពួក រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀង ១ បង្អុរភ្លៀងឥតគ្រហឹម ១ ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានតែនិយាយ តែមិនធ្វើ ម្នាលភិក្ខុទាំងឡាយ*

បុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមឥតបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលជាអ្នកបង្អុរភ្លៀងឥតគ្រហឹម តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើ តែមិននិយាយ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកបង្អុរភ្លៀងឥតគ្រហឹមយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ មេឃនោះបង្អុរភ្លៀងឥតគ្រហឹម មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទាំងមិននិយាយ ទាំងមិនធ្វើ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកគ្រហឹមផង បង្អុរភ្លៀងផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយផង ជាអ្នកធ្វើផង ម្នាលភិក្ខុទាំងឡាយ បុគ្គល

ជាអ្នកគ្រហឹមផង បង្អុរភ្លៀងផងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមផង បង្អុរភ្លៀងផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលឧបមាដោយមេឃ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា
# តតិយបណ្ណាសក
# វលាហកវគ្គទី ១

## បឋមវលាហកសូត្រ

[ ១០២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវលាហកសូត្រទី ១ នៃតតិយបណ្ណាសកដូចតទៅនេះ ក្នុងបទថា* **វលាហកា** *គឺមេឃ ។ បទថា* **ភាសិតា ហោតិ នោ កត្តា** *សេចក្តីថា បុគ្គលពួកខ្លះពោលតែម្យ៉ាងថា អាត្មាអញធ្វើវត្ថុនេះៗ តែមិនធ្វើ ។ បទថា* **កត្តា ហោតិ នោ ភាសិតា** *សេចក្តីថា បុគ្គលពួកខ្លះមិនពោល តែធ្វើ ដោយគិតថា អាត្មាអញគួរធ្វើវត្ថុនេះ ដូច្នេះ គប្បីជ្រាបអត្ថក្នុងបទទាំងពួងយ៉ាងនេះ ។*

**អដ្ឋកថា បឋមវលាហកសូត្រទី ១ ចប់**

# សុត្តន្តបិដក
## ទុតិយវលាហកសូត្រទី ២

[ ១០៣ ] *ម្នាលភិក្ខុទាំងឡាយ មេឃនេះមាន ៤ យ៉ាង ។ មេឃ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺគ្រហឹមឥតបង្អុរភ្លៀង ១ បង្អុរភ្លៀងឥតគ្រហឹម ១*

ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ មេឃមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ ឧបមាដោយមេឃរមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀង ១ បង្អុរភ្លៀងឥតគ្រហឹម ១ ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹមឥតបង្អុរភ្លៀងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមឥតបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកបង្អុរភ្លៀងឥតគ្រហឹម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានរៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គល

នោះរមែងដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកបន្លឺរភ្លៀងឥតគ្រហឹមយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះបន្លឺរភ្លៀងឥតគ្រហឹម មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនគ្រហឹម ទាំងមិនបន្លឺរភ្លៀង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះមិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនគ្រហឹម ទាំងមិនបន្លឺរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះទាំងមិនគ្រហឹម ទាំងមិនបន្លឺរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលគ្រហឹមផង បន្លឺរភ្លៀងផង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌ គឺសុត្តៈ

*គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹមផង បង្អុរភ្លៀងផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមផង បង្អុរភ្លៀងផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយមេឃ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។*

# អដ្ឋកថា

## ទុតិយវលាហកសូត្រ

*ទុតិយវលាហកសូត្រទី ២ មានអត្ថងាយហើយ ។*

*អដ្ឋកថាទុតិយវលាហកសូត្រទី ២ ចប់*

# សុត្តន្តបិដក

## កុម្ភសូត្រទី ៣

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ក្អមនេះមាន ៤ យ៉ាង ។ ក្អម ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺក្អមទទេគ្របមាត់ ១ ក្អមពេញ ( ដោយទឹក ) តែបើកចំហមាត់ ១ ក្អមទទេបើកចំហមាត់ ១ ក្អមពេញ ( ដោយទឹក ) គ្របមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្អមមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយក្អម ៤ ពួកនេះ រមែងមានទៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ គឺបុគ្គលទទេគ្របមាត់ ១ បុគ្គលពេញដោយទឹក តែបើកចំហមាត់ ១ បុគ្គលទទេបើកចំហមាត់ ១ បុគ្គលពេញដោយទឹក ទាំងគ្របមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទទេគ្របមាត់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទទេគ្របមាត់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមទទេគ្របមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គល

នេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលពេញដោយទឹកបើកចំហមាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរមិនជាទីជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលពេញដោយទឹកបើកចំហមាត់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមពេញដោយទឹកបើកចំហមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទទេទាំងបើកចំហមាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរមិនជាទីជ្រះថ្លា បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលភិក្ខុទាំង-

ឡាយ បុគ្គលទទេបើកចំហមាត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អម នោះជាក្អមទទេបើកចំហមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលពេញដោយទឹកគ្របមាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឈានដើរទៅមុខ ឈានដើរថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈ ចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទីជ្រះថ្លា បុគ្គលនោះរមែងដឹង ច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះ ជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលពេញដោយទឹកទាំងបិទមាត់ យ៉ាងនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ ក្អមនោះជាក្អមពេញដោយទឹកគ្របមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយក្អម ៤ ពួកនេះ រមែងមាននៅ ក្នុងលោក ។

# អដ្ឋកថា

## កុម្ភសូត្រ

[ ១០៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុម្ភសូត្រទី ៣ ដូចតទៅនេះ បទថា **កុម្ភោ** គឺឆ្នាំង ។ បទថា **តុច្ឆោ បិហិតោ** បានដល់ ឆ្នាំងទទេ បិទមាត់ ។ បទថា **បូរោ វិវដោ** បានដល់ ឆ្នាំងពេញដោយទឹកបើកមាត់ ។ ក្នុង ២ បទដ៏សេស ក៏មានន័យនេះដូចគ្នា ៕

**អដ្ឋកថា កុម្ភសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឧទករហទសូត្រទី ៤

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនេះមាន ៤ យ៉ាង ។ អន្លង់ទឹក ៤ យ៉ាង តើដូចម្តេច ។ គឺអន្លង់ទឹករាក់មានឱភាស ( ចុះស្រមោលទៅជ្រៅ ) ១ អន្លង់ទឹកជ្រៅមានឱភាសរាក់ ១ អន្លង់ទឹករាក់មានឱភាសរាក់ ១ អន្លង់ទឹកជ្រៅមានឱភាសជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយអន្លង់ទឹក ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលរាក់មានឱភាសជ្រៅ ១ បុគ្គលជ្រៅមានឱភាសរាក់ ១ បុគ្គលរាក់មាន

ឱកាសរាក់ ១ បុគ្គលជ្រៅមានឱកាសជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលរាក់មានឱកាសជ្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទីជ្រះថ្លា តែបុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលរាក់មានឱកាសជ្រៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះរាក់មានឱកាសជ្រៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជ្រៅមានឱកាសរាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរមិនជាទីជ្រះថ្លា បុគ្គលនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រៅមានឱកាស

រាក់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះជ្រៅមានឱភាសរាក់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលរាក់មានឱភាសរាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈាន ទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់ អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរ មិនជាទី ជ្រះថ្លា បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹង ច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តី ពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ-និរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលរាក់មានឱភាសរាក់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះរាក់មានឱភាសរាក់ មាន ឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មាន ឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជ្រៅមានឱភាសជ្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈាន ទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់ អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទី ជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹង ច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តី

ពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ-និរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រៅមានឱភាសជ្រៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះជ្រៅមានឱភាសជ្រៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយអន្លង់ទឹក ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## ឧទករហទសូត្រ

[ ១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទករហទសូត្រទី ៤ ដូចតទៅនេះ ក្នុងបទថា **ឧត្តានោ គម្ភីរោភាសោ** ជាដើម សេចក្តីថា អន្លង់ទឹកខ្មៅ មានពណ៌លាយដោយស្លឹកឈើចាស់ៗ ឈ្មោះថា មានស្រមោលជ្រៅ អន្លង់ទឹកមានពណ៌ថ្លាស្អាតដូចកែវមណី ឈ្មោះថា មានស្រមោលរាក់ ។

**អដ្ឋកថា ឧទករហទសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## អម្ពសូត្រទី ៥

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនេះមាន ៤ យ៉ាង ។ ផ្លែស្វាយ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺផ្លែស្វាយខ្ចីមានសម្បុរទុំ ១ ផ្លែស្វាយទុំមានសម្បុរខ្ចី ១ ផ្លែស្វាយខ្ចីមានសម្បុរខ្ចី ១ ផ្លែស្វាយទុំមានសម្បុរទុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានឧបមាដោយផ្លែស្វាយ ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលខ្ចីមានសម្បុរទុំ ១ បុគ្គលទុំមានសម្បុរខ្ចី ១ បុគ្គលខ្ចីមានសម្បុរខ្ចី ១ បុគ្គលទុំមានសម្បុរទុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ចីមានសម្បុរទុំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទីជ្រះថ្លា បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ-គាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ចីមានសម្បុរទុំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះខ្ចីមានសម្បុរទុំ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យ

ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទុំមានសម្បុរខ្ចី តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរមិនជាទីជ្រះថ្លា តែបុគ្គលនោះរមែងដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទុំ មានសម្បុរខ្ចីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះទុំមានសម្បុរខ្ចី មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ចីមានសម្បុរខ្ចី តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរមិនជាទីជ្រះថ្លា បុគ្គលនោះមិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ-សមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ចីមានសម្បុរខ្ចីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែ

ស្វាយនោះខ្ចីមានសម្បុរខ្ចី មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទុំមានសម្បុរទុំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរគួរជាទីជ្រះថ្លា បុគ្គលនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទុំមានសម្បុរទុំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះទុំមានសម្បុរទុំ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយផ្លែស្វាយ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## អម្ពសូត្រ

[ ១០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអម្ពសូត្រទី ៥ ដូចតទៅនេះ បទថា **អាមំ បក្កវណ្ណី** សេចក្តីថា កាលពិនិត្យមើលជាស្វាយខ្ចី តែប្រាកដដូចទុំ បទទាំងពួងគប្បីឃើញយ៉ាងនេះ ។ល។

**អដ្ឋកថា អម្ពសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អដ្ឋកថាសូត្រទី ៦

សូត្រទី ៦ បិដកខ្មែរមិនមាន ក្នុងបិដកប្រទេសដទៃៗ ក៏បាត់ទៅដូចគ្នា តែក្នុងអដ្ឋកថា ពន្យល់ទុកថា សូត្រទី ៦ មានអត្ថងាយយល់ហើយ ។

## មូសិកាសូត្រទី ៧

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ កណ្តុរនេះមាន ៤ ពួក ។ កណ្តុរ ៤ ពួក តើដូចម្តេចខ្លះ ។ គឺកណ្តុរកកាយរន្ធតែមិននៅ ១ នៅតែមិនកកាយរន្ធ ១ ទាំងមិនកកាយរន្ធទាំងមិននៅ ១ កកាយរន្ធផងនៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយកណ្តុរ ៤ ពួកនេះ រមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ បុគ្គល ៤

ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលកកាយរន្ធតែមិននៅ ១ នៅតែមិនកកាយរន្ធ ១ ទាំងមិនកកាយរន្ធទាំងមិននៅ ១ កកាយរន្ធផងនៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកកកាយរន្ធតែមិននៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកកកាយរន្ធតែមិននៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះកកាយរន្ធតែមិននៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកនៅតែមិនកកាយរន្ធ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលជាអ្នកនៅតែមិនកកាយរន្ធ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះនៅតែមិនកកាយរន្ធ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនកកាយរន្ធទាំងមិននៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាម សេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនកកាយរន្ធទាំងមិននៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះទាំងមិនកកាយរន្ធទាំងមិននៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកកកាយរន្ធផងនៅផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ-

និរោធដូច្នេះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកកកាយរន្ធផងនៅផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះកកាយរន្ធផងនៅផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានឧបមាដោយកណ្តុរ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## មូសិកាសូត្រ

[ ១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមូសិកាសូត្រទី ៧ ដូចតទៅនេះថា ទីលំនៅ ហៅថា រន្ធ កណ្តុរពួកណារមែងកកាយរន្ធ តែមិននៅក្នុងរន្ធនោះ កណ្តុរពួកនោះ ហៅថា កកាយរន្ធតែមិននៅ ។ បាលីថា **ឲ្យគ្នា** ដូច្នេះ ក៏មាន ។ បទទាំងពួង គប្បីជ្រាបដោយន័យនេះ ។៚

**អដ្ឋកថា មូសិកាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ពលិពទ្ទសូត្រទី ៨

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ គោបម្រើនេះមាន ៤ ពួក ។ គោបម្រើ ៤ ពួក តើដូចម្តេចខ្លះ ។ គឺជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ១ ជាសត្វកាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ ជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោរដទៃផង ១ ជាសត្វមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយគោបម្រើ ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ ១ កាចក្នុងហ្វូងគោដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ កាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង ១ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិស័ទរបស់ខ្លួន តែមិនគំរាមបរិស័ទដទៃ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគត

ពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិស័ទរបស់អ្នកដទៃ តែមិនគំរាមបរិស័ទរបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់អ្នកដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ ជាសត្វកាចក្នុងហ្វូងគោដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិស័ទរបស់ខ្លួនផង គំរាមបរិស័ទរបស់អ្នកដទៃផង ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ កាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនគំរាមបរិស័ទរបស់ខ្លួន ទាំងមិនគំរាមបរិស័ទរបស់អ្នកដទៃ ។ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ ជាសត្វមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយបុគ្គលឧបមាដោយគោបម្រើ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## ពលិពទ្ទសូត្រ

[ ១០៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពលិពទ្ទសូត្រទី ៨ ដូចតទៅនេះថា គោបម្រើណា រមែងបៀតបៀនហ្វូងរបស់ខ្លួន មិនបៀតបៀនហ្វូងគោដទៃ គោនេះ ឈ្មោះថា កាចតែក្នុងហ្វូងរបស់ខ្លួន មិនកាចក្នុងហ្វូងដទៃ ។ បទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។ បទថា **ឧព្វេជេតា ហោតិ** បានដល់ គំរាម គឺបុស ធ្វើឲ្យកើតនូវការភ័យខ្លាច ។៚

**អដ្ឋកថា ពលិពទ្ទសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## រុក្ខសូត្រទី ៩

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ដើមឈើនេះមាន ៤ ពួក ។ ដើមឈើ ៤ ពួក តើដូចម្តេចខ្លះ ។ គឺដើមឈើស្រាយមានដើមឈើស្រាយជាបរិវារ ១ ដើមឈើស្រាយមានដើមឈើខ្លឹមជាបរិវារ ១ ដើមឈើខ្លឹមមានដើមឈើស្រាយជាបរិវារ ១ ដើមឈើខ្លឹមមានដើមឈើខ្លឹមជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយដើមឈើ ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលស្រាយមានស្រាយជាបរិវារ ១ បុគ្គលស្រាយមានខ្លឹមជាបរិវារ ១ បុគ្គលខ្លឹមមានស្រាយជាបរិវារ ១ បុគ្គលខ្លឹមមានខ្លឹមជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលស្រាយមានស្រាយជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងបរិស័ទរបស់បុគ្គលនោះ ក៏ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមកដែរ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្រាយមានស្រាយជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះជាឈើស្រាយ មានដើមឈើស្រាយជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលស្រាយមានខ្លឹមជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏

លាមក ប៉ុន្តែបរិស័ទរបស់បុគ្គលនោះ ជាអ្នកមានសីល មានធម៌ល្អ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្រាយមានខ្លឹមជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះជាដើមឈើស្រាយ មានដើមឈើខ្លឹមជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លឹមមានស្រាយជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ប៉ុន្តែបរិស័ទរបស់បុគ្គលនោះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា បុគ្គលខ្លឹមមានស្រាយជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះជាដើមឈើខ្លឹមមានដើមឈើស្រាយជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្លឹមមានខ្លឹមជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិស័ទរបស់បុគ្គលនោះ ក៏ជាអ្នកមានសីល មានធម៌ល្អដែរ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លឹមមានខ្លឹមជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះជាដើមឈើមានខ្លឹម មានដើមឈើខ្លឹមជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយដើមឈើ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## រុក្ខសូត្រ

[ ១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរុក្ខសូត្រទី ៩ ដូចតទៅនេះ បទថា **ផេគ្គុ ផេគ្គុបរិវារោ** សេចក្តីថា ឈើស្រាយមិនមានខ្លឹម មានដើមឈើស្រាយដូចគ្នាចោមរោម ។ បទថា **សារបរិវារោ** សេចក្តីថា ដើមឈើមានខ្លឹម មានដើមគគីរជាដើមចោមរោម ។ បទទាំងពួង ក៏មានន័យដូច្នេះ ៗ។

**អដ្ឋកថា រុក្ខសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អាសីវិសសូត្រទី ១០

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ អាសិរពិសនេះមាន ៤ ពួក ។ អាសិរពិស ៤ ពួក តើដូចម្តេចខ្លះ ។ គឺអាសិរពិសមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក ១ មានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ ១ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង ១ មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយអាសិរពិស ៤ ពួកនេះ រមែងមានទៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក

តើដូចម្តេចខ្លះ ។ គឺបុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក ១ មានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ ១ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង ១ មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ តែសេចក្តីក្រោធរបស់បុគ្គលនោះ មិននំនៅអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនក្រោធរឿយៗ ទេ តែសេចក្តីក្រោធរបស់បុគ្គលនោះ រមែងនំនៅអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង តើដូច

ម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ ផង សេចក្តីក្រោធរបស់បុគ្គលនោះ រមែងនាំទៅអស់កាលយូរផង ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនក្រោធរឿយៗ ទាំងសេចក្តីក្រោធរបស់បុគ្គលនោះ ក៏មិននាំទៅអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយអាសិរពិស ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

*វលាហកវគ្គទី ១ ចប់*

## ឧទ្ទាននៃវលាហកវគ្គនោះ គឺ

និយាយអំពីមេឃមានពីរលើក អំពីក្អម ១ អំពីអន្លង់ទឹកមាន ពីរលើក អំពីផ្លែស្វាយ ១ អំពីសត្វកណ្ដុរ ១ អំពីគោបម្រើ ១ អំពីដើមឈើ ១ អំពីអាសិរពិស ១ រួមត្រូវជា ១០ ។

# អដ្ឋកថា

## អាសីវិសសូត្រ

[ ១១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាសីវិសសូត្រទី ១០ ដូចតទៅនេះ បទថា **អាគតវិសោ ន ឃោរវិសោ** សេចក្ដីថា ពិសរបស់អាសិរពិស ជ្រួតជ្រាបរហ័ស តែមិនខ្លាំងក្លា មិនបៀតបៀនអស់កាលយូរ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

**អដ្ឋកថា អាសីវិសសូត្រទី ១០ ចប់**

**វលាហកវគ្គទី ១ ចប់**

# សុត្តន្តបិដក

## កេសីវគ្គទី ២

### កេសីសូត្រទី ១

[ ១១១ ] គ្រានោះ កេសីជាសារថី អ្នកបង្ហាត់សេះដែលគួរបង្ហាត់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះកេសីជាសារថីអ្នកបង្ហាត់សេះដែលគួរបង្ហាត់ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលកេសី ខ្លួនអ្នក គេតែងដឹងច្បាស់ថា ជាសារថី អ្នកបង្ហាត់សេះដែលគួរបង្ហាត់ ម្នាលកេសី ចុះអ្នកបង្ហាត់សេះដែលគួរបង្ហាត់ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបង្ហាត់សេះដែលគួរបង្ហាត់ដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អ និងអាក្រក់ខ្លះ ។ ម្នាលកេសី ប្រសិនបើសេះដែលគួរបង្ហាត់របស់អ្នក ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អ និងអាក្រក់ក៏មិនបាន ចុះអ្នកធ្វើសេះនោះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើសេះដែលគួរបង្ហាត់របស់ខ្ញុំព្រះអង្គ ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អ និងអាក្រក់ក៏មិនបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏សម្លាប់សេះនោះចោល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យមានពាក្យដំណៀលដល់ត្រកូលនៃអាចារ្យរបស់ខ្ញុំ

ព្រះអង្គឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសារថី ទូន្មាននូវបុរសដែលគួរទូន្មាន រកបុគ្គលណាមួយស្មើគ្មាន បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ ទ្រង់ណែនាំបុរសដែលគួរទូន្មាន តើដូចម្តេច ។ ម្នាលកេសី តថាគតរមែងណែនាំបុរសដែលគួរទូន្មានដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អ និងអាក្រក់ខ្លះ ។ ម្នាលកេសី បណ្តាអំពើទាំងនោះ អំពើល្អដូច្នេះ គឺកាយសុចរិតដូច្នេះ ផលរបស់កាយសុចរិតដូច្នេះ វចីសុចរិតដូច្នេះ ផលរបស់វចីសុចរិតដូច្នេះ មនោសុចរិតដូច្នេះ ផលរបស់មនោសុចរិតដូច្នេះ ទេវតាដូច្នេះ មនុស្សដូច្នេះ ។ ម្នាលកេសី បណ្តាអំពើទាំងអស់នោះ អំពើអាក្រក់ដូច្នេះ គឺកាយទុច្ចរិតដូច្នេះ ផលរបស់កាយទុច្ចរិតដូច្នេះ វចីទុច្ចរិតដូច្នេះ ផលរបស់វចីទុច្ចរិតដូច្នេះ មនោទុច្ចរិតដូច្នេះ ផលរបស់មនោទុច្ចរិតដូច្នេះ នរកដូច្នេះ កំណើតតិរច្ឆានដូច្នេះ បិត្តិវិស័យដូច្នេះ ។ ម្នាលកេសី បណ្តាអំពើទាំងនោះ អំពើល្អ និងអំពើអាក្រក់ ដូច្នេះ គឺកាយសុចរិតដូច្នេះ ផលរបស់កាយសុចរិតដូច្នេះ កាយទុច្ចរិតដូច្នេះ ផលរបស់កាយទុច្ចរិតដូច្នេះ វចីសុចរិតដូច្នេះ ផលរបស់វចីសុចរិតដូច្នេះ វចីទុច្ចរិតដូច្នេះ ផលរបស់វចី-ទុច្ចរិតដូច្នេះ មនោសុចរិតដូច្នេះ ផលរបស់មនោសុចរិតដូច្នេះ មនោទុច្ចរិតដូច្នេះ ផលរបស់មនោទុច្ចរិតដូច្នេះ ទេវតាដូច្នេះ មនុស្សដូច្នេះ នរកដូច្នេះ កំណើតតិរច្ឆានដូច្នេះ បិត្តិវិស័យដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើបុរសដែលគួរទូន្មានរបស់ព្រះអង្គ ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធី

បង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អ និងអាក្រក់ក៏មិនបាន ចុះព្រះដ៏មានព្រះភាគ ទ្រង់ធ្វើបុរសនោះដូចម្តេចទៅវិញ ។ ម្នាលកេសី ប្រសិនបើបុរសដែលគួរទូន្មានរបស់តថាគត ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អ និងអាក្រក់ក៏មិនបាន ម្នាលកេសី តថាគតក៏សម្លាប់បុរសនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន បាណាតិបាតមិនគួរដល់ព្រះដ៏មានព្រះភាគរបស់យើងទេ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលកេសី តថាគតក៏សម្លាប់បុរសនោះដែរ ។ ម្នាល កេសី បាណាតិបាតមិនគួរដល់តថាគតក៏ពិតមែន តែថា បុរសដែលគួរទូន្មាន ណា ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អ និងអាក្រក់ក៏មិនបាន តថាគតរមែងមិនសម្គាល់នូវ បុរសនោះថា គួរពោល គួរប្រៀនប្រដៅទេ សូម្បីវិញ្ញូជនជាសព្រហ្មចារី ក៏មិនសម្គាល់ ( បុរសនោះ ) ថា គួរពោល គួរប្រៀនប្រដៅដែរ មួយទៀត តថាគតមិនសម្គាល់នូវបុរសណាថា គួរពោល គួរប្រៀនប្រដៅ សូម្បីពួកវិញ្ញូជនជាសព្រហ្មចារី ក៏មិនសម្គាល់នូវបុរសណាថា គួរពោល គួរប្រៀនប្រដៅដែរ ម្នាលកេសី បុរសនោះ ឈ្មោះថា ត្រូវសម្លាប់ដោយល្អ ក្នុងអរិយវិន័យ ។ ព្រះតថាគតមិនសម្គាល់បុរសណាថា គួរពោល គួរប្រៀន ប្រដៅ សូម្បីពួកវិញ្ញូជនជាសព្រហ្មចារី ក៏មិនសម្គាល់បុរសណាថា គួរពោល គួរប្រៀនប្រដៅដែរ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះឈ្មោះថាត្រូវសម្លាប់

ដោយល្អដោយពិត បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុរសផ្ងារនូវរបស់ដែលគេផ្កាប់ ឬបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះសោត ដូចជាបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថាបុគ្គលមានចក្ខុ រមែងមើលឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះដ៏មានព្រះភាគផងព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីពឹងទីរឭក បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសកដល់នូវសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា
# កេសិវគ្គទី ២

## កេសិសូត្រ

[ ១១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកេសិសូត្រទី ១ នៃកេសិវគ្គទី ២ ដូចតទៅនេះ បទថា **កេសិ** ជាឈ្មោះរបស់នាយសារថីដែលជាអ្នកទូន្មានសេះ ។ ឈ្មោះថា សារថីអ្នកទូន្មានសេះ ព្រោះធ្វើសេះដែលគួរបង្ហឹកឲ្យយល់ ទើបបង្ហឹក ។ បទថា **សណ្ហេនបិ ទមេតិ** ជាដើម នាយសារថីធ្វើសក្ការៈល្មមសមគួរដល់សេះនោះ គឺឲ្យបរិភោគភោជនយ៉ាងល្អ ឲ្យផឹកទឹកឆ្ងាញ់ ពោលដោយពាក្យពីរោះហើយ ទើបបង្ហឹក ឈ្មោះថា បង្ហឹកដោយវិធីទន់ភ្លន់ ។ លុះបង្ហឹកដោយចងជើង ចងមាត់ជាដើមហើយ ចាក់ដោយទន្ទ្រញ វាយដោយរំពាត់ ពោលពាក្យគ្រោតគ្រាត ឈ្មោះថា បង្ហឹកដោយវិធីខ្លាំងក្លា ត្រូវធ្វើវិធីទាំង ២ នោះ តាមកាលដ៏គួរ ឈ្មោះថា បង្ហឹកទាំងវិធីទន់ភ្លន់និងវិធីខ្លាំងក្លា ។ល។

### អដ្ឋកថា កេសិសូត្រទី ១ ចប់

# សុត្តន្តបិដក

## ជវសូត្រទី ២

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យប្រកបដោយអង្គ ៤ ជាសេះចម្រើនរបស់ស្តេច គួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ។ ប្រកបដោយអង្គ ៤ ដូចម្តេចខ្លះ ។ គឺប្រកបដោយសេចក្តីស្មោះត្រង់ ១ ដោយសម្ទុះ ១ ដោយអំណត់ ១ ដោយការស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យប្រកបដោយអង្គ ៤ នេះ ជាសេះចម្រើនរបស់ស្តេច គួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ក៏ដូច្នោះដែរ គឺជាអ្នកគួរគេបូជា គួរទទួលនូវអាគន្តុកទាន ជាអ្នកគួរទទួលនូវទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរនៃសត្វលោក ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺប្រកបដោយសេចក្តីស្មោះត្រង់ ១ ដោយសម្ទុះ ១ ដោយអំណត់ ១ ដោយការស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា ជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរនៃសត្វលោក ។

# អដ្ឋកថា

## ជវសូត្រ

[ ១១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជវសូត្រទី ២ ដូចតទៅនេះ បទថា **អាជ្ជវេន** គឺស្មោះត្រង់ ។ បទថា **ជវេន** គឺមានសម្ទុះដើររហ័ស ។ បទថា **ខន្តិយា** បានដល់ មានការអត់ធន់ គឺអត់សង្កត់ ។ បទថា **សោរច្ចេន** គឺមានការស្ងប់ស្ងាត់ជាប្រក្រតី ។ ក្នុងអង្គនៃគុណរបស់បុគ្គល បទថា **ជវេន** បានដល់ ដោយកម្លាំងរហ័សនៃញាណ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។៚

អដ្ឋកថា ជវសូត្រទី ២ ចប់

# សុត្តន្តបិដក

## បតោទសូត្រទី ៣

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនមាន ៤ ពួក រមែងមាននៅក្នុងលោក ។ ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ បានឃើញនូវស្រមោលនៃជន្លួញហើយ ក៏រំភើបដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ អញនឹងធ្វើតបទៅសារថី

នោះដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ១ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ បានឃើញស្រមោលនៃជន្ទួញហើយ នៅតែមិនរំភើប ដល់នូវសេចក្ដីតក់ស្លុតទេ លុះតែគេចាក់ត្រង់រោមដោយជន្ទួញ ទើបរំភើប ដល់នូវសេចក្ដីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ អញនឹងធ្វើតបទៅសារថីនោះដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ២ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ ឃើញនូវស្រមោលនៃជន្ទួញហើយ នៅតែមិនរំភើប ដល់នូវសេក្ដីតក់ស្លុត ទុកជាចាក់ត្រង់រោម ( ដោយជន្ទួញ ) ក៏នៅតែមិនរំភើប ដល់នូវសេចក្ដីតក់ស្លុតដែរ លុះតែចាក់ត្រង់ស្បែកដោយជន្ទួញ ទើបរំភើប ដល់នូវសេចក្ដីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើនូវហេតុអ្វីដល់អញ អញនឹងធ្វើតបទៅសារថីនោះដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជា-នេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ៣ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុ

ទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ បាន ឃើញស្រមោលនៃជន្លួញហើយ នៅតែមិនរំភើប ដល់នូវសេចក្តីតក់ស្លុត ទុកជាគេចាក់ត្រង់រោមដោយជន្លួញ ក៏នៅតែមិនរំភើប ដល់នូវសេចក្តីតក់ស្លុតដែរ ទុកជាគេចាក់ត្រង់ស្បែកដោយជន្លួញ ក៏នៅតែមិនរំភើប ដល់នូវសេចក្តីតក់ស្លុតដែរ លុះតែគេចាក់ដល់ឆ្អឹងដោយជន្លួញ ទើបរំភើប ដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ អញនឹងត្រូវធ្វើតបទៅនាយសារថីនោះ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ ក៏មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ៤ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើននេះមាន ៤ ពួក រមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ ឮថា ស្ត្រី ឬបុរសក្នុងស្រុក ឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខក្តី ធ្វើមរណកាលទៅក្តី បុរសអាជានេយ្យនោះ ក៏រំភើប ដល់នូវសេចក្តីតក់ស្លុត ដោយហេតុនោះ ( បុរសអាជានេយ្យនោះ ) ជាអ្នកតក់ស្លុត តម្កល់ព្យាយាមដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ច ដោយនាមកាយផង ចាក់ធ្លុះឃើញច្បាស់ដោយបញ្ញាផង

ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ គ្រាន់តែឃើញនូវស្រមោលជន្ទួញហើយ ក៏រំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ ចម្រើនទី ១ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មិនបានឮថា ស្ត្រីឬបុរសក្នុងស្រុក ឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ស្រាប់តែឃើញដោយខ្លួនឯងនូវស្ត្រី ឬបុរសដល់នូវសេចក្តីទុក្ខ ឬធ្វើមរណ-កាល បុរសអាជានេយ្យនោះ ក៏រំភើប ដល់នូវសេចក្តីតក់ស្លុតដោយហេតុនោះ ( បុរសអាជានេយ្យនោះ ) ជាអ្នកតក់ស្លុត តម្កល់នូវសេចក្តីព្យាយាមដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ច ដោយនាមកាយផង ចាក់ធ្លុះឃើញច្បាស់ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ គ្រាន់តែត្រូវគេចាក់ដោយជន្ទួញត្រង់រោម ក៏រំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជា-

នេយ្យដ៏ចម្រើនទី ២ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មិនបានឮថា ស្ត្រី ឬបុរសក្នុងស្រុក ឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ទាំងមិនបានឃើញដោយខ្លួនឯងនូវស្ត្រី ឬបុរសដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលឡើយ មួយទៀត លុះតែញាតិ ឬសាលោហិតរបស់បុរសអាជានេយ្យនោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលទៅ បុរសអាជានេយ្យនោះ ទើបរំភើប ដល់នូវសេចក្តីតក់ស្លុត ដោយហេតុនោះ ( បុរសអាជា-នេយ្យនោះ ) ជាអ្នកតក់ស្លុត តម្កល់នូវសេចក្តីព្យាយាម ដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចដោយនាមកាយផង ចាក់ធ្លុះឃើញច្បាស់ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ ត្រូវគេចាក់ដោយជន្លួញត្រង់ស្បែក ទើបរំភើប ដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ចម្រើនទី ៣ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុរសអាជា-នេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មិនឮថា ស្ត្រី ឬបុរសក្នុងស្រុក ឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ទាំងមិនឃើញដោយខ្លួនឯង

នូវស្រ្តី ឬបុរសដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលទៅ ទោះបីញាតិ ឬសាលោហិតរបស់បុរសអាជានេយ្យនោះ ក៏មិនដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលទៅ ស្រាប់តែខ្លួនឯងពាល់ត្រូវដោយទុក្ខវេទនា ជាទីប្រជុំចុះក្នុងកាយដ៏ក្លាខ្លាំង រឹងរូស ក្តៅផ្សា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ជាទីនាំបង់នូវជីវិតបុរសអាជានេយ្យនោះ ក៏រំភើប ដល់នូវសេចក្តីតក់ស្លុត ដោយហេតុនោះ ( បុរសអាជានេយ្យនោះ ) ជាអ្នកតក់ស្លុត ទើបតម្កល់សេចក្តីព្យាយាម ដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ច ដោយនាមកាយផង ចាក់ធ្លុះឃើញច្បាស់ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ ត្រូវគេចាក់ដោយជន្ទួញត្រង់ឆ្អឹង ក៏រំភើប ដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ចម្រើនទី ៤ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើន ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## បតោទសូត្រ

[ ១១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបតោទសូត្រទី ៣ ដូចតទៅនេះ បទថា **បតោទច្ឆាយំ** សេចក្តីថា ស្រមោលនៃជន្ទញដែលលើកឡើងដើម្បីចាក់ ។ បទថា **សំវិជតិ** សេចក្តីថា តក់ស្លុតដោយការកំណត់ថា អាត្មាអញ ត្រូវបង្កើនប្ញីជើង ។ បទថា **សំវេគំ អាបជ្ជតិ** សេចក្តីថា ចាក់ឲ្យខ្វាច ។ បទថា **លោមវេធវិទ្ធោ** សេចក្តីថា លុះត្រូវជន្ទញចាក់ត្រង់រណ្តៅរោម ។ បទថា **ចម្មវេធវិទ្ធោ** សេចក្តីថា យកជន្ទញចាក់ទម្លុះស្បែក ។ បទថា **អដ្ឋិវេធវិទ្ធោ** សេចក្តីថា យកជន្ទញចាក់ទម្លុះដល់ឆ្អឹង ។ បទថា **កាយេន** គឺដោយនាមកាយ ។ បទថា **បរមសច្ចំ** គឺនិព្វាន ។ បទថា **សច្ឆិករោតិ** គឺពាល់ត្រូវ ។ បទថា **បញ្ញាយ** គឺមគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ល។

អដ្ឋកថា បតោទសូត្រទី ៣ ចប់

# សុត្តន្តបិដក

## នាគសូត្រទី ៤

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៤ ជាដំរីគួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថា ជាអង្គ

របស់ស្តេច ។ ប្រកបដោយអង្គ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វមានត្រចៀក ( វៃ ) ១ ជាសត្វបៀតបៀន ១ ជាសត្វអត់ធ្មត់ ១ ជាសត្វដើរ ( លឿន ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វមានត្រចៀក ( វៃ ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ សារថីអ្នកបង្ហាត់នូវដំរី ដែលគួរបង្ហាត់ ឲ្យធ្វើនូវហេតុណា ទោះបីខ្លួនធ្លាប់ធ្វើក្តី ទោះបីខ្លួនមិនធ្លាប់ធ្វើក្តី ក៏ធ្វើនូវហេតុនោះឲ្យមានប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវហេតុទាំងអស់ដោយចិត្ត មានត្រចៀកផ្ទៀងស្តាប់ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វមានត្រចៀក ( វៃ ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វបៀតបៀន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលចូលសង្គ្រាម ក៏បៀតបៀននូវដំរីផងគ្នាផង បៀតបៀននូវទម័កដំរីផង បៀតបៀននូវសេះផង បៀតបៀននូវអ្នកជិះសេះផង បៀតបៀននូវរថផង បៀតបៀននូវបុរសអ្នកជិះរថផង បៀតបៀននូវសេនាថ្មើរជើងផង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វបៀតបៀន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធ្មត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលចូលសង្គ្រាម ជាសត្វអត់ធ្មត់នឹងការប្រហារដោយលំពែង ប្រហារ

ដោយដាវ ប្រហារដោយពូថៅ ( ជាសត្វអត់ធ្មត់ ) នឹងសំឡេងស្គរជ័យ ខ្លុយ ស័ង្ខ ស្គរធំ និងស្គរសំឡេងគឹកកងទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធ្មត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វដើរ ( លឿន ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ សារថីអ្នកបង្ហាត់នូវដំរីដែលគួរបង្ហាត់ បញ្ជូនទៅកាន់ទិសណា ទោះបីធ្លាប់ទៅក្តី មិនធ្លាប់ទៅក្តី ក៏ជាសត្វដើរ ( លឿន ) ទៅកាន់ទិសនោះដោយឆាប់ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វដើរ ( លឿន ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៤ នេះ ជាដំរីគួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងក៏ដូច្នោះដែរ គឺជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសោតប្រសាទវៃផង ជាអ្នកបៀតបៀនផង ជាអ្នកអត់ធ្មត់ផង ជាអ្នកដើរ ( លឿន ) ផង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានសោតប្រសាទ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលគេកំពុងសម្តែងធម្មវិន័យ ដែលតថាគតប្រកាសហើយ

ក៏ធ្វើឲ្យមានប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មវិន័យទាំងអស់ដោយចិត្ត មានសោតប្រសាទផ្ទៀងចុះចាំស្តាប់នូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសោតប្រសាទវៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបៀតបៀន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានតទៅទៀត នូវកាមវិតក្ក ដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត នូវព្យាបាទវិតក្ក ដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត នូវវិហឹសាវិតក្កដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានតទៅទៀត នូវអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយៗ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបៀតបៀន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកអត់ធ្មត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធ្មត់នូវត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ និងពាក្យដែលគេនិយាយអាក្រក់ និងគន្លងនៃពាក្យដែលកើតឡើង និងទុក្ខវេទនាជាទីប្រជុំចុះក្នុងសរីរៈដ៏ក្លាខ្លាំង រឹងរូស ក្តៅផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាទីនាំបង់នូវជីវិត ជាអ្នកប្រកបដោយអធិវាសនក្ខន្តិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកអត់ធ្មត់ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នក ដើរ ( លឿន ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទិសណាដែលគេមិនធ្លាប់ទៅ ដោយកាលយូរអង្វែងនេះ សភាវៈណាដែលជាទីរម្ងាប់បង់នូវសង្ខារទាំងពួង ជាទីលះបង់នូវឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាករាគៈ ជាទីរលត់ គឺព្រះនិព្វាន ភិក្ខុក្នុងសាសនានេះ ជាអ្នកដើរទៅកាន់ទិស និងសភាវៈនោះ ដោយឆាប់រួសរាន់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដើរ ( លឿន ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា ជាអ្នកគួរទទួលនូវអាគន្តុកទាន ជាអ្នកគួរទទួលនូវទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## នាគសូត្រ

[ ១១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាគសូត្រទី ៤ ដូចតទៅនេះ បទថា **អជ្ឈិកត្វា** គឺជាប្រយោជន៍ ។ ស្គរតូច ឈ្មោះថា **តិណវ** ក្នុងពាក្យនេះថា **តិណវនិន្នាទសទ្ទានំ។** បទថា **និន្នាទសទ្ទោ** បានដល់ សំឡេង ដូចផ្គរលាន់

ទៅជាមួយគ្នារបស់គ្រឿងវាយ ឬគ្រឿងផ្ចុំគ្រប់យ៉ាង ។ ក្នុងបទថា **ឧំសា** ជាដើម បទថា **ឧំសា** បានដល់ របោម ។ បទថា **មកសា** បានដល់ មូស ។ បទថា **ខិប្បញ្ញេវ គន្តា ហោតិ** សេចក្តីថា ភិក្ខុបំពេញសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈហើយ ទៅដោយរហ័ស ។៚

## អដ្ឋកថា ឆាគសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ឋានសូត្រទី ៥

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ ហេតុនេះមាន ៤ យ៉ាង ។ ហេតុ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលគួរធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ក៏មាន ។ ម្នាលភិក្ខុ

ទាំងឡាយ បណ្ដាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បុគ្គលរមែងសម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនមិនត្រូវធ្វើដោយហេតុ ២ ប្រការ គឺការធ្វើនូវហេតុណាមិនជាទីគាប់ចិត្ត ក៏សម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ហេតុណាដែលបុគ្គលធ្វើរមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ក៏សម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលរមែងសម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនមិនត្រូវធ្វើដោយហេតុ ២ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្ដី ជាបណ្ឌិតក្ដី គេត្រូវដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្ដីព្យាយាមរបស់បុរស ក្នុងសេចក្ដីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារណាដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តនេះក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ជនពាលនោះ ទើបមិនធ្វើនូវហេតុនោះ ហេតុដែលជនពាលមិនធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិតរមែងពិចារណាដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តនេះក៏ពិតមែនហើយ តែហេតុដែលបណ្ឌិតធ្វើនេះ រមែងប្រព្រឹត្ត

ទៅដើម្បីជាប្រយោជន៍ បណ្ឌិតនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិតធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណាជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្ដី ជាបណ្ឌិតក្ដី គេត្រូវដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្ដីព្យាយាមរបស់បុរស ក្នុងសេចក្ដីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារណាដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ជនពាលនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលជនពាលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិត រមែងពិចារណាដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះក៏មែនពិតហើយ តែជាហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ទើបបណ្ឌិតនោះមិនធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិតមិនធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណាជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បុគ្គលរមែងសម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើដោយហេតុ ២ ប្រការ គឺការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ក៏សម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនត្រូវធ្វើ ១

ហេតុណាដែលខ្លួនធ្វើ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ក៏សម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតសម្គាល់នូវហេតុនេះថា ជាហេតុដែលខ្លួនត្រូវធ្វើដោយហេតុ ២ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ ហេតុមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## ឋានសូត្រ

[ ១១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ៥ ដូចតទៅនេះ បទថា **ឋានានិ** បានដល់ ហេតុ ។ បទថា **អនត្ថាយ សំវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បីមិនមែនសេចក្តីចម្រើន ក្នុងពាក្យនេះ គប្បីជ្រាបកុសលកម្មដែលសម្បយុត្តដោយសោមនស្ស ក្នុងបទជាដើមយ៉ាងនេះថា បាបកម្ម មានទុក្ខ មានការបង្កៀតចង្អល់ មានការជីកអណ្តូង ចាប់ត្រី កាត់ជញ្ជាំងរបស់បុគ្គលនោះជាដើម គប្បីជ្រាបថា ជាឋានៈទី ១ ។ ការងារ មានការបោកសំរាមជាដើម និងការងារ មានការបូកលាបបាយ-អ ប្រក់ផ្ទះ បោសទីមិនស្អាតជាដើម សម្រាប់គ្រហស្ថដែលចិញ្ចឹមជីវិតដោយប្រពៃ គប្បីជ្រាបថា ជាឋានៈទី ២ កម្ម មានការផឹកសុរា លាបគ្រឿងក្រអូប និងការប្រដាប់ផ្កាជាដើម និងកម្ម មានបាណាតិបាតជាដើម ដែល

ប្រព្រឹត្តទៅហើយ ដោយអំណាចសេចក្តីត្រេកអរ គប្បីជ្រាបថា ជាឋានៈទី ៣ កុសលកម្មដែលប្រកបដោយសោមនស្ស ក្នុងកិច្ចកម្មជាដើមយ៉ាងនេះ គឺការស្លៀកដណ្តប់សំពត់ស្អាត កាន់យកផ្កា និងគ្រឿងក្រអូបជាដើមទៅក្នុងវេលាស្តាប់ធម៌ ការថ្វាយបង្គំព្រះចេតិយ ការថ្វាយបង្គំដើមពោធិ៍ ការស្តាប់ធម្មកថាដ៏ពីរោះ ការសមាទានសីល ៥ គប្បីជ្រាបថា ជាឋានៈទី ៤ ។ បទថា **បុរិសថាមេ** សេចក្តីថា ក្នុងកម្លាំង គឺញាណរបស់បុរស ។ ក្នុងបទដ៏សេសក៏មានន័យដូច្នេះ ។ល។

## អដ្ឋកថា ឋានសូត្រទី ៥ ចប់

# សុត្តន្តបិដក

## អប្បមាទសូត្រទី ៦

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីធ្វើសេចក្តីមិនប្រមាទ ដោយហេតុ ៤ យ៉ាង ។ ដោយហេតុ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះបង់នូវកាយទុច្ចរិត ចូរចម្រើននូវកាយសុចរិតវិញ ទាំងកុំបីប្រមាទក្នុងកាយសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះបង់នូវវចីទុច្ចរិត ចូរចម្រើននូវវចីសុចរិត

វិញ ទាំងកុំបីធ្វេសប្រហែសក្នុងវចីសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចូរលះបង់នូវមនោទុច្ចរិត ចូរចម្រើននូវមនោសុចរិតវិញ ទាំងកុំបីធ្វេសប្រហែសក្នុងមនោសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមិច្ឆាទិដ្ឋិ ចូរចម្រើននូវសម្មាទិដ្ឋិ ទាំងកុំបីធ្វេសប្រហែសក្នុងសម្មាទិដ្ឋិនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុលះបង់នូវកាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត លះបង់មិច្ឆាទិដ្ឋិ ចម្រើនសម្មាទិដ្ឋិហើយ ភិក្ខុនោះ តែងមិនខ្លាចសេចក្តីស្លាប់ដែលប្រព្រឹត្តទៅក្នុងខាងមុខ ។

# អដ្ឋកថា

## អប្បមាទសូត្រ

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បមាទសូត្រទី ៦ ដូចតទៅនេះ បទថា **យតោ ខោ** គឺកាលណា ។ បទថា **សម្បរាយិកស្ស** នោះ ត្រឹមតែជាទេសនា ។ តែព្រះវីណាស្រេព មិនខ្លាចចំពោះការស្លាប់ដែលមានមកក្នុងកាលខាងមុខ និងមិនខ្លាចចំពោះការស្លាប់ ដែលមានក្នុងបច្ចុប្បន្ន ព្រះវីណាស្រេពនោះ លោកបំណងយកក្នុងទីនេះ តែអាចារ្យពួកខ្លះពោលថា

លោកបំណាងយកព្រះអរិយៈទាំងឡាយទាំងពួង តាំងអំពីព្រះសោតាបន្ន ព្រោះព្រះបាលីថា **សម្មាទិដ្ឋិ ភាវិតា** ចម្រើនសម្មាទិដ្ឋិហើយ ។

### អដ្ឋកថា អប្បមាទសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អារក្ខសូត្រទី ៧

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ សេចក្ដីមិនប្រមាទ គឺការថែរក្សាចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនក្នុងហេតុ ៤ យ៉ាង ។ ហេតុ ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺសេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញកុំត្រេកត្រអាលទៅ ក្នុងធម៌ទាំងឡាយ ដែលគួរត្រេកត្រអាលឡើយ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ ដែលបុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញ កុំប្រទូស្តក្នុងធម៌ទាំងឡាយ ដែលគួរប្រទូស្តឡើយ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សានូវចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញកុំភ័ន្តច្រឡំក្នុងធម៌ទាំងឡាយ ដែលគួរភ័ន្តច្រឡំ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ បុគ្គល

គួរធ្វើតាមសមគួរដល់ខ្លួនថា អាត្មាអញកុំស្រើនក្នុងធម៌ទាំងឡាយ ដែលគួរស្រើនឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុមានចិត្តមិនត្រេកអរក្នុងធម៌ដែលគួរត្រេកអរ ព្រោះប្រាសចាករាគៈ មានចិត្តមិនប្រទូស្តក្នុងធម៌ដែលគួរប្រទូស្ត ព្រោះប្រាសចាកទោសៈ មានចិត្តមិនវង្វេងក្នុងធម៌ដែលគួរវង្វេង ព្រោះប្រាសចាកមោហៈ មានចិត្តមិនស្រើនក្នុងធម៌ដែលគួរស្រើន ព្រោះប្រាសចាកសេចក្តីស្រើន ភិក្ខុនោះមិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនដល់នូវសេចក្តីតក់ស្លុត ទាំងមិនប្រព្រឹត្តទៅ ព្រោះហេតុតែពាក្យរបស់សមណៈ ។

# អដ្ឋកថា

## អារក្ខសូត្រ

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអារក្ខសូត្រទី ៧ ដូចតទៅនេះ បទថា **អត្តរូបេន** បានដល់ តាមអនុរូប គឺតាមគួរដល់ខ្លួន អធិប្បាយថា តាមសេចក្តីប្រាថ្នាប្រយោជន៍ ។ បទថា **រជនីយេសុ** សេចក្តីថា ក្នុងធម៌ជាបច្ច័យនៃរាគៈ ។ បទថា **ធម្មេសុ** សេចក្តីថា ក្នុងសភាវៈ គឺអារម្មណ៍ដែលគួរប្រាថ្នា ។ ន័យក្នុងបទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។ បទថា **ឆម្ភតិ** សេចក្តីថា រមែងមិនតក់ស្លុតដោយអំណាចទិដ្ឋិ ។ ក្នុងបទដ៏សេស ក៏មានន័យ

ដូច្នេះ ។ បទថា **ឆ ច បឆ សមណាវចឆហោតុបិ គច្ឆតិ** សេចក្តីថា រមែងមិនវៀច សូម្បីព្រោះហេតុនៃពាក្យរបស់សមណៈ អ្នកពោលវាទៈដែលជាបរបក្ខ គឺមិនលះទិដ្ឋិរបស់ខ្លួន ហើយវៀចទៅដោយអំណាចទិដ្ឋិរបស់សមណៈទាំងនោះ ។ ក្នុងទីនេះ ក៏បំណងយកព្រះខីណាស្រពប៉ុណ្ណោះ ។៚

**អដ្ឋកថា អារក្ខសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សំវេជនីយសូត្រទី ៨

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធាគួរឃើញ គួរសង្វេគនេះមាន ៤ យ៉ាង ។ ហេតុ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសង្វេគថា ព្រះតថាគតកើតក្នុងលោកនេះហើយដូច្នេះ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសង្វេគថា ព្រះតថាគតត្រាស់ដឹងចំពោះនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោកនេះហើយដូច្នេះ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសង្វេគថា ព្រះតថាគតញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅក្នុងលោកនេះហើយដូច្នេះ ១ ម្នាលភិក្ខុ

*ទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសង្វេគថា ព្រះតថាគតទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងលោកនេះហើយ ដូច្នេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសង្វេគ មាន ៤ យ៉ាងនេះ ។*

# អដ្ឋកថា

## សំវេជនីយសូត្រ

*[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំវេជនីយសូត្រទី ៨ ដូចតទៅនេះ បទថា* **ទស្សនីយានិ** *ប្រែថា ដែលគួរឃើញ ។ បទថា* **សំវេជនីយានិ** *បានដល់ ទីដែលឲ្យកើតសេចក្ដីសង្វេគ ។*

**អដ្ឋកថា សំវេជនីយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមភយសូត្រទី ៩ និងទុតិយភយសូត្រទី ១០

*[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺជាតិភ័យ ១ ជរាភ័យ ១ ព្យាធិភ័យ ១ មរណភ័យ*

១ ។ ម្នាលភិក្ខុទាំងឡាយ ភ័យមាន ៤ យ៉ាងនេះឯង ។

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាងដូចម្ដេចខ្លះ ។ គឺអគ្គិភ័យ ១ ឧទកភ័យ ១ រាជភ័យ ១ ចោរភ័យ ១ ។ ម្នាល ភិក្ខុទាំងឡាយ ភ័យមាន ៤ យ៉ាងនេះឯង ។

កេសីវគ្គទី ២ ចប់

## ឧទ្ទាននៃកេសីវគ្គនោះ គឺ

និយាយអំពីសារថី អ្នកបង្ហាត់សេះឈ្មោះកេសី ១ អំពីសទ្ទុះ ១ អំពី ជនូញ ១ អំពីដំរីដ៏ប្រសើរ ១ អំពីហេតុជាគម្រប់ប្រាំ ១ អំពីសេចក្ដី មិនប្រមាទ គឺការថែរក្សាចិត្តដោយសតិ ១ អំពីហេតុ ដែលគួរសង្វេគ ១ អំពីភ័យមានពីរលើក ។

# អដ្ឋកថា

## បឋមភយសូត្រ និងទុតិយភយសូត្រ

[ ១១៩-១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមភយសូត្រទី ៩ ដូចតទៅនេះថា ភ័យដែលប្រារព្ធជាតិកើតឡើង ឈ្មោះថា **ជាតិភយ** ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

**អដ្ឋកថា បឋមភយសូត្រទី ៩-១០ ចប់**

**អដ្ឋកថា កេសីវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ភយវគ្គទី ៣

### បឋមភយសូត្រទី ១

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាង ដូចម្តេចខ្លះ ។ គឺអត្តានុវាទភ័យ ( ភ័យអំពីការតិះដៀលខ្លួនឯង ) ១ បរានុវាទភ័យ ( ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ) ១ ទណ្ឌភ័យ ( ភ័យអំពីទណ្ឌកម្ម ) ១ ទុគ្គតិភ័យ ( ភ័យអំពីទុគ្គតិ គឺអបាយទាំងបួន ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអត្តានុវាទភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាដូច្នេះថា ប្រសិនបើខ្លួនអញប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តើខ្លួនអញ នឹងមិនតិះដៀលខ្លួនឯងព្រោះសីលទេឬ បុគ្គលនោះក៏ខ្លាចចំពោះភ័យដែលកើតឡើងអំពីការតិះដៀលខ្លួនឯង ហើយលះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅអត្តានុវាទភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរានុវាទភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាដូច្នេះថា ប្រសិនបើអញ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តើបុគ្គលដទៃ នឹងមិនតិះដៀលខ្លួនអញព្រោះសីលទេឬ បុគ្គល

នោះក៏ខ្លាចចំពោះភ័យ ដែលកើតឡើងអំពីការតិះដៀលរបស់បុគ្គលដទៃ ហើយលះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បរានុវាទភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះទណ្ឌភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ឃើញព្រះរាជាទាំងឡាយ កំពុងចាប់ចោរប្រព្រឹត្តអាក្រក់ ហើយត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ មានប្រការផ្សេងៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយដំបងវែងខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើនូវពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំង ដាក់ទឹកជ្រក់ខ្លះ ធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចិរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេដ្កក់មាត់ដោយកាង ឬសន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្ទូចសរីរៈ

ប្រមាណប៉ុនកហាបណៈមួយៗ ខ្លះ ធ្វើនូវខារាបដិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើនូវបលិឃបរិវត្តកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងកំពុងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ បុគ្គលនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះរាជាទាំងឡាយកំពុងចាប់ចោរ ដែលប្រព្រឹត្តអាក្រក់ ហើយត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍មានប្រការផ្សេងៗ គឺវាយដោយរំពាត់ខ្លះ ។បេ។ កាត់ក្បាលដោយដាវខ្លះ ព្រោះហេតុនៃកម្មដ៏លាមកមានសភាពយ៉ាងណា ប្រសិនបើអញ ធ្វើនូវកម្មដ៏លាមក មានសភាពយ៉ាងនោះដែរ មុខជាព្រះរាជាទាំងឡាយចាប់ខ្លួនអញ ហើយធ្វើកម្មករណ៍ មានប្រការផ្សេងៗ យ៉ាងនោះមិនខាន គឺវាយដោយរំពាត់ខ្លះ ។បេ។ កាត់ក្បាលដោយដាវខ្លះ បុគ្គលនោះក៏ខ្លាចចំពោះភ័យដែលកើតឡើងអំពីទណ្ឌកម្ម ហើយក៏លែងប្រព្រឹត្តប្លន់ដណ្តើមយកទ្រព្យជាដើមទុនរបស់បុគ្គលដទៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទណ្ឌភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះទុគ្គតិភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាដូច្នេះថា កាយទុច្ចរិត មានផលអាក្រក់ក្នុងលោកខាងមុខ វចីទុច្ចរិតមានផលអាក្រក់ក្នុងលោកខាងមុខ មនោទុច្ចរិតមានផលអាក្រក់ក្នុងលោកខាងមុខ ប្រសិនបើអញ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិត

ដោយចិត្ត លុះអាត្មាអញបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះអំពើនោះពុំខានឡើយ បុគ្គលនោះក៏ខ្លាចចំពោះ ភ័យ ដែលកើតឡើងអំពីទុគ្គតិ ហើយក៏លះបង់កាយទុច្ចរិត ចម្រើនកាយ សុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើន មនោសុចរិត ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅ ថាទុគ្គតិភ័យ ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

# ភយវគ្គទី ៣

## បឋមភយសូត្រ

[ ១២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមភយសូត្រទី ១ នៃភយវគ្គទី ៣ ដូចតទៅ បទថា **អត្តានុវាទភយំ** បានដល់ ភ័យកើតឡើងដល់បុគ្គលដែលតិះដៀលខ្លួន ។ បទថា **បរានុវាទភយំ** បានដល់ ភ័យកើតអំពីការតិះដៀលរបស់អ្នកដទៃ ។ បទថា **ទណ្ឌភយំ** បានដល់ ភ័យកើតព្រោះអាស្រ័យកម្មករណ៍ ៣២ ។ បទថា **ទុគ្គតិភយំ** បានដល់ ភ័យដែលកើតព្រោះអាស្រ័យអបាយ ៤ ។ ក្នុងពាក្យជាដើមថា **ឥធំ វុច្ចតិ ភិក្ខវេ អត្តា-នុវាទភយំ** ជាបឋម ហិរិខាងក្នុងរមែងកើតឡើងដល់អ្នកពិចារណាឃើញអត្តានុវាទភ័យ ហិរិនោះរមែងញ៉ាំងនូវការសង្រួមឲ្យកើតក្នុងទ្វារ ៣ របស់បុគ្គលនោះ ការសង្រួមក្នុងទ្វារ ៣ ចាត់ជាចតុប្បារិសុទ្ធិសីល លោកតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះហើយ ចម្រើនវិបស្សនា រមែងតាំងនៅក្នុងអគ្គផល ។ ឯឱត្តប្បៈខាងក្រៅ រមែងកើតឡើងដល់បុគ្គលពិចារណាឃើញបរានុវាទភ័យ និងទណ្ឌភ័យ ឱត្តប្បៈនោះរមែងញ៉ាំងសេចក្ដីសង្រួមឲ្យកើតក្នុងទ្វារ ៣ របស់បុគ្គលនោះ ។ ការសង្រួមក្នុងទ្វារ ៣ ចាត់ជាចតុប្បា-រិសុទ្ធិសីល ។ លោកតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះហើយ ចម្រើនវិបស្សនា រមែងតាំងនៅក្នុងអគ្គផល ។ ហិរិខាងក្នុង រមែងកើតឡើងដល់

បុគ្គលដែលពិចារណាឃើញទុគ្គតិភ័យ ហិរិនោះ រមែងញ៉ាំងនូវការសង្រួមឲ្យកើតក្នុងទ្វារ ៣ របស់បុគ្គលនោះ ។ ការសង្រួមក្នុងទ្វារ ៣ ចាត់ជាចតុប្បារិសុទ្ធិសីល ។ លោកតាំងនៅចតុប្បារិសុទ្ធិសីលនោះហើយ ចម្រើនវិបស្សនា ចម្រើនវិបស្សនា រមែងតាំងនៅក្នុងអគ្គផល ។

**អដ្ឋកថា បឋមភយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយភយសូត្រទី ២

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង រមែងមានប្រាកដដល់បុគ្គលកាលចុះទឹក ។ ភ័យ ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺឩមិភ័យ ( ភ័យអំពីរលកទឹក ) ១ កុម្ភីលភ័យ ( ភ័យអំពីក្រពើ ) ១ អាវដ្ដភ័យ ( ភ័យអំពីទឹកក្ដួចវិលវល់ ) ១ សុសុកាភ័យ ( ភ័យអំពីត្រីកាច ) ១ ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង រមែងមានប្រាកដដល់បុគ្គលកាលចុះទឹក ។ ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង រមែងមានប្រាកដដល់កុលបុត្តខ្លះ ក្នុងលោកនេះ ដែលមានសទ្ធាក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួសក៏យ៉ាងនោះដែរ ។ ភ័យ ៤ យ៉ាង ដូចម្ដេចខ្លះ ។

គឺឩមិភ័យ ១ កុម្ភីលភ័យ ១ អាវដភ័យ ១ សុសុកាភ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះឩមិភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រខ្លះក្នុងលោកនេះ មានសទ្ធា ចេញចាកផ្ទះចូលកាន់ផ្នួស ដោយគិតថា អញតែងត្រូវជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ ពួកសព្រហ្មចារីក៏ទូន្មានប្រៀនប្រដៅនូវកុលបុត្រ ដែលបួសដោយប្រការដូច្នោះនោះថា អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ អ្នកត្រូវងាកមើលទិសផ្សេងៗ យ៉ាងនេះ អ្នកត្រូវបត់អវយវៈយ៉ាងនេះ អ្នកត្រូវលាអវយវៈយ៉ាងនេះ អ្នកត្រូវប្រើប្រាស់សង្ឃាដិ បាត្រ និងចីវរយ៉ាងនេះ ។ កុលបុត្រនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ ក៏ធ្លាប់ទូន្មានប្រៀនប្រដៅបុគ្គលដទៃដែរ គួរបើដែរលោកទាំងនេះ ( មានជំនាន់ ) ប្រហែលត្រឹមតែកូន ត្រឹមតែចៅរបស់យើងប៉ុណ្ណោះ មកសម្គាល់នូវយើងថាជាបុគ្គលគួរទូន្មាន គួរប្រៀនប្រដៅវិញ ។ កុលបុត្រនោះ ក៏ខឹងអាក់អន់ចិត្ត លាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីរលកហើយលាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីរលកនេះឯង ជាឈ្មោះនៃសេចក្តីក្រោធ និងសេចក្តីចង្អៀត

ចង្អល់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧម្មិភ័យ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះកុម្ភីលភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រខ្លះក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួស ដោយគិតថា អញតែងត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀនដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុត នៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ ពួកសព្រហ្មចារីក៏ទូន្មានប្រៀនប្រដៅកុលបុត្រ ដែលបួសដោយប្រការដូច្នោះនោះថា របស់នេះអ្នកគួរទំពាស៊ី របស់នេះអ្នកមិនគួរទំពាស៊ី របស់នេះអ្នកគួរបរិភោគ របស់នេះអ្នកមិនគួរបរិភោគ របស់នេះអ្នកគួរជញ្ជាបជញ្ជក់ របស់នេះអ្នកមិនគួរជញ្ជាបជញ្ជក់ របស់នេះអ្នកគួរផឹក របស់នេះអ្នកមិនគួរផឹក របស់ដែលគួរ អ្នកគប្បីទំពាស៊ី របស់ដែលមិនគួរ អ្នកមិនគប្បីទំពាស៊ី របស់ដែលគួរ អ្នកគប្បីបរិភោគ របស់ដែលមិនគួរ អ្នកមិនគប្បីបរិភោគ របស់ដែលគួរ អ្នកគប្បីជញ្ជាបជញ្ជក់ របស់ដែលមិនគួរ អ្នកមិនគប្បីជញ្ជាបជញ្ជក់ របស់ដែលគួរ អ្នកគប្បីផឹក របស់ដែលមិនគួរ អ្នកមិនគប្បីផឹក អ្នកគួរទំពាស៊ីតែក្នុងកាលគួរ អ្នកមិនគួរទំពាស៊ីក្នុងកាលមិនគួរ អ្នកគួរបរិភោគតែក្នុងកាលគួរ អ្នកមិនគួរបរិភោគក្នុងកាលមិនគួរ អ្នកគួរជញ្ជាបជញ្ជក់តែក្នុងកាលគួរ អ្នកមិនគួរជញ្ជាបជញ្ជក់ក្នុងកាលមិនគួរ អ្នកគួរផឹកតែក្នុងកាលគួរ អ្នកមិនគួរផឹកក្នុងកាលមិនគួរទេ ។ កុលបុត្រនោះមានសេចក្តីត្រិះរិះយ៉ាង

នេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ ( បើ ) ចង់របស់ណា ក៏ទំពាស៊ីរបស់នោះ មិនចង់របស់ណា មិនទំពាស៊ីរបស់នោះទេ ចង់របស់ណា ក៏បរិភោគរបស់នោះ មិនចង់របស់ណា ក៏មិនបរិភោគរបស់នោះទេ ចង់របស់ណា ក៏ជញ្ជាបជញ្ជក់របស់នោះ មិនចង់របស់ណា ក៏មិនជញ្ជាបជញ្ជក់របស់នោះ ចង់ទឹកណា ក៏ផឹកទឹកនោះ មិនចង់ទឹកណា ក៏មិនផឹកទឹកនោះ តែងទំពាស៊ីរបស់ដែលគួរក៏បាន ទំពាស៊ីរបស់ដែលមិនគួរក៏បាន បរិភោគភោជនដែលគួរក៏បាន បរិភោគភោជនដែលមិនគួរក៏បាន ជញ្ជាបជញ្ជក់របស់ដែលគួរក៏បាន ជញ្ជាបជញ្ជក់របស់ដែលមិនគួរក៏បាន ផឹកទឹកដែលគួរក៏បាន ផឹកទឹកដែលមិនគួរក៏បាន ទំពាស៊ីក្នុងកាលគួរក៏បាន ទំពាស៊ីក្នុងកាលមិនគួរក៏បាន បរិភោគក្នុងកាលគួរក៏បាន បរិភោគក្នុងកាលមិនគួរក៏បាន ជញ្ជាបជញ្ជក់ក្នុងកាលគួរក៏បាន ជញ្ជាបជញ្ជក់ក្នុងកាលមិនគួរក៏បាន ផឹកក្នុងកាលគួរក៏បាន ផឹកក្នុងកាលមិនគួរក៏បាន ពួកគហបតីដែលមានសទ្ធាធ្លាប់ឲ្យខាទនីយភោជនីយាហារដ៏ឧត្តមណា ដល់យើងក្នុងវេលាថ្ងៃជាកាលមិនគួរ ឥឡូវនេះ លោកទាំងនេះធ្វើទំនងដូចជាបិទមាត់ ( អញ ) ចំពោះខាទនីយភោជនីយាហារ ( របស់គហបតី ) ទាំងនោះ ។ កុលបុត្រនោះក៏ខឹងអាក់អន់ចិត្តហើយ លាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីក្រពើ ហើយលាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពី

ក្រពើនេះឯង ជាឈ្មោះនៃសេចក្តីប្រាថ្នាអាហារចម្អែតពោះ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា កុម្ភីលភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាវដ្ដភ័យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រខ្លះ ក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួស ដោយគិតថា អញត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀន ដូចម្ដេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កាលបុគ្គលនោះបួសយ៉ាងនេះ ក៏ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ដោយមិនសង្រួមកាយ មិនសង្រួមវាចា មិនសង្រួមចិត្ត មិនផ្ចង់ស្មារតី មិនសង្រួមឥន្ទ្រិយ កុលបុត្រនោះឃើញគហបតីក្តី កូនគហបតីក្តី ដែលឆ្អែតស្កប់ស្កល់ ព្រមព្រៀង មូលមិត្តដោយកាមគុណទាំង ៥ ក្នុងស្រុក ឬនិគមនោះ កុលបុត្រនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ ជាអ្នកធ្លាប់ឆ្អែតស្កប់ស្កល់ ព្រមព្រៀង មូលមិត្តដោយកាមគុណទាំង ៥ ដែរ ទាំងភោគសម្បត្តិក្នុងត្រកូលរបស់អញ ក៏មានគ្រប់គ្រាន់ អញអាចនឹងប្រើប្រាស់ភោគសម្បត្តិបានផងនឹងធ្វើនូវបុណ្យក៏បានផង បើដូច្នោះ គួរតែអញលាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ហើយប្រើប្រាស់ភោគសម្បត្តិផង ធ្វើបុណ្យផង ។ កុលបុត្រនោះក៏លាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ

នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីទឹកក្ខួចវិល ហើយលាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីទឹកក្ខួចវិលនេះឯង ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអាវដភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះសុសុកាភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រខ្លះ ក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួស ដោយគិតថា អញត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួលទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ត្រូវទុក្ខបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កាលកុលបុត្រនោះបួសយ៉ាងនេះ ក៏ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ដោយមិនរក្សាកាយ មិនរក្សាវាចា មិនរក្សាចិត្ត មិនផ្ចង់ស្មារតីមិនសង្រួមឥន្ទ្រិយ កុលបុត្រនោះឃើញមាតុគ្រាម ដែលស្លៀកមិនស្រួល ឬដណ្តប់មិនស្រួល លុះកុលបុត្រនោះឃើញមាតុគ្រាមដែលស្លៀកមិនស្រួលដណ្តប់មិនស្រួលហើយ ក៏មានចិត្តត្រូវរាគៈកម្សួលឡើង កាលកុលបុត្រនោះមានចិត្តត្រូវរាគៈកម្សួលឡើងហើយ ក៏លាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីត្រីកាចហើយលាសិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយពាក្យថា ភ័យអំពីត្រីកាចនេះ ជាឈ្មោះនៃមាតុគ្រាម ។ ម្នាលភិក្ខុទាំងឡាយ

នេះហៅថាសុសុកាភ័យ ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង រមែងមានប្រាកដដល់កុលបុត្រខ្លះ ក្នុងលោកនេះ ដែលមានសទ្ធាក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ។

# អដ្ឋកថា

## ទុតិយភយសូត្រ

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយភយសូត្រទី ២ ដូចតទៅនេះ បទថា **ឧទកោរោហន្តស្ស** គឺបុគ្គលដែលចុះកាន់ទឹក ។ បទថា **ចាដិកង្ខិតព្វានិ** បានដល់ គប្បីប្រាថ្នា ។ បទថា **សុសុកាភយំ** បានដល់ ភ័យ គឺត្រីកាច ។ បទថា **មុខាវរណំ មញ្ញេ ករោន្តិ** សេចក្តីថា ភិក្ខុទាំងនេះរមែងធ្វើដូចបិទមាត់ ។ បទថា **ឱទរិកត្តស្ស** ប្រែថា របស់បុគ្គលស៊ីច្រើន ព្រោះមានពោះធំ ។ ក្នុងបទថា **អរក្ខិតេនេវ កាយេន** ជាដើម គប្បីជ្រាបអត្ថដូច្នេះ លោកមានកាយមិនរក្សាហើយ ព្រោះមិនមានការសង្រួម ៣ យ៉ាង ក្នុងកាយទ្វារ មានវាចាមិនរក្សាហើយ ព្រោះមិនមានការសង្រួម ៤ យ៉ាងក្នុងវចីទ្វារ ៕

### អដ្ឋកថាទុតិយភយសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមជ្ឈានសូត្រទី ៣

[ ១២៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ក៏បានដល់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រាន្តនៅ ។ កុលបុត្រនោះ ក៏ត្រេកអរនឹងបឋមជ្ឈាននោះ ស្រឡាញ់បឋមជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរ ដោយបឋមជ្ឈាននោះ ស្ថិតនៅក្នុងបឋមជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងបឋមជ្ឈាននោះ ជាអ្នកនៅច្រើនដោយបឋមជ្ឈាននោះ មិនបានសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកព្រហ្មកាយិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកព្រហ្មកាយិកទេវតា ប្រមាណ ១ កប្ប ព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះមានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជននោះ ញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា ក៏ញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះសេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នា

របស់អរិយសាវក ដែលមានសេចក្ដីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្ដីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ បានដល់ទុតិយជ្ឈាន ជាធម្មជាតិកើតមានក្នុងសន្ដានចិត្តប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កមិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈានព្រោះរម្ងាប់វិតក្ក និងវិចារ សម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងទុតិយជ្ឈាននោះ ស្រឡាញ់ទុតិយជ្ឈាននោះ ដល់នូវសេចក្ដីត្រេកអរដោយទុតិយជ្ឈាននោះ ស្ថិតនៅក្នុងទុតិយជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងទុតិយជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងទុតិយជ្ឈាននោះ មិនបានសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតា ជាន់អាភស្សរៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់អាភស្សរៈប្រមាណ ២ កប្ប ព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញ៉ាំងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ក៏ស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញ៉ាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្ដង ។ ម្នាលភិក្ខុទាំងឡាយ នេះ

សេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ព្រោះនឿយណាយចាកបីតិផង ជាបុគ្គលព្រងើយកន្តើយផង មានស្មារតីដឹងខ្លួនផង បានទូវសុខដោយនាមកាយផង រមែងបានដល់នូវតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន ជាអ្នកព្រងើយកន្តើយ មានស្មារតីនៅជាសុខ ។ បុគ្គលនោះ ក៏ត្រេកអរនឹងតតិយជ្ឈាននោះ ស្រឡាញ់តតិយជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរ ដោយតតិយជ្ឈាននោះ ស្ថិតនៅក្នុងតតិយជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងតតិយជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងតតិយជ្ឈាននោះ មិនសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ ក៏ទៅកើតជាមួយនឹងពួកទេវតា ជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់សុភកិណ្ហៈ ប្រមាណ ៤ កប្ប ព្រហ្មបុថុជ្ជន ស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ពួកទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ស្ថិតនៅក្នុងទីនោះដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ពួកទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែង

បរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះសេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ដែលមិនមានសុខ មិនមានទុក្ខ មានតែសតិដ៏បរិសុទ្ធ កើតអំពីឧបេក្ខា សម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងចតុត្ថជ្ឈាននោះ ស្រឡាញ់ចតុត្ថជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរដោយចតុត្ថជ្ឈាននោះ ស្ថិតនៅក្នុងចតុត្ថជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងចតុត្ថជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងចតុត្ថជ្ឈាននោះ មិនបានសាបសូន្យចាកឈានលុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតា ជាន់វេហប្ផលៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់វេហប្ផលៈ ប្រមាណប្រាំរយកប្បព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគស្ថិតនៅក្នុងទីនោះដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ

ក៏រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវកដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## បឋមជ្ឈានសូត្រ

[ ១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមជ្ឈានសូត្រទី ៣ ដូចតទៅនេះ បទថា **តទស្សាទេតិ** សេចក្តីថា រមែងជាប់ចិត្តក្នុងឈាននោះ ដោយជាប់ចិត្តក្នុងសុខ ។ បទថា **និកាមេតិ** ប្រែថា នៅប្រាថ្នានៅឡើយ ។ បទថា **វិត្តឹ អាបជ្ជតិ** គឺដល់នូវការត្រេកអរ ។ បទថា **តទធិមុត្តោ** គឺដោតចិត្តក្នុងឈាននោះ ឬបង្អោនចិត្តទៅកាន់ឈាននោះ ។ បទថា **តព្ពហុលវិហារី** បានដល់ ច្រើនដោយឈាននោះ ។ បទថា **សហព្យតំ ឧបបជ្ជតិ** សេចក្តីថា រមែងទៅនៅរួមគ្នា គឺរមែងកើតក្នុងទេវតាជាន់វេហប្ផលានោះ ។

ក្នុងបទថា **កប្បោ អាយុប្បមាណំ** នេះ បឋមជ្ឈានមានទាប កណ្តាល និងប្រណីត ។ ក្នុងបឋមជ្ឈាននោះ ចំណែកទី ៣ នៃកប្ប ជា

ប្រមាណអាយុរបស់ទេវតា ដែលកើតឡើងដោយបឋមជ្ឈានជាន់ទាប ពាក់កណ្តាលកប្បជាអាយុរបស់ទេវតា ដែលកើតឡើងដោយបឋមជ្ឈានថ្នាក់កណ្តាល មួយកប្ប ជាអាយុរបស់ទេវតាដែលកើតឡើង ដោយបឋមជ្ឈានប្រណីត ។ លោកពោលពាក្យនេះ សំដៅដល់សេចក្តីនោះ ។ បទថា **និរយំបិ គច្ឆតិ** សេចក្តីថា បុគ្គលដែលនៅជាបុថុជ្ជន រមែងវិលវល់ព្រោះកម្មដែលត្រូវទៅនរក បុគ្គលនោះមិនទាន់លះបាន តែមិនមែនតជាប់គ្នា ។ បទថា **តស្មឹយេវ ភវេ បរិនិព្វាយតិ** សេចក្តីថា សាវករបស់ព្រះមានព្រះភាគនៅក្នុងរូបភពនោះហើយ តែងបរិនិព្វាន នឹងមិនធ្លាក់ទៅខាងក្រោម ។ បទថា **យទិទំ គតិយា ឧបបត្តិយា សតិ** សេចក្តីថា កាល គតិកើតឡើង មានអធិប្បាយថា អរិយសាវកដែលជាព្រះសេក្ខៈ មិនធ្លាក់ដោយអំណាចបដិសន្ធិបរិនិព្វានក្នុងរូបភពនោះឯង គឺក្នុងព្រហ្មលោកខ្ពស់ឡើងទៅ ព្រោះទុតិយជ្ឈានជាដើមណាមួយ ឯបុថុជ្ជន រមែងទៅនរកជាដើមបាន នេះជាហេតុផ្សេងគ្នា ។

ក្នុងបទថា **ទ្វេ កប្បា** នេះ ទុតិយជ្ឈានក៏មាន ៣ យ៉ាង ដោយន័យដែលពោលហើយនោះឯង ។ ក្នុងទុតិយជ្ឈាននោះ ៨ កប្ប ជាប្រមាណអាយុរបស់ទេវតាដែលកើតដោយទុតិយជ្ឈានប្រណីត ៤ កប្ប ដោយទុតិយជ្ឈានថ្នាក់កណ្តាល ២ កប្បដោយទុតិយជ្ឈានថ្នាក់ទាប លោកពោលពាក្យនេះសំដៅដល់សេចក្តីនោះ ។ ក្នុងបទថា **ចត្តារោ កប្បា** នេះ គប្បីនាំពាក្យដែលពោលខាងដើមថា **កប្បោ ទ្វេ កប្បា** ដូច្នេះ មកអធិប្បាយក៏ជ្រាប

*បាន ។ បទថា* **កប្បោ** *ជាឈ្មោះនៃការគុណ ៤ ដង ព្រោះដូច្នោះ គប្បី ឃើញអត្ថក្នុងសេចក្តីនេះ ដូច្នេះថា ១ កប្ប ២ កប្ប ៤ កប្ប ។ អធិប្បាយថា កប្បណាដែលលោកពោលហើយដំបូង រាប់កប្បនោះ ២ ដង យក ១ គុណ ត្រូវជា ២ កប្ប យក ២ គុណត្រូវជា ៤ កប្ប ។ ក្នុង ៤ កប្បនោះ យក ២ គុណនឹង ៤ កប្ប ព្រោះដូច្នោះ ត្រូវជា ៨ កប្ប ហើយគុណនឹង ២ ត្រូវជា ១៦ កប្ប ៣២ កប្ប ៦៤ កប្ប គប្បីជ្រាបថា ៦៤ កប្ប លោកកាន់យកដោយអំណាចឈានដែលប្រណីតក្នុងទីនេះយ៉ាងនេះ ។ បទថា* **បញ្ចកប្បសតានិ** *លោកពោលដោយអំណាចការកើតឡើងនៃឈានដែលប្រណីតទាំងនោះ ម្យ៉ាងទៀត ប្រមាណអាយុទាំងនេះក្នុងវេហប្ផលាព្រោះព្រហ្មលោក ១ ជាន់ ៣ មិនមាន ដូចក្នុងបឋមជ្ឈានភូមិជាដើម ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។*

## **អដ្ឋកថាបឋមជ្ឈានសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយជ្ឈានសូត្រទី ៤

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ បានដល់បឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខ កើតអំពីសេចក្តីស្ងាប់ស្ងាត់ សម្រាន្តនៅ ។ ធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនោះ បុគ្គលនោះ ក៏ពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថាមិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនរបស់ខ្លួន បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ ( ការកើត ) មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បានដល់ចតុត្ថជ្ឈាន សម្រាន្តនៅ ។ ធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មាននៅក្នុងលោកនោះ បុគ្គលនោះ ក៏ពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថាមិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជា

អាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនជារបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## ទុតិយជ្ឈានសូត្រ

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយជ្ឈានសូត្រទី ៤ ដូចតទៅនេះ រូបនោះឯង ឈ្មោះថា រូប ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ក្នុងបទជាដើមថា **អនិច្ចតោ** មានវិនិច្ឆ័យថា បុគ្គលនោះពិចារណាឃើញធម៌ទាំងនោះជារបស់មិនទៀង ដោយអត្ថថា មានហើយ ទៅជាមិនមាន ។ ពាក្យថា **រោគ** ដោយអត្ថថា ឈឺចាប់ ពាក្យថា **គណ្ឌតោ** ដោយអត្ថថា ប្រទូស្តខាងក្នុង ពាក្យថា **សល្លតោ** ដោយអត្ថថា ចាក់ទម្លុះចូលទៅ ពាក្យថា **អឃតោ** ដោយអត្ថថា ប្រកបដោយទុក្ខ ពាក្យថា **អាពាធតោ** ដោយអត្ថថា គ្រប់សង្កត់ ពាក្យថា **បរតោ** ដោយអត្ថថា មិនស្តាប់បង្គាប់ ពាក្យថា **បលោកតោ** ដោយអត្ថថា វិនាសទៅ ពាក្យថា **សុញ្ញតោ** ដោយអត្ថ

ថា មិនមែនសត្វ ពាក្យថា **អនត្តតោ** ដោយអត្ថថា មិនទៅក្នុងអំណាច ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបថា លោកពោលអនិច្ចលក្ខណៈ ដោយ ២ បទថា **អនិច្ចតោ បលោកតោ** ។ លោកពោលអនត្តលក្ខណៈ ដោយ ២ បទថា **សុញ្ញតោ អនត្តតោ** ។ លោកពោលទុក្ខលក្ខណៈ ដោយបទដែលសល់ ។ បទថា **សមនុបស្សតិ** គឺពិចារណាឃើញដោយឈាន ។ បុគ្គលកាលលើកបញ្ចក្ខន្ធឡើងកាន់ត្រៃលក្ខណ៍ ពិចារណាឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវមគ្គ ៣ ផល ៣ ។ បទថា **សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ** សេចក្ដីថា បុគ្គលតាំងនៅក្នុងជាន់សុទ្ធាវាសនោះ ត្រូវចម្រើនចតុត្ថជ្ឈាន ហើយ ទើបកើតឡើង ។l៚

អដ្ឋកថា ទុតិយជ្ឈានសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមមេត្តាសូត្រទី ៥

[ ១២៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុង លោក ។ បុគ្គល ៤ ពួក ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិស

ទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំ ទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងមេត្តានោះ ស្រឡាញ់មេត្តានោះ ដល់នូវសេចក្តីត្រេកអរដោយមេត្តានោះ ស្ថិតនៅក្នុងមេត្តានោះ មានចិត្តចុះស៊ប់ក្នុងមេត្តានោះ ជាអ្នកនៅដោយច្រើនដោយមេត្តានោះ មិនបានសាបសូន្យចាកមេត្តា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកព្រហ្មកាយិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកព្រហ្មកាយិកទេវតា មានប្រមាណ ១ កប្ប ព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ក៏ស្ថិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះ

ដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗគ្នា មានចិត្តប្រកបដោយករុណាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងករុណានោះ ស្រឡាញ់ករុណានោះ ដល់នូវសេចក្តីត្រេកអរដោយករុណានោះ ស្ថិតនៅក្នុងករុណានោះ មានចិត្តចុះស៊ប់ក្នុងករុណានោះ ជាអ្នកនៅដោយច្រើនដោយករុណានោះ មិនបានសាបសូន្យចាកករុណា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់អាភស្សរៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់អាភស្សរៈមានប្រមាណ ២ កប្ប ព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុ

ទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយមុទិតាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា មានចិត្តប្រកបដោយមុទិតាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងមុទិតានោះ ស្រឡាញ់មុទិតានោះ ដល់នូវសេចក្តីត្រេកអរដោយមុទិតានោះ ស្ថិតនៅក្នុងមុទិតានោះ មានចិត្តចុះស៊ប់ក្នុងមុទិតានោះ ជាអ្នកនៅច្រើនដោយមុទិតានោះ មិនបានសាបសូន្យចាកមុទិតា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់សុភកិណ្ហៈ មានប្រមាណ ៤ កប្ប បុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់

ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងនោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងឧបេក្ខានោះ ស្រឡាញ់ឧបេក្ខានោះ ដល់នូវសេចក្តីត្រេកអរដោយឧបេក្ខានោះ ស្ថិតនៅក្នុងឧបេក្ខានោះ មានចិត្តចុះស៊ប់ក្នុងឧបេក្ខានោះ ជាអ្នកនៅច្រើនដោយឧបេក្ខានោះ មិនបានសាបសូន្យចាកឧបេក្ខា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់វេហប្ផលៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់វេហប្ផលៈ មានប្រមាណ ៥០០ កប្ប ព្រហ្មបុថុជ្ជនស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆាន

កំណើតខ្ទះ ទៅកាន់បិត្តិវិស័យខ្ទះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ស្ថិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នារបស់អរិយសាវ័ក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិ និងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## បឋមមេត្តាសូត្រ

[ ១២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមមេត្តាសូត្រទី ៥ ដូចតទៅនេះ មេត្តាទ្រង់សម្តែងដោយអំណាចបឋមជ្ឈានករុណាជាដើម ទ្រង់សម្តែងដោយអំណាចទុតិយជ្ឈានជាដើម ។ល។

**អដ្ឋកថា បឋមមេត្តាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយមេត្តាសូត្រទី ៦

[ ១២៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចៗ គ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង សម្រេចសម្រាន្តនៅ ។ ធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនោះ បុគ្គលនោះ តែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពជាមិនទៀង ជាជាទុក្ខ ជាជារោគ ជាជាបូស ជាជាព្រួញ ជាជាសេចក្តីតានតឹង ជាជាអាពាធ ជាជារបស់អ្នកដទៃ ជាជារបស់ទ្រុឌទ្រោម ជាជារបស់សោះសូន្យ ជាជារបស់មិនមែនរបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយករុណា ... ។ មានចិត្តប្រកបដោយមុទិតា ... ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤

ក៏ដូចៗ គ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ ធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនោះ បុគ្គលនោះ តែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថាមិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនជារបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## ទុតិយមេត្តាសូត្រ

[ ១២៦ ] ទុតិយមេត្តាសូត្រទី ៦ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសូត្រទី ៤ ។

**អដ្ឋកថា ទុតិយមេត្តាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអច្ឆរិយសូត្រទី ៧

[ ១២៧ ] ម្នាលភិក្ខុទាំងឡាយ ហេតុដែលអស្ចារ្យចម្លែក ៤ យ៉ាង រមែងកើតប្រាកដ ព្រោះការកើតនៃតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ហេតុដែលអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពោធិសត្វច្យុតចាកពួកទេវតាជាន់តុសិត មានស្មារតីដឹងខ្លួន ចុះកាន់ផ្ទៃនៃព្រះមាតាក្នុងកាលណា កាលនោះ ពន្លឺដ៏លើសលុប ប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសចំណែកលោកន្តរិកនរកទាំងប៉ុន្មាន ដែលជាទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង ពន្លឺព្រះចន្ទ្រ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ រមែងផ្សាយទៅមិនដល់លោកន្តរិកនរកណា ពន្លឺដ៏លើសលុបប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដក្នុងលោកន្តរិក-នរកនោះឯង ពួកសត្វណាដែលកើតក្នុងលោកន្តរិកនរកនោះ សត្វទាំងនោះក៏ស្គាល់គ្នានិងគ្នាដោយសារពន្លឺនោះថា ឱហ្ន៎ ពួកសត្វដទៃមកកើតក្នុងទីនេះដែរតើ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ កើតប្រាកដឡើង ព្រោះការកើតឡើងនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុ

ទាំងឡាយ មួយទៀត ពោធិសត្វមានស្មារតីដឹងខ្លួន ប្រសូតចេញចាកផ្ទៃនៃព្រះមាតាក្នុងកាលណា ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុដែលអស្ចារ្យចម្លែកទី ២ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលណា ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៣ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះតថាគតញ៉ាំងធម្មចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅក្នុងកាលណា កាលនោះ ពន្លឺដ៏លើសលុបប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ចំណែកលោកន្តរិកនរកទាំងប៉ុន្មាន ដែលជាទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង ពន្លឺនៃព្រះចន្ទ្រ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក៏រមែងផ្សាយទៅមិនដល់ក្នុងលោកន្តរិកនរកណា ពន្លឺដ៏លើសលុបប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដក្នុងលោកន្តរិកនរកនោះឯង ពួកសត្វណា កើតក្នុងលោកន្តរិកនរកនោះ សត្វទាំងនោះឯង ក៏ស្គាល់គ្នានិងគ្នាដោយសារពន្លឺ

នោះថា ឱហ្ន៎ មានពួកសត្វដទៃមកកើតក្នុងទីនេះដែរតើ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៤ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង នេះឯង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មា-សម្ពុទ្ធ ។

# អដ្ឋកថា

## បឋមអច្ឆរិយសូត្រ

[ ១២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអច្ឆរិយសូត្រទី ៧ ដូចតទៅនេះ បទថា **ចាតុភាវា** គឺព្រោះប្រាកដឡើង ។ ក្នុងបទថា **កុច្ឆឹ ឱក្កមតិ** នេះ សេចក្ដីថា ជាអ្នកចុះកាន់គភ៌ហើយ ។ សេចក្ដីពិត កាលព្រះពោធិសត្វនោះ ចុះហើយ ពន្លឺក៏យ៉ាងនោះ កាលកំពុងឈមចុះ ពន្លឺក៏យ៉ាងនោះ ។ បទថា **អប្បមាណោ** បានដល់ មានប្រមាណបន្ថែមឡើង គឺបរិបូណ៌ទូលំទូលាយ ។ បទថា **ឧឡារោ** ជាវេវចនៈនៃបទថា **អប្បមាណោ** នោះឯង ។ ក្នុងបទថា **ទេវានំ ទេវានុភាវំ** នេះ បានដល់ អានុភាពដែលមិនមានប្រមាណរបស់ពួកទេវតា រស្មីរបស់សំពត់ស្លៀកផ្សាយទៅបាន ១២ យោជន៍ របស់សរីរៈក៏យ៉ាងនោះ របស់វិមានក៏យ៉ាងនោះ អធិប្បាយថា កន្លងទេវានុភាពនៃទេវតា

ទាំងនោះ ។ បទថា **លោកន្តរិកា** សេចក្តីថា ទីទទេក្នុងរវាង ៣ ចក្រវាល មានលោកន្តរិកនរក ១ ដូចក្នុងរវាងកង់រទេះទាំង ៣ ដែលដាក់ទល់គ្នា គឺមានទីទំនេរត្រង់កណ្តាល ។ ក្នុងលោកន្តរិកនរកនោះពោលដោយប្រមាណបាន ៨០០០ យោជន៍ ។ បទថា **អឃា** គឺបើកជានិច្ច ។ បទថា **អសំវុតា** គឺមិនមានឋាន: គឺទីតាំងខាងក្រោម ។ បទថា **អន្ធការា** គឺងងឹត ។ បទថា **អន្ធការតិមិសា** សេចក្តីថា ប្រកបដោយភាពងងឹត ធ្វើឲ្យដូចភ្នែកខ្វាក់ ព្រោះហាមការកើតឡើងនៃចក្ខុវិញ្ញាណ បានឮថា ចក្ខុវិញ្ញាណមិនកើតក្នុងលោកន្តរិកនរកនោះ ។ បទថា **ឯវំមហិទ្ធិកានំ** សេចក្តីថា បានឮថា ព្រះចន្ទ និងព្រះអាទិត្យប្រាកដក្នុងទ្វីបទាំង ៣ ក្នុងពេលតែមួយ ទើបមានឫទ្ធិច្រើនយ៉ាងនេះ ព្រះចន្ទ និងព្រះអាទិត្យ រមែងបញ្ចេញនូវពន្លឺកម្ចាត់ងងឹតបាន ៩ សែនយោជន៍ក្នុងទិស ១ ទើបមានអានុភាពច្រើនយ៉ាងនេះ ។ បទថា **អាភានានុភោន្តិ** គឺពន្លឺមិនគ្រប់គ្រាន់ ។ បានឮថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះគោចរទៅក្នុងកណ្តាលភ្នំកន្ទាប់ចក្រវាល ហួសភ្នំកណ្តាប់ចក្រវាលនោះទៅក៏ជាលោកន្តរិកនរក ព្រោះដូច្នោះ ពន្លឺនៃព្រះចន្ទ និងព្រះអាទិត្យទាំងនោះទើបជះមិនដល់ទីនោះ ។

បទថា **យេបិ តត្ថ សត្តា** សេចក្តីថា សត្វពួកណា កើតហើយក្នុងលោកន្តរិកមហានរកនោះ សួរថា សត្វទាំងនោះធ្វើកម្មអ្វី ទើបកើតក្នុងលោកន្តរិក-នរកនោះ ។ ឆ្លើយថា សត្វធ្វើកម្មធ្ងន់ចំពោះមាតាបិតា និងធ្វើខុសធ្ងន់ចំពោះ

សមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ និងធ្វើកម្មព្រៃផ្សៃដទៃ មានសម្លាប់សត្វរៀងរាល់ថ្ងៃជាដើម ទើបទៅកើតក្នុងទីនោះ ដូចអភយចោរ និងនាគចោរជាដើម ក្នុងតម្ពបណ្ណិទ្វីប ( លង្កា ) សត្វទាំងនោះមានអត្តភាពទំហំ ៣ គាវុត មានក្រចកវែងដូចប្រចៀវ យកក្រចកតោងសំយុងត្រង់ជើងភ្នំកណ្ដាប់ចក្រវាល ដូចគ្នានឹងសត្វប្រចៀវ ទំសំយុងខ្លួនត្រង់ដើមឈើ ដូច្នោះ កាលប្រវេប្រវាទៅប៉ះគ្នានិងគ្នា ក៏នាំគ្នាសម្គាល់ថា អញបានចំណីហើយ ដូច្នេះ ស្ទុះទៅដោយជុំវិញ ក៏ធ្លាក់ទៅក្នុងទឹកដែលទ្រចក្រវាល ដូចគ្នានឹងផ្លែស្រគំកាលត្រូវខ្យល់បក់បោក ក៏ដាច់ធ្លាក់ទៅក្នុងទឹក លុះធ្លាក់ទៅដល់ ក៏រលួយទៅក្នុងទឹកក្រុត ដូចគ្នានឹងម្សៅធ្លាក់ទឹករលាយទៅ ដូច្នោះ ។ បទថា **អញ្ញេបិ កិរ ភោ សន្តិ សត្តា** សេចក្ដីថា សត្វទាំងនោះឃើញគ្នាក្នុងថ្ងៃនោះ ទើបបានដឹងថា សត្វដទៃមកកើតក្នុងទីនេះ ដើម្បីសោយទុក្ខនេះ ដូចយើងទាំង-ឡាយសោយទុក្ខធំ ដូច្នោះ ។ តែពន្លឺនេះ ភ្លឺត្រឹមតែហុតបបរមួយក្អឹកក៏មិនមែន ភ្លឺត្រឹមតែរយៈពេលដែលសត្វបិទភ្នែក ហើយបើកភ្នែកឡើង អារម្មណ៍ជាក់ច្បាស់ ដូច្នោះ ។ ឯព្រះទីឃភាណកាចារ្យពោលថា ពន្លឺនោះ ភ្លឺត្រឹមតែល្មមសត្វពោលបានថា នេះអ្វីហ្ន៎ ក៏បាត់ទៅ ដូចគ្នានឹងពន្លឺផ្លេកបន្ទោរ ក្នុងមួយរយៈផ្ទាត់ម្រាមដៃ ដូច្នោះ ៕

## អដ្ឋកថាបឋមអច្ឆរិយសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយអច្ឆរិយសូត្រទី ៨

[ ១២៨ ] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ហេតុអស្ចារ្យ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានអាល័យជាទីត្រេកអរ ត្រេកអរក្នុងអាល័យ រីករាយក្នុងអាល័យ ពពួកសត្វនោះឯង កាលបើតថាគតសម្តែងធម៌ជាទំនាស់ដល់អាល័យ ក៏ចង់ស្តាប់ ផ្ទង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានមានះជាទីត្រេកអរ ត្រេកអរក្នុងមានះ រីករាយក្នុងមានះ ពពួកសត្វនោះ កាលបើព្រះតថាគតសម្តែងនូវធម៌ជាគ្រឿងកម្ចាត់បង់នូវមានះ ក៏ចង់ស្តាប់ ផ្ទង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ២ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានសេចក្តីមិនស្ងប់រម្ងាប់ជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីមិនស្ងប់រម្ងាប់ រីករាយក្នុងសេចក្តីមិនស្ងប់រម្ងាប់ ពពួកសត្វនោះកាលបើព្រះតថាគតសម្តែងនូវធម៌ជាគ្រឿងស្ងប់រម្ងាប់ក៏ចង់ស្តាប់ ផ្ទង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៣ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វ

ប្រកបដោយអវិជ្ជា ដូចខ្វាក់ ត្រូវអវិជ្ជារួបរឹត ពពួកសត្វនោះ កាលបើព្រះតថាគតសម្ដែងធម៌ជាគ្រឿងកម្ចាត់បង់អវិជ្ជា ក៏ចង់ស្ដាប់ ផ្ចង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៤ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកទាំង ៤ នេះឯង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

# អដ្ឋកថា

## ទុតិយអច្ឆរិយសូត្រ

[ ១២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអច្ឆរិយសូត្រទី ៨ ដូចតទៅនេះ បញ្ចកាមគុណ ឬវដ្តៈទាំងមូល ឈ្មោះថា អាល័យ ព្រោះអត្ថថា គប្បីត្រូវតណ្ហា និងទិដ្ឋិប្រកាន់ ។ ឈ្មោះថា **អារាម** ព្រោះជាទីត្រេកអរ ។ អាល័យដែលជាទីត្រេកអររបស់សត្វនេះ ហេតុនោះ ទើបសត្វនេះ ឈ្មោះថា **អាលយារាម** គឺមានអាល័យជាទីត្រេកអរ ។ ឈ្មោះថា **អាលយរត** ព្រោះត្រេកអរហើយក្នុងអាល័យ ។ ឈ្មោះថា **អាលយសម្មុទិត** ព្រោះត្រេកអរហើយក្នុងអាល័យ ។ បទថា **អនាលយេ ធម្មេ** សេចក្ដីថា អរិយធម៌

អាស្រ័យវិវដ្ត និព្វានដែលផុយគ្មានទីអាល័យ ។ បទថា **សុស្សូសតិ** គឺជាអ្នកប្រាថ្នានឹងស្តាប់ ។ បទថា **សោតំ ឱទហតិ** ប្រែថា ផ្ទៀងនូវសោតៈ ។ បទថា **អញ្ញាចិត្តំ ឧបដ្ឋបេតិ** សេចក្តីថា ចូលទៅតាំងចិត្តដើម្បីដឹងទូទៅដល់ធម៌ ។ បទថា **មានោ** គឺការសម្គាល់ ឬវដ្តៈទាំងមូលនោះឯង ឈ្មោះថា មានះ ព្រោះអត្ថថា ពួកសត្វគប្បីសម្គាល់ ។ បទថា **មានវិនយេ ធម្មេ** គឺធម៌ដែលជាគ្រឿងកម្ចាត់បង់នូវមានះ ។ ធម៌ដែលផុយគ្មានទីសេចក្តីស្ងប់ ឈ្មោះថា អនុបសម ឬវដ្តៈនោះឯង ឈ្មោះថា **អនុបសម** ព្រោះអត្ថថា មិនស្ងប់ហើយ ។ បទថា **ឧបសមិកោ** បានដល់ ធម៌ដែលធ្វើនូវការស្ងប់ គឺអាស្រ័យវិវដ្តៈ គឺនិព្វាន ។ ឈ្មោះថា **អវិជ្ជាគត** ព្រោះទៅ គឺប្រកបដោយអវិជ្ជា ។ ឈ្មោះថា **អណ្ឌភូត** ព្រោះដូចជាមនុស្សខ្វាក់ ព្រោះត្រូវគំនរងងឹត គឺអវិជ្ជាបិទបាំង ។ ឈ្មោះថា **បរិយោនទ្ធា** ព្រោះរួបរឹតដោយជុំវិញ ។ ក្នុងបទថា **អវិជ្ជាវិនយេ** អរហត្ត ហៅថា ធម៌ជាគ្រឿងកម្ចាត់អវិជ្ជា កាលធម៌ដែលអាស្រ័យធម៌ជាគ្រឿងកម្ចាត់អវិជ្ជានោះ ដែលព្រះតថាគតសម្តែង ។ ក្នុងសូត្រនេះ ត្រាស់វដ្តៈ ៤ ឋានៈ ត្រាស់វិវដ្តៈ ៤ ឋានៈ ដោយប្រការដូច្នេះ ។

## អដ្ឋកថា ទុតិយអច្ឆរិយសូត្រទី ៨ ចប់

# សុត្តន្តបិដក

## តតិយអច្ឆរិយសូត្រទី ៩

[ ១២៩ ] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទនេះមាន ៤ យ៉ាង ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិស័ទនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុនីបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុនីបរិស័ទនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបរិស័ទមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសកបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសកបរិស័ទតែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសកបរិស័ទនោះ តែងមានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសកបរិស័ទមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិស័ទ ក៏មានចិត្តរីករាយដោយ

ភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទ ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## តតិយអច្ឆរិយសូត្រ

[ ១២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអច្ឆរិយសូត្រទី ៩ ដូចតទៅនេះ បទថា **ភិក្ខុបរិសា អានន្ទំ ទស្សនាយ** សេចក្តីថា ភិក្ខុពួកណាបំណាំងនឹងគាល់ព្រះមានព្រះភាគ ក៏ចូលទៅរកព្រះថេរៈ ឬភិក្ខុពួកណាបានស្តាប់គុណរបស់ព្រះថេរៈថា បានឮថា ព្រះអានន្ទ គួរជ្រះថ្លាដោយជុំវិញល្អគួរសរសើរ ជាពហុសូត ជាធម្មកថិក ជាអ្នកធ្វើសង្ឃស្អាត ដូច្នេះ ទើបនាំគ្នាមក ទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ថា ភិក្ខុបរិស័ទចូលទៅសួរសុខទុក្ខអានន្ទ ដូច្នេះ ក្នុងបទទាំងអស់ ក៏ន័យនេះ ។ បទថា **អត្តមនា** សេចក្តីថា ភិក្ខុបរិស័ទនោះ មានចិត្តត្រេកអរ គឺមានចិត្តត្រេកអរថា ការឃើញរបស់អាត្មាអញ សមគ្នានឹងការស្តាប់មក ។ បទថា **ធម្មំ** សេចក្តីថា លោកពោលពាក់ទាក់យ៉ាងនេះថា អាវុសោទាំងឡាយ ល្មមប្រព្រឹត្តទៅបានឬ

ល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានឬ អ្នកទាំងឡាយ ធ្វើកិច្ចក្នុងយោនិសោ-មនសិការឬ អ្នកបំពេញអាចរិយវត្តនិងឧបជ្ឈាយវត្តឬ ដូច្នេះ បណ្ដាបុគ្គលទាំងនោះ ក្នុងភិក្ខុនីក៏នឹងពោលបដិសណ្ឋារៈផ្សេងគ្នាដូច្នេះថា នែប្អូនស្រីទាំងឡាយ នាងទាំងឡាយ សមាទានគរុធម៌ ៨ ជាប់លាប់ឬ ដូច្នេះ ។ ក្នុងឧបាសកទាំងឡាយ លោកមិនធ្វើបដិសណ្ឋារៈយ៉ាងនេះ ដោយពាក្យថា ឧបាសកមកល្អហើយ អ្នកមិនឈឺក្បាល ឬអវយវៈទេឬ កូនច្បង និងប្អូនប្រុសរបស់អ្នក មិនមានរោគភ័យទេឬ ដូច្នេះ តែលោកធ្វើបដិសណ្ឋារៈយ៉ាងនេះថា ឧបាសក ដូចម្ដេចទៅហើយ អ្នកចូររក្សាសរណៈ ៣ សីល ៥ ចូរធ្វើឧបោសថ ១ ខែ ៨ ដងចុះ ចូរចិញ្ចឹមមាតាបិតា ចូរទំនុកបម្រុងសមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ចុះ ដូច្នេះ សូម្បីក្នុងឧបាសិកាទាំងឡាយក៏ន័យនេះឯង ។៙

**អដ្ឋកថា តតិយអច្ឆរិយសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ចតុត្ថអច្ឆរិយសូត្រទី ១០

[ ១៣០ ] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ក្នុងចក្រពត្តិនេះ មាន ៤ យ៉ាង ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាល

ភិក្ខុទាំងឡាយ បើខត្តិយបរិស័ទចូលទៅដើម្បីគាល់ស្តេចចក្រពត្តិ ខត្តិយ-បរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះរាជឱង្ការ ( ដោយបដិសណ្ឋារធម៌ ) ក្នុងទីនោះ ខត្តិយបរិស័ទនោះក៏មានចិត្តរីករាយដោយព្រះរាជឱង្ការផង ម្នាលភិក្ខុទាំងឡាយ ខត្តិយបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើព្រាហ្មណបរិស័ទនោះ ចូលទៅដើម្បីគាល់ស្តេចចក្រពត្តិព្រាហ្មណបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះរាជឱង្ការក្នុងទីនោះ ព្រាហ្មណបរិស័ទនោះ ក៏មានចិត្តរីករាយដោយព្រះរាជឱង្ការផង ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំង-ឡាយ បើគហបតីបរិស័ទ ចូលទៅដើម្បីគាល់ស្តេចចក្រពត្តិ គហបតីបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះរាជឱង្ការក្នុងទីនោះ គហបតីបរិស័ទនោះ ក៏មានចិត្តរីករាយដោយព្រះរាជ-ឱង្ការផង ម្នាលភិក្ខុទាំងឡាយ គហបតីបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើសមណ-បរិស័ទចូលទៅដើម្បីជួបស្តេចចក្រពត្តិ សមណបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះឱង្ការក្នុងទីនោះ សមណបរិស័ទនោះ ក៏មានចិត្តរីករាយដោយព្រះឱង្ការផង ម្នាលភិក្ខុទាំង-

ឡាយ សមណបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្ដេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងស្ដេចចក្រពត្តិ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទក៏មាន ៤ យ៉ាងដូច្នោះដែរ ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិស័ទនោះតែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិស័ទនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិស័ទ ... ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសកបរិស័ទ ... ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិស័ទចូលទៅ ដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិស័ទនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិស័ទនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទ ៤ យ៉ាងនេះឯង ។

**ភយវគ្គទី ៣ ចប់**

## ឧទ្ទាននៃភយវគ្គនោះ គឺ

និយាយអំពីអត្តានុវាទភ័យ ១ អំពីឩម្មិភ័យ ១ អំពី

ដំណើរផ្សេងៗ គ្នានៃអរិយសាវក និងបុថុជ្ជនមានពីរ
២ ជង អំពីមេត្តា ១ អំពីហេតុអស្ចារ្យចម្លែក ២
លើកនិង ២ លើកដទៃ ទៀត ។

# អដ្ឋកថា

## ចតុត្ថអច្ឆរិយសូត្រ

[ ១៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុត្ថអច្ឆរិយសូត្រទី ១០ ដូចតទៅនេះ បទថា **ខត្តិយបរិសា** បានដល់ ពួកខត្តិយៈដែលអភិសេក និងមិនទាន់អភិសេក ។ បានឮថា ខត្តិយៈទាំងនោះ បានស្តាប់កថា ពោលអំពីគុណរបស់ស្តេចចក្រពត្តិនោះថា ធម្មតាស្តេចចក្រពត្តិល្អគួរជ្រះថ្លា ត្រាច់ទៅតាមអាកាសបាន គ្រប់គ្រងរាជសម្បត្តិ ទ្រទ្រង់ធម៌ ជាធម្មរាជា ដូច្នេះ លុះឃើញសមគ្នានឹងបានស្តាប់មក ក៏ត្រេកអរ ។ បទថា **ភាសតិ** សេចក្តីថា ស្តេចចក្រពត្តិបានធ្វើបដិសណ្ឋារៈថា អ្នកជាបុរសស្ត្រីទាំងឡាយ នៅបំពេញរាជធម៌ រក្សាប្រពៃណីឬ ។ ឯក្នុងព្រាហ្មណ៍ទាំងឡាយ ក៏ធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោកអាចារ្យទាំងឡាយ អ្នកទាំងឡាយបង្រៀនមន្តឬ សិស្សទាំងឡាយនៅរៀនមន្តឬ អ្នករមែងបាននូវទក្ខិណាឬ សំពត់ឬ គោក្របីខ្វះឬ ។ ក្នុងគហបតីទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា នែបា អ្នក

មិនត្រូវបៀតបៀនដោយតម្លៃសំណូកទេឬ ដោយគ្រឿងចងអំពីពជត្រកូលទេឬ ភ្លៀងធ្លាក់ត្រូវតាមកាលដែរឬ ស្រូវទាំងឡាយ បានផលសម្បូរឬ ។ ក្នុងសមណៈទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោកម្ចាស់ដ៏ចម្រើន បរិក្ខាររបស់បព្វជិត រកបានងាយឬ សូមលោកម្ចាស់ទាំងឡាយ កុំលះបង់សមណធម៌នេះឡើយ ៗ។

## អដ្ឋកថា ចតុត្ថអច្ចតិយសូត្រទី ១០ ចប់
## ភយវគ្គទី ៣ ចប់

# សុត្តន្តបិដក

# បុគ្គលវគ្គទី ៤

## សំយោជនសូត្រទី ១

[ ១៣១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ មិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ ( សំយោជនៈជាបច្ច័យដើម្បីបានទូវឧបបត្តិភព ) មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ( សំយោជនៈជាបច្ច័យដើម្បីបានទូវភព ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះបាន លះបង់ឱរម្ភាគិយសញ្ញោជនៈ តែមិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ បានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ តែមិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះក្នុងលោកនេះ បានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេចដែលមិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បាន

លះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់សកទាគាមី ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលនេះឯងដែលមិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិនបាន លះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិក-សញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្ដេចដែលបានលះបង់ឱរម្ភា-គិយសញ្ញោជនៈ តែមិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិន ទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់ឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯងដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ តែមិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្ដេចដែលបាន លះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ តែ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់អន្តរាបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯង ដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ តែមិនទាន់បានលះបង់ភវប្បដិលា-ភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្ដេចដែលបានលះបង់ ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់អរហន្តខីណាស្រព ។ ម្នាលភិក្ខុ ទាំងឡាយ បុគ្គលនេះឯងដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា
# បុគ្គលវគ្គទី ៤

## អដ្ឋកថា សំយោជនសូត្រ

[ ១៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំយោជនសូត្រទី ១ នៃបុគ្គលវគ្គទី ៤ ដូចតទៅនេះ បុគ្គលពួកខ្លះ បានទូវឧបបត្តិភព ក្នុងចន្លោះដោយសំយោជនៈពួកណា សំយោជនៈទាំងនោះ ឈ្មោះថា ឧប្បត្តិប្បដិលាភិក ។ បទថា **ភវប្បដិលាភិយានិ** បានដល់ ជាបច្ច័យដល់ការបានទូវឧបបត្តិភព ។ បទថា **សកទាគាមិស្ស** នេះ លោកកាន់យកដោយចំណែកដ៏ឧត្តមក្នុងព្រះអរិយៈទាំងឡាយ ដែលមិនទាន់លះសំយោជនៈបាន ព្រោះហេតុនេះ អន្តរាឧប្បត្តិ គឺការកើតឡើងក្នុងចន្លោះនៃព្រះអរិយបុគ្គល ដែលជាអន្តរាបរិនិព្វាយីមិនមាន តែលោកចូលឈានណាក្នុងទីនោះ ឈាននោះរាប់ថា ជាបច្ច័យដល់ឧបបត្តិភព ព្រោះឈានជាចំណែកកុសលធម៌ ដូច្នោះ ទើបត្រាស់សម្រាប់ព្រះអរិយបុគ្គលដែលជាអន្តរាបរិនិព្វាយីនោះថា លះឧប្បត្តិបដិលាភិកសំយោជនៈ គឺសំយោជនៈដែលជាហេតុឲ្យមានការកើតបាន តែលះភវប្បដិលាភិកសំយោជនៈ គឺសំយោជនៈដែលជាហេតុឲ្យមានភពមិនបាន ។ សំដៅដល់សំយោជនៈដែលជាចំណែកមិនទាន់លះបាន ក្នុងឱរម្ភាគិយសំយោជនៈទាំងឡាយ ទើបត្រាស់ថា លះឱរម្ភាគិយសំយោជនៈមិនបាន ដូច្នេះ ដោយការមិនផ្សេងគ្នានៃសកទាគាមិបុគ្គល ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់

ទាំងអស់ហើយ ។ល។

អដ្ឋកថា សំយោជនសូត្រទី ១ ចប់

# សុត្តន្តបិដក

## បដិភាណសូត្រទី ២

[ ១៣២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមានប្រាជ្ញាគួរ តែមិនមាន ប្រាជ្ញារហ័ស ១ មានប្រាជ្ញារហ័ស តែមិនមានប្រាជ្ញាគួរ ១ មានប្រាជ្ញាគួរផង មានប្រាជ្ញារហ័សផង ១ មានប្រាជ្ញាមិនគួរ មានប្រាជ្ញាមិនរហ័ស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯងរមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## បដិភាណសូត្រ

[ ១៣២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបដិភាណសូត្រទី ២ ដូចតទៅនេះ បទថា* **យុត្តប្បដិភាណោ នោ មុត្តប្បដិភាណោ** *សេចក្តីថា បុគ្គលកាលស្រាយបញ្ហា ក៏ស្រាយតែបញ្ហាដែលចងប៉ុណ្ណោះ តែស្រាយមិនបានរហ័ស គឺស្រាយសន្សឹមៗ ។ បទទាំងពួង គប្បីជ្រាបដោយន័យនេះឯង ។l៚*

**អដ្ឋកថា បដិភាណសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឧគ្ឃដិតញ្ញូសូត្រទី ៣

[ ១៣៣ ] *ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺឧគ្ឃដិតញ្ញូបុគ្គល ១ វិបចិតញ្ញូបុគ្គល ១ នេយ្យបុគ្គល ១ បទបរមបុគ្គល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។l៚*

# អដ្ឋកថា

## ឧគ្ឃដិតញ្ញូសូត្រ

[ ១៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧគ្ឃដិតញ្ញូសូត្រទី ៣ ដូចតទៅនេះថា គប្បីជ្រាបការផ្សេងគ្នានៃបុគ្គល ៤ ពួក ដោយសូត្រនេះ ដូច្នេះថា បុគ្គលជាឧគ្ឃដិតញ្ញូ តើដូចម្ដេច ។ បុគ្គលណាមានការត្រាស់ដឹងនូវមគ្គ និងផលដំណាលគ្នានឹងវេលានៃធម៌ ដែលធម្មកថិកបង្ហើបសម្ដែងហើយ នេះហៅថា បុគ្គលជាឧគ្ឃដិតញ្ញូ ។ បុគ្គលជាវិបចិតញ្ញូ តើដូចម្ដេច ។ បុគ្គលណាកាលធម្មកថិកសម្ដែងចែកអត្ថនៃភាសិតដែលសង្ខេបឲ្យពិស្ដារ ទើបមានការត្រាស់ដឹងនូវមគ្គ និងផល នេះហៅថា បុគ្គលជាវិបចិតញ្ញូ ។ បុគ្គលជានេយ្យៈ តើដូចម្ដេច ។ បុគ្គលណា លុះតែរៀនបាលី រៀនអដ្ឋកថា ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា សេព គប់រក ចូលទៅអង្គុយជិតនឹងពួកកល្យាណមិត្តតាមលំដាប់យ៉ាងនេះ ទើបមានការត្រាស់ដឹងនូវមគ្គ និងផលបាន នេះហៅថា បុគ្គលជានេយ្យៈ ។ បុគ្គលជាបទបរមៈ តើដូចម្ដេច ។ បុគ្គលណាទុកជាស្ដាប់ច្រើនក៏ដោយ ពោលច្រើនក៏ដោយ ចងចាំច្រើនក៏ដោយ បង្រៀនច្រើនក៏ដោយ ក៏មិនមានការត្រាស់ដឹងនូវមគ្គ និងផលក្នុងជាតិនោះ នេះហៅថា ជាបទបរមបុគ្គល ។ល។

**អដ្ឋកថា ឧគ្ឃដិតញ្ញូសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឧដ្ឋានសូត្រទី ៨

[ ១៣៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង មិនចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម ១ ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម មិនចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង ១ ចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែងផង ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្មផង ១ មិនចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង មិនចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## ឧដ្ឋានសូត្រ

[ ១៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧដ្ឋានសូត្រទី ៤ ដូចតទៅនេះ បុគ្គល ១ ពួក ប្រើពេលឲ្យកន្លងទៅដោយសេចក្តីព្យាយាម គឺការប្រឹងប្រែងប៉ុណ្ណោះ បានអ្វីមក ត្រឹមតែផលនៃសេចក្តីព្យាយាមនោះ ដែលហូរចេញមកចិញ្ចឹមជីវិត បុគ្គលនោះអាស្រ័យតែសេចក្តីព្យាយាមនោះ មិនបានផលបុណ្យណា

មួយ បុគ្គលពួកនេះ ឈ្មោះថា បុគ្គលចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង មិនចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម ។ ឯពួកទេវតាទាំងអស់ តាំងអំពីចាតុម្មហារាជជាដើមទៅ ព្រោះចូលទៅអាស្រ័យផលបុណ្យ តាំងជីវិតនៅ វៀរសេចក្តីព្យាយាម គឺការប្រឹងប្រែង ឈ្មោះថា ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម មិនចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង ។ ឥស្សរជន មានព្រះរាជា និងមហាមាត្យជាដើម ឈ្មោះថា ចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែងផង ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្មផង ។ ពួកសត្វនរក តាំងជីវិតនៅដោយផលនៃសេចក្តីព្យាយាមក៏មិនមែន ដោយផលរបស់កម្មក៏មិនមែន ។ ផលបុណ្យនោះឯង លោកបំណងយកថា ជាផលរបស់កម្ម ក្នុងសូត្រនេះ ផលបុណ្យនោះ មិនមានដល់ពួកសត្វនរកទាំងនោះ ។ ល។

**អដ្ឋកថា ឧដ្ឋានសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សាវជ្ជសូត្រទី ៥

[ ១៣៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលប្រកបដោយទោស ១

ច្រើនដោយទោស ១ មានទោសតិច ១ មិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រកបដោយទោស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបកាយកម្មមានទោស ប្រកបដោយវចីកម្មមានទោស ប្រកបដោយមនោកម្មមានទោស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយទោស ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលច្រើនដោយទោស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្ម មានទោសច្រើន មិនមានទោសតិច ប្រកបដោយវចីកម្មមានទោសច្រើន មិនមានទោសតិច ប្រកបដោយមនោកម្មមានទោសច្រើន មិនមានទោសតិច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលច្រើនដោយទោសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានទោសតិច តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្ម មិនមានទោសច្រើន មានទោសតិច ប្រកបដោយវចីកម្ម មិនមានទោសច្រើនមានទោសតិច ប្រកបដោយមនោកម្ម មិនមានទោសច្រើន មានទោសតិច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានទោសតិច យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមិនមានទោស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្មមិនមានទោស ប្រកបដោយវចីកម្មមិនមានទោស ប្រកបដោយមនោកម្មមិនមានទោស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទោស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## សាវជ្ជសូត្រ

[ ១៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាវជ្ជសូត្រទី ៥ ដូចតទៅនេះថា បុគ្គល ១ ពួក បានដល់ បុថុជ្ជនល្ងង់ខ្លៅ បុគ្គលទី ២ បានដល់ លោកិយ-បុថុជ្ជនដែលបំពេញកុសលក្នុងចន្លោះៗ ពួកទី ៣ បានដល់ ព្រះសោតាបន្ន រហូតដល់ព្រះសកទាគាមី និងអនាគាមី ក៏រួមចូលគ្នានឹងបុគ្គលពួកទី ៣ នោះដូចគ្នា បុគ្គលពួកទី ៤ បានដល់ ព្រះខីណាស្រព ពិតហើយ ព្រះខីណាស្រពនោះ មិនមានទោសដោយចំណែកមួយ ៗ។

អដ្ឋកថា សាវជ្ជសូត្រទី ៥ ចប់

# សុត្តន្តបិដក

## បឋមសីលសូត្រទី ៦

[ ១៣៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនបំពេញក្នុងសីល មិនបំពេញក្នុងសមាធិ មិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបំពេញតែក្នុងសីល មិនបំពេញក្នុងសមាធិ មិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំង-

ឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបំពេញក្នុងសីល បំពេញក្នុងសមាធិ តែមិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ បំពេញក្នុងសីល បំពេញក្នុងសមាធិ បំពេញក្នុងបញ្ញា ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## បឋមសីលសូត្រ

[ ១៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសីលសូត្រទី ៦ ដូចតទៅនេះថា បុគ្គល ១ ពួក បានដល់ លោកិយមហាជន ពួកទី ២ បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមីដែលជាអ្នកបំពេញវិបស្សនាសុទ្ធ ពួកទី ៣ បានដល់ ព្រះអនាគាមី ពិតហើយ ព្រះអនាគាមីនោះ ព្រោះហេតុដែលបានឈាន ដែលធ្វើឧប្បត្តិឲ្យកើតខណៈនោះ ដូច្នោះ សូម្បីលោកបំពេញវិបស្សនា ក៏ធ្វើឲ្យបរិបូណ៌ក្នុងសមាធិដោយពិត បុគ្គលពួកទី ៤ បានដល់ ព្រះខីណាស្រពប៉ុណ្ណោះ ពិតហើយ ព្រះខីណាស្រពនោះ ឈ្មោះថា ធ្វើឲ្យបរិបូណ៌ក្នុងសីល សមាធិ និងបញ្ញាទាំងអស់ ព្រោះលោកលះធម៌ដែលជាសត្រូវចំពោះសីលជាដើមទាំងអស់បានហើយ ៕

**អដ្ឋកថា បឋមសីលសូត្រទី ៦ចប់**

## ទុតិយសីលសូត្រទី ៧

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ មិនគោរពក្នុងសីល មិនយកសីលជាធំ មិនគោរពក្នុងសមាធិ មិនយកសមាធិជាធំ មិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ តែមិនគោរពក្នុងសមាធិ មិនយកសមាធិជាធំ មិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ គោរពក្នុងសមាធិ យកសមាធិជាធំ តែមិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ គោរពក្នុងសមាធិ យកសមាធិជាធំ គោរពក្នុងបញ្ញា យកបញ្ញាជាធំ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

## អដ្ឋកថា

## ទុតិយសីលសូត្រ

[ ១៣៧ ] ក្នុងទុតិយសីលសូត្រទី ៧ គប្បីជ្រាបការកំណត់បុគ្គលដោយន័យដែលពោលហើយ ក្នុងបឋមសីលសូត្រទី ៦ ។

**អដ្ឋកថា ទុតិយសីលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## និក្ខន្តសូត្រទី ៨

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលមានកាយចេញទៅ មានចិត្តមិនចេញទៅ ១ មានកាយមិនចេញទៅ មានចិត្តចេញទៅ ១ មានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង ១ មានកាយចេញទៅផង មានចិត្តចេញទៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយចេញទៅ មានចិត្តមិនចេញទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ នៅអាស្រ័យព្រៃតូច ឬព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ តែបុគ្គលនោះតែងត្រិះរិះនូវកាមវិតក្កក្តី ត្រិះរិះនូវព្យាបាទវិតក្កក្តី ត្រិះរិះនូវវិហឹសាវិតក្កក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយចេញទៅ តែមានចិត្តមិនចេញទៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយមិនចេញទៅ មានចិត្តចេញទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិននៅអាស្រ័យព្រៃតូច ឬព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ទេ តែបុគ្គលនោះ តែងត្រិះរិះនូវនេក្ខម្មវិតក្កក្តី ត្រិះរិះនូវអព្យាបាទវិតក្កក្តី ត្រិះរិះនូវអវិហឹសាវិតក្កក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយមិនចេញ តែមានចិត្តចេញទៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិននៅអាស្រ័យព្រៃតូច ឬព្រៃធំ

ជាសេនាសនៈដ៏ស្ងាត់ទេ បុគ្គលនោះថែមទាំង ត្រិះរិះនូវកាមវិតក្កក្តី ត្រិះរិះនូវព្យាបាទវិតក្កក្តី ត្រិះរិះនូវវិហឹសាវិតក្កក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយចេញទៅផង មានចិត្តក៏ចេញទៅផង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ នៅអាស្រ័យព្រៃតូច ឬព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ បុគ្គលនោះថែមទាំងត្រិះរិះនូវនេក្ខម្មវិតក្កក្តី ត្រិះរិះនូវអព្យាបាទវិតក្កក្តី ត្រិះរិះនូវអវិហឹសាវិតក្កក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយចេញទៅផង មានចិត្តក៏ចេញទៅផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

## និក្កដ្ឋសូត្រ

[ ១៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិក្កដ្ឋសូត្រទី ៨ ដូចតទៅនេះ បទថា **និក្កដ្ឋកាយោ** ប្រែថា មានកាយចេញទៅ ។ បទថា **និក្កដ្ឋចិត្តោ** ប្រែថា មានចិត្តមិនចេញ ។ លោកអធិប្បាយថា បុគ្គលមានកាយប៉ុណ្ណោះចេញអំពីស្រុក សូម្បីនៅក្នុងព្រៃ ក៏គង់យកចិត្តចូលស្រុកនោះឯង ។ អត្ថក្នុងបទ

ទាំងអស់ គប្បីជ្រាបដោយន័យនេះ ។ល។

## អដ្ឋកថា និក្ខដ្ឋសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ធម្មកថិកសូត្រទី ៩

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ ធម្មកថិក ( អ្នកសំដែងធម៌ ) នេះ មាន ៤ ពួក ។ ធម្មកថិកទាំង ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកខ្លះ ក្នុងសាសនានេះ សំដែងធម៌តិចផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកមិនឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សំដែងធម៌តិចផង ប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សំដែងធម៌

ច្រើនផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកមិនឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ធម្មកថិកខ្វះ ក្នុងសាសនានេះ សម្តែងធម៌ច្រើនផង ប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិក ៤ ពួកនេះឯង ។

# អដ្ឋកថា

## ធម្មកថិកសូត្រ

[ ១៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មកថិកសូត្រទី ៩ ដូចតទៅនេះ បទថា **អសហិតំ** គឺមិនប្រកបដោយប្រយោជន៍ ។ បទថា **ន កុសលា ហោតិ** គឺជាបុគ្គលមិនឈ្លាស ។ បទថា **សហិតាសហិតស្ស** សេចក្តីថា ចំពោះវត្ថុដែលប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ។ អត្ថ

*ក្នុងបទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។*

**អដ្ឋកថា ធម្មកថិកសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## វាទីសូត្រទី ១០

*[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលនេះមាន ៤ ពួក ។ បុគ្គលអ្នកពោល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោល តែងដល់នូវការអស់ទៅដោយអត្ថ គឺអដ្ឋកថា មិនអស់ទៅដោយព្យញ្ជនៈ គឺបាលីក៏មាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលតែងដល់នូវការអស់ទៅដោយព្យញ្ជនៈ មិនអស់ទៅដោយអត្ថក៏មាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលតែងដល់នូវការអស់ទៅដោយអត្ថផង ដោយព្យញ្ជនៈផងក៏មាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលមិនដល់នូវការអស់ទៅដោយអត្ថ ទាំងមិនដល់នូវការអស់ទៅដោយព្យញ្ជនៈក៏មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះគ្មានហេតុ គ្មានបច្ច័យដែលនាំឲ្យភិក្ខុប្រកបដោយបដិសម្ភិទាទាំង ៤ ដល់នូវការអស់ទៅដោយអត្ថដោយព្យញ្ជនៈឡើយ ។*

*បុគ្គលវគ្គទី ៤ ចប់*

## ឧទ្ទាននៃបុគ្គលវគ្គនោះ គឺ

និយាយអំពីសញ្ញោជនៈ ១ អំពីបុគ្គលមានប្រាជ្ញា ១ អំពីឧគ្ឃដិតញ្ញូបុគ្គល ១ អំពីបុគ្គលចិញ្ចឹមជីវិតដោយផលនៃព្យាយាម ១ អំពីបុគ្គលប្រកបដោយទោស ១ អំពីសីលមាន ២ លើក ១ អំពីបុគ្គលមានកាយចេញទៅ មានចិត្តមិនចេញទៅ ១ អំពីធម្មកថិក ១ អំពីបុគ្គលអ្នកពោល ១ ។

# អដ្ឋកថា

## វាទីសូត្រ

[ ១៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវាទីសូត្រទី ១០ ដូចតទៅនេះ បទថា **អត្ថតោ បរិយាទានំ គច្ឆតិ** សេចក្ដីថា អ្នកនិយាយត្រូវសួរដល់អត្ថ ក៏រមែងចុះចាញ់ អស់នូវបដិភាណ មិនអាចឆ្លើយតបបាន ។ បទថា **នោ ព្យញ្ជនតោ** សេចក្ដីថា តែព្យញ្ជនៈនៃបុគ្គលនោះនៅប្រព្រឹត្តទៅបាន ក៏មិនព្រមចុះចាញ់ ។ ក្នុងបទទាំងអស់ ក៏មានន័យដូច្នេះឯង ៕

**អដ្ឋកថា វាទីសូត្រទី ១០ ចប់**

**បុគ្គលវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## អាភាវគ្គទី ៥

### អាភាសូត្រទី ១

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ ពន្លឺនេះមាន ៤ យ៉ាង ។ ពន្លឺ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺពន្លឺព្រះចន្ទ ១ ពន្លឺព្រះអាទិត្យ ១ ពន្លឺភ្លើង ១ ពន្លឺប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពន្លឺទាំង ៤ នេះ ពន្លឺដែលប្រសើរទុំះ គឺពន្លឺប្រាជ្ញា ។

# អដ្ឋកថា

## អាភាវគ្គទី ៥

### អាភាសូត្រ

[ ១៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាភាសូត្រទី ១ នៃអាភាវគ្គទី ៥ ដូចតទៅនេះ ព្រះចន្ទនោះឯង ឈ្មោះថា **ចន្ទាភា** ដោយអំណាចការបញ្ចេញពន្លឺ ។ ក្នុងបទដ៏សេស ក៏ន័យនេះឯង ។៚

**អដ្ឋកថាអាភាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បភាសូត្រទី ២

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ រស្មីនេះមាន ៤ យ៉ាង ។ រស្មី ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺរស្មីព្រះចន្ទ ១ រស្មីព្រះអាទិត្យ ១ រស្មីភ្លើង ១ រស្មីប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ រស្មី ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តារស្មីទាំង ៤ នេះ រស្មីដែលប្រសើរនុ៎ះ គឺរស្មីប្រាជ្ញា ។

# អដ្ឋកថា

## បភាសូត្រ

[ ១៨២ ] ក្នុងសូត្រទី ២ ព្រះចន្ទ ឈ្មោះថា **ចន្ទាភា** ដោយអំណាចការបញ្ចេញរស្មី ។ល។

**អដ្ឋកថា បភាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អាលោកសូត្រទី ៣

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿងនេះមាន ៤ យ៉ាង ។ សេចក្តីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីរុងរឿងនៃព្រះចន្ទ ១ សេចក្តីរុងរឿងនៃព្រះអាទិត្យ ១ សេចក្តីរុងរឿងនៃភ្លើង ១ សេចក្តីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីរុងរឿងទាំង ៤ នេះ សេចក្តីរុងរឿងដែលប្រសើរនុ៎ះ គឺសេចក្តីរុងរឿងនៃប្រាជ្ញា ។

# អដ្ឋកថា

## អាលោកសូត្រ

[ ១៨៣ ] *ព្រះចន្ទ ឈ្មោះថា* **ចន្ទាលោក** *ដោយអំណាចសេចក្តីរុងរឿង ។ល។*

**អដ្ឋកថា អាលោកសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឱភាសសូត្រទី ៤

[ ១៨៤ ] *ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿងនេះមាន ៤ យ៉ាង ។ រស្មីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺរស្មីរុងរឿងនៃព្រះចន្ទ ១ រស្មីរុងរឿងនៃព្រះអាទិត្យ ១ រស្មីរុងរឿងនៃភ្លើង ១ រស្មីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តារស្មីរុងរឿងទាំង ៤ នេះ រស្មីរុងរឿងដែលប្រសើរទុំះ គឺរស្មីរុងរឿងនៃប្រាជ្ញា ។*

# អដ្ឋកថា

## ឱភាសសូត្រ

[ ១៨៤ ] ព្រះចន្ទ ឈ្មោះថា ចន្ទាភាស ដោយអំណាចរស្មីពន្លឺ ។ល។

អដ្ឋកថា ឱភាសសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បជ្ជោតសូត្រទី ៩

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ ពន្លឺរស្មីនេះមាន ៤ យ៉ាង ។ ពន្លឺរស្មី ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺពន្លឺរស្មីព្រះចន្ទ ១ ពន្លឺរស្មីព្រះអាទិត្យ ១ ពន្លឺរស្មីភ្លើង ១ ពន្លឺរស្មីប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺរស្មី ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពន្លឺរស្មីទាំង ៤ យ៉ាងនេះ ពន្លឺរស្មីដែលប្រសើរនុ៎ះ គឺពន្លឺរស្មីប្រាជ្ញា ។

# អដ្ឋកថា

## បជ្ជោតសូត្រ

[ ១៨៥ ] *ព្រះចន្ទ ឈ្មោះថា* **ចន្ទប្បជ្ជោត** *ដោយអំណាចពន្លឺរស្មី ។ អត្ថក្នុងបទទាំងពួងគប្បីជ្រាបយ៉ាងនេះ ។*

**អដ្ឋកថា បជ្ជោតសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បឋមកាលសូត្រទី ៦

[ ១៨៦ ] *ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) នេះមាន ៤ យ៉ាង ។ កាល ៤ យ៉ាង តើដូចម្ដេច ។ គឺការស្ដាប់ធម៌តាមកាល ១ សាកច្ឆាធម៌តាមកាល ១ ការចម្រើនសមថៈតាមកាល ១ ការចម្រើនវិបស្សនាតាមកាល ១ ។ ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) ៤ យ៉ាងនេះឯង ។*

# អដ្ឋកថា

## បឋមកាលសូត្រ

[ ១៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកាលសូត្រទី ៦ ដូចតទៅនេះ បទថា **កាលេន** គឺកាលដែលសម កាលដែលគួរ ។ បទថា **កាលេន ធម្មស្សវនំ** បានដល់ ការស្តាប់ធម៌ក្នុងកាលដែលសមគួរ ។ បទថា **ធម្មសាកច្ឆា** សេចក្តីថា ការសន្ទនាដែលប្រព្រឹត្តទៅដោយអំណាចការសួរ និងការឆ្លើយបញ្ហា ។ល។

### អដ្ឋកថា បឋមកាលសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ទុតិយកាលសូត្រទី ៧

[ ១៨៧ ] ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) ៤ យ៉ាងនេះ កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការស្តាប់ធម៌តាមកាល ១ សាកច្ឆាធម៌តាមកាល ១ ការចម្រើនសមថៈតាមកាល ១ ការចម្រើនវិបស្សនាតាមកាល ១ ។ ម្នាលភិក្ខុទាំង-ឡាយ កាល ៤ យ៉ាងនេះឯង កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្ត

ទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈដោយលំដាប់ ម្នាលភិក្ខុទាំងឡាយ ភ្លៀងមានតំណក់ដ៏ថ្លោសធ្លាក់ចុះលើកំពូលភ្នំ ទឹកកាលហូរទៅកាន់ទំនាប រមែងញ៉ាំងជ្រោះ អូរ និងប្រឡាយភ្នំឲ្យពេញ លុះជ្រោះ អូរ និងប្រឡាយភ្នំពេញហើយ រមែងញ៉ាំងបាភយណ៍តូចឲ្យពេញ លុះបាភយណ៍តូចពេញហើយ រមែងញ៉ាំងបាភយណ៍ធំឲ្យពេញ លុះបាភយណ៍ធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ លុះស្ទឹងធំពេញហើយ រមែងញ៉ាំងសមុទ្រសាគរឲ្យពេញ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលទាំង ៤ យ៉ាងនេះ បើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈដោយលំដាប់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

# អដ្ឋកថា

## ទុតិយកាលសូត្រ

[ ១៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយកាលសូត្រទី ៧ ដូចតទៅនេះ បទថា **កាលា** នោះ ជាឈ្មោះនៃកុសលធម៌ដែលប្រព្រឹត្តទៅដោយអំណាចការស្តាប់ធម៌ជាដើម ក្នុងកាលនោះៗ កាលទាំងនោះ នឹងជាក់ច្បាស់ ហើយនឹងប្រព្រឹត្តទៅ ។ បទថា **អាសវានំ ខយំ** បានដល់ព្រះអរហត្ត ។l៙

**អដ្ឋកថា ទុតិយកាលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## បឋមចរិតសូត្រទី ៨

[ ១៤៨ ] ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតនេះមាន ៤ យ៉ាង ។ វចីទុច្ចរិត ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការនិយាយកុហក ១ ការនិយាយញុះញង់ ១ ការនិយាយពាក្យទ្រគោះ ១ ការនិយាយពាក្យរោយរាយ ១ ។ ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិត ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមចរិតសូត្រ

*ក្នុងបឋមចរិតសូត្រទី ៨ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាបឋមចរិតសូត្រទី ៨ ចប់*

# សុត្តន្តបិដក

## ទុតិយចរិតសូត្រទី ៩

[ ១៤៩ ] ម្នាលភិក្ខុទាំងឡាយ វចីសុចរិតនេះមាន ៤ យ៉ាង ។ វចីសុចរិត ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺនិយាយពាក្យសត្យ ១ មិននិយាយ

ពាក្យញុះញង់ ១ និយាយពាក្យពីរោះពិសា ១ និយាយតែពាក្យដែលប្រកប ដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិត ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយចរិតសូត្រ

[ ១៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយចរិតសូត្រទី ៩ ដូចតទៅនេះ បទថា **សណ្ហវាចា** បានដល់ វាចាទន់ភ្លន់ ។ បទថា **មន្តាភាសា** បានដល់ រឿងដែលកំណត់ដោយបញ្ញា ដែលហៅថាមន្តាហើយទើបពោល ។៚

**អដ្ឋកថា ទុតិយចរិតសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សារសូត្រទី ១០

[ ១៥០ ] ម្នាលភិក្ខុទាំងឡាយ សារៈ ( ខ្លឹម ) នេះមាន ៤ យ៉ាង ។ សារៈ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសីលសារៈ ១ សមាធិសារៈ បញ្ញាសារៈ ១ វិមុត្តិសារៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សារៈ ៤ យ៉ាង

នេះឯង ។

អាកាវគ្គទី ៥ ចប់

បណ្ណាសកទី ៣ ចប់

ឧទ្ទាននៃអាកាវគ្គនោះ គឺ

និយាយអំពីពន្លឺ ១ អំពីរស្មី ១ អំពីសេចក្ដីរុងរឿង ១ អំពីរស្មីរុងរឿង ១ អំពីពន្លឺរស្មី ១ អំពីកាលមាន ២ លើក អំពីចរិតមាន ២ លើក អំពីសីលសារៈ ១ ត្រូវជា ១០ ក្នុងវគ្គនេះ ។

# អដ្ឋកថា

## សារសូត្រ

[ ១៥០ ] សារសូត្រទី ១០ បទថា **សីលសារោ** គឺសីលដែលឲ្យដល់នូវសារៈ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។៚

អដ្ឋកថា សារសូត្រទី ១០ ចប់

អាកាវគ្គទី ៥ ចប់

តតិយបណ្ណាសក ចប់

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ចតុក្កនិបាត

# ចតុត្ថភាគ

## ចតុត្ថបណ្ណាសក

## ឥន្ទ្រិយវគ្គទី ១

### ឥន្ទ្រិយសូត្រទី ១

[ ១ ] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៤ ។ ឥន្ទ្រិយ ៤ គឺអ្វីខ្លះ ។ ឥន្ទ្រិយ គឺសទ្ធា ១ ឥន្ទ្រិយ គឺវិរិយៈ ១ ឥន្ទ្រិយ គឺសមាធិ ១ ឥន្ទ្រិយ គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៤ នេះឯង ។

# អដ្ឋកថា

# ចតុត្ថបណ្ណាសក

## ឥន្ទ្រិយវគ្គទី ១

## ឥន្ទ្រិយសូត្រ

*[ ១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយសូត្រទី ១ នៃចតុត្ថបណ្ណាសក ដូចតទៅ ឈ្មោះថា* ***សទ្ធិន្ទ្រិយ*** *ព្រោះធ្វើនូវភាពជាធំក្នុងសទ្ធាធុរៈ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។*

**អដ្ឋកថា ឥន្ទ្រិយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បឋមពលសូត្រទី ២

*[ ២ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំង គឺសទ្ធា ១ កម្លាំង គឺវីរិយៈ ១ កម្លាំង គឺសមាធិ ១ កម្លាំង គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។*

# អដ្ឋកថា

## បឋមពលសូត្រ

[ ២ ] *បឋមពលសូត្រទី ២ ឈ្មោះថា* **សទ្ធាពល** *ព្រោះអត្ថថា មិនញាប់ញ័រ ក្នុងអស្សទ្ធិយ គឺការមិនជឿ ។ ក្នុងបទដ៏សេស ក៏ន័យនេះឯង ។l ១៩៣*

**អដ្ឋកថា បឋមពលសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទុតិយពលសូត្រទី ៣

[ ៣ ] *ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំង គឺបញ្ញា ១ កម្លាំង គឺវិរិយៈ ១ កម្លាំង គឺកម្មដែលមិនមានទោស ១ កម្លាំង គឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។*

# អដ្ឋកថា

## ទុតិយពលសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយពលសូត្រទី ៣ ដូចតទៅនេះ បទថា **អនវជ្ជពលំ** សេចក្តីថា ពល គឺកម្មដែលមិនមានទោស ។ បទថា **សង្គាហាកពលំ** បានដល់ ពល គឺការសង្គ្រោះបុគ្គលដែលគួរសង្គ្រោះ ។ល។

**អដ្ឋកថា ទុតិយពលសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## តតិយពលសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំង គឺសតិ ១ កម្លាំង គឺសមាធិ ១ កម្លាំង គឺកម្មដែលមិនមានទោស ១ កម្លាំង គឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## តតិយពលសូត្រ

*តតិយពលសូត្រទី ៤ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាតតិយពលសូត្រទី ៤ ចប់*

# សុត្តន្តបិដក

## ចតុត្ថពលសូត្រទី ៥

*[ ៥ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំង គឺការពិចារណាមុនហើយទើបធ្វើ ១ កម្លាំង គឺការចម្រើនកុសលដែលមិនទាន់មានឲ្យមានឡើង ១ កម្លាំង គឺកម្មដែលមិនមានទោស ១ កម្លាំង គឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។*

# អដ្ឋកថា

## ចតុត្ថពលសូត្រ

*ក្នុងចតុត្ថពលសូត្រទី ៥ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាចតុត្ថពលសូត្រទី ៥ ចប់*

# សុត្តន្តបិដក

## កប្បសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះមាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បសូន្យទៅ តាំងមានឡើង កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះវិនាសទៅ តាំងមានឡើង ក៏កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បត្រឡប់ចម្រើន តាំងមានឡើងវិញ ក៏កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះ ចម្រើនតាំងមានឡើង ក៏កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យនៃកប្បមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## កប្បសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកប្បសូត្រទី ៦ ដូចតទៅនេះ បទថា **សំវដ្តោ** នេះ ការវិនាស ៣ គឺវិនាសដោយទឹក ១ វិនាសដោយភ្លើង ១

វិនាសដោយខ្យល់ ១ ។ ខេត្តនៃការវិនាសមាន ៣ គឺអាភស្សរព្រហ្ម ១ សុភកិណ្ហព្រហ្ម ១ វេហប្ផលព្រហ្ម ១ ។ ក្នុងគ្រាដែលកប្បវិនាសដោយភ្លើង ភ្លើងរមែងឆេះខាងក្រោមអំពីអាភស្សរព្រហ្ម ។ ក្នុងកាលដែលវិនាសដោយទឹក ទឹករមែងទម្លាយតែខាងក្រោមសុភកិណ្ហព្រហ្ម ។ ក្នុងគ្រាដែលវិនាសដោយខ្យល់ ខ្យល់រមែងទម្លាយខាងក្រោមតែវេហប្ផលព្រហ្ម ។ តែកាលពោល ដោយពិស្តារ ពុទ្ធក្ខេត្ត ១ រមែងវិនាសបានគ្រប់កាល ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ ឯរឿងពិស្តារ អ្នកសិក្សាគប្បីជ្រាបបានដោយន័យដែលពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។l៚

**អដ្ឋកថា កប្បសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## រោគសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ រោគនេះមាន ២ យ៉ាង ។ រោគ ២ យ៉ាង គឺអ្វីខ្លះ ។ គឺកាយិករោគ ( រោគកាយ ) ១ ចេតសិករោគ ( រោគចិត្ត ) ១ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ រមែងប្រាកដដោយកាយិករោគ តែងប្តេជ្ញាថា មិនមានរោគអស់មួយឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគ

អស់ ២ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៣ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៤ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៥ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ១០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ២០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៣០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៤០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៥០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគលើសជាង ១០០ ឆ្នាំក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តែថា សត្វទាំងនោះ ដែលប្តេជ្ញាថា មិនមានរោគដោយចេតសិក សូម្បីត្រឹមតែវេលាមួយស្របក់ប៉ុណ្ណោះ ក៏រកបានដោយកម្រក្នុងលោក វៀរលែងតែព្រះខីណាស្រព ។ ម្នាលភិក្ខុទាំងឡាយ រោគរបស់បព្វជិតនេះមាន ៤ យ៉ាង ។ រោគ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ។ កាលភិក្ខុនោះ មានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ហើយរមែងតាំងសេចក្តីប្រាថ្នាលាមក ដើម្បីបាននូវសេចក្តីធំធ្កើង ដើម្បីបានលាភសក្ការៈ និងសេចក្តីសរសើរ ១ ។ ភិក្ខុនោះតែងប្រឹងប្រែងខ្នះខ្នែង ព្យាយាម ដើម្បីបាននូវសេចក្តីធំធ្កើង ដើម្បីបាននូវលាភសក្ការៈ

និងសេចក្ដីសរសើរ ១ ។ ភិក្ខុនោះតែងចូលទៅកាន់ត្រកូល ដើម្បីឲ្យគេរាប់អាន អន្ទុយនៅ ( ក្នុងត្រកូល ) ដើម្បីឲ្យគេរាប់អាន ពោលធម៌ ( ក្នុងត្រកូល ) ដើម្បីឲ្យគេរាប់អាន អត់ទ្រាំឧច្ចារបស្សាវៈ ( ក្នុងត្រកូល ) ដើម្បីឲ្យគេរាប់អាន ១ ។ ម្នាលភិក្ខុទាំងឡាយ ភេតរបស់បព្វជិតមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងមិនជាអ្នកប្រាថ្នាច្រើន មានសេចក្ដីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្ដោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន នឹងមិនតាំងសេចក្ដីប្រាថ្នាលាមក ដើម្បីបាននូវសេចក្ដីធំថ្កើង ដើម្បីបាននូវលាភសក្ការៈ និងសេចក្ដីសរសើរ នឹងមិនប្រឹងប្រែង ខ្នះខ្នែង ព្យាយាម ដើម្បីបាននូវសេចក្ដីធំថ្កើង ដើម្បីបានលាភសក្ការៈ និងសេចក្ដីសរសើរ នឹងជាអ្នកចេះអត់ទ្រាំចំពោះត្រជាក់ក្ដៅ សេចក្ដីឃ្លាន ស្រេក សម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្ដីដែលអាក្រក់ជួជាតិ ជាអ្នកអត់ធ្មត់ចំពោះវេទនា ដែលកើតឡើងក្នុងសរីរៈរាងកាយ ដែលជាទុក្ខក្លៀវក្លា ក្រហល់ក្រហាយ ខ្លោចផ្សា មិនត្រជាក់ចិត្ត មិនគាប់ចិត្ត ដែលអាចនឹងផ្ដាច់យកជីវិតទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

## រោគសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរោគសូត្រទី ៧ ដូចតទៅនេះ បទថា **វិឃាតវា** បានដល់ ប្រកបដោយការក្តៅក្រហាយចិត្ត គឺទុក្ខ មានការប្រាថ្នាច្រើនជាបច្ច័យ ។ បទថា **អសន្តុដ្ឋោ** បានដល់ ជាអ្នកមិនសន្តោសដោយបច្ច័យ ៣ ក្នុងបច្ច័យ ៤ ។ បទថា **អនវញ្ញប្បដិលាភាយ** បានដល់ ដើម្បីបាននូវការលើកតម្កើងអំពីអ្នកដទៃ ។ បទថា **លាភសក្ការសិលោកប្ប-ដិលាភាយ** បានដល់ ដើម្បីបានលាភសក្ការៈ បានដល់ បច្ច័យ ៤ ដែលគេរៀបចំយ៉ាងល្អ និងសេចក្តីចម្រើន ដែលបានដល់ការពោលសរសើរ ។ បទថា **សង្ខាយ កុលានិ ឧបសង្កមតិ** បានដល់ ចូលទៅកាន់ត្រកូលដើម្បីដឹងថា ជនទាំងនេះស្គាល់អាត្មាអញឬទេ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។៚

**អដ្ឋកថា រោគសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## បរិហានិសូត្រទី ៨

[ ៨ ] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ បានហៅភិក្ខុទាំងឡាយ

មកថា ម្នាលភិក្ខុដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះបានទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ ៤ ប្រការដែលមាននៅក្នុងខ្លួន គប្បីចូលចិត្តបានថា អាត្មាអញសាបសូន្យចាកកុសលធម៌ទាំងឡាយ ព្រោះការដែលមានធម៌ ៤ ប្រការនេះនៅក្នុងខ្លួនទុំះ ព្រះដ៏មានព្រះភាគត្រាស់ហៅថា ជាសេចក្តីសាបសូន្យ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺការដុះដាលរាគៈ ១ ការដុះដាលទោសៈ ១ ការដុះដាលមោហៈ ១ នឹងមិនមានបញ្ញាចក្ខុប្រព្រឹត្តទៅក្នុងឋានៈ និងអដ្ឋានៈដ៏ជ្រាលជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ ៤ ប្រការនេះ មាននៅក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញសាបសូន្យចាកកុសលធម៌ ព្រោះការដែលមានធម៌ ៤ ប្រការនេះនៅក្នុងខ្លួនទុំះ ព្រះដ៏មានព្រះភាគត្រាស់ហៅថាជាសេចក្តីសាបសូន្យ ។ ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ ៤ ប្រការដែលមានក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ព្រោះការដែលមានធម៌ ៤ ប្រការនេះនៅក្នុងខ្លួនទុំះ ព្រះដ៏មានព្រះភាគត្រាស់ហៅថាជាសេចក្តីមិនសាបសូន្យ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺការស្រោលស្តើងរាគៈ ១ ការស្រោលស្តើងទោសៈ ១ ការស្រោលស្តើងមោហៈ ១ មាន

បញ្ញាចក្ខុប្រព្រឹត្តទៅក្នុងឋានទីងងឹតអង្គនដ៏ជ្រាលជ្រៅ ១ ។ ម្នាលអាវុសោទាំង-ឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី ពិចារណាឃើញធម៌ទាំង ៤ ប្រការនេះ ដែលមាននៅក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ទាំងឡាយឡើយ ព្រោះការដែលមានធម៌ ៤ ប្រការនេះនៅក្នុងខ្លួននុ៎ះ ព្រះដ៏មានព្រះភាគត្រាស់ហៅថា ជាសេចក្តីមិនសាបសូន្យ ។

# អដ្ឋកថា

## បរិហានិសូត្រ

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិហានិសូត្រទី ៨ ដូចតទៅនេះ បទថា **គម្ភីរេសុ** បានដល់ ជ្រៅដោយអត្ថ ។ បទថា **ឋានាឋានេសុ** បានដល់ក្នុងហេតុ និងមិនមែនហេតុ ។ បទថា **ន គមតិ** បានដល់ មិននាំទៅ គឺមិនប្រព្រឹត្តទៅ ។ ក្នុងបទថា **បញ្ញាចក្ខុំ** នេះ សូម្បីបញ្ញាកើតអំពីការរៀន ការសាកសួរក៏គួរ សូម្បីបញ្ញាកើតអំពីពិចារណាការចាក់ធ្លុះក៏គួរ ។

**អដ្ឋកថា បរិហានិសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ភិក្ខុនីសូត្រទី ៩

[ ៩ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ភិក្ខុនីមួយរូប បានហៅបុរសម្នាក់មកបង្គាប់ថា នែបុរសអើយ ចូរអ្នកមកអាយ ចូរអ្នកចូលរកព្រះអានន្ទជាម្ចាស់ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះបាទា ព្រះអានន្ទជាម្ចាស់ ដោយត្បូងតាមពាក្យរបស់យើងថា បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុនីឈ្មោះនេះ មានអាពាធ ទទួលទុក្ខវេទនា ឈឺធ្ងន់ នាងក្រាបថ្វាយបង្គំព្រះបាទា ព្រះអានន្ទជាម្ចាស់ ដោយត្បូងដូច្នេះហើយ ចូរទូលយ៉ាងនេះថា សូមព្រះអានន្ទជាម្ចាស់ ករុណាចូលទៅសួរភិក្ខុនីនោះ ក្នុងសម្នាក់ភិក្ខុនី ដោយអាស្រ័យសេចក្តីអនុគ្រោះផងចុះ ។ បុរសនោះ ក៏ទទួលពាក្យនាងភិក្ខុនីនោះថា ព្រះករុណានាងម្ចាស់ ហើយក៏ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ ទើបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ រួចអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ទើបទូលព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុនីឈ្មោះនេះមានអាពាធ ទទួលទុក្ខវេទនា ឈឺធ្ងន់ នាងក្រាបថ្វាយបង្គំព្រះបាទា ព្រះអានន្ទជាម្ចាស់ដោយត្បូង រួចនាងពោលយ៉ាងនេះថា បពិត្រលោកកម្ចាស់ដ៏ចម្រើន សូមព្រះអានន្ទជាម្ចាស់ ករុណាចូលទៅសួរភិក្ខុនីនោះ ក្នុងសម្នាក់ភិក្ខុនី ដោយអាស្រ័យសេចក្តីអនុគ្រោះផងចុះ ។ ព្រះអានន្ទដ៏មានអាយុ ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះអានន្ទ

ដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនាងភិក្ខុនី ។ ឯភិក្ខុនីនោះ បានឃើញព្រះអានន្ទដ៏មានអាយុ និមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏សិងលើគ្រែដណ្តប់ទទូរទាំងក្បាល ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅត្រង់ទីដែលនាងភិក្ខុនីនោះនៅ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ លុះព្រះអានន្ទដ៏មានអាយុគង់ហើយ ទើបនិយាយទៅនឹងនាងភិក្ខុនីនោះ ដូច្នេះថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញ ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យនូវតណ្ហាហើយ គប្បីលះតណ្ហាចេញ ម្នាលនាង កាយនេះកើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះមានះចេញ ម្នាលនាង កាយនេះ កើតមកដោយមេថុន បុគ្គលត្រូវលះបង់នូវមេថុនចេញ ព្រោះថា មេថុននោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាទោសសម្ងាប់នូវហេតុ ។ ក៏ពាក្យដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញ ដូច្នេះនេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បរិភោគនូវអាហារ ពិចារណាដោយឧបាយ មិនបរិភោគដើម្បីលេងទេ មិនបរិភោគដើម្បីស្រវឹងទេ មិនបរិភោគដើម្បីប្រដាប់ទេ មិនបរិភោគដើម្បីស្អិតស្អាងទេ បរិភោគគ្រាន់តែដើម្បីតាំងនៅនៃកាយនេះ ដើម្បី

ញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់សេចក្ដីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ គឺបរិភោគដោយគិតថា អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង ទាំងមិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តទៅនៃឥរិយាបថ ៤ ក្ដី ការមិនមានទោស គឺមិនប្រអូសកាយ មិនប្រអូសចិត្តក្ដី ការនៅជាសុខក្ដី នឹងមានដល់អាត្មាអញ ។ លុះសម័យខាងក្រោយមក ភិក្ខុនោះ ក៏អាស្រ័យអាហារ ហើយលះបង់អាហារចេញ ។ ពាក្យណាដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញដូច្នេះ ពាក្យនោះដែលយើងពោលហើយព្រោះអាស្រ័យហេតុនេះឯង ។ ក៏ពាក្យថា ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យនូវតណ្ហាហើយ គប្បីលះតណ្ហាចេញដូច្នេះនេះយើងបានពោលហើយ ពាក្យនោះដែលយើងពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះបានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្ដម ដោយខ្លួនឯងក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ។ ភិក្ខុនោះក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្ដម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ។ លុះសម័យខាងក្រោយមក ភិក្ខុនោះក៏អាស្រ័យនូវ

តណ្ហា ហើយលះបង់តណ្ហាបាន ។ ពាក្យណាដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យនូវតណ្ហាហើយ គប្បីលះតណ្ហាចេញដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលថា ម្នាលនាង កាយនេះ កើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះមានះចេញ ដូច្នេះនេះ យើងបានពោលហើយ ពាក្យនុ៎ះ ដែលយើងពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្បាលយ៉ាងលោកដ៏មានអាយុនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ចំណែកអាត្មាអញ ចាំបាច់និយាយធ្វើអ្វី ។ លុះសម័យខាងក្រោយមក ភិក្ខុនោះអាស្រ័យមានះ ហើយលះបង់មានះបាន ។ ពាក្យណាដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះមានះចេញដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលនាង កាយនេះ កើតមកដោយមេថុន បុគ្គលត្រូវលះបង់នូវមេថុនចេញ ព្រោះមេថុននោះ

ព្រះដ៏មានព្រះភាគត្រាស់ថា ជាទោស តែងសម្លាប់នូវហេតុ ។ លំដាប់នោះ នាងភិក្ខុនីនោះ ក្រោកអំពីគ្រែហើយ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបចុះទៀបព្រះបាទានៃព្រះអានន្ទដ៏មានអាយុដោយសិរសា ហើយពោលខមាទោសនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទោសកំហុសត្រូវនូវខ្ញុំម្ចាស់ហើយ ដោយខ្ញុំម្ចាស់ជាស្ត្រីល្ងង់ ជាស្ត្រីវង្វេង ជាស្ត្រីមិនឈ្លាសវៃ យ៉ាងណា ខ្ញុំម្ចាស់ឯណាបានធ្វើអំពើយ៉ាងនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះអានន្ទជាម្ចាស់ អត់នូវទោសកំហុសតាមទោសកំហុសដល់ខ្ញុំម្ចាស់នោះ ដើម្បីនឹងសង្រួមតទៅ ។ ព្រះអានន្ទតបថា អើនាង ទោសកំហុសត្រូវនាងហើយ ដោយសានាងជាស្ត្រីល្ងង់ ជាស្ត្រីវង្វេង ជាស្ត្រីមិនឈ្លាសវៃ យ៉ាងណា នាងបានធ្វើអំពើយ៉ាងនេះ ម្នាលនាង កាលណាបើនាងឃើញទោសកំហុស តាមទោសកំហុស ហើយសម្តែងឲ្យសមគួរតាមធម៌ យើងនឹងទទួលទោសកំហុសនោះរបស់នាង ម្នាលនាង ស្ត្រីឯណាបានឃើញទោសកំហុសតាមទោសកំហុស ហើយសម្តែងឲ្យសមគួរតាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នោះជាសេចក្តីចម្រើន របស់ស្ត្រីនោះ ក្នុងវិន័យរបស់ព្រះអរិយៈ ។

# អដ្ឋកថា

## ភិក្ខុនីសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភិក្ខុនីសូត្រទី ៩ ដូចតទៅនេះ បទថា **ឯហិ ត្វំ** បានដល់ ភិក្ខុនីមានចិត្តប្រតិព័ទ្ធក្នុងព្រះថេរៈ ទើបពោលយ៉ាងនេះ ដើម្បីបញ្ជូនបុរសនោះទៅ ។ បទថា **សសីសំ បារុបិត្វា** បានដល់ ដណ្តប់កាយរហូតដល់ក្បាល ។ បទថា **មញ្ចកេ និបជ្ជិ** បានដល់ ភិក្ខុនីប្រញាប់ក្រាលនូវកម្រាល ហើយដេកលើគ្រែនោះ ។ បទថា **ឯតទវោច** សេចក្តីថា ព្រះអានន្ទសង្កេតអាការរបស់ភិក្ខុនីនោះ ទើបបានពោលជាមួយភិក្ខុនីនោះ ដើម្បីសម្តែងអសុភកថាដ៏ពីរោះ ដើម្បីឲ្យភិក្ខុនីលះនូវសេចក្តីលោភ ។

បទថា **អាហារសម្ភូតោ** បានដល់ រាងកាយនេះ កើតមកព្រោះអាហារ គឺចម្រើនឡើងព្រោះអាស្រ័យអាហារ ។ បទថា **អាហារំ និស្សាយ អាហារំ បជហាតិ** សេចក្តីថា បុគ្គលអាស្រ័យកពឡិង្ការាហារដែលជាបច្ចុប្បន្ន សេពអាហារនោះដោយឧបាយយ៉ាងនេះ រមែងលះអាហារ ពោលគឺកម្មចាស់ គប្បីលះតណ្ហាដែលជាការប្រាថ្នាក្នុងកពឡិង្ការាហារ ដែលជាបច្ចុប្បន្ន ។ បទថា **តណ្ហំ បជហាតិ** សេចក្តីថា បុគ្គលអាស្រ័យតណ្ហាដែលជាបច្ចុប្បន្នដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ក្នុងឥឡូវនេះ រមែងលះបុព្វ-តណ្ហា ដែលមានវដ្តៈជាមូល ។ សួរថា តណ្ហាដែលជាបច្ចុប្បន្ននេះ ជាកុសល ឬអកុសល ។ ឆ្លើយថា ជាអកុសល ។ សួរថា គួរសេព ឬមិនគួរសេព ។ ឆ្លើយថា គួរសេព ។ សួរថា ទាញយកបដិសន្ធិមក ឬមិន

ទាញមក ។ ឆ្លើយថា មិនទាញមក ។ តែគួរលះនូវការប្រាថ្នាក្នុងតណ្ហា ដែលគួរសេព ដែលជាបច្ចុប្បន្ននេះឯង ។ បទថា **កិមង្គំ បន** ក្នុងបទថា **សោ ហិ នាម អាយស្មា អាសវានំ ខយា ។បេ។ ឧបសម្បជ្ជ វិហរិស្សតិ កិមង្គំ បនាហំ** នេះ ជាការបរិវិតក្កដល់ហេតុ ។ លោកអធិប្បាយសេចក្ដីនេះថា ភិក្ខុនោះ នឹងធ្វើអរហត្តផលឲ្យជាក់ច្បាស់ ដោយហេតុណា អាត្មាអញនឹងមិនធ្វើឲ្យជាក់ច្បាស់ ភិក្ខុនោះ ក៏ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ សូម្បីអាត្មាអញ ក៏ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធដូចគ្នា អរហត្តផលនោះ នឹងកើតដល់អាត្មាអញផងដែរ ។

បទថា **មានំ និស្សាយ** បានដល់ អាស្រ័យមានះដែលគួរសេព ដែលកើតឡើងហើយយ៉ាងនេះ ។ បទថា **មានំ បជហតិ** បានដល់ បុគ្គលលះបុព្វមានះដែលមានវដ្តៈជាមូល ។ អធិប្បាយថា បុគ្គលនោះ អាស្រ័យមានះណា លះមានះនោះបាន សូម្បីមានះនោះ ក៏ជាអកុសលគួរសេព និងមិនទាញយកបដិសន្ធិមកដូចតណ្ហា តែគួរលះនូវការប្រាថ្នាក្នុងមានះនោះចេញ ។ បទថា **សេតុឃាតោ វុត្តោ ភគវតា** សេចក្ដីថា ព្រះមានព្រះភាគដែលជាពុទ្ធៈ ត្រាស់ប្រៀនប្រដៅឲ្យទម្លាយនូវផ្លូវ គឺទម្លាយនូវបច្ច័យ ។ កាលព្រះថេរៈទេសនាជាស់ស្មារតីដោយអង្គទាំង ៤ នេះហើយ ឆន្ទរាគៈដែលប្រារព្ធព្រះថេរៈ កើតឡើងដល់ភិក្ខុនីនោះ បានអស់ទៅហើយ ។ ភិក្ខុនីនោះ ក៏សូមទោសដែលកន្លងល្មើស ដើម្បីឲ្យព្រះថេរៈអត់ទោសឲ្យ ។ សូម្បី

*ព្រះថេរៈក៏ទទួលទោស ដែលកន្លងល្មើសរបស់ភិក្ខុនីនោះ ។ ដើម្បីសម្ដែងដល់សេចក្ដីនោះ ទើបលោកពោលពាក្យជាដើមថា* **អថ ខោ សា ភិក្ខុនី** *ដូច្នេះ ។*

**អដ្ឋកថា ភិក្ខុនីសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សុគតសូត្រទី ១០

*[ ១០ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្ដី វិន័យព្រះសុគតក្ដី ប្រតិស្ឋានទៅក្នុងលោក ការនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រះសុគតដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមក*

កាន់កំពប្ផីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាព្រះសុគត ។ ម្នាលភិក្ខុទាំង-ឡាយ ចុះវិន័យព្រះសុគតដូចម្ដេច ។ ព្រះសុគតនោះ ទ្រង់សម្ដែងធម៌ ពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិន័យព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ កាល ព្រះសុគតក្ដី វិន័យព្រះសុគតក្ដី ប្រតិស្ឋានទៅក្នុងលោកយ៉ាងនេះ កាលនោះ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនា នេះ រៀនព្រះសូត្រដែលខ្លួនរៀនខុស ដោយបទ និងព្យញ្ជនៈ ដែលរៀប រៀងខុសលំដាប់ ម្នាលភិក្ខុទាំងឡាយ បទ និងព្យញ្ជនៈ ដែលរៀបរៀងខុស លំដាប់ រមែងយល់សេចក្ដីបានដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ នេះជា ធម៌ទី ១ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាមនុស្សដែលគេប្រដៅបាន ដោយក្រ ប្រកបដោយធម៌ ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្ដាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២

ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីចេះដឹងច្រើន មានអាគម គឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ មិនញុំាងបុគ្គលដទៃឲ្យរៀនព្រះសូត្រដោយគោរព លុះអំណឹះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះក៏ដាច់មូល លែងប្រតិស្ឋានទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ប្រជុំនៃជនដែលកើតខាងក្រោយ គឺសទ្ធិវិហារិក និងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំនៃជនទាំងនោះឯង ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ

នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ ប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ធម៌ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀន ត្រូវដោយបទ និងព្យញ្ជនៈ ដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយ បទ និងព្យញ្ជនៈ ដែលរៀបរៀងត្រូវ រមែងយល់សេចក្ដីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលនូវពាក្យប្រៀនប្រដៅខាងស្ដាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីចេះដឹងច្រើន មានអាគម គឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ញ៉ាំងបុគ្គលដទៃឲ្យរៀននូវព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះ មិនបានដាច់ឫស តាំងនៅតៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាប

សូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈមិន ប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈចុះក្នុង ការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បី ដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួន មិនទាន់ធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតខាងក្រោយ គឺសទ្ធិវិហារិក និង អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុទាំងនោះ ប្រជុំជនទាំងនោះឯង ជាអ្នក ប្រតិបត្តិឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈចុះក្នុង ការប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវ គុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីសម្រេចគុណវិសេស ដែល ខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិន ទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្ត ទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុ ទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះ សទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

ឥន្ទ្រិយវគ្គទី ១ ចប់

### ឧទ្ទាននៃឥន្ទ្រិយវគ្គនោះ គឺ

*និយាយអំពីឥន្ទ្រិយ ១ អំពីពល ៣ គឺសទ្ធាពល ១ បញ្ញាពល ១ សតិពល ១ និងបដិសង្ខានពល ១ ជាគម្រប់ ៥ អំពីកប្ប ១ អំពីរោគ ១ អំពីការសាបសូន្យ ១ អំពីនាងភិក្ខុនី ១ អំពីព្រះសុគតនឹងវិន័យរបស់ព្រះសុគត ១ រួមត្រូវជា ១០ ។*

# អដ្ឋកថា

## សុគតសូត្រ

[ ១០ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងសុគតសូត្រទី ១០ ដូចតទៅនេះ បទថា* **ឧគ្គហិតំ** *បានដល់ ប្រកាន់មកក្រៅលំដាប់ ។ បទថា* **បរិយាបុណន្តិ** *បានដល់ បន្ទោបង់ចេញមក គឺពោល ។ ក្នុងបទថា* **បទព្យញ្ជនេហិ** *នេះ លោកពោលថា បទរបស់អត្ថនោះឯង ជាព្យញ្ជនៈដោយព្យញ្ជនៈ ។ បទថា* **ទុន្និក្ខិត្តស្ស** *បានដល់ ប្រើខុស គឺតាំងទុកក្រៅលំដាប់ ។ បទថា* **អត្ថោបិ ទុន្នយោ ហោតិ** *បានដល់ មិនអាចនាំអដ្ឋកថាចេញមកពោលបាន ។ បទថា* **ឆិន្នមូលកោ** *បានដល់ ឈ្មោះថា ឆិន្នមូលកៈ ព្រោះដាច់ភិក្ខុដែលជាមូល គឺដាច់ភិក្ខុដែលជាអាចារ្យ ។ បទថា* **អប្បដិស្សរណោ** *គឺមិនមានទីពឹង ។ បទថា* **ពាហុល្លិកា** *បានដល់ បដិបត្តិដើម្បីសន្សំបច្ច័យ ។ បទថា*

**សាថលិកា** *បានដល់ កាន់យកនូវត្រៃសិក្ខាដូវថយ ។ បទថា* **ឱក្កមនេ បុព្វង្គមា** *បានដល់ នីវរណៈ ៥ លោកហៅថា* **ឱក្កមន** *ព្រោះប្រព្រឹត្តទៅរកទីទាប គឺវិនាស អធិប្បាយថា បែរមុខទៅក្នុងឱក្កមនៈនោះ គឺបែរមុខទៅកាន់ផ្លូវលាសិក្ខា ។ បទថា* **បវិវេកេ** *បានដល់ វិវេក ៣ ។ បទថា* **និក្ខិត្តធុរា** *បានដល់ មិនមានសេចក្តីព្យាយាម ។ គប្បីជ្រាបអត្ថក្នុងទីទាំងពួង ក្នុងសូត្រនេះ ។ល។*

**អដ្ឋកថាសុគតសូត្រទី ១០ ចប់**

**ឥន្ទ្រិយវគ្គទី ១ ចប់**

# សុត្តន្តបិដក

# បដិបទាវគ្គទី ២

## សង្ខិត្តសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ បដិបទា ( ការប្រតិបត្តិ ) នេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា
# បដិបទាវគ្គទី ២

## សង្ខិត្តសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខិត្តសូត្រទី ១ នៃបដិបទាវគ្គទី ២ ដូចតទៅនេះ ឈ្មោះថា បដិបត្តិលំបាក ព្រោះបដិសេធការបដិបត្តិងាយ ឈ្មោះថា បដិបទា ព្រោះគួរបដិបត្តិ ។ ឈ្មោះថា ទន្ធាភិញ្ញា ព្រោះមានការដឹងយឺតយូរ ។ ដោយភាពជាការៈធ្ងន់ ព្រោះបដិបត្តិបានមិនរហ័ស ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយន័យនេះ ។

### អដ្ឋកថា សង្ខិត្តសូត្រទី ១ ចប់

# សុត្តន្តបិដក

## វិត្ថារសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិលំបាក ទាំង

ត្រាស់ដឹងក៏យឺតយូរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី ជាអ្នកមានរាគៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានទោសៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានមោហៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នូវទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ ទន់ខ្សោយ បុគ្គលនោះ រមែងសម្រេចអនន្តរិយគុណ ( មគ្គសមាធិដែលឲ្យផលជាលំដាប់ ) ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី ជាអ្នកមានរាគៈក្លៀវក្លា តែងទទួលទុក្ខទោមនស្សដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានទោសៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានមោហៈក្លៀវក្លា តែងទទួលទុក្ខទោមនស្សដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ របស់បុគ្គលនោះក្លៀវក្លា ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ បុគ្គលនោះ រមែង

សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយ បានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិលំបាក តែងត្រាស់ដឹងឆាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី មិនមែនជាអ្នកមានរាគៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានទោសៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានមោហៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្សដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយនៅទន់ខ្សោយ រមែងកើតប្រាកដដល់បុគ្គលនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ បុគ្គលនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិស្រួលតែត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី មិនមែនជាអ្នកមានរាគៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានទោសៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានមោហៈក្លៀវក្លា តែងមិនទទួល

ទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយក្លៀវក្លា រមែង កើតប្រាកដដល់បុគ្គលនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ បុគ្គល នោះរមែងសម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ បដិបទា មាន ៤ យ៉ាង នេះឯង ។

# អដ្ឋកថា

## វិត្ថារសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិត្ថារសូត្រទី ២ ដូចតទៅនេះ បទថា **អភិក្ខណំ** ប្រែថា រឿយៗ ។ បទថា **អនន្តរិយំ** បានដល់ មគ្គសមាធិ ដែលឲ្យផលជាអនន្តរិយគុណ ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីអរហត្តផល ។ បទថា **បញ្ចិន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៥ ដែលមាន វិបស្សនាជាគម្រប់ ៥ ក្នុងបទថា **បញ្ញិន្ទ្រិយំ** នេះ លោកបំណងយកវិបស្សនា បញ្ញាប៉ុណ្ណោះថា ជាបញ្ញិន្ទ្រិយ ។ ពាក្យដ៏សេស ក្នុងសូត្រនេះ ងាយយល់ ទាំងអស់ ដោយអំណាចដែលត្រាស់ហើយក្នុងបាលី ។

កថាចែកបដិបទាទាំងនេះ មានដូច្នេះ ។ ភិក្ខុក្នុងធម្មវិន័យនេះ មិនធ្លាប់

ធ្វើការប្រកាន់មកអំពីខាងដើម រមែងលំបាកក្នុងការកំណត់រូប រមែងលំបាកក្នុងការកំណត់អរូប រមែងលំបាកក្នុងការកំណត់បច្ច័យ រមែងលំបាកក្នុងកាលទាំង ៣ រមែងលំបាកក្នុងមគ្គាមគ្គ គឺផ្លូវ និងមិនមែនផ្លូវ កាលលំបាកក្នុងឋានៈ ៥ យ៉ាងនេះ រមែងសម្រេចវិបស្សនា កាលសម្រេចវិបស្សនាហើយក៏លំបាកក្នុងវិបស្សនាញាណទាំង ៩ គឺក្នុងឧទយព្វយានុបស្សនាញាណ ១ ក្នុងភង្គានុបស្សនាញាណ ១ ក្នុងភយតុបដ្ឋានញ្ញាណ ១ ក្នុងអាទីនវានុ-បស្សនាញាណ ១ ក្នុងនិព្វិទានុបស្សនាញាណ ១ ក្នុងមុញ្ចិតុកម្យតាញាណ ១ ក្នុងសង្ខារុបេក្ខាញាណ ១ ក្នុងអនុលោមញ្ញាណ ១ ក្នុងគោត្រភូញាណ ១ ហើយទើបសម្រេចលោកុត្តរមគ្គ លោកុត្តរមគ្គនៃភិក្ខុនោះ ឈ្មោះថា បដិបត្តិលំបាកផង ត្រាស់ដឹងលំបាកផង ព្រោះធ្វើឲ្យជាក់ច្បាស់ដោយការធ្ងន់ទៅដោយទុក្ខយ៉ាងនេះ ភិក្ខុណាខាងដើមលំបាក ក្នុងញាណ ៥ តែខាងចុងមិនលំបាក ក្នុងវិបស្សនាញាណ ៩ រមែងធ្វើឲ្យជាក់ច្បាស់នូវមគ្គ មគ្គនោះរបស់ភិក្ខុនោះ ឈ្មោះថា បដិបត្តិលំបាក តែដឹងបានរហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់ដោយមិនធ្ងន់ដោយទុក្ខយ៉ាងនេះ ។ បដិបទា ២ ទៀត គប្បីជ្រាបដោយឧបាយនេះឯង ។

ម្យ៉ាងទៀត បដិបទាទាំងនេះ គប្បីជាក់ច្បាស់ដោយការប្រៀបធៀបនឹងបុរសរកគោ ។ គោ ៤ របស់បុរសម្នាក់ គេចចូលទៅក្នុងព្រៃជ្រៅ ។ បុរសនោះរកគោទាំងនោះក្នុងព្រៃដែលមានបន្ទាក្រាស់ ផ្លូវដែលទៅក៏ទៅបានដោយ

លំបាក គោពួនក្នុងទីដែលមានបន្លាក្រាស់យ៉ាងនោះ ក៏ឃើញដោយសេចក្ដីលំបាក ។ បុរសម្នាក់ទៅដោយសេចក្ដីលំបាក គោឈរនៅត្រង់ទីវាល ក៏ឃើញបានដោយឆាប់រួសរាន់ ។ បុរសម្នាក់ទៀត ទៅដោយផ្លូវស្រឡះ មិនមានបន្លា គោលាក់ខ្លួនក្នុងទីដែលមានបន្លាក្រាស់ ក៏ឃើញដោយលំបាក ។ បុរសម្នាក់ទៀត ទៅដោយស្រួល តាមផ្លូវដែលស្រឡះ គោឈរក្នុងទីស្រឡះ ក៏ឃើញបានឆាប់រួសរាន់ ។ ក្នុងឧបមានោះ អរិយមគ្គ ៤ គប្បីឃើញដូចគោ ៤ ព្រះយោគាវចរដូចបុរសអ្នករកគោ ការបដិបត្តិលំបាកខាងដើមរបស់ភិក្ខុដែលលំបាកក្នុងញាណ ៥ ដូចទៅក្នុងផ្លូវបន្លាក្រាស់ដោយសេចក្ដីលំបាក ការឃើញអរិយមគ្គខាងចុងរបស់បុគ្គលដែលនឿយណាយក្នុងញាណ ៩ ដូចការឃើញគោដែលពួនក្នុងទីដែលស្គុក ឃើញដោយលំបាក ។ គប្បីជ្រាបឧបមាដ៏សេសដោយឧបាយនេះ ។ល។

## អដ្ឋកថា វិត្ថារសូត្រទី ២ ចប់

# សុត្តន្តបិដក

## អសុភសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែ

ត្រាស់ដឹងបាន ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះកំណត់សេចក្តីស្លាប់ តម្កល់ទុកដោយប្រពៃដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យសេក្ខពល ( ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ ) ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយ-ពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយនៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះ ក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរ ក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្តីស្លាប់ តម្កល់ទុកដោយប្រពៃដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យ

នូវសេក្ខពល ( ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ ) ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វិរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះ គឺសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះ ក៏សម្រេចនូវអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ស្ងាត់ចាកវិតក្កវិចារ ក៏បានដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់សុខផង

លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម្មជាតទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ។ ភិក្ខុនោះ ក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ព្រោះស្ងប់ស្ងាត់វិតក្ក និងវិចារ ។បេ។ ក៏ដល់នូវទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។បេ។ ក៏ដល់នូវតតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ ក៏ដល់នូវចតុត្ថជ្ឈាន ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះ ក៏សម្រេចអនន្តរិយគុណ

ដើម្បីអស់អាសវៈទាំងឡាយបានដាច់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានដាច់ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## អសុភសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសុភសូត្រទី ៣ ដូចតទៅនេះ បទថា **អសុភានុបស្សី កាយេ វិហរតិ** សេចក្តីថា ភិក្ខុពិចារណាឃើញក្នុងករជកាយរបស់ខ្លួនថាមិនស្អាត ដោយការចូលទៅប្រៀបធៀបនឹងអសុភ ១០ ដែលខ្លួនឃើញហើយខាងក្រៅ ដោយន័យនេះថា នោះយ៉ាងណា នេះក៏យ៉ាងនោះ អធិប្បាយថា ឃើញកាយរបស់ខ្លួនដោយញាណ ដោយជាវត្ថុមិនស្អាត ដោយជាវត្ថុបដិកូល ។ បទថា **អាហារេ បដិក្កូលសញ្ញី** សេចក្តីថា មានការសម្គាល់ក្នុងកពឡិង្ការាហារថាជាបដិកូល ដោយអំណាចបដិកូល ៩ ។ បទថា **សព្វលោកេ អនភិរតសញ្ញី** សេចក្តីថា ប្រកបដោយការមិនគួរត្រេកអរ គឺដោយសញ្ញាថា គួរខ្ពើមរអើ ក្នុងលោកសន្និវាសដែលជាត្រៃធាតុទាំងអស់ ។ បទថា **សព្វសង្ខារេសុ អនិច្ចានុបស្សី** សេចក្តីថា ពិចារណាឃើញសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ដោយភាពជារបស់

មិនទៀង ។ បទថា **មរណសញ្ញា** បានដល់ សញ្ញាដែលកើតឡើង ព្រោះប្រារព្ធសេចក្តីស្លាប់ ។ បទថា **អជ្ឈត្តំ សុបដ្ឋិតា ហោតិ** បានដល់ ចូលទៅតាំងទុកដោយល្អខាងក្នុងកាយរបស់ខ្លួន ។ លោកពោលវិបស្សនាដែលមានកម្លាំង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ បទថា **សេក្ខពលានិ** បានដល់ កម្លាំងរបស់បុគ្គលដែលត្រូវសិក្សា ។ ពាក្យដ៏សេសក្នុងបទនេះ ងាយយល់ទាំងអស់ ដោយអំណាចបាលី ។ បទថា **អសុភានុបស្សី** ជាដើម លោកពោលដើម្បីសម្តែងដល់បដិបទាលំបាក បឋមជ្ឈានជាដើម លោកពោលដើម្បីសម្តែងបដិបទាងាយស្រួល ។ ព្រោះថា អសុភជាដើម មានបដិកូលជាអារម្មណ៍ ។ តាមប្រក្រតី ចិត្តដែលស្រឡាញ់ រមែងជាប់នៅក្នុងអារម្មណ៍ទាំងនោះ ព្រោះដូច្នោះ កាលចម្រើនអសុភជាដើមនោះ ឈ្មោះថាបដិបត្តិបដិបទាលំបាក ។ បឋមជ្ឈានជាដើម ជាសុខប្រណីត ព្រោះដូច្នោះ អ្នកបដិបត្តិបឋមជ្ឈានជាដើមទាំងនោះ ឈ្មោះថា បដិបត្តិបដិបទាងាយស្រួល ។

ក្នុងសេចក្តីនេះ មានឧបមាដែលជាសាធារណៈដូចតទៅនេះ ពិតហើយ បុរសដែលចូលកាន់សង្គ្រាម ធ្វើស៊ុមដោយបន្ទះក្តារ ហើយស៊កអាវុធ ៥ ចូលកាន់សង្គ្រាម បុរសនោះបំណាងនឹងសម្រាកក្នុងចន្លោះ ទើបចូលទៅកាន់ស៊ុមបន្ទះក្តារ សម្រាក និងផឹកទឹក បរិភោគអាហារជាដើម បន្ទាប់អំពីនោះ ក៏ចូលកាន់សង្គ្រាម ធ្វើនូវចម្បាំងតទៅ ។ ក្នុងការឧបមានោះ គប្បីឃើញថា ការធ្វើសង្គ្រាមជាមួយកិលេស ដូចចូលកាន់សង្គ្រាម កម្លាំងដែលជាទី

អាស្រ័យ ៥ ដូចស៊ុមបន្ទះក្តារ ។ ព្រះយោគាវចរ ដូចបុរសចូលកាន់សង្គ្រាម ឥន្ទ្រិយដែលមានវិបស្សនាជាគម្រប់ ៥ ដូចគ្រឿងស័កអាវុធ ៥ ខណៈចម្រើនវិបស្សនា ដូចពេលចូលសង្គ្រាម វេលាដែលព្រះយោគាវចរចម្រើនវិបស្សនា ខណៈចិត្តុប្បាទមិនមានសេចក្តីត្រេកអរ ក៏អាស្រ័យពល ៥ លួងលោមចិត្តឲ្យត្រេកអរ ដូចកាលអ្នកចម្បាំងបំណាំងនឹងសម្រាក ក៏ចូលទៅកាន់ស៊ុមបន្ទះក្តារ ខណៈដែលព្រះយោគាវចរបង្អោនចិត្តឲ្យត្រេកអរដោយពល ៥ ហើយចម្រើនវិបស្សនាទៀត ក៏បែរត្រឡប់មកទាញយកអរហត្តបាន គប្បីជ្រាបដូចការដែលអ្នកចម្បាំងសម្រាកបរិភោគ និងផឹកហើយត្រឡប់ចូលកាន់សង្គ្រាមតទៅ ។ ក្នុងព្រះសូត្រនេះ ត្រាស់ពល និងឥន្ទ្រិយលាយឡំគ្នា ។

### អដ្ឋកថា អសុភសូត្រទី ៣ ចប់

# សុត្តន្តបិដក

## បឋមខមសូត្រទី ៤

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិមិនអត់ធន់ ១ ប្រតិបត្តិអត់ធន់ ១ ប្រតិបត្តិទូន្មាន

( ឥន្ទ្រិយ ) ១ ប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះ ប្រតិបត្តិមិនអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជេរតបនឹងបុគ្គលដែលជេរ ខឹងតបនឹងបុគ្គលដែលខឹង ប្រកួត ប្រកាន់តបនឹងបុគ្គលដែលប្រកួតប្រកាន់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិមិនអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនជេរតបនឹងបុគ្គល ដែលជេរ មិនខឹងតបនឹងបុគ្គលដែលខឹង មិនប្រកួតប្រកាន់តបនឹងបុគ្គល ដែលប្រកួតប្រកាន់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិទូន្មាន ( នូវឥន្ទ្រិយ ) តើដូចម្តេច ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយមិនកាន់យក នូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺ អភិជ្ឈា និងទោមនស្ស គប្បីជាប់តាមភិក្ខុដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះ ហេតុតែមិនសង្រួមចក្ខុន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សា ចក្ខុន្ទ្រិយ ដល់នូវការសង្រួមចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ... ធុំក្លិន ដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុ-ព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បី ជាប់តាមនូវភិក្ខុដែលជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួម

មនិន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិទូន្មាន ( នូវឥន្ទ្រិយ ) ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្ដោយឲ្យកាម-វិតក្កដែលកើតឡើងហើយ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ធ្វើឲ្យវិនាស មិនឲ្យកើតមាន មិនបណ្ដោយឲ្យព្យាបាទវិតក្ក ដែលកើតឡើងហើយ ... មិនបណ្ដោយឲ្យវិហិង្សាវិតក្ក ដែលកើតឡើងហើយ ... មិនបណ្ដោយឲ្យអកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលកើតឡើងហើយរឿយៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមខមសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមខមសូត្រទី ៤ ដូចតទៅនេះ បទថា **អក្ខមា** បានដល់ បដិបទារបស់បុគ្គលមិនអត់ធន់ ។ បទថា **ខមា** បានដល់ បដិបទារបស់អ្នកអត់ធន់ ។ បទថា **ទមា** បានដល់ បដិបទារបស់បុគ្គល

ដែលទូន្មានឥន្ទ្រិយ ។ បទថា **សមា** បានដល់ បដិបទារបស់បុគ្គលដែលស្ងប់ចាកអកុសលវិតក្ក ។ បទថា **រោសន្តំ បដិរោសតិ** បានដល់ បើគេទ្រគោះបោះបោក រមែងទ្រគោះបោះបោកតប ។ បទថា **ភណ្ឌន្តំ បដិភណ្ឌតិ** បានដល់ គេប្រហារ រមែងប្រហារតប ។៚

**អដ្ឋកថា បឋមខមសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ទុតិយខមសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិមិនអត់ធន់ ១ ប្រតិបត្តិអត់ធន់ ១ ប្រតិបត្តិទូន្មាន ( នូវឥន្ទ្រិយ ) ១ ប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិមិនអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអត់ធន់ចំពោះត្រជាក់ ក្តៅ សេចក្តីឃ្លាន ស្រេក ចំពោះសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្តីដែលអាក្រក់ជូជាតិ ជាអ្នកមិនអត់ធ្មត់ ចំពោះវេទនាដែលកើតឡើងក្នុងសរីរៈរាងកាយ ដែលជាទុក្ខក្លៀវក្លា ក្រហល់ក្រហាយ ខ្លោចផ្សា

មិនត្រជាក់ចិត្ត មិនគាប់ចិត្ត ដែលអាចនឹងឆក់យកជីវិតទៅបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិមិនអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិអត់ធន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអត់ធន់ចំពោះត្រជាក់ ក្ដៅ សេចក្ដីឃ្លាន ស្រេក ចំពោះសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្ដីដែលអាក្រក់ជួជាតិ ជាអ្នកអត់ធ្មត់ ចំពោះវេទនាដែលកើតឡើងក្នុងសរីរៈរាងកាយ ដែលជាទុក្ខក្លៀវក្លា ក្រហល់ក្រហាយ ខ្វាចផ្សា មិនត្រជាក់ចិត្ត មិនគាប់ចិត្ត ដែលអាចនឹងឆក់យកជីវិតទៅបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិទូន្មាន ( នូវឥន្ទ្រិយ ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវភិក្ខុដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮនូវសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្ដាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្តហើយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវភិក្ខុ

ដែលមិនសង្រួមមនិន្ទ្រិយនោះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិទូន្មាន ( នូវឥន្ទ្រិយ ) ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្ដោយឲ្យកាមវិតក្ក ដែលកើតឡើងហើយអាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន មិនបណ្ដោយឲ្យព្យាបាទវិតក្ក ដែលកើតឡើងហើយ ... មិនបណ្ដោយឲ្យវិហឹង្សាវិតក្ក ដែលកើតឡើងហើយ ... មិនបណ្ដោយឲ្យអកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលកើតឡើងហើយរឿយៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិបត្តិស្ងប់រម្ងាប់ ( វិតក្ក ) ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយខមសូត្រ

[ ១៥ ] ក្នុងទុតិយខមសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយខមសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ឧភយសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាកតែត្រាស់ដឹងបានឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណា ទាំងមានសេចក្តីលំបាក ទាំងត្រាស់ដឹងបានក៏យឺតយូរ ម្នាលភិក្ខុទាំងឡាយ បដិបទានេះ ចាត់ជាថោកទាប ដោយហេតុ ២ ស្ថាន គឺថាប្រតិបត្តិលំបាក ចាត់ជាថោកទាប ដោយប្រតិបត្តិលំបាក ១ ប្រតិបត្តិត្រាស់ដឹងបានយឺតយូរ ចាត់ជាថោកទាប ដោយសេចក្តីយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះចាត់ជាបដិបទាថោកទាប ដោយហេតុ ២ ស្ថាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណាលំបាក ត្រាស់ដឹងបានឆាប់ ម្នាលភិក្ខុទាំងឡាយ បដិបទានេះ ចាត់ជាថោកទាប ព្រោះសេចក្តីលំបាក ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណាស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ម្នាលភិក្ខុទាំងឡាយ បដិបទានេះចាត់ជាថោកទាប ព្រោះត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបដិបទាទាំង ៤ នោះ បដិបទាណាស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ម្នាលភិក្ខុទាំងឡាយ បដិបទានេះចាត់ជាថ្លៃថ្លា ដោយហេតុ ២ ស្ថាន គឺថាប្រតិបត្តិស្រួល ចាត់ជាថ្លៃថ្លាដោយប្រតិបត្តិ ១ បដិបទាណា

ត្រាស់ដឹងបានឆាប់ ចាត់ជាថ្លៃថ្លា ដោយការត្រាស់ដឹងបានឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះចាត់ជាបដិបទាថ្លៃថ្លា ដោយហេតុ ២ ស្ថាន ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

## ឧភយសូត្រ

[ ១៦ ] ក្នុងឧភយសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧភយសូត្រទី ៦ ចប់

# សុត្តន្តបិដក

## មហាមោគ្គល្លានសូត្រទី ៧

[ ១៧ ] គ្រានោះ ព្រះសារីបុត្តមានអាយុ ចូលទៅរកព្រះមហាមោគ្គលានមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាមោគ្គល្លានមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ក៏បានពោលនឹងព្រះមហាមោគ្គល្លានមានអាយុថា

ម្នាលអាវុសោមោគ្គល្លាន បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺ ប្រតិបត្តិលំបាក ទាំងត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិបត្តិស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្ដាបដិបទាទាំង ៤ នេះ ចិត្តអ្នកអាស្រ័យនូវបដិបទាណា ទើបរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោសារីបុត្ត បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិបត្តិស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្ដាបដិបទាទាំង ៤ នេះ ចិត្តខ្ញុំអាស្រ័យនូវបដិបទាដែលជាប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់នេះ ទើបរួចចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។

# អដ្ឋកថា

## មហាមោគ្គល្លានសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាមោគ្គល្លានសូត្រទី ៧ ដូចតទៅនេះ មគ្គ ៣ ខាងក្រោមរបស់ព្រះមហាមោគ្គល្លានត្ថេរ ជាសុខាបដិបទាទន្ធាភិញ្ញា គឺបដិបត្តិងាយ ត្រាស់ដឹងយឺតយូរ ។ អរហត្តមគ្គ ជាទុក្ខាបដិបទាខិប្បាភិញ្ញា គឺបដិបត្តិលំបាក ត្រាស់ដឹងរហ័ស ។ ព្រោះដូច្នោះ ទើបព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា **យាយំ បដិបទា ទុក្ខា ខិប្បាភិញ្ញា តយំ មេ បដិបទំ អាគម្ម អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តំ** ប្រែថា ចិត្តរបស់ខ្ញុំរួចផុតហើយចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ព្រោះអាស្រ័យទុក្ខាបដិបទាខិប្បាភិញ្ញា ដូច្នេះ ៕

**អដ្ឋកថា មហាមោគ្គល្លានសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សារីបុត្តសូត្រទី ៨

[ ១៨ ] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរ

រឭកហើយ ក៏គង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះសារីបុត្តដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺ ប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្តាបដិបទាទាំង ៤ នេះ ចិត្តអ្នកអាស្រ័យនូវបដិបទា ដែលនាំឲ្យរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោមោគ្គល្លាន បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺ ប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្តាបដិបទាទាំង ៤ នេះ ចិត្តខ្ញុំអាស្រ័យនូវបដិបទា ដែលជាប្រតិបត្តិស្រួល ទាំងត្រាស់ដឹងបានឆាប់នេះ ទើបរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

# អដ្ឋកថា

## សារីបុត្តសូត្រ

[១៨] គប្បីជ្រាបវិនិច្ឆ័យក្នុងសារីបុត្តសូត្រទី ៨ ដូចតទៅនេះ មគ្គ ៣ ខាងក្រោមរបស់ព្រះធម្មសេនាបតី ជាសុខាបដិបទាទន្ធាភិញ្ញា គឺបដិបត្តិងាយ ត្រាស់ដឹងយឺតយូរ អរហត្តមគ្គ ជាសុខាបដិបទាខិប្បាភិញ្ញា គឺបដិបត្តិងាយ ត្រាស់ដឹងរហ័ស ព្រោះដូច្នោះ ទើបព្រះសារីបុត្តត្ថេរពោលថា **យាយំ បដិបទា សុខា ខិប្បាភិញ្ញា** ដូច្នេះជាដើម ក្នុង ២ សូត្រនេះ គប្បីជ្រាបថា លោកពោលបដិបទាលាយគ្នា ។

**អដ្ឋកថា សារីបុត្តសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សសង្ខារសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដនៅក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសសង្ខារបរិនិព្វាយីក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

ជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសសង្ខារបរិនិព្វាយីក្នុងបច្ចុប្បន្ន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្ដីបដិកូលក្នុងអាហារ កំណត់សេចក្ដីមិនត្រេកអរ ក្នុងលោកទាំងពួង ឃើញនូវសេចក្ដីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្ដីស្លាប់ តម្កល់ទុកដោយប្រពៃព្ធដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យនៅសេក្ខពល ( ធម៌ជាកម្លាំងព្រះសេក្ខៈ ) ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដ៏ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះក៏ជាសសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្នយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្ដីបដិកូលក្នុងអាហារ កំណត់សេចក្ដីមិនត្រេកអរក្នុងលោកទាំងពួង ឃើញនូវសេចក្ដីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្ដីស្លាប់ តម្កល់ទុកដោយប្រពៃព្ធដ៏ខាងក្នុង ។ ភិក្ខុនោះ តែង

អាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយនៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះ នៅទន់ខ្សោយដែរ ភិក្ខុនោះលុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយីយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ននេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្ក វិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដ៏ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះ ទើបជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្នយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលុះតែបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់

ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់ នូវវិតក្កវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ ក៏ចូលកាន់ចតុត្ថជ្ឈាន ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺ សទ្ធាពល ហិរិពល ឱត្តប្បពល វិរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះ លុះបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលុះតែបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមានប្រាកដនៅក្នុងលោក ។

# អដ្ឋកថា

## សសង្ខារសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសសង្ខារសូត្រទី ៩ ដូចតទៅនេះថា បុគ្គលទី ១ ទី ២ ជាសុខវិបស្សកៈ ញ៉ាំងសង្ខារនិមិត្តឲ្យប្រាកដ ដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លា ។ ក្នុងបុគ្គលទាំងនោះ បុគ្គលម្នាក់ រមែងបរិនិព្វាន

ដោយកិលេសបរិនិព្វានក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយ គឺវិបស្សនាមានកម្លាំង បុគ្គលម្នាក់ទៀត បរិនិព្វានមិនបានក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយមិនមានកម្លាំង លុះបានមូលកម្មដ្ឋាននោះប៉ុណ្ណោះ ក្នុងអត្តភាពលំដាប់ទៅ ញុំាងសង្ខារនិមិត្ត ឲ្យប្រាកដដោយសេចក្ដីព្យាយាមដ៏មានកម្លាំងហើយ ទើបបរិនិព្វាន ដោយ កិលេសបរិនិព្វាន ។ បុគ្គលទី ៣ ទី ៤ ជាសមថយានិក គឺមានសមថៈនាំ ទៅ ។ បណ្ដាបុគ្គលទាំងនោះ គប្បីជ្រាបថា បុគ្គលម្នាក់ ធ្វើកិលេសឲ្យអស់ ទៅ ក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយមានកម្លាំង ដោយមិនចាំបាច់ប្រើសេចក្ដី ព្យាយាមខ្លាំងក្លា បុគ្គលម្នាក់ធ្វើកិលេសឲ្យអស់ទៅ មិនបានក្នុងអត្តភាពនេះ ក្នុងលោកនេះ ព្រោះឥន្ទ្រិយមិនមានកម្លាំង លុះបានមូលកម្មដ្ឋាននោះប៉ុណ្ណោះ ក្នុងអត្តភាពលំដាប់តទៅ ធ្វើកិលេសឲ្យអស់ទៅដោយមិនចាំបាច់ប្រើសេចក្ដី ព្យាយាមឲ្យខ្លាំងក្លា ដូច្នេះ ។ល។

**អដ្ឋកថា សសង្ខារសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## យុគនទ្ធសូត្រទី ១០

[ ២០ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ក្នុងទីនោះ ព្រះអានន្ទដ៏មានអាយុ បានហៅភិក្ខុទាំង-ឡាយមកថា ម្នាលភិក្ខុដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតប ថេរវាចានៃព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មាន អាយុ ក៏បានពោលពាក្យដូច្នេះថា ម្នាលអាវុសោទាំងឡាយ សហធម្មិក ឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ព្យាករនូវការដល់ព្រះអរហត្តក្នុងសម្នាក់ខ្ញុំ ដោយមគ្គទាំង ៤ ឬបណ្តាមគ្គទាំង ៤ នុ៎ះ មគ្គណាមួយ ដោយអាការ ទាំងពួង ។ មគ្គទាំង ៤ គឺអ្វីខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុង សាសនានេះ ចម្រើនវិបស្សនា មានសមថៈជាប្រធាន កាលលោកចម្រើន វិបស្សនា មានសមថៈជាប្រធាន មគ្គក៏កើតឡើង ។ លោកក៏បន្ទុំចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំចម្រើន ធ្វើឲ្យច្រើនឡើងនូវមគ្គ នោះ លោកក៏អាចលះបង់សញ្ញោជនៈទាំងឡាយបាន ទាំងអនុស័យក៏អស់ ទៅ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនសមថៈ មាន វិបស្សនាជាប្រធាន កាលលោកចម្រើនសមថៈមានវិបស្សនាជាប្រធាន មគ្គ ក៏កើតឡើង ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោក បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោជនៈបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើន

សមថៈ និងវិបស្សនា ជាគូនឹងគ្នា កាលលោកចម្រើនសមថៈ និងវិបស្សនា ជាគូនឹងគ្នា មគ្គក៏កើតឡើង ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោជនៈបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ចិត្តរបស់ភិក្ខុដែលឧទ្ធច្ចៈ ( វិបស្សនូបក្កិលេស ១០ ) ក្នុងសមថៈ និងវិបស្សនា ធម៌ក្ដួចកាន់មាំ ម្នាលអាវុសោទាំងឡាយ ដល់សម័យដែលចិត្តឈប់នឹង ស្ងប់ស្ងៀម មានអារម្មណ៍ខ្ពស់ឯក នៅខាងក្នុង ជាសមាធិ មគ្គរមែងកើតឡើងដល់ភិក្ខុនោះ ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោជនៈទាំងឡាយបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្ដី ជាភិក្ខុនីក្ដី ព្យាករនូវការដល់ព្រះអរហត្ត ក្នុងសម្នាក់ខ្ញុំ ដោយមគ្គទាំង ៤ នេះ ឬក៏បណ្ដាមគ្គទាំង ៤ នោះ ដោយមគ្គណាមួយ ដោយអាការទាំងពួងបាន ។

**បដិបទាវគ្គទី ២ ចប់**

## ឧទ្ទាននៃបដិបទាវគ្គនោះ គឺ

និយាយអំពីបដិបទា ៤ យ៉ាងដោយសង្ខេប ១ អំពីបដិបទា ៤ យ៉ាងដោយពិស្ដារ ១ អំពីបដិបទា ៤ យ៉ាង មានភិក្ខុពិចារណាឃើញថា មិនស្អាតជាដើម ១ អំពីបដិបទា ៤ យ៉ាង

មានសេចក្តីអត់ធន់ជាដើម ២ លើក អំពីបដិបទារួមគ្នាដោយ
ចំណែកពីរ ១ អំពីរឿងព្រះមោគ្គល្លាន ១ អំពីព្រះសារីបុត្ត
១ អំពីសសង្ខារបរិនិព្វាយីជាដើម ១ អំពីការចម្រើនសមថៈ
និងវិបស្សនា ជាគូនឹងគ្នា ១ ។

# អដ្ឋកថា

## យុគនទ្ធសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយុគនទ្ធសូត្រទី ១០ ដូចតទៅនេះ
បទថា **សមថបុព្វង្គមំ** បានដល់ ធ្វើសមថៈទៅខាងមុខ គឺឲ្យជាបុរេចារិក ។
បទថា **មគ្គោ សញ្ជាយតិ** បានដល់ លោកុត្តរមគ្គទី ១ រមែងកើតឡើង ។
បទថា **សោ តំ មគ្គំ** សេចក្តីថា ឈ្មោះថា អាសេវនៈជាដើមមិនមានដល់
មគ្គដែលប្រព្រឹត្តទៅក្នុងខណៈចិត្ត ១ តែកាលញ៉ាំងមគ្គទី ២ ឲ្យកើតឡើង
លោកពោលថា អ្នកសេពចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះឯង ។ បទថា
**វិបស្សនាបុព្វង្គមំ** បានដល់ ធ្វើវិបស្សនាឲ្យទៅខាងមុខ គឺឲ្យជាបុរេចារិក ។
បទថា **សមថំ ភាវេតិ** សេចក្តីថា ដោយប្រក្រតី បុគ្គលបានវិបស្សនា
តាំងនៅក្នុងវិបស្សនា រមែងញ៉ាំងសមាធិឲ្យកើតឡើង ។

បទថា **យុគនទ្ធំ ភាវេតិ** បានដល់ ធ្វើឲ្យជាគូជាប់គ្នាទៅ ។ ក្នុងសេចក្តីនោះ ភិក្ខុមិនអាចនឹងប្រើចិត្តដួងនោះចូលសមាបត្តិ ហើយប្រើចិត្តដួងនោះឯង ពិចារណាសង្ខារបាន ។ តែភិក្ខុនេះចូលសមាបត្តិដរាបណា រមែងពិចារណាសង្ខារដរាបនោះ ពិចារណាសង្ខារដរាបណា រមែងចូលសមាបត្តិដរាបនោះ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា ភិក្ខុចូលបឋមជ្ឈាន កាលចេញអំពីបឋមជ្ឈានហើយ ពិចារណាសង្ខារទាំងឡាយ កាលពិចារណាសង្ខារទាំងឡាយហើយ ចូលទុតិយជ្ឈាន ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ កាលចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ពិចារណាសង្ខារទាំងឡាយ ដោយអាការយ៉ាងនេះ ភិក្ខុនេះ ឈ្មោះថា ចម្រើនបឋមវិបស្សនាឲ្យជាគូគ្នា ។ បទថា **ធម្មុទ្ធច្ចវិគ្គហិតំ** សេចក្តីថា ដែលឧទ្ធច្ចៈ គឺវិបស្សនូបក្កិលេស ១០ ក្នុងធម៌ គឺសមថៈ និងវិបស្សនាចាប់ហើយ គឺចាប់តោងដោយល្អ ។ ដោយបទថា **ហោតិ សោ អាវុសោ សមយោ** នេះ លោកពោលដល់កាលដែលបានសប្បាយ ៧ ។ បទថា **យន្តំ ចិត្តំ** បានដល់ ចិត្តដែលឈានចុះកាន់វិថីនៃវិបស្សនា ក្នុងសម័យណាប្រព្រឹត្តទៅហើយ ។ បទថា **អជ្ឈត្តំយេវ សន្តិដ្ឋតិ** សេចក្តីថា ចិត្តឈានចុះកាន់វិថីនៃវិបស្សនាហើយ ឈប់នៅក្នុងអារម្មណ៍ បានដល់ អារម្មណ៍ខាងក្នុងនោះឯង ។ បទថា **សន្និសីទតិ** បានដល់ ស្ងៀមដោយប្រពៃដោយអំណាចនៃអារម្មណ៍ ។ បទថា **ឯកោទិ ហោតិ** បានដល់ ចិត្តមាន

*អារម្មណ៍តែមួយ ។ បទថា* **សមាធិយតិ** *បានដល់ ចិត្តតាំងទុកដោយប្រពៃ គឺតាំងទុកល្អហើយ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។*

## អដ្ឋកថាយុគនទ្ធសូត្រទី ១០ ចប់
## បដិបទាវគ្គទី ២ ចប់

# សុត្តន្តបិដក

# សញ្ចេតនិយវគ្គទី ៣

## ចេតនាសូត្រទី ១

[ ២១ ] ម្នាលភិក្ខុទាំងឡាយ កាលបើកាយទ្វារមាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះកាយសញ្ចេតនាជាហេតុ ម្នាលភិក្ខុទាំងឡាយ កាលបើវចីទ្វារមាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះវចីសញ្ចេតនាជាហេតុ ម្នាលភិក្ខុទាំងឡាយ កាលបើមនោទ្វារមាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះមនោសញ្ចេតនាជាហេតុ ឬព្រោះអវិជ្ជាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងកាយសង្ខារដោយខ្លួនឯង ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងកាយសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្តីដឹងច្បាស់ តាក់តែងកាយសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដែលមិនមានសេចក្តីដឹងច្បាស់ តាក់តែងកាយសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងវចីសង្ខារដោយខ្លួនឯង ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើនឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងវចីសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ

បុគ្គលមានសេចក្ដីដឹងច្បាស់ តាក់តែងវចីសង្ខារដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងមនោ-សង្ខារដោយខ្លួនឯង ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងមនោសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្ដីដឹងច្បាស់ តាក់តែងមនោសង្ខារ ដែលបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនមានសេចក្ដីដឹងច្បាស់ តាក់តែងមនោសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជាតែងជាប់តាមទៅក្នុងធម៌ទាំងនេះ ព្រោះអវិជ្ជាវិនាស រលត់មិនមានសេសសល់ កាយនោះ រមែងមិនជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន វាចានោះ រមែងមិនជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ចិត្តនោះ រមែងមិនជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ខេត្ត រមែងមិនមាន ... វត្ថុ រមែងមិនមាន ... អាយតនៈរមែងមិនមាន ... អធិករណ៍រមែងមិនជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាពនេះ មាន ៤ យ៉ាង ។ ការបានអត្តភាព ៤ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាពដែលសញ្ចេតនារបស់ខ្លួននាំទៅ មិនមែនជាសញ្ចេតនារបស់បុគ្គលដទៃនាំទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែល

សញ្ចេតនារបស់បុគ្គលដទៃនាំទៅ មិនមែនជាសញ្ចេតនារបស់ខ្លួននាំទៅ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅផង សញ្ចេតនារបស់បុគ្គលដទៃនាំទៅផងក៏មាន ។ ម្នាលភិក្ខុទាំង-ឡាយ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅក៏មិនមែន សញ្ចេតនារបស់បុគ្គលដទៃនាំទៅក៏មិនមែនក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្ត-ភាព មាន ៤ យ៉ាងនេះឯង ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតដែលព្រះអង្គសម្តែងសង្ខេបនេះ ខ្ញុំព្រះអង្គអាចយល់សេចក្តីដោយពិស្តារបានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅ មិនមែនជាសញ្ចេតនារបស់បុគ្គលដទៃនាំទៅ ការច្យុតិចាកកាយនេះ របស់ពួកសត្វទាំងនោះ រមែងមាន ព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្ត-ភាព ដែលសញ្ចេតនារបស់បុគ្គលដទៃនាំទៅ មិនមែនសញ្ចេតនារបស់ខ្លួននាំទៅ ការច្យុតិចាកកាយនោះ របស់ពួកសត្វទាំងនោះ រមែងមាន ព្រោះសញ្ចេតនារបស់បុគ្គលដទៃជាហេតុ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅផង សញ្ចេតនារបស់បុគ្គលដទៃនាំទៅផង ការច្យុតិចាកកាយនោះ របស់

ពួកសត្វទាំងនោះ រមែងមានព្រោះសញ្ចេតនារបស់ខ្លួនជាហេតុផង ព្រោះសញ្ចេតនារបស់បុគ្គលដទៃជាហេតុផង ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្ដាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាពដែលសញ្ចេតនា របស់ខ្លួននាំទៅក៏មិនមែន សញ្ចេតនារបស់បុគ្គលដទៃនាំទៅក៏មិនមែន គេគប្បីឃើញថាបានដល់ទេវតាពួកណា ។ ម្នាលសារីបុត្ត គេឃើញថា បានដល់ទេវតាដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតិចាកកាយ ( នេវសញ្ញានាសញ្ញាយតនៈ ) នោះហើយ ជាអាគាមិបុគ្គល មកកាន់អត្តភាពនេះទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតិចាកកាយនោះហើយជាអនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានលះបង់ឱរម្ភាគិយសញ្ញោជនៈ តែបុគ្គលនោះក៏បានសម្រេចនេវសញ្ញានាសញ្ញាយតនៈក្នុងបច្ចុប្បន្ន បុគ្គលនោះក៏ត្រេកអរនឹងឈាននោះ ពេញចិត្តនឹងឈាននោះ ដល់នូវសេចក្ដីរីករាយនឹងឈាននោះ កាលលោកតាំងនៅក្នុងឈាននោះ ចុះចិត្តស៊ប់ក្នុងឈាននោះ សម្រេចសម្រាន្តដោយឈាននោះយ៉ាងច្រើន មិនបានឲ្យសាបសូន្យចាកឈាននោះទៅវិញ លុះដល់ធ្វើមរណកាលទៅ តែងទៅកើតជាមួយនឹងពួកទេវតាដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនៈ កាលបុគ្គលនោះ ច្យុតិចាកភពនោះ

ក៏ជាអាគាមិបុគ្គល មកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត ចំណែក បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់ឱរម្ភាគិយសញ្ញោជនៈ បុគ្គលនោះបាន សម្រេចនេវសញ្ញានាសញ្ញាយតនៈ ក្នុងបច្ចុប្បន្ន បុគ្គលនោះក៏ត្រេកអរនឹង ឈាននោះ ពេញចិត្តនឹងឈាននោះ ដល់នូវសេចក្តីរីករាយដោយឈាននោះ កាលលោកតាំងនៅក្នុងឈាននោះ ចុះចិត្តស៊ប់ក្នុងឈាននោះ សម្រេច សម្រាន្តដោយឈាននោះយ៉ាងច្រើន មិនបានសាបសូន្យចាកឈាននោះទៅ វិញ លុះដល់ធ្វើមរណកាលទៅ តែងទៅកើតជាមួយនឹងពួកទេវតា ដែល កើតក្នុងនេវសញ្ញានាសញ្ញាយតនៈ កាលបុគ្គលនោះច្យុតិចាកភពនោះ ក៏ជា អនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត នេះឯងជា ហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតិចាក កាយនោះ បានជាអាគាមិបុគ្គល មកកាន់អត្តភាពនេះទៀត ម្នាលសារីបុត្ត នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតិចាកកាយនោះ បានជាអនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។

# អដ្ឋកថា
# សញ្ចេតនិយវគ្គទី ៣

## ចេតនាសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចេតនាសូត្រទី ១ នៃសញ្ចេតនិយវគ្គទី ៣ ដូចតទៅនេះ បទថា **កាយេ** បានដល់ កាលកាយទ្វារ អធិប្បាយថា កាលការកម្រើកកាយមាន ។ បទថា **កាយសញ្ចេតនាហេតុ** ជាដើម ការសម្រេចនៃចេតនាក្នុងកាយទ្វារ ឈ្មោះថា **កាយសញ្ចេតនា** គឺការដាក់ចិត្តធ្វើតាមផ្លូវកាយ កាយសញ្ចេតនានោះ មាន ២០ គឺកាមាវចរកុសល ៨ អកុសល ១២ ។ វចីសញ្ចេតនាក៏ដូចគ្នា មនោសញ្ចេតនាក៏ដូចគ្នា ។ម្យ៉ាងទៀត មហគ្គតចេតនា ៩ ក៏បានក្នុងបទនេះ ។ បទថា **កាយសញ្ចេតនាហេតុ** បានដល់ ព្រោះកាយសញ្ចេតនាជាបច្ច័យ ។ បទថា **ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ** បានដល់ សុខកើតឡើងខាងក្នុងខ្លួន ព្រោះកុសលកម្ម ៨ ជាបច្ច័យ ទុក្ខកើតឡើង ព្រោះអកុសលកម្ម ១២ ជាបច្ច័យ ។ ក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **អវិជ្ជាបច្ចយា វា** បានដល់ ព្រោះអវិជ្ជាជាហេតុ ។ ពិតហើយ បើអវិជ្ជាដែលត្រូវបិទបាំងជាបច្ច័យ កាលបើដូច្នោះ ចេតនាដែលជាបច្ច័យនៃសុខ និងទុក្ខក្នុងទ្វារ ៣ រមែងកើតឡើង ។ នេះលោកពោលដោយអំណាចបច្ច័យដែលជាមូល ដោយប្រការដូច្នេះ ។

ក្នុងបទថា **សាមំ វា** ជាដើម បុគ្គលដែលអ្នកដទៃមិនបានប្រើ កាល

តាក់តែងដោយខ្លួនឯង ឈ្មោះថា តាក់តែងកាយសង្ខារដោយខ្លួនឯង ។ បបួលអ្នកដទៃឲ្យតាក់តែងកាយសង្ខារណា អ្នកដទៃ ឈ្មោះថា តាក់តែងកាយ-សង្ខារនោះរបស់បុគ្គលនោះ ។ បុគ្គលណាដឹងកុសលថាជាកុសល ដឹងអកុសលថាជាអកុសល ដឹងកុសលវិបាកថាជាកុសលវិបាក ដឹងអកុសល-វិបាកថាជាអកុសលវិបាក រមែងតាក់តែងសង្ខារ ២០ ក្នុងកាយទ្វារ បុគ្គលនេះ ឈ្មោះថា តាក់តែងសង្ខារ បុគ្គលណាមិនដឹងយ៉ាងនេះ តាក់តែងសង្ខារ បុគ្គលនេះ ឈ្មោះថា មិនដឹងច្បាស់តាក់តែងសង្ខារ ។ ក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។

ក្នុងសេចក្តីនោះ គប្បីជ្រាបការធ្វើដោយមិនដឹង ដូច្នេះថា ។ ពួកក្មេងតូចៗ គិតថា អញនឹងធ្វើកិច្ចដែលមាតាបិតាធ្វើ ទើបថ្វាយបង្គំព្រះចេតិយ បូជាដោយផ្កា ថ្វាយបង្គំភិក្ខុសង្ឃ ទាំងដែលមិនដឹងថាជាកុសល ការធ្វើនោះ ក៏ជាកុសលទាំងអស់ ។ ឯសត្វតិរច្ឆាន មានម្រឹគ និងបក្សីជាដើមក៏ដូចគ្នា ស្តាប់ធម៌ ថ្វាយបង្គំព្រះសង្ឃ ថ្វាយបង្គំចេតិយ ទាំងដឹងខ្លះ មិនដឹងខ្លះ ការធ្វើនោះក៏ជាកុសលដូចគ្នា ពួកក្មេងតូចៗ យកដៃ និងជើងទាត់ វាយមាតាបិតា លើកដៃសម្លុត គំហក ចោលដុំដី ជេរ មេគោដេញតាមពួកភិក្ខុ ពួកឆ្កែដេញតាមខាំ សីហៈ និងខ្លាជាដើមដេញតាមសម្លាប់ ការធ្វើនេះ ដឹងខ្លះមិនដឹងខ្លះ គប្បីជ្រាបថា ជាអកុសលកម្ម ។

ឥឡូវនេះ គប្បីរួបរួមចេតនាដែលប្រមូលចុះក្នុងទ្វារទាំង ៣ ។ សួរថា

សេចក្តីនេះ ដូចម្តេច ។ ឆ្លើយថា ក្នុងកាយទ្វារ ចេតនាដែលធ្វើដោយខ្លួនឯង ជាមូល ២០ ដែលអ្នកដទៃប្រើឲ្យធ្វើជាមូល ២០ ដែលដឹងជាមូល ២០ ដែលមិនដឹងជាមូល ២០ រួមជាចេតនា ៨០ ។ ក្នុងវចីទ្វារក៏ដូចគ្នា ។ តែក្នុងមនោទ្វារ វិកប្បនីមួយៗ ២៩ គុណនឹង ៤ វិកប្ប ត្រូវជា ១១៦ ដូច្នោះ ចេតនាទាំងអស់ ក្នុងទ្វារ ៣ មាន ២៧៦ ចេតនាទាំងអស់នោះ រមែងរាប់បានថាជាសង្ខារក្ខន្ធទាំងអស់ ការសោយអារម្មណ៍ ដែលសម្បយុត្តដោយសង្ខារក្ខន្ធនោះ ជាវេទនាក្ខន្ធ អាការចាំជាសញ្ញា ចិត្តជាវិញ្ញាណក្ខន្ធ កាយជាឧបាទារូប ធាតុ ៤ ជាបច្ច័យនៃឧបាទារម្មណ៍ ជាភូតរូប ៤ ខន្ធ ៥ ដូចពោលមកនេះ ឈ្មោះថា ទុក្ខសច្ច ។ បទថា **ឥមេសុ ភិក្ខវេ ធម្មេសុ អវិជ្ជានុបតិតា** សេចក្តីថា អវិជ្ជាធ្លាក់ទៅហើយក្នុងចេតនាធម៌ មានប្រភេទដូចពោលហើយទាំងនេះ ដោយអំណាចសហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ឈ្មោះថា លោកសម្តែងដល់វដ្ដៈ និងអវិជ្ជា ដែលជាមូលនៃវដ្ដៈ ដោយអាការយ៉ាងនេះ ។

ឥឡូវនេះ ទើបព្រះមានព្រះភាគ កាលទ្រង់សរសើរព្រះខីណាស្រព ដែលចម្រើនវិបស្សនា ដោយហេតុមានប្រមាណប៉ុណ្ណោះហើយ សម្រេចអរហត្ត ទើបត្រាស់ថា **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អសេសវិរាគនិរោធា** បានដល់ ខ្ចាក់ចោលដោយមិនមានសេសសល់ និងរម្ងត់ដោយមិនមានសេសសល់ ។ បទថា **សោ**

**កាយោ ន ហោតិ** សេចក្តីថា ការធ្វើតាមផ្លូវកាយរបស់ព្រះខីណាស្រព រមែងប្រាកដជាដើមយ៉ាងនេះ គឺការបោសលានចេតិយ ការបោសលានព្រះពោធិព្រឹក្ស ការឈានទៅមុខ ការឈានថយក្រោយ ការធ្វើវត្តបដិបត្តិ ។ តែក្នុងកាយទ្វារ ចេតនា ២០ របស់ព្រះខីណាស្រពនោះ រមែងដល់នូវភាពជាកិច្ច មិនមានវិបាកជាធម្មតា ។ ដោយហេតុនោះ ទើបលោកពោលថា **សោ កាយោ ន ហោតិ យម្បច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ** ប្រែថា កាយដែលជាបច្ច័យឲ្យសុខទុក្ខខាងក្នុង របស់ព្រះខីណាស្រពនោះកើត មិនមានចេតនា ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ លោកបំណងយកថាជាកាយក្នុងទីនេះ ។ ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យនេះដូចគ្នា ។ សូម្បីបទជាដើមថា **ខេត្តំ** ដូច្នេះ ក៏ជាឈ្មោះរបស់កម្មដែលជាកុសល និងអកុសលនោះឯង ។ ពិតហើយ សុខ និងទុក្ខនោះ លោកពោលថា ឈ្មោះថា **ខេត្ត** ព្រោះអត្ថថា ជាទីដុះនៃវិបាក ឈ្មោះថា **វត្ថុ** ព្រោះអត្ថថា ជាគ្រឹះ ជាទីតាំង ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាហេតុ ឈ្មោះថា **អធិករណ** ព្រោះអត្ថថា ជារឿងរ៉ាវ ។

ព្រះសាស្តា កាលទ្រង់សម្តែងកម្មដែលប្រមូលចុះដោយទ្វារ ៣ ដោយឋានៈ ប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់ឋានៈដែលជាផលនៃកម្មនោះ ទើបត្រាស់ថា **ចត្តារោ មេ ភិក្ខវេ** ដូច្នេះជាដើម ។ ក្នុងបទនោះ បទថា **អត្តភាវប្បដិលាភា** បានដល់ អត្តភាពដែលខ្ទបបានហើយ ។

បទថា **អត្តសញ្ចេតនា កមតិ** បានដល់ ចេតនាដែលខ្លួនត្រិះរិះ រមែងនាំទៅ គឺរមែងប្រព្រឹត្តទៅ ។ ក្នុងបទជាដើមថា **អត្តសញ្ចេតនាហេតុ តេសំ សត្តានំ តម្ហា កាយា ចុតិ ហោតិ** ប្រែថា ការចុតិអំពីកាយនោះ របស់សត្វទាំងឡាយនោះ រមែងមានព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ បានដល់ពួកទេវតាដែលជាខិឌ្ឌាបទោសិក គឺទេវតាប្រាថ្នាតែលេង រមែងចុតិព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ ។ ដ្បិតថា កាលទេវតាទាំងនោះភ្លើតភ្លើនក្នុងការពេញចិត្តរបស់ជាទិព្វក្នុងសួននន្ទវន ចិត្តលតាវន និងបារុសកវនជាដើម ខ្សោយកម្លាំង ព្រោះភ្លេចផឹក និងបរិភោគ រមែងរីងស្ងួតទៅ ព្រោះដាច់នូវអាហារ ដូចផ្កាដែលស្វិតទៅព្រោះកម្ដៅថ្ងៃ ។

មនោបទោសិកា គឺទេវតាដែលប្រទូស្តផ្លូវចិត្ត រមែងចុតិព្រោះសញ្ចេតនារបស់អ្នកដទៃជាហេតុ បានដល់ទេវតាជាន់ចាតុម្មហារាជិកា ។ បានឮថា បណ្ដាទេវតាទាំងនោះ ទេវបុត្រមួយអង្គបំណងនឹងលេងនក្ខត្តឫក្ស មួយអន្លើដោយបរិវារ ជិះរថទៅតាមផ្លូវ ពេលនោះ ទេវបុត្រមួយអង្គទៀតចេញទៅ ឃើញទេវបុត្រនោះកំពុងទៅខាងមុខ ទើបក្រោធពោលថា នេះអ្វីហ្ន៎ អ្នកសុំទាននេះ ឃើញទេវបុត្រដូចអាត្មាអញ ធ្វើដូចមិនធ្លាប់ឃើញ ហើយធ្វើព្រងើយ ហើយតម្កើងខ្លួន ហែក្បួនទៅតាមផ្លូវ ទេវបុត្រដែលធ្វើដំណើរទៅខាងមុខ បែរមើលឃើញទេវបុត្រនោះក្រោធ គិតថា ឈ្មោះថាមនុស្សក្រោធដឹងបានងាយ កាលដឹងថា ទេវបុត្រនោះក្រោធពិតមែន ទើប

ក្រោធតបវិញ ពោលថា ឯងធ្វើអ្វីយើងបាន យើងបានសម្បត្តិនេះមកដោយអំណាចទាន និងសីលជាដើម មិនមែនបានមកដោយអំណាចរបស់ឯង កាលទេវបុត្រមួយអង្គក្រោធ មួយអង្គទៀតមិនក្រោធ មិនជាការថ្វីឡើយ តែកាលជនទាំង ២ ក្រោធ សេចក្តីក្រោធរបស់ទេវបុត្រមួយអង្គ ជាបច្ច័យរបស់ទេវបុត្រមួយអង្គទៀត សេចក្តីក្រោធរបស់ទេវបុត្រអង្គនោះ ក៏ជាបច្ច័យរបស់ទេវបុត្រមួយអង្គទៀត ព្រោះដូច្នោះ ទេវបុត្រទាំង ២ រមែងចុតិ ទាំងដែលនាងទេពអប្សរកំពុងយំសោកនោះឯង ។

មនុស្សទាំងឡាយ រមែងចុតិព្រោះសញ្ចេតនារបស់ខ្លួន និងសញ្ចេតនារបស់អ្នកដទៃជាហេតុ អធិប្បាយថា មនុស្សទាំងឡាយរមែងចុតិ ព្រោះហេតុសញ្ចេតនារបស់ខ្លួន និងនៃសញ្ចេតនារបស់អ្នកដទៃ ។ ពិតហើយ មនុស្សទាំងឡាយ កាលក្រោធហើយ ក៏យកដៃខ្លះ ជើងខ្លះ វាយខ្លួនដោយខ្លួនឯងចងដោយចំណង គឺខ្សែជាដើមខ្លះ កាត់ក្បាលដោយដាវខ្លះ បរិភោគថ្នាំពុលខ្លះ លោតក្នុងជ្រោះខ្លះ លោតទឹកខ្លះ ចូលគំនរភ្លើងខ្លះ យកដំបង ឬសស្ត្រាប្រហារអ្នកដទៃឲ្យស្លាប់ខ្លះ ។ សញ្ចេតនារបស់ខ្លួនក្តី សញ្ចេតនារបស់អ្នកដទៃក្តី រមែងប្រព្រឹត្តទៅក្នុងមនុស្សទាំងនោះ ដោយអាការយ៉ាងនេះ ។

បទថា **កតមេ តេន ទេវា ឧជ្ឈត្តា** សេចក្តីថា គប្បីឃើញទេវតាទាំងនោះដូចម្តេច ឬថា គប្បីឃើញទេវតាទាំងនោះ ដោយអត្តភាពនោះដូចម្តេចដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈសួរបញ្ហានេះ ការពោលដោយ

ខ្ទួនឯង មិនទាន់គ្រប់គ្រាន់ឬ ។ ឆ្លើយថា មិនទាន់គ្រប់គ្រាន់ ។ បទនេះ ជាបញ្ហាពុទ្ធវិស័យ ដោយសការៈរបស់បញ្ហា ព្រោះហេតុនោះ ទើបព្រះថេរៈមិនពោល ។ បទថា **តេន ចជ្ជញា** បានដល់ គប្បីឃើញដោយអត្ថភាពនោះ ។ បញ្ហានេះរមែងបានក្នុងកាមាវចរខ្លះ រូបាវចរខ្លះ ក្នុងខាងក្រោម តែត្រាស់កំណត់ដោយភវគ្គព្រហ្ម ឈ្មោះថា ត្រាស់ដោយឥតសេសសល់ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ បទថា **អាគន្តាពោ ឥត្ថត្តំ** បានដល់ ជាអ្នកត្រឡប់មកកាន់ភាពយ៉ាងនេះ គឺកាន់ភាពជាកាមាវចរនិងបញ្ចក្ខន្ធនោះឯង មិនកើតក្នុងភពនោះឡើយ មិនបានកើតក្នុងភពខាងលើ ។ បទថា **អនាគន្តាពោ ឥត្ថត្តំ** បានដល់ ជាអ្នកមិនត្រឡប់មកកាន់ខន្ធបញ្ចកៈនេះ គឺជាអ្នកមិនកើតខាងក្រោម អធិប្បាយថា ជាអ្នកកើតក្នុងភពនោះខ្លះ ជាអ្នកកើតក្នុងខាងលើខ្លះ ជាអ្នកបរិនិព្វានក្នុងភពនោះឯងខ្លះ ។ បទនេះ គប្បីជ្រាបសត្វដែលកើតខាងលើ ដោយអំណាចសត្វទាំងឡាយដែលកើតហើយ ក្នុងភពជាន់ទាប ។ ខន្ធបញ្ចកៈនេះ មិនមានក្នុងភវគ្គព្រហ្ម ។ ពាក្យដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថា ចេតនាសូត្រទី ១ ចប់

# សុត្តន្តបិដក

## វិភត្តិសូត្រទី ២

[ ២២ ] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ បានហៅពួកភិក្ខុមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលតបថេរវាចានៃព្រះសារីបុត្តដ៏មានអាយុថា ព្រះករុណា អាវុសោ ។ ទើបព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ ក៏អាចធ្វើឲ្យជាក់ច្បាស់នូវអត្ថប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យយល់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវអត្ថប្បដិសម្ភិទានោះដោយអនេកបរិយាយបាន ។ បើអ្នកណាមានសេចក្តីសង្ស័យ ងឿងឆ្ងល់ អ្នកនោះចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្មៀវឆ្លាសលើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ ក៏អាចធ្វើឲ្យជាក់ច្បាស់នូវធម្មប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យជាក់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវធម្មប្បដិសម្ភិទានោះដោយអនេកបរិយាយបាន ។ បើអ្នកណាមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ អ្នកនោះចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយ ដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្មៀវឆ្លាសលើសលុបក្នុងធម៌ទាំងឡាយ គង់នៅ ចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។

ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ អាចធ្វើឲ្យជាក់ច្បាស់នូវនិរុត្តិប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យជាក់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវនិរុត្តិប្បដិសម្ភិទានោះ ដោយអនេកបរិយាយបាន ។ បើអ្នកណាមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ អ្នកនោះ ចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយ ដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្លៀវឆ្លាសលើសលុបក្នុងធម៌ទាំង-ឡាយ គង់នៅចំពោះមុខយើងទាំងឡាយ ស្រាប់ហើយ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧសម្បទាបានកន្លះខែ អាចធ្វើឲ្យជាក់ច្បាស់នូវបដិភាណប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យជាក់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវបដិភាណប្បដិសម្ភិទានោះ ដោយអនេកបរិយាយបាន ។ បើអ្នកឯណាមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ អ្នកនោះ ចូរសួរប្រស្នានឹងខ្ញុំចុះខ្ញុំនឹងឆ្លើយ ដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្លៀវឆ្លាស លើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។

# អដ្ឋកថា

## វិភត្តិសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិភត្តិសូត្រទី ២ ដូចតទៅនេះ បទថា **អត្ថប្បដិសម្ភិទា** បានដល់ ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថទាំង-ឡាយ ៥ ។ បទថា **ឱធិសោ** គឺដោយហេតុ ។ បទថា **ព្យញ្ជនសោ** គឺដោយអក្ខរៈ ។ បទថា **អនេកបរិយាយេន** គឺដោយហេតុច្រើនយ៉ាង ។ បទថា **អាចិក្ខាមិ** ប្រែថា ប្រាប់ ។ បទថា **ទេសេមិ** គឺពោលធ្វើឲ្យប្រាកដ ។ បទថា **បញ្ញាបេមិ** គឺឲ្យបុគ្គលនោះដឹង ។ បទថា **បដ្ឋបេមិ** គឺលើកឡើងឲ្យប្រព្រឹត្តទៅហើយ ។ បទថា **វិវរាមិ** គឺប្រាប់បែបផែនឲ្យបើកផ្ទារ ។ បទថា **វិភជាមិ** គឺប្រាប់បែបផែននូវការចែក ។ បទថា **ឧត្តានីករោមិ** គឺប្រាប់អត្ថដែលជ្រៅឲ្យរាក់ ។ បទថា **សោ មំ បញ្ហេន** បានដល់ សូមបុគ្គលនោះចូលទៅសួរបញ្ហានឹងខ្ញុំ ។ បទថា **អហំ វេយ្យាករណេន** សេចក្តីថា ខ្ញុំព្រះអង្គនឹងញុំាងចិត្តរបស់បុគ្គលនោះឲ្យត្រេកអរ ដោយការស្រាយបញ្ហា ។ បទថា **យោ នោ ធម្មានំ សុកុសលោ** សេចក្តីថា ព្រះសាស្តាទ្រង់ឈ្លាសក្នុងធម៌ ដែលទ្រង់សម្រេចហើយ ទ្រង់ប្រថាប់នៅចំពោះមុខត្រាស់ថា បើ **អត្ថប្បដិសម្ភិទា** តថាគតមិនទាន់ធ្វើឲ្យជាក់ច្បាស់ ម្នាលសារីបុត្រ អ្នកចូរធ្វើឲ្យជាក់ច្បាស់មុនហើយ ទ្រង់នឹងហាម ព្រោះហេតុនោះទើបព្រះសារីបុត្រ ឈ្មោះថា អង្គុយក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តាបន្លឺសីហនាទ ។ គប្បីជ្រាបក្នុងបទទាំងអស់ដោយឧបាយនេះ ។ ក្នុងបដិ-

សម្បិទាទាំងនេះ បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទាជាលោកិយផង ជាលោកុត្តរផង ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថា វិភត្តិសូត្រទី ២ ចប់

# សុត្តន្តបិដក

## កោដ្ឋិកសូត្រទី ៣

[ ២៣ ] គ្រានោះ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាកោដ្ឋិកៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាស រលត់មិនមែនសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានទេឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាស រលត់មិនមានសេស

សល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាស រលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មានក៏មិនមែន មិនមានក៏មិនមែនឬ ។ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ចុះសេចក្តីនៃភាសិតនេះគប្បីយល់បានដោយប្រការដូចម្តេច ។ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាស រលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមាន ឈ្មោះថា ធ្វើធម៌មិនបានយឺតយូរឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦

វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមាន ឈ្មោះថា ធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះ ឈ្មោះថា ធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែន ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ ។ ម្នាលអាវុសោ ផស្សាយតនៈទាំង ៦ នៅប្រព្រឹត្តទៅបានដរាបណា បបញ្ចធម៌ ( ធម៌ជាគ្រឿងយឺតយូរ ) ក៏មាននៅដរាបនោះ បបញ្ចធម៌នៅប្រព្រឹត្តទៅបានដរាបណា ផស្សាយតនៈទាំង ៦ ក៏ប្រព្រឹត្តទៅបានដរាបនោះ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ បបញ្ចធម៌ក៏រលត់ទៅ បបញ្ចធម៌ក៏ស្ងប់ទៅ ។

# អដ្ឋកថា

## កោដ្ឋិកសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោដ្ឋិកសូត្រទី ៣ ដូចតទៅនេះ បទថា **ឆន្នំ ផស្សាយតនានំ** បានដល់ ជាអណ្តូងកើតនៃផស្សៈ អធិប្បាយថា ទីដែលកើតនៃផស្សៈ ។ បទថា **អត្ថញ្ញំ កិញ្ចិ** សេចក្តីថា ព្រះមហាកោដ្ឋិកៈសួរថា

កាលផស្សាយតនៈទាំងនោះ រលត់ដោយមិនសេសសល់ កិលេសណាមួយ ក្រៅអំពីនោះ ច្រើន តិច នៅមានឬ ។ ក្នុងបទថា **ឆន្នំ កិញ្ចិ** ព្រះមហាកោដ្ឋិកៈក៏សួរថា កិលេសតិចតួចក៏មិនមានឬ ។ ក្នុង ២ បទដ៏សេសក៏មានន័យដូច្នេះ ។ ព្រះមហាកោដ្ឋិកៈសួរបញ្ហា ៤ នេះ ដោយអំណាចសស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ ឯកច្ចសស្សតទិដ្ឋិ គឺយល់ឃើញថាទៀងដោយចំណែកខ្លះ និងអមរាវិក្ខេបទិដ្ឋិ គឺការយល់ឃើញដោយបោះពាក្យបោះសម្ដីមិនឲ្យស្លាប់ខ្លួន ។ ដោយហេតុនោះ ព្រះថេរៈ គឺ ព្រះសារីបុត្រកាលជំទាស់នូវបញ្ហាដែលព្រះមហាកោដ្ឋិកៈសួរហើយសួរទៀត ទើបពោលថា **មា ហេវំ** ដូច្នេះ ។ ពាក្យថា **ហិ** ក្នុងពាក្យនេះ គឺ **មា ហេវំ** ត្រឹមតែជានិបាត អធិប្បាយថា អ្នកកុំពោលយ៉ាងនេះ ។ ព្រះមហាកោដ្ឋិកៈសួរដោយអាការមានសស្សតទិដ្ឋិជាដើមថា វត្ថុណាមួយដទៃ ដោយអំណាចការចូលទៅប្រកាន់ថា អត្តាមានឬ គឺឈ្មោះថា អត្តាណាមួយដទៃមានឬ ។ សួរថា ព្រះថេរៈ គឺព្រះមហាកោដ្ឋិកៈនេះជាអត្តបលទ្ធិ កាន់លទ្ធិថាមានអត្តាឬ ។ ឆ្លើយថា មិនមែនអត្តបលទ្ធិទេ តែភិក្ខុមួយរូបដែលអង្គុយនៅក្នុងទីនោះ មានលទ្ធិយ៉ាងនេះ ភិក្ខុនោះមិនអាចសួរបាន ព្រះមហាកោដ្ឋិកៈសួរយ៉ាងនេះ ដើម្បីឲ្យព្រះសារីបុត្រដោះស្រាយនូវលទ្ធិនោះ ។ ព្រះមហាកោដ្ឋិកៈគិតថា មហាសាវកទាំងឡាយឆ្លើយបញ្ហានេះ ក្នុងពុទ្ធកាល ដល់បុគ្គលដែលមានលទ្ធិយ៉ាងនេះ ក្នុងអនាគតកាល ទើបសួរដើម្បីកាត់ឱកាសដែលនឹងពោលចរចា ។

បទថា **អបបញ្ចំ បបញ្ចេតិ** បានដល់ មិនធ្វើនូវការយឺតយូរ ក្នុងទីដែលគួរធ្វើឲ្យយឺតយូរ គឺរាំងផ្លូវដែលមិនគួររាំង ។ បទថា **តាវតា បបញ្ចស្ស គតិ** សេចក្ដីថា គតិនៃផស្សាយតនៈ ៦ នៅមានដរាបណា គតិនៃបបញ្ចធម៌ គឺធម៌ធ្វើឲ្យយឺតយូរ មានតណ្ហា ទិដ្ឋិ មានះ ក៏មានដរាបនោះ ។ បទថា **ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា បបញ្ចនិរោធោ បបញ្ចវូបសមោ** ប្រែថា នៃអាវុសោ ផស្សាយតនៈ ៦ រលត់ដោយការខ្ជាក់ចោលមិនមានសេសសល់ បបញ្ចធម៌រលត់ បបញ្ចធម៌ក៏ស្ងប់រម្ងាត់ទៅ ។ សេចក្ដីថា កាលអាយតនៈ ៦ នេះ រលត់ដោយប្រការទាំងពួង សូម្បីបញ្ចធម៌ក៏ឈ្មោះថា រលត់ទៅ ឈ្មោះថា រម្ងាប់ទៅ តែក្នុងអរូបភព ផស្សាយតនៈ ៥ របស់ទេវតាដែលជាបុថុជ្ជន រលត់ទៅក៏ពិត តែព្រោះផស្សាយតនៈទី ៦ មិនទាន់រលត់ បបញ្ចធម៌ ៣ ក៏ឈ្មោះថា មិនទាន់លះបាន ។ លោកពោលបញ្ហានេះ ដោយអំណាចបញ្ចវោការភពរបស់សត្វដែលមានខន្ធ ៥ ប៉ុណ្ណោះ ៕

## អដ្ឋកថា កោដ្ឋិកសូត្រទី ៣ ចប់

# សុត្តន្តបិដក

## អានន្ទសូត្រទី ៤

[ ២៤ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះមហាកោដ្ឋិតៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាកោដ្ឋិតៈដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏បានសួរព្រះមហាកោដ្ឋិតៈដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ។ កាលបើខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិន

មានសេសសល់ អ្វីដទៃតិចតួច មិនមានឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ចុះសេចក្តីនៃភាសិតនេះ គប្បីយល់បានដោយប្រការដូចម្តេច។ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួចមាន ឈ្មោះថា ធ្វើធម៌ដែលមិនបានយឺតយូរ ឲ្យយឺតយូរ កាលពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមាន ឈ្មោះថា ធ្វើធម៌ដែលមិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះ ឈ្មោះថា ធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែន ឈ្មោះថា ធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ ។ ម្នាលអាវុសោ ផស្សាយតនៈទាំង ៦ នៅប្រព្រឹត្តទៅបានដរាបណា បបញ្ចធម៌

ក៏ប្រព្រឹត្តទៅបានដរាបនោះ បបញ្ចធម៌នៅប្រព្រឹត្តទៅបានដរាបណា ផស្សា-យតនៈទាំង ៦ ក៏នៅប្រព្រឹត្តទៅបានដរាបនោះ ម្នាលអាវុសោ ព្រោះផស្សា-យតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ បបញ្ចធម៌ក៏រលត់ទៅ បបញ្ចធម៌ក៏ស្ងប់រម្ងាប់ទៅ ។

# អដ្ឋកថា

## អានន្ទសូត្រ

[ ២៤ ] ក្នុងអានន្ទសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអានន្ទសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ឧបវាណសូត្រទី ៥

[ ២៥ ] គ្រានោះ ព្រះឧបវាន:ដ៏មានអាយុ ចូលទៅរកព្រះសារីបុត្ត ដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះឧបវាន:ដ៏មានអាយុ អង្គុយ

ក្នុងទីសមគួរហើយ ក៏បានសួរព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបានដោយវិជ្ជាឬ ។ ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជា និងចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជា និងចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជា អ្នកក៏ពោលថា ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបានដោយចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជា និងចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជា និងចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយប្រការដូចម្ដេច ។ ម្នាលអាវុសោ បើបុគ្គលនឹងធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជាហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថាធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយ

ចរណៈហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថា ធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជា និងចរណៈហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថា នឹងធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជា និងចរណៈហើយ បុថុជ្ជន ក៏ឈ្មោះថា នឹងធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ ព្រោះបុថុជ្ជន វៀរចាកវិជ្ជា និងចរណៈ ម្នាលអាវុសោ បុគ្គលប្រាសចាកចរណៈហើយ រមែងមិនដឹង មិនឃើញតាមសេចក្តីពិតបាន បុគ្គលប្រកបដោយចរណៈហើយ រមែងដឹង រមែងឃើញ តាមសេចក្តីពិតបាន កាលបុគ្គលដឹង ឃើញតាមសេចក្តីពិត ក៏រមែងធ្វើនូវទីបំផុតទុក្ខបាន ។

# អដ្ឋកថា

## ឧបវាណសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបវានសូត្រទី ៥ ដូចតទៅនេះ បទថា **វិជ្ជាយន្តករោ ហោតិ** សេចក្តីថា បុគ្គលធ្វើទីបំផុតវដ្តទុក្ខបានដោយវិជ្ជា គឺធ្វើវដ្តទុក្ខឲ្យអស់ ឲ្យដាច់ ក្នុងបទដ៏សេសក៏មានន័យដូចគ្នា ។ បទថា **សឧបាទានោ** ប្រែថា ជាអ្នកមានការប្រកាន់ ។ បទថា **អន្តករោ អភវិស្ស** គឺបុគ្គលធ្វើទីបំផុតនៃវដ្តទុក្ខបាន ។ បទថា **ចរណសម្បន្នោ** គឺដល់ព្រមហើយ

ដោយចរណធម៌ ១៥ ប្រការ ។ បទថា **យថាភូតំ ជានំ បស្សំ អន្តករោ ហោតិ** សេចក្តីថា បុគ្គលឃើញដោយមគ្គប្បញ្ញា តាមសេចក្តីពិតហើយ ឈ្មោះថា ជាអ្នកធ្វើនូវទីបំផុតនៃវដ្តទុក្ខ តាំងនៅ ព្រោះដូច្នោះ ទើបព្រះសារីបុត្តត្រូវឲ្យបញ្ចប់ដោយអគ្គធម៌ គឺអរហត្ត ។ល។

**អដ្ឋកថា ឧបាទានសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អាយាចនសូត្រទី ៦

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា កាលបើប្រាថ្នា ( ធ្វើខ្លួន ) ឲ្យត្រឹមត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណសម្បត្តិដូចជាព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសារីបុត្ត និងមោគ្គល្លានទុំះ ទុកជាជញ្ជីង ជាបែបផែនដល់ពួកភិក្ខុជាសាវករបស់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណសម្បត្តិដូចជាខេមាភិក្ខុនី និងឧប្បលវណ្ណាភិក្ខុនី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខេមាភិក្ខុនី និងឧប្បលវណ្ណាភិក្ខុនីទុំះ ទុកជាជញ្ជីង ជាបែបផែនដល់ពួកភិក្ខុនីជាសាវិកា

របស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មា អញមានគុណសម្បត្តិដូចជាចិត្តគហបតី និងហត្ថកអាឡវកៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តគហបតី និងហត្ថកអាឡវកៈនុ៎ះ ទុកជាជញ្ជីង ជាបែបផែនដល់ពួកឧបាសកជាសាវ័ករបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណសម្បត្តិដូចជាឧបាសិកាឈ្មោះខុជ្ជុត្តរា និងវេឡុកណ្ឌកិយានន្ទមាតា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខុជ្ជុត្តរាឧបាសិកា និងវេឡុកណ្ឌកិយានន្ទមាតានុ៎ះ ទុកជាជញ្ជីង ជាបែបផែនដល់ពួកឧបាសិកា ជាសាវិកាបស់តថាគត ។

# អដ្ឋកថា

## អាយាចនសូត្រ

[ ២៦ ] អាយាចនសូត្រទី ៦ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងអដ្ឋកថា ឯកនិបាតខាងដើម ។៚

**អដ្ឋកថា អាយាចនសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## រាហុលសូត្រទី ៧

[ ២៧ ] គ្រានោះឯង ព្រះរាហុលដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា នែរាហុល បឋវីធាតុដែលជាខាងក្នុងខ្លួន និងបឋវីធាតុជាខាងក្រៅនោះ ក៏ជាបឋវីធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញបឋវីធាតុនោះ គួរតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញបឋវីធាតុនុ៎ះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងបឋវីធាតុ រមែងញ៉ាំងចិត្តឲ្យនឿយណាយក្នុងបឋវីធាតុ ។ នែរាហុល អាបោធាតុដែលជាខាងក្នុង និងអាបោធាតុជាខាងក្រៅនុ៎ះ ក៏ជាអាបោធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញអាបោធាតុនុ៎ះ គួរតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញអាបោធាតុនុ៎ះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងអាបោធាតុ រមែងញ៉ាំងចិត្តឲ្យនឿយណាយក្នុងអាបោធាតុ ។ នែរាហុល តេជោធាតុដែលជាខាងក្នុង និងតេជោធាតុជាខាងក្រៅនុ៎ះ ក៏ជាតេជោធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញតេជោធាតុតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញ

តេជោធាតុនុ៎ះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងតេជោធាតុ រមែងញ៉ាំងចិត្តឲ្យនឿយណាយ ក្នុងតេជោធាតុ ។ នែរាហុល វាយោធាតុដែលជាខាងក្នុង និងវាយោធាតុជាខាងក្រៅនុ៎ះ ក៏ជាវាយោធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញវាយោធាតុនុ៎ះគួរតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញវាយោធាតុនុ៎ះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃតាមហេតុយ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងវាយោធាតុ រមែងញ៉ាំងចិត្តឲ្យនឿយណាយក្នុងវាយោធាតុ ។ នែរាហុល ភិក្ខុពិចារណាឃើញច្បាស់នូវធាតុទាំង ៤ នេះថា មិនមែនខ្លួន មិនមែនកើតក្នុងខ្លួន ក្នុងកាលណា នែរាហុល ភិក្ខុនេះតថាគតហៅថា បានផ្តាច់ផ្តិលតណ្ហា គាស់រម្លើងសញ្ញោជនៈ ធ្វើទីបំផុតទុក្ខបានហើយ ព្រោះត្រាស់ដឹងនូវការលះសេចក្តីប្រកាន់តាមហេតុ ។

# អដ្ឋកថា

## រាហុលសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរាហុលសូត្រទី ៧ ដូចតទៅនេះ បទថា **អជ្ឈត្តិកា** បានដល់ បឋវីធាតុក្នុង ២០ អាការ មានសក់ជាដើម មានលក្ខណៈរឹង ។ បទថា **ពាហិរា** បានដល់ គប្បីជ្រាបបឋវីធាតុក្នុងថ្ម និងភ្នំ

ជាដើម ដែលមិនមានឥន្ទ្រិយជាខាងក្រៅ មានលក្ខណៈរឹង ។ គប្បីជ្រាបភាពដ៏សេសដោយន័យនេះឯង ។ បទថា **នេតំ មម នេសោហមស្មិ ន មេសោ អត្តា** នេះ លោកពោលដោយអំណាចការបដិសេធនូវសេចក្តីប្រកាន់ដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។ បទថា **សម្មប្បញ្ញាយ ទដ្ឋព្វំ** បានដល់ គប្បីឃើញដោយមគ្គប្បញ្ញា ដោយហេតុ ដោយការណ៍ ។

បទថា **ទិស្វា** បានដល់ ឃើញដោយមគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ បទថា **អច្ឆេជ្ជិ តណ្ហំ** បានដល់ កាត់នូវតណ្ហាដែលគប្បីសម្លាប់ដោយមគ្គ មួយអន្លើដោយមូល ។ បទថា **វិវត្តយិ សញ្ញោជនំ** បានដល់ រើ គឺដកនូវសំយោជនៈ ១០ ។ បទថា **សម្មាមានាភិសមយា** បានដល់ ព្រោះលះនូវមានះ ៩ យ៉ាង ដោយហេតុ ដោយការណ៍ ។ បទថា **អន្តមកាសិ ទុក្ខស្ស** បានដល់ ធ្វើវដ្តទុក្ខឲ្យដាច់ផ្លូវ អធិប្បាយថា ធ្វើហើយនៅតាំង ព្រះសាស្តាត្រាស់វិបស្សនាក្នុងរាហុលោវាទសូត្រ ក្នុងសំយុត្តនិកាយដោយប្រការដូច្នេះ ។ ក្នុងចូឡរាហុលោវាទសូត្រក៏ត្រាស់វិបស្សនា ត្រាស់ការវៀរចាកមុសាវាទរបស់ភិក្ខុកំលោះក្នុងរាហុលោវាទសូត្រ ក្នុងអម្ពលដ្ឋិ-ការាម ។ ត្រាស់វិបស្សនាប៉ុណ្ណោះ ក្នុងមហារាហុលោវាទសូត្រ ។ ត្រាស់ចតុក្កោដិកសុញ្ញតាក្នុងអង្គុត្តរនិកាយនេះ ។៚

**អដ្ឋកថា រាហុលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ជម្ពាលីសូត្រទី ៨

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង តែងមានក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការរម្ងត់សក្កាយ កាលភិក្ខុនោះ កំពុងធ្វើទុកក្នុងចិត្តនូវការរម្ងត់សក្កាយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនស្ងប់ចុះក្នុងការរលត់សក្កាយ ម្នាលភិក្ខុទាំងឡាយ ការរម្ងត់សក្កាយនុ៎ះ របស់ភិក្ខុនោះ មិនគប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានដៃប្រឡាក់ជ័រស្អិត ចាប់មែកឈើ ដៃបុរសនោះស្អិតជាប់ជាប់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ( ការរម្ងត់សក្កាយ ) កាលបើលោកធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសក្កាយនិរោធ ម្នាលភិក្ខុទាំងឡាយ សក្កាយនិរោធនុ៎ះ របស់ភិក្ខុនោះឯង មិនគប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ កាលបើលោកធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងសក្កាយនិរោធ ម្នាលភិក្ខុទាំងឡាយ សក្កាយនិរោធនុ៎ះ របស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំង-

ឡាយ ប្រៀបដូចបុរសមានដៃស្អាតចាប់មែកឈើ ដៃរបស់បុរសនោះ មិនស្អិត មិនកាន់ មិនជាប់ទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិដ៏ល្អិតណាមួយ ។ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ កាលបើលោកធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅចុះស៊ប់ក្នុងសក្កាយនិរោធ ម្នាលភិក្ខុទាំងឡាយ សក្កាយនិរោធនុ៎ះ របស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះ របស់ភិក្ខុនោះឯង មិនគប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចត្រពាំងដ៏ស្មោកគ្រោកដែលកើតឡើង រាប់ដោយឆ្នាំដ៏ចម្រើន បុរសបិទមាត់រង្វះ សម្រាប់បង្ហូរចូលរបស់ត្រពាំងនោះ បើកមាត់រង្វះសម្រាប់បង្ហូរចេញ ភ្លៀងសោតក៏មិនគប្បីបង្អុរជារទឹកដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ការធ្លាយភ្លឺត្រពាំងនុ៎ះ ក៏មិនសម្រេចបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្ត នូវការទម្លាយអវិជ្ជា ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ការទម្លាយអវិជ្ជានុ៎ះ របស់ភិក្ខុ

នោះឯង មិនគប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះ របស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចត្រពាំងស្មោកគ្រោកដែលកើតឡើងរាប់ដោយឆ្នាំដ៏ច្រើន បុរសបើកមាត់រង្វះ សម្រាប់បង្ហូរចូលរបស់ត្រពាំងនោះ បិទមាត់រង្វះសម្រាប់បង្ហូរចេញ ភ្លៀងសោតក៏បង្អុរនូវធារទឹកដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ការធ្លាយភ្លឺត្រពាំងនោះ ក៏សម្រេចបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះ របស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង តែងមានក្នុងលោក ។

# អដ្ឋកថា

## ជម្ពាលីសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជម្ពាលីសូត្រទី ៨ ដូចតទៅនេះ បទថា **សន្តំ ចេតោវិមុត្តឹ** បានដល់ សមាបត្តិ ៨ ណាមួយ ។ បទថា **សក្កាយនិរោធំ** បានដល់ រលត់សក្កាយ ដែលបានដល់ វដ្ដៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ អធិប្បាយថា និព្វាន ។ បទថា **ន បក្ខន្ទតិ** បានដល់ មិនស្ទុះទៅដោយអំណាចអារម្មណ៍ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **ន បាដិកង្ខោ** បានដល់ មិនគប្បីសង្ឃឹមបាន ។ បទថា **ន លបគតេន** បានដល់ ប្រឡាក់ជ័រស្អិត ។

ក្នុងសេចក្ដីនេះ គួរនាំមកប្រៀបដូចបុរសដែលបំណងនឹងឆ្លងទៅកាន់ត្រើយនាយ បានឮថា បុរសម្នាក់បំណងនឹងឆ្លងស្ទឹងទៅកាន់ត្រើយនាយ ដែលមានខ្សែទឹកហូរខ្លួលខ្លាញ់ ច្រើនទៅដោយត្រីកាច គិតថា ត្រើយអាយគួរខ្លៀស មានភ័យចំពោះមុខ ត្រើយនាយជាទីក្សេម ជាទីផុតភ័យ អាត្មាអញនឹងធ្វើម្ដេចហ្ន៎ ទើបឆ្លងទៅកាន់ត្រើយនាយបាន ឃើញដើមថ្ងាន់ ៨ ដើមនៅរៀងគ្នា ទើបសម្រេចចិត្តថា អញគួរទៅតាមលំដាប់របស់ដើមឈើនេះបាន ឈ្មោះថា ដើមថ្ងាន់ មានមែករអិល កាលចាប់មែកទាញទុកមិនបាន ទើបយកជ័រជ្រៃ និងជ័រលៀបជាដើមណាមួយលាបដៃ និងជើង យកដៃស្រវាចាប់មែកមួយ ។ ដៃក៏ជាប់ត្រង់មែកនោះឯង យកដៃឆ្វេង ជើងស្ដាំ ជើងឆ្វេង គោងក៏ជាប់ទៀត ព្រោះហេតុនោះ ដៃ និងជើងទាំង ៤ ជាប់នៅ

ត្រង់មែកនោះឯង ។ បុរសនោះ សំយុងខ្លួនចុះ កាលភ្លៀងធ្លាក់ គាត់ក៏ធ្លាក់ចូលក្នុងស្ទឹង លេចក្នុងក្រសែទឹកដែលពេញ ក្លាយជាចំណីក្រពើជាដើម ។ ក្នុងសេចក្តីនោះ ក្រសែនៃសង្សារ គប្បីឃើញដូចក្រសែទឹក ។ ព្រះយោគាវចរ ដូចបុរសបំណងនឹងឆ្លងត្រើយស្ទឹង សក្កាយដូចត្រើយអាយ និព្វានដូចត្រើនាយ សមាបត្តិ ៨ ដូចដើមថ្ងាន់ ៨ ដើម ដែលដុះរៀងគ្នា ការមិនជម្រះធម៌ ដែលជាអន្តរាយចំពោះឈាន និងវិបស្សនាឲ្យបរិសុទ្ធ ហើយចូលសមាបត្តិ ដូចយកដៃដែលប្រឡាក់ជ័យ ចាប់ត្រង់មែកឈើ កាលត្រូវការជាប់ចិត្តទាញទុកក្នុងបឋមជ្ឈាន ដូចយកដៃ និងជើងតោងត្រង់មែកឈើ សំយុងខ្លួនចុះ ខណៈដែលកិលេសកើតក្នុងទ្វារ ៦ ដូចភ្លៀងធ្លាក់លើខ្សែទឹក ខណៈដែលលិចចុះក្នុងក្រសែសង្សារ សោយទុក្ខក្នុងអបាយ ៤ ដូចកាលដែលលិចចុះក្នុងខ្សែទឹកដ៏ពេញ ជាចំណីរបស់ក្រពើជាដើម ។

បទថា **សុធោតេហិ ហត្ថេហិ** បានដល់ ដោយដៃដែលលាងស្អាតល្អហើយ ក្នុងសេចក្តីនេះ គប្បីប្រៀបធៀបដូច្នោះដូចគ្នា ។ បុរសម្នាក់ឆ្លងត្រើយ គិតថា ឈ្មោះថា ដើមថ្ងាន់រលោង បុគ្គលដែលចាប់ដោយដៃដែលស្មោកគ្រោកក៏គប្បីជាប់ ទើបលាងដៃ និងជើងឲ្យស្អាត ហើយចាប់ត្រង់មែកមួយ ឡើងដើមទី ១ ចុះអំពីដើមទី ១ ឡើងដើមទី ២ ។បេ។ ចុះអំពីដើមទី ៧ ឡើងដើមទី ៨ ចុះអំពីដើមទី ៨ ហើយក៏ដល់ទីដែលផុតភ័យ ក្នុងត្រើយនាយ ។ ក្នុងសេចក្តីនោះ កាលដែលព្រះយោគីគិតថា អាត្មាអញនឹងចូលសមាបត្តិ ៨

កាលចេញអំពីសមាបត្តិហើយ ក៏ទាញយកអរហត្តឲ្យបាន ដូច្នេះ គប្បីជ្រាប ដូចកាលដែលបុរសនោះគិតថា អញនឹងឆ្លងទៅត្រើយនាយ ដោយដើមឈើទាំងនេះ ជម្រះធម៌ដែលជាអន្តរាយចំពោះឈាន និងវិបស្សនា ហើយចូលសមាបត្តិ ដូចការទាញមែកឈើដោយដៃស្អាត ពេលចូលបឋមជ្ឈាន ដូចកាលឡើងដើមឈើទី ១ ក្នុងដើមឈើទាំងនោះ កាលដែលមិនត្រូវការជាប់ចិត្តចង់ទុកក្នុងបឋមជ្ឈាន ចេញពីបឋមជ្ឈាននោះហើយចូលទុតិយជ្ឈាន ។បេ។ ដូចវេលាចុះអំពីដើមឈើទី ១ ហើយឡើងដើមទី ២ ។បេ។ ពេលដែលមិនជាប់ចិត្តចង់ទុកក្នុងអាកិញ្ចញ្ញាយតនសាមាបត្តិ ចេញអំពីអាកិញ្ចញ្ញាយតន-សមាបត្តិនោះហើយ ចូលនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដូចចុះអំពីដើមឈើទី ៧ ហើយឡើងដើមឈើទី ៨ កាលមិនត្រូវការជាប់ចិត្តចង់ទុកក្នុងនេវសញ្ញានាសញ្ញាយតនៈ ចេញអំពីសមាបត្តិហើយ ពិចារណាសង្ខារសម្រេចអរហត្ត ដូចកាលដែលបុរសចុះអំពីដើមឈើទី ៨ ហើយ ទៅដល់ត្រើយនាយ ដែលជាទីមិនមានភ័យ ។

បទថា **អវិជ្ជាប្បភេទំ មនសិករោតិ** បានដល់ ភិក្ខុមនសិការអរហត្តពោល គឺធម៌ជាគ្រឿងទម្លាយអវិជ្ជាដ៏ធំក្រាស់ ដែលជាការមិនដឹងក្នុងឋានៈ ៨ អវិជ្ជា ៨ ។ បទថា **ន បក្ខន្ទតិ** បានដល់ មិនស្ទុះទៅដោយអារម្មណ៍ ។ បទថា **ជម្ពាលី** បានដល់ អណ្តូងធំដែលជាទីដក់ទឹក ដែលហូរចេញពីភូមិ ។ បទថា **អនេកវស្សគណិកា** បានដល់ អណ្តូង ឈ្មោះថា **អនេកវស្ស-**

**គណ្ឋិកា** ព្រោះមានអណ្តូងទឹកកើតឡើងជាច្រើនឆ្នាំ ព្រោះអណ្តូងទឹកនោះកើតឡើងក្នុងពេលដែលភូមិ ឬនគរកើតឡើង ។ បទថា **អាយមុខានិ** បានដល់ ប្រឡាយហូរចូល ៤ កន្លែង ។ បទថា **អបាយមុខានិ** បានដល់ប្រហោងហូរចេញ ។

បទថា **ន អាលិប្បភេទោ បាដិកង្ខោ** បានដល់ មិនគប្បីសង្ឃឹមថា មានទឹកលិចប្រាំងទៅបាន ព្រោះថា ទឹកដែលឡើងអំពីនោះ មិនអាចទម្លាយប្រាំង ហើយក្តួចយកសំរាមទៅកាន់មហាសមុទ្របានឡើយ ដើម្បីលម្អិតសេចក្តីនេះឲ្យជាក់ច្បាស់ គួរនាំរឿងមនុស្សស្វែងរកចម្ការមកប្រៀបធៀប ។ មានរឿងតំណាលថា កុលបុត្រអ្នកក្រុងម្នាក់ស្វែងរកចម្ការ បានឃើញអណ្តូងធំ ដែលនៅមិនឆ្ងាយអំពីក្រុង ។ បុរសនោះយល់ថា ក្នុងទីនេះ នឹងជាចម្ការដែលគួររីករាយ ទើបយកចបបិទផ្លូវទាំង ៤ ទិស ហើយបើកប្រហោងឲ្យទឹកហូរ ។ ភ្លៀងមិនធ្លាក់មកទៀត ទឹកដែលសល់ក៏ហូរទៅតាមប្រហោងនោះ កំណាត់ស្បែក និងកំណាត់សំពត់ចាស់ៗ ជាដើម ក៏ស្អុយរលួយក្នុងទីនោះឯង ។ ជនទាំងឡាយក៏ឈរនៅក្បែរ មិនព្រមចូលទៅ ។ សូម្បីចូលទៅក៏ត្រូវបិទច្រមុះ ដើរចៀសចេញទៅ ។ កន្លងទៅ ២-៣ ថ្ងៃ បុរសនោះមកឈរសម្លឹងមើល មិនអាចចូលទៅបាន ក៏ចៀសចេញទៅ ។ ក្នុងឧបមានោះ ព្រះយោគាវចរគប្បីឃើញដូចកុលបុត្រអ្នកក្រុង ។ កាយ គឺមហាភូតរូប ៤ ដូច កាលដែលកុលបុត្រស្វែងរកចម្ការ ឃើញអណ្តូងទឹកធំក្បែរទ្វារស្រុក

កាលដែលខ្ជួនមិនបានទឹក គឺការស្តាប់ធម៌ ដូចកាលដែលបិទផ្លូវទឹកហូរចូល ពេលដែលលះបង់ការសង្រួមក្នុងទ្វារ ៦ ដូចកាលដែលបើកផ្លូវទឹកហូរចេញ ពេលដែលមិនបានកម្មដ្ឋានជាទីសប្បាយ ដូចពេលដែលភ្លៀងមិនធ្លាក់ត្រូវតាមរដូវកាល វេលាដែលគុណខាងក្នុងសាបសូន្យ ដូចពេលដែលទឹកហូរចេញទៅតាមផ្លូវដែលទឹកហូរចេញ ពេលដែលមិនអាចទម្លាយប្រាំង គឺអវិជ្ជាបានដោយអរហត្តមគ្គ ហើយកម្ចាត់នូវគំនរកិលេស ធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ ដូចទឹកដែលជន់ឡើង ហើយមិនអាចទម្លាយប្រាំង នាំសំរាមទៅកាន់មហាសមុទ្របាន វេលាដែលពេញទៅដោយកិលេស មានរាគៈជាដើមខាងក្នុង ដូចកំណាត់ស្បែក និងសំពត់ចាស់ៗ ជាដើម ស្អុយនៅក្នុងអណ្តូងទឹកនោះឯង ពេលដែលបុគ្គលដែលមានសេចក្តីព្រមព្រៀងក្នុងវដ្តៈ ត្រេកអរក្នុងវដ្តៈ ដូចពេលដែលបុរសមកឃើញ ហើយមានការក្តៅក្រហាយចិត្ត ត្រឡប់ទៅ ។

បទថា **អាលិបូរកោ ចាជិកវេគ្វា** បានដល់ គប្បីសង្រួមទឹកដែលលិចលើមាត់ប្រាំងអណ្តូងទៅបាន អធិប្បាយថា ពិតហើយ ទឹកដែលជន់អំពីនោះ អាចទម្លាយមាត់អណ្តូង ហើយនាំសំរាមទៅកាន់មហាសមុទ្របាន ។ ក្នុងសេចក្តីនេះ គប្បីនាំការប្រៀបធៀបនោះមកបាន ។ ពេលដែលបានស្តាប់ធម៌ជាទីសប្បាយ គប្បីជ្រាបដូចពេលដែលបើកផ្លូវទឹកហូរចេញក្នុងអណ្តូងទឹកនោះ ពេលសង្រួមក្នុងទ្វារ ៦ តាំងមាំហើយ ដូចពេលដែលបិទផ្លូវហូរចេញ ពេលដែលខ្ជួនបានកម្មដ្ឋានជាទីសប្បាយ ដូចពេលដែលភ្លៀងធ្លាក់

ត្រូវតាមរដូវកាល ពេលខ្នងទម្លាយអវិជ្ជាចេញបាន ដោយអរហត្តមគ្គហើយ កម្ចាត់គំនរកិលេស ធ្វើនិព្វានឲ្យជាក់ច្បាស់ ដូចពេលទឹកហូរជន់ឡើងទម្លាយប្រាំង នាំយកសំរាមទៅកាន់មហាសមុទ្រ ពេលដែលពេញដោយលោកុត្តរធម៌ខាងក្នុង ដូចពេលដែលស្រះពេញដោយទឹក ដែលចូលទៅតាមផ្លូវដែលហូរចូល ពេលឡើងកាន់ធម្មបសាទ អង្គុយសោយផលសមាបត្តិមាននិព្វានជាអារម្មណ៍ ដូចការដែលបុគ្គលធ្វើរបងដោយជុំវិញ ហើយដាំដើមឈើ សាងប្រាសាទត្រង់កណ្ដាលចម្ការ ។ រកអ្នករបាំមកបម្រើ ហើយអង្គុយបរិភោគអាហារដែលល្អ ។ ពាក្យដ៏សេសក្នុងបទនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។ ទេសនាទ្រង់ត្រាស់លាយគ្នា ដោយលោកិយផង និងលោកុត្តរផង ។

**អដ្ឋកថា ជម្ពាលីសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## និព្វានសូត្រទី ៩

[ ២៩ ] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭក

ហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោ អានន្ទ សត្វទាំងឡាយ ក្នុងលោកនេះ មិនដឹងតាមពិតថា នេះជាហានភាគិយសញ្ញា ( សញ្ញាជាចំណែកវិនាស ) មិនដឹងតាមពិតថា នេះជាឋិតិភាគិយសញ្ញា ( សញ្ញាជាចំណែកតាំងនៅ គឺស្មើដើម ) មិនដឹងតាមពិតថា នេះជាវិសេសភាគិយសញ្ញា ( សញ្ញាជាចំណែកវិសេសឡើង គឺបានចំណេញ ) មិនដឹងតាមពិតថា នេះជានិព្វេធភាគិយសញ្ញា ( សញ្ញាជាចំណែកត្រាស់ដឹង ) ។ ម្នាលអាវុសោអានន្ទ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោសារីបុត្ត ចុះហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោអានន្ទ សត្វទាំងឡាយ ក្នុងលោកនេះ បានដឹងច្បាស់តាមពិតថា នេះជាហានភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជាឋិតិភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជាវិសេសភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជានិព្វេធភាគិយសញ្ញា ។ ម្នាលអាវុសោអានន្ទ នេះឯងជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្នភពនេះឯង ។

# អដ្ឋកថា

## និព្វានសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វានសូត្រទី ៩ ដូចតទៅនេះ ក្នុងបទទាំងឡាយ មានបទថា **ហានភាគិយា សញ្ញា** គប្បីជ្រាបដោយន័យដែលលោកពោលហើយ ក្នុងអភិធម្មនោះឯងយ៉ាងនេះថា ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយកាម រមែងជាសាត្រៀននូវបុគ្គលដែលបានបឋមជ្ឈានឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីសាបសូន្យ ។ បទថា **យថាភូតំ នប្បជានន្តិ** បានដល់ មិនដឹងដោយមគ្គញ្ញាណតាមសេចក្ដីពិត ៕

អដ្ឋកថា និព្វានសូត្រទី ៩ ចប់

# សុត្តន្តបិដក

## មហាបទេសសូត្រទី ១០

[ ៣០ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងអានន្ទចេតិយក្បែរភោគនគរ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងមហាបទេស ( គ្រឿង

សម្រាប់អានយ៉ាងធំ ) ៤ យ៉ាងនេះ អ្នកទាំងឡាយចូរ ស្ដាប់ភាសិតនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្ដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះមហាប្រទេស ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្ដាប់ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសួង់មើលក្នុងសូត្រ ប្រៀបធៀបក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ សួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ មិនប្រជុំចុះ គឺមិនមានក្នុងសូត្រ ទាំងមិនឃើញប្រាកដក្នុងវិន័យផងទេ អ្នកទាំង-ឡាយគប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនោះថា នេះមិនមែនជាព្រះពុទ្ធ-ដីកា របស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះជាប្រាកដ ទំនងជាភិក្ខុនេះរៀនខុសទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវចោលពាក្យនេះដោយទំនងដូច្នេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្ដាប់

បានទទួល ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ កុំអាលត្រេកអរ កុំអាលឃាត់កាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនទូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះដោយពិត ជាពាក្យដែលភិក្ខុនេះរៀនត្រូវល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចាំទុកនូវមហាប្រទេសជាបឋមនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់កាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនទូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ

កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រ ទាំងមិនឃើញមានប្រាកដក្នុងវិន័យផងទេ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនោះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះដោយពិត ទំនងជាសង្ឃនោះរៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីបោលពាក្យនេះ ដោយទំនងដូច្នេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះមែន ជាពាក្យដែលព្រះសង្ឃនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហា-

បទេសជាគម្រប់ពីរនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុទាំងឡាយជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនន្ទូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនឹងព្យញ្ជនៈ ទាំងនោះ កាលបើអ្នកទាំងឡាយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រ ទាំងមិនឃើញសមក្នុងវិន័យផងទេ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនោះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះដោយពិត ទំនងជាព្រះថេរៈទាំងនោះ រៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ ត្រូវអ្នកទាំងឡាយចោលពាក្យនេះ ដោយទំនងដូច្នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ពួកភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យ

ប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយសួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំង-ឡាយគប្បីដល់នូវសេចក្ដីចូលចិត្តក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះដោយពិត ជាពាក្យដែលព្រះថេរៈទាំងនោះរៀនត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចាំទុកនូវមហា-បទេសជាគម្រប់ ៣ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈមួយអង្គនៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្ដាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ គប្បីរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះកាលបើអ្នកទាំងឡាយ សួង់មើលក្នុង

សូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រ ទាំងមិនឃើញសមក្នុងវិន័យផងទេ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះដោយពិត ទំនងជាព្រះថេរៈនោះរៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីពោលពាក្យនេះដោយទំនងដូច្នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈមួយអង្គ នៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ គប្បីរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ សួង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះដោយពិត ជាពាក្យដែលព្រះថេរៈនោះ រៀនត្រូវហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចាំទុកនូវមហាបទេស ជា

គម្រប់ ៤ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាមហាបទេសទាំង ៤ ។

សញ្ចេតនិយវគ្គទី ៣ ចប់

**ឧទ្ទាននៃសញ្ចេតនិយវគ្គនោះ គឺ**

សម្តែងអំពីសញ្ចេតនា ១ ការចែកបដិសម្ភិទា ១ រឿងព្រះកោដ្ឋិតត្ថេរ ១ ព្រះអានន្ទត្ថេរ ១ ព្រះឧបវានត្ថេរ ១ ជាគម្រប់ ៥ ការប្រាថ្នាយកតម្រាប់ ១ រឿងព្រះរាហុលត្ថេរ ១ ការប្រៀបធៀបនឹងត្រពាំង ១ ព្រះនិព្វាន ១ មហាបទេស ១ ក្នុងវគ្គ ។

# អដ្ឋកថា

## មហាបទេសសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាបទេសសូត្រទី ១០ ដូចតទៅនេះ បទថា **ភោគនគរេ វិហរតិ** បានដល់ ក្នុងបរិនិព្វានសម័យ ព្រះមានព្រះភាគទ្រង់ចារិកទៅនគរនោះ ហើយប្រថាប់នៅ ។ បទថា **អានន្ទចេតិយេ** បានដល់ ក្នុងវិហារដែលតាំងនៅត្រង់ទីជាកពរបស់អានន្ទយក្ខ ។ បទថា **មហាបទេសេ** ប្រែថា ឱកាសធំ ឬគោលអាងធំ អធិប្បាយថា ហេតុធំដែលពោលអាងដល់បុគ្គលធំៗ មានព្រះពុទ្ធជាដើម ។ បទថា **នេវ អភិនន្ទិតព្វំ**

សេចក្តីថា ភាសិតនោះ ដែលអ្នកទាំងឡាយជាអ្នកត្រេកអរ ឲ្យសាធុការ ហើយ មិនគប្បីស្តាប់មុន កុំគប្បីជឿ ព្រោះកាលមានបុគ្គលធ្វើយ៉ាងនេះ ភិក្ខុនោះសូម្បីត្រូវប្រកែកក្នុងកាលខាងក្រោយថា ពាក្យនេះមិនសម ក៏គង់ពោលថា កាលមុននេះជាធម៌ ឥឡូវនេះមិនមែនជាធម៌ហើយឬ ដូច្នេះហើយ មិនព្រមលះលទ្ធិ ។ បទថា **ឆប្បដិក្កោសិតព្វំ** បានដល់ មិនគប្បីពោលមុនថា បុគ្គលល្ងង់នេះពោលអ្វី ព្រោះកាលពោលយ៉ាងនេះហើយ ភិក្ខុនោះ នឹងមិនពោលដល់ប្រការដែលត្រូវ និងមិនត្រូវ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនភិនន្ទិត្វា អប្បដិក្កោសិត្វា** ដូច្នេះ ។

បទថា **បទព្យញ្ជនានិ** បានដល់ ព្យញ្ជនៈ ពោល គឺបទ ។ បទថា **សាធុកំ ឧគ្គហេត្វា** បានដល់ រៀនដោយល្អថា លោកពោលបាលីក្នុងទីនេះ ពោលសេចក្តីក្នុងទីនេះ ពោលអនុសន្ធិក្នុងទីនេះ ពោលពាក្យដើមពាក្យចុងក្នុងទីនេះ ដូច្នេះ ។

បទថា **សុត្តេ ឱតារេតព្វានិ** បានដល់ គប្បីប្រៀបធៀបគ្នាក្នុងព្រះសូត្រ ។ បទថា **វិនយេ សន្ទស្សេតព្វានិ** បានដល់ គប្បីសាកសួរក្នុងព្រះវិន័យ ។ ក្នុងទីនេះ លោកពោលវិន័យថាជាសូត្រ ដូចដែលលោកពោលក្នុងសុត្តវិភង្គថា ជំទាស់ក្នុងទីណា ជំទាស់ក្នុងក្រុងសាវត្ថី ។ ខន្ធកៈ លោកហៅថា វិន័យ ដូចដែលលោកពោលថា **កោសម្ពិយំ វិនយាតិសារេ** ដូច្នេះ ។ មិនប្រកាន់យកវិនយបិដកយ៉ាងនេះ តែកាន់យកវិនយបិដកយ៉ាងនេះថា

ឧកតោវិភង្គជាព្រះសូត្រ ខន្ធកៈ និងបរិវារជាព្រះវិន័យ ដូច្នេះ ។ ម្យ៉ាងទៀត កាន់យកបិដក ២ យ៉ាងនេះ គឺសុត្តន្តបិដកជាព្រះសូត្រ វិនយបិដកជាព្រះវិន័យ ។ ឬបើមិនកាន់យកបិដក ៣ យ៉ាងនេះមុន គឺសុត្តន្តបិដក និងអភិធម្មបិដកជាព្រះសូត្រ វិនយបិដកជាព្រះវិន័យ ពិតហើយ ឈ្មោះថាពុទ្ធវចនៈ ដែលមិនមានឈ្មោះថាសូត្រ មាន គឺជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន តែព្រះសុទិន្នត្ថេរជំទាស់ពុទ្ធវចនៈទាំងអស់នោះថា ពុទ្ធវចនៈដែលមិនមានឈ្មោះថាសូត្រនោះ មិនមាន ដូច្នេះហើយ ពោលថា បិដក ៣ ជាព្រះសូត្រ តែវិន័យជាការណៈ ។ កាលសម្តែងដល់ការណៈ បន្ទាប់អំពីនោះ ទើបពោលសូត្រនេះថា ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំង-ឡាយណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំកិលេសវដ្តៈ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធ

សេចក្ដីព្យាយាម ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅរបស់ព្រះសាស្ដាទេ ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណាថា ធម៌ទាំងនេះប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក ប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្ដៈ ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន ប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការប្រឡូកប្រឡំដោយពួក ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដាហើយ ។ ព្រោះដូច្នោះ ទើបអត្ថក្នុងសេចក្ដីនេះ មានដូច្នេះថា បទថា **សុត្តេ** បានដល់ គប្បីប្រៀបធៀបក្នុងពុទ្ធវចនៈ គឺបិដក ៣ ។ បទថា **វិនយេ** នេះ បានដល់ គប្បីត្រួតពិនិត្យក្នុងហេតុនៃការកម្ចាត់កិលេស មាន

រាគៈជាដើម ។

បទថា **ន ចេវ សុត្តេ ឱតរន្តិ** សេចក្ដីថា បទព្យញ្ជនៈទាំងឡាយមិនមកក្នុងទីណាមួយតាមលំដាប់ក្នុងព្រះសូត្រ លើកសម្បកឡើងហើយ ប្រាកដច្បាស់ថា មកអំពីគម្ពីរគុឡ្ហវេស្សន្តរ គុឡ្ហឧម្មគ្គ គុឡ្ហវិន័យ និងវេទល្លបិដកណាមួយ ( ដែលជាគម្ពីរមហាយាន ) ។ បទព្យញ្ជនៈដែលមកហើយយ៉ាងនេះ នឹងមិនប្រាកដក្នុងការនាំកិលេស មានរាគៈជាដើមចេញទៅ គប្បីបោះបង់ចោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឥតិ ហិទំ ភិក្ខវេ ឆឌ្ឌេយ្យាថ** ដូច្នេះ ។ គប្បីជ្រាបអត្ថក្នុងបទទាំងអស់ដោយឧបាយនេះ ។ បទថា **ឥទំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីទ្រទ្រង់ចាំទុកនូវឱកាសជាទីប្រតិស្ឋានធម៌ទី ៤ នេះទុក ។

### អដ្ឋកថាមហាបទេសសូត្រទី ១០ ចប់

### សញ្ចេតនិយវគ្គទី ៣ ចប់

# សុត្តន្តបិដក
# យោធាជីវវគ្គទី ៤

## យោធសូត្រទី ១

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ( អ្នករស់នៅដោយឋានៈជាទាហាន ) ប្រកបដោយអង្គ ៤ ទើបគួរជារាជបុរស ជារាជបម្រើរាប់ថាជាអង្គ ( អវយវៈ ) របស់ព្រះរាជាបាន ។ អង្គ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈក្នុងលោកនេះ ជាអ្នកឈ្លាសវៃក្នុងជយភូមិ ១ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់ត្រង់ ១ ជាអ្នកអាចទម្លាយនូវកងទ័ពដ៏ធំបាន ១ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈប្រកបដោយអង្គ ៤ នេះឯង ទើបគួរជារាជបុរស ជារាជបម្រើ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ទើបជាអ្នកគួរទទួលគ្រឿងដែលគេនាំមកបូជា គួរទទួលរបស់ដែលគេទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏ដូច្នោះដែរ ។ ប្រកបដោយអង្គ ៤ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងជយភូមិ ១ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់ត្រង់ ១ ជាអ្នកទម្លាយនូវកងទ័ពដ៏ធំបាន ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះភិក្ខុជាអ្នកឈ្លាសក្នុងជយភូមិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទ

ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសក្នុងជយភូមិយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់បានឆ្ងាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិត នូវរូបណាទីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជារូបក្នុងខ្លួនក្តី ក្រៅខ្លួនក្តី គ្រោតគ្រាតក្តី ល្អិតក្តី អាក្រក់ក្តី ល្អក្តី នៅឆ្ងាយក្តី នៅជិតក្តី ទាំងអស់នុ៎ះ យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនអញ វេទនាណាទីមួយ ... សញ្ញាណាទីមួយ ... សង្ខារទាំងឡាយណាទីមួយ ... ភិក្ខុឃើញដោយបញ្ញាដ៏ប្រពៃតាមពិត នូវវិញ្ញាណណាទីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាវិញ្ញាណក្នុងខ្លួនក្តី ក្រៅខ្លួនក្តី គ្រោតគ្រាតក្តី ល្អិតក្តី អាក្រក់ក្តី ល្អក្តី នៅឆ្ងាយក្តី នៅជិតក្តី ទាំងអស់នុ៎ះ យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនអញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់បានឆ្ងាយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់ត្រង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់ត្រង់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកទម្លាយកងទ័ពធំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទម្លាយគំនរអវិជ្ជាដ៏ធំបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកទម្លាយកងទ័ពធំបានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-

*ឡាយ ភិក្ខុជាអ្នកប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបគួរទទួលគ្រឿងបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។*

# អដ្ឋកថា

# យោធាជីវវគ្គទី ៤

## យោធសូត្រ

*[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយោធសូត្រទី ១ នៃយោធាជីវវគ្គទី ៤ ដូចតទៅ បទថា* **ឋានកុសលោ** *បានដល់ ជាអ្នកឈ្លាសក្នុងឋានៈដែលខ្ទនឈរ ដោយអំណាចបាញ់មិនខុស ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង ។*

**អដ្ឋកថា យោធសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ចាដិភោគសូត្រទី ២

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាក្នុងលោក ជាអ្នកធានាធម៌ទាំង ៤ យ៉ាងបានទេ ។ ធម៌ទាំង ៤ យ៉ាង តើអ្វីខ្លះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីគ្រាំគ្រាជាធម្មតា កុំគ្រាំគ្រាឡើយ ដូច្នេះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីឈឺចាប់ជាធម្មតា កុំឈឺចាប់ឡើយ ដូច្នេះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីស្លាប់ជាធម្មតា កុំស្លាប់ឡើយ ដូច្នេះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា បាបកម្មទាំងឡាយណា ដែលប្រកបដោយសេចក្តីសៅហ្មង ធ្វើឲ្យមានភពថ្មី ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល នាំឲ្យមានជាតិជរាមរណៈតទៅ វិបាករបស់កម្មទាំងនោះ កុំកើតឡើយ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាធម៌ទាំង ៤ យ៉ាងនេះឯងបានឡើយ ។

# អដ្ឋកថា

## ចាជិភោគសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបាជិកោគសូត្រទី ២ ដូចតទៅនេះ បទថា **ឧត្តិ កោចិ ចាជិភោគោ** សេចក្ដីថា ឈ្មោះថា ជាអ្នកអាច ជាអ្នកទទួល ជានាយ៉ាងនេះថា ខ្ញុំជាអ្នកជានាក្នុងធម៌ទាំងនេះ ដូច្នេះ រមែងមិនមាន ។ បទថា **ជរាធម្មំ** បានដល់ ភាវៈដែលមានការចាស់ ។ ក្នុងបទទាំងអស់ ក៏មានន័យនេះដូចគ្នា ៕

**អដ្ឋកថាចាជិភោគសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សុតសូត្រទី ៣

[ ៣៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរ

ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា អ្នកណាមួយនិយាយចំពោះរូប ដែលខ្លួនឃើញហើយថា ខ្ញុំបានឃើញយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះសំឡេង ដែលខ្លួនឮហើយថា ខ្ញុំបានឮយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះវត្ថុ ដែលខ្លួនបានហិត ភ្លក្ស ពាល់ត្រូវថា ខ្ញុំបានហិត ភ្លក្ស ពាល់ត្រូវយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះវត្ថុ ដែលខ្លួនបានដឹងច្បាស់ ( ដោយចិត្ត ) ថា ខ្ញុំបានដឹងច្បាស់យ៉ាងនេះ ឥតមានទោសអំពីអ្នកនោះទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលត្រូវតែនិយាយចំពោះរូបទាំងអស់ ដែលខ្លួនឃើញហើយទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះរូបទាំងអស់ ដែលខ្លួនឃើញហើយទេ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះសំឡេងទាំងអស់ ដែលខ្លួនឮហើយទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះសំឡេង ដែលខ្លួនឮហើយទេ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈទាំងអស់ ដែលខ្លួនហិត ភ្លក្ស ពាល់ត្រូវហើយទេ ម្នាលព្រាហ្មណ៍ តែតថាគតពោលថា បុគ្គលមិនត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈទាំងអស់ ដែលខ្លួនហិត ភ្លក្ស ពាល់ត្រូវហើយទេ ម្នាលព្រាហ្មណ៍ តថាគតមិនពោល

ថា បុគ្គលត្រូវនិយាយចំពោះធម្មារម្មណ៍ទាំងអស់ ដែលខ្លួនដឹងច្បាស់ហើយទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះធម្មារម្មណ៍ទាំងអស់ ដែលខ្លួនដឹងច្បាស់ហើយទេ ។ ម្នាលព្រាហ្មណ៍ តែតថាគតពោលថា កាលបើបុគ្គលពោលចំពោះរូបណា ដែលបានឃើញហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅវិញ បុគ្គលមិនត្រូវនិយាយចំពោះរូប ដែលខ្លួនឃើញហើយបែបនេះទេ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាលបើបុគ្គលនោះពោលចំពោះរូបណា ដែលខ្លួនបានឃើញហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលគួរនិយាយចំពោះរូប ដែលខ្លួនបានឃើញបែបនេះ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាលបើបុគ្គលពោលចំពោះសំឡេងណា ដែលខ្លួនបានឮហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ បុគ្គលមិនគួរនិយាយចំពោះសំឡេងដែលខ្លួនបានឮបែបនេះ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាលបើបុគ្គលនោះពោលចំពោះសំឡេងណា ដែលខ្លួនបានឮហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលគួរនិយាយចំពោះសំឡេងបែបនេះ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាលបើបុគ្គលពោលចំពោះក្លិន រស ផោដ្ឋព្វៈណាដែលខ្លួនបានហិត ភ្លក្ស ពាល់ត្រូវហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ

សាបសូន្យទៅ បុគ្គលមិនត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈដែលខ្លួនបាន ហិត ភ្លក្ស ពាល់ត្រូវបែបនេះ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាលបើ បុគ្គលនោះ ពោលចំពោះក្លិន រស ផោដ្ឋព្វៈណា ដែលខ្លួនបានហិត ភ្លក្ស ពាល់ត្រូវហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំង-ឡាយ ចម្រើនឡើង បុគ្គលត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈ ដែលខ្លួន បានហិត ភ្លក្ស ពាល់ត្រូវបែបនេះ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាល បើបុគ្គលពោលចំពោះធម្មារម្មណ៍ណា ដែលខ្លួនដឹងច្បាស់ហើយ អកុសល-ធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ បុគ្គល មិនត្រូវនិយាយចំពោះធម្មារម្មណ៍ ដែលខ្លួនបានដឹងច្បាស់បែបនេះទេ ម្នាល ព្រាហ្មណ៍ តថាគតពោលថា កាលបើបុគ្គលនោះ ពោលចំពោះធម្មារម្មណ៍ ណា ដែលខ្លួនបានដឹងច្បាស់ហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលត្រូវនិយាយចំពោះធម្មារម្មណ៍ ដែលខ្លួនបានដឹងច្បាស់បែបនេះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជា មហាមាត្យ ក្នុងដែនមគធៈ ត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះដ៏មាន ព្រះភាគហើយ ក៏ក្រោកចាកអាសនៈថយចេញទៅ ។

# អដ្ឋកថា

## សុតសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុតសូត្រទី ៣ ដូចតទៅនេះ បទថា **ឆត្តិ តតោ ទោសោ** សេចក្តីថា ឈ្មោះថា ទោសក្នុងការពោលនោះ មិនមាន ។ល។

### អដ្ឋកថាសុតសូត្រទី ៣ ចប់

# សុត្តន្តបិដក

## អភយសូត្រទី ៤

[ ៣៤ ] គ្រានោះ ជានុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះជានុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកយើងខ្ញុំ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ មិន

ដែលមានឡើយ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ខ្លាច តក់ស្លុត នឹងសេចក្តីស្លាប់ក៏មាន ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ក៏មាន ។ ម្នាលព្រាហ្មណ៍ ចុះបុគ្គលអ្នកមានសេចកីស្លាប់ជាធម្មតា ខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកចំណង់ ក្នុងកាមទាំងឡាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា កាមទាំងឡាយ ដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញ មុខជានឹងលះបង់កាមទាំងឡាយ ជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ ក៏សោកស្តាយលំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកចំណងក្នុងកាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាល

បើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា រាងកាយ ជាទីស្រឡាញ់នឹងលះបង់អាត្មាអញ អាត្មាអញនឹងលះបង់រាងកាយ ជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ ក៏សោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមក ហើយបុគ្គលនោះ ក៏កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមក អើហ្ន៎ គតិរបស់បុគ្គលនោះ ដែលមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមកត្រឹមណា អាត្មាអញលះលោកនេះហើយ នឹងទៅកាន់គតិនោះ ។ បុគ្គលនោះ ក៏សោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីសន្ទិះសង្ស័យ មិនជឿស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះ កើតរោគធ្ងន់ណាមួយ

កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱ អាត្មាអញ មានសេចក្តីសន្ទិះសង្ស័យ មិនជឿស៊ប់ក្នុងព្រះសទ្ធម្ម ។ បុគ្គលនោះ ក៏សោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូង យំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ៤ ពួកនេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ ចុះបុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ ក្នុងកាមទាំងឡាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ មិនដែលត្រិះរិះយ៉ាងនេះថា កាមទាំងឡាយ ដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញមុខជានឹងលះបង់កាមទាំងឡាយជាទីស្រឡាញ់ដែរ ។ បុគ្គលនោះមិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទួញយំ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាក

សេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ក្នុងកាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ មិនដែលត្រិះរិះយ៉ាងនេះថា ឱរាងកាយដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញ មុខជានឹងលះបង់រាងកាយជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង យំទួញ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនធ្វើបាប មិនធ្វើអំពើអាក្រក់ មិនធ្វើអំពើលាមក ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញ មិនដែលធ្វើអំពើបាប មិនធ្វើអំពើអាក្រក់ មិនធ្វើអំពើលាមកទេ ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យ អើហ្ន៎ គតិរបស់បុគ្គលដែលមិនបានធ្វើបាប មិនបានធ្វើអំពើអាក្រក់ មិនបានធ្វើអំពើលាមក ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យត្រឹមណា អាត្មាអញលះលោកនេះហើយ នឹងទៅកាន់គតិនោះ ។ បុគ្គលនោះ ក៏មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះ

ឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនមានសេចក្តីសន្ទិះសង្ស័យ ជាបុគ្គលជឿស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញលែងសន្ទិះសង្ស័យ បានជឿស៊ប់ក្នុងព្រះសទ្ធម្មហើយ ។ បុគ្គលនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ៤ ពួកនេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណៈស្មើជីវិតតាំងពីថ្ងៃនេះទៅ ។

# អដ្ឋកថា

## អភយសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភយសូត្រទី ៤ ដូចតទៅនេះ រោគនោះឯង ឈ្មោះថា **រោគាតង្ក** ព្រោះអត្ថថា ជាហេតុធ្វើជីវិតឲ្យលំបាក ។

 ៤១៦

បទថា **ផុដ្ឋស្ស** បានដល់ ប្រកបដោយរោគាតង្កៈនោះ ។ បទថា **ឧរត្តាឡឹ កន្ទតិ** បានដល់ វាយដំ ។ បុញ្ញកម្ម លោកហៅថា កល្យាណ ក្នុងបទថា **អកតកល្យាណោ** ដូច្នេះជាដើម ។ ឈ្មោះថា **អកតកល្យាណោ** ព្រោះបុគ្គលនោះមិនបានធ្វើបុញ្ញកម្មនោះ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ពិតហើយ បុញ្ញកម្មនោះឯង ឈ្មោះថា កុសល ព្រោះកើតអំពីការឈ្លាស ។ កុសល លោកហៅថា **ភីរុត្តាណោ** ព្រោះជាគ្រឿងរាំងសម្រាប់បុគ្គលភ័យខ្លាច ។ អកុសលកម្មដ៏លាមក លោកហៅថា **បាប** ក្នុងបទថា **កតបាបោ** ដូច្នេះជាដើម ។ បទថា **លុទ្ទំ** បានដល់ កម្មគ្រោតគ្រាត ។ បទថា **កិព្វិសំ** បានដល់ កម្មមិនបរិសុទ្ធ មានមន្ទិល ។ បទថា **កង្ខី ហោតិ** បានដល់ ជាអ្នកប្រកបដោយសេចក្តីសង្ស័យក្នុងឋានៈទាំង ៨ គឺក្នុងពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ក្នុងសិក្ខា ក្នុងអតីត ក្នុងអនាគត ក្នុងអតីតផង អនាគតផង និងក្នុងបដិច្ចសមុប្បាទ ។ បទថា **វិចិកិច្ឆី** បានដល់ ជាអ្នកប្រកបដោយការរារែកចិត្ត គឺមិនដល់នូវការចុះចិត្តស៊ប់ក្នុងព្រះសទ្ធម្មដែលជាពាក្យប្រៀនប្រដៅ មិនអាចដាក់ចិត្តដោយការរៀន និងការសាកសួរ ។ គប្បីជ្រាបអត្ថក្នុងបទទាំងអស់ ដោយន័យនេះ ។

## អដ្ឋកថា អភយសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ព្រាហ្មណសច្ចសូត្រទី ៥

[ ៣៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង បរិព្វាជកច្រើននាក់ សុទ្ធតែជាអ្នកល្បីឈ្មោះ អាស្រ័យនៅក្នុងបរិព្វាជការាម ក្បែរឆ្នេរស្ទឹងសប្បិនី គឺបរិព្វាជកឈ្មោះអន្នភារៈ ១ វរធរៈ ១ សកុលុទាយី ១ និងបរិព្វាជកឯទៀតដែលមានឈ្មោះល្បីល្បាញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ស្ដេចចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយទ្រង់ស្ដេចចូលទៅឯបរិព្វាជការាម ក្បែរឆ្នេរស្ទឹងសប្បិនីនោះ ។ កាលដែលពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំសន្និបាត ក្នុងសម័យនោះឯង អន្តរាកថានេះ កើតឡើងថា សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ស្ដេចចូលទៅរកពួកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ទើបត្រាស់សួរបរិព្វាជកទាំងនោះ ដូច្នេះថា ម្នាលបរិព្វាជកទាំងឡាយ អម្បាញ់មិញអ្នកទាំងឡាយ អង្គុយប្រជុំនិយាយគ្នាអំពីរឿងអ្វី មួយទៀត អន្តរាកថារបស់អ្នកទាំងឡាយដូចម្ដេច ដែលបញ្ឈប់ដាច់ទៅ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលដែលយើងខ្ញុំអង្គុយប្រជុំគ្នាក្នុងទីនេះ អន្តរាកថានេះកើតឡើងថា សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ ។ ម្នាលបរិព្វាជកទាំងឡាយ សច្ចៈរបស់ពួកព្រាហ្មណ៍នេះមាន ៤

ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯងហើយ ទើបប្រកាសឲ្យដឹងច្បាស់ ។ សច្ចៈរបស់ពួកព្រាហ្មណ៍ ៤ តើដូចម្តេច ។ ម្នាលបរិព្វាជកទាំងឡាយ ព្រាហ្មណ៍ក្នុងលោកនេះ ពោលយ៉ាងនេះថា សត្វទាំងពួងមិនគួរសម្លាប់ ព្រាហ្មណ៍ កាលពោលដូច្នេះ ឈ្មោះថាពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះ មិនប្រកាន់ថា ជាសមណៈ មិនប្រកាន់ថា ជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះតែការសម្លាប់នោះ គ្រាន់តែប្រតិបត្តិដើម្បីអាណិត អនុគ្រោះចំពោះសត្វទាំងឡាយ ព្រោះការត្រាស់ដឹងសច្ចៈនោះ ក្នុងការមិនសម្លាប់នោះប៉ុណ្ណោះ ។ ម្នាលបរិព្វាជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា កាមទាំងពួង មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ព្រាហ្មណ៍ កាលពោលដូច្នេះ ឈ្មោះថា ពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះ មិនប្រកាន់ថា ជាសមណៈ មិនប្រកាន់ថា ជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះតែសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិដើម្បីនឿយណាយ ធុញទ្រាន់ រលត់កាមទាំងឡាយ ព្រោះការត្រាស់ដឹងនូវសច្ចៈនោះ ក្នុងដំណើរនោះប៉ុណ្ណោះ ។ ម្នាលបរិព្វាជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា ភពទាំងពួងមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជា

ធម្មតា ព្រាហ្មណ៍ កាលពោលដូច្នេះ ឈ្មោះថា ពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះ មិនប្រកាន់ថា ជាសមណៈ មិនប្រកាន់ថា ជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិដើម្បីនឿយណាយ ធុញទ្រាន់ រម្ងត់កពទាំងឡាយ ព្រោះការត្រាស់ដឹងសច្ចៈនោះ ក្នុងដំណើរនោះប៉ុណ្ណោះ ។ ម្នាលបរិញ្វជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា អាត្មាអញមិនមានក្នុងវត្ថុនីមួយ មិនមានក្នុងកង្វល់អ្នកណាមួយ អ្នកដទៃក៏មិនមានក្នុងវត្ថុនីមួយ ទាំងវត្ថុនីមួយរបស់អ្នកដទៃ ក៏មិនមានក្នុងកង្វល់នីមួយរបស់អញ ព្រាហ្មណ៍ កាលពោលយ៉ាងនេះ ឈ្មោះថា ពោលពាក្យសច្ចៈ មិនមែនពោលមុសាទេ ព្រាហ្មណ៍នោះ មិនប្រកាន់ថា ជាសមណៈ មិនប្រកាន់ថា ជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិអាកិញ្ចញ្ញប្បដិបទា ( ផ្លូវដែលឥតកង្វល់ ) ព្រោះការត្រាស់ដឹងនូវសច្ចៈនោះ ក្នុងដំណើរនោះប៉ុណ្ណោះ ។ ម្នាលបរិញ្វជកទាំងឡាយ សច្ចៈរបស់ពួកព្រាហ្មណ៍ទាំង ៤ នេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងហើយ ទើបប្រកាសឲ្យដឹងច្បាស់ ។

# អដ្ឋកថា

## ព្រាហ្មណសច្ចសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្រាហ្មណសច្ចសូត្រទី ៥ ដូចតទៅនេះ បទថា **ព្រាហ្មណសច្ចានិ** ប្រែថា សច្ចៈរបស់ព្រាហ្មណ៍ទាំងឡាយ ។ បទថា **សោ តេន ន សមណោតិ មញ្ញតិ** សេចក្តីថា ដោយសច្ចៈនោះ ព្រះខីណាស្រពនោះ រមែងមិនសម្គាល់ដោយតណ្ហា មានះ ទិដ្ឋិ ថាអញជាសមណៈ ដូច្នេះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **យទេវ តត្ថ សច្ចំ តទភិញ្ញាយ** សេចក្តីថា សច្ចៈណាជាសេចក្តីពិត មិនប្រែប្រួលក្នុងបដិបត្តិនោះថា សត្វទាំងពួងមិនគួរសម្លាប់ ដូច្នេះ ។ ដោយបទនេះ ទ្រង់ធ្វើវចីសច្ចក្នុងខាងក្នុង សម្តែងនិព្វានជាបរមត្ថសច្ច ។ បទថា **តទភិញ្ញាយ** បានដល់ ដឹងសច្ចៈទាំង ២ នោះ ដោយបញ្ញាដ៏វិសេសក្រៃលែង ។ បទថា **អនុទយាយ អនុកម្បាយ បដិបន្នោ ហោតិ** សេចក្តីថា ជាអ្នកបដិបត្តិបដិបទា ដើម្បីសេចក្តីករុណា និងដើម្បីការអនុគ្រោះ អធិប្បាយថា ជាអ្នកបំពេញគ្រប់គ្រាន់ ។ បទថា **សព្វេ កាមា** បានដល់ វត្ថុកាមទាំងអស់ កិលេសកាមទាំងអស់ ។ ក្នុងបដិបទាដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ** បានដល់ ព្រាហ្មណ៍ដែលជាព្រះខីណាស្រពពោលយ៉ាងនេះ ក៏ឈ្មោះថា ពោលពិតទាំងអស់ ។ បទថា **សព្វេ ភវា** បានដល់ ភព ៣ មានកាមភពជាដើម ។

ក្នុងបទថា **នាហំ ខ្ចិនិ** នេះ ត្រាស់សុញ្ញតា ៤ ចំណុច ពិតហើយ

ព្រះខីណាស្រពនេះមិនឃើញខ្លួនក្នុងទីណាមួយឡើយថា អញរមែងមិនមានក្នុងវត្ថុណាមួយ ។ បទថា **កស្សចិ កិញ្ចនតស្មឹ** សេចក្តីថា មិនឃើញខ្លួនរបស់ខ្លួន ដែលគប្បីនាំចូលទៅក្នុងសេចក្តីកង្វល់សម្រាប់បុគ្គលណាដទៃ អធិប្បាយថា មិនឃើញថា បងប្រុស គួរសម្គាល់ នាំចូលទៅក្នុងឋានៈជាបងប្រុស សម្លាញ់ក្នុងឋានៈជាសម្លាញ់ បរិក្ខារក្នុងឋានៈបរិក្ខារ ដូច្នេះ ។ ក្នុងបទថា **ន ច មម ក្វចិនិ** នេះ វៀរ **មម** សព្ទចេញ មានសេចក្តីដូច្នេះថា ព្រះខីណាស្រពមិនឃើញថា ខ្លួនមានកង្វល់នៅក្នុងវត្ថុណាមួយ របស់បុគ្គលណា និងការកង្វល់ក្នុងវត្ថុណាមួយ ក្នុងបុគ្គលណាម្នាក់ ។ ឥឡូវនេះ **មម** សព្ទ មានអត្ថថា ការកង្វល់ក្នុងវត្ថុណាមួយ មិនមានដល់អាត្មាអញ ព្រោះហេតុនោះ បុគ្គលណាមិនឃើញថា ខ្លួនរបស់អ្នកដទៃរមែងមានដល់អាត្មាអញ ក្នុងការកង្វល់ក្នុងវត្ថុណាមួយ បុគ្គលនោះ ឈ្មោះថា មិនឃើញខ្លួនរបស់អ្នកដទៃ គួរនាំចូលមកដោយកង្វល់នេះ មិនថាក្នុងឋានៈណាមួយ គឺបងប្រុសក្នុងឋានៈជាបងប្រុសរបស់ខ្លួន សម្លាញ់ក្នុងឋានៈជាសម្លាញ់ បរិក្ខារក្នុងឋានៈជាបរិក្ខារ ដូច្នេះ ។ ព្រោះហេតុដែលព្រាហ្មណ៍នេះ មានសភាពយ៉ាងនេះ ដូច្នោះ ទើបមិនឃើញខ្លួនក្នុងទីណាមួយ មិនឃើញខ្លួនដែលគួរនាំចូលទៅក្នុងការកង្វល់របស់អ្នកដទៃ មិនឃើញខ្លួនរបស់អ្នកដទៃ ដែលគួរនាំចូលទៅក្នុងកង្វល់របស់ខ្លួន ។ បទថា **ឥតិ វទំ ព្រាហ្មណោ** គប្បីជ្រាបថា ព្រាហ្មណ៍ដែលជាព្រះខីណាស្រពពោលសុញ្ញតា គឺការសូន្យទាំង ៤ ចំណុច

ឈ្មោះថា ពោលពាក្យពិតទាំងអស់ ព្រោះការដឹងច្បាស់ដោយប្រពៃ ក្នុងបដិបទានោះហើយ មិនបានពោលពាក្យកុហកផង មិនសម្គាល់ផង ព្រោះខ្លួនលះនូវការសម្គាល់ទាំងឡាយគ្រប់វារៈបានហើយ ។

បទថា **អាកិញ្ចញ្ញំយេវ បដិបទំ** បានដល់ បដិបទាដែលវៀរចាកការកង្វល់ មិនមាននូវការជាប់ជំពាក់ គឺមិនប្រកាន់នោះឯង ។ បទថា **បដិបន្នោ ហោតិ** បានដល់ បំពេញដ៏ពេញលេញ ។ បទថា **ឥមានិ ខោ បរិព្វាជកា ។បេ។ បវេទិតានិ** សេចក្ដីថា តថាគតដឹងសច្ចៈ ៤ នេះរបស់ព្រាហ្មណ៍ដែលមានបាបបន្សាត់ហើយ ក្រៅអំពីសច្ចៈរបស់ព្រាហ្មណ៍ ដែលលោកពោលដោយមគ្គ ៤ កិច្ច ១៦ ហើយ ទើបប្រកាសសម្ដែងយ៉ាងជាក់ច្បាស់ ក្នុងសូត្រនេះ ត្រាស់វិបីសច្ចតែម្យ៉ាង សម្រាប់ព្រះខីណាស្រព ក្នុងឋានៈ ៤ ដូច្នេះ ។៚

## អដ្ឋកថា ព្រាហ្មណសច្ចសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ឧម្មគ្គសូត្រទី ៦

[ ៣៦ ] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោកលុះអំណាចរបស់អ្វីដែលកើតឡើង ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្ដីឆ្លាសរបស់អ្នកស្រួលហើយ សេចក្ដីវាងវៃរបស់អ្នកស្រួលហើយ សេចក្ដីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតថា អ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោកលុះអំណាចរបស់អ្វីដែលកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ចិត្តដឹកនាំសត្វលោកទៅ ចិត្តទង់ទាញសត្វលោកទៅ សត្វលោកលុះអំណាចចិត្តដែលកើតឡើង ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិត របស់ព្រះដ៏មានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏បានសួរប្រស្នា នឹងព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូត អ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្ដេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្ដីឆ្លាសរបស់អ្នកស្រួលហើយ

សេចក្តីវាងវៃស្រួលហើយ សេចក្តីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូត អ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ធម៌ទាំងឡាយដែលតថាគតសម្តែងទុកច្រើនយ៉ាង គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បើភិក្ខុដឹងអត្ថ និងធម៌របស់គាថាត្រឹមតែ ៤ បាទហើយ ជាអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ក៏គួរហៅថា ជាពហុស្សូត អ្នកទ្រទ្រង់ធម៌បាន ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏សួរប្រស្នានឹងព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុ សេចក្តីឆ្លាសរបស់អ្នកស្រួលហើយ សេចក្តីវាងវៃរបស់អ្នកស្រួលហើយ សេចក្តីសាកសួររបស់អ្នកល្អហើយ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បពិត្រព្រះអង្គដ៏ចម្រើន

បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ ដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ បានឮថា នេះទុក្ខ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខសមុទ័យ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខនិរោធ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខនិរោធគាមិនីបដិបទា ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា ម្នាលភិក្ខុ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះយ៉ាងនេះឯង ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏ក្រាបទូលសួរប្រស្នានឹងព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិត អ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុ សេចក្តីឆ្លាសរបស់អ្នកស្រួលហើយ សេចក្តីវាងវៃរបស់អ្នកស្រួលហើយ សេចក្តីសាកសួររបស់អ្នកល្អហើយ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិត អ្នកមានប្រាជ្ញាច្រើន

ក្នុងសាសនានេះ មិនគិតដើម្បីបៀតបៀនខ្លួន មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង កាលបើគិត ក៏គិតតែប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ប្រយោជន៍ទាំងពីរខាង និងប្រយោជន៍ដល់លោកទាំងមូល ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិត អ្នកមានប្រាជ្ញាច្រើន យ៉ាងនេះឯង ។

# អដ្ឋកថា

## ឧម្មគ្គសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧម្មគ្គសូត្រទី ៦ ដូចតទៅនេះ បទថា **បរិកស្សតិ** បានដល់ ដែលវត្ថុណាមួយប្រានមក ។ បទថា **ឧម្មង្គោ** បានដល់ ផុសឡើង អធិប្បាយថា ទៅដោយបញ្ញា ។ មួយវិញទៀត បញ្ញានោះឯង ហៅថា **ឧម្មគ្គ** ព្រោះអត្ថថា ផុសឡើង ឧម្មគ្គបញ្ញានោះ ឈ្មោះថា **បដិភាណា** ព្រោះអត្ថថា ជាក់ច្បាស់ភ្លាមៗ ។ បទថា **ចិត្តស្ស ឧប្បន្នស្ស វសំ គច្ឆតិ** សេចក្តីថា បុគ្គលពួកណា រមែងធ្លាក់នៅក្នុងអំណាចចិត្ត គប្បីជ្រាបការប្រែកាន់របស់បុគ្គលទាំងនោះ ដោយអំណាចចិត្តនេះ ។ បទថា **អត្ថមញ្ញាយ ធម្មមញ្ញាយ** បានដល់ ដឹងអត្ថ និងបាលី ។ បទថា **ធម្មានុធម្មប្បដិបន្នោ ហោតិ** សេចក្តីថា ជាអ្នកបដិបត្តិធម៌ គឺបដិបទាដែលជាចំណែកខាងដើម មួយអន្លើដោយសីលដែលសមគួរ ដល់លោកុត្តរធម៌ ។

បទថា **និព្វេធិកបញ្ញោ** បានដល់ បញ្ញាជាគ្រឿងចាក់ធ្លុះ ។ បទថា **ឥទំ ទុក្ខំ** លោកអធិប្បាយថា ខន្ធ ៥ ប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស វៀរតណ្ហា ជាទុក្ខ ។ បទថា **បញ្ញាយ** គឺមគ្គប្បញ្ញា ។ បទថា **អយំ ទុក្ខសមុទយោ** លោកអធិប្បាយថា តណ្ហាជាមូលរបស់វដ្ដៈ ជាហេតុកើតទុក្ខនោះ ។ ក្នុង ២ បទដ៏សេស គប្បីជ្រាបអត្ថដោយឧបាយនេះ ។ អរហត្តផល គប្បីជ្រាបថា ត្រាស់ដោយការឆ្លើយបញ្ហាប្រការទី ៤ ។

**អដ្ឋកថាឧម្មង្គសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## វស្សការសូត្រទី ៧

[ ៣៧ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭករួចហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវស្សាការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីសមគួរហើយ

បានទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អសប្បុរស គប្បីស្គាល់អសប្បុរសដូចគ្នាថា អ្នកនេះជាអសប្បុរស បានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះមិនសមហេតុ មិនសមផលទេ ដែលអសប្បុរស គប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះអសប្បុរសគប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរស បានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរសគប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរស ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន សប្បុរសគប្បីស្គាល់សប្បុរសដូចគ្នាថា អ្នកនេះជាសប្បុរសបានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ទើបមានទំនងដែលថា សប្បុរសគប្បីស្គាល់សប្បុរសដូចគ្នាថា អ្នកនេះជាសប្បុរសដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរសបានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មានទំនងដែរ ដែលសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ព្រោះពាក្យនេះ ព្រះគោតមដ៏ចម្រើន ត្រាស់ត្រូវហើយថា ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ មិនសមហេតុ មិនសមផលទេ ដែលថា អសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ មិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរសគប្បីស្គាល់

សប្បុរសថា អ្នកនេះជាសប្បុរស ដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ទើបមានទំនងពិត ដែលថា សប្បុរសគប្បីស្គាល់សប្បុរសបានថា អ្នកនេះជាសប្បុរស ដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មានទំនងដែរ ដែលថា សប្បុរសគប្បីស្គាល់អសប្បុរសបានថា អ្នកនេះជាអសប្បុរស ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន សម័យមួយ ក្នុងបរិសទ្យរបស់តោទេយ្យ-ព្រាហ្មណ៍ ពួកជននិយាយពាក្យជាទីតិះដៀលមនុស្សដទៃថា ស្តេចឯឡេយ្យនេះល្ងង់ ដែលទ្រង់ជ្រះថ្លាខ្លាំង ក្នុងសមណរាមបុត្ត ថែមទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរពក្នុងសមណរាមបុត្ត ។ ទាំងពួកបរិវាររបស់ស្តេចឯឡេយ្យទាំងនេះ គឺយមកៈ ១ មោគ្គល្លៈ ១ ឧគ្គៈ ១ នាវិនាកី ១ គន្ធព្វ ១ អគ្គិវេស្សៈ ១ ក៏ល្ងង់ដែរ ដែលទៅជ្រះថ្លាក្នុងសមណរាមបុត្ត ហើយនាំគ្នាធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរពក្នុងសមណរាមបុត្ត ។ ប៉ុន្តែ តោទេយ្យព្រាហ្មណ៍ ត្រឡប់ជាណែនាំពួកជនទាំងនោះ ដោយន័យនេះថា អ្នកដ៏ចម្រើនទាំងឡាយ សម្គាល់សេចក្តីនុ៎ះដូចម្តេច ស្តេចឯឡេយ្យជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើជាងពួកអ្នកប្រាជ្ញដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូច និងកិច្ចធំក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ ម្នាលអ្នកចម្រើន យ៉ាងហ្នឹងហើយស្តេចឯឡេយ្យជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើ ជាងពួកអ្នកប្រាជ្ញ

ដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូច និងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន សមណារាមបុត្តជាអ្នកប្រាជ្ញគ្រាន់បើជាងស្តេចឯឡេយ្យដែលជាអ្នកប្រាជ្ញ សមណារាមបុត្តនោះ ជាអ្នកអាចយល់ប្រយោជន៍ គ្រាន់បើជាងស្តេចឯឡេយ្យ ដែលជាអ្នកអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូច និងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ហេតុនោះ បានជាស្តេចឯឡេយ្យជ្រះថ្លាខ្លាំង ក្នុងសមណារាមបុត្ត ថែមទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរពក្នុងសមណារាមបុត្ត ។ អ្នកដ៏ចម្រើនទាំងឡាយ សម្គាល់សេចក្តីនុ៎ះដូចម្តេច ។ ពួកបរិវាររបស់ស្តេចឯឡេយ្យ គឺយមកៈ មោគ្គល្លៈ ឧគ្គៈ នាវិនាកី គន្ធព្វ អគ្គិវេស្សៈ សុទ្ធតែជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើជាងពួកអ្នកប្រាជ្ញ ដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូច និងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ នែអ្នកដ៏ចម្រើន យ៉ាងហ្នឹងហើយ ពួកបរិវាររបស់ស្តេចឯឡេយ្យ គឺយមកៈ មោគ្គល្លៈ ឧគ្គៈ នាវិនាកី គន្ធព្វ អគ្គិវេស្សៈ ជាអ្នកប្រាជ្ញអាចយល់ប្រយោជន៍គ្រាន់បើជាងពួកអ្នកប្រាជ្ញអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូច និងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ នែអ្នកដ៏ចម្រើន សមណារាមបុត្ត ជាអ្នកប្រាជ្ញគ្រាន់បើជាងពួកបរិវាររបស់ស្តេចឯឡេយ្យ ដែលជាអ្នកប្រាជ្ញ ជាអ្នកយល់ប្រយោជន៍គ្រាន់បើជាងពួកបរិវារ ដែលអាចយល់ប្រយោជន៍ គ្រាន់បើក្នុងកិច្ចតូច និង

កិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ហេតុនោះ បានជាពួកបរិវាររបស់ស្តេចឯឡេយ្យជ្រះថ្លាខ្លាំង ក្នុងសមណរាមបុត្ត ទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរពក្នុងសមណរាមបុត្ត ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ព្រោះពាក្យនេះ ព្រះគោតមដ៏ចម្រើនបានត្រាស់ត្រូវហើយថា ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះមិនសមហេតុ មិនសមផលទេ ដែលថាអសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរសដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះក៏មិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរសគប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរសដូច្នេះ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះទើបមានទំនង ដែលថា សប្បុរសគប្បីស្គាល់សប្បុរសបានថា អ្នកនេះជាសប្បុរស ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះក៏មានទំនងដែរ ដែលថា សប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ។ បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំនឹងទៅឥឡូវនេះ ព្រោះយើងខ្ញុំ ជាអ្នកមានកិច្ចច្រើន មានការត្រូវធ្វើច្រើន ។ ម្នាលព្រាហ្មណ៍ ឥឡូវនេះ អ្នកសម្គាល់នូវកាលគួរចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ រីករាយអនុមោទនា ភាសិតរបស់ព្រះដ៏មានព្រះភាគហើយ ក្រោកចាកទីអង្គុយចេញទៅ ។

# អដ្ឋកថា

## វស្សការសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវស្សការសូត្រទី ៧ ដូចតទៅនេះ បទថា **តោទេយ្យស្ស** បានដល់ គឺព្រាហ្មណ៍អ្នកដែនតុទិគាម ។ បទថា **បរិសតិ** បានដល់ ក្នុងបរិស័ទដែលប្រជុំព្រមគ្នាហើយ ។ បទថា **បរូចារម្ភំ វត្តេន្តិ** សេចក្តីថា ប្រព្រឹត្តហើយ តិះដៀលអ្នកដទៃ ។ បទថា **ពាលោ អយំ រាជា** ជាដើម លោកពោលដើម្បីសម្តែងពាក្យតិះដៀលដល់ជនទាំងនោះប្រព្រឹត្ត ។ បទថា **សមណេ រាមបុត្តេ** បានដល់ ឧទកតាបសរាមបុត្ត ។ បទថា **អភិប្បសន្នោ** បានដល់ ជ្រះថ្លាពន់ពេក ។ បទថា **បរមនិបច្ចការំ** បានដល់ កិរិយាដែលខ្ទនបន្ទោនយ៉ាងក្រៃលែង គឺប្រព្រឹត្តឱនលំទោន ។ បទថា **បរិហារកា** បានដល់ បរិវារ ។ បទជាដើមថា **យមកោ** ជាឈ្មោះនៃបរិវារជនទាំងនោះ ពិតហើយ បណ្តាបរិវារជនទាំងនោះ បុគ្គលម្នាក់ឈ្មោះយមកៈ បុគ្គលម្នាក់ឈ្មោះមោគ្គល្លៈ បុគ្គលម្នាក់ឈ្មោះឧគ្គៈ បុគ្គលម្នាក់ឈ្មោះនាវិនាកី បុគ្គលម្នាក់ឈ្មោះគន្ធព្វ បុគ្គលម្នាក់ឈ្មោះអគ្គិវេស្សៈ ។ បទថា **អស្សុទំ** ក្នុងបទថា **ត្យស្សុទំ** នេះ ត្រឹមតែជានិបាត អធិប្បាយថា នូវបរិវារជនទាំងនោះ ដែលអង្គុយក្នុងបរិស័ទរបស់ខ្លួន ។ បទថា **ឥមិនា ឆយេន នេតិ** សេចក្តីថា តោទេយ្យព្រាហ្មណ៍ទូន្មាន គឺឲ្យបុគ្គលនោះដឹងដោយហេតុនេះ ។

បទថា **ករណីយាធិករណីយេសុ** សេចក្តីថា ក្នុងកិច្ចដែលបណ្ឌិតគួរ

ធ្វើ និងកិច្ចដែលគួរធ្វើក្រៃលែង ។ បទថា **វចនីយាធិវចនីយេសុ** សេចក្តីថា ក្នុងពាក្យគួរពោល និងពាក្យគួរពោលដ៏ក្រៃលែង ។ ក្នុងបទថា **អលមត្ថ-ទសតរេហិ** នេះ សេចក្តីថា ជាអ្នកអាចឃើញប្រយោជន៍ទាំងឡាយ ឈ្មោះថា អលមត្ថទស គឺជាអ្នកអាចឃើញប្រយោជន៍ ជាងបរិវារជនទាំងនោះ ឈ្មោះថា **អលមត្ថទសតរ** ជាងជននោះដែលជាអ្នកអាចឃើញប្រយោជន៍ ។ បទថា **អលមត្ថទសតរោ** សេចក្តីថា ព្រះបាទឯឡេយ្យ ជាបុគ្គលក្រៃលែងជាង ព្រោះអាចឃើញប្រយោជន៍ តោទេយ្យព្រាហ្មណ៍កាលសួរថា សមណ-រាមបុត្ត ដែលជាអ្នកឈ្លាសជាងអ្នកឈ្លាសទាំងឡាយ ជាបណ្ឌិតជាងបណ្ឌិតទាំងឡាយ ទើបពោលយ៉ាងនេះ ។ កាលបើដូច្នោះ បរិវារទាំងនោះ កាលនឹងសាកសួរ ទើបពោលពាក្យជាដើមថា **ឯវំ ភោ** ដល់តោទេយ្យព្រាហ្មណ៍នោះ ។ ដូច្នោះ ព្រាហ្មណ៍សរសើរព្រះបាទឯឡេយ្យខ្លះ បរិវាររបស់ព្រះបាទឯឡេយ្យនោះខ្លះ ឧទករាមបុត្តខ្លះ ព្រោះជាសប្បុរស ។ អសប្បុរសដូចបុគ្គលខ្វាក់ សប្បុរសដូចបុគ្គលមានភ្នែក ។ បុគ្គលខ្វាក់រមែងមើលមិនឃើញនូវបុគ្គលមិនខ្វាក់ផង បុគ្គលដែលខ្វាក់ដូចគ្នាផង យ៉ាងណា អសប្បុរសរមែងមិនស្គាល់សប្បុរសផង អសប្បុរសផង ដូច្នោះ ។ បុគ្គលមានចក្ខុរមែងឃើញទាំងអ្នកខ្វាក់ ទាំងអ្នកមិនខ្វាក់ យ៉ាងណា សប្បុរស រមែងស្គាល់សប្បុរសផង អសប្បុរសផង ដូច្នោះ ។ ព្រាហ្មណ៍បានអាស្រ័យអំណាចប្រយោជន៍នេះថា សូម្បីតោទេយ្យព្រាហ្មណ៍បានដឹងហើយ នូវអសប្បុរស

ទាំងឡាយ ព្រោះជាសប្បុរស ដូច្នេះ ទើបមានចិត្តត្រេកអរ ពោលពាក្យជាដើមថា **អច្ឆរិយំ ភោ គោតម** ដូច្នេះ អនុមោទនាភាសិតរបស់ព្រះតថាគត ហើយធ្វើសក្ការៈ ក៏ត្រឡប់ទៅ ។ល។

**អដ្ឋកថា វស្សការសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧបកសូត្រទី ៨

[ ៣៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ឧបកមណ្ឌិកាបុត្ត ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះឧបកមណ្ឌិកាបុត្ត អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុគ្គលណាមួយនិយាយពាក្យតិះដៀលអ្នកដទៃ កាលបើនិយាយពាក្យតិះដៀលអ្នកដទៃ បុគ្គលទាំងអស់នោះ ឈ្មោះថា មិនញុំាងកុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ ឲ្យកើតឡើងបានទេ ក៏ឈ្មោះថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយទោស ។ ម្នាលឧបកៈ បើបុគ្គលនិយាយពាក្យ

តិះដៀលអ្នកដទៃ អ្នកដែលនិយាយពាក្យតិះដៀលអ្នកដទៃ រមែងមិនញុំាង
កុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ឲ្យកើតឡើងទេ ក៏ឈ្មោះ
ថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយទោស ម្នាលឧបកៈ អ្នកឯង
និយាយពាក្យតិះដៀលអ្នកដទៃ កាលបើអ្នកឯងនិយាយពាក្យតិះដៀលអ្នក
ដទៃ រមែងមិនញុំាងកុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ឲ្យ
កើតឡើងបានទេ ក៏ឈ្មោះថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយ
ទោសហើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបដូចបុគ្គលយកអន្ទាក់ដ៏ធំ
ទាក់កមនុស្សដែលទើបនឹងងើបឡើង ( អំពីទឹក ) យ៉ាងណាមិញ បពិត្រ
ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែងើបឡើងភ្លាម ត្រូវព្រះដ៏មានព្រះភាគ
ទាក់ដោយអន្ទាក់ គឺសម្ដីដ៏ធំ ក៏យ៉ាងនោះដែរ ។ ម្នាលឧបកៈ តថាគត
បញ្ញត្តទុកហើយថា របស់នេះជាអកុសល បទ ព្យញ្ជនៈ ធម្មទេសនារបស់
តថាគតក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា របស់នេះជាអកុសល
ព្រោះហេតុដូច្នេះៗ ម្នាលឧបកៈ រឿងនោះ តថាគតបញ្ញត្តទុកហើយថា របស់
នេះជាអកុសល គួរតែលះបង់ចេញ បទ ព្យញ្ជនៈ ធម្មទេសនារបស់
តថាគត ក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា អកុសលនេះ គួរ
លះបង់ចេញ ព្រោះហេតុដូច្នេះៗ ម្នាលឧបកៈ តថាគត បញ្ញត្តទុកហើយថា
របស់នេះជាកុសល បទ ព្យញ្ជនៈ ធម្មទេសនារបស់តថាគត ក្នុងរឿងនោះ
មានច្រើនប្រមាណមិនបានថា របស់នេះជាកុសល ព្រោះហេតុដូច្នេះៗ ម្នាល

ឧបក: រឿងនោះ តថាគតបញ្ញត្តទុកហើយថា របស់នេះជាកុសល គួរតែចម្រើន បទ ព្យញ្ជនៈ ធម្មទេសនារបស់តថាគត ក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា កុសលនេះគួរតែចម្រើន ព្រោះហេតុដូច្នេះៗ លំដាប់នោះ ឧបកមណ្ឌិកាបុត្ត រីករាយ អនុមោទនា ភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ដើរប្រទក្សិណរួចហើយ ក៏ចូលទៅគាល់ព្រះបាទអជាតសត្តុវេទេហិបុត្ត ក្នុងដែនមគធៈ លុះចូលទៅដល់ហើយ ក៏ក្រាបទូលរឿងរ៉ាវដែលខ្លួនបានទៅគាល់ ចរចាជាមួយនឹងព្រះមានព្រះភាគគ្រប់ប្រការ ចំពោះព្រះបាទអជាតសត្តុវេទេហិបុត្ត ក្នុងដែនមគធៈ ។ កាលបើឧបកមណ្ឌិកាបុត្តក្រាបទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ក្នុងដែនមគធៈ ទ្រង់ខ្ញាល់តូចព្រះរាជហឫទ័យត្រាស់នឹងឧបកមណ្ឌិកាបុត្តដូច្នេះថា ឱក្មេងអ្នកស្រុកធ្វើអំបិលនេះ លុបលាងគុណអ្វីម្ល៉េះ មាត់រឹងអ្វីម្ល៉េះ គឃ្លើនអ្វីម្ល៉េះ ព្រោះវាហ៊ានសម្គាល់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ថាជាមនុស្សដែលគេមិនគួររាប់អាន នែឧបកអ្នកឯងចូរចេញទៅ ចូរវិនាសទៅ កុំឲ្យអញឃើញឯង ។

# អដ្ឋកថា

## ឧបកសូត្រ

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបកសូត្រទី ៨ ដូចតទៅនេះ បទថា **ឧបកោ** ជាឈ្មោះនៃមណ្ឌិកាបុត្តនោះ ។ បទថា **មណ្ឌិកាបុត្តោ** ប្រែថា កូនរបស់នាងមណ្ឌិកា ។ បទថា **ឧបសង្កមិ** សេចក្ដីថា បានឮថា ឧបក-មណ្ឌិកាបុត្តនោះ ជាឧបដ្ឋាករបស់ទេវទត្ត ចូលទៅគាល់ដើម្បីកំណត់ថា កាលអាត្មាអញចូលទៅគាល់ព្រះសាស្ដា នឹងត្រាស់សរសើរ ឬត្រាស់តិះដៀលហ្ន៎ អាចារ្យពួកខ្លះពោលដូច្នេះថា គាត់ចូលទៅគាល់បំណងនឹងស្ដាប់ពាក្យថា ទេវទត្តធ្លាក់នរកតាំងនៅអស់មួយកប្ប អ្នកណាក៏កែមិនបាន ដូច្នេះហើយ នឹងបានចាក់ដោតព្រះសាស្ដាក៏មាន ។ បទថា **បរូបវាទម្ពុំ វទេតិ** បានដល់ ពោលតិះដៀលអ្នកដទៃ ។ បទថា **សព្វោ សោ ន ឧប្បាទេតិ** សេចក្ដីថា បុគ្គលទាំងអស់នោះមិនធ្វើកុសលធម៌ឲ្យកើតឡើង ឬមិនអាចធ្វើពាក្យនៃខ្លួនឲ្យសមគួរបានឡើយ ។ បទថា **អនុប្បាទេន្តោ គារយ្ហោ ហោតិ** សេចក្ដីថា មិនអាចឲ្យកុសលធម៌កើតឡើងបាន កាលមិនអាចធ្វើពាក្យរបស់ខ្លួនឲ្យសមគួរបាន ក៏រមែងជាបុគ្គលត្រូវតិះដៀល ។ បទថា **ឧបវជ្ជោ** សេចក្ដីថា រមែងជាបុគ្គលត្រូវតិះដៀល ត្រូវស្ដីថាដូចគ្នា ឬជាបុគ្គលប្រកបដោយទោស អធិប្បាយថា មានទោស ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចាប់នូវវាទៈរបស់ឧបកៈនោះហើយ កាលទ្រង់ច្បាម-កឧបកៈនោះ ទើបត្រាស់ថា **បរូបវាទម្ពុំ** ជាដើម ។ បទថា

**ឧម្មុជ្ជមានកាំយោវ** បានដល់ កាលងើបក្បាលឡើងអំពីទឹកប៉ុណ្ណោះ ។ ក្នុងបទថា **តត្ថ អបរិមាណា បទា** ជាដើម គប្បីជ្រាបបវិនិច្ឆ័យដូច្នេះ ។ បទក្តី អក្ខរៈក្តី ធម្មទេសនាក្តី រាប់មិនបានក្នុងការបញ្ញត្តិថា អកុសលនោះ ។ បទថា **ឥតិបីទំ អកុសលំ** សេចក្តីថា បទទាំងឡាយដែលមកហើយក្នុងអកុសលបញ្ញត្តយ៉ាងនេះថា នេះក៏អកុសល ព្រោះហេតុនេះៗ ក៏អកុសលដូច្នេះ ក៏រាប់មិនបាន ។ កាលបើដូច្នោះ ព្រះតថាគត ទ្រង់គប្បីសម្តែងធម៌នោះ ដោយអាការណាមួយ ទេសនារបស់ព្រះអង្គយ៉ាងនេះ ក៏គប្បីរាប់មិនបាន ដូចដែលលោកពោលថា ធម៌ទេសនារបស់តថាគតនោះ កំណត់កាន់យកមិនបាន បទព្យញ្ជនៈនៃធម៌ ក៏កំណត់កាន់យកមិនបាន អត្ថគ្រប់វារៈគប្បីជ្រាបដោយឧបាយនេះ ។

បទថា **យាវធំសីវតាយំ** គឺកុមារនេះប្រហែលជាលុបគុណ ។ បទថា **លោណការកទារកោ** គឺក្មេងក្នុងស្រុកអ្នកស្រែអំបិល ។ ពាក្យថា **យត្រ ហិ ណាម** កាត់បទជា **យោ ហិ ណាម** ប្រែថា ឈ្មោះណា ។ បទថា **អបសាទេតព្វំ មញ្ញិស្សតិ** គឺនឹងសម្គាល់ព្រះពុទ្ធថា គួររុកកួន ។ បទថា **អបេហិ** សេចក្តីថា អ្នកចូរចៀសចេញទៅ កុំមកឈរចំពោះមុខអញឡើយ ។ ព្រះបាទអជាតសត្រូវត្រាស់យ៉ាងនេះហើយ ឲ្យបរិវារចាប់ត្រង់កអូសចេញទៅ ។

**អដ្ឋកថា ឧបកសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សច្ចិកិរិយសូត្រទី ៩

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលត្រូវធ្វើឲ្យជាក់ច្បាស់នេះ មាន ៤ យ៉ាង ។ ធម៌ទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាមកាយក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ដោយចក្ខុក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាក៏មាន ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាមកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មោក្ខធម៌ ៨ ជាធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាម-កាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុព្វេនិវាស ជាធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ដោយចក្ខុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការច្យុតិ និងការកើតឡើងរបស់សត្វទាំងឡាយ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ការអស់អាសវៈ ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះឯង ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។

# អដ្ឋកថា

## សច្ចិកិរិយសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចិកិរិយសូត្រទី ៩ ដូចតទៅនេះ បទថា **កាយេន** បានដល់ ដោយនាមកាយ ។ បទថា **សច្ឆិករណីយា** បានដល់ គប្បីធ្វើឲ្យប្រចក្ស ។ បទថា **សតិយា** បានដល់ ដោយបុព្វេនិវាសានុស្សតិ ។ បទថា **ចក្ខុនា** គឺដោយទិព្វចក្ខុ ។ បទថា **បញ្ញាយ** សេចក្តីថា វិបស្សនាបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយឈានបញ្ញា មគ្គបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយវិបស្សនាបញ្ញា ផលបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយមគ្គបញ្ញា បច្ចវេក្ខណបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយផលបញ្ញា អធិប្បាយថា គប្បីត្រាស់ដឹង ។ ចំណែកអរហត្ត ពោល គឺការអស់អាសវៈ ឈ្មោះថា គប្បីធ្វើឲ្យជាក់ច្បាស់ដោយបច្ចវេក្ខណបញ្ញា ។ល។

**អដ្ឋកថា សច្ចិកិរិយសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ឧបោសថសូត្រទី ១០

[ ៤០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងមិគារមាតុប្បាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះភិក្ខុសង្ឃចោមរោម គង់នៅក្នុងថ្ងៃឧបោសថនោះ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញភិក្ខុសង្ឃ នៅស្ងៀមស្ងាត់ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ មិនមានការចរចាអ្វី ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មិនមានការស្តីនិយាយអ្វី ជាបរិសទ្យស្អាត តាំងនៅក្នុងខ្លឹមធម៌ បរិសទ្យមានសភាពយ៉ាងណា ដែលក្រនឹងបានឃើញក្នុងលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ បរិសទ្យមានសភាពយ៉ាងណា ដែលគួរទទួលគ្រឿងបូជា គួរទទួលរបស់ទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ ទានមានប្រមាណតិច ដែលគេឲ្យដល់បរិសទ្យមានសភាពយ៉ាងណា ហើយបានផលច្រើន ទានច្រើន ដែលគេឲ្យហើយរឹងរឹតតែមានផលច្រើនឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ បរិសទ្យណាដែលគួរគេស្ពាយស្បៀងទៅមើល សូម្បីអស់ទីរាប់ទាំងយោជន៍ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ មានគុណសម្បត្តិយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពជាទេវតា ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុ

ដែលសម្រេចភាពជាព្រហ្ម ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពមិនញាប់ញ័រ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពជាអរិយៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាទេវតា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់វិតក្កវិចារបាន ។បេ។ ចូលកាន់ទុតិយជ្ឈានព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន ព្រោះលះសុខបានផង លះទុក្ខបានផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាទេវតា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាព្រហ្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទិសខាងលើ ខាងក្រោម និងទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងអស់ មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទិសខាងលើ ខាងក្រោម និងទទឹង មានចិត្តប្រកបដោយឧបេក្ខាជា ចិត្តធំទូលាយ ប្រមាណមិនបាន

មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាព្រហ្ម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពមិនញាប់ញ័រ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងរូបសញ្ញាដោយអាការទាំងពួង ព្រោះរលត់បដិឃ-សញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ពិចារណាថា អាកាសមិនមានទីបំផុត បានសម្រេចអាកាសានញ្ចាយតនជ្ឈាន កន្លងអាកាសានញ្ចាយត-នជ្ឈាន ដោយអាការទាំងពួងហើយ ពិចារណាថា វិញ្ញាណ មិនមានទីបំផុត បានសម្រេចវិញ្ញាណញ្ចាយតនជ្ឈាន កន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយអាការទាំងពួង ហើយពិចារណាថា របស់អ្វីតិចតួចមិនមាន បានសម្រេចអាកិញ្ចញ្ញាយតនជ្ឈាន កន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយអាការទាំងពួងហើយបានសម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពមិនញាប់ញ័រយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាអរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាអរិយៈ យ៉ាងនេះឯង ។

យោធាជីវវគ្គទី ៤ ចប់

### ឧទ្ទាននៃយោធាជីវវគ្គនោះ គឺ

និយាយអំពីការប្រៀបធៀបនឹងយោធាជីវៈ ១ ការធានាមិនបាន ១ របស់ដែលឮហើយ ១ ការមិនខ្លាចស្លាប់ ១ នឹងសមណសច្ចៈ ១ ជាគម្រប់ ៥ រឿងភិក្ខុច្នាស ១ វស្សការព្រាហ្មណ៍ ១ រឿងឧបកៈ ១ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ១ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងថ្ងៃឧបោសថ ១ ។

# អដ្ឋកថា

## ឧបោសថសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបោសថសូត្រទី ១០ ដូចតទៅនេះ បទថា **តុណ្ហីភូតំ តុណ្ហីភូតំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្លឹងមើលក្នុងទិសណាមួយ ភិក្ខុសង្ឃក្នុងទិសនោះៗ ក៏អង្គុយស្ងៀម ។ បទថា **ភិក្ខូ អាមន្តេសិ** សេចក្តីថា ទ្រង់សម្លឹងមើលដោយព្រះចក្ខុដ៏ជ្រះថ្លា ហើយកើតនូវបាមោជ្ជក្នុងធម៌ ទើបត្រាស់នឹងភិក្ខុទាំងឡាយ ដែលដល់ព្រមដោយបដិបទា ព្រោះទ្រង់បំណងនឹងលើកតម្កើងធម៌ ។ បទថា **អបលាបា** បានដល់ បរិស័ទវៀរនូវការសន្ទនា ។ បទក្រៅអំពីនេះ ជាវេវចនៈរបស់បទថា **អបលាបា** នោះឯង ។ បទថា **សុទ្ធា** គឺអស់មន្ទិល ។ បទថា **សារេ បតិដ្ឋិតា** បានដល់ តាំងនៅក្នុងធម្មសារៈ មានសីលសារៈជាដើម ។ បទថា

**អលំ** ប្រែថា គួរ ។ បទថា **យោជនគណានិ** សេចក្ដីថា ចម្ងាយផ្លូវមួយយោជន៍ សូម្បី ១០ យោជន៍ ច្រើនជាងនោះ ក៏ហៅថា រាប់ជាយោជន៍ ។ តែក្នុងទីនេះបំណងយក ១០០ យោជន៍ខ្លះ ១០០០ យោជន៍ខ្លះ ។ បទថា **បុដោសេនាបិ** បានដល់ ស្បៀងដើរផ្លូវ ហៅថា **បុដោសំ** អធិប្បាយថា ត្រូវកាន់យកស្បៀងដើរផ្លូវចូលទៅរក ក៏គួរពិត ។ បាលីថា **បុដំសេន** ដូច្នេះក៏មាន ។ អត្ថនៃបទនោះថា បង្វេច ហេតុនោះ បុគ្គលនោះឈ្មោះថា មានបង្វេចនៅត្រង់ស្មា ដោយបង្វេចត្រង់ស្មានោះ ។ អធិប្បាយថា ស្ពាយស្បៀងទៅ ដូច្នេះ ។

ឥឡូវនេះ ត្រាស់ថា **សន្តិ ភិក្ខវេ** ជាដើម ដើម្បីសម្ដែងថា ភិក្ខុទាំងឡាយដែលជាអ្នកប្រកបដោយគុណទាំងឡាយបែបនេះ មាននៅក្នុងទីនេះ ។ បណ្ដាបទទាំងនោះ បទថា **ទេវប្បត្តា** សេចក្ដីថា ភិក្ខុទាំងឡាយ សូម្បីទិព្វវិហារដែលជាហេតុកើតជាឧបបត្តិទេព និងព្រះអរហត្ត ដោយទិព្វវិហារ ។ បទថា **ព្រហ្មប្បត្តា** សេចក្ដីថា ភិក្ខុទាំងឡាយសូម្បីព្រហ្មវិហារ គឺជាហេតុសម្រេចជាព្រហ្ម ដោយអត្ថថា មិនមានទោស និងលំដាប់ព្រះអរហត្តដោយព្រហ្មវិហារ ។ បទថា **អានេញ្ជប្បត្តា** សេចក្ដីថា ភិក្ខុទាំងឡាយ ដល់អានេញ្ជា គឺហេតុជាការមិនញាប់ញ័រ និងព្រះអរហត្តដោយអានេញ្ជា ។ បទថា **អរិយប្បត្តា** សេចក្ដីថា កន្លងនូវការៈបុថុជ្ជន ដល់នូវអរិយការៈ ។

ក្នុងបទថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ ទេវប្បត្តោ ហោតិ** ជាដើម មាន

*វិនិច្ឆ័យដូច្នេះ ភិក្ខុតាំងនៅក្នុងចតុត្ថជ្ឈានដែលជារូបាវចរយ៉ាងនេះហើយ ទើបត្រឡប់ចិត្តទៅសម្រេចអរហត្ត ឈ្មោះថា ជាអ្នកដល់នូវជាន់ទេវតា ។ ភិក្ខុតាំងនៅក្នុងព្រហ្មវិហារ ៤ ត្រឡប់ចិត្តទៅសម្រេចអរហត្ត ឈ្មោះថា ជាអ្នកដល់នូវជាន់ព្រហ្ម ។ តាំងនៅក្នុងអរូបជ្ឈាន ៤ ត្រឡប់ចិត្តទៅសម្រេចអរហត្ត ឈ្មោះថា ជាអ្នកដល់នូវលំដាប់អានេញ្ជា មគ្គ ៤ និងផល ៣ ត្រាស់ដោយសច្ចៈ ៤ មានបទថា* **ឥទំ ទុក្ខំ** *ដូច្នេះជាដើម ព្រោះដូច្នោះ ភិក្ខុដែលសម្រេចអរិយធម៌នេះ ទើបបានឈ្មោះថា ជាអ្នកដល់នូវលំដាប់អរិយៈ ។ល។*

**អដ្ឋកថាឧទោសិតសូត្រទី ១០ ចប់**

**យោធាជីវវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# មហាវគ្គទី ៥

## សោតានុគតសូត្រទី ១

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការនៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ជាធម៌ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ។ អានិសង្ស ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិបាន ។ ភិក្ខុនោះ ភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកធម៌ទាំងឡាយ រមែងប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខ ក្នុងទេវនិកាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ ឯសត្វនោះ រំលោជល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ១ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យា-

ករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ ។ ភិក្ខុនោះភ្លេចស្មារតី ធ្វើមរណ-កាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំង-ឡាយ មិនសូវប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខក្នុងទេវ-និកាយនោះ ប៉ុន្តែជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញខាងផ្លូវចិត្ត សម្តែងធម៌ដល់ទេវបរិសទ្យបាន ។ ទេវតានោះ មានសេចក្តីត្រិះរិះយ៉ាង នេះថា អាត្មាអញបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា នេះ គឺ ធម្មវិន័យនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា យឺតយូរ សត្វនោះដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។ ម្នាល ភិក្ខុទាំងឡាយ ប្រៀបដូចបុរសជាអ្នកឈ្លាសវៃខាងសំឡេងស្គរ បុរសនោះ ដើរទៅកាន់ផ្លូវឆ្ងាយ បានឮសំឡេងស្គរ បុរសនោះ ក៏មិនមានសេចក្តី សង្ស័យ ឬងឿងឆ្ងល់នឹងសំឡេងស្គរនោះថា សំឡេងស្គរមែន ឬមិនមែន សំឡេងស្គរទេដូច្នេះឡើយ បុរសនោះគប្បីដល់នូវសេចក្តីចូលចិត្តថា សំឡេង ស្គរដោយពិត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។បេ។ ជាអ្នកដល់នូវគុណវិសេស ឆាប់រហ័ស ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃធម៌ ដែលចូលទៅកាន់ ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ

ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀន នូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយ ទិដ្ឋិ ។ ភិក្ខុនោះ ភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវ-និកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខ ក្នុងទេវនិកាយនោះឡើយ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសម្តែងធម៌ ដល់ទេវបរិសទ្យ បានឡើយ ។ គ្រាន់តែថា ទេវបុត្តអាចសម្តែងធម៌ដល់ទេវបរិសទ្យបាន ប៉ុណ្ណោះ ។ ទេវបុត្តនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញបាន ប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា នេះ គឺ ធម្មវិន័យនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា យឺតយូរ សត្វនោះ ដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសជាអ្នកឈ្លាសវៃនឹងសំឡេងស័ង្ខ បុរសនោះដើរទៅកាន់ផ្លូវ ឆ្ងាយ បានឮសំឡេងស័ង្ខ បុរសនោះក៏មិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ នឹងសំឡេងស័ង្ខនោះថា សំឡេងស័ង្ខមែន ឬមិនមែនសំឡេងស័ង្ខទេ បុរស នោះគប្បីដល់នូវសេចក្តីចូលចិត្តថា ជាសំឡេងស័ង្ខដោយពិត មានឧបមា យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យយ៉ាងនោះ

ដែរ ។បេ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៣ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ធម៌ទាំងនោះជាសភាវៈចូលទៅកាន់ប្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ ។ ភិក្ខុនោះ ក៏ភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដដល់ភិក្ខុនោះ ដែលមានសេចក្ដីសុខក្នុងទេវនិកាយនោះទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសម្ដែងធម៌ដល់ទេវបរិសទ្យ ទាំងមិនមែនជាទេវបុត្ត អាចសម្ដែងធម៌ដល់ទេវបរិសទ្យបានទេ តែបើមានឱបបាតិកសត្វរឭកនូវឱបបាតិកសត្វថា ម្នាលគ្នាយើង ពួកយើងបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា អ្នករឭកបាននូវធម្មវិន័យនោះដែរឬ ។ ទេវបុត្តនោះ ក៏និយាយយ៉ាងនេះថា ម្នាលគ្នាយើង យើងរឭកបាន ម្នាលគ្នាយើង យើងរឭកបាន ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា យឺតយូរ សត្វនោះដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចសម្លាញ់ ២ នាក់លេងអាចម៍ដីជាមួយគ្នា សម្លាញ់ទាំង ២ នាក់នោះ មកជួបគ្នាក្នុងទីណា

មួង១ សម្លាញ់ម្នាក់ ក៏និយាយទៅនឹងសម្លាញ់ម្នាក់នោះយ៉ាងនេះថា នែសម្លាញ់ ឯងរឭកបាននូវហេតុនេះដែរឬទេ ។ សម្លាញ់នោះគប្បីតបយ៉ាងនេះថា នែសម្លាញ់ អញរឭកបាន នែសម្លាញ់ អញរឭកបាន មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។បេ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង ៤ ប្រការនេះ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។

# អដ្ឋកថា

# មហាវគ្គទី ៥

## សោតានុគតសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោតានុគតសូត្រទី ១ នៃមហាវគ្គទី ៥ ដូចតទៅនេះ បទថា **សោតានុគតានំ** សេចក្តីថា ធម៌ដែលបុគ្គលផ្សៀងសោតបសាទស្តាប់ ហើយកំណត់ដោយសោតញ្ញាណ ។ បទថា **ចត្តារោ អានិសំសា បដិកង្ខា** សេចក្តីថា គុណានិសង្ស ៤ ប្រការ គប្បីប្រាថ្នាបាន ។ សូត្រនេះ ព្រះមានព្រះភាគទ្រង់ប្រារព្ធដោយអំណាចអត្ថុប្បត្តិហេតុ ។ សួរថា អត្ថុប្បត្តិហេតុដូចម្តេច ។ ឆ្លើយថា ដោយអំណាចអត្ថុប្បត្តិហេតុ គឺភិក្ខុទាំង-ឡាយ មិនចូលទៅស្តាប់ធម៌ ។ បានឮថា ពួកព្រាហ្មណ៍ ៥០០ បួសហើយទៅស្តាប់ធម៌ ដោយគិតថា ព្រះសម្មាសម្ពុទ្ធកាលត្រាស់អំពីលិង្គវចនៈ វិភត្តិ បទ និងព្យញ្ជនៈជាដើម និងត្រាស់តែអ្វីដែលពួកយើងចេះហើយនោះឯង អ្វីដែលយើងមិនទាន់ចេះ នឹងត្រាស់អ្វីបាន ដូច្នេះ ។ ព្រះសាស្តា បានឮរឿងនោះហើយ ទើបហៅព្រាហ្មណ៍ដែលបួសទាំងនោះមកហើយ ត្រាស់ថា ព្រោះហេតុអ្វី ទើបពួកអ្នកធ្វើយ៉ាងនេះ ពួកអ្នកចូរស្តាប់ធម៌ដោយគោរព ការស្តាប់ធម៌ដោយគោរព និងស្វាធ្យាយធម៌ អានិសង្សទាំងនេះប៉ុណ្ណេះ សង្ឃឹមបាន ដូច្នេះ កាលទ្រង់សម្តែង ទើបផ្តើមទេសនានេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ បរិយាបុណាតិ** សេចក្តីថា ភិក្ខុរមែង

រៀនធម៌ គឺបាលីដែលជានវង្គសត្ថុសាសនៈរបស់ព្រះសាស្ដាមានអង្គ ៩ គឺ សុត្តៈ គេយ្យៈ ជាដើម ។ បទថា **សោតានុគតា ហោន្តិ** សេចក្ដីថា ធម៌ទាំងនោះក៏រមែងតាមទៅចូលសោតៈរឿយៗ ។ បទថា **មនសានុបេក្ខិតា** បានដល់ សម្លឹងមើលដោយចិត្ត ។ បទថា **ទិដ្ឋិយា សុប្បដិវិទ្ធា** សេចក្ដីថា ដឹងធ្លុះ តាក់តែងដោយល្អ គឺធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា ដោយផលផង ដោយហេតុផង ។ ព្រះពុទ្ធវចនៈថា **មុដ្ឋស្សតិ កាលំ កុរុមានោ** នេះ មិនមែនត្រាស់ព្រោះមិនមានសតិរឭកដល់ តែត្រាស់សំដៅដល់ការស្លាប់របស់បុថុជ្ជន ។ ពិតហើយ បុថុជ្ជន ឈ្មោះថា ជាអ្នកស្លាប់ដោយមិនមានស្មារតី ។ បទថា **ឧបបជ្ជតិ** សេចក្ដីថា ភិក្ខុតាំងនៅក្នុងសីលបរិសុទ្ធហើយ រមែងកើតក្នុងទេវលោក ។ បទថា **ធម្មបទា បិលវន្តិ** សេចក្ដីថា ធម៌ គឺព្រះពុទ្ធ-វចនៈដែលរត់មាត់ មានការស្វាធ្យាយជាមូលមកអំពីមុនទាំងអស់ រមែងអណ្ដែតឡើងប្រាកដ ដឹងបានច្បាស់ដល់ភិក្ខុដែលមានសុខ ដែលកើតក្នុងវិមានកែវ ដូចស្រមោលក្នុងកញ្ចក់ដែលថ្លា ។ បទថា **ទន្ធោ ភិក្ខវេ សតុប្បាទោ** សេចក្ដីថា ការរឭកដល់ព្រះពុទ្ធវចនៈកើតឡើងយឺតយូរ គឺធូន់ ។ បទថា **អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ** សេចក្ដីថា រមែងសម្រេចនិព្វាន ។ បទថា **ឥទ្ធិមា ចេតោវសិប្បត្តោ** បានដល់ ព្រះខីណាស្រពដែលដល់ព្រមដោយឫទ្ធិ ដល់នូវភាពជំនាញនៃចិត្ត ។ ក្នុងបទថា **អយំ វា សោ ធម្មវិនយោ** នេះ **វា** សព្ទ មានអត្ថថា ក្លឹច្បាស់ ។

បទថា **យត្ថ** គឺក្នុងធម្មវិន័យណា ។ បទថា **ព្រហ្មចរិយំ អចរឹ** បាន ដល់ អាត្មាអញបាននៅប្រព្រឹត្តព្រហ្មចរិយៈ ។ បទនោះ ត្រាស់ដោយ អំណាចការរឭកដល់ព្រះពុទ្ធវចនៈថា ឈ្មោះថា ព្រះពុទ្ធវចនៈនេះ អាត្មា អញក៏បានរៀនសូត្រមកហើយអំពីមុន ។ បទថា **ទេវបុត្តោ** បានដល់ ទេវបុត្រដែលជាធម្មកថិកមួយអង្គ ដូចបញ្ចាលចណ្ឌទេវបុត្រ ដូចហត្ថក-មហាព្រហ្ម និងសនង្កុមារព្រហ្ម ។ បទថា **ឱបចាតិកោ ឱបចាតិកំ សារេតិ** សេចក្ដីថា ទេវបុត្រកើតមុន ឲ្យទេវបុត្រកើតក្រោយរឭក ទ្រង់សម្ដែងភាព ដែលសម្លាញ់ទាំងនោះស្និទ្ធស្នាលគ្នាអស់កាលដ៏យូរ ដោយបទថា **សហាបំ-សុកីឡកា** នោះ ។ បទថា **សមាគច្ឆេយ្យុំ** សេចក្ដីថា សម្លាញ់ទាំងនោះ គប្បីទៅជាមួយគ្នាត្រង់សាលាខ្លះ ត្រង់គល់ឈើខ្លះ ។ បទថា **ឯវំ វទេយ្យ** សេចក្ដីថា សម្លាញ់នោះ អង្គុយមុនត្រង់សាលាខ្លះ ត្រង់គល់ឈើខ្លះ គប្បី ពោលយ៉ាងនេះនឹងសម្លាញ់ដែលមកខាងក្រោយ ។ បទដ៏សេស ក្នុងទីគ្រប់ អន្លើ គប្បីជ្រាបដោយន័យដែលពោលមកហើយ ។

**អដ្ឋកថា សោតានុគតសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ឋានសូត្រទី ២

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ នេះ បុគ្គលគប្បីដឹងច្បាស់ដោយហេតុ ៤ ប្រការ ។ ហេតុ ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សីល បុគ្គលគប្បីដឹងបាន ដោយការនៅរួមគ្នា តែសីលនោះ បុគ្គលធ្វើទុកក្នុងចិត្តឱ្យខ្ជាប់ខ្ជួនមិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន ទាំងបុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្អាត បុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្តីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តឱ្យខ្ជាប់ខ្ជួនមិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន ទាំងបុគ្គលឥតប្រាជ្ញា មិនគប្បីដឹងបានដោយកាលជាអង្វែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំង បុគ្គលគប្បីដឹងបាន ក្នុងកាលដែលសេចក្តីអន្តរាយ តែកម្លាំងនោះ បុគ្គលធ្វើទុកក្នុងចិត្តឱ្យខ្ជាប់ខ្ជួន មិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន ទាំងបុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញា បុគ្គលគប្បីដឹងបាន ដោយការសាកច្ឆា ក៏តែប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តឱ្យខ្ជាប់ខ្ជួន មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គល ឥតប្រាជ្ញា មិនគប្បីដឹងបាន ដោយកាលជាអង្វែង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សីល គឺបុគ្គលដឹងបាន

ដោយការនៅរួមគ្នា តែសីលនោះបុគ្គលធ្វើទុកក្នុងចិត្តវិញ មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលនៅរួមជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា យូរមកហើយ លោកដ៏មានអាយុនេះ ជាអ្នកធ្វើសីលឲ្យដាច់ ធ្វើសីលឲ្យធ្លុះ ធ្វើសីលឲ្យពព្រុស ធ្វើសីលឲ្យពពាល មិនមែនជាអ្នកធ្វើសីលឲ្យខ្ជាប់ខ្ជួន មិនមែនជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ លោកដ៏មានអាយុនេះ ជាអ្នកទ្រុស្ត-សីល លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានសីលទេ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត បុគ្គលក្នុងលោកនេះ កាលនៅរួមជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា យូរមកហើយ លោកដ៏មានអាយុនេះ មិនមែនជាអ្នកធ្វើសីលឲ្យដាច់ មិនមែនធ្វើសីលឲ្យធ្លុះ មិនមែនធ្វើសីលឲ្យពព្រុស មិនមែនធ្វើសីលឲ្យពពាលទេ ជាអ្នកធ្វើសីលខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ លោកដ៏មានអាយុនេះ ជាអ្នកមានសីល លោកដ៏មានអាយុនេះ មិនមែនទ្រុស្តសីលឡើយ ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សីល បុគ្គលគប្បីដឹងបាន ដោយការនៅរួមគ្នា តែសីលនោះ បុគ្គលធ្វើទុកក្នុងចិត្តវិញ មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹង

បាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ គឺតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីស្អាត បុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្ដីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនោះ ពាក្យនុ៎ះ គឺតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលនិយាយជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា លោកដ៏មានអាយុនេះ កាលនិយាយជាមួយនឹងមនុស្សម្នាក់ ដោយឡែកផ្សេង លុះនិយាយនឹងមនុស្ស ២ នាក់ ដោយឡែកផ្សេង និយាយនឹងមនុស្ស ៣ នាក់ ដោយឡែកផ្សេង និយាយនឹងមនុស្សច្រើននាក់ ដោយឡែកផ្សេងមុន លោកដ៏មានអាយុនេះ និយាយពាក្យក្រោយខុសគ្នានឹងពាក្យមុន លោកដ៏មានអាយុនេះ មានសម្ដីមិនបរិសុទ្ធទេ លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានសម្ដីបរិសុទ្ធទេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលក្នុងលោកនេះ កាលនិយាយជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា លោកដ៏មានអាយុនេះ តែម្នាក់ឯង តែងនិយាយនឹងមនុស្សម្នាក់យ៉ាងណា និយាយនឹងមនុស្ស ២ នាក់ ក៏យ៉ាងនោះដែរ និយាយនឹងមនុស្ស ៣ នាក់ក៏យ៉ាងនោះដែរ និយាយនឹងមនុស្សច្រើននាក់ក៏យ៉ាងនោះដែរ លោកដ៏មានអាយុនេះ និយាយពាក្យ

ក្រោយមិនខុសគ្នានឹងពាក្យមុន លោកដ៏មានអាយុនេះ ជាអ្នកមានសម្តីបរិសុទ្ធ លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានសម្តីមិនបរិសុទ្ធទេ ។ ពាក្យណា ដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីស្អាតបុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្តីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ កម្លាំង បុគ្គលគប្បីដឹងបាន ក្នុងកាលដែលមានអន្តរាយ តែកម្លាំងនុ៎ះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសនៃភោគសម្បត្តិពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសដោយរោគពាល់ត្រូវក្តី ពិចារណាឲ្យឃើញច្បាស់ថា លោកសន្និវាស និងការបាននូវអត្តភាពនេះកើតឡើង តាមទំនងដែលលោកធម៌ទាំង ៨ តែងប្រព្រឹត្តទៅតាមសត្វលោក ក្នុងលោកសន្និវាស និងការបាននូវអត្តភាព ( នោះឯង ) ទាំងសត្វលោក ក៏រមែងប្រព្រឹត្តទៅតាមលោកធម៌ទាំង ៨ ប្រការ គឺលាភ ១

អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ លុះបុគ្គលនោះ ត្រូវសេចក្ដីវិនាសនៃញាតិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសនៃភោគសម្បត្តិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសដោយរោគពាល់ត្រូវក្ដី ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្ដីវង្វេងវង្វាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះទៀត ក្នុងលោកនេះ ជាអ្នកត្រូវសេចក្ដីវិនាសនៃញាតិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសនៃភោគសម្បត្តិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសដោយរោគពាល់ត្រូវក្ដី ទើបពិចារណាឃើញច្បាស់ដូច្នេះថា លោកសន្និវាសនិងការបាននូវអត្តភាពនេះ កើតឡើងតាមទំនងដែលលោកធម៌ទាំង ៨ រមែងប្រព្រឹត្តទៅតាមសត្វលោក ក្នុងលោកសន្និវាសនិងការបាននូវអត្តភាព ( នោះឯង ) ទាំងសត្វលោក ក៏រមែងប្រព្រឹត្តទៅតាមលោកធម៌ទាំង ៨ ប្រការ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ លុះបុគ្គលនោះ កាលត្រូវសេចក្ដីវិនាសនៃញាតិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសនៃភោគសម្បត្តិពាល់ត្រូវក្ដី ត្រូវសេចក្ដីវិនាសដោយរោគពាល់ត្រូវក្ដី មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង ទ្រហោយំ មិនដល់នូវសេចក្ដីវង្វេងវង្វាង ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ កម្លាំង បុគ្គលគប្បីដឹងបាន ក្នុងកាលដែលមានសេចក្ដីអន្តរាយ តែកម្លាំងនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការ

មិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាបុគ្គលគប្បីដឹងបាន ដោយការសាកច្ឆា ក៏ប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជាមិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលពោលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា រមែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកដ៏មានអាយុនេះ យ៉ាងណា មួយទៀត អភិនីហាររបស់លោកដ៏មានអាយុនេះ យ៉ាងណា ការចោទសួរប្រស្នារបស់លោកដ៏មានអាយុនេះ យ៉ាងណា លោកដ៏មានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ព្រោះថា ដោយសេចក្តីពិត លោកដ៏មានអាយុនេះ មិនសំដែងនូវអត្ថ និងបទ ដ៏ជ្រាលជ្រៅ ដ៏ស្អាត ឧត្តម បុគ្គលមិនគប្បីស្ទង់ប្រមើលដោយការត្រិះរិះ ជាធម៌ល្អិត មានតែបណ្ឌិតទើបដឹងបាន មួយទៀត លោកដ៏មានអាយុនេះ ពោលនូវធម៌ឯណា មិនអាចនឹងប្រាប់ សំដែង បញ្ញត្ត តែងតាំង បើកចំហ ចែករំលែក ធ្វើឲ្យរាក់ឡើងនូវសេចក្តីអធិប្បាយនៃធម៌នោះ ដោយសង្ខេប ឬដោយពិស្តារឡើយ លោក

ដ៏មានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានចក្ខុ ឈរក្បែរមាត់ប្រាំងនៃអន្លង់ទឹក គប្បីឃើញត្រីតូចកំពុងងើបឡើង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ការងើបឡើងនៃត្រីនេះយ៉ាងណា មួយទៀត ការពន្លៀកនៃត្រីនេះយ៉ាងណា សម្ទុះនៃត្រីនេះយ៉ាងណា ត្រីនេះជាត្រីតូច ត្រីនេះមិនមែនជាត្រីធំទេ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា រមែងដឹងច្បាស់យ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នា របស់លោកដ៏មានអាយុនេះយ៉ាងណា ។បេ។ លោកដ៏មានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលក្នុងលោកនេះកាលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា រមែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រាជ្ញារបស់លោកដ៏មានអាយុនេះយ៉ាងណា មួយទៀត អភិនីហារនៃលោកដ៏មានអាយុនេះយ៉ាងណា កាលចោទសួរនូវប្រស្នានៃលោកដ៏មានអាយុនេះយ៉ាងណា លោកដ៏មានអាយុនេះ ជាអ្នកមានប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា ដោយសេចក្តីពិត លោកដ៏មានអាយុនេះ តែងសម្តែងនូវអត្ថ និងបទ ដ៏ជ្រៅ ដ៏ស្ងាត ឧត្តម បុគ្គលមិនគប្បីស្ទង់ប្រមើលដោយការត្រិះរិះ ជាធម៌ល្អិត មានតែបណ្ឌិតទើបដឹងបាន លោកដ៏មានអាយុនេះ ពោលនូវធម៌

ណា ក៏អាចនឹងប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើកចំហ ចែករំលែក ធ្វើឲ្យរាក់នូវសេចក្តីអធិប្បាយនៃធម៌នោះ ដោយសេចក្តីសង្ខេប ឬដោយសេចក្តីពិស្តារបាន លោកដ៏មានអាយុនេះ ជាអ្នកមានប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានចក្ខុ ឈរក្បែរមាត់ច្រាំងនៃអន្លង់ទឹក គប្បីឃើញត្រីធំដែលកំពុងងើបឡើង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ការងើបឡើងរបស់ត្រីនេះយ៉ាងនេះយ៉ាងណា មួយទៀត ការពន្លៀកនៃត្រីនេះយ៉ាងណា សម្ទុះនៃត្រីនេះយ៉ាងណា ត្រីនេះជាត្រីធំ ត្រីនេះ មិនមែនជាត្រីតូចទេ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកដ៏មានអាយុនេះ យ៉ាងណា ។បេ។ លោកដ៏មានអាយុនេះ ជាអ្នកមានប្រាជ្ញា លោកដ៏មានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ក៏យ៉ាងនោះឯង ។ ពាក្យណា ដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាបុគ្គលដឹងបានដោយការសាកច្ឆា តែប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តឱ្យយូរ មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា មិនគប្បីដឹងបាន ព្រោះការមិនធ្វើទុកក្នុងចិត្ត បុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ នេះ បុគ្គលគប្បីដឹងបានដោយហេតុទាំង ៤ នេះ ។

# អដ្ឋកថា

## ឋានសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ២ ដូចតទៅនេះ បទថា **ឋានានិ** គឺហេតុទាំងឡាយ ។ បទថា **ឋានេហិ** គឺដោយហេតុទាំងឡាយ ។ ការស្អាត ឈ្មោះថា **សោចេយ្យំ** ។ បទថា **សំវសមានោ** ប្រែថា កាលនៅរួមគ្នា ។ បទថា **ន សតតការី ន សតតវុត្តី សីលេសុ** សេចក្តីថា បុគ្គលនេះមានជីវិតរស់នៅដោយសីលជានិច្ច គ្រប់កាលក៏មិនមែន ។ បទថា **សំវោហារមានោ** គឺកាលពោល ។ បទថា **ឯកេន ឯកោ វោហរតិ** សេចក្តីថា បុគ្គលនេះពោលខ្វែងចំពោះខ្វែង ។ បទថា **វោក្កមតិ** គឺពោល ។ បទថា **បុរិមវោហារា បច្ឆិមវោហារំ** គឺបុគ្គលនេះពោលពាក្យក្រោយខុសពីពាក្យមុន ។ អធិប្បាយថា ពាក្យក្រោយ និងពាក្យមុន ពាក្យមុន និងពាក្យក្រោយមិនស៊ីគ្នា ។ ក្នុងបទថា **ញាតិព្យសនេន** ជាដើម គឺវិនាសញាតិ អធិប្បាយថា បាត់បង់នូវញាតិ ។ ក្នុងបទទី ២ ក៏មានន័យនេះឯង ។ ឯក្នុងការកើតរោគ រោគនោះឯង ឈ្មោះថា វិនាស ព្រោះធ្វើការមិនមានរោគឲ្យវិនាសទៅ ។

បទថា **អនុបរិវត្តន្តិ** គឺជាប់តាម ។ ក្នុងបទថា **លាភោ ច** ជាដើម គប្បីនាំន័យទៅយ៉ាងនេះថា លាភរមែងវិលទៅតាមអត្តភាពមួយ ការវិនាសលាភ រមែងវិលទៅតាមអត្តភាពមួយ ។ បទថា **សាកច្ឆាយមានោ** សេចក្តីថា កាលធ្វើការសន្ទនាដោយអំណាចការសួរ និងការឆ្លើយបញ្ហា ។ បទថា

**យថា** *ប្រែថា ដោយអាការណា ។ ឧម្មគ្គនៃបញ្ហា ឈ្មោះថា* **ឧម្មគ្គ** ។ *អភិនីហារនៃចិត្ត ដោយអំណាចការចងបញ្ហា ឈ្មោះថា* **អភិនីហារ** ។ *ការសួរបញ្ហា ឈ្មោះថា* **សមុទាហារ** ។ *បទថា* **សន្តំ** *សេចក្តីថា មិនពោលឲ្យស្ងប់ ព្រោះសត្រូវស្ងប់ ។ បទថា* **បណីតំ** *បានដល់ ដល់នូវភាពប្រសើរ ។ បទថា* **អតក្កាវចរំ** *សេចក្តីថា បុគ្គលនេះមិនពោលដោយប្រការ ដែលអាចកាន់យកបាន ដោយការដៅស្មាន ដោយការគិតស្មាន ។ បទថា* **និបុណំ** *ប្រែថា ល្អិត ។ បទថា* **បណ្ឌិតវេទនីយំ** *ប្រែថា ដែលពួកបណ្ឌិតគប្បីដឹងបាន ។ បទដ៏សេស ក្នុងទីគ្រប់អន្លើ គប្បីជ្រាបដោយទំនងដែលពោលហើយនោះឯង ។*

**អដ្ឋកថា ឋានសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ភទ្ទិយសូត្រទី ៣

[ ៤៣ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯង ស្តេចលិច្ឆវី ព្រះនាមភទ្ទិយៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយ*

បង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ កាលស្តេចភទ្ទិយលិច្ឆវី គង់ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ជាអ្នកមានកិច្ចកល បេះនូវកិច្ចកលសម្រាប់បោកប្រាស់ តែងបោកប្រាស់ពួកសាវករបស់អន្យតិរ្ថិយ ។ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណា បាននិយាយយ៉ាងនេះថា ព្រះសមណគោតម ព្រះអង្គជាអ្នកមានកិច្ចកល បេះនូវកិច្ចកលសម្រាប់បោកប្រាស់ តែងបោកប្រាស់ពួកសាវក របស់អន្យតិរ្ថិយទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយនោះ ឈ្មោះថា ពោលពាក្យតាមព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ មិនមែនពោលបង្កាច់ ព្រះដ៏មានព្រះភាគ ដោយពាក្យមិនពិតផង ពោលនូវធម៌ដ៏សមគួរដល់ធម៌ផង ការប្រព្រឹត្តទៅតាមវាទៈ ដែលប្រកបដោយធម៌ឯណានីមួយ ក៏មិនដល់នូវហេតុដែលគួរតិះដៀលផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា យើងខ្ញុំព្រះអង្គ មិនមែនជាអ្នកចង់ពោលបង្កាច់ ព្រះដ៏មានព្រះភាគទេ ។ ម្នាលភទ្ទិយៈ អ្នកចូរមក អ្នកចូរកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយសេចក្តីត្រិះរិះតាមអាការ កុំជឿប្រកាន់ដោយឃើញសមនឹងយោបល់ កុំជឿប្រកាន់ចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថាសមណៈជាគ្រូនៃយើង ។ ម្នាលភទ្ទិយៈ អ្នកគប្បីដឹងដោយខ្លួនឯងថា ធម៌ទាំងនេះ

ជាអកុសល ធម៌ទាំងនេះ ប្រកបដោយទោស ធម៌ទាំងនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខដូច្នេះក្នុងកាលណា ម្នាលកទ្ទិយៈ អ្នកគប្បីលះបង់ក្នុងកាលនោះចុះ ។ ម្នាលកទ្ទិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ។ កាលសេចក្តីលោភកើតឡើង ក្នុងសន្តានខៃបុរសកើតឡើង ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនជាប្រយោជន៍ទេ ។ ម្នាលកទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកល្មោភ ដែលលោភៈគ្របសង្កត់ហើយ មានចិត្តដែលលោភៈរួបរឹតហើយ តែងសម្លាប់នូវសត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងកិរិយាអ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ បបួលអ្នកដទៃដោយអំពើនោះខ្លះ ដែលឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខអស់កាលជាយូរអង្វែងមែនឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មែនហើយ ។ ម្នាលកទ្ទិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ទោសៈ ... មោហៈ ... ការប្រណាំងប្រជែងកាលកើតឡើងខាងក្នុងសន្តានចិត្តរបស់បុរស រមែងកើតឡើង ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនជាប្រយោជន៍ទេ ។ ម្នាលកទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកប្រណាំងប្រជែងដែលការប្រណាំងប្រជែងគ្របសង្កត់ហើយ មានចិត្តដែលការប្រណាំងប្រជែងរួបរឹតហើយ តែងសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ

ប្រព្រឹត្តខុសក្នុងកិរិយារបស់បុគ្គលដទៃខ្លះ ពោលពាក្យកុហកខ្លះ បបួលអ្នកដទៃដោយអំពើនោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្ដីទុក្ខ អស់កាលជាយូរអង្វែងមែនឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មែនហើយ ។ ម្នាលកាលាមៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច ធម៌ទាំងនេះ ជាកុសល ឬជាអកុសល ។ បពិត្រព្រះអង្គដ៏ចម្រើន ជាអកុសល ។ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រកបដោយទោស ។ វិញ្ញូជនតិះដៀល ឬវិញ្ញូជនសរសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញូជនតិះដៀល ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ និងសេចក្ដីទុក្ខ ឬមួយពុំមែនទេ ឬក៏ក្នុងដំណើរនុ៎ះ មានប្រការដូចម្ដេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្ដីទុក្ខ ក្នុងដំណើរនុ៎ះ យើងខ្ញុំព្រះអង្គយល់យ៉ាងនេះ ។ ម្នាលកាលាមៈ យើងបានពោលពាក្យណា ដូច្នេះថា ម្នាលកាលាមៈ អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗគ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយត្រិះរិះគ្មាន កុំជឿប្រកាន់ដោយការទឹកស្មាន កុំជឿប្រកាន់ដោយត្រិះរិះតាមអាការ កុំជឿប្រកាន់ដោយការយល់ត្រូវនឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈ

ជាគ្រូរបស់យើង ។ ម្នាលកាលាមៈ ក្នុងកាលណា អ្នកគប្បីដឹងដោយខ្លួនឯងពិតៗ ថា ធម៌ទាំងនេះ ជាអកុសល ធម៌ទាំងនេះ ប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនតិះដៀល ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខ ម្នាលកាលាមៈ ក្នុងកាលនោះ អ្នកត្រូវលះបង់ចេញ ពាក្យណាដែលតថាគតបានពោលទុកហើយ ដូច្នេះ ពាក្យដែលតថាគតពោលទុកហើយនោះ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលកាលាមៈ ចូរអ្នកមក អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងគម្ពីរ កុំជឿប្រកាន់ដោយត្តេកគ្នាន់ កុំជឿប្រកាន់ដោយការទឹកស្មាន កុំជឿប្រកាន់ដោយត្រិះរិះតាមអាការ កុំជឿប្រកាន់ដោយការយល់ត្រូវនឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូរបស់យើង ។ ម្នាលកាលាមៈ ក្នុងកាលណា អ្នកគប្បីដឹងដោយខ្លួនឯងពិតៗ ថា ធម៌ទាំងនេះ ជាកុសល ធម៌ទាំងនេះ មិនប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ម្នាលកាលាមៈ ក្នុងកាលនោះ អ្នកគប្បីសម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ចុះ ។ ម្នាលកាលាមៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អលោភៈ កាលកើតឡើង ខាងក្នុងសន្តាន

ចិត្តរបស់បុរស រមែងកើតឡើងដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាប្រយោជន៍មែន ។ ម្នាលកទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកមិនល្មោភ មិនត្រូវលោភៈគ្របសង្កត់ហើយ មានចិត្តដែលលោភៈមិនរួបរឹតហើយ រមែងមិនសម្លាប់សត្វ មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ មិនប្រព្រឹត្តខុសក្នុងកិរិយារបស់បុគ្គលដទៃ មិននិយាយកុហក ទាំងបបួលបុគ្គលដទៃ ដើម្បីអំពើនោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ អស់កាលជាយូរអង្វែងឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលកទ្ទិយៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អទោសៈ ... អមោហៈ ... សេចក្ដីមិនប្រណាំងប្រជែង កាលកើតឡើងខាងក្នុងសន្ដានចិត្តរបស់បុរស រមែងកើតឡើង ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាប្រយោជន៍មែន ។ ម្នាលកទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកមិនមានសេចក្ដីប្រណាំងប្រជែង មិនត្រូវសេចក្ដីប្រណាំងប្រជែងគ្របសង្កត់ហើយ មានចិត្តដែលសេចក្ដីប្រណាំងប្រជែងមិនរួបរឹតហើយ រមែងមិនសម្លាប់សត្វ មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ មិនប្រព្រឹត្តខុសក្នុងកិរិយារបស់បុគ្គលដទៃ មិននិយាយកុហក ទាំងបបួលបុគ្គលដទៃ ដើម្បីអំពើនោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខអស់កាលជាយូរអង្វែង ។បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលកទ្ទិយៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច ធម៌ទាំងនេះ ជាកុសល ឬជា

អកុសល ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ជាកុសល ។ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនប្រកបដោយទោសទេ ។ វិញ្ញូជនតិះដៀល ឬវិញ្ញូជនសរសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញូជនសរសើរ ។ ធម៌ទាំងឡាយ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ឬមិនមែនទេ ឬមួយក្នុងដំណើរនុ៎ះ មានប្រការដូចម្ដេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ក្នុងដំណើរនុ៎ះ យើងខ្ញុំព្រះអង្គយល់យ៉ាងនេះ ។ ម្នាលភទ្ទិយៈ យើងបានពោលពាក្យណា ដូច្នេះថា ម្នាលភទ្ទិយៈ ក្នុងដំណើរនុ៎ះ អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយត្តេរគ្នាន់ កុំជឿប្រកាន់ដោយការនឹកស្មាន កុំជឿប្រកាន់ដោយត្រិះរិះតាមអាការ កុំជឿប្រកាន់ដោយការយល់ត្រូវនឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូរបស់យើង ។ ម្នាលភទ្ទិយៈ ក្នុងកាលណា អ្នកត្រូវដឹងដោយខ្លួនឯងពិតៗ ថា ធម៌ទាំងនេះ ជាកុសល ធម៌ទាំងនេះ មិនប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍

និងសេចក្ដីសុខ ម្នាលកាលាមៈ អ្នកគប្បីចូលទៅសម្រេចសម្រាន្ត ក្នុងកាល នោះចុះ ពាក្យណា ដែលតថាគតពោលទុកហើយ ដូច្នេះ ពាក្យដែល តថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យសេចក្ដីនេះឯង ។ ម្នាលកាលាមៈ សប្បុរសទាំងឡាយណា ដែលជាអ្នកស្ងប់រម្ងាប់ក្នុងលោក សប្បុរសទាំង នោះ តែងបបួលសាវកយ៉ាងនោះថា ម្នាលបុរសដ៏ចម្រើន អ្នកចូរមកនេះ អ្នកចូរបន្ទោបង់ កម្ចាត់បង់នូវលោភៈ ហើយសម្រេចសម្រាន្ត កាលអ្នក បន្ទោបង់ កម្ចាត់បង់នូវលោភៈបានហើយ នឹងមិនធ្វើកម្ម ដែលកើតអំពី លោភៈ ដោយកាយវាចាចិត្តឡើយ ចូរអ្នកបន្ទោបង់ កម្ចាត់បង់នូវទោសៈ ហើយសម្រេចសម្រាន្តនៅ កាលអ្នកបន្ទោបង់ កម្ចាត់បង់នូវទោសៈហើយ នឹងមិនធ្វើកម្ម ដែលកើតអំពីទោសៈ ដោយកាយវាចាចិត្តឡើយ ចូរអ្នកបន្ទោ បង់ កម្ចាត់បង់នូវមោហៈហើយ សម្រេចសម្រាន្តនៅ កាលបើអ្នកបន្ទោបង់ កម្ចាត់បង់នូវមោហៈហើយ នឹងមិនធ្វើកម្មដែលកើតអំពីមោហៈ ដោយកាយ វាចាចិត្តឡើយ អ្នកចូរបន្ទោបង់ កម្ចាត់បង់នូវសេចក្ដីប្រណាំងប្រជែងហើយ សម្រេចសម្រាន្តនៅ កាលអ្នកបន្ទោបង់ កម្ចាត់បង់នូវសេចក្ដីប្រណាំងប្រជែង ហើយនឹងមិនធ្វើកម្ម ដែលកើតអំពីសេចក្ដីប្រណាំងប្រជែង ដោយកាយវាចា ចិត្តឡើយ ។ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ស្ដេចកាលាមលិច្ឆវី ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះ អង្គដ៏ចម្រើន ពីរោះណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មាន

ព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនោះទៅ ។ ម្នាលកទ្ទិយៈ តថាគតបានពោលយ៉ាងនេះដល់អ្នកថា ម្នាលកទ្ទិយៈ អ្នកចូរចូលមក អ្នកចូរជាសាវ័ករបស់តថាគតចុះ តថាគតនឹងជាគ្រូរបស់អ្នកដូច្នេះខ្លះដែរឬ ។ មិនមែនដូច្នោះទេព្រះអង្គ ។ ម្នាលកទ្ទិយៈ សមណៈ និងព្រាហ្មណ៍ពួកមួយ ពោលពាក្យបង្កាច់តថាគត ដែលជាអ្នកមានវាទៈយ៉ាងនេះ បានពោលទុកយ៉ាងនេះដោយពាក្យមិនពិត ជាពាក្យទទេ ជាពាក្យកុហក ជាពាក្យមិនមែនថា ព្រះសមណគោតម ជាអ្នកមានកិច្ចកល ចេះនូវកិច្ចកលជាគ្រឿងបោកប្រាស់តែងបោកប្រាស់ពួកសាវ័ក របស់អន្យតិរ្ថិយទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន កិច្ចកលជាគ្រឿងបោកប្រាស់ជាកិច្ចកលដ៏ប្រសើរ បពិត្រព្រះអង្គដ៏ចម្រើន កិច្ចកលជាគ្រឿងបោកប្រាស់ ( នេះ ) ជាកិច្ចដ៏ល្អ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកញាតិ និងសាលោហិត ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គត្រូវចាញ់បោកដោយកលជាគ្រឿងបោកប្រាស់នេះ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកញាតិ និងសាលោហិត ដែលជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើក្សត្រទាំងពួង ត្រូវចាញ់បោក ដោយកលជាគ្រឿងបោកប្រាស់នេះ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកក្សត្រទាំងពួង អស់កាលជាយូរអង្វែង ។

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ... ពួកវេស្សៈ ... ពួកសុទ្ទៈ ត្រូវចាញ់បោកដោយកលជាគ្រឿងបោកប្រាស់នេះ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលកទ្ទិយៈ ពាក្យនុ៎ះ ពិតយ៉ាងនេះមែន ម្នាលកទ្ទិយៈ ពាក្យនុ៎ះពិតយ៉ាងនេះមែន ។ ម្នាលកទ្ទិយៈ ប្រសិនបើក្សត្រទាំងពួង ត្រូវចាញ់បោក ដើម្បីឲ្យលះបង់អកុសលធម៌ នឹងបំពេញកុសលធម៌ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកក្សត្រទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលកទ្ទិយៈ ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ... ពួកវេស្សៈ ... ពួកសុទ្ទៈត្រូវចាញ់បោក ដើម្បីឲ្យលះបង់នូវអកុសលធម៌ និងបំពេញកុសលធម៌ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសត្វលោក ព្រមទាំងទេវ-លោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ត្រូវចាញ់បោក ដើម្បីឲ្យលះបង់នូវអកុសលធម៌ នឹងបំពេញកុសលធម៌ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ដល់សត្វលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលជាយូរអង្វែង ។ ម្នាល

កទ្ទិយៈ ប្រសិនបើដើមសាលព្រឹក្សធំៗ ទាំងនេះ ត្រូវចាញ់បោកប្រាស់ ដោយកលជាគ្រឿងបោកប្រាស់នេះ ដើម្បីឲ្យលះបង់នូវអកុសលធម៌ នឹងបំពេញកុសលធម៌ ( អំពើនោះ ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកដើមសាលព្រឹក្សធំៗ ទាំងនេះ អស់កាលជាយូរអង្វែង ប្រសិនបើដើមសាលព្រឹក្សទាំងនោះ ចេះត្រិះរិះ នឹងបាច់និយាយទៅថ្វីដល់សត្វដែលជាមនុស្ស ។

# អដ្ឋកថា

## កទ្ទិយសូត្រ

[ ៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកទ្ទិយសូត្រទី ៣ ដូចតទៅនេះ បទថា **ឧបសង្កមិ** សេចក្តីថា ស្តេចលិច្ឆវីសោយអាហារព្រឹកស្រេចហើយ កាន់យកផ្កា គ្រឿងក្រអូប និងគ្រឿងលាប ចូលទៅគាល់ ដោយគិតថា អញនឹងថ្វាយបង្គំព្រះមានព្រះភាគ ដូច្នេះ ។ ក្នុងបទថា **មា អនុស្សវេន** ជាដើម គប្បីជ្រាបអត្ថដោយន័យនេះថា អ្នកទាំងឡាយ កុំកាន់យកពាក្យរបស់តថាគត ដោយអំណាចការស្តាប់តាមគ្នាមក ។ បទថា **សារម្ភោ** បានដល់ការគិតប្រណាំងប្រជែងគ្នា ជាលក្ខណៈប្រជែងគ្នាច្រើនជាងហេតុ ។ ធម៌មានអលោភៈជាដើម គប្បីជ្រាបដោយន័យដែលផ្ទុយគ្នានឹងលោភៈជាដើម ។

បទថា **កុសលធម្មូបសម្បទាយ** បានដល់ ដើម្បីបំពេញកុសលធម៌ឲ្យដល់ព្រម លោកអធិប្បាយថា ដើម្បីឲ្យបានកុសលធម៌ ។ បទថា **ឥមេ ចេបិ ភទ្ទិយ មហាសាលា** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់បង្ហាញដើមសាលៈដែលដុះខាងមុខ ទើបត្រាស់យ៉ាងនេះ ។ បទដ៏សេស ក្នុងសូត្រនេះ គប្បីដឹងបានងាយ ព្រោះមានន័យដូចពោលហើយខាងដើម និងព្រោះមានអត្ថងាយ ។ តែកាលព្រះសាស្តាទ្រង់ជាស់ស្មារតីស្តេចភទ្ទិយៈ ដោយទេសនាទ្រង់ក៏បានជាសោតាបន្នបុគ្គល ។៚

**អដ្ឋកថា ភទ្ទិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សាបុគិយសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងនិគម ឈ្មោះសាបុគ របស់ពួកកោឡិយជន ក្នុងដែនកោឡិយៈ ។ គ្រានោះឯង ពួកកោឡិយបុត្ត អ្នកសាបុគនិគមជាច្រើន ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកកោឡិយបុត្ត អ្នកសាបុគនិគម អង្គុយក្នុងទីសមគួរហើយ

ទើបព្រះអានន្ទដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនេះ មាន ៤ ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកហើយដោយល្អ ដើម្បីសេចក្តីបរិសុទ្ធដល់ពួកសត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវញេយ្យធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធមាន ៤ តើដូចម្តេច ។ គឺអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីល ១ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត ១ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិ ១ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃវិមុត្តិ ១ ។ ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីល តើដូចម្តេច ។ ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ បានសមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយថា អាត្មាអញនឹងធ្វើសីលបារិសុទ្ធិ មានសភាពយ៉ាងនេះ ដែលមិនទាន់ពេញលេញឲ្យពេញលេញក្តី និងអនុគ្រោះនូវសីលបារិសុទ្ធិ ដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃសីល ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តី

ឯណា ដែលមានក្នុងការអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីល ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ដោយគិតថា អាត្មាអញនឹងធ្វើចិត្តបារិសុទ្ធិ មានសភាពយ៉ាងនេះ ដែលមិនទាន់ពេញលេញ ឲ្យពេញលេញឡើងក្តី និងអនុគ្រោះនូវចិត្តបារិសុទ្ធិ ដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃចិត្ត ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តីឯណា ដែលមានក្នុងការអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិ តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដោយត្រិះរិះដូច្នេះថា អាត្មាអញនឹងធ្វើទិដ្ឋិបារិសុទ្ធិ មានសភាពយ៉ាងនេះ ដែលមិនទាន់ពេញលេញ ឲ្យពេញលេញក្តី និងជួយអនុគ្រោះនូវទិដ្ឋិបារិសុទ្ធិ ដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ

នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃទិដ្ឋិ ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីឧស្សាហ៍ក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តី ឯណា ដែលមាននៅក្នុងការអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិ ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃវិមុត្តិ តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ អរិយសាវកនោះ ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីលនេះផង ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្តនេះផង ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិនេះផង ទើបធ្វើចិត្តឲ្យនឿយណាយក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃតម្រេក ធ្វើចិត្តឲ្យផុតស្រឡះក្នុងធម៌ទាំងឡាយ ដែលគួរឲ្យរួចផុតស្រឡះ ។ លុះអរិយសាវកនោះ ធ្វើចិត្តឲ្យនឿយណាយ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃតម្រេកហើយ ធ្វើចិត្តឲ្យផុតស្រឡះក្នុងធម៌ទាំងឡាយ ដែលគួរឲ្យរួចផុតស្រឡះហើយ ទើបពាល់ត្រូវនូវវិមុត្តិដោយប្រពៃ ដោយត្រិះរិះថា អាត្មាអញនឹងធ្វើវិមុត្តិបារិសុទ្ធិដែលមិនទាន់ពេញលេញ ឲ្យពេញលេញក្តី និងអនុគ្រោះវិមុត្តិបារិសុទ្ធិដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃវិមុត្តិ ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីឧស្សាហ៍ក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តី

ឯណា ដែលមាននៅក្នុងសេចក្តីអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃវិមុត្តិ ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធមាន ៤ នេះ ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកហើយដោយប្រពៃ ដើម្បីសេចក្តីបរិសុទ្ធរបស់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោក និងខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវញាយធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

# អដ្ឋកថា

## សាបុគិយសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាបុគិយសូត្រទី ៤ ដូចតទៅនេះ បទថា **សាបុគិយា** បានដល់ កុលបុត្រអ្នកនិគមសាបុគៈ ។ បទថា **ព្យគ្ឃបជ្ជ** សេចក្តីថា ព្រះអានន្ទកាលហៅកោលិយបុត្រទាំងនោះ ទើបពោលយ៉ាងនេះ កោលនគរមានឈ្មោះ ២ គឺកោលនគរ ព្រោះនាំដើមក្រពៅមកសាង ១ ឈ្មោះព្យគ្ឃបជ្ជៈ ព្រោះគេសាងក្នុងផ្លូវខ្លាធ្លងកាត់ ១ ។ បុព្វបុរសអ្នកកោលិយៈទាំងនោះ អាស្រ័យនៅក្នុងព្យគ្ឃបជ្ជនគរនោះ ព្រោះដូច្នោះ ទើប

លោកហៅថា **ព្យគ្ឃបជ្ជ** ព្រោះអាស្រ័យនៅក្នុងព្យគ្ឃបជ្ជនគរ ។ ដោយហេតុនោះ ព្រះអានន្ទកាលហៅអ្នកកោលិយៈទាំងនោះ ទើបពោលយ៉ាងនេះ ។

បទថា **ចារិសុទ្ធិប្បធានិយង្គានិ** បានដល់ អង្គជាទីតាំងនៃសេចក្តីព្យាយាមដើម្បីភាពបរិសុទ្ធ អធិប្បាយថា អង្គ គឺជាចំណែកនៃសេចក្តីព្យាយាម គួរតាំងទុក ។ បទថា **សីលចារិសុទ្ធិប្បធានិយង្គំ** នេះ ជាឈ្មោះនៃអ្នកមានសេចក្តីព្យាយាម ដែលញ៉ាំងសីលឲ្យបរិសុទ្ធ ។ ពិតហើយ បារិសុទ្ធិប្បធានិយង្គនោះ ជាអង្គ ជាទីតាំងនៃសេចក្តីព្យាយាម ដើម្បីឲ្យនូវភាពបរិសុទ្ធនៃសីលពេញបរិបូណ៌ ព្រោះហេតុនោះ ទើបឈ្មោះថា **សីល-ចារិសុទ្ធិប្បធានិយង្គំ** ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** សេចក្តីថា អាត្មាអញនឹងផ្គងដោយវិបស្សនាក្នុងទីនោះៗ ។ ក្នុងបទថា **យោ តត្ថ ឆន្ទោ** ជាដើម គប្បីជ្រាបដោយន័យនេះថា កត្តុកម្យតាឆន្ទៈ គឺការពេញចិត្ត គឺការប្រាថ្នានឹងធ្វើក្នុងការផ្គងនោះឯណា ។ **សតិសម្បជញ្ញ** លោកពោលក្នុងទីនេះ ដើម្បីកិច្ចចូលទៅតាំងនូវសតិ ហើយកំណត់ដោយញាណ ញ៉ាំងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ ។ បទថា **រជនីយេសុ ធម្មេសុ ចិត្តំ វិរាជេតិ** សេចក្តីថា រមែងធ្វើដោយអាការដែលចិត្តប្រាសចាកតម្រេក ក្នុងឥដ្ឋារម្មណ៍ដែលជាបច្ច័យនៃរាគៈ ។ បទថា **វិមោចនីយេសុ ធម្មេសុ ចិត្តំ វិមោចេតិ** សេចក្តីថា រមែងធ្វើដោយអាការដែលចិត្តដោះទៅអំពីអារម្មណ៍ ដែលចិត្តគួរដោះ ។ ក្នុង

បទថា **វិរាជេត្វា** នេះ ឈ្មោះថា ប្រាសចាកតម្រេកក្នុងខណៈនៃមគ្គ ឈ្មោះថា ប្រាសចាកតម្រេកហើយ ក្នុងខណៈនៃផល ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ បទថា **សម្មាវិមុត្តឹ ផុសតិ** បានដល់ ពាល់ត្រូវអរហត្តផលវិមុត្តិតាមហេតុ តាមន័យដោយញាណផស្សៈ ។

**អដ្ឋកថា សាបុគិយសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## វប្បសូត្រទី ៥

[ ៤៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ គ្រានោះ វប្បសក្យជាសាវកនិគ្រន្ថ បានចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះវប្បសក្យៈ ជាសាវករបស់និគ្រន្ថ អង្គុយក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលដូច្នេះថា ម្នាលវប្បៈ បុគ្គលក្នុងលោកនេះគប្បីសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃអវិជ្ជា អាសវៈទាំងឡាយ ដែលជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរសក្នុងលោកខាងមុខបាន ព្រោះហេតុឯណា

ម្នាលវប្បៈ ចុះអ្នកឃើញហេតុនោះដែរឬទេ ។ បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណាឃើញនូវហេតុនោះដែរ បពិត្រព្រះថេរៈដ៏ចម្រើន បាបកម្មដែលបុគ្គលធ្វើក្នុងកាលពីដើម ជាវិបាកដែលមិនទាន់ឲ្យផល ក្នុងលោកនេះទេ ព្រោះហេតុនោះ បានជាអាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ។ ការនិយាយជាមួយនឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានឈប់ផ្អាកត្រឹមប៉ុណ្ណេះ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ស្ដេចចេញចាកផលសមាបត្តិក្នុងវេលាសាយណ្ហសម័យ ទើបស្ដេចទៅកាន់ឧបដ្ឋានសាលា លុះស្ដេចទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់រួចហើយ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះមហាមោគ្គល្លានដ៏មានអាយុ ដូច្នេះថា ម្នាលមោគ្គល្លាន អ្នកអង្គុយប្រជុំនិយាយគ្នាដោយរឿងអ្វី អម្បាញ់មិញនេះ ចុះអន្តរាកថា ( ពាក្យជាចន្លោះ ) ដូចម្ដេច ដែលអ្នកពោលផ្អាកទុក ។ បពិត្រព្រះអង្គដ៏ចម្រើន នៅទីនេះ ខ្ញុំព្រះអង្គបានពោលពាក្យនេះ នឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថថា ម្នាលវប្បៈ បុគ្គលក្នុងលោកនេះ គប្បីសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃអវិជ្ជា អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំ

ព្រះអង្គពោលយ៉ាងនេះហើយ វប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ បានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណាមែនឃើញនូវហេតុនោះដែរ បពិត្រព្រះថេរៈដ៏ចម្រើន បាបកម្មដែលបុគ្គលធ្វើក្នុងកាលពីមុន ជាវិបាកដែលមិនទាន់ឲ្យផល ក្នុងលោកនេះ ព្រោះហេតុនោះ បានជាអាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរសក្នុងលោកខាងមុខបាន បពិត្រព្រះអង្គដ៏ចម្រើន នេះគឺការនិយាយជាមួយនឹងវប្បសក្យៈជាសាវ័ករបស់និគ្រន្ថ ដែលយើងខ្ញុំព្រះអង្គបានពោលផ្អាកទុក ក៏ស្រាប់តែព្រះដ៏មានព្រះភាគ ស្តេចមកដល់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថដូច្នេះថា ម្នាលវប្បៈ ប្រសិនបើអ្នកយល់ព្រមចំពោះពាក្យ ដែលគួរយល់ព្រមតាមផង គួរហាមឃាត់ចំពោះពាក្យ ដែលគួរហាមឃាត់ផង មួយទៀត អ្នកមិនទាន់ដឹងនូវសេចក្តីអធិប្បាយនៃភាសិតណារបស់តថាគត គួរអ្នកសាកសួរនឹងតថាគត ក្នុងសេចក្តីអធិប្បាយនៃសុភាសិតនោះតទៅទៀតចុះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះ ដូចម្តេច ។ ការសន្ទនានៃយើងខ្ញុំព្រះអង្គ គប្បីមានក្នុងដំណើរនុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងយល់ព្រមតាមចំពោះពាក្យ ដែលគួរយល់ព្រមតាមផង នឹងហាមឃាត់ចំពោះពាក្យដែលគួរហាមឃាត់ផង មួយទៀត ខ្ញុំព្រះអង្គមិនទាន់ដឹងនូវសេចក្តីអធិប្បាយនៃភាសិតណា របស់ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គនឹងទូល

សាកសួរចំពោះព្រះដ៏មានព្រះភាគ ក្នុងសេចក្តីអធិប្បាយនៃភាសិតនោះតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះដូចម្តេច ។ ការសន្ទនានៃយើងខ្ញុំព្រះអង្គ ចូរមានក្នុងជំណើរនុ៎ះ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្តៅក្រហាយ រមែងកើតឡើង ព្រោះកាយកម្មជាបច្ច័យ អាសវៈទាំងឡាយ ដែលប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ រមែងមិនមានដល់បុគ្គល ដែលវៀរស្រឡះចាកកាយកម្ម បុគ្គលនោះ រមែងមិនធ្វើនូវកម្មថ្មីផង នូវកម្មចាស់ផង លុះពាល់ត្រូវ ( នូវកម្ម ) ហើយ រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅអ្នកផងចូលមកមើល គួរបង្អោនទុកក្នុងខ្លួន ពួកអ្នកប្រាជ្ញគប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្តីនុ៎ះដូចម្តេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្តៅក្រហាយ រមែងកើតឡើង ព្រោះវចីកម្មជាបច្ច័យ អាសវៈដែលប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ រមែងមិនមានដល់បុគ្គលដែលវៀរចាកវចីកម្មយ៉ាងនេះឡើយ បុគ្គលនោះ មិនធ្វើនូវកម្មថ្មីផង នូវកម្មចាស់ផង លុះពាល់ត្រូវ ( នូវកម្ម ) ហើយ

រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅឲ្យអ្នកផងចូលមកមើលបាន គួរបង្អោនទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរសក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្ដៅក្រហាយ រមែងកើតឡើង ព្រោះមនោកម្មជាបច្ច័យ អាសវៈទាំងឡាយប្រកបដោយទុក្ខ ក្ដៅក្រហាយទាំងនោះ រមែងមិនមានដល់បុគ្គលដែលវៀរចាកមនោកម្មយ៉ាងនេះឡើយ បុគ្គលនោះ ក៏មិនធ្វើកម្មថ្មីផង កម្មចាស់ផង លុះពាល់ត្រូវ ( នូវកម្ម ) ហើយ រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅឲ្យអ្នកផងចូលមកមើលបាន គួរបង្អោនមកទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំង-ឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អាសវៈទាំងឡាយ ដែលប្រកបដោយទុក្ខ ក្ដៅក្រហាយ

រមែងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ អាសវៈទាំងឡាយ ប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ រមែងមិនមាន ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃវិជ្ជាយ៉ាងនេះ បុរសនោះក៏មិនធ្វើកម្មថ្មីផង កម្មចាស់ផង លុះពាល់ត្រូវ ( នូវកម្ម ) ហើយ រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅអ្នកផងឲ្យចូលមកមើលបាន គួរបង្អោនមកទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខ-វេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ ភិក្ខុដែលមានចិត្តផុតស្រឡះហើយ ដោយប្រពៃយ៉ាងនេះ តែងបានសម្រេចនូវធម៌ ៦ ប្រការជាគ្រឿងនៅរឿយៗ ភិក្ខុនោះបានឃើញរូបដោយចក្ខុ ក៏មិនជាសោមនស្ស មិនជាទោមនស្សឡើយ តែងព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន ឮសំឡេងដោយត្រចៀកហើយ ... ធុំក្លិនដោយច្រមុះហើយ ... ជញ្ជាប់រសដោយអណ្តាតហើយ ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយហើយ ... ដឹងធម្មារម្មណ៍ដោយចិត្តហើយ ក៏ជាអ្នកមិនសោមនស្ស មិនទោមនស្សឡើយ តែងនៅព្រងើយកន្តើយ មានស្មារតីដឹងខ្លួន ។ ភិក្ខុនោះ កាលទទួលវេទនា កំណត់ដោយកាយ តែងដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយកាយ កាលទទួលវេទនាកំណត់ដោយ

ជីវិត តែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាកំណត់ដោយជីវិត លុះបែក ធ្លាយរាងកាយ បន្ទាប់អំពីការអស់ជីវិតទៅ ក៏ដឹងច្បាស់ថា កាលទទួល អារម្មណ៍ទាំងអស់ ដែលអាត្មាអញមិនបានត្រេកអរក្នុងលោកនេះ នឹងមាន សេចក្តីត្រជាក់ទៅខាងមុខ ។ ម្នាលវប្បៈ ប្រៀបដូចប្រមោលមានប្រាកដ ព្រោះអាស្រ័យដើមឈើ កាលនោះ មានបុរសកាន់ចប និងកញ្ជើដើរមក បុរសនោះ ក៏កាប់ដើមឈើនោះត្រង់គល់ លុះកាប់គល់ហើយ ក៏ជីកគាស់ លុះជីកគាស់ហើយ ក៏រម្ងើងឫសគល់ ដោយហោចទៅ សូម្បីប៉ុនចម្រៀក ស្បូវក្លាំង ( ក៏មិនឲ្យសល់ ) បុរសនោះក៏កាត់ដើមឈើនោះ ឲ្យជាកំណាត់ តូចធំ លុះកាត់ឲ្យជាកំណាត់តូចធំបានហើយ ក៏ពុះ លុះពុះហើយ ក៏ធ្វើឲ្យជា ចម្រៀកៗ លុះធ្វើឲ្យជាចម្រៀកៗ ហើយ ក៏ហាលសំដិលក្នុងទីមានខ្យល់ និងកម្តៅថ្ងៃ លុះហាលសំដិលក្នុងទីមានខ្យល់ និងកម្តៅថ្ងៃហើយ ក៏ដុត ដោយភ្លើង លុះដុតដោយភ្លើងហើយ ក៏ធ្វើឲ្យជាធ្យូង លុះធ្វើឲ្យជាធ្យូងហើយ ក៏ជះរោយទៅលើខ្យល់ដ៏ខ្លាំង ឬបណ្តែតទៅតាមខ្សែទឹក ដែលហូរខ្លាំងក្នុង ទន្លេ ម្នាលវប្បៈ ស្រមោលឯណា ដែលអាស្រ័យនឹងដើមឈើ ស្រមោល នោះ មានឫសគល់ដាច់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតចុង ធ្វើមិនឲ្យមានបែប ភាព មានកិរិយាមិនកើតឡើងតទៅទៀតជាធម្មតា មានឧបមាយ៉ាងណា ។ ម្នាលវប្បៈ ភិក្ខុដែលមានចិត្តផុតស្រឡះហើយ ដោយប្រពៃយ៉ាងនេះ តែង បានសម្រេចធម៌ ៦ ប្រការ ជាគ្រឿងនៅរឿយៗ ក៏មានឧបមេយ្យដូច្នោះដែរ ។

ភិក្ខុនោះបានឃើញរូបដោយចក្ខុហើយ ក៏មិនជាសោមនស្ស មិនជាទោម-នស្ស រមែងនៅព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន ឮសំឡេងដោយត្រចៀកហើយ ... ធុំក្លិនដោយច្រមុះហើយ ... ជញ្ជាប់រសដោយអណ្តាតហើយ ... ពាល់ត្រូវផោដ្ឋព្វដោយកាយហើយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ មិនជាសោមនស្ស មិនទោមនស្សឡើយ តែងនៅព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន ។ ភិក្ខុនោះ កាលទទួលវេទនា កំណត់ដោយកាយ ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយកាយ កាលទទួលវេទនា កំណត់ដោយជីវិត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយជីវិត លុះបែកធ្លាយរាងកាយ បន្ទាប់អំពីការអស់ទៅនៃជីវិត ក៏ដឹងច្បាស់ថា ការទទួលអារម្មណ៍ទាំងពួង ដែលអាត្មាអញមិនបានត្រេកអរហើយក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ទៅខាងមុខ ។ កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ វប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុរសមានសេចក្តីត្រូវការ ដោយសេចក្តីចម្រើន ក៏ចិញ្ចឹមកូនសេះ បុរសនោះក៏នៅតែមិនបានសេចក្តីចម្រើន ថែមទាំងបានតែសេចក្តីលំបាក និងសេចក្តីព្រួយលើសឡើងទៅទៀតផង មានឧបមាយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយសេចក្តីចម្រើន ក៏ចូលទៅបម្រើពួកនិគ្រន្ថ ដែលជាមនុស្សល្ងង់ ខ្ញុំព្រះអង្គនោះ ក៏មិនបានទទួលសេចក្តីចម្រើន

ថែមទាំងបានតែសេចក្តីលំបាក សេចក្តីព្រួយលើសឡើងទៅទៀត ក៏មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងអំពីថ្ងៃនេះជាដើមទៅ សេចក្តីជ្រះថ្លារបស់ខ្ញុំព្រះអង្គឯណា ក្នុងពួកនិគ្រន្ថពាល ខ្ញុំព្រះអង្គនឹងជះចោលសេចក្តីជ្រះថ្លានោះទៅតាមខ្យល់ដ៏ខ្លាំង ឬនឹងបណ្តែតសេចក្តីជ្រះថ្លានោះទៅតាមខ្សែទឹកដែលហូរខ្លាំងក្នុងទន្លេ ។ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គក្តីច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គក្តីច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុគ្គល ផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះដូចបុគ្គលទ្រោលប្រទីបបំភ្លឺ ក្នុងទីងងឹត ដោយគិតថា បុរសមានភ្នែកភ្លឺ នឹងមើលឃើញនូវរូបទាំងឡាយបាន យ៉ាងណា ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គ សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងជាទីរឭក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## វប្បសូត្រ

[ ៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវប្បសូត្រទី ៥ ដូចតទៅនេះ បទថា **វប្បោ** បានដល់ សក្យរាជដែលជាព្រះបិតុលារបស់ព្រះទសពល ។ បទថា **និគណ្ឋសាវកោ** បានដល់ ជាឧបដ្ឋាករបស់និគណ្ឋនាដបុត្រ ដូចសីហសេនាបតី ក្នុងក្រុងវេសាលី និងដូចឧបាលិគហបតី ក្នុងក្រុងនាឡន្ទា ។ បទថា **កាយេន សំវុតោ** សេចក្តីថា ឈ្មោះថា សង្រួមដោយកាយ ព្រោះសង្រួម គឺបិទនូវកាយទ្វារ ។ សូម្បីក្នុង ២ បទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា **អវិជ្ជាវិរាគា** បានដល់ ព្រោះអវិជ្ជាប្រាសទៅ ។ បទថា **វិជ្ជុប្បាទា** បានដល់ ព្រោះមគ្គវិជ្ជាកើតឡើង ។ បទថា **តំ ឋានំ** ប្រែថា ហេតុនោះ ។ បទថា **អវិបក្កវិបាកំ** បានដល់ មិនដល់ភាវៈបានទទួលផល ។ បទថា **តតោនិទានំ** បានដល់ មានកម្មនោះជាហេតុ មានបាបកម្មនោះជាបច្ច័យ ។ បទថា **ទុក្ខវេទនីយា អាសវា អស្សវេយ្យុំ** សេចក្តីថា កិលេសទាំងឡាយដែលជាបច្ច័យនៃទុក្ខវេទនា គប្បីហូរទៅតាម គឺគប្បីចូលទៅតាម អធិប្បាយថា កិលេសទាំងឡាយ គប្បីកើតឡើងដល់បុរសនោះ ។ បទថា **អភិសម្ប-រាយំ** បានដល់ ក្នុងអត្តភាពទី ២ នោះឯង ។ បទថា **កាយសមា-រម្ភប្បច្ចយា** ប្រែថា ព្រោះកាយកម្មជាបច្ច័យ ។ បទថា **អាសវា** បានដល់ កិលេសទាំងឡាយ ។ ក្នុងបទថា **វិឃាតបរិឡាហា** នេះ ទុក្ខ ឈ្មោះថា **វិឃាត** ការក្តៅក្រហាយផ្លូវកាយ និងផ្លូវចិត្ត ឈ្មោះថា **បរិឡាហា** ។ បទថា

**ផុស្ស ផុស្ស ព្យន្តីករោតិ** សេចក្តីថា កម្មដែលញាណគប្បីសម្លាប់ លុះប៉ះខ្ទប់ញាណសម្ផស្សក៏អស់ទៅ កម្មដែលវិបាកគប្បីសម្លាប់ លុះប៉ះខ្ទប់វិបាកផស្សៈក៏អស់ទៅ ។ បទថា **និជ្ជរា** បានដល់ បដិបទាដែលធ្វើកិលេសឲ្យទ្រោមទៅ ។ ក្នុងវារៈដ៏សេស ក៏មានន័យនេះដូចគ្នា ។

ភិក្ខុនេះ តាំងនៅក្នុងបដិបទានេះ គួរជាព្រះខីណាស្រព ។ គួរនាំមហាភូតរូប ៤ ចេញ ហើយសម្តែងការកំណត់ដោយអរិយសច្ច ៤ ហើយគប្បីប្រាប់កម្មដ្ឋានរហូតដល់អរហត្តផល ។ ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងសតតវិហារធម៌ គឺធម៌ជាគ្រឿងនៅប្រចាំរបស់ព្រះខីណាស្រពនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវំ សម្មាវិមុត្តចិត្តស្ស** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សម្មាវិមុត្តចិត្តស្ស** បានដល់ ផុតហើយដោយជុំវិញដោយប្រពៃ ដោយហេតុការណ៍ ដោយន័យ ។ បទថា **សតតវិហារា** បានដល់ ធម៌ជាគ្រឿងនៅជានិច្ច ធម៌ជាគ្រឿងនៅប្រចាំ ។ បទថា **នេវ សុមនោ ហោតិ** បានដល់ ជាអ្នកមិនកើតសោមនស្ស ដោយអំណាចការត្រេកត្រអាលក្នុងឥដ្ឋារម្មណ៍ ។ បទថា **ន ទុម្មនោ** បានដល់ មិនជាអ្នកកើតទោមនស្ស ដោយអំណាចការល្អក់កករចិត្ត ក្នុងអនិដ្ឋារម្មណ៍ ។ បទថា **ឧបេក្ខកោ វិហរតិ សតោ សម្បជានោ** បានដល់ ជាអ្នកមានឧបេក្ខា គឺភាពជាកណ្តាលក្នុងអារម្មណ៍ទាំងនោះ ដោយឧបេក្ខា មានអាការ គឺភាពជាកណ្តាលជាលក្ខណៈកំណត់កាន់យក ដោយសតិសម្បជញ្ញៈ ។

បទថា **កាយបរិយន្តិកំ** បានដល់ វេទនា មានកាយជាទីបំផុត គឺកំណត់ដោយកាយ អធិប្បាយថា វេទនាប្រព្រឹត្តទៅក្នុងទ្វារ ៥ នៅប្រព្រឹត្តទៅដរាបស្មើនឹងកាយ គឺទ្វារ ៥ នៅប្រព្រឹត្តទៅ ។ បទថា **ជីវិតបរិយន្តិកំ** បានដល់ វេទនាមានជីវិតជាទីបំផុត គឺកំណត់ដោយជីវិត ។ អធិប្បាយថា វេទនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ដែលប្រព្រឹត្តទៅដរាបស្មើនឹងជីវិតនៅប្រព្រឹត្តទៅ ។ ក្នុងវេទនាទាំងនោះ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ កើតក្រោយ តែរលត់មុន ។ វេទនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ កើតមុន តែរលត់ក្រោយ ។ ព្រោះវេទនានោះ តាំងនៅក្នុងវត្ថុរូបក្នុងបដិសន្ធិក្ខណៈ ។ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ នៅប្រព្រឹត្តទៅដោយអំណាចបញ្ចទ្វារក្នុងបច្ចុប្បន្ន ក្នុងកាលមានអាយុ ២០ ឆ្នាំ ក្នុងបឋមវ័យ នៅមានកម្លាំងរឹងមាំដោយអំណាចសេចក្តីស្រឡាញ់ សេចក្តីក្រោធ និងសេចក្តីវង្វេង លុះមានអាយុ ៥០ នៅមាំទាំនៅឡើយ ចាប់ផ្តើមថយតាំងអំពីអាយុ ៦០ ឆ្នាំ លុះអាយុ ៨០ ឬ ៩០ ឆ្នាំ ក៏ថមថយដល់កម្រិត ដ្បិតថា ក្នុងគ្រានោះ សត្វទាំងឡាយ កាលមានបុគ្គលពោលថា ពួកយើងអង្គុយ ដេក រួមគ្នាមកយូរហើយ ក៏ពោលថា ខ្ញុំមិនដឹង ដូច្នេះក៏មាន ពោលថា ខ្ញុំមិនឃើញអារម្មណ៍មានរូបជាដើម មានប្រមាណច្រើន ខ្ញុំមិនបានឮ ខ្ញុំមិនដឹងក្លិនក្រអូប ក្លិនស្អុយ រសឆ្ងាញ់ រសមិនឆ្ងាញ់ ឬរឹងទន់ ដូច្នេះក៏មាន ។ វេទនាប្រព្រឹត្តទៅក្នុងទ្វារ ៥ នៃសត្វទាំងនោះ សូម្បីរលត់ទៅ តែវេទនាប្រព្រឹត្តទៅក្នុង

មនោទ្វារក៏នៅប្រព្រឹត្តទៅ ដោយប្រការដូច្នេះ ។ វេទនានោះវិនាសទៅដោយលំដាប់ ក្នុងកាលជិតស្លាប់ អាស្រ័យចំណែករបស់ហទយវត្ថុប៉ុណ្ណោះ ដែលនៅប្រព្រឹត្តទៅបាន ។ វេទនានោះនៅប្រព្រឹត្តទៅបានដរាបណា លោកពោលថា សត្វនៅមានជីវិតដរាបនោះ ។ កាលណាវេទនាប្រព្រឹត្តទៅមិនបាន កាលនោះ លោកពោលថា សត្វស្លាប់ហើយ រលត់ហើយ ដូច្នេះ ។ គប្បីប្រៀបសេចក្តីនេះដោយស្រះទឹក ។

ឧបមាដូចបុរសធ្វើស្រះទឹក ឲ្យមានផ្លូវទឹក ៥ ខ្សែ កាលភ្លៀងធ្លាក់ដំបូង គប្បីបង្ហូរទឹកទៅដោយផ្លូវទាំង ៥ ហើយទឹកក៏ដក់ក្នុងអណ្តូងដែលនៅខាងក្នុងស្រះធំ កាលភ្លៀងធ្លាក់រឿយៗ ទឹកក៏ពេញតាមផ្លូវដែលហូរចូលស្រះហើយហៀរ ចេញទៅប្រមាណមួយគាវុត ឬកន្លះយោជន៍ ទឹកក៏នៅដក់ ទឹកកាលហូរចេញអំពីនោះ ត្រូវអ្នកស្រែបើកភ្លឺស្រែ ធ្វើការងារក្នុងស្រែ ទឹកហូរចេញ កាលស្រូវទុំ ទឹកក៏ហូរចេញ ទឹកក៏ខះទៅ អ្នកស្រែក៏ពោលថា អញនឹងចាប់ត្រី បន្ទាប់អំពីនោះ កន្លងទៅ ២-៣ ថ្ងៃ ទឹកក៏ដក់នៅតែក្នុងអណ្តូងប៉ុណ្ណោះ ដរាបណាទឹកនោះនៅមានក្នុងអណ្តូង ដរាបនោះក៏រាប់បានថា ទឹកនៅមានក្នុងស្រះដរាបនោះ កាលណាទឹកក្នុងអណ្តូងនោះខះអស់ កាលនោះក៏ហៅបានថា ទឹកមិនមានក្នុងស្រះ យ៉ាងណា ការឧបមេយ្យ គប្បីជ្រាបដូច្នេះ ។

វេលាដែលវេទនាប្រព្រឹត្តទៅក្នុងមនោទ្វារ តាំងនៅក្នុងវត្ថុរូប ក្នុង

បដិសន្ធិក្ខណៈដំបូង ដូចពេលដែលភ្លៀងធ្លាក់ដំបូង កាលទឹកហូរចូលទៅដោយផ្លូវទាំង ៥ អណ្តូងដែលនៅក្នុងស្រះក៏ពេញ កាលវត្ថុរូបនៅប្រព្រឹត្តទៅ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ក៏ប្រព្រឹត្តទៅបាន ដូចកាលភ្លៀងធ្លាក់រឿយៗ ទឹកពេញផ្លូវទាំង ៥ ការដែលវេទនានោះ មានកម្លាំងដោយអំណាចការស្រឡាញ់ជាដើម គ្រាដែលមានអាយុ ២០ ឆ្នាំ ក្នុងបឋមវ័យ ដូចទឹកដែលហៀរចេញទៅប្រមាណមួយគាវុត និងកន្លះយោជន៍ កាលដែលវេទនានោះនៅមាំទាំនៅឡើយ ក្នុងគ្រាមានអាយុ ៥០ ដូចពេលដែលទឹកដក់នៅពេញក្នុងស្រះ ទល់គ្នានឹងទឹកមិនទាន់ហូរចេញអំពីស្រះនោះ វេទនាវិនាសតាំងអំពីពេលដែលមានអាយុ ៦០ ឆ្នាំ ដូចពេលដែលបើកទំនប់ការពារទឹក កាលធ្វើការងារ ទឹកក៏ហូរចេញ ពេលដែលវេទនាប្រព្រឹត្តទៅក្នុងទ្វារ ៥ ខ្សោយចុះ ក្នុងកាលមានអាយុ ៨០ ឬ ៩០ ឆ្នាំ ដូចកាលដែលទឹកខះ នៅមានទឹកតិចតួចត្រង់ផ្លូវទឹក ពេលដែលវេទនាក្នុងមនោទ្វារនៅប្រព្រឹត្តទៅបាន ព្រោះអាស្រ័យចំណែកនៃហទយវត្ថុ ដូចពេលដែលទឹកដក់នៅក្នុងអណ្តូងនោះឯង ដរាបណាវេទនានោះ នៅប្រព្រឹត្តទៅបាន ដរាបនោះក៏ហៅបានថា សត្វនៅមានជីវិតនៅឡើយ ដូចពេលដែលគួរពោលបានថា កាលក្នុងអណ្តូងមានទឹកតិចតួច ទឹកក្នុងស្រះក៏នៅមាន កាលទឹកក្នុងអណ្តូងខះអស់ ក៏ហៅបានថា មិនមានទឹកក្នុងស្រះ យ៉ាងណា កាលវេទនាប្រព្រឹត្តទៅក្នុងមនោទ្វារប្រព្រឹត្តទៅមិនបាន ក៏ហៅបានថា សត្វស្លាប់ដូច្នោះ ។ បទថា **ជីវិត-**

**បរិយន្តិកំ វេទនំ វេទិយមានោ** លោកពោលសំដៅដល់វេទនានេះឯង ។

បទថា **កាយស្ស ភេទា** បានដល់ កាយបែកធ្លាយ ។ បទថា **ឧទ្ធំ ជីវិតបរិយាទានា** បានដល់ ខាងមុខអំពីជីវិតអស់ទៅ ។ បទថា **ឥធេវ** បានដល់ ក្នុងលោកនេះប៉ុណ្ណោះ មិនទៅខាងមុខ ដោយអំណាចបដិសន្ធិឡើយ ។ បទថា **សីតិ ភវិស្សន្តិ** បានដល់ វេទនាទាំងពួង វៀរចាកការប្រព្រឹត្តទៅ ការអន្ទះអន្ទែង និងការក្រវល់ក្រវាយ ក៏នឹងជារបស់ត្រជាក់ ដែលមានការមិនប្រព្រឹត្តទៅជាធម្មតា ។ បទថា **ថូណំ បដិច្ច** បានដល់ អាស្រ័យដើមឈើ ។ បទថា **កុទ្ទាលបិដកំ អាទាយ** សេចក្តីថា កាន់ចប ចបជីក និងកញ្ជើ តែទេសនា លោកសំដៅយកតែចបប៉ុណ្ណោះ ។ បទថា **មូលេ ឆិន្ទេយ្យ** បានដល់ គប្បីយកចបកាត់ត្រង់គល់ ។ បទថា **បលិ-ខណេយ្យ** បានដល់ យកចបជីក ជីកដោយជុំវិញ ។ ក្នុងពាក្យថា **ឯវមេវ ខោ** នេះ ប្រៀបធៀបដោយឧបមា ដូច្នេះ ។ អត្តភាពគប្បីឃើញដូចដើមឈើ កុសលកម្ម និងអកុសលកម្ម ដូចស្រមោលអាស្រ័យដើមឈើ ព្រះយោគាវចរ ដូចបុរសដែលបំណងនឹងធ្វើស្រមោលមិនឲ្យប្រព្រឹត្តទៅ បញ្ញាដូចចប សមាធិដូចកញ្ជើ វិបស្សនាដូចចបជីក ពេលដែលកាត់អវិជ្ជាដោយអរហត្តមគ្គ ដូចពេលដែលយកចបជីក ជីកត្រង់ឫស ពេលដែលឃើញជាគំនរ ដូចពេលដែលធ្វើឲ្យជាកំណាត់តូចធំ ពេលដែលឃើញជាអាយតនៈ ដូចពេលដែលពុះបំបែកចេញ ពេលដែលឃើញជាធាតុ ដូចពេលដែលធ្វើឲ្យ

ជាលម្អិត ពេលដែលធ្វើសេចក្តីព្យាយាមផ្លូវកាយ ផ្លូវចិត្ត ដូចពេលដែលហាលឲ្យស្ងួត ឲ្យត្រូវខ្យល់ និងកម្តៅថ្ងៃ ពេលដែលដុតកិលេសដោយញាណ ដូចពេលដែលយកភ្លើងដុត ពេលដែលខន្ធ ៥ នៅទ្រទ្រង់នៅឡើយ ដូចពេលដែលធ្វើជាធ្យូង ។ ការរម្ងត់ខន្ធ ៥ ដែលមានឫសដាច់ហើយ ដោយមិនមានបដិសន្ធិ ដូចពេលដែលបាចទៅក្នុងព្យុះធំ ដូចពេលដែលបណ្តែតទៅតាមខ្សែទឹក ការដែលមិនមានបញ្ញត្ត ព្រោះវិបាកក្ខន្ធមិនកើតក្នុងភពថ្មី គប្បីជ្រាបដូចការចូលទៅកាន់ការមិនមានបញ្ញត្ត ដោយបាចសាចទៅនិងបណ្តែតទៅ ។

បទថា **ភគវន្តំ ឯតទវោច** សេចក្តីថា កាលព្រះសាស្តាទ្រង់ជាស់ស្មារតីដោយទេសនា វប្បសក្យរាជសម្រេចសោតាបត្តិផលហើយ បានក្រាបទូលពាក្យជាដើមថា **សេយ្យថាបិ ភន្តេ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឧទយត្ថិកោ** គឺជាបុគ្គលមានសេចក្តីត្រូវការចំណេញ ។ បទថា **អស្ស-បណិយំ បោសេយ្យ** សេចក្តីថា គប្បីចិញ្ចឹម ដោយគិតថា អញនឹងទិញកូនសេះ ៥០០ ហើយសឹមលក់ ក្នុងកាលខាងក្រោយ ។ ត្រូវប្រើគ្រឿងឧប-ករណ៍ប្រមាណ ៥០០ ជាថ្ងៃចិញ្ចឹមសេះ ដែលមានតម្លៃ ១០០០ ដោយជាគ្រឿងក្រអូប និងផ្កាជាដើម ។ បន្ទាប់មក សេះទាំងនោះរបស់បុរសនោះកើតរោគតែមួយថ្ងៃប៉ុណ្ណោះ ក៏ស្លាប់អស់ ព្រោះហេតុនោះ បុរសនោះពោលយ៉ាងនេះ ដោយបំណងនេះ ។ បទថា **ឧទយញ្ចេវ នាធិគច្ឆេយ្យ** បានដល់

មិនបានចំណេញផង ខាតដើមផង ។ បទថា **បយិរុបាសី** បានដល់ ទំនុកបម្រុងដោយបច្ច័យ ៤ ។ បទថា **សោហំ ឱទយញ្ញោវ ឆាធិគច្ឆី** សេចក្ដីថា ខ្ញុំព្រះអង្គមិនបានចំណេញផង ខាតដើមទៀតផង ។ លោកសម្ដែងថា ខ្ញុំឈ្មោះថា ទំនុកបម្រុងសេះទុកលក់ ។ ពាក្យដ៏សេសក្នុងបទនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។៚

**អដ្ឋកថា វប្បសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សាឡ្ហសូត្រទី ៦

[ ៤៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី គ្រានោះ ក្សត្រិយ៍លិច្ឆវី ព្រះនាមសាឡ្ហៈ និងក្សត្រលិច្ឆវីព្រះនាមអភយៈ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះសាឡ្ហលិច្ឆវី គង់ក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការឆ្លងចេញចាកឱឃៈ ដោយហេតុ ២ ប្រការ

គឺសីលវិសុទ្ធិជាហេតុ ១ តបោជិគុច្ឆា ( ការខ្ពើមបាបដោយប្រព្រឹត្តតបៈ គឺធ្វើទុក្ករកិរិយា ) ជាហេតុ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូចម្តេច ក្នុងរឿងនេះ ។ ម្នាលសាឡ្ហៈ តថាគតពោលនូវសីល-វិសុទ្ធិ ថាជាអង្គនៃសមណធម៌ ១ ។ ម្នាលសាឡ្ហៈ ពួកសមណព្រាហ្មណ៍ណា ជាអ្នកពោលនូវតបោជិគុច្ឆា មានតបោជិគុច្ឆាជាខ្លឹមសារ ជាប់ជំពាក់ក្នុងតបោជិគុច្ឆា ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីរលាស់ខ្លួនចេញចាកឱឃៈបានទេ ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា ដែលមានកាយសមាចារមិនបរិសុទ្ធ មានវចីសមាចារមិនបរិសុទ្ធ មានមនោសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង ( នូវអរហត្ត ) ដ៏ប្រសើរបានឡើយ ។ ម្នាលសាឡ្ហៈ ប្រៀបដូចបុរសប្រាថ្នានឹងឆ្លងនូវទន្លេ ក៏កាន់ដឹងដ៏មុត ដើរចូលទៅកាន់ព្រៃ បុរសនោះ បានឃើញដើមសាលព្រឹក្សមួយដើមដ៏ធំ មានដើមត្រង់ សាវ មិនមានសេចក្តីរង្កៀស ( មិនវៀចក្ងិកក្ងក់ ) ក្នុងព្រៃនោះហើយ ក៏កាត់នូវដើមសាលព្រឹក្សនោះត្រង់គល់ លុះកាត់គល់ហើយ ក៏កាត់ចុង លុះកាត់ចុងហើយ ក៏លួសមែក និងស្លឹកឲ្យស្អាតល្អ លុះលួសមែក និងស្លឹកឲ្យស្អាតល្អហើយ ក៏ចាំងដោយដឹងទាំងឡាយ លុះចាំងដោយដឹងរួចហើយ ក៏ប្រាស់ដោយកាំបិត លុះប្រាស់ដោយកាំបិតរួចហើយ ក៏លាក់ដោយគ្រឿងលាក់ លុះលាក់ដោយគ្រឿងដោយលាក់រួចហើយ

ក៏ដុសដោយដុំថ្ម លុះដុសដោយដុំថ្មហើយ ក៏បណ្តែតទៅក្នុងទន្លេ ។ ម្នាលសាឡ្ហៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសនោះអាចឆ្លងទន្លេរួចឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនអាចឆ្លងបានទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ដើមសាលព្រឹក្សឯណោះ គេធ្វើបរិកម្មល្អតែខាងក្រៅ ខាងក្នុងមិនស្អាតទេ ។ ហេតុនោះនឹងមានប្រាកដដល់បុរសនោះ គឺថា ដើមសាលព្រឹក្សនឹងលិចចុះ ឯបុរសក៏ដល់នូវសេចក្តីមិនចម្រើន នឹងវិនាសទៅមិនខាន មានឧបមាយ៉ាងណា ។ ម្នាលសាឡ្ហៈ ពួកសមណព្រាហ្មណ៍ណា ជាអ្នកពោលនូវតបោជិគុច្ឆា មានតបោជិគុច្ឆាជាខ្លឹមសារ ជាប់ជំពាក់ក្នុងតបោជិគុច្ឆា សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីរលាស់ខ្លួនចេញចាកឱឃៈបានឡើយ ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា ដែលមានកាយសមាចារមិនបរិសុទ្ធ មានវចីសមាចារមិនបរិសុទ្ធ មានមនោសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង ( នូវអរហត្ត ) ដ៏ប្រសើរបាន មានឧបមេយ្យដូច្នោះដែរ ។ ម្នាលសាឡ្ហៈ ចំណែកពួកសមណព្រាហ្មណ៍ណា ជាអ្នកមិនពោលនូវតបោជិគុច្ឆា មិនមានតបោជិគុច្ឆាជាខ្លឹមសារមិនជាប់ជំពាក់ក្នុងតបោជិគុច្ឆា សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីរលាស់ខ្លួនចេញចាកឱឃៈបាន ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា មានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មាន

មានសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង ( នូវអរហត្ត ) ដ៏ប្រសើរបាន ។ ម្នាលសាឡ្ហៈ ប្រៀបដូចបុរសប្រាថ្នានឹងឆ្លងទន្លេ ក៏កាន់ដឹងដ៏មុត ដើរចូលទៅកាន់ព្រៃ បុរសនោះក៏ឃើញដើមសាលព្រឹក្សដ៏ធំត្រង់សាវ មិនមានសេចក្តីវៀនសក្នុងព្រៃនោះហើយ ក៏កាត់នូវដើមសាលព្រឹក្សនោះត្រង់គល់ លុះកាត់គល់ហើយ ក៏កាត់ចុង លុះកាត់ចុងហើយ ក៏លួសមែក និងស្លឹកឲ្យស្អាតល្អ លុះលួសមែក និងស្លឹកឲ្យស្អាតល្អហើយ ទើបចាំងដោយដឹងទាំងឡាយ លុះចាំងដោយដឹងរួចហើយ ក៏ប្រាស់ដោយកាំបិត លុះប្រាស់ដោយកាំបិតរួចហើយ ក៏យកពន្លាកដាប់ខាងក្នុងឲ្យស្អាតល្អ លុះដាប់ខាងក្នុងឲ្យស្អាតហើយ ក៏លាក់ដោយគ្រឿងលាក់ លុះលាក់ដោយគ្រឿងលាក់រួចហើយ ក៏ដុសដោយដុំថ្ម លុះដុសដោយដុំថ្មរួចហើយ ក៏ធ្វើឲ្យបានជាទូក លុះធ្វើបានជាទូករួចហើយ ក៏ចងប្រវាថែវ លុះចងប្រវាថែវរួចហើយ ក៏បណ្តែតទៅក្នុងទន្លេ ។ ម្នាលសាឡ្ហៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសនោះអាចឆ្លងទន្លេរួចបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អាចឆ្លងបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ដើមសាលព្រឹក្សឯណោះ គេធ្វើបរិកម្មល្អទាំងខាងក្រៅទាំងក្នុងស្អាតល្អ ទាំងទូកគេក៏បានចងប្រវាថែវរួចហើយ ។ ហេតុនុ៎ះនឹងមានប្រាកដដល់បុរសនោះ គឺទូកក៏មិនលិច បុរសក៏នឹងឆ្លងដល់ត្រើយនាយដោយសួស្តីបាន មានឧបមាយ៉ាងណា ។ ម្នាលសាឡ្ហៈ ពួកសមណ-

ព្រាហ្មណ៍ណា មិនមែនជាអ្នកពោលនូវតេបោជិគុច្ឆា មិនមានតេបោជិគុច្ឆាជាខ្លឹមសារ មិនជាប់ជំពាក់ក្នុងតេបោជិគុច្ឆា សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីរលាស់ខ្លួនចេញចាកឱឃៈបាន ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា មានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានមនោសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង ( នូវអរហត្ត ) ដ៏ប្រសើរបាន មានឧបមេយ្យដូច្នោះដែរ ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន តែងស្គាល់នូវសរដ៏វិចិត្រទាំងឡាយដ៏ច្រើន ទាហាននោះ ជាអ្នកគួរដល់ព្រះរាជាជារាជ-បម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេចដោយហេតុ ៣ យ៉ាងដោយពិត ។ ហេតុ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យធ្លាក់ចុះក្នុងទីឆ្ងាយបាន ១ បាញ់ត្រង់គ្មានខណៈ ១ បាញ់ទម្លុះទម្លាយពួកធំៗ បាន ១ ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហានបាញ់សរឲ្យធ្លាក់ចុះក្នុងទីឆ្ងាយបានយ៉ាងណា ម្នាលសាឡ្ហៈ អរិយសាវក មានចិត្តតម្កល់ខ្ជាប់ដោយប្រពៃ ក៏យ៉ាងនោះដែរ ម្នាលសាឡ្ហៈ អរិយសាវក មានចិត្តតម្កល់ខ្ជាប់ដោយប្រពៃ តែងពិចារណាឃើញនូវរូបនុ៎ះដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា រូបឯណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ទោះខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ក៏ពិចារណាឃើញនូវរូបទាំងអស់នោះថា នុ៎ះមិនមែនរបស់អញ នុ៎ះមែនជាអញ

នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ វេទនាឯណានីមួយ ... សញ្ញាឯណានីមួយ ... សង្ខារទាំងឡាយឯណានីមួយ ... វិញ្ញាណឯណានីមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ទោះនៅខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ក៏ពិចារណាឃើញនូវវិញ្ញាណទាំងអស់នោះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន អ្នកបាញ់ត្រង់គ្មានខណៈយ៉ាងណា ម្នាលសាឡ្ហៈ អរិយសាវកអ្នកឃើញត្រូវ ក៏យ៉ាងនោះដែរ ម្នាលសាឡ្ហៈ អរិយសាវកអ្នកឃើញត្រូវ តែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ តែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន បាញ់ទម្លាយកងទ័ពធំៗ បានយ៉ាងណា ម្នាលសាឡ្ហៈ អរិយសាវកអ្នកមានចិត្តផុតស្រឡះដោយប្រពៃក៏យ៉ាងនោះដែរ ។ ម្នាលសាឡ្ហៈ អរិយសាវកដែលមានចិត្តផុតស្រឡះដោយប្រពៃហើយ តែងទម្លាយនូវគំនរនៃអវិជ្ជាដ៏ធំបាន ។

# អដ្ឋកថា

## សាត្ថសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាត្ថសូត្រទី ៦ ដូចតទៅនេះ បទថា **ទ្វយេន** គឺព្រោះ ២ ចំណែក ។ បទថា **ឱឃស្ស និត្ថរណំ** បានដល់ ការដកនូវឱឃៈ ៤ ។ បទថា **តបោជិគុច្ឆាហេតុ** បានដល់ ព្រោះហេតុខ្ពើមនូវបាបដោយតបៈ ពោល គឺការធ្វើទុក្ករកិរិយា ។ បទថា **អញ្ញតរំ សាមញ្ញង្គំ** បានដល់ ចំណែកនៃសមណធម៌ណាមួយ ។ ក្នុងបទថា **អបរិ-សុទ្ធកាយសមាចារា** ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងដល់សីល គឺការប្រព្រឹត្តផ្លូវកាយ វាចា និងចិត្តមិនបរិសុទ្ធ ដោយ ៣ បទខាងដើម ។ ទើបទ្រង់សម្តែងដល់ភាពជាអ្នកមានអាជីវៈមិនបរិសុទ្ធ ដោយបទក្រោយ ។ បទថា **ញាណទស្សនាយ** បានដល់ ទស្សនៈ គឺមគ្គញ្ញាណ ។ បទថា **អនុត្តរាយ សម្ពោធាយ** បានដល់ អរហត្ត ។ លោកអធិប្បាយថា មិនគួរសម្ផស្សដោយញាណផស្សៈ គឺអរហត្តឡើយ ។

បទថា **សាលលដ្ឋិ** បានដល់ ដើមរាំងភ្នំ ។ បទថា **នវំ** គឺជំទង់ ។ បទថា **អកុក្កុច្ចកជាតំ** គឺមិនកើតសេចក្តីរង្កៀសថា គួរ ឬមិនគួរហ្ន៎ ។ បទថា **លេខណិយា លិខេយ្យ** បានដល់ កើតជាស្នាម ។ បទថា **ធោវេយ្យ** បានដល់ ដុសខាត់ ។ បទថា **អន្តោ អវិសុទ្ធា** បានដល់ មិនរៀបរយខាងក្នុង គឺមិនយកខ្លឹមចេញ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ ប្រៀបធៀបដោយឧបមា ដូច្នេះ ។ ពិតហើយ អត្តភាពគប្បីឃើញដូចដើមរាំងភ្នំ ក្រសៃនៃ

សន្ធារ គប្បីឃើញដូចក្រសែទឹក បុគ្គលប្រកាន់ទិដ្ឋិ ៦២ ដូចបុគ្គលដែលទៅកាន់ត្រើយនាយ ពេលដែលប្រកាន់ក្នុងអារម្មណ៍ខាងក្រៅ ដូចពេលដែលធ្វើដើមសាលព្រឹក្សឲ្យរាបល្អខាងក្រៅ ពេលដែលសីលខាងក្នុងមិនបរិសុទ្ធ ដូចពេលមិនធ្វើខាងក្នុងរបស់ដើមសាលព្រឹក្សឲ្យរាបស្មើ ការដែលបុគ្គលប្រកាន់ទិដ្ឋិ លិចចុះទៅក្នុងក្រសែសន្ធារវដ្ដ គប្បីជ្រាបដូចការដែលដើមសាលព្រឹក្សលិចចុះទៅខាងក្រោម ។

បទថា **ឯវំ ហិ សោ** បានដល់ ចងជងចៃ និងកន្ទៃ ។ បទថា **ឯវមេវ ខោ** ប្រៀបធៀបដោយឧបមាដូច្នេះថា អត្តភាពប្រៀបដូចដើមសាលព្រឹក្សធំទង់ ក្រសែសន្ធារវដ្ដ ដូចក្រសែទឹក ព្រះយោគាវចរ ដូចបុគ្គលបំណាងនឹងទៅកាន់ត្រើយនាយ ពេលដែលការសង្រួមតាំងមាំក្នុងទ្វារ ៦ ដូចពេលដែលធ្វើខាងក្រៅឲ្យស្អាត សីលាចារបរិសុទ្ធខាងក្នុង ដូចការធ្វើខាងក្នុងឲ្យស្អាត ។ ការធ្វើសេចក្ដីព្យាយាមតាមផ្លូវកាយ និងចិត្ត ដូចការចងជងចៃ និងកន្ទៃ ការបំពេញសីល សមាធិ បញ្ញាដោយលំដាប់ ហើយដល់នូវនិព្វាន គប្បីឃើញដូចការទៅដល់ត្រើយនាយ បានដោយសួស្ដី ។

បទថា **កណ្ហចិត្តកានិ** បានដល់ វិធីការដែលគួរធ្វើដោយព្រួញ មិនមានតិច ដូចជាជង-ស ខ្សែរុំស ទ្រនាប-ស ធាក-ស ខ្សែ-ស និងគ្រឿងលម្អ-ស ។ បទថា **អជខោ សោ តីហិ ឋានេហិ** សេចក្ដីថា បុគ្គលសូម្បីជីងរបៀបធ្វើព្រួញច្រើនយ៉ាងនេះ ក៏មិនគួរដល់ព្រះរាជា តែគួរដោយ

៣ ឋានៈប៉ុណ្ណោះ ។

បទថា **សម្មាសមាធិ ហោតិ** ក្នុងបទនេះ មានអត្ថថា ជាអ្នកតាំងមាំហើយ ដោយមគ្គសមាធិ និងផលសមាធិ ។ បទថា **សម្មាទិដ្ឋិ** បានដល់ប្រកបហើយ ដោយមគ្គសម្មាទិដ្ឋិ ។ លោកពោលមគ្គ ៤ ផល ៣ ដោយសច្ចៈ ៤ មាន **ឥទំ ទុក្ខំ** ដូច្នេះជាដើម ។ គប្បីជ្រាបថា បុគ្គលប្រកបដោយសម្មាទិដ្ឋិនេះ គប្បីជ្រាបថា ឈ្មោះថា បាញ់មិនខុសដោយមគ្គប៉ុណ្ណោះ ។ បទថា **សម្មាវិមុត្តិ** បានដល់ ប្រកបហើយដោយវិមុត្តិ គឺអរហត្តផល ។ បទថា **អវិជ្ជាក្ខន្ធំ បទាលេតិ** សេចក្ដីថា ជាអ្នកប្រកបដោយសម្មាវិមុត្តិ លោកពោលថា ឈ្មោះថា ទម្លាយនូវគំនរអវិជ្ជា ដោយអរហត្តមគ្គ ។ ពិតហើយ គំនរអវិជ្ជាត្រូវទម្លាយដោយអរហត្តមគ្គនេះខាងក្រោយ តែក្នុងទីនេះ គួរពោលថា រមែងទម្លាយអាស្រ័យគំនរអវិជ្ជាដែលត្រូវទម្លាយហើយ ។៚

**អដ្ឋកថា សាត្ថសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## មល្លិកាសូត្រទី ៧

[ ៤៧ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ នាងមល្លិកាទេវី ក៏ចូល

ទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងមល្លិកាទេវី អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ជាមនុស្សកម្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានសក្តិតូចផង បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្តិធំ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ មានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ជាអ្នកប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង តែជាអ្នកកម្សត់ មានទ្រព្យតិច មានភោគៈតិច មានសក្តិតូច ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានសក្តិធំផង ។ ម្នាលនាងមល្លិកា មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តី

ចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹងព្យាបាទ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ មាតុគ្រាមនោះ មិនដែល ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ គ្រឿងប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ឡើយ ជាអ្នកមានចិត្តឫស្យា តែងឫស្យា ប្រទូស្ត ចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះ និងការបូជារបស់ជនទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ ជាអ្នកមានសម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ជាអ្នកកម្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានសក្តិតូចផង ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តីចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹងព្យាបាទ រឹងត្អឹង ធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ តែមាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ទាំងមិនមានចិត្តប្រកបដោយឫស្យា រមែងមិនមានឫស្យា មិនប្រទូស្ត មិនចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អាន សំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើ

មាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ប៉ុន្តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្តិធំ ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ តែមាតុគ្រាមនោះ មិនដែលឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ឡើយ ទាំងជាអ្នកមានចិត្តប្រកបដោយឫស្យា តែងឫស្យា ប្រទូស្ត ចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អាន សំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់ មានទ្រព្យតិច មានភោគៈតិច មានសក្តិតូច ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន

ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្ដីក្រោធ ទោសៈ និងសេចក្ដីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ មាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ទាំងជាអ្នកមានចិត្តមិនប្រកបដោយឫស្យា តែងមិនឫស្យា មិនប្រទូស្ត មិនចងសេចក្ដីឫស្យាក្នុងលាភសក្ការៈ សេចក្ដីគោរពរាប់អាន សំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ទាំងជាអ្នកស្ដុកស្ដម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានសក្ដិធំផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានសម្បុរអាក្រក់ផង អាក្រក់មើលណាស់ផង ជាអ្នកខ្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានសក្ដិតូចផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ប៉ុន្តែជាអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្ដិធំផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ

ជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់ មានទ្រព្យតិច មានភោគៈតិច មានសក្តិតូចផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានសក្តិធំផង ។ កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មល្លិកាទេវី ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹង ព្យាបាទ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ក្នុងជាតិមុនដោយពិត បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានពណ៌សម្បុរអាក្រក់ រូបអាក្រក់ អាក្រក់មើលណាស់ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ក្នុងជាតិមុនដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកមិនមានចិត្តឫស្យា មិនច្រណែន មិនប្រទូស្ត មិនចងសេចក្តី

ប្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ អំពីជាតិមុន បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានសក្តិធំដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ខត្តិយកញ្ញាខ្លះ ព្រាហ្មណកញ្ញាខ្លះ គហបតិកញ្ញាខ្លះ ដែលមានក្នុងរាជត្រកូលនេះ កញ្ញាទាំងនោះ ខ្ញុំព្រះអង្គតែងធ្វើជាធំ ជាអធិបតីលើកញ្ញាទាំងនោះ បពិត្រព្រះអង្គដ៏ចម្រើន តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំព្រះអង្គជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ខ្ញុំព្រះអង្គនឹងឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសម្នាក់ និងគ្រឿងប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ខ្ញុំព្រះអង្គនឹងមិនមានចិត្តឫស្យា មិនប្រណែន មិនប្រទូស្ត មិនចងនូវសេចក្តីប្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសិកា អ្នកដល់នូវសរណៈ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## មល្លិកាសូត្រ

[ ៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមល្លិកសូត្រទី ៧ ដូចតទៅនេះ បទថា **មល្លិកា ទេវី** បានដល់ ព្រះទេវីរបស់ព្រះបាទបសេនទិកោសល ។ បទថា **យេន មិធេកច្ចោ មាតុគាមោ** បានដល់ ស្រីពួកខ្លះក្នុងលោកនេះ ។ បទថា **ទុព្វណ្ណោ** បានដល់ មានពណ៌សម្បុរគួរខ្ពើម ។ បទថា **ទុរូបោ** បានដល់ មានទ្រង់ទ្រាយមិនល្អ ។ បទថា **សុបាបិកោ** បានដល់ អាក្រក់ពន់ពេក អាក្រក់ក្រៃលែង ។ បទថា **ទស្សនាយ** ប្រែថា ដើម្បីឃើញ ។ បទថា **ទលិទ្ទោ** បានដល់ ក្រទ្រព្យ ។ បទថា **អប្បស្សកោ** បានដល់ វៀរចាក ទ្រព្យ និងស្រូវជារបស់ខ្លួនឯង ។ បទថា **អប្បភោគោ** បានដល់ វៀរចាក គ្រឿងប្រើប្រាស់ ។ បទថា **អប្បេសក្ខោ** បានដល់ មានបរិវារតិច ។ បទថា **អឌ្ឍោ** បានដល់ ជាឥស្សរៈ ។ បទថា **មហទ្ធនោ** បានដល់ មានទ្រព្យច្រើន ដោយទ្រព្យសម្រាប់ប្រើប្រាស់ ។ បទថា **មហាភោគោ** គឺមានភោគៈច្រើន ដោយភោគៈជាគ្រឿងឧបភោគបរិភោគ ។ បទថា **មហេសក្ខោ** គឺមានបរិវារ ច្រើន ។ បទថា **អភិរូបោ** គឺមានរូបស្អាត ។ បទថា **ទស្សនីយោ** គឺគួរ មើល ។ បទថា **បាសាទិកោ** គឺមានចិត្តជ្រះថ្លាដោយការមើល ។ បទថា **វណ្ណបោក្ខរតាយ** គឺដោយពណ៌សម្បុរ ទ្រង់ទ្រាយនៃសរីរៈ ។

បទថា **អភិសជ្ជតិ** ប្រែថា អាក់អន់ ។ បទថា **ព្យាបជ្ជតិ** បានដល់ លះប្រក្រតី ។ បទថា **បតិត្ថីយតិ** បានដល់ ដល់នូវភាពជាអ្នករួញរា និង

រឹងត្អឹងដោយសេចក្តីក្រោធ ។ បទថា **ឆ ធាតា ហោតិ** គឺជាស្រីមិនឲ្យ ។ ក្នុងបទថា **សេយ្យាវសថប្បទីបេយ្យំ** នេះ ទីដេក គឺគ្រែ និងបន្ទះក្តារជាដើម ឈ្មោះថា **សេយ្យ** ។ ផ្ទះ ទីនៅអាស្រ័យ ឈ្មោះថា **អាវសថ** ។ គ្រឿងប្រកបប្រទីប ដែលមានប្រទេះ និងប្រេងជាដើម លោកហៅថា **បទីបេយ្យំ**។ បទថា **ឥស្សាមនកោ** បានដល់ មានចិត្តប្រកបដោយសេចក្តីច្រណែន ។ គប្បីជ្រាបអត្ថទាំងអស់ដោយន័យនេះ ។ បទថា **កោធនា អហោសិ** គឺជាស្រីក្រោធ ។ បទថា **អនិស្សាមនកា អហោសិ** គឺបានជាស្រីមានចិត្តវៀរចាកសេចក្តីច្រណែន ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា មល្លិកសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អត្តន្តបសូត្រទី ៨

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយ ៤ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកដុត

កម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ មិនជាអ្នកដុតកម្តៅខ្លួន មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃ មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ ១ ។ ឯបុគ្គលដែលមិនជាអ្នកដុតកម្តៅខ្លួន និងមិនដុតកម្តៅបុគ្គលដទៃនោះឯង ជាអ្នកឥតមានតណ្ហាគ្រឿងស្រេកឃ្លាន រលត់កិលេស មានសន្តានដ៏ត្រជាក់ ទទួលសុខជាប្រក្រតី សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរ ក្នុងកាលជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកអាក្រាតលះបង់មារយាទល្អ ស៊ីលិទ្ធដៃ ឬជម្រះឧច្ចារៈដោយម្រាមដៃ បើគេអញ្ជើញឲ្យចូលមក ក៏មិនមក គេឃាត់ថា ឈប់ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងភត្ត ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចដែលគេនិមន្តបុគ្គលនោះ មិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ ឬកញ្ឆ្រាប៊ី មិនទទួលភត្តដែលគេនាំមកកន្លងធរណីទ្វារ មិនទទួលភត្ត ដែលគេនាំមកកន្លងកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកកន្លងអង្រែ

មិនទទួលភត្តរបស់មនុស្ស ២ នាក់ ដែលកំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តក្នុងទីដែលមានពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកដែលត្រាំ បុគ្គលនោះ ទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ១ ពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះ ២ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ២ ពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ១ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ២ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍ ៧ ខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ បុគ្គលនោះ ប្រកបដោយសេចក្តីព្យាយាម ក្នុងការផ្លាស់ប្តូរ នូវការបរិភោគភត្តរំលងកន្លះខែខ្លះ មានសភាពដូច្នេះឯង បុគ្គលនោះមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្គួយជាអាហារខ្លះ មានកម្ទេចស្បែកជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្មៅ ឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើម

ឈើ និងផ្លែឈើក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើ ដែលជ្រុះស្រាប់ខ្លះ បុគ្គលនោះ ស្លៀកដណ្តប់សំពត់សម្បកធ្មៃខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ស្លៀកដណ្តប់សំពត់ដែលគេបកចេញអំពីសាកសពខ្លះ ស្លៀកដណ្តប់សំពត់បង្សុកូលខ្លះ ស្លៀកដណ្តប់សំពត់សម្បកឈើខ្លះ ស្លៀកដណ្តប់ស្បែកខ្លាខ្លះ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកដណ្តប់សំពត់ស្បូវភ្លាំងខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញដោយសម្បកប្រទៀខ្លះ ស្លៀកដណ្តប់សំពត់ចម្រៀកក្តារខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្សខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលគេត្បាញដោយរោមកន្ទុយសត្វខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញដោយស្លាបមៀមខ្លះ ទុកសក់ និងពុកមាត់ ប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយការទុកសក់ និងពុកមាត់ខ្លះ ឈរជ្រង់ សម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោងប្រកបរឿយៗ នូវសេចក្តីព្យាយាមអង្គុយច្រហោងខ្លះ ប្រកបដោយបន្លែកបន្លា សម្រេចការដេកលើបន្លែក ដ៏ហើយដោយបន្លាខ្លះ ប្រកបរឿយៗ នូវសេចក្តីព្យាយាម ដោយការចុះត្រាំទឹកមួយថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ( បុគ្គលនោះ ) ប្រកបរឿយៗ នូវសេចក្តីព្យាយាមដុតកម្តៅកាយមានប្រការច្រើនយ៉ាង មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាអ្នកដុតកម្តៅខ្លួនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដុតកម្តៅបុគ្គល

ដទៃប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់បក្សី សម្លាប់ម្រឹគ ជាព្រាន ជាអ្នកសម្លាប់ត្រី ជាចោរ ជាអ្នកសម្លាប់ចោរ ជានាយគុក ឬពួកជនឯទៀតណាមួយ ដែលមានអំពើអាក្រក់ ( បែបនេះដែរ ) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកដុតកម្តៅបុគ្គលដទៃប្រកបព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកដុតកម្តៅខ្លួន ប្រកបព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅបុគ្គលដទៃផង ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយក្តី ជាព្រាហ្មណមហាសាលក្តី បុគ្គលនោះ បានឲ្យគេសាងរោងយញ្ញថ្មី ខាងកើតនគរ រួចឲ្យគេកោរសក់ពុកមាត់ពុកចង្កាឲ្យ ហើយស្លៀកស្បែកខ្លាទាំងក្រចក លាបកាយដោយខ្លាញ់ថ្លា និងប្រេង ហើយយកស្នែងម្រឹគ អេះខ្នងដើរចូលទៅកាន់រោងយញ្ញ ជាមួយនឹងអគ្គមហេសី និងព្រាហ្មណ៍ បុរោហិត បុគ្គលនោះ សម្រេចការដេកលើផែនដី ប្រាសចាកកម្រាលដែលគេលាបលទដោយពណ៌ខៀវ ក្នុងរោងយញ្ញនោះ ព្រះរាជាបានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះក្នុងដោះទី ១ របស់មេគោ ១ ដែលមានកូនមានរូបប្រហែលនឹងមេវា អគ្គមហេសីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះក្នុងដោះទី ២ ព្រាហ្មណ៍

បុរោហិតញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះក្នុងដោះទី ៣ បានបូជាភ្លើងដោយទឹកដោះក្នុងដោះទី ៤ កូនគោបានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយទឹកដោះដ៏សេសសល់ ព្រះរាជានោះបានត្រាស់យ៉ាងនេះថា ពួកជនចូរសម្លាប់គោឈ្មោលប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់គោស្ទាវប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់មេគោជំទង់ប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់ពពែប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់ចៀមប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរកាប់ឈើប៉ុណ្ណេះ ដើម្បីប្រយោជន៍ជាសសរយញ្ញ ចូរដកស្មៅជំណោកទន្សាយប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ។ ជនពួកណា ទោះបីជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការងារក្តី ជនពួកនោះ លុះត្រូវគេគំរាមដោយអាជ្ញា ត្រូវភ័យគ្របសង្កត់ហើយ ក៏មានមុខជោកដោយទឹកភ្នែកទួញយំ ធ្វើបរិកម្មផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកដុតកម្តៅខ្លួន ប្រកបព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនជាអ្នកដុតកម្តៅខ្លួន មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃ មិនប្រកបព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ តើដូចម្តេច ។ ឯបុគ្គលមិនជាអ្នកដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃនោះឯង ជាអ្នកឥតមានតណ្ហាជាគ្រឿងស្រេកឃ្លាន រលត់កិលេស មានសន្តានដ៏ត្រជាក់

ទទួលសុខជាប្រក្រតី សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរបំផុត ជាសារថី ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលមកកាន់ភពថ្មីទៀត កើតឡើងក្នុងលោកនេះ ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចនឹងប្រកាសបាន ។ ព្រះអង្គទ្រង់សម្តែងធម៌ពីពេះបទដើម ពីពេះបទកណ្តាល ពីពេះបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតីក្តី បុត្តនៃគហបតីក្តី ជនដែលកើតក្នុងត្រកូលណាមួយក្តី រមែងស្តាប់នូវធម៌នោះ លុះបានស្តាប់នូវធម៌នោះហើយ រមែងបាននូវសទ្ធាក្នុងព្រះតថាគត បុគ្គលនោះ លុះប្រកបដោយការបាននូវសទ្ធានោះហើយ រមែងពិចារណាឃើញដូច្នេះថា ឃរាវាសប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាផ្លូវហូរមកនៃធូលី គឺកិលេស ឯបព្វជ្ជា ទើបមានឱកាសកាលបើអាត្មាអញនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ដូចជាស័ង្ខដែលបុគ្គលដុសខាត់បានឡើយ

បើដូច្នោះ គួរតែអាត្មាអញ កោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់ជ្រលក់ទឹកអម្ចត់ ចេញចាកផ្ទះ បួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ ។ លុះកាលជាខាងក្រោយមក បុគ្គលនោះក៏បានលះបង់គំនរទ្រព្យតិចខ្លះ លះបង់គំនរទ្រព្យច្រើនខ្លះ លះបង់វង្សញាតិច្រើនខ្លះ លះបង់វង្សញាតិតិចខ្លះ ហើយកោរសក់ និងពុកមាត់ពុកចង្ការូបស្លៀកដណ្តប់សំពត់កាសាយជ្រលក់ទឹកអម្ចត់ ចេញចាកផ្ទះ មកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ ។ បុគ្គលនោះបានបួសយ៉ាងនេះហើយ ក៏ជាអ្នកបរិបូណ៌ដោយសិក្ខា និងសាជីវៈរបស់ភិក្ខុទាំងឡាយ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ជាអ្នកកាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ ជាអ្នកមិនលួច មានខ្លួនដ៏ស្អាត លះបង់អព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុនធម្ម ជារបស់អ្នកស្រុក លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរអ្នកផងជឿបាន មិនពោលបំភ្លាត់សត្វលោក លះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា ជាអ្នកបានឮពាក្យក្នុងសម្នាក់នៃពួកជនឯណោះ

ហើយ មិននាំទៅប្រាប់ដល់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះឡើយ ឬបានឮពាក្យក្នុងសម្នាក់នៃពួកជនឯណោះហើយ មិននាំយកមកប្រាប់ដល់ពួកជនឯណោះ ដើម្បីបំបែកពួកជនឯណោះឡើយ ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាហើយ ឬបន្ថែមកម្លាំងឲ្យដល់ពួកជនដែលព្រមព្រៀងគ្នាហើយ ជាអ្នកមានសេចក្តីព្រមព្រៀង ជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ជាអ្នកពោលវាចា ដែលធ្វើឲ្យព្រមព្រៀងគ្នា លះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា វាចាណាដែលឥតទោស ជាសុខដល់ត្រចៀក គួរឲ្យអ្នកផងស្រឡាញ់ពេញហឫទ័យ ជាសម្តីអ្នកក្រុង ជាទីត្រេកអរដល់ជនច្រើននាក់ ជាទីពេញចិត្តដល់ជនច្រើននាក់ ក៏ពោលតែវាចាបែបនោះ លះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកពោលពាក្យក្នុងការគួរ ពោលតែពាក្យដែលពិតប្រាកដ ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ពោលតែពាក្យដែលជាវិន័យ ពោលតែពាក្យមានឱកាស ជាទីតម្កល់ទុកក្នុងហឫទ័យ ប្រកបដោយគ្រឿងអាង មានគ្រឿងកំណត់ ប្រកបដោយប្រយោជន៍តាមកាលគួរ ។ បុគ្គលនោះវៀរស្រឡះចាកកិរិយាធ្វើពីជគាម និងភូតគាមឲ្យវិនាស ជាអ្នកបរិភោគភត្តតែមួយពេល វៀរបរិភោគក្នុងរាត្រី វៀរបរិភោគក្នុងកាលខុស វៀរចាកការមើលនូវល្បែង រាំ ច្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ វៀរចាកការទ្រទ្រង់ ការប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និង

គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ វៀរចាកទីដេកទីអង្គុយដ៏ប្រសើរ វៀរចាកការទទួលនូវមាស និងប្រាក់ វៀរចាកការទទួលនូវធញ្ញជាតិស្រស់ វៀរចាកការទទួលសាច់ឆៅ វៀរចាកការទទួលស្រី និងកុមារី វៀរចាកការទទួលខ្ញុំស្រី និងខ្ញុំប្រុស វៀរចាកការទទួលពពែ និងចៀម វៀរចាកការទទួលមាន់ និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោល ញី វៀរចាកការទទួលស្រែ និងចម្ការ វៀរចាកការប្រកបនូវទូតកម្ម គឺការនាំសំបុត្រ ឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយពាក្យគេប្រើ អំពីផ្ទះមួយទៅផ្ទះមួយ វៀរចាកការទិញ និងការលក់ដូរ វៀរចាកការបញ្ឆោត ឬបន្លំដោយជញ្ជីង បញ្ឆោតដោយកាជន៍ក្រឡៃមាស ( ជាដើម ) បញ្ឆោតដោយរង្វាស់រង្វាល់ វៀរចាកការប្រកបនូវអំពើវៀច បញ្ឆោតបំភាន់ បញ្ឆោតបោកប្រាស់ បន្លំដោយរបស់ក្លែង វៀរចាកការកាត់ ( នូវអវយវៈមានដៃជាដើម ) សម្លាប់ចាប់ចង លាក់ខ្លួនពួនចាំធ្វើអំពើអាក្រក់ និងកំហែងយកទ្រព្យគេ ។ បុគ្គលនោះ ជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ និងបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ កាលបើចេញទៅកាន់ទីណាៗ ក៏កាន់យកតែ ( បរិក្ខារ ) ប៉ុណ្ណោះចេញទៅ ។ ដូចជាសកុណជាតិមានស្លាប ទោះហើរទៅកាន់ទីណាៗ ក៏មានតែស្លាបរបស់ខ្លួនជាភារៈប៉ុណ្ណោះហើរទៅ យ៉ាងណា ភិក្ខុជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ និងបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ទោះទៅកាន់ទីណា ក៏កាន់យកតែ ( បរិក្ខារ ) ប៉ុណ្ណោះ ហើយចេញទៅ យ៉ាងនោះដែរ

បុគ្គលនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលចំពោះនូវសុខមិនមានទោស ក្នុងសន្តាននៃខ្លួន ។ បុគ្គលនោះបានឃើញរូបដោយចក្ខុហើយ តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក ... បានធុំក្លិនដោយច្រមុះ ... បានទទួលរសដោយអណ្តាត ... បានពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនុ៎ះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ បុគ្គលនុ៎ះប្រកបដោយការសង្រួមឥន្ទ្រិយដ៏ប្រសើរនេះ ទទួលសុខដែលមិនច្រឡំដោយកិលេសជាខាងក្នុង ។ បុគ្គលនោះ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការឈានទៅមុខ និងការឈានថយក្រោយ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការមើលទៅមុខ និងមើលផ្សេងៗ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការបត់ចូល និងលាចេញ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការបរិភោគ ផឹក ទំពាស៊ី និង

ទទួលរស ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងឧច្ចារបស្សាវកម្ម ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ លក់ ភ្ញាក់ពីដេក និយាយ នៅស្ងៀម ។ បុគ្គលនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង សេពគប់នូវសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ជង្រៃ ទីវាល គំនរចំបើង ។ លុះបុគ្គលនោះ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តវិញ ក៏ពត់ភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មារតីឲ្យមានមុខឆ្ពោះ ( ទៅរកកម្មដ្ឋាន ) ។ បុគ្គលនោះ លះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់នូវព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនមានព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តចាកព្យាបាទ និងសេចក្តីប្រទូស្ត លះបង់នូវថីនមិទ្ធៈ គឺសេចក្តីងងុយងោកងក់ មានថីនមិទ្ធៈទៅប្រាសហើយ មានសេចក្តីសម្គាល់នូវពន្លឺ មានស្មារតី មានសេចក្តីដឹងខ្លួន ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយសោយចិត្ត មានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆា គឺសេចក្តីងឿងឆ្ងល់ មានចិត្តឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្តីសង្ស័យក្នុងកុសលធម៌ ជម្រះចិត្តចាកវិចិកិច្ឆា ។ បុគ្គលនោះលះបង់នូវនីវរណធម៌ទាំង ៥ នេះ ដែលជាឧបក្កិលេសនៃចិត្ត ជាគ្រឿងធ្វើប្រាជ្ញាឲ្យ

ថយកម្លាំង ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ បុគ្គលនោះកាលបើចិត្ត តម្កល់មាំ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស មានឧបក្កិលេស ទៅប្រាស មានសភាពជាចិត្តទន់ភ្លន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិន ដល់នូវការរំភើបទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តឲ្យទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញាជាគ្រឿងរឭកតាមនូវខន្ធ ដែល សត្វធ្លាប់អាស្រ័យនៅហើយ ក្នុងកាលមុន បុគ្គលនោះ រមែងរឭកតាមនូវ បុព្វេនិវាស គឺខន្ធដែលមនុស្សសត្វធ្លាប់អាស្រ័យនៅហើយ ក្នុងភពមុនជា ច្រើនប្រការ ការរឭកបាននោះ តើដូចម្តេច គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិ ខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ មួយ សែនជាតិខ្លះ អស់សំវដ្តកប្ប គឺកប្បដែលវិនាសជាច្រើនខ្លះ អស់វិវដ្តកប្ប គឺកប្បដែលចម្រើនជាច្រើនខ្លះ អស់សំវដ្តវិវដ្តកប្ប គឺកប្បវិនាស និង កប្បចម្រើនជាច្រើនខ្លះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះ យ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មា អញច្យុតចាកភពនោះហើយ ទៅកើតក្នុងភពឯណោះ ដែលអាត្មាអញបាន ទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរ

យ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះហើយ ទើបបានមកកើតក្នុងភពនេះ ដូច្នេះ រឭកតាមនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរ និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និងគោត្រកូល ដោយប្រការដូច្នេះឯង បុគ្គលនោះ កាលបើចិត្តតម្កល់មាំបរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ភ្លន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនរំភើបទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវចុតិ និងបដិសន្ធិនៃសត្វទាំងឡាយ បុគ្គលនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធស្អាត កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត និងកើតឡើង ថោកទាប និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯពួកសត្វនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជា

អ្នកមិនតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ ពួកសត្វនោះ លុះទម្លាយរាងកាយ ស្លាប់ទៅ រមែងចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌ដូច្នេះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ បុគ្គលនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ភ្លន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនរំភើបទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ បុគ្គលនោះ រមែងដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាទីរលត់នៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់នៃអាសវៈ ។ កាលបើបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏

ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ សេចក្ដីដឹងក៏កើតឡើងថា ចិត្ត ( នៃអាត្មាអញ ) ផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ ដែលអាត្មាអញប្រព្រឹត្ត គ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនជាអ្នកដុតកម្ដៅខ្លួន ទាំងមិនប្រកបព្យាយាម ជាគ្រឿងដុតកម្ដៅខ្លួន មិនជាអ្នកដុតកម្ដៅបុគ្គលដទៃ ទាំងមិនប្រកបព្យាយាម ជាគ្រឿងដុតកម្ដៅបុគ្គលដទៃ យ៉ាងនេះឯង ។ បុគ្គលដែលមិនដុតកម្ដៅខ្លួន ទាំងមិនដុតកម្ដៅបុគ្គលដទៃនោះ ជាបុគ្គលមិនមានតណ្ហាគ្រឿងស្រេកឃ្លាន រលត់ទុក្ខ ជាអ្នកមានសន្ដានចិត្តដ៏ត្រជាក់ ទទួលតែសេចក្ដីសុខ សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរ ក្នុងកាលជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មានប្រាកដនៅក្នុងលោក ។

# អដ្ឋកថា

## អត្តទណ្ឌសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអត្តទណ្ឌសូត្រទី ៨ ដូចតទៅនេះ បទថា **អត្តទណ្ឌា** ជាដើម ឈ្មោះថា ធ្វើខ្លួនឲ្យក្ដៅក្រហាយ ព្រោះដុតខ្លួន គឺធ្វើខ្លួនឲ្យដល់នូវទុក្ខ ។ ការប្រកបសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យក្ដៅក្រហាយ ឈ្មោះថា ការខ្វល់ខ្វាយក្នុងការធ្វើខ្លួនឲ្យក្ដៅក្រហាយ ឈ្មោះថា ធ្វើអ្នកដទៃឲ្យក្ដៅក្រហាយ ព្រោះដុតអ្នកដទៃ ។ ការប្រកបសេចក្ដីព្យាយាម ធ្វើអ្នកដទៃឲ្យក្ដៅក្រហាយ ឈ្មោះថា ការខ្វល់ខ្វាយក្នុងការធ្វើអ្នកដទៃឲ្យក្ដៅក្រហាយ ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពនេះឯង ។ ក្នុងបទថា **និច្ឆាតោ** តណ្ហា លោកហៅថា **ឆាត** ឈ្មោះថា **និច្ឆាត** ព្រោះមិនមានតណ្ហា ។ ឈ្មោះថា **និព្វុត** ព្រោះកិលេសទាំងអស់រលត់ ។ ឈ្មោះថា **សីតិភូត** ព្រោះជាអ្នកត្រជាក់ ព្រោះមិនមានកិលេសដុតខាងក្នុង ។ ឈ្មោះថា **សុខប្បដិសំវេទី** ព្រោះសោយសុខក្នុងឈាន មគ្គ ផល និងនិព្វាន ។ បទថា **ព្រហ្មភូតេន អត្តនា** បានដល់ មានខ្លួនប្រសើរ ។ បទជាដើមថា **អចេលកោ** មានអត្ថដូចបានពោលហើយ ។

ក្នុងបទមានការសម្លាប់ពពែជាដើម ពពែ លោកហៅថា **ឩរព្ភា** ឈ្មោះថា **ឩរព្ភិក** ព្រោះសម្លាប់ពពែ ។ ក្នុងពាក្យថា **សូករិក** អ្នកសម្លាប់ជ្រូកជាដើម ក៏មានន័យដូចគ្នា ។ បទថា **លុទ្ទោ** គឺទារុណឃោរឃៅ ។ បទថា **មច្ឆឃាតកោ** បានដល់ អ្នករកត្រី គឺអ្នកចាប់ត្រី អ្នកប្រមង ។ បទថា

**ពន្ធនា គារិកោ** បានដល់ អ្នកគ្រប់គ្រងគុក ។ បទថា **ក្ខុរកម្មន្តា** បានដល់ ជាអ្នកមានការងារថោកទាប ។

បទថា **មុទ្ធាភិសិត្តោ** បានដល់ ព្រះរាជាដែលគេស្រោចទឹកលើព្រះសីសៈ ហើយអភិសេកជាស្ដេច ។ បទថា **បុរត្ថិមេន នគរស្ស** បានដល់ ផ្លូវទិសខាងកើតនៃព្រះនគរ ។ បទថា **សណ្ឋាគារំ** បានដល់ រោងបូជាយញ្ញ ។ បទថា **ខរាជិនំ និវាសេត្វា** បានដល់ ស្លៀកសំពត់ស្បែកខ្លាទាំងក្រចក ។ បទថា **សប្បិតេលេន** បានដល់ ដោយសប្បិ និងប្រេង ។ វៀរសប្បិក្រៅអំពីនោះ វត្ថុ មានជ័រដ៏សេស លោកហៅថា ប្រេង ។ បទថា **កណ្ឌុវមានោ** បានដល់ ព្រោះកាត់ក្រចកអស់ កាលត្រូវអេះក៏អេះដោយស្នែងសត្វនោះ ។

បទថា **អនត្តរហិតាយ** បានដល់ មិនមានគ្រឿងកម្រាល ។ បទថា **សរូបវច្ឆាយ** បានដល់ កូនគោដែលមានពណ៌ដូចគ្នា ។ អធិប្បាយថា បើមេគោមានពណ៌ស កូនគោក៏មានពណ៌ស បើមេគោមានពណ៌ក្រហមលាយខ្មៅ ឬពណ៌ក្រហម កូនគោក៏មានពណ៌ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបឈ្មោះថា មេគោមានកូនដែលមានពណ៌ដូចគ្នា ។ បទថា **សោ ឯវមាហ** គឺព្រះរាជានោះត្រាស់យ៉ាងនេះ ។ បទថា **វច្ឆតរា** បានដល់ គោមានកម្លាំងព្រោះជាគោជំទង់ ក្នុងគោញីជំទង់ក៏ដូចគ្នា ។ បទថា **ពរិហិសត្ថាយ** បានដល់ ដើម្បីព័ទ្ធ និងដើម្បីក្រាលក្នុងទីដែលបូជាយញ្ញ ។

ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងដល់បុគ្គលទី ៤ តាំងអំពីព្រះពុទ្ធទ្រង់កើតឡើង ទើបត្រាស់ពាក្យថា **ឥធ ភិក្ខវេ តថាគតោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **តថាគតោ** ជាដើម មានអត្ថដូចបានពោល ៣៤ហើយ ។ បទថា **តំ ធម្មំ** បានដល់ ធម៌ដែលសម្បូរដោយប្រការដូចបានពោលហើយនោះ ។ បទថា **សុណាតិ គហបតិ វា** សួរថា ព្រោះហេតុអ្វីទើបទ្រង់ចង្អុលដល់គហបតីមុន ។ ឆ្លើយថា ព្រោះគហបតីកម្ចាត់មានះហើយនិងព្រោះមានចំនួនច្រើន ពិតហើយ ដោយច្រើន បុគ្គលដែលបួសអំពីត្រកូលក្សត្រ ធ្វើនូវមានះ ព្រោះអាស្រ័យជាតិ ។ បុគ្គលដែលបួសអំពីត្រកូលព្រាហ្មណ៍ ធ្វើមានះ ព្រោះអាស្រ័យមន្ត បុគ្គលដែលបួសអំពីត្រកូលដែលមានជាតិទាប មិនអាចតាំងនៅបាន ព្រោះខ្លួនមានជាតិទាប ។ ពួកទារករបស់គហបតី មានញើសហូរចេញអំពីក្លៀក ផ្កាអំបិលពេញខ្នងក្រដីដែលជាអ្នកអស់នូវមានះ និងការលើកតម្កើងខ្លួន ព្រោះមិនមានមានះដូច្នោះ ។ ទារកពួកនោះ កាលបួសហើយ ក៏មិនធ្វើមានះ ឬការលើកតម្កើងខ្លួន រៀនពុទ្ធវចនៈតាមកម្លាំង បំពេញវិបស្សនាកម្មដ្ឋាន អាចតាំងនៅក្នុងអរហត្តបាន ។ ចំណែកបុគ្គលដែលចេញបួសអំពីត្រកូលក្រៅ អំពីនេះ មិនមានច្រើន បុគ្គលជាគហបតីចេញបួសមានច្រើន ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគ ទ្រង់ចង្អុលដល់គហបតីមុន ព្រោះកម្ចាត់នូវមានះនិងព្រោះមានចំនួនច្រើននោះឯង ។ បទថា **អញ្ញតរស្មឹ វា** បានដល់ ត្រកូល

ក្រៅពីនេះ ត្រកូលណាមួយ ។ បទថា **បច្ឆាជាតោ** បានដល់ កើតខាងក្រោយ ។

បទថា **តថាគតេ សទ្ធំ បដិលភតិ** សេចក្តីថា បុគ្គលនោះបានស្តាប់ធម៌ដែលបរិសុទ្ធហើយ រមែងបាននូវសទ្ធាក្នុងព្រះតថាគត ដែលជាធម្មសាមី គឺម្ចាស់របស់ធម៌ថា ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធហ្ន៎ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** ប្រែថា ពិចារណាយ៉ាងនេះ ។ បទថា **សម្ពាធោ ឃរាវាសោ** សេចក្តីថា សូម្បីគូស្វាមីករិយានៅក្នុងផ្ទះទំហំ ៦០ ហត្ថ ឬ ១០០ យោជន៍ក៏ដោយ ការនៅគ្រប់គ្រងផ្ទះ ក៏ឈ្មោះថា ចង្អៀតទាំងអស់ ព្រោះគូស្វាមីករិយានៅមានសេចក្តីកង្វល់ និងការហួងហែង ។ បទថា **រជាបថោ** លោកពោលក្នុងមហាអដ្ឋកថាដែលជាទីកើតនៃធូលី មានរាគៈជាដើម ។ និងពោលថា **អាគមនបថោ** ជាផ្លូវមកដូច្នេះក៏គួរ ។ ឈ្មោះថា **អព្ភោកាសោ** ព្រោះដូចជាទីវាល ដោយអត្ថថា មិនមានទីជាប់ជំពាក់ ពិតហើយ បព្វជិតដែលបួសហើយ សូម្បីនៅក្នុងផ្ទះកំពូល រតនប្រាសាទ ទេវ-វិមានជាដើម ដែលមានទ្វារ និងបង្អួចបិទជិត ជាទីកំបាំង ក៏មិនជាប់ មិនជំពាក់ មិនទើសទាក់ ដោយហេតុនោះ ទើបត្រាស់ថា បព្វជ្ជាជាទីវាល ដូច្នេះ ។ ម្យ៉ាងទៀត ឃរាវាស ជាទីចង្អៀត ព្រោះមិនមានឱកាសធ្វើកុសលបានតាមត្រូវការ ។ ឈ្មោះថា ជាផ្លូវមកនៃធូលី ព្រោះជាទីប្រជុំចុះរបស់ធូលី គឺកិលេស ដូចគំនរសំរាម ដែលមិនបានបិទបាំង ។ បព្វជ្ជា ឈ្មោះថា ជាទីវាល

ព្រោះមានឱកាសធ្វើកុសល គឺសេចក្ដីល្អបានតាមសប្បាយ ។

ក្នុងបទថា **ឆយិទំ សុករំ ។បេ។ បព្វជ្ជយ្យំ** នេះ ពោលដោយសង្ខេប ដូច្នេះ ។ ព្រហ្មចរិយៈ គឺសិក្ខា ៣ នេះ បានឈ្មោះថា បរិបូណ៌ដោយចំណែកមួយ ព្រោះអ្នកបួសធ្វើមិនឲ្យដាច់សូម្បីមួយថ្ងៃ ហើយក៏គប្បីឲ្យសម្រេចចរិមកចិត្តបាន និងឈ្មោះថា បរិសុទ្ធដោយចំណែកមួយ ព្រោះអ្នកបួសធ្វើមិនឲ្យមានមន្ទិល ដោយមន្ទិល គឺកិលេសសូម្បីមួយថ្ងៃ ក៏គប្បីឲ្យសម្រេចចរិមកចិត្តបាន ។ បទថា **សង្ខលិខិតំ** បានដល់ គប្បីប្រព្រឹត្តឲ្យដូចជាស័ង្ខដែលខាត់ គឺប្រៀបដូចស័ង្ខដែលខាត់ហើយ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ ទោះប្រព្រឹត្តព្រហ្មចរិយៈ គឺសិក្ខា ៣ នេះ ឲ្យបរិសុទ្ធ បរិបូណ៌ដោយចំណែកមួយ មិនធ្វើបានងាយឡើយ បើដូច្នោះ អាត្មាអញ គប្បីកោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់ ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ឈ្មោះថា សំពត់កាសាវពស្ត្រ ព្រោះជ្រលក់ដោយទឹកម្ចត់ ចេញអំពីផ្ទះបួសជាអ្នកមិនមានផ្ទះចុះ ។ ព្រោះហេតុដែលកសិកម្ម ពាណិជ្ជកម្មជាដើម ជាប្រយោជន៍ដល់ផ្ទះ ទើបលោកហៅថា **អគារិយំ** អគារិយកិច្ចនោះ មិនមានក្នុងបព្វជ្ជា ដូច្នោះ បព្វជ្ជា គប្បីជ្រាបថា ជាអនគារិយៈ គឺមិនមានផ្ទះក្នុងសេចក្ដីនេះ មិនមានផ្ទះនោះ។ បទថា **បព្វជ្ជេយ្យំ** បានដល់ គប្បីបដិបត្តិ។ បទថា **អប្បំ វា** បានដល់ គំនរភោគៈតិចជាងពាន់ ឈ្មោះថា តិច តាំងអំពីមួយពាន់ឡើងទៅ ឈ្មោះថា ច្រើន ។ ញាតិនោះឯង ឈ្មោះថា **ញាតិ-**

**បរិវដ្ដ** *គឺខ្សែស្រឡាយ ព្រោះអត្ថថា ជាប់ទាក់ទងគ្នា ខ្សែស្រឡាយញាតិជាង ២០ ឈ្មោះថា តិច តាំង ២០ ឡើងទៅឈ្មោះថា ច្រើន ។ បទថា* **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** *សេចក្តីថា សិក្ខាឯណាដែលបានដល់អធិសីលនៃភិក្ខុទាំងឡាយ ភិក្ខុទាំងនោះនៅរួមគ្នា រស់នៅជាមួយគ្នា មានការប្រព្រឹត្តស្មើគ្នា ក្នុងសិក្ខាណា បព្វជិតចូលដល់សិក្ខានោះ និងសាជីវៈដល់សិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកហើយនោះ ព្រោះហេតុនោះ បព្វជិតនោះ ឈ្មោះថា ជាអ្នកដល់ព្រមហើយ ដោយសិក្ខា និងការនៅរួមគ្នារបស់ភិក្ខុទាំងឡាយ ។ បទថា* **សមាបន្នោ** *សេចក្តីថា បព្វជិតបំពេញសិក្ខាឲ្យបរិបូណ៌ និងមិនល្មើសសាជីវៈ គឺការនៅរួមគ្នា អធិប្បាយថា ចូលដល់សិក្ខា និងសាជីវៈទាំង ២ នោះ ។*

*បទថា* **ចាណាតិបាតំ បហាយ** *ជាដើម មានអត្ថដូចពោលហើយនោះឯង ។ បទថា* **ឥមេសំ ភេទាយ** *បានដល់ ដើម្បីឲ្យបុគ្គលដែលខ្លួនស្តាប់មកខាងនេះបែកគ្នា ។ បទថា* **ភិន្នានំ វា សន្ធាតា** *សេចក្តីថា កាលមិត្រ ២ នាក់ ឬបុគ្គលនៅរួមឧបជ្ឈាយ៍បែកគ្នា ដោយហេតុណាមួយ បព្វជិតចូលទៅរកតែបុគ្គលម្នាក់ ហើយពោលពាក្យជាដើមថា នេះមិនសមគួរដល់អ្នក ដែលកើតក្នុងត្រកូលបែបនេះ ជាអ្នកទ្រទ្រង់បាំយ៉ាងនេះ ដូច្នេះ ឈ្មោះថា ធ្វើការស្មោះស្មើនឹងគ្នា ។ បទថា* **អនុប្បានាតា** *សេចក្តីថា បន្ថែមបុគ្គលដែលស្មោះស្មើនឹងគ្នា អធិប្បាយថា បព្វជិតឃើញបុគ្គល ២ នាក់*

ស្រឡាញ់រាប់អាន ហើយពោលពាក្យជាដើមថា នេះសមគួរដល់ពួកអ្នកដែលកើតក្នុងត្រកូលបែបនេះ ដែលប្រកបដោយគុណបែបនេះ ដូច្នេះ នឹងធ្វើឲ្យមាំទាំឡើង ។ ឈ្មោះថា **សមគ្គារាម** ព្រោះថា មានការសាមគ្គី ជាទីមកត្រេកអរ អធិប្បាយថា មិនប្រាថ្នា សូម្បីតែនៅក្នុងទីដែលមិនមានការសាមគ្គីគ្នា ដូច្នេះ ។ បាលីថា **សមគ្គារាមោ** ដូច្នេះក៏មាន តែសេចក្ដីដូចគ្នានោះឯង ។ បទថា **សមគ្គរតោ** ប្រែថា ត្រេកអរហើយក្នុងបុគ្គលដែលសាមគ្គីគ្នា អធិប្បាយថា មិនប្រាថ្នាលះបង់បុគ្គលដែលសាមគ្គីទាំងនោះ ហើយទៅកាន់ទីដទៃ ។ ឈ្មោះថា **សមគ្គនន្ទី** ព្រោះឃើញក្ដី បានឮក្ដី នូវបុគ្គលដែលសាមគ្គីគ្នា ក៏ត្រេកអរ ។ បទថា **សមគ្គករណី វាចំ ភាសិតា** សេចក្ដីថា វាចាណាធ្វើឲ្យបុគ្គលសាមគ្គីគ្នា រមែងពោលវាចានោះ ដែលសម្ដែងដល់គុណនៃសាមគ្គីប៉ុណ្ណោះ មិនពោលក្រៅអំពីនេះ ។

ក្នុងបទថា **នេលា** ទោសលោកហៅថា **ឯល** ។ ឈ្មោះថា **នេលា** ព្រោះមិនមានទោស អធិប្បាយថា មិនមានទោស ។ ដូច **នេល** សព្ទដែលលោកពោលក្នុងបទនេះថា **នេលង្គោ សេតបច្ឆាទោ** រថមានគ្រឿងប្រកបមិនមានទោស មានដំបូលពណ៌ស ដូច្នេះ ។ បទថា **កណ្ណសុខា** បានដល់ ជាទីសប្បាយត្រចៀក ព្រោះពីរោះដោយព្យញ្ជនៈ មិនកើតដូចលំពែងចាក់ត្រចៀក ឬដូចចាក់ដោយដែកស្រួច ។ ឈ្មោះថា **បេមនីយា** ព្រោះមិនកើតការអាក់អន់ក្នុងសកលកាយ កើតតែសេចក្ដីស្រឡាញ់ ព្រោះ

ពីរោះដោយអត្ថ ។ ឈ្មោះថា **ហទយង្គមា** ព្រោះចូលដល់ចិត្តមិនទ្រគោះ បោះបោក ចូលទៅ គឺចូលដល់ហទយៈ ដោយស្រួល ។ ឈ្មោះថា **បោរី** ព្រោះជាពាក្យរបស់អ្នកក្រុង ព្រោះបរិបូណ៌ដោយគុណ ។ ឈ្មោះថា **បោរី** ព្រោះល្អិតល្អន់ ដូចនារីដែលចម្រើនក្នុងក្រុង ដូច្នេះក៏មាន ។ ឈ្មោះថា **បោរី** ព្រោះជាពាក្យរបស់អ្នកក្រុង ដូច្នេះក៏មាន ។ ឈ្មោះថា **បោរី** បានដល់ពាក្យសម្តីរបស់អ្នកក្រុង អធិប្បាយថា ពិតហើយ អ្នកក្រុងរមែងពោលពាក្យដែលសមគួរ ហៅបុគ្គលស្រករឪពុក ថាឪពុក បុគ្គលដែលស្រករបងថាបង ដូច្នេះ ។ ឈ្មោះថា **ពហុជនកន្តា** ព្រោះពាក្យបែបនោះ ជាទីស្រឡាញ់របស់ជនជាច្រើន ។ ឈ្មោះថា **ពហុជនមនាបា** ព្រោះជាទីពេញចិត្ត គឺធ្វើសេចក្តីចម្រើនចិត្តនៃជនដ៏ច្រើន ដោយពាក្យជាទីស្រឡាញ់ ។

ឈ្មោះថា **កាលវាទី** ព្រោះពោលត្រូវកាល អធិប្បាយថា កំណត់កាលដែលគួរពោល ហើយទើបពោល ឈ្មោះថា **ភូតវាទី** ព្រោះនិយាយតែរឿងដែលពិត ដែលមានប៉ុណ្ណោះ ។ ឈ្មោះថា **អត្ថវាទី** ព្រោះពោលអាស្រ័យប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ក្នុងកពខាងមុខ ។ ឈ្មោះថា **ធម្មវាទី** ព្រោះពោលអាស្រ័យលោកុត្តរធម៌ ។ ឈ្មោះថា **វិនយវាទី** ព្រោះពោលអាស្រ័យសំវរវិន័យ និងបហានវិន័យ ។ ឱកាសដែលជាទីតាំងទុក ឈ្មោះថា **និធាន** និធាន គឺគោល ទីតាំងនៃវាចានោះមាន ហេតុនោះ វាចានោះឈ្មោះថា **និធានវតី** មានគោល មានទីតាំង អធិប្បាយថា ជាអ្នកពោល

ពាក្យគួរស្តាប់ក្នុងចិត្ត ។ បទថា **កាលេន** បានដល់ កាលពោលវាចាបែប នេះ ក៏គិតថា អញនឹងពោលវាចាដែលគួរចាំ ដូច្នេះ មិនពោលវាចាផ្តេសផ្តាស អធិប្បាយថា ពិចារណាដល់កាលដែលគួរមុនហើយ ទើបពោល ដូច្នេះ ។ បទថា **សាបទេសំ** បានដល់ មានឧបមា អធិប្បាយថា មានហេតុផល ។ បទថា **បរិយន្តវតី** បានដល់ សម្តែងមាតិកា អធិប្បាយថា ពោលដោយអាការដែលវាចានោះប្រាកដមាតិកា ។ បទថា **អត្ថសញ្ហិតំ** បានដល់ មានបុគ្គលចែកទុកដោយច្រើនន័យ ក៏មិនអាចកំណត់បាន ឈ្មោះថា ដល់ព្រមដោយអត្ថ ។ ម្យ៉ាងទៀត លោកអធិប្បាយថា រមែងពោលវាចាដែលប្រកបដោយប្រយោជន៍ ព្រោះវាចានោះប្រកបដោយប្រយោជន៍ ដែលបុគ្គលពោលអាស្រ័យប្រយោជន៍ បំណងនឹងពោល មិនមែនលើករឿងមួយឡើងហើយពោលរឿងដទៃឡើយ ។

បទថា **ពីជគាមភូតគាមសមារម្ភា** សេចក្តីថា ជាអ្នកវៀរចាកការកម្ចាត់ គឺការទម្លាយ ដោយការកាត់ និងការដុតនូវពីជគាម ៥ យ៉ាង គឺពូជដែលកើតអំពីឫស ១ ពូជកើតអំពីដើម ១ ពូជកើតអំពីថ្នាំង ១ ពូជកើតពីត្រួយ ១ ពូជកើតអំពីគ្រាប់ ១ និងនូវពីជគាម មានស្មៅពណ៌ខៀវ និងដើមឈើជាដើម ។

បទថា **ឯកភត្តិកោ** បានដល់ ភត្ត ២ យ៉ាង គឺភត្តក្នុងពេលព្រឹក ១ ភត្តក្នុងពេលល្ងាច ១ ក្នុងភត្ត ២ យ៉ាងនោះ ភត្តក្នុងពេលព្រឹក កំណត់ខាង

ក្នុងពេលថ្ងៃត្រង់ កត្តក្នុងពេលល្ងាច កំណត់ក្រោយថ្ងៃត្រង់ទៅ ព្រោះដូច្នោះ ទោះ បរិភោគ ១០ ដង ពីព្រឹកទល់ថ្ងៃត្រង់ ក៏ឈ្មោះថា ជាឯកកត្តិកៈនោះ ទើបពោលថា **ឯកភត្តិកោ** ដូច្នេះ ។ ការបរិភោគក្នុងពេលយប់ ឈ្មោះថា **រត្តិ** ឈ្មោះថា **រត្តូបរតោ** ព្រោះវៀរចាកការបរិភោគក្នុងពេលយប់ ។ កាលហួសពេលថ្ងៃត្រង់ទៅហើយ បរិភោគរហូតដល់ព្រះអាទិត្យលិច ឈ្មោះថា បរិភោគខុសកាល ព្រោះវៀរចាកការបរិភោគខុសកាលនោះ ឈ្មោះថា **វិរតោ វិកាលភោជនា** វៀរការបរិភោគអាហារក្នុងវេលាវិកាល ។

បទថា **ជាតរូបំ** បានដល់ មាស ។ បទថា **រជតំ** បានដល់ ប្រាក់ដែលសត្វលោកហៅថា កហាបណៈ លោហមាសក ជតុមាសក គឺមាសកធ្វើអំពីជ័រ ទារមាសក គឺមាសកធ្វើអំពីឈើ វៀរចាកការទទួលមាស និងប្រាក់ទាំង ២ នោះ អធិប្បាយថា មិនទទួលឯង មិនឲ្យអ្នកដទៃទទួល មិនត្រេកអររបស់ដែលគេរក្សា ។

បទថា **អាមកធញ្ញប្បដិគ្គហណា** បានដល់ វៀរចាកការទទួលធញ្ញជាតិ ៧ យ៉ាង ពោល គឺស្រូវសាលី ១ ស្រូវខ្សាយ ១ ស្រូវជំណើប ១ ស្រងែ ១ ថ្ពាំ ១ ស្កួយ ១ ស្មៅគែលលក ១ មិនមែនទទួលធញ្ញជាតិតែម្យ៉ាងប៉ុណ្ណោះ ដែលថា មិនគួរ សូម្បីតែប៉ះពាល់ ក៏មិនគួរដល់ភិក្ខុទាំង-ឡាយដោយពិត ។ ក្នុងបទថា **អាមកមំសប្បដិគ្គហណា** នេះ ការទទួលសាច់ និងត្រីស្រស់ ក៏មិនគួរ ប៉ះពាល់ ក៏មិនគួរដល់ភិក្ខុទាំងឡាយ វៀរតែ

ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតដោយចំពោះ ។

ក្នុងបទថា **ឥត្ថីកុមារិកាបដិគ្គហណា** នេះ ស្រីដែលនៅជាមួយបុរស ឈ្មោះថា ឥត្ថី ស្រីក្រៅអំពីនោះ ឈ្មោះថា កុមារិកា ការទទួលក្តី ការស្ទាបអង្អែលក្តី នូវស្រីទាំងនោះ ជាអកប្បិយ ។ ក្នុងបទថា **ទាសី-ទាសប្បដិគ្គហណា** នេះ ការទទួលទាសីទាសាមិនគួរ តែបើពោលយ៉ាងនេះថា ខ្ញុំប្រគេនជាកប្បិយការក ខ្ញុំប្រគេនជាញោមវត្ត ដូច្នេះ គួរ ។

ក្នុងពពែ និងចៀមជាដើម មានស្រែ និងចម្ការជាទីបំផុត គួរផ្ទៀងផ្ទាត់ថា ជាកប្បិយ ឬអកប្បិយ តាមផ្លូវព្រះវិន័យ ។ ក្នុងសេចក្តីនោះ បុព្វណ្ណជាតិ ស្រូវដុះឡើងក្នុងទីណា ទីនោះ ឈ្មោះថា ស្រែ អបរណ្ណជាតិ មានសណ្តែក ល្ងជាដើម ដុះឡើងក្នុងទីណា ទីនោះ ឈ្មោះថា ចម្ការ ។ ម្យ៉ាងទៀត វត្ថុទាំង ២ ដុះឡើងក្នុងទីណា ទីនោះ ឈ្មោះថា ស្រែ ទឹកដីដែលមិនបានធ្វើប្រយោជន៍ដល់ស្រែនោះ ឈ្មោះថា ចម្ការ ។ សូម្បីជីង និងស្រះធំជាដើម លោកក៏សង្គ្រោះចូលក្នុងបទនេះ ដោយមាតិកា ថាជាស្រែ និងចម្ការ ។

បទថា **កយវិក្កយា** បានដល់ ការទិញ និងការលក់ ។ ទូតកម្ម បានដល់ ការរត់សំបុត្រ ឬដំណឹងរបស់គ្រហស្ថ ហើយទៅក្នុងទីនោះៗ លោកហៅថា **ទូតេយ្យ** ការដែលភិក្ខុត្រូវគ្រហស្ថបញ្ជូនពីផ្ទះមួយ ទៅកាន់ផ្ទះមួយដោយការងារបន្តិចបន្តួច លោកហៅថា **បហិណគមន** គឺទទួលបម្រើ ។

*ធ្វើទាំង ២ យ៉ាងនោះ ឈ្មោះថា* **អនុយោគ** *គឺប្រកបរឿយៗ ព្រោះដូច្នោះ គប្បីជ្រាបអត្ថក្នុងបទនេះយ៉ាងនេះថា វៀរចាកការប្រកបរឿយៗ នូវភាពជាទូត និងទទួលបម្រើគ្រហស្ថ ។*

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងការបន្លំភ្នែកជញ្ជីងជាដើម ដូច្នេះ ការបោកបញ្ឆោត ឈ្មោះថា កែបន្លំ ។ ក្នុងការកែបន្លំនោះ ការកែបន្លំដោយភ្នែកជញ្ជីង មាន ៤ យ៉ាង គឺកែបន្លំដោយរូប ១ កែបន្លំដោយអវយវៈ ១ កែបន្លំដោយការចាប់ ១ កែបន្លំដោយការកំបាំង ១ ។ ក្នុងការកែបន្លំ ៤ យ៉ាងនោះ បុគ្គលនោះធ្វើជញ្ជីង ២ ដែលមានរូបប៉ុនគ្នា កាលទទួលក៏ទទួលដោយជញ្ជីងដែលធំ កាលថ្លឹងចេញ ក៏ថ្លឹងដោយជញ្ជីងដែលតូច ឈ្មោះថា កែបន្លំដោយរូប ។ កាលទទួល ក៏ប្រើដៃសង្កត់ជញ្ជីងខាងក្រោយ កាលឲ្យក៏ប្រើដៃសង្កត់ជញ្ជីងខាងមុខ ឈ្មោះថា កែបន្លំដោយអវយវៈ ។ កាលទទួល ក៏ចាប់ខ្សែត្រង់គល់ជញ្ជីង កាលឲ្យក៏ចាប់ខ្សែត្រង់ចុងជញ្ជីង ឈ្មោះថា កែបន្លំដោយការចាប់ ។ ធ្វើជញ្ជីងឲ្យប្រហោង ដាក់កម្ទេចដែកខាងក្នុង កាលទទួល ក៏រំកិលកម្ទេចដែកនោះទៅខាងចុងជញ្ជីង កាលថ្លឹងចេញ ក៏រំកិលកម្ទេចដែកនោះទុកខាងគល់ ឈ្មោះថា កែបន្លំដោយការកំបាំង ។ ថាសមាស លោកហៅថា* **កំស** *ការបោកបញ្ឆោតដោយថាសមាសនោះ ឈ្មោះថា* **កំសកូដ** *គឺបន្លំដោយសំរិទ្ធ ។ សួរថា កែបន្លំដូចម្តេច ។ ឆ្លើយថា ធ្វើថាសមាសមួយ ហើយធ្វើថាសលោហៈដទៃ ២-៣ ឲ្យមានពណ៌ដូចមាស*

បន្ទាប់អំពីនោះ បុគ្គលនោះក៏ទៅកាន់ជនបទ ចូលទៅកាន់ត្រកូលដែលស្តុកស្តម្ភមួយ ហើយពោលថា សូមអ្នកទិញភាជនៈមាសចុះ កាលសួរដល់តម្លៃបំណាំងនឹងឲ្យតម្លៃប៉ុនគ្នា កាលអ្នកទិញសួរថា ដឹងបានដូចម្តេចថា ថាសនេះជាមាស បុគ្គលដែលបោកបញ្ឆោតពោលថា សាកល្បងហើយ សឹមទទួលហើយកូតថាសមាស ដោយដុំថ្ម លក់ថាសទាំងអស់ហើយក៏ទៅ ។

ការកែបន្លំដោយគ្រឿងវាស់ មាន ៣ យ៉ាង គឺហទយភេទ ទម្លាយដោយរន្ធ ១ សិក្ខាភេទ ទម្លាយដោយកំពូល ១ រជ្ជុភេទ ទម្លាយដោយខ្សែ ១ ។ ក្នុង ៣ យ៉ាងនោះ ហទយភេទ បានក្នុងពេលវាល់សប្បិ និងប្រេងជាដើម ព្រោះថា កាលទទួលរបស់ទាំងនោះ ប្រើគ្រឿងវាល់ដែលមានរន្ធខាងក្រោម ប្រាប់ថា ចាក់សន្សឹមៗ ហើយឲ្យហូរចូលទៅក្នុងភាជនៈរបស់ខ្លួនច្រើន ហើយទទួលយកទៅ កាលឲ្យក៏បិទរន្ធ ធ្វើឲ្យពេញ ហើយឲ្យ ។ សិក្ខាភេទ បានក្នុងកាលវាល់ល្ង និងអង្ករជាដើម ព្រោះថា កាលទទួលរបស់ទាំងនោះក៏ទទួលសន្សឹមៗ ធ្វើកំពូលឲ្យកំពុង ទទួលយកទៅ កាលវាល់ចេញ ក៏ធ្វើពេញដោយរហ័ស កៀសមាត់ចេញ ទើបឲ្យ ។ រជ្ជុភេទ បានក្នុងកាលវាស់ស្រែ និងដីជាដើម ព្រោះថា កាលមិនបានសំណូក សូម្បីស្រែមិនធំក៏វាស់ឲ្យធំបាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងការឆបោកជាដើម ដូច្នេះថា ។ ពាក្យថា ឆបោក បានដល់ ទទួលសំណូកដើម្បីធ្វើម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ។ បទថា **វញ្ចនំ** បានដល់ ការបោកបញ្ឆោតអ្នកដទៃដោយឧបាយ

នោះៗ ។ ក្នុងបទទាំង ២ នោះ មានរឿងមួយជាឧទាហរណ៍ ដូច្នេះ ។

បានឮថា ព្រានម្នាក់ ចាប់បានម្រឹគ និងកូនម្រឹគដើរមក អ្នកលេងម្នាក់ ពោលនឹងព្រាននោះថា នែអ្នក បាម្រឹគតម្លៃប៉ុន្មាន កូនម្រឹគតម្លៃប៉ុន្មាន ។ កាលព្រានប្រាប់ថា បាម្រឹគ ២ កហាបណៈ កូនម្រឹគ ១ កហាបណៈ ។ ទើបអ្នកលេងឲ្យ ១ កហាបណៈ ហើយយកកូនម្រឹគទៅ កាលទៅបានបន្តិច ក៏ត្រឡប់មកវិញ ពោលថា នែអ្នក ខ្ញុំមិនត្រូវការកូនម្រឹគទេ ចូរឲ្យបាម្រឹគ ដល់ខ្ញុំ ។ ព្រានពោលថា បើដូច្នោះ អ្នកចូរឲ្យខ្ញុំ ២ កហាបណៈ ។ អ្នកលេងនោះពោលថា នែអ្នក ខ្ញុំឲ្យទៅ ១ កហាបណៈពីមុនហើយ មិនមែនឬ ព្រានឆ្លើយថា ពិតហើយ អ្នកឲ្យ ១ កហាបណៈហើយ ។ អ្នកលេងពោលថា ពីមុន ១ កហាបណៈ ហើយកូនម្រឹគនេះ ក៏មានតម្លៃ ១ កហាបណៈ ព្រោះដូច្នោះ ទើបរួមជា ២ កហាបណៈ ។ ព្រានយល់ថា អ្នកលេងពោលដោយហេតុផល ទើបទទួលយកកូនម្រឹគមក ហើយឲ្យបាម្រឹគទៅ ។

បទថា **និកតិ** បានដល់ បោកបញ្ឆោតដោយរបស់ក្លែងក្លាយ គឺធ្វើវត្ថុដែលមិនមែនសង្វារឲ្យជាសង្វារ ធ្វើវត្ថុដែលមិនមែនកែវមណីឲ្យជាកែវមណី ធ្វើវត្ថុដែលមិនមែនមាសឲ្យជាមាស ដោយប្រកបឡើង ឬដោយល្បិចកលមាយា ។ បទថា **សាវិយោគោ** បានដល់ វិធីគៃបន្លំ ពាក្យនេះជាឈ្មោះនៃការគៃបន្លំជាដើមនោះឯង ។ ព្រោះដូច្នោះ គប្បីជ្រាបអត្ថក្នុងបទនេះយ៉ាងនេះថា វិធីគៃបន្លំ ដោយការគៃបន្លំ ការបោកបញ្ឆោត វិធីគៃបន្លំ

ដោយការធ្វើរបស់ក្លែងក្លាយ ដូច្នេះ ។ អាចារ្យពួកខ្លះពោលថា ការសម្តែងរបស់មួយ ហើយប្តូរទៅជារបស់មួយទៀត ឈ្មោះថា វិធីគៃបន្លំ ។ បទនោះសង្គ្រោះដោយការបោកបញ្ឆោតនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការកាត់ជាដើម ដូច្នេះថា បទថា **ឆេទនំ** បានដល់ ការកាត់ដៃជាដើម ។ បទថា **វធោ** បានដល់ ធ្វើឲ្យស្លាប់ ។ បទថា **ពន្ធោ** បានដល់ ចងដោយចំណង គឺខ្សែជាដើម ។ បទថា **វិបរាមោសោ** បានដល់ ការវាយដណ្តើម ២ យ៉ាង គឺ **ហិមវិបរាមោស** បិទបាំងដោយសន្ទើម វាយដណ្តើម ១ **គុម្ពវិបរាមោស** បិទបាំងដោយគុម្ពឈើ វាយដណ្តើម ១ ។ ក្នុងកាលសន្ទើមធ្លាក់ ចោរទាំងឡាយយកសន្ទើមបិទបាំង ហើយវាយដណ្តើមអ្នកដើរផ្លូវ ឈ្មោះថា **ហិមវិបរាមោស** ចោរទាំងឡាយយកគុម្ពឈើជាដើម បិទបាំង ហើយវាយដណ្តើម ឈ្មោះថា **គុម្ពវិបរា-មោស** វិធីកោងដោយការប្លន់អ្នកស្រុក និងអ្នកនិគមជាដើម លោកហៅថា **អាលោប** គឺប្លន់ ។ បទថា **សហសាការោ** បានដល់ ការធ្វើដ៏ខ្លាំងក្លា ។ គឺការចូលទៅក្នុងផ្ទះយកសស្ត្រាភ្ជង់ដើមទ្រូងរបស់មនុស្ស គំរាមយករបស់ដែលខ្លួនត្រូវការ ។ ព្រោះដូច្នោះ ភិក្ខុនោះ ជាអ្នកវៀរបង់នូវទារុណកម្មដ៏ខ្លាំងក្លា គឺកាត់ ចាក់ សម្លាប់ ចង វាយដណ្តើម ប្លន់ ដោយប្រការដូច្នេះឯង ។ បទថា **សោ សន្តុដ្ឋោ ហោតិ** បានដល់ ភិក្ខុនេះជាអ្នកប្រកបដោយការសន្តោសដោយបច្ច័យតាមមាន តាមបាន ១២ យ៉ាង ក្នុងបច្ច័យ

៤ ដែលពោលហើយខាងដើម ។ បរិក្ខារ ៨ គឺត្រៃចីវរ បាត្រ កាំបិតជម្រះឈើស្ទន់ ម្ជុល វត្ថពន្ធចង្កេះ តម្រងទឹក រមែងសមគួរដល់ភិក្ខុដែលប្រកបដោយសន្តោស គឺការត្រេកអរដោយបច្ច័យតាមមាន តាមបាន ១២ យ៉ាងដូចលោកពោលទុកថា

**តិចីវរញ្ច បត្តោ ច វាសិ សូចិ ច ពន្ធនំ**
**បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ ។**

បរិក្ខារ ៨ គឺត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ
ធម្មក្រក សម្រាប់ភិក្ខុដែលប្រកបសេចក្តីព្យាយាម ។

បរិក្ខារទាំងអស់នោះ ជាគ្រឿងបរិហារកាយខ្លះ បរិហារផ្ទៃខ្លះ សួរថាបរិហារដូចម្តេច ។ ឆ្លើយថា ជាបឋម ត្រៃចីវរ រមែងបរិហារកាយ ក្នុងពេលភិក្ខុស្លៀក និងដណ្តប់ ហើយចារិកទៅ ព្រោះដូច្នោះ ទើបជាគ្រឿងបរិហារកាយ ។ ត្រៃចីវរ រមែងបរិហារចិញ្ចឹមផ្ទៃ ក្នុងពេលយកជាយចីវរត្រងទឹកផឹក ក្នុងវេលាខ្ចប់របស់ដែលគួរទំពា និងផ្លែឈើ ព្រោះដូច្នោះ ទើបជាគ្រឿងបរិហារផ្ទៃ ។ ឯបាត្រ ជាគ្រឿងបរិហារកាយ ក្នុងពេលយកបាត្រនោះដងទឹកងូត និងក្នុងកាលធ្វើការសម្អាតកុដិ ជាគ្រឿងបរិហារផ្ទៃ ក្នុងកាលទទួលអាហារបរិភោគ ។ កាំបិតក៏ជាគ្រឿងបរិហារកាយ ក្នុងកាលយកកាំបិតនោះ កាត់ឈើស្ទន់ និងក្នុងពេលតាក់តែងចំណែកនៃជើងរបស់គ្រែនិងតាំង និងដងក្រស់ ជាគ្រឿងបរិហារផ្ទៃ ក្នុងពេលសកអំពៅ និងកាប់ដូង

ជាដើម ។ មួយជាគ្រឿងបរិហារកាយ ក្នុងកាលដេរចីវរ ជាគ្រឿងបរិហារផ្ទៃ ក្នុងពេលចាក់នំ ឬផ្លែឈើបរិភោគ ។ វត្ថពន្ធចង្កេះ ជាគ្រឿងបរិហារកាយ ក្នុងពេលចងកាយ ត្រាច់ទៅ ជាគ្រឿងបរិហារផ្ទៃ ក្នុងពេលចងអំពៅជាដើម ហើយយួរទៅ តម្រងទឹកជាគ្រឿងបរិហារកាយ ក្នុងពេលយកតម្រងទឹកនោះ ត្រងទឹកងូត និងក្នុងពេលធ្វើការសម្អាតសេនាសនៈ ជាគ្រឿងបរិហារផ្ទៃ ក្នុងពេលត្រងទឹកផឹក និងក្នុងពេលកាន់យកល្ង អង្ករ និងអំបុកជាដើម ដោយតម្រងទឹកនោះ ហើយបរិភោគ នេះត្រឹមតែជាបរិក្ខាររបស់ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ។ តែសម្រាប់ភិក្ខុដែលមានបរិក្ខារ ៩ ចូលទៅកាន់ដំណេក កម្រាលតាំងនៅលើទីដេកនោះ ឬមេសោ រមែងគួរសម្រាប់ភិក្ខុដែលមានបរិក្ខារ ១០ ទីអង្គុយ ឬបន្ទះស្បែក រមែងគួរ ។ សម្រាប់ភិក្ខុដែលមានបរិក្ខារ ១១ ឈើច្រត់ ឬក្លាក់ប្រេង រមែងគួរ ។ សម្រាប់ភិក្ខុដែលមានបរិក្ខារ ១២ ឆត្រ ឬស្បែកជើង រមែងគួរ ។ បណ្ដាភិក្ខុដែលមានបរិក្ខារទាំងនេះ ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ជាអ្នកសន្ដោស ។ មិនគួរថា ភិក្ខុក្រៅអំពីនោះ ថាជាអ្នកមិនសន្ដោស ជាអ្នកប្រាថ្នាច្រើន ប្រាថ្នាធំឡើយ ។ ភិក្ខុទាំងនេះ ជាអ្នកប្រាថ្នាតិច សន្ដោស ចិញ្ចឹមងាយ មានការប្រព្រឹត្តស្រាល ។ តែព្រះមានព្រះភាគ មិនបានត្រាស់ព្រះសូត្រនេះ ដោយសំដៅយកភិក្ខុទាំងនោះ ត្រាស់ដោយសំដៅយកភិក្ខុដែលមានបរិក្ខារ ៨ ។ ពិតហើយ ភិក្ខុមានបរិក្ខារ ៨ នោះ ដាក់កាំបិតតូច និង

មូលក្នុងត្រឡោកធម្មក្រក ហើយយកធម្មក្រកដាក់ក្នុងបាត្រ ស្ពាយបាត្រត្រង់ស្មា ចងចីវរឲ្យជាប់នឹងកាយ ចៀសចេញទៅរកសេចក្តីសុខ តាមប្រាថ្នា ។ ឈ្មោះថា ភិក្ខុនោះ នឹងត្រឡប់កាន់យកអ្វីទៀត មិនមាន ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ភិក្ខុនេះ ជាអ្នកមានការប្រព្រឹត្តស្រាល ទើបត្រាស់ថា **សន្តុដ្ឋោ ហោតិ កាយបរិហារកេន ចីវរេន** ភិក្ខុដែលជាអ្នកសន្តោសដោយចីវរ ជាគ្រឿងបរិហារកាយជាដើម ។

ក្នុងបទទាំងនោះ បទថា **កាយបរិហារិកេន** បានដល់ ត្រឹមតែជាគ្រឿងបរិហារកាយ ។ បទថា **កុច្ឆិបរិហារិកេន** បានដល់ ត្រឹមតែជាគ្រឿងបរិហារផ្ទៃ ។ បទថា **សមាទាយេវ បក្កមតិ** សេចក្តីថា ភិក្ខុកាន់យកបរិក្ខារទាំងអស់នោះ ត្រឹមតែ ៨ យ៉ាងជាប់កាយទៅ ។ ភិក្ខុនោះ មិនមានការជាប់ជំពាក់ថា វិហាររបស់អញ បរិវេណរបស់អញ ឧបដ្ឋាករបស់អញ ដូច្នេះ ភិក្ខុនោះប្រើប្រាស់សេនាសនៈ ដងព្រៃ គល់ឈើ ព្រៃ ញកភ្នំ ដែលខ្លួនប្រាថ្នាហើយ ដូចព្រួញផុតអំពីបន្ទោះធ្នូ ដូចដំរីចុះប្រេងចៀសចេញចាកហ្វូង ដូច្នោះ ឈរតែឯង អង្គុយតែឯង តែឯងគ្រប់ឥរិយាបថ មិនមានសម្ពាញ់ ដល់នូវភាពដូចកុយរមាស ដែលលោកពណ៌នាយ៉ាងនេះថា

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនមាន
ថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុ តាមមានតាមបាន
ជាអ្នកអត់ធន់ ចំពោះអន្តរាយ ជាអ្នកមិនតក់ស្លុត

គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សាធកអត្ថនោះដោយឧបមា ទើបត្រាស់ពាក្យជាដើមថា **សេយ្យថាបិ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **បក្ខី សកុណោ** បានដល់ បក្សីមានស្លាប ។ បទថា **ឌេតិ** ប្រែថា ហើរទៅ ។ សេចក្ដីសង្ខេបក្នុងរឿងនេះ មានដូច្នេះ ធម្មតាបក្សីទាំងឡាយ ដឹងថា ទីកដី នោះមានដើមឈើ មានផ្លែទុំ ទើបនាំគ្នាមកអំពីទិសផ្សេងៗ យកក្រចកស្លាប និងចំពុះជាដើមចោះ ចឹក ស៊ីផ្លែឈើនៃដើមឈើនោះ បក្សីទាំងនោះ មិនបាន គិតថា ផ្លែនេះ សម្រាប់ថ្ងៃនេះ ផ្លែនេះ សម្រាប់ស្អែកនេះ កាលផ្លែឈើអស់ បក្សីទាំងឡាយ មិនបានដាក់ការរក្សាដើមឈើ មិនបានដាក់ស្លាប រោម ក្រចក ឬចំពុះត្រង់ដើមឈើនោះ មិនហួងហែងដើមឈើនោះ ប្រាថ្នានឹងទៅទិសណា ក៏មានភារៈ គឺស្លាបប៉ុណ្ណោះ ហើរទៅកាន់ទិសនោះ ភិក្ខុនេះក៏ដូចគ្នា អស់នូវ ការជាប់ជំពាក់ អស់នូវការហួងហែង ចៀសចេញទៅ គឺកាន់យកត្រឹមតែ បរិក្ខារ ៨ ហើយចៀសចេញទៅ ។

បទថា **អរិយេន** បានដល់ មិនមានទោស ។ បទថា **អជ្ឈត្តំ** បាន ដល់ ក្នុងអត្តភាពរបស់ខ្លួន ។ បទថា **អនវជ្ជសុខំ** បានដល់ សេចក្ដីសុខ ដែលមិនមានទោស ។ បទថា **សោ ចក្ខុនា រូបំ ទិស្វា** សេចក្ដីថា ភិក្ខុ នោះជាអ្នកប្រកបហើយ ដោយសីលក្ខន្ធដែលជាអរិយៈនេះ ព្រោះឃើញរូប ដោយចក្ខុវិញ្ញាណ ។ ក្នុងបទដ៏សេស ពាក្យដែលគួរពោល ក៏បានពោល

អស់ហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **អព្យាសេកសុខំ** បានដល់ សេចក្ដីសុខដែលមិនទទឹកដោយកិលេស លោកពោលថា **អវិកិណ្ណសុខំ** ដូច្នេះក៏មាន ។ ព្រោះថា សុខកើតអំពីឥន្ទ្រិយសំវរៈ ឈ្មោះថា ជាសេចក្ដីសុខដែលមិនកន្ទល់ ព្រោះប្រព្រឹត្តទៅដើម្បីត្រឹមតែឃើញជាដើមក្នុងអារម្មណ៍មានរូបដែលខ្លួនឃើញជាដើមប៉ុណ្ណោះ ។

បទថា **សោ អភិក្កន្តេ បដិក្កន្តេ** សេចក្ដីថា ភិក្ខុដែលប្រកបដោយការសង្រួមឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ រមែងជាអ្នកធ្វើនូវការដឹងខ្លួនដោយសតិសម្បជញ្ញៈ ក្នុងឋានៈ ៧ មានឈានទៅមុខ និងថយក្រោយជាដើម ។ ក្នុងបទទាំងនោះ បទថា **អភិក្កន្តំ** បានដល់ ឈានទៅមុខ ។ បទថា **បដិក្កន្តំ** បានដល់ ឈានថយក្រោយ ។ បទថា **សម្បជានការី ហោតិ** សេចក្ដីថា ភិក្ខុចូលទៅតាំងសតិដោយអំណាចសម្បជញ្ញៈ ដែលសម្បយុត្តដោយសតិ ៤ គឺសាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១ អសម្មោហសម្បជញ្ញៈ ១ ហើយកំណត់ដោយញាណធ្វើការឈានទៅ និងឈានថយទាំងនោះ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ នេះជាសេចក្ដីសង្ខេបក្នុងទីនេះ ឯសេចក្ដីពិស្ដារ បុគ្គលប្រាថ្នាគប្បីមើលបានអំពីអដ្ឋកថា សាមញ្ញផលសូត្រ ក្នុងទីឃនិកាយ ឬអំពីអដ្ឋកថា សតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ ។

សួរថា ព្រះមានព្រះភាគ ទ្រង់សម្ដែងអ្វី ដោយបទជាដើមថា **សោ**

**ខមិណា** ច ដូច្នេះ ។ ឆ្លើយថា ទ្រង់សម្តែងដល់បច្ចយសម្បត្តិនៃភិក្ខុដែលនៅព្រៃ ព្រោះបច្ច័យទាំង ៤ នេះ មិនមានដល់ភិក្ខុណា ការនៅព្រៃរបស់ភិក្ខុនោះ រមែងមិនសម្រេច ភិក្ខុនោះគួរត្រូវពោលដោយសត្វតិរច្ឆាន ឬពួកព្រាន ។ ទេវតាដែលស្ថិតនៅក្នុងព្រៃ នាំគ្នាបន្ទឺសំឡេងគួរខ្ពើមថា ប្រយោជន៍អ្វី ដោយការនៅព្រៃរបស់ភិក្ខុលាមកបែបនេះ ដូច្នេះហើយ ខោកក្បាលដេញចេញទៅ ។ ការអេប្បយស ក៏មិនផ្សាយចេញទៅថា ភិក្ខុរូបនោះចូលទៅព្រៃ បានធ្វើកម្មលាមកយ៉ាងនេះៗ ។

បច្ច័យ ៤ ទាំងនេះ មានដល់ភិក្ខុណា ការនៅព្រៃរបស់ភិក្ខុនោះរមែងសម្រេច ព្រោះថា ភិក្ខុនោះពិចារណាសីលរបស់ខ្លួន កាលមិនឃើញប្រឡាក់ប្រឡូស ឬធ្លាក់ចុះណាមួយ កើតបីតិ កាលឃើញបីតិនោះ ដោយការអស់ដោយការវិនាស រមែងឈានចុះកាន់អរិយភូមិ ។ ពួកទេវតាដែលអាស្រ័យនៅក្នុងព្រៃ មានចិត្តជារបស់ខ្លួន នាំគ្នាសរសើរ កិត្តិយសនៃភិក្ខុនោះ រមែងផ្សាយទៅ ដូចតំណក់ទឹកដែលគេដាក់ក្នុងទឹក ដោយប្រការដូច្នេះ ។

បទថា **វិវិត្តំ** បានដល់ ព្រៃមានសំឡេងតិច ។ អធិប្បាយថា មានសំឡេងអឺងកងតិច ។ ក្នុងវិភង្គសំដៅដល់សំឡេងអឺងកងតិចនោះ ទើបពោលថា ត្រង់ពាក្យថា ទីមិនមានសំឡេង គឺថា បើសេនាសនៈនៅក្នុងទីជិត តែសេនាសនៈនោះ មិនប្រឡូកប្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ ទីនោះ ឈ្មោះថា ទីមិនមានសំឡេង ។ ទីដេក និងទីអង្គុយ

ឈ្មោះថា សេនាសនៈ ។ ពាក្យនេះ ជាឈ្មោះរបស់គ្រែ និងតាំងជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា ពាក្យថា ទីដេកទីអង្គុយ បានដល់ គ្រែខ្លះ ទីដេកទីអង្គុយខ្លះ តាំងខ្លះ ពូកខ្លះ ខ្នើយខ្លះ វិហារខ្លះ ផ្ទះដែលប្រក់តែមួយចំហៀងខ្លះ ប្រាសាទខ្លះ ប្រាសាទត្រងិលខ្លះ គុហាខ្លះ ប៉មខ្លះ ផ្ទះកំពូលខ្លះ ទីសម្ងំខ្លះ គុម្ពប្ញស្សីខ្លះ គល់ឈើខ្លះ មណ្ឌបខ្លះ ឬថា ភិក្ខុទាំង-ឡាយចៀសចេញទៅក្នុងទីណា ទីទាំងអស់នោះ ឈ្មោះថា សេនាសនៈ ។ ម្យ៉ាងទៀត សេនាសនៈនេះ គឺវិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រងិល គុហា ឈ្មោះថា វិហារសេនាសនៈ ។ សេនាសនៈ គឺគ្រែ តាំង ពូក ខ្នើយ ឈ្មោះថា មញ្ចបីឋសេនាសនៈ ។ សេនាសនៈនេះ គឺស្រោមខ្នើយធ្វើអំពីបន្ទះស្បែក កម្រាលធ្វើដោយស្មៅ កម្រាលធ្វើដោយស្លឹកឈើ ឈ្មោះថា សន្ថតសេនាសនៈ ។ ភិក្ខុទាំងឡាយ ចៀសចេញទៅក្នុងទីណា នេះឈ្មោះថា សេនាសនៈ គឺឱកាសសេនាសនៈ ។ សេនាសនៈមាន ៤ យ៉ាង ដោយប្រការដូច្នេះ ។ សេនាសនៈនោះ លោកប្រើសព្ទថា **សេនាសន** ដូចគ្នាទាំងអស់ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់សេនាសនៈ ដែលសមគួរដល់ភិក្ខុដែលចារិកទៅក្នុងទិសទាំង ៤ ដូចគ្នាបក្សនេះ ទើបត្រាស់ថា **អរញ្ញំ រុក្ខមូលំ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អរញ្ញំ** បានដល់ ទីដែលចេញទៅខាងក្រៅសសរខឿនទាំងអស់ ។ បទថា **អរញ្ញំ** នេះ ចាត់ថាព្រៃដែល

មកព្រោះអំណាចភិក្ខុនី ។ ឈ្មោះថា សេនាសនៈព្រៃ បានដល់ សេនាសនៈដែលកំណត់ ៥០០ ជួរធ្នូ ព្រោះដូច្នោះ ទើបសេនាសនៈនេះ សមគួរដល់ភិក្ខុនេះ ។ លក្ខណៈនៃសេនាសនៈនោះ ពោលហើយក្នុងធុតង្គនិទ្ទេស គម្ពីរវិសុទ្ធិមគ្គ ។

បទថា **រុក្ខមូលំ** បានដល់ គល់ឈើដ៏ស្ងាត់ មានម្លប់ក្រាស់ណាមួយ ។ បទថា **បព្វតំ** បានដល់ ភ្នំថ្ម ។ ពិតហើយ ក្នុងទីនោះ ភិក្ខុងូតទឹក ត្រង់ទឹកជ្រោះ ហើយអង្គុយក្រោមម្លប់ឈើដ៏ត្រជាក់ កាលទិសផ្សេងៗ ប្រាកដ ត្រូវខ្យល់ត្រជាក់បក់មក ចិត្តក៏មានអារម្មណ៍តែមួយ ។ បទថា **កន្ទរំ** សេចក្ដីថា ទឹក លោកហៅថា **កំ** ឯកទេសនៃភ្នំដែលត្រូវទឹកច្រោះបាក់ ព្រោះទឹក ដែលគេហៅថា **និតម្ព** គឺខ្នងភ្នំខ្វះ **នទីកុញ្ជ** គឺពោះភ្នំខ្វះ ។ ក្នុងទីនោះ មានខ្សាច់ពណ៌ដូចប្រាក់ ។ ទឹកដូចគ្នានឹងដុំកែវមណី ហូរទៅខាងលើព្រៃស្ដុក ដូចពិតានកែវមណី ភិក្ខុចុះទៅកាន់ជ្រោះបែបនេះ ផឹកទឹក យកទឹកលាបខ្លួនឲ្យត្រជាក់ ពូកខ្សាច់ឡើងហើយ ក្រាលបង្សុកូលចីវរ អង្គុយបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយ ។ បទថា **គិរិគុហំ** បានដល់ រវាង ២ ភ្នំ ឬចន្លោះធំ ដូចគ្នានឹងឧម្មង្គក្នុងភ្នំ ។ លក្ខណៈព្រៃស្មសាន ពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **វនបត្ថំ** បានដល់ ដែលរំលងឧបចារៈរបស់ពួកមនុស្ស ដែលគេមិនបានភ្ជួរ មិនបានព្រោះ ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា ពាក្យថា **វនបត្ថំ** នេះ ជាឈ្មោះ

របស់សេនាសនៈដែលនៅឆ្ងាយ ។ បទថា **អព្ភោកាសំ** បានដល់ ដែលមិនបានប្រក់បាំង ។ ភិក្ខុកាលបំណងធ្វើក្រស់ក្នុងទីនេះ ហើយនៅបាន ។ បទថា **បលាលបុញ្ជំ** បានដល់ ពំនូកចំបើង ។ ពិតហើយ ភិក្ខុទាំងឡាយទាញចំបើងមកអំពីពំនូកធំ ហើយធ្វើជាលំនៅ ដូចទីពួនក្នុងញកភ្នំ ដាក់ចំបើងលើមែកឈើ គុម្ពឈើជាដើម ហើយអង្គុយខាងក្រោម បំពេញសមណធម៌ ។ លោកពោលពាក្យនេះ សំដៅដល់ ពំនូកចំបើងនោះ ។

បទថា **បច្ឆាភត្តំ** បានដល់ ខាងក្រោយភត្ត ។ បទថា **បិណ្ឌ-បាតប្បដិក្កន្តោ** បានដល់ ត្រឡប់មកអំពីស្វែងរកបិណ្ឌបាត ។ បទថា **បល្លង្កំ** បានដល់ អង្គុយពត់ជើងដោយជុំវិញ ។ បទថា **អាភុជិត្វា** បានដល់ អង្គុយពត់ភ្នែន ។ បទថា **ឧជុំ កាយំ បណិធាយ** បានដល់ តម្កល់សរីរៈខាងលើឲ្យត្រង់ ឲ្យចុងឆ្អឹងខ្នង ១៨ កំណាត់ត្រួតលើគ្នា កាលអង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃ ក៏មិនកោង កាលបើដូច្នោះ វេទនាពួកណាដែលមានការកោងជាបច្ច័យគប្បីកើតឡើងគ្រប់ខណៈដល់ភិក្ខុទាំងនោះ វេទនានោះក៏មិនកើតឡើង កាលវេទនាទាំងនោះមិនកើត ចិត្តក៏រមែងមានអារម្មណ៍តែមួយ កម្មដ្ឋានមិនធ្លាក់ចុះ មានតែចម្រើនប៉ុណ្ណោះ ។

បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** សេចក្តីថា តាំងសតិដែលមានមុខចំពោះកម្មដ្ឋាន ឬធ្វើទុកចំពោះមុខ ។ ដោយហេតុនោះឯង ទើបលោកពោលទុកក្នុងវិភង្គថា សតិនេះ ឈ្មោះថា ចូលទៅតាំងទុកហើយ ចូលទៅតាំងទុក

ហើយដោយល្អ ត្រង់ចុងច្រមុះ ឬត្រង់មុខនិមិត្ត ដោយហេតុនោះ ទើបលោកពោលថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** ដូច្នេះ ។ មា្យ៉ាងទៀត សព្ទថា **បរិ** មានអត្ថថា កំណត់ ។ សព្ទថា **មុខំ** មានអត្ថថា នាំចេញទៅ ។ បទថា **សតិ** មានអត្ថថា ចូលទៅតាំងទុក ។ ដោយហេតុនោះ ទើបលោកពោលថា **បរិមុខំ សតឹ** ដូច្នេះ គប្បីជ្រាបក្នុងបទនេះ ដោយន័យដែលពោលហើយក្នុងបដិសម្ភិទា ដោយប្រការដូច្នេះ ។ សេចក្ដីសង្ខេប ក្នុងបដិសម្ភិទានោះថា ធ្វើសតិដែលកំណត់នឹងនាំចេញទៅ ។

ក្នុងបទថា **អភិជ្ឈំ លោកេ** នេះ ឧបាទានក្ខន្ធ ៥ ឈ្មោះថា លោក ព្រោះអត្ថថា ទ្រុឌទ្រោមទៅ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា លះរាគៈ សង្កត់កាមច្ឆន្ទៈក្នុងឧបាទានក្ខន្ធ ៥ ដូច្នេះ ។ បទថា **វិគតាភិជ្ឈេន** សេចក្ដីថា មានចិត្ត ឈ្មោះថា ប្រាសចាកអភិជ្ឈា ព្រោះលះបានដោយការសង្កត់ទុក មិនមែនមានចិត្តដូចគ្នានឹងចក្ខុវិញ្ញាណទេ ។ បទថា **អភិជ្ឈាយ ចិត្តំ បរិសោធេតិ** បានដល់ ជម្រះចិត្តឲ្យបរិសុទ្ធចាកអភិជ្ឈា ។ អធិប្បាយថា កិច្ចធ្វើដោយប្រការដែលអភិជ្ឈាលែងនូវចិត្តនោះ ហើយមិនត្រឡប់មកគោងចិត្តនោះវិញ ។ ក្នុងបទថា **ព្យាបាទប្បទោសំ បហាយ** ជាដើម ក៏មានន័យនេះដូចគ្នា ។ ឈ្មោះថា ព្យាបាទ ព្រោះបៀតបៀន គឺចិត្តត្រូវលះប្រក្រតីដែលធ្លាប់មានមកក្នុងកាលមុន ដោយព្យាបាទនេះ ដូចនំផ្អូមជាដើម ឈ្មោះថា ទោសៈ ព្រោះប្រទូស្ត ឬឲ្យអ្នកដទៃប្រទូស្ត គឺឲ្យវិនាស

ដោយឲ្យដល់ភាពពិការ ។ ទាំង ២ នេះ ជាឈ្មោះនៃសេចក្តីក្រោធនោះឯង ។

ការឈឺផ្សាចិត្ត ឈ្មោះថា ថីនៈ ការឈឺផ្សាចេតសិក ឈ្មោះថា មិទ្ធៈ ថីនៈ គឺការរួញរា មិទ្ធៈ គឺការងងុយ ឈ្មោះថា ថីនមិទ្ធៈ ។ បទថា **អាលោកសញ្ញី** សេចក្តីថា ភិក្ខុប្រកបដោយសញ្ញាដែលបរិសុទ្ធ ប្រាសចាកនីវរណៈ អាចចាំនូវពន្លឺដែលឃើញ ទាំងពេលយប់ ទាំងពេលថ្ងៃ ។ បទថា **សតោ សម្បជានោ** បានដល់ ប្រកបដោយសតិ និងញាណ ។ លោកពោលទាំង ២ នេះ ព្រោះជាធម៌ឧបការៈដល់អលោកសញ្ញា ។ ការរាយមាយ និងការស្តាយក្រោយ ឈ្មោះថា ឧទ្ធច្ចកុក្កុច្ចៈ ។

បទថា **តិណ្ណាវិចិកិច្ឆោ** បានដល់ ឆ្លង គឺកន្លងនូវវិចិកិច្ឆាបាន ។ ឈ្មោះថា **អកថំកថី** ព្រោះមិនមានការសម្គាល់ថា នេះជាអ្វី ។ បទថា **កុសលេសុ ធម្មេសុ** បានដល់ ក្នុងធម៌ដែលមិនមានទោស ។ អធិប្បាយថា មិនសង្ស័យ គឺមិនចំបែងយ៉ាងនេះថា ធម៌ទាំងនេះ មិនជាកុសល ធម៌ទាំងនេះ ជាកុសល ដូចម្តេច ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។ ក្នុងនីវរណៈទាំងនេះ ពាក្យដែលគួរពោលដោយការផ្សេងនៃពាក្យសម្តី អត្ថ និងលក្ខណៈជាដើម ក៏ពោលអស់ហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **បញ្ញាយ ទុព្វលីករណេ** សេចក្តីថា ព្រោះហេតុដែលនីវរណៈទាំង ៥ នេះ កាលកើត រមែងមិនឲ្យកើតបញ្ញាដែលជាលោកិយ និងលោកុត្តរ

ដែលមិនទាន់កើតឡើង កាលកើតឡើងហើយ ក៏កម្ចាត់សមាបត្តិ ៨ ឬអភិញ្ញា ៥ ឲ្យធ្លាក់ទៅ ដូច្នោះ ទើបត្រាស់ថា **បញ្ញាយ ទុព្វលីករណេ** គឺធ្វើបញ្ញាឲ្យខ្សោយកម្លាំង ដូច្នេះ ។ បទទាំងឡាយ មានបទថា **វិវិច្ចេវ កាមេហិ** ពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទជាដើមថា **ឥមេ អាសវា** ត្រាស់ដើម្បីប្រកាសសច្ចៈ ៤ ដោយបរិយាយដទៃទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងភាពដែលលទ្ធិខាងក្រៅមិនមានផល ដោយអង្គ ៣ ខាងក្រោយ ហើយទ្រង់ប្រកាសភាពដែលពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ជ្រាលជ្រៅដោយអង្គទី ៤ ទ្រង់បញ្ចប់ទេសនាដោយកំពូលធម៌ គឺអរហត្ត ដោយបទ មានប្រមាណប៉ុណ្ណោះថា **នាបរំ ឥត្ថត្តាយាតិ បជានាតិ** ដូច្នេះ ឥឡូវនេះ កាលទ្រង់ភ្ជាប់នូវទេសនាឲ្យមាំទាំល្អ ទើបត្រាស់ពាក្យជាដើមថា **ឯវំ ខោ ភិក្ខវេ** ដូច្នេះ ។

## អដ្ឋកថា អត្តន្តបសូត្រទី ៨ ចប់

# សុត្តន្តបិដក

## តណ្ហាសូត្រទី ៩

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ សត្វលោកនេះ ត្រូវតណ្ហាណា រួបរឹតឲ្យរន្ធត់ហើយ មានសន្តានសាំញុាំដូចជាតម្បាញ ស្មុគស្មាញដូចជាអំបោះជាង តម្បាញ ដែលជំពាក់ប្រឡាក់ដោយទឹកបាយ ចាក់កណ្តាញ់ ដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយ មិនងាយប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តថាគតនឹងសម្តែងនូវតណ្ហានោះ ដែលជាគ្រឿងចាក់ស្រែះ នាំសត្វឲ្យត្រាច់រង្គាត់ ផ្សាយទៅជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ចុះសត្វលោក ដែលតណ្ហាណារួបរឹតឲ្យរន្ធត់ហើយ មានសន្តានសាំញុាំ ដូចជាតម្បាញស្មុគស្មាញ ដូចជាអំបោះជាងតម្បាញ ដែលជំពាក់ប្រឡាក់ដោយទឹកបាយ ចាក់កណ្តាញ់ដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តណ្ហាជាគ្រឿងចាក់ស្រែះ នាំសត្វឲ្យត្រាច់រង្គាត់ ផ្សាយទៅ ជាប់នៅក្នុងអារម្មណ៍ផ្សេងៗ នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាវិចរិត ( ការប្រព្រឹត្តទៅនៃតណ្ហា ) ដែលអាស្រ័យ ( ខន្ធបញ្ចកៈ ) ខាងក្នុងនេះ មាន ១៨ តណ្ហាវិចរិតដែលអាស្រ័យ ( ខន្ធ-

បញ្ចកៈ ) ខាងក្រៅក៏មាន ១៨ ដែរ ។ តណ្ហាវិចរិត ដែលអាស្រ័យ ( ខន្ធ-បញ្ចកៈ ) ខាងក្នុង ១៨ នោះ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្ដីប្រកាន់ថា អាត្មាអញមាន ដោយប្រការដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញមានយ៉ាងនេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញទៀង ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញសូន្យ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដូច្នេះខ្លះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃខ្លះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញនឹងមាន ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃ ដូច្នេះ ក៏រមែង

មាន ។ ទាំង ១៨ នេះ ជាតណ្ហាវិចរិត ដែលអាស្រ័យ ( ខន្ធបញ្ចកៈ ) ខាងក្នុង ។ តណ្ហាវិចរិត ១៨ ដែលអាស្រ័យ ( ខន្ធបញ្ចកៈ ) ខាងក្រៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើសេចក្ដីប្រកាន់ថា អាត្មាអញ មានដោយខន្ធនេះ ដូច្នេះ សេចក្ដីប្រកាន់ថា អាត្មាអញមាន ដោយប្រការនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញ ទៀង ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា អាត្មាអញសូន្យ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយប្រការនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយប្រការដទៃ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមាន

សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយខន្ធនេះ ដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដូច្នេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមានសេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមាន ។ ទាំង ១៨ នេះ ជាតណ្ហាវិចរិត ដែល អាស្រ័យ ( ខន្ធបញ្ចកៈ ) ខាងក្រៅ ។ តណ្ហាវិចរិតដែលអាស្រ័យ ( ខន្ធ-បញ្ចកៈ ) ខាងក្នុង មាន ១៨ និងតណ្ហាវិចរិតដែលអាស្រ័យ ( ខន្ធបញ្ចកៈ ) ខាងក្រៅ ១៨ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា តណ្ហាវិចរិតនេះ មាន ៣៦ មានសភាពយ៉ាងនេះ ដូច្នេះ គឺតណ្ហាវិចរិត ជាអតីត ៣៦ តណ្ហាវិចរិតជាអនាគត ៣៦ តណ្ហាវិចរិតជាបច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិចរិត ១០៨ ។ ម្នាលភិក្ខុទាំងឡាយ សត្វលោកនេះ ត្រូវតណ្ហា ណារួបរឹតឲ្យរន្ធត់ហើយ ជាសត្វមានសន្តានសាំញ៉ាំ ដូចជាតម្បាញស្មុគ ស្មាញ ដូចជាអំបោះជាងតម្បាញ ដែលជំពាក់ប្រឡាក់ដោយទឹកបាយ ចាក់ កណ្តាញ់ដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយ មិនប្រព្រឹត្តកន្លងនូវ អបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តណ្ហានេះឯង ជាគ្រឿង ចាក់ស្រែះនាំសត្វឲ្យត្រាច់រង្គាត់ផ្សាយទៅជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ។ ៚

# អដ្ឋកថា

## តណ្ហាសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាសូត្រទី ៩ ដូចតទៅនេះ បទថា **ជាលិនី** គឺដូចសំណាញ់ អធិប្បាយថា សំណាញ់គេប្រទាក់ក្រឡាដោយជុំវិញ យ៉ាងណា តណ្ហាក៏យ៉ាងនោះ លោកហៅថា **ជាលិនី** ព្រោះដូចជាសំណាញ់ ។ តណ្ហា ឈ្មោះថា **ជាលិនី** ព្រោះតណ្ហានេះ គ្របសង្កត់នូវភព ៣ មានសំណាញ់ដែលជាចំណែករបស់ខ្លួនក្នុងភពនោះ ដូច្នេះក៏មាន ។ បទថា **សំសរិតំ** គឺអន្ទោលទៅក្នុងភពនោះៗ ។ បទថា **វិសដំ** បានដល់ផ្សាយទៅ គឺផ្សព្វផ្សាយទៅ ។ បទថា **វិសត្តិកំ** បានដល់ ជាប់នៅក្នុងភពនោះៗ ។ ម្យ៉ាងទៀត គប្បីឃើញដោយន័យជាដើមថា តណ្ហា ឈ្មោះថា **វិសត្តិកា** គឺមានឫសជាពិស តណ្ហា ឈ្មោះថា **វិសត្តិកា** មានផ្លែជាពិស ដូច្នេះ ។ បទថា **ឧទ្ធស្តោ** បានដល់ គ្របដណ្តប់ខាងលើ ។ បទថា **បរិយោនទ្ធោ** បានដល់ រឹតរុំដោយជុំវិញ ។

បទថា **តន្តាកុលកជាតោ** គឺជាប់ជំពាក់ដូចអំបោះជំពាក់ ។ អធិប្បាយថា អំបោះរបស់ជាងតម្បាញទុកដាក់មិនល្អ ត្រូវកណ្តុរកាត់ រមែងជំពាក់ក្នុងទីនោះៗ លំបាកនឹងកំណត់ចុង និងចុង ឬគល់ និងគល់ ថានេះចុង នេះគល់ ដូច្នេះ យ៉ាងណា សត្វទាំងឡាយក៏ដូច្នោះដូចគ្នា ត្រូវតណ្ហានេះរឹតរុំជាប់ជំពាក់ស្មុគស្មាញ មិនអាចធ្វើផ្លូវចេញនៃតណ្ហារបស់ខ្លួនឲ្យត្រង់បាន ។ បទថា **គុលាគុណ្ឋិកជាតោ** បានដល់ អំបោះដែលជ្រលក់បាយម៉ាន លោក

ហៅថា **គុលាគុណ្ឋិក** អាចារ្យពួកខ្លះពោលថា សម្បុករបស់បក្សី ឈ្មោះថា **គុលា** ដូច្នេះក៏មាន គប្បីប្រកបសេចក្ដីដោយន័យមុនថា ទាំង ២ នោះក៏ស្មុគស្មាញ ដែលនឹងកំណត់ចុង និងចុង ឬគល់ និងគល់ដូចគ្នា ។

បទថា **មុញ្ជបព្វជភូតោ** បានដល់ ដូចគ្នានឹងស្មៅជំណោកទន្សាយ និងស្មៅយាប្លង គឺលោកកើតយ៉ាងនោះ ។ ការដែលនឹងកាន់យកខ្សែដែលគេវាយស្មៅនោះៗ ធ្វើហើយ ធ្លាក់ទៅក្នុងទីណាមួយ ក្នុងកាលដែលវាចាស់ហើយ ក៏លំបាកនឹងកំណត់ចុង ឬគល់របស់ស្មៅទាំងនោះបានថា នេះចុង នេះគល់ ដូច្នេះ បុគ្គលដែលតាំងនៅក្នុងព្យាយាមចំពោះខ្លួន ទើបអាចធ្វើខ្សែនោះឲ្យត្រង់បាន វៀរព្រះពោធិសត្វនោះចេញ សត្វដទៃ ក៏មិនអាចទម្លាយសំណាញ់ គឺតណ្ហាដោយធម្មតារបស់ខ្លួន ហើយធ្វើផ្លូវស្រុះចេញអំពីទុក្ខរបស់ខ្លួនឲ្យត្រង់បាន យ៉ាងណា លោកនេះ ក៏ដូច្នោះ ត្រូវសំណាញ់ គឺតណ្ហារឹតរុំ មិនឲ្យកន្លងផុតអបាយ ទុគ្គតិ វិនិបាត វដ្តសង្សារទៅបាន ។

ក្នុងបទទាំងនោះ បទថា **អបាយោ** បានដល់ នរក កំណើតតិរច្ឆាន បេតវិស័យ និងអសុរកាយ ។ ទាំងអស់នោះ លោកហៅថា អបាយ ព្រោះមិនមានសេចក្ដីចម្រើន ពោល គឺការលូតលាស់ ។ម្យ៉ាងទៀត ឈ្មោះថា **ទុគ្គតិ** ព្រោះភាពជាផ្លូវទៅនៃទុក្ខ ។ ឈ្មោះថា **វិនិបាត** ព្រោះធ្លាក់ទៅចាកកាយដែលជាសុខ ។ ចំណែកក្រៅអំពីនេះ មានអធិប្បាយថា លំដាប់នៃខន្ធ ធាតុ អាយតនៈ ប្រព្រឹត្តទៅមិនដាច់ខ្សែ លោកហៅថា **សង្សារ** ។

សត្វលោកមិនអាចកន្លង មិនអាចផុតសភាពទាំងអស់នោះ ដោយពិត សត្វលោក កាន់យកចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺបន្ទាប់អំពីចុតិ កាន់យកបដិសន្ធិ បន្ទាប់អំពីបដិសន្ធិ កាន់យកចុតិ រមែងវិលទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ដូចទូកត្រូវខ្យល់បន្សាត់ទៅក្នុងមហាសមុទ្រ ដូចគោដែលទឹមដោយឈើយន្ត ។

បទថា **អជ្ឈត្តិកស្ស ឧបាទាយ** ប្រែថា អាស្រ័យខន្ធបញ្ចកៈខាងក្នុង ។ បទថា **អជ្ឈត្តិកស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **ពាហិរស្ស ឧបាទាយ** ប្រែថា អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ។ បទថា **អស្មីតិ ភិក្ខវេ សតិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ការរួមកាន់យកដោយអំណាចតណ្ហា មានះ ទិដ្ឋិ អាស្រ័យខន្ធបញ្ចកៈខាងក្នុងនេះ រមែងមានការនឹកថា អាត្មាអញរមែងមាន គឺរមែងនឹកក្នុងខន្ធបញ្ចកៈនោះ ។ ក្នុងបទទាំងឡាយជាដើមថា **ឥត្ថស្មីតិ ហោតិ** ដូច្នេះ ។ កាលមានការប្រកាន់ដោយស្អិតយ៉ាងនេះថា ជាអញ រមែងឈ្មោះថា ប្រកាន់ដោយ ២ ចំណែក គឺមិនប្រៀបធៀប និងប្រៀបធៀប ។ ក្នុងពាក្យទាំងនោះ ពាក្យថា មិនប្រៀបធៀប សេចក្តីថា មិនប្រៀបធៀបហេតុដទៃ គឺការនឹកថា ជាអញយ៉ាងនេះ រមែងមាន ព្រោះធ្វើឲ្យជាអារម្មណ៍ក្នុងធម៌ គឺការលោមកតាមភាវៈរបស់ខ្លួន ។ អធិប្បាយថា ការនឹកថា ក្នុងបណ្តាក្សត្រជាដើម ការគិតថា ជាអញយ៉ាងនេះ រមែងមានដោយអំណាចតណ្ហា មានះ និងទិដ្ឋិយ៉ាងនេះ ។ នេះ គឺការ

មិនប្រៀបធៀបប្រកាន់មាំ ។ ឯការប្រៀបធៀបប្រកាន់មាំ មាន ២ យ៉ាង គឺដោយស្មើគ្នា និងដោយមិនស្មើគ្នា ដើម្បីទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ថា អញយ៉ាងនេះ និងអញដទៃ ។ ក្នុងបទទាំងនោះ បទថា **ឯវស្មិ** នេះ បានដល់ ប្រៀបធៀបប្រកាន់ដោយស្មើគ្នាថា អញដូចគ្នានឹងក្សត្រអង្គនេះ ដូចព្រាហ្មណ៍នេះ ។ បទថា **អញ្ញថាស្មិ** សេចក្តីថា ប្រកាន់ដោយមិនស្មើគ្នាដូច្នេះថា អញជាមនុស្សអាក្រក់ ឬជាមនុស្សល្អជាងក្សត្រអង្គនេះ ព្រាហ្មណ៍នេះ ។ គប្បីជ្រាបតណ្ហាវិចរិត គឺការនឹកគិតដោយអំណាចតណ្ហាទាំង ៤ យ៉ាងនេះ ដោយអំណាចបច្ចុប្បន្នកាលមុន ។ តណ្ហាវិចរិតទាំង ២ នេះ គឺអសស្មីតិ សតស្មីតិ គប្បីជ្រាបថា ព្រោះហេតុដែលបទថា **អសស្មិ** នេះ ជាឈ្មោះនៃការទៀងនៃវត្ថុ ដែលមិនទៀង ។ បទថា **សតស្មិ** នេះ ជាឈ្មោះនៃការមិនទៀងនៃវត្ថុដែលទៀង ដូច្នោះ ទើបត្រាស់ដោយអំណាចសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ តណ្ហាវិចរិត ៤ មានពាក្យថា **សន្តិ** ជាដើម បន្ទាប់អំពីនេះ ត្រាស់ដោយអំណាចការសង្ស័យ និងបរិវិតក្ក ។ ក្នុងតណ្ហាវិចរិតទាំងឡាយ មានពាក្យថា **សន្តិ ហោតិ** ជាដើម គប្បីជ្រាបយ៉ាងនេះថា ការនឹកថា អញគប្បីកើត រមែងមាន ។ ចំណែកអធិប្បាយក្នុងបទនេះ គប្បីកាន់យកដោយន័យដែលពោលហើយ ក្នុងចតុក្កៈមុនៗ ម្យ៉ាងទៀត តណ្ហាវិចរិត ៤ មានពាក្យថា **សន្តិ** ជាដើម ត្រាស់ដោយអំណាចការប្រាថ្នា និងការតាំងចិត្តយ៉ាងនេះថា ហេតុអ្វី អាត្មាអញគប្បីកើត ដូច្នេះ ។ តណ្ហាវិចរិត

ទាំងនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងចតុក្កៈមុនៗ ឯតណ្ហាវិចរិត ៤ មានពាក្យថា **ភវិស្សន្តិ** ជាដើម ត្រាស់ដោយអំណាចអនាគតកាល ។ គប្បីជ្រាបអត្ថនៃតណ្ហាវិចរិតទាំងនោះ ដោយន័យដែលពោលហើយ ក្នុងចតុក្កៈមុនៗ នោះឯង ។

បណ្ឌិតគប្បីធ្វើឲ្យជាក់ច្បាស់នូវតណ្ហាវិចរិតទាំង ១៨ នេះ គឺទិដ្ឋិសីសៈ ២ សុទ្ធសីសៈ ៤ សីសមូលកៈ ១២ ។

ក្នុងតណ្ហាវិចរិតទាំងនោះ ២ មាតិកា គឺ **អស្មីតិ** ការនឹកថាជាអញ ១ **ឥត្ថស្មីតិ** ការនឹកថា អញយ៉ាងនេះ ១ ឈ្មោះថា **ទិដ្ឋិសីស។** មាតិកា ៤ គឺ **ឯវស្មីតិ** ការនឹកថា អញយ៉ាងនោះ ១ **អញ្ញថាស្មីតិ** ការនឹកថា អញដទៃ ១ **អសស្មីតិ** ការនឹកថា អញជាមនុស្សមិនល្អ ១ **សតស្មីតិ** ការនឹកថា អញជាមនុស្សល្អ ១ ឈ្មោះថា **សុទ្ធសីស។** មាតិកា ១២ គឺតណ្ហាវិចរិត ៣ គឺ **អត្ថស្មីតិ** ជាដើម ឈ្មោះថា **សីសមូលក** គប្បីជ្រាបធម៌ គឺតណ្ហាវិចរិតទាំង ១៨ នេះ គឺទិដ្ឋិសីសៈ ២ សុទ្ធសីសៈ ៤ សីសមូលកៈ ១២ ដូចពោលមកដូច្នេះ ។ គប្បីជ្រាបតណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុងនេះមុន ។ ឯក្នុងតណ្ហាវិចរិត អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ក៏ន័យនេះដូចគ្នា ។ បទថា **ឥមិនា** គប្បីជ្រាបការផ្សេងគ្នានេះ គឺដោយរូបនេះឬ ។បេ។ ដោយវិញ្ញាណនេះ ។ បទដ៏សេស ក៏ដូច្នោះដូចគ្នា ។ បទថា **ឥតិ ឯវរូបានិ អតីតានិ ឆត្តឹស** បានដល់ តណ្ហាវិចរិត ៣៦ ក្នុងកាលជាអតីតនៃបុគ្គលតែម្នាក់ ។

បទថា **អនាគតានិ ឆត្តឹស** បានដល់ តណ្ហាវិចរិត ៣៦ ក្នុងអនាគតកាល នៃបុគ្គលតែម្នាក់ ។ បទថា **បច្ចុប្បន្នានិ ឆត្តឹស** បានដល់ តណ្ហាវិចរិត ៣៦ ក្នុងបច្ចុប្បន្នកាលនៃបុគ្គលម្នាក់ ឬបុគ្គលច្រើន តាមហេតុដែលពិត ។ តណ្ហាវិចរិតក្នុងអតីតកាល ៣៦ ក្នុងអនាគតកាល ៣៦ ក្នុងបច្ចុប្បន្នកាល ៣៦ ដោយទំនងនេះឯង របស់សត្វទាំងអស់ ។ ពិតហើយ សត្វទាំងឡាយដែលផ្សេងគ្នាដោយតណ្ហា មានះ ទិដ្ឋិ មិនមានប្រមាណ មិនមានទីបំផុត ។ ក្នុងបទថា **អដ្ឋតណ្ហាវិចរិតសតំ ហោតិ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា តណ្ហាវិចរិតរួមជា ១០៨ ដូច្នេះ ។៚

អដ្ឋកថា តណ្ហាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## បេមសូត្រទី ១០

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាង រមែងកើតមាន ។ ធម្មជាត ៤ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីស្រឡាញ់កើត ព្រោះសេចក្ដីស្រឡាញ់ ១ សេចក្ដីប្រទូស្តកើត ព្រោះសេចក្ដីស្រឡាញ់ ១ សេចក្ដីស្រឡាញ់កើត ព្រោះសេចក្ដីប្រទូស្ត ១ សេចក្ដីប្រទូស្តកើត ព្រោះសេចក្ដី

ប្រទូស្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីស្រឡាញ់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។ បុគ្គល ( អ្នកចូលចិត្ត ) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្តដែរ បុគ្គលនោះ ក៏ធ្វើសេចក្តីស្រឡាញ់ ឲ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីស្រឡាញ់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើតមាន ព្រោះសេចក្តីស្រឡាញ់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល ( អ្នកចូលចិត្ត ) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត របស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តសោះ បុគ្គលនោះក៏ធ្វើសេចក្តីប្រទូស្ត ឲ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើត ព្រោះសេចក្តី

ស្រឡាញ់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើតឡើង ព្រោះសេចក្តីប្រទូស្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល ( អ្នកមិនពេញចិត្ត ) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តដែរ បុគ្គលនោះ ក៏ធ្វើសេចក្តីស្រឡាញ់ឲ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីប្រទូស្ត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើត ព្រោះសេចក្តីប្រទូស្តតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។ បុគ្គល ( ជាអ្នកមិនពេញចិត្ត ) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណា មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត របស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្តទៅវិញ បុគ្គលនោះ ក៏ធ្វើសេចក្តីប្រទូស្តឲ្យកើត ក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ

សេចក្តីប្រទូស្តកើត ព្រោះសេចក្តីប្រទូស្ត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ធម្មជាត ៤ យ៉ាងនេះឯង តែងកើតមាន ។

ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុព្រោះរម្ងាប់នូវវិតក្ក និងវិចារទាំងឡាយ ។បេ។ បានដល់នូវទុតិយជ្ឈាន ។បេ។ នូវតតិយជ្ឈាន ។បេ។ បានដល់នូវចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តី

ប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែជាទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀតជាធម្មតា សេចក្តីប្រទូស្តឯណាកើតដល់ភិក្ខុនោះ ព្រោះ សេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀតជាធម្មតា សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀតជាធម្មតា សេចក្តីប្រទូស្តឯណាកើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ ភិក្ខុនោះក៏លះបង់ បានផ្តាច់ផ្តិល

ឫសគល់អស់ហើយ បានធ្វើឲ្យ សល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មិនរលោរលាំ មិនតតប មិនរបិញរបុញ មិនធុរធេះ មិនសុបសៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរលោរលាំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ ពិចារណានូវរូបថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានវេទនាខ្លះ ពិចារណាឃើញនូវវេទនាថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវេទនាខ្លះ ពិចារណាឃើញនូវសញ្ញាថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានសញ្ញាខ្លះ ពិចារណាឃើញនូវសញ្ញាថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងសញ្ញាខ្លះ ពិចារណាឃើញនូវសង្ខារទាំងឡាយថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានសង្ខារខ្លះ ពិចារណាឃើញនូវសង្ខារថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថា តាំងនៅក្នុងពួកសង្ខារខ្លះ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរលោរលាំដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរលោរលាំ តើដូច

ម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញនូវរូបថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងរូបខ្លះ មិនពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានវេទនាខ្លះ មិនពិចារណាឃើញនូវវេទនាថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវេទនាខ្លះ មិនពិចារណាឃើញនូវសញ្ញាថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានសញ្ញាខ្លះ មិនពិចារណាឃើញនូវសញ្ញាថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងសញ្ញាខ្លះ មិនពិចារណាឃើញនូវពួកសង្ខារថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានសង្ខារខ្លះ មិនពិចារណាឃើញនូវពួកសង្ខារថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងពួកសង្ខារខ្លះ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនពិចារណាឃើញនូវវិញ្ញាណថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរលោះរលាំដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុតតប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជេរតបចំពោះបុគ្គលដែលជេរ ខឹងតបចំពោះបុគ្គលដែលខឹង ឈ្លោះតបចំពោះបុគ្គលដែលឈ្លោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកតតបដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុមិនតតប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនជេរតបចំពោះបុគ្គលដែលជេរ មិនខឹងតបចំពោះបុគ្គលដែលខឹង មិនឈ្លោះតបចំពោះបុគ្គលដែលឈ្លោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនតតបដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរបិញរបុញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញទៀងដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដូច្នេះខ្លះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃខ្លះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មា អញនឹងមានដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយ

ប្រការនេះដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការដទៃដូច្នេះ ក៏រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរបិញរបុញដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរបិញរបុញ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានសេចក្ដីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្ដីប្រកាន់ថា អាត្មាអញមានដោយប្រការនេះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា អាត្មាអញសូន្យដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដូច្នេះខ្លះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃខ្លះដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា អាត្មាអញនឹងមានដូច្នេះ ក៏មិនមាន សេចក្ដីប្រកាន់ថា អាត្មាអញនឹងមាន

ដោយប្រការនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការដទៃដូច្នេះ ក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរបិញរបុញដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធុរធេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីប្រកាន់ថា អាត្មាអញមានដោយខន្ធនេះដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញទៀងដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះខ្លះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះដោយខន្ធនេះដូច្នេះ ក៏រមែងមាន

សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយខន្ធនេះដូច្នេះ ក៏ រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការដទៃដោយខន្ធនេះដូច្នេះ ក៏រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធុរនេះ ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធុរនេះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានសេចក្តីប្រកាន់ថា អាត្មាអញមានដោយខន្ធនេះដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញទៀងដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា

សូមឲ្យអាត្មាអញមានខ្វះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការនេះខ្វះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្វះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការដទៃខ្វះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដោយប្រការដទៃដោយខន្ធនេះដូច្នេះ ក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធុរធេះដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសញ្ជប់សញ្ជឹងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ មិនបានលះបង់ ទាំងមិនបានផ្តាច់ផ្តិលឫសគល់ មិនធ្វើទីកើតដូចជាទីកើតនៃដើមត្នោត មិនធ្វើឲ្យលែងមានបែបភាពជាអស្មិមានះ មិនមែនជាមិនមានកំណើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសញ្ជប់សញ្ជឹងដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនសញ្ជប់សញ្ជឹងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ បានលះបង់ ទាំងបានផ្តាច់ផ្តិលឫសគល់ ធ្វើទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាពជាអស្មិមានះ មិនមានកំណើតតទៅទៀតជាធម្មតា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនសញ្ជប់សញ្ជឹង ដោយ ប្រការយ៉ាងនេះឯង ។

## មហាវគ្គទី ៥

## បណ្ណាសកទី ៤ ចប់

## ឧទ្ទាននៃមហាវគ្គនោះ គឺ

និយាយអំពីអានិសង្សនៃធម៌ដែលបានបញ្ចូនចិត្តស្តាប់ ១ អំពីហេតុ ៤ យ៉ាង ១ អំពីភទ្ទិយលិច្ឆវី ១ អំពីកោឡិយបុត្ត ក្នុងនិគមឈ្មោះសាបុគិយៈ ១ អំពីវប្បសក្យៈ ១ អំពីសាឡ្ហលិច្ឆវី ១ អំពីមល្លិកាទេវី ១ អំពីបុគ្គលអ្នកព្យាយាមដុតកម្តៅនូវខ្លួន ១ អំពីតណ្ហា ១ អំពីសេចក្តីស្រឡាញ់ ១ រួមជា ១០ ប្រការ ។

# អដ្ឋកថា

## បេមសូត្រ

[ ៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបេមសូត្រទី ១០ ដូចតទៅនេះ បទថា **ឧស្សេនេតិ** បានដល់ មិនលើកឡើងដោយអំណាចទិដ្ឋិ ។ បទថា **បដិសេនេតិ** បានដល់ មានបុគ្គលក្រោធ ក៏កាន់យកជាហេតុនៃជម្លោះ

ទាស់ទែង ។ បទថា **ធ ធូបាយតិ** បានដល់ មិនបង្អួយផ្សេង គឺការត្រិះរិះ ដោយអំណាចតណ្ហាវិចរិតអាស្រ័យខន្ធបញ្ចកៈខាងក្នុង ។ បទថា **ធ បជ្ជលតិ** បានដល់ មិនឆេះជាអណ្តាត ដោយអំណាចតណ្ហាវិចរិតអាស្រ័យខន្ធបញ្ចកៈខាងក្រៅ ។ បទថា **ធ បជ្ឈាយតិ** បានដល់ មិនឆេះដោយអំណាចអស្មិមានះ ។ បទដ៏សេស គប្បីជ្រាបដោយន័យនៃបាលីនោះឯង ។ វដ្តៈ វិវដ្តៈ បានត្រាស់ហើយ ក្នុងសូត្រនេះ ៕

**អដ្ឋកថា បេមសូត្រទី ១០ ចប់**

**មហាវគ្គទី ៥ ចប**

**ចតុត្ថបណ្ណាសក ចប់**

# សុត្តន្តបិដក
# បណ្ណាសកាសង្គហិតវគ្គ

## សប្បុរិសវគ្គទី ១
### សិក្ខាបទសូត្រទី ១

[ ៥១ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក ផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការសម្លាប់សត្វផង កាន់យកទ្រព្យដែលគេ

មិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង ប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង និយាយកុហកដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការនិយាយកុហកផង ផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការសម្លាប់សត្វផង វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯងផង

ទាំងបបួលជនដទៃ ក្នុងការវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង វៀរចាកការនិយាយកុហកដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយកុហកផង វៀរចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

# អសប្បុរិសសូត្រទី ២

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា មិនខ្មាសបាប មិនក្តៅនឹងបាប ជាអ្នកមិនចេះដឹង ខ្ជិលប្រអូស មិនមានស្មារតី មិនមានប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែង ជាងអសប្បុរស

តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានសទ្ធាផង មិនខ្មាសបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការមិនខ្មាសបាបផង មិនក្តៅទីងបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនក្តៅទីងបាបផង មិនបានចេះដឹងដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនចេះដឹងផង ខ្ជិលច្រអូសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការខ្ជិលច្រអូសផង មិនមានស្មារតីដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានស្មារតីផង មិនមានប្រាជ្ញាដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការមិនមានប្រាជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសទ្ធា ខ្មាសបាប ក្តៅទីងបាប ចេះដឹងច្រើន ប្រារព្ធព្យាយាម មានស្មារតី មានប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសទ្ធាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការបរិបូណ៌ដោយសទ្ធាផង ខ្មាសបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការខ្មាសបាបផង ក្តៅទីងបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការក្តៅទីងបាបផង ចេះដឹងច្រើនដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចេះដឹងច្រើនផង

ប្រារព្ធព្យាយាមដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រារព្ធព្យាយាមផង មានស្មារតីដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមានស្មារតីផង បរិបូណ៌ដោយប្រាជ្ញាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការបរិបូណ៌ដោយប្រាជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

## សត្តកម្មសូត្រទី ៣

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែង ជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យរោយរាយឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាអសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការសម្លាប់សត្វផង កាន់យកទ្រព្យ ដែលគេមិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការកាន់យកទ្រព្យដែល

គេមិនបានឲ្យផង ប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយផង និយាយពាក្យកុហកដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការនិយាយពាក្យកុហកផង និយាយពាក្យញុះញង់ដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការនិយាយពាក្យញុះញង់ផង និយាយពាក្យទ្រគោះ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យទ្រគោះផង និយាយពាក្យរោយរាយឥតប្រយោជន៍ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យរោយរាយឥតប្រយោជន៍ផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយពាក្យកុហក វៀរចាកការនិយាយពាក្យញុះញង់ វៀរចាកការនិយាយពាក្យទ្រគោះ វៀរចាកការនិយាយពាក្យរោយរាយឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកសម្លាប់សត្វផង វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលអ្នក

ជទៃក្នុងការវៀរចាកកាន់យកទ្រព្យដែលគេមិនបានឲ្យផង វៀរចាកការប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាក ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយផង វៀរចាកការនិយាយពាក្យកុហក ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យ កុហកផង វៀរចាកការនិយាយពាក្យញុះញង់ដោយខ្លួនឯងផង ទាំងបបួល ជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យញុះញង់ផង វៀរចាកការនិយាយ ពាក្យទ្រគោះដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការ និយាយពាក្យទ្រគោះផង វៀរចាកការនិយាយពាក្យរោយរាយឥតប្រយោជន៍ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យ រោយរាយឥតប្រយោជន៍ផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ក្រៃលែងជាងសប្បុរស ។

## ធសកម្មសូត្រទី ៤

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរស ក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ ពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ច្រើន ដោយអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅ

ថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង ។បេ។ ច្រើនដោយអភិជ្ឈាដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងអភិជ្ឈាផង មានចិត្តព្យាបាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាបាទផង ជាមិច្ឆាទិដ្ឋិដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងមិច្ឆាទិដ្ឋិផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។បេ។ មិនច្រើនដោយអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងកិរិយាវៀរចាកការសម្លាប់សត្វផង ។បេ។ មិនច្រើនដោយអភិជ្ឈាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានអភិជ្ឈាផង មិនមានចិត្តព្យាបាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានព្យាបាទផង ជាសម្មាទិដ្ឋិដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសម្មាទិដ្ឋិផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

# អដ្ឋង្គិកសូត្រទី ៥

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីយល់ខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានការព្យាយាមខុស មានសេចក្តីរឭកខុស មានការតាំងចិត្តខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីយល់ខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងសេចក្តីយល់ខុសផង មានសេចក្តីត្រិះរិះខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីត្រិះរិះខុសផង មានវាចាខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងវាចាខុសផង មានការងារខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការងារខុសផង មានការចិញ្ចឹមជីវិតខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចិញ្ចឹមជីវិតខុសផង មានការព្យាយាមខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាយាមខុសផង មានសេចក្តីរឭកខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីរឭកខុសផង មានការតាំងចិត្តខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការតាំងចិត្តខុសផង ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានការព្យាយាមត្រូវ មានសេចក្តីរឭកត្រូវ មានការតាំងចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការឃើញត្រូវផង មានសេចក្តីត្រិះរិះត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីត្រិះរិះត្រូវផង មានវាចាត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងវាចាត្រូវផង មានការងារត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការងារត្រូវផង មានការចិញ្ចឹមជីវិតត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចិញ្ចឹមជីវិតត្រូវផង មានការព្យាយាមត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាយាមត្រូវផង មានសេចក្តីរឭកត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីរឭកត្រូវផង មានការតាំងចិត្តត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការតាំងចិត្តត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

# ទសមគ្គសូត្រទី ៦

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្ដីយល់ឃើញខុស ។បេ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្ដីយល់ឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្ដីយល់ឃើញខុសផង ។បេ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្ដីយល់ឃើញត្រូវ ។បេ។ មានញាណត្រូវ មានការរួចត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា

សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។បេ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងញាណត្រូវផង មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

# អដ្ឋកថា
# សប្បុរិសវគ្គទី ១

## សិក្ខាបទសូត្រទី ១ ជាដើម

[ ៥១-៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទសូត្រទី ១ ជាដើម នៃបណ្ណាសកទី ៥ ដូចតទៅនេះ បទថា **អសប្បុរិសំ** បានដល់ បុរសលាមក បុរសទទេ បុរសវង្វេង បុរសដែលធ្វើឲ្យខ្វាក់ដោយអវិជ្ជា ។ បទថា **អសប្បុរិសតរំ** បានដល់ ក្រៃលែងជាងអសប្បុរស គប្បីជ្រាបសប្បុរសទាំង ២ ក្រៅអំពីនេះ ដោយផ្ទុយគ្នាដែលពោលហើយ ។ ពាក្យដ៏សេសក្នុងបទនេះ ងាយយល់ទាំងអស់ហើយ ។

ក្នុងសូត្រ ៥ បន្ទាប់អំពីនេះ ក៏ដូចក្នុងសូត្រនេះ ។ ពិតហើយ សូត្រទាំងនោះ សូត្រទី ១ ត្រាស់ដោយពៀរ ៥ សូត្រទី ២ ត្រាស់ដោយអសទ្ធម្ម សូត្រទី ៣ ត្រាស់ដោយកាយទ្វារ វចីទ្វារ សូត្រទី ៤ ត្រាស់ដោយមនោទ្វារ សូត្រទី ៥ ត្រាស់ដោយមិច្ឆត្តៈ ៨ សូត្រទី ៦ ត្រាស់ដោយមិច្ឆត្តៈ ១០ ។ល។

**អដ្ឋកថា សិក្ខាបទសូត្រទី ១ ជាដើម ចប់**

# សុត្តន្តបិដក

## បឋមចាបធម្មសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវបុគ្គលលាមកផង នូវបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមកផង នូវបុគ្គលល្អផង នូវបុគ្គលល្អក្រៃលែងជាងបុគ្គលល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីឃើញខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង ។បេ។ មានសេចក្តីឃើញដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។បេ។ មានសេចក្តីឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អក្រៃលែងជាងបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងកិរិយាវៀរចាកការសម្លាប់សត្វផង ។បេ។

មានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ។

# អដ្ឋកថា

## បឋមបាបធម្មសូត្រ

[ ៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបាបធម្មសូត្រទី ៧ ដូចតទៅនេះ បទថា **បាបំ** បានដល់ បុគ្គលលាមក គឺបុគ្គលសៅហ្មង ។ បទថា **កល្យាណំ** បុគ្គលចម្រើន គឺបុគ្គលមិនមានទោស ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា បឋមបាបធម្មសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយចាបធម្មសូត្រទី ៨

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលលាមកផង នូវបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមកផង នូវបុគ្គលល្អផង នូវបុគ្គលល្អក្រៃលែងជាងបុគ្គលល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ មានសេចក្តីឃើញខុស ។បេ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។បេ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវ ។បេ។ មានញាណត្រូវ មានការរួចត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អក្រៃលែងជាងបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង

ទាំងបបួលជនដទៃ ក្នុងសេចក្ដីឃើញត្រូវផង ។បេ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណត្រូវផង មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ។

# អដ្ឋកថា

## ទុតិយបាបធម្មសូត្រ

ក្នុងទុតិយបាបធម្មសូត្រទី ៨ ក៏មានន័យនេះដូចគ្នា ។

អដ្ឋកថាទុតិយបាបធម្មសូត្រទី ៨ ចប់

# សុត្តន្តបិដក

## តតិយបាបធម្មសូត្រទី ៩

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌ល្អផង នូវបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ

ផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីឃើញខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង ។បេ។ មានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ មានសេចក្តីឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯង ទាំងបបួលជនដទៃ ក្នុងកិរិយាវៀរចាកបាណាតិបាតផង ។បេ។ មានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ ។

# អដ្ឋកថា

## តតិយបាបធម្មសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយបាបធម្មសូត្រទី ៩ ដូចតទៅនេះ បទថា **បាបធម្មំ** បានដល់ ធម៌លាមក ។ បទថា **កល្យាណធម្មំ** បានដល់ ធម៌ដែលមិនមានទោស ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថា តតិយបាបធម្មសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ចតុត្ថបាបធម្មសូត្រទី ១០

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌ល្អផង នូវបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវពាក្យនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីយល់ឃើញខុស ។បេ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមាន

ធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។បេ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ក្រៃលែង ជាងបុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកឃើញត្រូវ ។បេ។ មានញាណត្រូវ មានការរួចត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។បេ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណត្រូវផង មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ ។

*សប្បុរិសវគ្គទី ១ ចប់*

## ឧទ្ទាននៃសប្បុរិសវគ្គនោះ គឺ

*និយាយអំពីសិក្ខាបទ ១ អំពីបុគ្គលមិនមានសទ្ធា ១ អំពីធម៌ ៧ នាំឲ្យវិនាស ១ មួយយ៉ាងទៀត និយាយអំពីកម្មទាំង១០ ប្រការ ១ អំពីមគ្គប្រកបដោយអង្គ ៨ ប្រការ ១ អំពីមគ្គ ១០ ប្រការ ១ អំពីបាបធម៌ ២ ប្រការ ១ អំពីបាបធម៌ ២ ប្រការដទៃទៀត ១ ។*

# អដ្ឋកថា

## ចតុត្ថបាបធម្មសូត្រ

*[ ៦០ ] ក្នុងអដ្ឋកថាចតុត្ថធម្មបាបសូត្រទី ១០ ក៏មានន័យនេះដូចគ្នា ។ ក្នុងវគ្គនេះ លោកពោលដល់បដិបទារបស់បុគ្គលដែលគ្រប់គ្រងផ្ទះទាំង ១០ សូត្រ ។ បើគ្រហស្ថជាព្រះសោតាបន្ន ព្រះសកទាគាមី រមែងគួរដូចគ្នា ។*

**អដ្ឋកថា ចតុត្ថបាបធម្មសូត្រទី ១០ ចប់**

**សប្បុរិសវគ្គទី ១ ចប់**

# សោភនវគ្គទី ២

## បរិសាសូត្រទី ១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ ការទ្រុស្តបរិស្សនេះមាន ៤ យ៉ាង ។ ការទ្រុស្តបរិសទ្យ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសកទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ការទ្រុស្តបរិសទ្យមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើបរិសទ្យឲ្យល្អមាន ៤ យ៉ាង ។ ការធ្វើបរិសទ្យឲ្យល្អ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីល មានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមានសីល មានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំង-ឡាយ ឧបាសកមានសីល មានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាមានសីល មានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើបរិសទ្យឲ្យល្អមាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

# សោភនវគ្គទី ២

## បរិសាសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិសាសូត្រទី ១ នៃសោភនវគ្គទី ២ ដូចតទៅនេះ ឈ្មោះថា **បរិសទូសនា** ព្រោះប្រទូស្តបរិស័ទ ។ ឈ្មោះថា **បរិសសោភនា** ព្រោះញុំាងបរិស័ទឲ្យស្អាត ។ល។

**អដ្ឋកថា បរិសាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទិដ្ឋិសូត្រទី ២

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ( គឺប្រកប ) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ មិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូច

ជាគេនាំយកទៅតម្កល់ទុក ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ( គឺប្រកប ) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ សម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

# អដ្ឋកថា

## ទិដ្ឋិសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិសូត្រទី ២ ដូចតទៅនេះ មិច្ឆាទិដ្ឋិ សូម្បីទាក់ទងក្នុងមនោទុច្ចរិត លោកពោលដោយឡែក ព្រោះមានទោសច្រើន ចំណែកសម្មាទិដ្ឋិ លោកពោលដោយជាបដិបក្ខចំពោះមិច្ឆាទិដ្ឋិនោះ ។

**អដ្ឋកថា ទិដ្ឋិសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អកតញ្ញុតាសូត្រទី ៣

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល

ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេច ។ ( គឺប្រកប ) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ អកតញ្ញូអកតវេទិតា ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេច ។ ( គឺប្រកប ) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ កតញ្ញូកតវេទិតា ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

# អដ្ឋកថា

## អកតញ្ញុតាសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអកតញ្ញុតាសូត្រទី ៣ ដូចតទៅនេះ បទថា **អកតញ្ញុតា អកតវេទិតា** បានដល់ ដោយការមិនដឹងគុណ ដោយការមិនតបគុណ ។ ទាំង ២ បទនោះ ដោយអត្ថក៏តែមួយនោះឯង ។ ឯធម៌

ក្នុងសុក្កបក្ខ ក៏មានន័យនេះដូចគ្នា ។l៚

អដ្ឋកថា អកតញ្ញុតាសូត្រទី ៣ ចប់

# សុត្តន្តបិដក

## បាណាតិបាតសូត្រទី ៤

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺបុគ្គលជាអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយពាក្យកុហក ១ ។បេ។ គឺបុគ្គលជាអ្នកវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយពាក្យកុហក ១ ។បេ។

# អដ្ឋកថា

## បាណាតិបាតសូត្រ

[ ៦៤ ] បាណាតិបាតសូត្រទី ៤ លោកពោលដោយកម្មកិលេស ៤ និងធម៌ជា បដិបក្ខចំពោះកម្មកិលេសនោះ ។

**អដ្ឋកថាបាណាតិបាតសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមមគ្គសូត្រទី ៥

[ ៦៥ ] បុគ្គលមានសេចក្តីឃើញខុស ១ មានសេចក្តីត្រិះរិះខុស ១ មានវាចាខុស ១ មានការងារខុស ១ ។បេ។ បុគ្គលមានសេចក្តីឃើញត្រូវ ១ មានសេចក្តីត្រិះរិះត្រូវ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ ។បេ។

# អដ្ឋកថា

## បឋមមគ្គសូត្រ

[ ៦៥ ] បឋមមគ្គសូត្រទី ៥ លោកពោលដោយមិច្ឆត្តៈ ៤ ខាងដើម នៃសុក្កបក្ខ ( សម្មត្តៈ ) ។

**អដ្ឋកថា បឋមមគ្គសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយមគ្គសូត្រទី ៦

[ ៦៦ ] បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតខុស ១ មានសេចក្តីព្យាយាមខុស ១ មានសេចក្តីរឭកខុស ១ មានសេចក្តីតាំងចិត្តខុស ១ ។បេ។ បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតត្រូវ ១ មានសេចក្តីព្យាយាមត្រូវ ១ មានសេចក្តីរឭកត្រូវ ១ មានសេចក្តីតាំងចិត្តត្រូវ ១ ។បេ។

# អដ្ឋកថា

## ទុតិយមគ្គសូត្រ

[ ៦៦ ] ទុតិយមគ្គសូត្រទី ៦ លោកពោលដោយមិច្ឆត្តៈ ៤ ដែលសល់ ។ល។

**អដ្ឋកថា ទុតិយមគ្គសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមវោហារបថសូត្រទី ៧

[ ៦៧ ] បុគ្គលអ្នកពោលថា ឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថា ឮក្នុងរបស់ដែលមិនបានឮ ១ ពោលថា ហិតជញ្ជក់ប៉ះពាល់ក្នុង

របស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា ដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។បេ។ បុគ្គលអ្នកពោលថា មិនឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថា មិនឮក្នុងរបស់ដែលមិនបានឮ ១ ពោលថាមិន បានហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា មិនដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។បេ។

# អដ្ឋកថា

## បឋមវោហារបថសូត្រ

[ ៦៧ ] បឋមវោហារបថសូត្រទី ៧ លោកពោលអនរិយវោហារ និងអរិយវោហារ ។

**អដ្ឋកថា បឋមវោហារបថសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយវោហារបថសូត្រទី ៨

[ ៦៨ ] បុគ្គលអ្នកពោលថា មិនឃើញក្នុងរបស់ដែលបានឃើញ ១ ពោលថា មិនឮក្នុងរបស់ដែលបានឮ ១ ពោលថា មិនបានហិតជញ្ជក់ប៉ះ

ពាល់ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា មិនដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។បេ។ បុគ្គលអ្នកពោលថា ឃើញក្នុងរបស់ដែលបានឃើញ ១ ពោលថា ឮក្នុងរបស់ដែលបានឮ ១ ពោលថា ហិតជញ្ជក់ប៉ះ ពាល់ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា ដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។បេ។

# សុត្តន្តបិដក

## អហិរិកសូត្រទី ៩

[ ៦៩ ] បុគ្គលជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ មិនខ្មាសបាប ១ មិនក្តៅនឹងបាប ១ ។បេ។ បុគ្គលជាអ្នកមានសទ្ធា ១ មានសីល ១ ខ្មាសបាប ១ ក្តៅនឹងបាប ១ ។បេ។

## ទុប្បញ្ញាសូត្រទី ១០

[ ៧០ ] បុគ្គលជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ ខ្ជិលច្រអូស ១ គ្មានបញ្ញា ១ ។បេ។ បុគ្គលជាអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេយកទៅតម្កល់ទុក ។

សោភនវគ្គទី ២ ចប់

## ឧទ្ទាននៃសោភនវគ្គនោះ គឺ

*និយាយអំពីការទ្រុស្តបរិសទ្យ និងការធ្វើបរិសទ្យឲ្យល្អ ១ អំពីជនអ្នកប្រកបដោយធម៌មានមិច្ឆាទិដ្ឋិជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ មានអកតញ្ញូតាជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ មានបាណាតិបាតជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ ជាផ្លូវ ២ ប្រការ ១ អំពីគន្លងនៃវោហារ ២ យ៉ាងដែលបុគ្គលពោលហើយ ១ អំពីជនអ្នកប្រកបដោយធម៌ មានហិរិជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ មានការមិនមានបញ្ញាជាដើម ១ ។*

# អដ្ឋកថា

## ទុតិយវោហារបថសូត្រទី ៨ ជាដើម

*[ ៦៨-៧០ ] ទុតិយវោហារបថសូត្រទី ៨ ជាដើម លោកពោលដោយអសទ្ធម្ម ដែលជាបដិបក្ខចំពោះសុក្កធម៌នោះ ៗ ធម៌ដែលជាសុក្កបក្ខ លោកពោលលាយឡំ ដោយលោកិយផង និងលោកុត្តរផង ក្នុងសូត្រទាំងពួង ៗ ក្នុង ៩ សូត្រ លោកពោលទុកក្នុងមគ្គដូច្នេះក៏ពិត តែទោះជាយ៉ាងនេះ ក៏រមែងបានមគ្គ ៣ និងផល ៣ ផងដែរ ។*

**អដ្ឋកថា ទុតិយវោហារបថសូត្រទី ៨ ជាដើមចប់**

**សោភនវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ទុច្ចរិតវគ្គទី ៣

### ទុច្ចរិតសូត្រទី ១

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតនេះ មាន ៤ យ៉ាង ។ វចីទុច្ចរិត ៤ យ៉ាង តើដូចម្តេច ។ គឺការនិយាយកុហក ១ និយាយញុះញង់ ១ និយាយពាក្យទ្រគោះ ១ និយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។ ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិតនេះ មាន ៤ យ៉ាង ។ វចីសុចរិត ៤ យ៉ាង តើដូចម្តេច ។ គឺនិយាយពាក្យពិត ១ មិននិយាយពាក្យញុះញង់ ១ និយាយពាក្យពីរោះ ១ និយាយដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិតមាន ៤ យ៉ាងនេះឯង ។

### ទិដ្ឋិសូត្រទី ២

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ( គឺប្រកប ) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ មិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ

ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួនមិនឲ្យមានគុណជីកចោល កម្ចាត់ចោលផង មិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ( គឺប្រកប ) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ សម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួន មិនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកមិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។

## អកតញ្ញូសូត្រទី ៣

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ( គឺប្រកប ) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ អកតញ្ញូអកតវេទិតា ១ ។បេ។ ( ប្រកប ) ដោយកាយសុចរិត ១ វចីសុចរិត ១

មនោសុចរិត ១ កតញ្ញុកតវេទិតា ១ ។បេ។

# ចាណាតិបាតសូត្រទី ៤

[ ៧៤ ] បុគ្គលជាអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយពាក្យកុហក ១ ។បេ។ បុគ្គលជាអ្នកវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ វៀរចាកការនិយាយកុហក ១ ។បេ។

# បឋមមគ្គសូត្រទី ៥

[ ៧៥ ] បុគ្គលជាអ្នកមានសេចក្តីឃើញខុស ១ មានសេចក្តីត្រិះរិះខុស ១ មានវាចាខុស ១ មានការងារខុស ១ ។បេ។ បុគ្គលជាអ្នកមានសេចក្តីឃើញត្រូវ ១ មានសេចក្តីត្រិះរិះត្រូវ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ ។បេ។

# ទុតិយមគ្គសូត្រទី ៦

[ ៧៦ ] បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតខុស ១ មានការព្យាយាមខុស ១ មានការរឭកខុស ១ មានការតាំងចិត្តខុស ១ ។បេ។ បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតត្រូវ ១ មានព្យាយាមត្រូវ ១ មានការរឭកត្រូវ ១ មានការតាំងចិត្តត្រូវ ១ ។បេ។

# បឋមវោហារបថសូត្រទី ៧

[ ៧៧ ] បុគ្គលអ្នកពោលថា ឃើញ ក្នុងរបស់ដែលមិនបានឃើញ ១ ពោលថា ឮក្នុងរបស់ដែលមិនបានឮ ១ ពោលថា ហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា ដឹងច្បាស់ ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។បេ។ បុគ្គលអ្នកពោលថា មិនឃើញ ក្នុងរបស់ដែលមិនបានឃើញ ១ ពោលថា មិនឮ ក្នុងរបស់ដែលមិនបានឮ ១ ពោលថា មិនបានហិតជញ្ជក់ប៉ះពាល់ ក្នុងរបស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា មិនដឹងច្បាស់ ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។បេ។

# ទុតិយវោហារបថសូត្រទី ៨

[ ៧៨ ] បុគ្គលអ្នកពោលថា មិនឃើញ ក្នុងរបស់ដែលបានឃើញ ១ ពោលថា មិនឮ ក្នុងរបស់ដែលបានឮ ១ ពោលថា មិនបានហិតជញ្ជក់ប៉ះពាល់ ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា មិនដឹងច្បាស់ ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។បេ។ បុគ្គលអ្នកពោលថា ឃើញ ក្នុងរបស់ដែលបានឃើញ ១ ពោលថា ឮ ក្នុងរបស់ដែលបានឮ ១ ពោលថា ហិតជញ្ជក់ប៉ះពាល់ ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា ដឹងច្បាស់ ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។បេ។

# អហិរិកសូត្រទី ៩

[ ៧៩ ] បុគ្គលអ្នកមិនមានសទ្ធា ១ អ្នកទ្រុស្តសីល ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីក្តៅនឹងបាប ១ ។បេ។ បុគ្គលជាអ្នកមាន

សទ្ធា ១ ជាអ្នកមានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីក្តៅនឹងបាប ១ ។បេ។

## ធុបញ្ញាសូត្រទី ១០

[ ៨០ ] បុគ្គលអ្នកមិនមានសទ្ធា ១ អ្នកទ្រុស្តសីល ១ មានសេចក្តីខ្ជិលច្រអូស ១ មិនមានបញ្ញា ១ ។បេ។ បុគ្គលអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួន មិនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកមិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។

## កវីសូត្រទី ១១

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញនេះមាន ៤ ពួក ។ អ្នកប្រាជ្ញ ៤ ពួក តើដូចម្តេច ។ គឺអ្នកប្រាជ្ញព្រោះគិត ១ អ្នកប្រាជ្ញព្រោះស្តាប់ ១ អ្នកប្រាជ្ញព្រោះអាស្រ័យសេចក្តី ១ អ្នកប្រាជ្ញព្រោះប្រាជ្ញាវាងវៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញ មាន ៤ ពួកនេះឯង ។

ទុច្ចរិតវគ្គទី ៣ ចប់

# ឧទ្ទាននៃទុច្ចរិតវគ្គនោះ គឺ

និយាយអំពីទុច្ចរិត ១ អំពីមិច្ឆាទិដ្ឋិ ១ អំពីបុគ្គលប្រកប ដោយធម៌ មានអកតញ្ញុតាជាដើម ១ អំពីបុគ្គលប្រកប ដោយធម៌ មានបាណាតិបាតជាដើម ១ អំពីផ្លូវ ២ ប្រការ ១ អំពីគន្លងពាក្យពោល ២ ប្រការដែលពោល ១ អំពី បុគ្គលប្រកបដោយធម៌ មានសេចក្តីខ្មាសបាបជាដើម ១ អំពីបុគ្គលប្រកបដោយធម៌ មានមិនមានប្រាជ្ញាជាដើម ១ អំពីអ្នកប្រាជ្ញ ៤ ពួក ១ ។

# អដ្ឋកថា

# ទុច្ចរិតវគ្គទី ៣

## ទុច្ចរិតសូត្រទី ១ ជាដើម

[ ៧១-៨១ ] *ទុច្ចរិតសូត្រទី ១ ជាដើម នៃទុច្ចរិតវគ្គទី ៣ មានអត្ថងាយយល់ទាំងអស់ហើយ ក្នុងកវីសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា បុគ្គលដែលគិតហើយ ទើបចងបទកវី ឈ្មោះថា* **ចិន្តាកវី** *។ បុគ្គលដែលស្តាប់ហើយ ទើបចងបទកវី ឈ្មោះថា* **សុតកវី** *។ បុគ្គលដែលអាស្រ័យអត្ថ ហើយចងបទកវី ឈ្មោះថា* **អត្ថកវី** *។ បុគ្គលចងដោយបដិភាណរបស់ខ្លួនក្នុងខណៈនោះឯង ដូចជាព្រះវង្គីសត្ថេរជាដើម ឈ្មោះថា* **បដិភាណកវី** ៕៚

អដ្ឋកថា ទុច្ចរិតសូត្រទី ១ ជាដើមចប់

# សុត្តន្តបិដក

# កម្មវគ្គទី ៤

## សង្ខិត្តសូត្រទី ១

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅ មានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ ប្រភេទនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

# អដ្ឋកថា

# កម្មវគ្គទី ៤

## សន្ខិត្តសូត្រ

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្ខិត្តសូត្រទី ១ នៃកម្មវគ្គទី ៤ ដូចតទៅនេះ បទថា **កណ្ហំ** បានដល់ កម្មខ្មៅ គឺអកុសលកម្មបថ ១០ ។ បទថា **កណ្ហវិបាកំ** បានដល់ មានវិបាកខ្មៅ ព្រោះកើតក្នុងអបាយ ។ បទថា **សុក្កំ** បានដល់ កម្មស គឺកុសលកម្មបថ ១០ ។ បទថា **សុក្កវិបាកំ** បានដល់ មានវិបាកស ព្រោះកើតក្នុងស្ថានសួគ៌ ។ បទថា **កណ្ហំ សុក្កំ** បានដល់ កម្មលាយគ្នា ។ បទថា **កណ្ហសុក្កវិបាកំ** បានដល់ មានវិបាកទាំងសុខ និងទុក្ខ ។ ពិតហើយ បុគ្គលធ្វើកម្មលាយគ្នា ហើយកើតក្នុងកំណើតតិរច្ឆានដោយអកុសល ក្នុងឋានៈជាមង្គលហត្ថីជាដើម សោយសុខក្នុងបច្ចុប្បន្នដោយកុសល ។ បុគ្គលកើតក្នុងរាជត្រកូលដោយកុសល រមែងសោយទុក្ខក្នុងបច្ចុប្បន្នដោយអកុសល ។ បទថា **អកណ្ហំ អសុក្កំ** លោកបំណងយកមគ្គញាណ ៤ ដែលធ្វើកម្មឲ្យអស់ទៅ ។ ពិតហើយ កម្មនោះបើជាកម្មខ្មៅ ក៏គប្បីឲ្យវិបាកខ្មៅ បើជាជាកម្មស គប្បីឲ្យវិបាកស តែមិនខ្មៅមិនស ព្រោះមិនឲ្យវិបាកទាំង ២ ដូចពោលមកនេះ ជាអត្ថក្នុងសេចក្តីនេះ ៕

**អដ្ឋកថា សន្ខិត្តសូត្រទី ១ ចប់**

# សុត្តន្តបិដក

## វិត្ថារសូត្រទី ២

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មសមានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារ ប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោស លុះបុគ្គលនោះតាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារ ប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោស ហើយ រមែងចូលទៅកាន់លោក ដែលប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយប្រកបដោយទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកប្រកបដោយទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ ប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងរងវេទនាប្រកបដោយទុក្ខ មានសេចក្តីលំបាកដោយពិត ដូចពួកសត្វដែលកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូច

ម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយ-សង្ខារ មិនមានទោស តាក់តែងវចីសង្ខារ មិនមានទោស តាក់តែងមនោ-សង្ខារ មិនមានទោស ។ លុះបុគ្គលនោះ តាក់តែងកាយសង្ខារ មិនមានទោស តាក់តែងវចីសង្ខារ មិនមានទោស តាក់តែងមនោសង្ខារ មិនមានទោស រមែងចូលទៅកាន់លោកដែលមិនមានទុក្ខ ។ ផស្សៈទាំងឡាយដែលមិនមានទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកមិនមានទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយមិនមានទុក្ខពាល់ត្រូវហើយ រមែងរងនូវវេទនាមិនមានទុក្ខ មានតែសេចក្តីសុខដោយពិត ដូចពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មសមានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ។ លុះបុគ្គលនោះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ រមែងចូលទៅកាន់លោក មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ ផស្សៈទាំងឡាយ មានទុក្ខខ្លះ មិនមានទុក្ខខ្លះ តែងពាល់ត្រូវនូវបុគ្គលដែលចូលទៅកាន់លោក មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ បុគ្គលនោះ

កាលផស្សៈទាំងឡាយ មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ពាល់ត្រូវហើយ រមែងរងនូវវេទនា មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ជាវេទនាមានសុខ និងទុក្ខលាយគ្នា ដូចមនុស្សពួកខ្លះ ទេវតាពួកខ្លះ វិនិបាតពួកខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំង-ឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំង ៤ នោះ ចេតនាដើម្បីលះកម្មខ្មៅ មានវិបាក ខ្មៅឯណា ចេតនាដើម្បីលះកម្មស មានវិបាកសឯណា ចេតនាដើម្បីលះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសឯណា ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

# អដ្ឋកថា

## វិត្ថារសូត្រ

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិត្ថារសូត្រទី ២ ដូចតទៅនេះ បទថា **សព្យាបជ្ឈំ** គឺមានទោស ។ បទថា **កាយសង្ខារំ** បានដល់ ចេតនាក្នុង

*កាយទ្វារ ។ បទថា* **អភិសង្ខរោតិ** *បានដល់ តាក់តែងដ៏ក្រៃលែង គឺប្រមូលមក ។ ក្នុង ២ បទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា* **សព្យាបជ្ឈំ លោកំ** *បានដល់ លោកមានទុក្ខ ។ បទថា* **សព្យាបជ្ឈា ផស្សា** *បានដល់ ផស្សៈជាវិបាកមានទុក្ខ ។ បទថា* **សព្យាបជ្ឈំ វេទនំ វេទិយតិ** *បានដល់ សោយវេទនាមានវិបាក ប្រព្រឹត្តទៅដោយការបៀតបៀន ។ បទថា* **ឯកន្តទុក្ខំ** *បានដល់ ជាទុក្ខដោយចំណែកមួយប៉ុណ្ណោះ គឺមិនលាយដោយសុខ ។*

*បទថា* **សេយ្យថាបិ** *ក្នុងបទនេះថា* **សេយ្យថាបិ សត្តា នេរយិកា** *គប្បីឃើញថា ជានិបាត ចុះក្នុងអត្ថថា ជាឧទាហរណ៍ ។ ដោយបទនោះ ទ្រង់សម្តែងដល់សត្វនរកតែម្យ៉ាង សត្វដទៃឈ្មោះថា ប្រហែលគ្នានឹងសត្វនរកនោះមិនមាន ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួង ដោយឧបាយនេះ ។*

*ក្នុងបទថា* **សេយ្យថាបិ មនុស្សា** *ជាដើម ពោលដល់មនុស្សមុន សុខវេទនា រមែងកើតតាមកាល ទុក្ខវេទនាក៏កើតតាមកាល ។ ឯក្នុងបទនេះថា* **ឯកច្ចេ ច ទេវា** *គប្បីឃើញថា ទេវតាជាន់កាមាវចរ ពិតហើយ ទេវតាឃើញទេវតាដែលមានសក្តិធំ ជាងកាមាវចរទេវតាទាំងនោះ រមែងដល់នូវទុក្ខតាមកាល ដោយកិច្ចថា ត្រូវក្រោកអំពីទីអង្គុយ ត្រូវដោះសំពត់ដណ្តប់ ធ្វើសំពត់ឆៀងស្មា ត្រូវផ្គងអញ្ជលីជាដើម ។ កាលសោយទិព្វសម្បត្តិ រមែងដល់នូវសុខតាមកាល ។ ក្នុងបទថា* **ឯកច្ចេ ច វិនិបាតិកា** *គប្បីឃើញថា ជាវេមានិកប្រេតពួកខ្លះ ។ វេមានិកប្រេតទាំងនោះ សោយសុខក្នុងកាលមួយ*

សោយទុក្ខក្នុងកាលមួយជានិរន្តរ៍ សត្វទាំងឡាយ មាននាគ គ្រុឌ ដំរី និង សេះជាដើម រមែងមានទាំងសុខ និងទុក្ខលាយឡំគ្នាដូចមនុស្សដែរ ។ ក្នុងបទថា **បហានាយ យា ចេតនា** នេះ គប្បីជ្រាបមគ្គចេតនាដែលដល់នូវវដ្ដៈ និងវិវដ្ដៈ ។ ពិតហើយ មគ្គចេតនានោះ រមែងប្រព្រឹត្តទៅដើម្បីការអស់នូវកម្ម ។ល។

**អដ្ឋកថាវិត្ថារសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សោណកាយនសូត្រទី ៣

[ ៨៤ ] គ្រានោះ ព្រាហ្មណ៍ឈ្មោះសិខាមោគ្គល្លាន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលរឭកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសិខាមោគ្គល្លានព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រ ព្រះគោតមចម្រើន កាលពីថ្ងៃមុនៗ យូរមកហើយ មាណពឈ្មោះសោណកាយនៈចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ ក៏និយាយនឹងខ្ញុំព្រះអង្គដូច្នេះថា ព្រះ

សមណគោតម បញ្ញត្តនូវការមិនធ្វើនូវកម្មទាំងពួង កាលព្រះអង្គបញ្ញត្តនូវការមិនធ្វើនូវកម្មទាំងពួង ឈ្មោះថា ពោលឧច្ឆេទ ( សេចក្តីដាច់សូន្យ ) នៃលោក បពិត្រព្រះអង្គដ៏ចម្រើន លោកនេះជាកម្មសច្ចៈ ( មានកម្មជាសភាវៈ ) ជាកម្មសមារម្ភដ្ឋាយី ( តាំងនៅដោយការធ្វើកម្ម ) ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមិនដែលបានឃើញសោណ-កាយនមាណពសោះ ការចរចាពាក្យមានសភាពយ៉ាងនោះ នឹងមានមកពីណា ។ ម្នាលព្រាហ្មណ៍ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលព្រាហ្មណ៍ កម្មខ្មៅ មានវិបាកខ្មៅក៏មាន ម្នាលព្រាហ្មណ៍ កម្មសមានវិបាកសក៏មាន ម្នាលព្រាហ្មណ៍ កម្មទាំងខ្មៅទាំងសមានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលព្រាហ្មណ៍ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលព្រាហ្មណ៍ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោស លុះបុគ្គលនោះ តាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារ ប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោសហើយ រមែងចូលទៅកាន់លោកប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយប្រកបដោយទុក្ខ រមែង

ពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកប្រកបដោយទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយពាល់ត្រូវហើយ រមែងរងនូវវេទនាប្រកបដោយទុក្ខ មានសេចក្ដីលំបាកដោយពិត ដូចពួកសត្វដែលកើតក្នុងនរក ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលព្រាហ្មណ៍ ចុះកម្មស មានវិបាកស តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មិនមានទោស តាក់តែងវចីសង្ខារ មិនមានទោស តាក់តែងមនោសង្ខារ មិនមានទោស លុះបុគ្គលនោះ តាក់តែងកាយសង្ខារ មិនមានទោស តាក់តែងវចីសង្ខារ មិនមានទោស តាក់តែងមនោសង្ខារ មិនមានទោសហើយ រមែងចូលទៅកាន់លោក ដែលមិនប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយដែលមិនប្រកបដោយទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកដែលមិនប្រកបដោយទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ មិនប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងទទួលនូវវេទនា មិនប្រកបដោយទុក្ខ មានតែសេចក្ដីសុខដោយពិត ដូចពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មស មានវិបាកស ។ ម្នាលព្រាហ្មណ៍ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ លុះបុគ្គលនោះ

តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ហើយរមែងចូលទៅកាន់លោកប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ផស្សៈទាំងឡាយ ប្រកបដោយ ទុក្ខខ្លះ មិនប្រកបដោយទុក្ខខ្លះ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោក ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ពាល់ត្រូវហើយ រមែងទទួលវេទនា ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ មានសុខ និងទុក្ខប្រឡំគ្នា ដូចមនុស្សពួកខ្លះ ទេវតាពួកខ្លះ វិនិបាតពួកខ្លះ ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលព្រាហ្មណ៍ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បណ្តាកម្ម ទាំង ៤ នោះ ចេតនាដើម្បីលះបង់កម្មខ្មៅ មានវិបាកខ្មៅឯណា ចេតនាដើម្បីលះបង់កម្មស មានវិបាកសឯណា ចេតនាដើម្បីលះបង់កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសឯណា ម្នាលព្រាហ្មណ៍ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលព្រាហ្មណ៍ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

# អដ្ឋកថា

## សោណកាយនសូត្រ

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោណកាយតនសូត្រទី ៣ ដូចតទៅ បទថា **សិខាមោគ្គល្លានោ** បានដល់ ព្រាហ្មណ៍មោគ្គល្លានគោត្រ ដែលមានផ្នួងសក់ជំតាំងនៅត្រង់កណ្តាលក្បាល ។ បទថា **បុរិមានិ** បានដល់ ថ្ងៃមុន តាំងអំពីថ្ងៃដែលកន្លងទៅហើយ ។ គប្បីជ្រាបថ្ងៃក្រៃលែងជាងថ្ងៃមុន ចាប់តាំងអំពីថ្ងៃទី ២ ជាដើម ។ បទថា **សោណកាយនោ** បានដល់ អន្តេវាសិករបស់ព្រាហ្មណ៍នោះឯង ។ បទថា **កម្មសច្ចាយំ ភោ លោកោ** បានដល់ លោកនេះមានកម្មជាសភាវៈ ។ បទថា **កម្មសមារម្ភដ្ឋាយី** សេចក្តីថា លោកនេះតាំងនៅដោយការសាងកម្ម គឺតាក់តែងកម្ម តាំងនៅមិនមែនមិនតាក់តែង ។ ពាក្យថា **ឧច្ឆិជ្ជតិ** គឺសម្តែង ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ខាងដើមនោះឯង ។៚

**អដ្ឋកថា សោណកាយនសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សិក្ខាបទសូត្រទី ៤

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មសមានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកនិយាយកុហក ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ បណ្ដាកម្មទាំង ៤ នោះ កម្មខ្មៅមានវិបាកខ្មៅឯណា ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់។

## អរិយមគ្គសូត្រទី ៩

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មសមានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកផ្ដាច់ផ្ដិលជីវិតមាតា ផ្ដាច់ផ្ដិលជីវិតបិតា ផ្ដាច់ផ្ដិលព្រះជន្មាយុព្រះអរហន្តទីណាស្រេច មានចិត្តប្រទូស្តព្រះតថាគត ញុំាង

លោហិតឲ្យពុះពងឡើង ជាអ្នកបំបែកសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមិនរំពៃទ្រព្យអ្នកដទៃ មានចិត្តមិនព្យាបាទ មានសេចក្តីយល់ឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះមិនមានទោសខ្លះ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំង ៤ នោះ កម្មខ្មៅ មានវិបាកខ្មៅឯណា ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់។

# ពោជ្ឈង្គសូត្រទី ៦

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្មទាំង ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅ មានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារប្រកបដោយទោស ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារមិនមានទោស ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះមិនមានទោសខ្លះ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ សេចក្តីយល់ឃើញត្រូវ ។បេ។ ការតម្កល់ចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា

កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

## សាវជ្ជសូត្រទី ៧

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មសមានវិបាកសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងសក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារប្រកបដោយទោស ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះកម្មសមានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មិនមានទោស ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មសមានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិន

មានទោសខ្លះ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ សតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

# អព្យាបជ្ឈសូត្រទី ៨

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចគេនាំមកទៅទម្លាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មប្រកដោយទោស ១ វចីកម្មប្រកដោយទោស ១ មនោកម្មប្រកបដោយទោស ១ ទិដ្ឋិប្រកដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល

ប្រកបធម៌ ៤ នេះ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

## សប្បុរិសសូត្រទី ៩

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មប្រកដោយទោស ១ វចីកម្មប្រកដោយទោស ១ មនោកម្មប្រកដោយទោស ១ ទិដ្ឋិប្រកដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

# អដ្ឋកថា

## សិក្ខាបទសូត្រជាដើម

[ ៨៥-៩០ ] ក្នុងសិក្ខាបទសូត្រទី ៤ ជាដើម មានអត្ថងាយយល់ហើយ ។ ក្នុងអដ្ឋមគ្គទាំងឡាយ លោកពោលថា ព្រោះព្រះយោគាវចរ

ចូលទៅតម្កល់ស្មារតី ហើយកំណត់ដោយបញ្ញា ដូច្នោះធម៌ទាំង ២ នោះឯង ជាកម្ម ធម៌ដ៏សេសជាអង្គប៉ុណ្ណោះ មិនមែនកម្ម ។ ក្នុងពោជ្ឈង្គក៏ន័យនេះដូចគ្នា ។ ចំណែកក្នុងអភិធម្ម លោកពណ៌នាកម្មទាំងអស់នោះថា ជាកម្មដែលសម្បយុត្តដោយចេតនា ដោយមិនផ្ទែកគ្នា ។៚

**អដ្ឋកថា សិក្ខាបទសូត្រទី ៤ ជាដើមចប់**

# សុត្តន្តបិដក

## សមណសូត្រទី ១០

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ២ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៣ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៤ ក៏មានក្នុងធម្មវិន័យនេះ បរប្បវាទ ( លទ្ធិ ) ទាំងឡាយសូន្យចាកពួកសមណៈដទៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបន្លឺសីហនាទដោយប្រពៃយ៉ាងនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់សំយោជនៈ ៣ ជាសោតាបន្នបុគ្គល មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ

នេះហៅថា សមណៈទី ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ២ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់សំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈស្រាលស្តើង ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយទើបធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមណៈទី ២ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ឱរម្ភាគិយសំយោជនៈ ៥ ជាឱបបាតិកកំណើត បរិនិព្វានក្នុងទីនោះ មិនបានវិលត្រឡប់ចាកលោកនោះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសមណៈទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសមណៈទី ៤ ។ ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ២ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៣ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៤ ក៏មានក្នុងធម្មវិន័យនេះ បរប្បវាទ ( លទ្ធិ ) ទាំងឡាយ សូន្យចាកពួកសមណៈដទៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរបន្លឺនូវសីហនាទ ដោយប្រពៃយ៉ាងនេះចុះ ។

# អដ្ឋកថា

## សមណសូត្រ

[ ៩១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងក្នុងសមណសូត្រទី ១០ ដូចតទៅនេះ បទថា **ឥធេវ** គឺក្នុងសាសនានេះប៉ុណ្ណោះ ។ ការមិនពិតប្រាកដនេះ គប្បីជ្រាបក្នុងបទដ៏សេស ។ ពិតហើយ សមណៈទី ២ ជាដើម ក៏មាននៅក្នុងសាសនានេះប៉ុណ្ណោះ មិនមានក្នុងសាសនាដទៃ ។ បទថា **សុញ្ញា** ប្រែថា ទទេ ។ បទថា **បរប្បវាទា** បានដល់ ទិដ្ឋិ ៦២ ដែលមកហើយ ក្នុងព្រហ្មជាលសូត្រទាំងអស់ គឺសស្សតវាទ ៤ ឯកច្ចសស្សតិកៈ ៤ អន្តានន្តិកៈ ៤ អមរាវិក្ខេបិកៈ ៤ អធិច្ចសមុប្បន្និកៈ ២ សញ្ញីវាទ ១៦ អសញ្ញីវាទ ៨ នេវសញ្ញីនាសញ្ញីវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ វាទៈរបស់អ្នកដទៃ ក្រៅអំពីធម្មវិន័យនេះ ឈ្មោះបរប្បវាទ ។ វាទៈទាំងអស់នោះ ទទេចាកសមណៈដែលតាំងនៅក្នុងផល ៤ នេះ ទាំងវាទៈទាំងនោះ ក៏មិនមានក្នុងធម្មវិន័យនេះ ។ ម្យ៉ាងទៀត វាទៈទាំងនោះ មិនមែនទទេចាកសមណៈទាំងនេះតែម្យ៉ាងប៉ុណ្ណោះទេ ថែមទាំងទទេចាកសមណៈ ១២ គឺសមណៈតាំងនៅក្នុងមគ្គ ៤ ខ្លះ សមណៈដែលប្រារព្ធវិបស្សនាដើម្បីជាប្រយោជន៍ដល់មគ្គ ៤ ខ្លះ ។ ព្រះមានព្រះភាគ ត្រាស់សំដៅសេចក្តីនេះ ទើបត្រាស់ក្នុងមហាបរិនិព្វានសូត្រថា

ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ ឆ្នាំ បានបួសហើយ ជាអ្នកស្វែងរកនូវកុសល ( សព្វញ្ញុតញ្ញាណ ) ម្នាលសុភទ្ទ កាលណាបើ

តថាគតបួសបានជាង ៥០ ឆ្នាំ ហើយញុំាងប្រទេស គឺវិបស្សនាមគ្គ ឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹង គឺអរិយមគ្គ ព្រោះហេតុនោះ សមណៈ ( ទី ១ ) ខាងក្រៅអំពីសាសនានៃតថាគតនេះ មិនមានឡើយ ។

សមណៈទី ២ ក៏មិនមាន សមណៈទី ៣ ក៏មិនមាន សមណៈទី ៤ ក៏មិនមាន លទ្ធិដទៃ ទទេចាកសមណៈអ្នកត្រាស់ដឹង ។

ពិតហើយ បុគ្គលប្រារព្ធវិបស្សនា លោកបំណងយកក្នុងបទថា ប្រទេស គឺវិបស្សនាមគ្គនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើសមណៈ ៣ ពួក គឺសមណៈដែលប្រារព្ធវិបស្សនា ដើម្បីសោតាបត្តិមគ្គ ១ សមណៈតាំងនៅក្នុងមគ្គ ១ សមណៈតាំងនៅក្នុងផល ១ រួមគ្នា ទើបត្រាស់ថា សមណៈក៏មិនមាន ដូច្នេះ ។ ទ្រង់ធ្វើសមណៈ ៣ ពួក គឺសមណៈដែលប្រារព្ធវិបស្សនា ដើម្បីសកទាគាមិមគ្គ ១ សមណៈដែលតាំងនៅក្នុងមគ្គ ១ សមណៈដែលតាំងនៅក្នុងផល ១ រួមគ្នា ទើបត្រាស់ថា សមណៈទី ២ ក៏មិនមាន ដូច្នេះ ។ ក្នុងសមណៈ ២ ពួកក្រៅពីនេះ ក៏មានន័យនេះដូចគ្នា ។ល។

**អដ្ឋកថាសមណសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## អានិសង្សសូត្រទី ១១

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការ កើតប្រាកដឡើងបាន ព្រោះអាស្រ័យសប្បុរស ។ អានិសង្ស ៤ ប្រការ តើដូចម្តេចខ្លះ ។ បុគ្គល ( អាស្រ័យសប្បុរស ) រមែងចម្រើនដោយសីលដ៏ប្រសើរ រមែងចម្រើនដោយសមាធិដ៏ប្រសើរ រមែងចម្រើនដោយបញ្ញាដ៏ប្រសើរ រមែងចម្រើនដោយវិមុត្តិដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការនេះ កើតឡើងប្រាកដបាន ព្រោះអាស្រ័យសប្បុរស ។

កម្មវគ្គទី ៤ ចប់

ឧទ្ទាននៃកម្មវគ្គនោះ គឺ

និយាយអំពីកម្ម ៤ យ៉ាង ដោយសង្ខេប និងពិស្តារ អំពីរឿងសោណកាយនមាណពពោលថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តកម្មទាំងពួង ថាជាអកិរិយវាទ អំពីកម្មទាំងខ្មៅទាំងសបែកជាសិក្ខាបទអំពីកម្មមិនខ្មៅមិនស បានដល់អរិយមគ្គ អំពីកម្មមិនខ្មៅមិនស បានដល់ពោជ្ឈង្គ អំពីកម្មប្រកដោយទោស ៤ យ៉ាង អំពីកម្មមិនមានទោស ៤ យ៉ាង អំពីសមណៈ ៤ ពួក អំពីអានិសង្សអាស្រ័យសប្បុរស ៤ យ៉ាង ។

# អដ្ឋកថា

## អានិសង្សសូត្រទី ១១

[ ៩២ ] ក្នុងអានិសង្សសូត្រទី ១១ មានអត្ថងាយយល់ទាំងហើយ ៕

### អដ្ឋកថាអានិសង្សសូត្រទី ១១ ចប់

### កម្មវគ្គទី ៤ ចប់

# សុត្តន្តបិដក
# អាបត្តិភយវគ្គទី ៥

## សង្ឃភេទសូត្រទី ១

[ ៩៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិ-តារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់សួរថា ម្នាលអានន្ទ អធិករណ៍នោះបានរម្ងាប់ហើយឬ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អធិករណ៍នោះនឹងរម្ងាប់អំពីណាបាន បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់អនុរុទ្ធដ៏មានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកសង្ឃ ឥតឈប់ឈរ ក្នុងរឿងនោះ ព្រះអនុរុទ្ធដ៏មានអាយុ ក៏មិនឃើញមានស្តីថាអ្វី សូម្បីតែ ១ ម៉ាត់ក៏គ្មាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ចុះអនុរុទ្ធធ្លាប់ចូលគំនិតក្នុងអធិករណ៍នាកណ្តាលសង្ឃពីកាលណាមក ម្នាលអានន្ទ អធិករណ៍ទាំងឡាយណាមួយកើតឡើង អធិករណ៍ទាំងនោះ គួរតែអ្នកទាំងឡាយផងសារីបុត្ត និងមោគ្គល្លានផង រម្ងាប់ មិនមែនទេឬ ។ ម្នាលអានន្ទ ភិក្ខុបាបកាលបើឃើញច្បាស់នូវអំណាចប្រយោជន៍ ៤ យ៉ាងនេះ រមែងត្រេកអរដោយការបំបែកសង្ឃ ។ អំណាចប្រយោជន៍ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាល

អានន្ទ ភិក្ខុបាបក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌លាមក មានអំពើមិនស្អាត មានមារយាទគួរឲ្យអ្នកផង រឭកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយក្នុង មានចិត្តទទឹកដោយរាគាទិក្កិលេស ជាមនុស្សជ្រោកជ្រាក ភិក្ខុបាបនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាភិក្ខុទ្រុស្តសីល មានធម៌លាមក មានអំពើមិនស្អាត មានមារយាទគួរឲ្យអ្នកផង រឭកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយក្នុង មានចិត្តទទឹកដោយរាគាទិក្កិលេស ជាមនុស្សជ្រោកជ្រាក កាលភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ១ នេះ ទើបត្រេកអរដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាប មានសេចក្តីយល់ខុសប្រកបដោយអន្តគ្គាហិកទិដ្ឋិ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាភិក្ខុមានសេចក្តីយល់ខុស ប្រកបដោយអន្តគ្គាហិកទិដ្ឋិ កាលភិក្ខុទាំងឡាយព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាប កាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ២ នេះ ទើបត្រេកអរដោយការបំបែក

សង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាបមានការចិញ្ចឹមជីវិតខុស សម្រេចជីវិតដោយមិច្ឆាជីវៈ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាអ្នកចិញ្ចឹមជីវិតខុស សម្រេចជីវិតដោយមិច្ឆាជីវៈ កាលភិក្ខុទាំង-ឡាយព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ៣ នេះ ទើបត្រេកអរដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាប ជាអ្នកប្រាថ្នាលាភ ប្រាថ្នាសក្ការៈ ប្រាថ្នាមិនឲ្យគេមើលងាយ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាអ្នកប្រាថ្នាលាភ ប្រាថ្នាសក្ការៈ ប្រាថ្នាមិនឲ្យគេមើលងាយ កាលភិក្ខុទាំងឡាយព្រមព្រៀងគ្នា មុខជានឹងមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាអញឡើយ បើបែកគ្នាហើយ នឹងធ្វើសក្ការៈ គោរពរាប់អានបូជាអញ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ៤ នេះ ទើបត្រេកអរដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ ភិក្ខុបាប កាលឃើញអំណាចប្រយោជន៍ទាំង ៤ នេះ រមែងត្រេកអរដោយការបំបែកសង្ឃ ។

# អដ្ឋកថា

# អាបត្តិភយវគ្គទី ៥

## សង្ឃភេទសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ឃភេទសូត្រទី ១ នៃអាបត្តិភយវគ្គទី ៥ ដូចតទៅនេះ បទថា **អបិ នុ តំ អានន្ទ អធិករណំ** សេចក្តីថា បណ្តាអធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើម អធិករណ៍ណាមួយកើតឡើងហើយដល់ភិក្ខុសង្ឃ ព្រះសាស្តាកាលសួរដល់រឿងអធិករណ៍នោះស្ងប់ហើយទើបត្រាស់យ៉ាងនេះ ។ បទថា **កុតោ តំ ភន្តេ** សេចក្តីថា ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អធិករណ៍នោះ រម្ងាប់ក្នុងទីណាបាន អធិករណ៍នោះរម្ងាប់បានដោយហេតុអ្វី ។ បទថា **កេវលកប្បំ** បានដល់ចំណែកមួយ ។ បទថា **សង្ឃភេទាយ ឋិតោ** បានដល់ ព្រះពាហិយៈនៅឈរក្រាញ ពោលនូវវាទៈជាមួយសង្ឃ ។ បទថា **តត្រាយស្មា** សេចក្តីថា កាលព្រះពាហិយៈនោះឈរក្រាញយ៉ាងនេះ ព្រះអនុរុទ្ធ ... ។ បទថា **ន ឯកវាចិកំបិ ភណិតព្វំ មញ្ញតិ** សេចក្តីថា ព្រះអនុរុទ្ធមិនយកធុរៈដែលនឹងពោលថា អាវុសោ លោកកុំពោលយ៉ាងនេះនឹងសង្ឃឡើយ ។ បទថា **វោយុញ្ជតិ** បានដល់ ខ្វល់ខ្វាយ គឺតាំងសេចក្តីព្យាយាម ។ បទថា **អត្ថវសេ** ប្រែថា អំណាចនៃហេតុ ។ បទថា **ឆាសេស្សន្តិ** បានដល់ ភិក្ខុទាំងឡាយមិនឲ្យខ្ញុំចូលទៅ ប្រានខ្ញុំចេញទៅចាកឧបោសថ និងបវារណា ។ បទដ៏

សេស គប្បីជ្រាបតាមបាលីនោះឯង ។

អដ្ឋកថា សង្ឃភេទសូត្រទី ១ ចប់

# សុត្តន្តបិដក

## អាបត្តិសូត្រទី ២

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ភ័យកើតព្រោះអាបត្តិនេះមាន ៤ យ៉ាង ។ ភ័យ ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចរាជបុរសចាប់ចោរប្រព្រឹត្តអាក្រក់ មកថ្វាយព្រះរាជា ហើយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស បុរសនេះ ជាចោរប្រព្រឹត្តអាក្រក់ សូមទ្រង់ដាក់ព្រះរាជអាជ្ញាចោរនេះ ។ ព្រះរាជាទ្រង់ត្រាស់នឹងរាជបុរសនោះយ៉ាងនេះថា នែប្រស្ដែង ចូរអ្នកទាំងឡាយ នាំគ្នាទៅចាប់បុរសនេះ ចងស្លាបសេកឲ្យខ្ជាប់ ដោយខ្សែដ៏មាំ ហើយកោរត្រងោល ទូងស្គរជ័យដែលមានសំឡេងឮខ្លាំង នាំបណ្ដើរអាក្រោស សព្វច្រកសព្វផ្លូវត្រៃឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាត់ក្បាលខាងត្បូងព្រះនគរ ។ រាជបុរសទាំងឡាយ ក៏ចាប់បុរសនោះចងស្លាបសេកឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរត្រងោល ទូងស្គរដែលមានសំឡេងឮខ្លាំង នាំបណ្ដើរអាក្រោស សព្វច្រកសព្វផ្លូវត្រៃឡែងកែង រួចនាំ

ចេញតាមទ្វារខាងត្បូង ហើយកាត់ក្បាលខាងត្បូងព្រះនគរ ។ ក្នុងទីនោះមាន បុរស ១ នាក់ឈរក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះបាន ធ្វើអំពើអាក្រក់ ជាអំពើគួរតិះដៀល គួរគេកាត់ក្បាលទៅហើយហ្ន៎ មើលចុះ ហ្ន៎ រាជបុរសចាប់បុរសនោះ ចងស្លាបសេកឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយ កោរត្រងោល ទូងស្គរជ័យ ដែលមានសំឡេងឮខ្លាំង នាំបណ្តើរអាក្រោស សព្វច្រកសព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាត់ ក្បាលខាងត្បូងព្រះនគរ ឱ បុរសនេះ មិនគួរនឹងធ្វើបាបកម្ម ជាអំពើគួរដល់ កិរិយាកាត់ក្បាល ដែលមានសភាពយ៉ាងនេះសោះឡើយ ។ ម្នាលភិក្ខុទាំង- ឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភ័យសញ្ញា ( សេចក្តីសម្គាល់ថាគួរខ្លាច ) ដ៏ក្លៀវក្លា ក្នុងធម៌ទាំងឡាយ គឺបារាជិក ភ័យសញ្ញានោះ ក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវ បារាជិកទេ ក៏នឹងមិនហ៊ានឲ្យត្រូវ ឬត្រូវបារាជិកហើយ ក៏នឹងសម្តែងឲ្យ សមគួរតាមធម៌ ( សឹកចេញ ) ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរស ស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ លីអង្រែ ដើរចូលទៅកាន់ទីប្រជុំ មហាជន ប្រកាស ( សេចក្តីខុសរបស់ខ្លួន ) យ៉ាងនេះថា អ្នកដ៏ចម្រើន ខ្ញុំ បានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរលីអង្រែ អ្នកដ៏មានអាយុ ពេញចិត្ត ឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ។ ក្នុងទីនោះ មានបុរសមួយ នាក់ ឈរនៅក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះ បានធ្វើ

បាបកម្មជាអំពើគួរតិះដៀល គួរឲ្យលីអង្រែទៅហើយហ្ន៎ មើលចុះហ្ន៎ បុរសនេះ ស្លៀកដណ្តប់សំពត់ខ្មៅរំសាយសក់ លីអង្រែ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស ( សេចក្តីខុសរបស់ខ្លួន ) យ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរឲ្យលីអង្រែ អ្នកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ឱ បុរសនេះមិនគួរនឹងធ្វើបាបកម្ម ដែលគួរតិះដៀល គួរឲ្យលីអង្រែ មានសភាពយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភ័យសញ្ញា ( សេចក្តីសម្គាល់ថាគួរខ្លាច ) ដ៏ក្លៀវក្លាយ៉ាងនេះ ក្នុងធម៌ទាំងឡាយ គឺសង្ឃាទិសេស ភ័យសញ្ញានោះ ក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវសង្ឃាទិសេសាបត្តិទេ ក៏នឹងមិនហ៊ានឲ្យត្រូវ ឬត្រូវសង្ឃាទិសេសាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ លីកញ្ច្រប់ផេះ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស ( សេចក្តីខុសរបស់ខ្លួន ) យ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្មគួរតិះដៀល ជាអំពើគួរលីកញ្ច្រប់ផេះ អ្នកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ។ ក្នុងទីនោះ មានបុរសមួយនាក់ ឈរក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនោះ បានធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញ្ច្រប់ផេះទៅហើយហ្ន៎ មើលចុះហ្ន៎ បុរសនេះ

ស្លៀកដណ្តប់សំពត់ខ្មៅរំសាយសក់ លីកញូប់ផេះ ដើរចូលទៅកាន់ទីប្រជុំមហាជន និយាយស្រែកប្រកាស យ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញូប់ផេះ លោកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ឱ បុរសនោះ មិនគួរធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញូប់ផេះ មានសភាពយ៉ាងនោះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភ័យសញ្ញា ( សេចក្តីសម្គាល់ថាគួរខ្លាច ) ដ៏ក្លៀវក្លាយ៉ាងនេះ ក្នុងធម៌ទាំងឡាយ គឺបាចិត្តិយៈ ភ័យសញ្ញានោះ ក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវបាចិត្តិយាបត្តិទេ ក៏នឹងមិនហ៊ានឲ្យត្រូវ ឬត្រូវបាចិត្តិយាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស ( សេចក្តីខុសរបស់ខ្លួន ) យ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម ជាអំពើដែលគួរតិះដៀល គួរស្តីបន្ទោស អ្នកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ។ ក្នុងទីនោះ មានបុរសមួយនាក់ ឈរនៅក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះ បានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរស្តីបន្ទោស ទៅហើយហ្ន៎ មើលចុះហ្ន៎ បុរសនោះស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាសយ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំ

បានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរស្តីបន្ទោស អ្នកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ឱ បុរសនេះ មិនគួរនឹងធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរស្តីបន្ទោស មានសភាពយ៉ាងនេះឡើយៗ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី តាំងភ័យសញ្ញា ( សេចក្តីសម្គាល់ថាគួរខ្លាច ) ដ៏ក្លៀវក្លា យ៉ាងនេះ ក្នុងធម៌ទាំងឡាយ គឺបាដិទេសនីយកយសញ្ញាទុំះ ក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវបាដិទេសនីយាបត្តិទេ ក៏នឹងមិនហ៊ានឲ្យត្រូវ ឬបើត្រូវបាដិទេសនីយាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៤ នេះ ហៅថា ភ័យកើតព្រោះអាបត្តិ ។

# អដ្ឋកថា

## អាបត្តិសូត្រ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាបត្តិសូត្រទី ២ ដូចតទៅនេះ បទថា **ខុរមុណ្ឌំ ករិត្វា** បានដល់ កោរសក់បន្សល់ ៥ កណ្តុប ។ បទថា **ខរស្សរេន** គឺសំឡេងក្រាងក្រអៅ ។ បទថា **បណវេន** គឺស្គរប្រកាសដំណឹងប្រហារ ។ បទថា **ថលដ្ឋស្ស** គឺបុរសឈរក្នុងទីមួយកន្លែង ។ បទថា

**សីសច្ឆេជ្ជំ** *គឺគួរដល់ការកាត់ក្បាល ។ បទថា* **យត្រ ហិ នាម** *គឺ* **យំ នាម។** *បទថា* **សោ វតស្សំ** *សេចក្តីថា ខ្ញុំនុ៎ះហ្ន៎ មិនគួរធ្វើបាបបែបនេះឡើយ ។ បទថា* **យថាធម្មំ បដិករិស្សតិ** *គឺនឹងសម្តែងសមគួរដល់ធម៌ ។ អធិប្បាយថា នឹងតាំងនៅក្នុងសាមណេរភូមិ ។ បទថា* **កាឡកំ វត្ថំ បរិធាយ** *បានដល់ ស្លៀកសំពត់ចាស់ពណ៌ខ្មៅ ។ បទថា* **មោសល្លំ** *ប្រែថា គួរលើអង្រែ ។*

*បទថា* **យថាធម្មំ** *សេចក្តីថា ចេញចាកអាបត្តិក្នុងធម្មវិន័យនេះ ហើយតាំងនៅក្នុងសេចក្តីបរិសុទ្ធ ។ ឈ្មោះថា រមែងសម្តែងតាមធម៌ ។ បទថា* **អស្សបុដំ** *បានដល់ កញ្ចប់ផេះ ។ បទថា* **គារយ្ហំ អស្សបុដំ** *បានដល់ គួរទូលកញ្ចប់ផេះ គួរតិះដៀល ។ បទថា* **យថាធម្មំ** *បានដល់ សម្តែងអាបត្តិ ក្នុងធម្មវិន័យនេះ ឈ្មោះថា រមែងសម្តែងតាមធម៌ ។ បទថា* **ឧបវជ្ជំ** *បានដល់ គួរតិះដៀល ។ បទថា* **បាដិទេសនីយេសុ** *គឺគួរសម្តែង ។ អាបត្តិដ៏សេស លោកសង្គ្រោះដោយបទនេះ ។ បទថា* **ឥមានិ ខោ ភិក្ខវេ ចត្តារិ អាបត្តិភយានិ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អាបត្តិភ័យទាំង ៤ នេះ ឈ្មោះថា អាស្រ័យអាបត្តិកើតឡើង ។*

## អដ្ឋកថា អាបត្តិសូត្រទី ២ ចប់

# សុត្តន្តបិដក

## សិក្ខានិសំសសូត្រទី ៣

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈនេះ មានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈ មានសិក្ខាជាអានិសង្ស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សិក្ខាជាអភិសមាចារិកា ដែលតថាគតបានបញ្ញត្តដល់ពួកសាវក ក្នុងសាសនានេះ ដើម្បីធ្វើពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាឡើង ម្នាលភិក្ខុទាំងឡាយ សិក្ខាជាអភិសមាចារិកា ដែលតថាគតបានបញ្ញត្តដល់ពួកសាវក ដើម្បីធ្វើពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាឡើង ដោយប្រការណាៗ សិក្ខាកាមភិក្ខុនោះ ក៏ធ្វើមិនឲ្យដាច់ ធ្វើមិនឲ្យធ្លុះ ធ្វើមិនឲ្យពពាល ធ្វើមិនឲ្យពព្រុសក្នុងសិក្ខានោះ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សិក្ខាជាអាទិព្រហ្មចរិយកា ដែលតថាគតបានបញ្ញត្តដល់ពួកសាវក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ សិក្ខាជាអាទិព្រហ្មចរិយកា ដែលតថាគតបានបញ្ញត្តដល់ពួកសាវក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ សិក្ខាកាមភិក្ខុនោះ ក៏ធ្វើមិនឲ្យដាច់ ធ្វើមិនឲ្យធ្លុះ ធ្វើមិនឲ្យពពាល ធ្វើមិនឲ្យពព្រុស ក្នុងសិក្ខានោះ សមាទាន សិក្សាក្នុងសិក្ខាបទ

ទាំងឡាយ ដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈ មានសិក្ខាជាអានិសង្សយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានបញ្ញាជាកំពូល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ដែលតថាគតសម្តែងហើយ ដល់សាវកទាំងឡាយ ក្នុងសាសនានេះ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតបានសម្តែងហើយ ដល់ពួកសាវក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ បញ្ញាកាមភិក្ខុ ក៏បានឃើញច្បាស់នូវចតុសច្ចធម៌ទាំងអស់នោះ ដោយប្រាជ្ញាដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានបញ្ញាជាកំពូលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានវិមុត្តិជាខ្លឹម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតសម្តែងហើយ ដល់ពួកសាវក ក្នុងសាសនានេះ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតសម្តែងហើយ ដល់ពួកសាវក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ ពួកសាវកក៏បានពាល់ត្រូវចតុសច្ចធម៌ទាំងពួងនោះដោយវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានវិមុត្តិជាខ្លឹមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានសតិជាអធិបតី តើដូចម្តេច ។ សតិដែលពួកសាវកបានតម្កល់ទុកប្រពៃ ព្រោះខាងក្នុងថា អាត្មាអញនឹងបំពេញអភិសមាចារិកាសិក្ខា ដែលមិនទាន់បរិបូណ៌

នឹងឲ្យបរិបូណ៌ខ្លះ នឹងរក្សាទុកអភិសមាចារិកាសិក្ខា ដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការដូច្នេះ ។ សតិដែលពួកសាវកបាន តម្កល់ទុកប្រពៃហើយ ពួដ៏ខាងក្នុងថា អាត្មាអញនឹងបំពេញអាទិព្រហ្ម-ចរិយកាសិក្ខា ដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ខ្លះ នឹងរក្សាទុកអាទិព្រហ្ម-ចរិយកាសិក្ខាដែលបរិបូណ៌ហើយដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការ ដូច្នេះ សតិដែលពួកសាវកបានតម្កល់ទុកប្រពៃហើយ ពួដ៏ខាងក្នុងថា អាត្មា អញនឹងធ្វើចតុសច្ចធម៌ ដែលមិនទាន់ឃើញច្បាស់ឲ្យឃើញច្បាស់ ដោយ បញ្ញាក្នុងទីនោះៗ ខ្លះ នឹងរក្សាទុកចតុសច្ចធម៌ ដែលឃើញច្បាស់ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ។ សតិដែលពួកសាវកបានតម្កល់ទុកប្រពៃ ហើយ ពួដ៏ខាងក្នុងថា អាត្មាអញនឹងពាល់ត្រូវនូវចតុសច្ចធម៌ ដែលមិន ទាន់ពាល់ត្រូវដោយវិមុត្តិខ្លះ នឹងរក្សាទុកនូវចតុសច្ចធម៌ ដែលប៉ះពាល់ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានសតិជាអធិបតីយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្រហ្មចរិយៈមានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតី ។ ពាក្យណា ដែលតថាគតបានពោលហើយ ពាក្យនោះ តថាគតពោលព្រោះអាស្រ័យព្រហ្មចរិយៈនេះ ។

# អដ្ឋកថា

## សិក្ខានិសំសសូត្រ

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខានិសំសសូត្រទី ៣ ដូចតទៅនេះ ព្រហ្មចរិយៈ ឈ្មោះថា **សិក្ខានិសំស** ព្រោះមានសិក្ខាជាអានិសង្ស ។ ឈ្មោះថា **បញ្ញុត្តរ** ព្រោះមានបញ្ញាជាកំពូល ។ ឈ្មោះថា **វិមុត្តិសារ** ព្រោះមានវិមុត្តិជាខ្លឹម ។ ឈ្មោះថា **សតាធិបតេយ្យ** ព្រោះមានសតិជាធំ ។ លោកអធិប្បាយថា ព្រហ្មចរិយៈដែលនៅប្រព្រឹត្តដើម្បីប្រយោជន៍ដល់អានិសង្សជាដើម ដែលបានដល់សិក្ខាជាដើមនោះ ។ បទថា **អភិសមាចារិកា** បានដល់ សិក្ខាទាក់ទងដោយអភិសមាចារដ៏ឧត្តម ។ បទនេះ ជាឈ្មោះនៃសីល ដែលទ្រង់បញ្ញត្ត ជាបដិបទា ។ បទថា **តថា តថា សោ តស្សា សិក្ខាយ** សេចក្តីថា ភិក្ខុនោះជាអ្នកប្រាថ្នាសិក្សាក្នុងសិក្ខាបទនោះយ៉ាងនោះៗ ។ បទថា **អាទិព្រហ្មចរិយកា** នេះ ជាឈ្មោះនៃមហាសីល ៤ ដែលជាខាងដើមរបស់ព្រហ្មចរិយៈ ។ បទថា **សព្វសោ** ប្រែថា ដោយអាការទាំងពួង ។ បទថា **ធម្មា** បានដល់ សច្ចធម៌ ៤ ។ បទថា **បញ្ញាយ សមវេក្ខិតា ហោន្តិ** សេចក្តីថា ធម៌ទាំងឡាយ ឈ្មោះថា សាវកពិចារណាឃើញដោយល្អ ដោយមគ្គប្បញ្ញា សមាធិ និងវិបស្សនា ។ បទថា **វិមុត្តិយា ផុសិតា ហោន្តិ** បានដល់ ធម៌ទាំងឡាយដែលសាវកពាល់ត្រូវដោយផស្សៈ គឺញាណនៃវិមុត្តិ គឺអរហត្តផល ។ បទថា **អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ** សេចក្តីថា សតិ ដែលសាវកចូលទៅតាំងដោយល្អខាងក្នុងខ្លួននោះ

*ឯង ។ បទថា* **បញ្ញាយ អនុគ្គហេស្សាមិ** *សេចក្តីថា តថាគតនឹងផ្គង ដោយវិបស្សនាបញ្ញា ។ ក្នុងបទថា* **បញ្ញាយ សមវេក្ខិស្សាមិ** *នេះ លោក បំណាងយកវិបស្សនាបញ្ញា តែក្នុងបទនេះថា* **ផុសិតំ វា ធម្មំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** *ប្រែថា តថាគតផ្គងធម៌ដែលបានពាល់ត្រូវហើយ ដោយបញ្ញាក្នុងទីនោះៗ លោកបំណាងយកមគ្គប្បញ្ញាតែម្យ៉ាង ៗ។*

**អដ្ឋកថា សិក្ខានិសំសសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សេយ្យសូត្រទី ៤

*[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ ដំណេកនេះមាន ៤ ។ ដំណេក ៤ គឺ អ្វីខ្លះ ។ គឺដំណេកដូចមនុស្សស្លាប់ ១ ដំណេកអ្នកបរិភោគកាម ១ ដំណេក សីហៈ ១ ដំណេកព្រះតថាគត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកដូច មនុស្សស្លាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មនុស្សស្លាប់ច្រើនតែដេក ផ្ងារ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកមនុស្សស្លាប់ ។ ម្នាល ភិក្ខុទាំងឡាយ ចុះដំណេកអ្នកបរិភោគកាម តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ពួកអ្នកបរិភោគកាម ច្រើនតែដេកផ្អៀងទៅខាងឆ្វេង ។ ម្នាលភិក្ខុទាំង-*

ឡាយ នេះហៅថា ដំណេកអ្នកបរិភោគកាម ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកសីហៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ សម្រេចការដេកដោយខាងៗ ស្ដាំ យកជើងតម្រួតលើជើង សិកកន្ទុយក្នុងចន្លោះភ្លៅ សីហមិគរាជនោះ លុះភ្ញាក់ឡើង ងើបកាយខាងមុខ គឺងើបក្បាល សម្លឹងមើលកាយខាងក្រោម ។ ម្នាលភិក្ខុទាំងឡាយ បើសីហមិគរាជ ឃើញសេចក្ដីភ្លាំងភ្លាត់ ឬការឃ្លៀងឃ្លាតកាយណាមួយសោត ម្នាលភិក្ខុទាំងឡាយ សីហ-មិគរាជរមែងតូចចិត្ត ព្រោះការភ្លាំងភ្លាត់ និងឃ្លៀងឃ្លាតនៃកាយនោះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសីហមិគរាជ មិនឃើញសេចក្ដីភ្លាំងភ្លាត់ ឬឃ្លៀងឃ្លាតនៃកាយណាមួយទេ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ រមែងត្រេកអរដោយការមិនភ្លាំងភ្លាត់ និងឃ្លៀងឃ្លាតនៃកាយនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកសីហៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកព្រះតថាគត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកព្រះតថាគត ម្នាលភិក្ខុទាំងឡាយ នេះដំណេក ៤ ប្រការ ។

# អដ្ឋកថា

## សេយ្យសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេយ្យសូត្រទី ៤ ដូចតទៅនេះថា មនុស្សស្លាប់ហើយ លោកហៅថា **បេត។** បទថា **ឧត្តានា សេន្តិ** បានដល់ អ្នកស្លាប់ទាំងនោះ ដោយច្រើនដេកផ្ងារ ។ ម្យ៉ាងទៀត សត្វដែលកើតក្នុងបិត្តិវិស័យ ឈ្មោះថា **បេត** ប្រេតទាំងនោះ ជាអ្នកមានសាច់ និងឈាមតិច មានឆ្អឹងឡើងរគាម មិនអាចដេកផ្អៀងបាន ទើបដេកផ្ងារតែម្យ៉ាង ។

បទថា **អនត្តមនោ ហោតិ** សេចក្ដីថា សីហមិគរាជ ព្រោះជាសត្វមានអំណាចច្រើន ដាក់ជើងមុខ និងជើងក្រោយទុកមួយកន្លែង ស៊កកន្ទុយក្នុងចន្លោះភ្លៅ កំណត់ឱកាសដែលជើងមុខ ជើងក្រោយ និងកន្ទុយ ដាក់ក្បាលលើជើងមុខទាំង ២ ហើយដេកអស់មួយថ្ងៃ កាលដេកលក់ភ្ញាក់ឡើងក៏មិនភ្ញាក់ដោយភ្ញាក់ផ្អើល អើតក្បាលឡើង សង្កេតឱកាសដែលជើងមុខជាដើមដាក់ បើឃ្លាតចាកទី គឺមិននៅដូចពីមុន ក៏មិនពេញចិត្ត ទូន្មានខ្លួនថា នេះមិនសមគួរដល់ជាតិ ត្រកូលរបស់អ្នក មិនសមគួរដល់ភាពជាអ្នកក្លាហាន ដូច្នេះ ទើបដេកក្នុងទីនោះបន្តទៀត មិនចេញទៅស្វែងរកអាហារ ។ បទថា **អនត្តមនោ ហោតិ** លោកពោលសំដៅយកសេចក្ដីនេះ ។ តែក្នុងកាលណា ជើងមុខជើងក្រោយមិនឃ្លាតចាកទី ទើបសីហមិគរាជត្រេកអរថា នេះសមគួរដល់ជាតិ ត្រកូលរបស់អ្នក និងសមគួរដល់ភាពជាអ្នកក្លាហានរបស់អ្នក ហើយក្រោកអំពីទីនោះ ពត់កាយ រលាស់កេសរ បន្លឺសីហនាទ ៣ ដង

ហើយទើបចេញរកអាហារ ។ បទថា **អត្តមនោ ហោតិ** លោកពោល ដោយមាតិកានោះ ។

**អដ្ឋកថា សេយ្យសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ថូបារហសូត្រទី ៥

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរបញ្ចុះទុកក្នុងថូបៈនេះមាន ៤ ពួក ។ បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ គួរបញ្ចុះក្នុងថូបៈ ១ ព្រះបច្ចេកពុទ្ធ គួរបញ្ចុះក្នុងថូបៈ ១ សាវករបស់ព្រះតថាគត គួរបញ្ចុះក្នុងថូបៈ ១ ស្តេចចក្រពត្តិ គួរបញ្ចុះក្នុងថូបៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ គួរបញ្ចុះទុកក្នុងថូបៈ ។

# អដ្ឋកថា

## ថូបារហសូត្រ

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងថូបារហសូត្រទី ៥ ដូចតទៅនេះ បទថា

**រាជា ចក្កវត្តី** នេះ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់អនុញ្ញាតការសាងស្តូបដល់ស្តេចចក្រពត្តិដែលសោយទិវង្គតហើយ ទ្រង់មិនអនុញ្ញាតឲ្យធ្វើដល់ភិក្ខុជាបុថុជ្ជនដែលមានសីល ។ ឆ្លើយថា ព្រោះជាអច្ឆរិយៈ ។ កាលបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតស្តូបទាំងឡាយដល់ភិក្ខុដែលជាបុថុជ្ជន ក៏មិនគប្បីមានឱកាសទំនេរដល់អ្នកស្រុក និងកំពង់ទូកក្នុងតម្ពបណ្ណិទ្វីបឡើយ ក្នុងឋានៈដទៃក៏យ៉ាងនោះ ព្រោះដូច្នោះ ទើបទ្រង់មិនអនុញ្ញាត ដោយទ្រង់ឃើញថា ភិក្ខុទាំងនោះមិនជាអច្ឆរិយៈ ស្តេចចក្រពត្តិទ្រង់កើតឡើងមួយអង្គប៉ុណ្ណោះ ដោយហេតុនោះ ទើបស្តូបរបស់ស្តេចចក្រពត្តិជាអច្ឆរិយៈ ។ តែគួរធ្វើសក្ការៈធំដល់ភិក្ខុបុថុជ្ជន ដែលជាអ្នកមានសីល ដូចភិក្ខុដែលបរិនិព្វានហើយ ដូច្នោះដោយពិត ។៚

### អដ្ឋកថា ថូបារហសូត្រទី ៥ ចប់

# សុត្តន្តបិដក

## បញ្ញាវុឌ្ឍិសូត្រទី ៦

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺការសេពគប់សប្បុរស ១ ការ

*ស្តាប់ធម៌របស់សប្បុរស ១ យកចិត្តទុកដាក់ដោយឧបាយ ១ ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ។*

# អដ្ឋកថា

## បញ្ញាវុឌ្ឍិសូត្រ

*[ ៩៨ ] ក្នុងបញ្ញាវុឌ្ឍិសូត្រទី ៦ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាបញ្ញាវុឌ្ឍិសូត្រទី ៦ ចប់*

# សុត្តន្តបិដក

## ពហុការសូត្រទី ៧

*[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ រមែងមានឧបការៈច្រើនដល់មនុស្ស ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការយកចិត្តទុកដាក់ដោយឧបាយ ១ ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ ប្រការ រមែងមានឧបការៈច្រើនដល់មនុស្ស ។*

# អដ្ឋកថា

## ពហុការសូត្រ

[ ៩៩ ] ពហុការសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពហុការសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បឋមវោហារសូត្រទី ៨

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ វោហារមិនប្រសើរនេះមាន ៤ យ៉ាង ។ វោហារមិនប្រសើរ ៤ គឺអ្វីខ្លះ ។ គឺមិនឃើញ ពោលថាឃើញ ១ មិនឮ ពោលថាឮ ១ មិនធុំក្លិន ពោលថាធុំក្លិន ១ មិនដឹង ពោលថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះវោហារមិនប្រសើរ ៤ យ៉ាង ។

# អដ្ឋកថា

## បឋមវោហារសូត្រ

[ ១០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវោហារសូត្រទី ៨ ដូចតទៅនេះ បទថា **អនរិយវោហារា** បានដល់ ការពោលរបស់បុគ្គលមិនជាអរិយៈ

សុម្បីបទដ៏សេស ក៏មានន័យនេះដូចគ្នា ៗ។

អដ្ឋកថា បឋមវោហារសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ទុតិយវោហារសូត្រទី ៩

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ វោហារប្រសើរនេះមាន ៤ យ៉ាង ។ វោហារប្រសើរ ៤ គឺអ្វីខ្លះ ។ គឺមិនឃើញ ពោលថាមិនឃើញ ១ មិនឮ ពោលថាមិនឮ ១ មិនធុំក្លិន ពោលថាមិនធុំក្លិន ១ មិនដឹង ពោលថាមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវោហារប្រសើរ ៤ យ៉ាង ។

# អដ្ឋកថា

## ទុតិយវោហារសូត្រ

[ ១០១ ] ទុតិយវោហារសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយវោហារសូត្រទី ៩ ចប់

# សុត្តន្តបិដក

## តតិយវោហារសូត្រទី ១០

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ វោហារមិនប្រសើរនេះមាន ៤ យ៉ាង ។ វោហារមិនប្រសើរ ៤ គឺអ្វីខ្លះ ។ គឺឃើញ ពោលថាមិនឃើញ ១ ឮ ពោលថាមិនឮ ១ ធុំក្លិន ពោលថាមិនធុំក្លិន ១ ដឹង ពោលថាមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវោហារមិនប្រសើរ ៤ យ៉ាង ។

# អដ្ឋកថា

## តតិយវោហារសូត្រ

[ ១០២ ] ក្នុងតតិយវោហារសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាតតិយវោហារសូត្រទី ១០ ចប់

## ចតុត្ថវោហារសូត្រទី ១១

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ វោហារប្រសើរនេះមាន ៤ យ៉ាង ។ វោហារប្រសើរ ៤ គឺអ្វីខ្លះ ។ គឺឃើញ ពោលថាឃើញ ១ ឮ ពោលថាឮ ១ ធុំក្លិន ពោលថាធុំក្លិន ១ ដឹង ពោលថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះ

ជាវោហារប្រសើរ ៤ យ៉ាង ។

អាបត្តិភយវគ្គទី ៥ ចប់

ឧទ្ទាននៃវគ្គនោះ គឺ

និយាយអំពីភិក្ខុទម្លាយសង្ឃ ៤ យ៉ាង អំពីភ័យកើតអំពីអាបត្តិ ៤ យ៉ាង អំពីអានិសង្សនៃព្រហ្មចរិយៈ ៤ យ៉ាង មានសិក្ខាជាអានិសង្សជាដើម អំពីដំណេក ៤ យ៉ាង អំពីថូបារហបុគ្គល ៤ ពួក អំពីហេតុចម្រើនបញ្ញា ៤ យ៉ាង អំពីធម៌មានឧបការៈច្រើនដល់មនុស្ស ៤ យ៉ាង អំពីវោហារ ៤ យ៉ាង ទាំង ២ ចំណែក ។

# អដ្ឋកថា

## ចតុត្ថវោហារសូត្រ

[ ១០៣ ] ចតុត្ថវោហារសូត្រទី ១១ មានអត្ថងាយយល់ហើយ ។

អដ្ឋកថា ចតុត្ថវោហារសូត្រទី ១១ ចប់

អាបត្តិភយវគ្គទី ៥ ចប់

# សុត្តន្តបិដក
# អភិញ្ញាវគ្គទី ៦

## អភិញ្ញាសូត្រទី ១

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌នេះមាន ៤ យ៉ាង ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌គួរកំណត់ដឹងដោយបញ្ញាក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរលះបង់ដោយបញ្ញាក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរចម្រើនដោយបញ្ញាក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរកំណត់ដឹងដោយបញ្ញា តើដូចម្តេច ។ គឺឧបាទានក្ខន្ធទាំង ៥ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរកំណត់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរលះបង់ដោយបញ្ញា តើដូចម្តេច ។ គឺ អវិជ្ជា និងភវតណ្ហា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរលះបង់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរចម្រើនដោយបញ្ញាតើដូចម្តេច ។ គឺ សមថៈ និងវិបស្សនា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរចម្រើនដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា តើដូចម្តេច ។ គឺ វិជ្ជា និងវិមុត្តិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ យ៉ាង ។

# អដ្ឋកថា

# អភិញ្ញាវគ្គទី ៦

## អភិញ្ញាសូត្រ

[ ១០៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិញ្ញាសូត្រទី ១ នៃអភិញ្ញាវគ្គទី ៦ ដូចតទៅនេះ បទថា **អភិញ្ញា** បានដល់ ដឹងក្រៃលែងដោយបញ្ញា ។ បទថា **សមថោ ច វិបស្សនា ច** បានដល់ ភាពជាបុគ្គលមានចិត្តមានអារម្មណ៍មួយ និងវិបស្សនាញាណកំណត់ដឹងសង្ខារ ។ បទថា **វិជ្ជា ច វិមុត្តិ ច** បានដល់ វិជ្ជាដែលមគ្គញាណ និងសម្បយុត្តធម៌ដ៏សេស ។ល។

**អដ្ឋកថា អភិញ្ញាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បរិយេសនាសូត្រទី ២

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមិនប្រសើរនេះ មាន ៤ យ៉ាង ។ ការស្វែងរកមិនប្រសើរ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ខ្លួនឯងជាអ្នកមានជរាជាធម្មតា ក៏ស្វែងរកជរាធម៌ថែមទៀត ខ្លួនឯងជាអ្នកមានព្យាធិជាធម្មតា ក៏ស្វែងរកព្យាធិធម៌ថែម

ទៀត ខ្លួនឯងជាអ្នកមានមរណៈជាធម្មតា ក៏ស្វែងរកមរណធម៌ថែមទៀត ខ្លួនឯងជាអ្នកមានសេចក្តីសៅហ្មងជាធម្មតា ក៏ស្វែងរកសេចក្តីសៅហ្មងថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាការស្វែងរកមិនប្រសើរ ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកប្រសើរមាន ៤ យ៉ាង ។ ការស្វែងរកប្រសើរ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ខ្លួនឯងជាអ្នកមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ក៏ស្វែងរកនូវធម៌មិនជរា ដ៏ក្សេមចាកយោគៈ ដ៏ប្រសើរ គឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ក៏ស្វែងរកធម៌មិនមានព្យាធិ ដ៏ក្សេមចាកយោគៈ ដ៏ប្រសើរ គឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានមរណៈជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណៈធម៌ ក៏ស្វែងរកធម៌មិនស្លាប់ ដ៏ក្សេមចាកយោគៈ ដ៏ប្រសើរ គឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានសេចក្តីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោសក្នុងសេចក្តីសៅហ្មង ក៏ស្វែងរកធម៌មិនសៅហ្មង ដ៏ក្សេមចាកយោគៈ ដ៏ប្រសើរ គឺព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ នេះការស្វែងរកដ៏ប្រសើរ ៤ យ៉ាង ។

# អដ្ឋកថា

## បរិយេសនាសូត្រ

[ ១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិយេសនាសូត្រទី ២ ដូចតទៅនេះ បទថា **អនរិយបរិយេសនា** បានដល់ ការស្វែងរក គឺស្វែងរករបស់ដែលមិនមែនអរិយៈ ។ បទថា **ជរាធម្មំ** បានដល់ វត្ថុដែលមានការចាស់ជាធម្មតា ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ៕

**អដ្ឋកថា បរិយេសនាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សង្គហសូត្រទី ៣

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុ ( វត្ថុជាគ្រឿងសង្គ្រោះ ) នេះមាន ៤ យ៉ាង ។ សង្គហវត្ថុ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺការឲ្យ ១ ការពោលពាក្យពីរោះ ១ ការប្រព្រឹត្តជាប្រយោជន៍ ១ ភាពជាអ្នកទុកដាក់ខ្លួនស្មើ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសង្គហវត្ថុ ៤ យ៉ាង ។

# អដ្ឋកថា

## សង្គហសូត្រ

[ ១០៦ ] សង្គហសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសង្គហសូត្រទី ៣ ចប់

# សុត្តន្តបិដក

## មាលុង្ក្យបុត្តសូត្រទី ៤

[ ១០៧ ] គ្រានោះ ព្រះមាលុង្ក្យបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះមាលុង្ក្យបុត្តដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ជាធម៌ដែលនាំខ្ញុំព្រះអង្គឲ្យចៀសចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះស្តាប់នូវធម៌របស់ព្រះដ៏មានព្រះភាគ ។ ម្នាលមាលុង្ក្យបុត្ត ក្នុងដំណើរនេះ តថាគតនឹងនិយាយប្រាប់ភិក្ខុកំលោះ ដូចម្តេចបាន បើខ្លួនអ្នកជាមនុស្សចាស់គ្រាំគ្រាមានវ័យចម្រើន មកសុំនូវឱវាទ ដោយសង្ខេបចំពោះតថាគតដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំ

ព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ធ្វើម្តេចហ្ន៎ ខ្ញុំព្រះអង្គគប្បីដឹងសេចក្តីនៃភាសិតរបស់ព្រះដ៏មានព្រះភាគបាន ធ្វើម្តេចហ្ន៎ ខ្ញុំព្រះអង្គគប្បីបានទទួលមតិកនៃភាសិតរបស់ព្រះដ៏មានព្រះភាគបាន ។ ម្នាលមាលុង្ក្យបុត្ត តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងក្នុងវត្ថុណា ការកើតនៃតណ្ហា ( ក្នុងវត្ថុនោះ ) មាន ៤ ប្រការ ។ តណ្ហា ៤ ប្រការ ដូចម្តេចខ្លះ ។ ម្នាលមាលុង្ក្យបុត្ត តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងព្រោះហេតុចីវរ ១ ម្នាលមាលុង្ក្យបុត្ត តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើង ព្រោះហេតុបិណ្ឌបាត ១ ម្នាលមាលុង្ក្យបុត្ត តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើង ព្រោះហេតុសេនាសនៈ ១ ម្នាលមាលុង្ក្យបុត្ត តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងព្រោះហេតុភពតូច និងភពធំ ដូច្នេះ ១ ។ ម្នាលមាលុង្ក្យបុត្ត នេះជាតណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងក្នុងវត្ថុណា ការកើតនៃតណ្ហា ( ក្នុងវត្ថុនោះ ) មាន ៤ យ៉ាង ។ ម្នាលមាលុង្ក្យបុត្ត កាលតណ្ហាដែលភិក្ខុបានលះបង់ បានផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា ។ ម្នាលមាលុង្ក្យបុត្ត ភិក្ខុនេះ ហៅថា បានផ្តាច់តណ្ហា បានរលាស់ចោលសញ្ញោជនៈ ធ្វើនូវទីបំផុតទុក្ខបាន ព្រោះលះមានះបានដោយប្រពៃ ។ លំដាប់នោះ មាលុង្ក្យបុត្តដ៏មានអាយុ បានទទួលពុទ្ធឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ

រូបចេញទៅ ។ តមក មាលុង្ក្យបុត្តដ៏មានអាយុ តែម្នាក់ឯងចេញចាកពួក មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងកម្ចាត់បង់កិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួស ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ មានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចបានធ្វើស្រេចហើយ កិច្ចដទៃដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ មាលុង្ក្យបុត្តដ៏មានអាយុ បានជាព្រះអរហន្ត ១ អង្គដែរ ។

# អដ្ឋកថា

## មាលុង្ក្យបុត្តសូត្រ

[ ១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមាលុង្ក្យបុត្តសូត្រទី ៤ ដូចតទៅនេះ បទថា **មាលុង្ក្យបុត្តោ** បានដល់ កូនរបស់មាលុង្ក្យព្រាហ្មណ៍ ។ បទថា **ឯត្ថ** បានដល់ ក្នុងការអារាធនាសូមឱវាទរបស់លោក ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សង្កត់ខ្លះ ទ្រង់លើកខ្លះ នូវព្រះថេរៈ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា បានឮថា កាលនៅក្មេងមាលុង្ក្យបុត្រនេះ ជាប់នៅក្នុង

លាភសក្ការៈ បន្ទាប់មក ដល់ពេលចាស់ ប្រាថ្នានឹងនៅព្រៃ ទើបទូលសូមកម្មដ្ឋាន ។ គប្បីប្រកបសេចក្តីថា លំដាប់នោះ ព្រះមានព្រះភាគកាលត្រាស់ដោយបំណងថា ឥឡូវនេះ តថាគតនឹងពោលជាមួយភិក្ខុកំលោះដូចម្តេចហ្ន៎ ព្រោះពួកភិក្ខុក៏ដូចមាលុង្ក្យបុត្រ ក្នុងកាលនៅក្មេង ជាអ្នកជាប់ក្នុងបច្ច័យ លុះខ្លួនចាស់ ក៏ចូលព្រៃបំពេញសមណធម៌ ដូច្នេះ ឈ្មោះថា ការសង្កត់ព្រះថេរៈ ព្រោះព្រះថេរៈក្នុងកាលខ្លួនចាស់ថមថយ ចូលព្រៃបំណងធ្វើសមណធម៌ ដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ដោយបំណងថា តថាគតនឹងពោលជាមួយភិក្ខុកំលោះៗ ដូចម្តេចហ្ន៎ មាលុង្ក្យបុត្ររបស់ពួកភិក្ខុនោះ ដល់ពេលចាស់ ក៏ចូលព្រៃ បំណងបំពេញសមណធម៌ ទើបសូមកម្មដ្ឋាន ពួកភិក្ខុនេះ កាលនៅក្មេង ក៏មិនធ្វើសេចក្តីព្យាយាមមុន ដូច្នេះ ឈ្មោះថា លើកតម្កើងព្រះថេរៈ ដូច្នេះ ។ល។

## អដ្ឋកថា មាលុង្ក្យបុត្តសូត្រទី ៨ ចប់

# សុត្តន្តបិដក

## កុលសូត្រទី ៩

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណាមួយ ដល់នូវ

ភាពស្តុកស្តម្ភក្នុងភោគៈទាំងឡាយហើយ មិនស្ថិតស្ថេរនៅបានយូរ ត្រកូលទាំងអស់នោះ សាបសូន្យព្រោះហេតុ ៤ ប្រការ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ហេតុ ៤ ប្រការ គឺអ្វីខ្លះ ។ គឺមិនស្វែងរករបស់ដែលបាត់ទៅ ១ មិនជួសជុលរបស់ដែលចាស់គ្រាំគ្រា ១ មានការផឹក និងការបរិភោគមិនដឹងប្រមាណ ១ តាំងស្ត្រី ឬបុរសទ្រុស្តសីលឲ្យជាអធិបតី ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ ដល់នូវភាពស្តុកស្តម្ភក្នុងភោគៈទាំង-ឡាយ ហើយមិនស្ថិតស្ថេរនៅបានយូរ ត្រកូលទាំងអស់នោះ សាបសូន្យព្រោះហេតុ ៤ ប្រការនេះ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ ដល់នូវភាពស្តុកស្តម្ភ ក្នុងភោគៈទាំងឡាយ ហើយមិនស្ថិតស្ថេរនៅបានយូរ ត្រកូលទាំងអស់នោះ ចម្រើនព្រោះហេតុ ៤ ប្រការ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ហេតុ ៤ ប្រការ គឺអ្វីខ្លះ ។ គឺស្វែងរករបស់ដែលបាត់ទៅ ១ ជួសជុលរបស់ដែលចាស់គ្រាំគ្រា ១ មានការផឹក និងការបរិភោគដឹងប្រមាណ ១ តាំងស្ត្រី ឬបុរសមានសីលឲ្យជាអធិបតី ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ ដល់នូវភាពស្តុកស្តម្ភ ក្នុងភោគៈទាំងឡាយ ហើយមិនស្ថិតស្ថេរនៅបានយូរ ត្រកូលទាំងអស់នោះ ចម្រើនព្រោះហេតុ ៤ ប្រការនេះ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។

# អដ្ឋកថា

## កុលសូត្រ

[ ១០៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុលសូត្រទី ៥ ដូចតទៅនេះ បទថា **អាធិបច្ចំ ឋបេន្តិ** បានដល់ តាំងទុកក្នុងតំណែងជាអ្នករក្សាឃ្លាំង ។៚

**អដ្ឋកថា កុលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បឋមអាជានីយសូត្រទី ៦

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គ ៤ គួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថា ជាអង្គរបស់ព្រះរាជាបាន ។ អង្គ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អស្សាជានីយៈដ៏ប្រសើររបស់ព្រះរាជា ក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកម្ពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ អស្សាជានីយៈដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គ ៤ នេះ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលវត្ថុ ដែលគេបង្អោនចូលមកបូជា ។បេ។

ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៤ ប្រការ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ឲ្យកុសលទាំងឡាយកើតឡើង ខំព្យាយាមខ្នះខ្នែង មិនលះបង់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿនយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបរិបូណ៌ដោយកម្ពស់ និងទំហំ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសានានេះ ជាអ្នកស្ទាក់លាភចំពោះចីវរបិណ្ឌបាតសេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកមានជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជា

អ្នកបរិបូណ៌ដោយកម្ពស់ និងទំហំ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## បឋមអាជានីយសូត្រ

[ ១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាជានីយសូត្រទី ៦ ដូចតទៅនេះ បទថា **វណ្ណសម្បន្នោ** បានដល់ ដល់ព្រមដោយពណ៌សម្បុរ ។ បទថា **ពលសម្បន្នោ** បានដល់ ដល់ព្រមដោយកម្លាំងកាយ។ បទថា **ភិក្ខុ វណ្ណសម្បន្នោ** បានដល់ ដល់ព្រមដោយពណ៌សម្បុរ គឺគុណ ។ បទថា **ពលសម្បន្នោ** បានដល់ ដល់ព្រមដោយកម្លាំង គឺសេចក្តីព្យាយាម ។ បទថា **ជវសម្បន្នោ** បានដល់ ដល់ព្រមដោយល្បឿន គឺញាណ ។

**អដ្ឋកថា បឋមអាជានីយសូត្រទី៦ ចប់**

# សុត្តន្តបិដក

## ទុតិយអាជានីយសូត្រទី ៧

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គ ៤ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ អង្គ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ក្នុងលោកនេះ បរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ល្បឿន ១ បរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គទាំង ៤ នេះ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុដ៏ប្រកបដោយធម៌ ៤ ប្រការក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។បេ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ល្បឿន ១ បរិបូណ៌ដោយកម្ពស់ និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ឲ្យកុសលធម៌ទាំង-

ឡាយកើតឡើង ជាអ្នកខំព្យាយាម ខ្នះខ្នែង មិនលះបង់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយ ល្បឿនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកម្ពស់ និងទំហំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាក់លាភចំពោះចីវរបិណ្ឌបាតសេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មានជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្ពស់ និងទំហំ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ ទើបជាអ្នកគួរទទួលនូវទានដែលបុគ្គលនាំមកបូជា ។បេ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។

# អដ្ឋកថា

## ទុតិយអាជានីយសូត្រ

[ ១១០ ] សូម្បីទុតិយអាជានីយសូត្រទី ៧ ក៏មានន័យនេះដូចគ្នា ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថាទុតិយអាជានីយសូត្រទី៧ចប់**

# សុត្តន្តបិដក

## ពលសូត្រទី ៨

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ យ៉ាង ។ កម្លាំង ៤ យ៉ាង គឺអ្វីខ្លះ ។ កម្លាំង គឺវិរិយៈ ១ កម្លាំង គឺសតិ ១ កម្លាំង គឺសមាធិ ១ កម្លាំង គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះកម្លាំង ៤ យ៉ាង ។

# អដ្ឋកថា

## ពលសូត្រ

[ ១១១ ] ពលសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពលសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អរញ្ញសូត្រទី ៩

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ មិនគួរសេពសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំបាន ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺភិក្ខុប្រកបដោយកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ ជាអ្នកអប្បឥតប្រាជ្ញា លលា ឆ្កួតទឹកមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ មិនគួរសេពសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ទើបគួរសេពសេនាសនៈស្ងាត់ គឺព្រៃតូចព្រៃធំបាន ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ គឺភិក្ខុប្រកបដោយនេក្ខម្មវិតក្ក ១ អព្យាបាទវិតក្ក ១ អវិហិង្សាវិតក្ក ១ អ្នកមានប្រាជ្ញា មិនលលា មិនឆ្កួតទឹកមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ទើបគួរសេពសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំបាន ។

# អដ្ឋកថា

## អរញ្ញសូត្រ

*[ ១១២ ] អរញ្ញសូត្រទី ៩ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាអរញ្ញសូត្រទី ៩ ចប់*

# សុត្តន្តបិដក

## កម្មបថសូត្រទី ១០

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ ជាមនុស្សពាល មិនឈ្លាស ជាអសប្បុរស រមែងបរិហារខ្លួន ដូចដើមឈើដែលគាស់ឫសចោល ឆាប់ពាក់កណ្ដាល ជាអ្នកប្រកបដោយទោសផង ដែលពួកវិញ្ញូជនតិះដៀលផង រមែងបាននូវរបស់មិនជាបុណ្យដ៏ច្រើនផង ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ទិដ្ឋិប្រកបដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ ជាមនុស្សពាល មិនឈ្លាស ជាអសប្បុរស រមែងបរិហារខ្លួន ដូចជាដើមឈើដែលគាស់ឫសចោលឆាប់ពាក់កណ្ដាល ជាអ្នកប្រកបដោយទោសផង ដែលពួកវិញ្ញូជនតិះដៀលផង បាននូវរបស់មិនមែនជាបុណ្យដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ជាបណ្ឌិត ជាអ្នកឈ្លាសវៃ ជាសប្បុរស រមែងបរិហារខ្លួនដូចដើមឈើដែលមិនបានគាស់ឫសចោល មិនឆាប់ពាក់កណ្ដាល ជាអ្នកមិនមានទោសផង ដែលពួកវិញ្ញូជនមិនតិះដៀលផង រមែងបាននូវបុណ្យដ៏ច្រើនផង ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាសប្បុរស រមែងបរិហារខ្លួន ដូចដើមឈើ

ដែលមិនបានគាស់ឫស មិនផាប់ពាក់កណ្តាល ជាអ្នកមិនមានទោសផង ដែលពួកវិញ្ញូជនមិនតិះដៀលផង រមែងបានបុណ្យដ៏ច្រើនផង ។

អភិញ្ញាវគ្គទី ៦ ចប់

## ឧទ្ទាននៃវគ្គនោះ គឺ

និយាយអំពីអភិញ្ញាធម៌ ៤ ប្រការ អំពីការស្វែងរក ៤ ប្រការ អំពីសង្គហៈ ៤ ប្រការ អំពីមាលុង្ក្យបុត្ត អំពីត្រកូលស្ថិតស្ថេរ និងមិនស្ថិតស្ថេរដោយហេតុ ៤ ប្រការ ២ រឿង អំពីសេះអាជានេយ្យប្រកបដោយអង្គ ៤ ជាសេះគួរដល់ព្រះរាជា អំពីពល ៤ ប្រការ អំពីភិក្ខុមិនគួរនៅ និងគួរនៅក្នុងសេនាសនៈព្រៃបាន និងអំពីកម្មដែលឥតទោស និងមានទោស ។

# អដ្ឋកថា

## កម្មបថសូត្រ

[ ១១៣ ] កម្មបថសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា កម្មបថសូត្រទី ១០ ចប់**

**អភិញ្ញាវគ្គទី ៦ ចប់**

# សុត្តន្តបិដក

## កម្មបថវគ្គទី ៧

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺបុគ្គលដែលសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំអ្នកដទៃក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ពោលសរសើរការសម្លាប់សត្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងស្ថានសួគ៌ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺបុគ្គលវៀរចាកការសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំអ្នកដទៃក្នុងការវៀរចាកការសម្លាប់សត្វ ១ ពេញចិត្តក្នុងការវៀរចាកការសម្លាប់សត្វ ១ ពោលសរសើរការវៀរចាកការសម្លាប់សត្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺបុគ្គលជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្តក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពោលសរសើរការកាន់យកទ្រព្យដែលគេមិន

បានឲ្យ ១ ។ អម្បាលនេះ ។បេ។ គឺបុគ្គលជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ដឹកនាំអ្នកដទៃក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ពេញចិត្តក្នុងការវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ពោលសរសើរការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ អម្បាលនេះ ។បេ។

[ ១១៦ ] ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងកាមេសុមិច្ឆាចារ ពេញចិត្តក្នុងកាមេសុមិច្ឆាចារ ពោលសរសើរកាមេសុមិច្ឆាចារ ។ អម្បាលនេះ ។បេ។ ជាអ្នកវៀរចាកកាមេសុ-មិច្ឆាចារដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកកាមេសុមិច្ឆាចារ ពេញចិត្តក្នុងការវៀរចាកកាមេសុមិច្ឆាចារ ពោលសរសើរការវៀរចាកកាមេ-សុមិច្ឆាចារ ។ អម្បាលនេះ ។បេ។

[ ១១៧ ] ជាអ្នកនិយាយកុហកដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងមុសាវាទ ពេញចិត្តក្នុងមុសាវាទ ពោលសរសើរមុសាវាទ ។ អម្បាលនេះ ។បេ។ ជាអ្នកវៀរចាកមុសាវាទដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកមុសាវាទ ពេញចិត្តក្នុងការវៀរចាកមុសាវាទ ពោលសរសើរការវៀរចាកមុសាវាទ ។ អម្បាលនេះ ។បេ។

[ ១១៨ ] ជាអ្នកពោលពាក្យញុះញង់ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងបិសុណាវាចា ពេញចិត្តក្នុងបិសុណាវាចា ពោលសរសើរបិសុណាវាចា។

អម្បាលនេះ ។បេ។ ជាអ្នកវៀរចាកបិសុណាវាចាដោយខ្លួនឯង ជីកនាំបុគ្គលដទៃ ក្នុងការវៀរចាកបិសុណាវាចា ពេញចិត្តក្នុងការវៀរចាកបិសុណាវាចា ពោលសរសើរការវៀរចាកបិសុណាវាចា ។ អម្បាលនេះ ។បេ។

[ ១១៩ ] ជាអ្នកនិយាយពាក្យអាក្រក់ដោយខ្លួនឯង ជីកនាំបុគ្គលដទៃ ក្នុងផរុសវាចា ពេញចិត្តក្នុងផរុសវាចា ពោលសរសើរផរុសវាចា ។ អម្បាលនេះ ។បេ។ ជាអ្នកវៀរចាកផរុសវាចាដោយខ្លួនឯង ជីកនាំបុគ្គលដទៃក្នុងការវៀរចាកផរុសវាចា ពេញចិត្តក្នុងការវៀរចាកផរុសវាចា ពោលសរសើរការវៀរចាកផរុសវាចា ។ អម្បាលនេះ ។បេ។

[ ១២០ ] ជាអ្នកពោលពាក្យឥតប្រយោជន៍ដោយខ្លួនឯង ជីកនាំបុគ្គលដទៃ ក្នុងសម្ផប្បលាបៈ ពេញចិត្តក្នុងសម្ផប្បលាបៈ ពោលសរសើរសម្ផប្បលាបៈ ។ អម្បាលនេះ ។បេ។ ជាអ្នកវៀរចាកសម្ផប្បលាបៈ ដោយខ្លួនឯង ជីកនាំបុគ្គលដទៃ ក្នុងការវៀរចាកសម្ផប្បលាបៈ ពេញចិត្តក្នុងការវៀរចាកសម្ផប្បលាបៈ ពោលសរសើរការវៀរចាកសម្ផប្បាលាបៈ ។ អម្បាលនេះ ។បេ។

[ ១២១ ] ជាអ្នកមានចិត្តសម្លឹងរំពៃទ្រព្យអ្នកដទៃ ដោយខ្លួនឯង ជីកនាំបុគ្គលដទៃក្នុងអភិជ្ឈា ពេញចិត្តក្នុងអភិជ្ឈា ពោលសរសើរអភិជ្ឈា ។ អម្បាលនេះ ។បេ។ ជាអ្នកមានចិត្តមិនរំពៃ ( ទ្រព្យអ្នកដទៃ ) ដោយខ្លួនឯង ជីកនាំបុគ្គលដទៃក្នុងអនភិជ្ឈា ពេញចិត្តក្នុងអនភិជ្ឈា ពោលសរសើរអនភិជ្ឈា ។ អម្បាលនេះ ។បេ។

[ ១២២ ] ជាអ្នកមានចិត្តព្យាបាទ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងព្យាបាទ ពេញចិត្តក្នុងព្យាបាទ ពោលសរសើរព្យាបាទ ។អម្បាលនេះ ។បេ។ ជាអ្នកមានចិត្តមិនព្យាបាទដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងការមិនព្យាបាទ ពេញចិត្តក្នុងការមិនព្យាបាទ ពោលសរសើរការមិនព្យាបាទ ។ អម្បាលនេះ ។បេ។

[ ១២៣ ] ជាអ្នកយល់ខុសដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងសេចក្តីយល់ខុស ពេញចិត្តក្នុងសេចក្តីយល់ខុស ពោលសរសើរសេចក្តីយល់ខុស ។ អម្បាលនេះ ។បេ។ ជាអ្នកយល់ត្រូវដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងសេចក្តីយល់ត្រូវ ពេញចិត្តក្នុងសេចក្តីយល់ត្រូវ ពោលសរសើរសេចក្តីយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ នេះ រមែងកើតក្នុងឋានសួគ៌ ដូចគេនាំទៅដាក់ ។

កម្មបថវគ្គទី ៧ ចប់

# អដ្ឋកថា

## កម្មបថវគ្គទី ៧

[ ១១៤-១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មបថវគ្គទី ៧ ដូចតទៅនេះ កម្មបថ ១០ លោកពោលលាយឡំគ្នា ដោយលោកិយផង លោកុត្តរផង ។

អដ្ឋកថាកម្មបថវគ្គទី ៧ ចប់

# សុត្តន្តបិដក

## ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗ នូវកាយក្នុងកាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងល្អ មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណារឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ... ពិចារណារឿយៗ នូវចិត្តក្នុងចិត្តទាំងឡាយ ... ពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងល្អ មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះបង់អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ... ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ឲ្យកើតឡើង ... ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីឲ្យកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យស្ថិតនៅ មិនឲ្យ

វិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ធំទូលាយ ចម្រើនបរិបូណ៌ ។ ម្នាល ភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាល ភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទៈ សមាធិ និងបធានសង្ខារ វីរិយសមាធិ ចិត្តសមាធិ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសសមាធិ និងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ នេះ គួរចម្រើន ដើម្បីកំណត់ដឹងនូវរាគៈ ។បេ។ ដើម្បីអស់ទៅ ដើម្បីលះបង់ ដើម្បីក្សយទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ ។ ធម៌ ៤ ប្រការនេះ គួរចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ ដើម្បីក្សយទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ ( ចងក្រោធទុក ) មក្ខៈ ( រមិលគុណ ) បឡាសៈ ( លើកខ្លួនផ្ទឹម ) ឥស្សា ( ឫស្យា ) មច្ឆរិយៈ ( កំណាញ់ ) មាយា ( បិទបាំងទោស ) សាឋេយ្យ ( អួតអាង ) ថម្ភៈ ( មុខរឹង ) សារម្ភៈ ( ប្រណាំងវាសនា ) មានៈ ( ប្រកាន់ខ្លួន ) អតិមានៈ ( មើលងាយគេ ) មទៈ ( ស្រវឹង ) បមាទៈ ( ប្រាសចាកសតិ ) ។

**ចតុក្កនិបាត ចប់**

# អដ្ឋកថា

## ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក

[ ១២៤ ] *ភគវេយ្យាល លោកពោលឲ្យសម្រេចដល់អរហត្ត ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។*

ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក ចប់

អដ្ឋកថា ចតុក្កនិបាតនៃអង្គុត្តរនិកាយ

ឈ្មោះមនោរថបូរណី ចប់

# សុត្តន្តបិដក

# អង្គុត្តរនិកាយ បញ្ចកនិបាត

# បញ្ចមភាគ

*សូមថ្វាយបង្គំព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## បឋមបណ្ណាសក

## សេក្ខពលវគ្គទី ១

### សង្ខិត្តសូត្រទី ១

[ ១ ] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គល មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកបដោយកម្លាំងសទ្ធា*

ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងហិរិ ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងឱត្តប្បៈ ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងវីរិយៈ ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខ-បុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា
# អង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី
# បញ្ចកនិបាត
# បឋមបណ្ណាសក
# សេក្ខពលវគ្គទី ១

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## សង្ខិត្តសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខិត្តសូត្រទី ១ នៃបញ្ចកនិបាតដូចតទៅនេះថា ពលរបស់ព្រះសេក្ខៈ ៧ ពួក ហេតុនោះ ទើបឈ្មោះថា* **សេក្ខពល** ។ *បណ្តាសទ្ធាពលជាដើម ឈ្មោះថា* **សទ្ធាពល** *ព្រោះមិនញាប់ញ័រដោយការមិនជឿ ។ ឈ្មោះថា* **ហិរិពល** *ព្រោះមិនញាប់ញ័រដោយការមិនមានខ្មាស ។ ឈ្មោះថា* **អនោត្តប្បពល** *ព្រោះមិនញាប់ញ័រដោយការមិនខ្លាចបាប ។ ឈ្មោះថា* **វីរិយពល** *ព្រោះមិនញាប់ញ័រដោយការខ្ជិលច្រអូស ។ ឈ្មោះថា* **បញ្ញាពល** *ព្រោះមិនញាប់ញ័រដោយអវិជ្ជា ។ បទថា* **តស្មា** *ប្រែថា ព្រោះហេតុដែលពលទាំងនោះ ជាពលរបស់ព្រះសេក្ខៈទាំងឡាយ ដូច្នោះ ។*

# សុត្តន្តបិដក

## វិត្ថតសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធាជឿពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាស្មើគ្មាន ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់កំណើតថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងហិរិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានហិរិ អៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត អៀនខ្មាសចំពោះការប៉ះពាល់នូវអកុសលធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងហិរិ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងឱត្តប្បៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានឱត្តប្បៈ តក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត តក់ស្លុតចំពោះការប៉ះពាល់នូវអកុសលធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ នេះហៅថា

កម្លាំងឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវីរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាមដើម្បីលះបង់អកុសលធម៌ ដើម្បីញ៉ាំងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីខ្មីឃ្មាតដ៏មាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងវីរិយៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា បរិបូណ៌ដោយបញ្ញា ដែលអាចកំណត់ដឹងនូវការកើតនិងការរលត់ ( នូវខន្ធ ) ជាបញ្ញាដ៏ប្រសើរ សម្រាប់ទម្លុះទម្លាយ ( នូវគំនរកិលេស ) ជាបញ្ញាអាចញ៉ាំងវដ្តទុក្ខឲ្យអស់ទៅដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គល មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកបដោយកម្លាំងសទ្ធា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ដោយកម្លាំងហិរិ ... ដោយកម្លាំងឱត្តប្បៈ ... ដោយកម្លាំងវីរិយៈ ... គួរជាអ្នកប្រកបដោយកម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## វិត្ថតសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិត្ថតសូត្រទី ២ ដូចតទៅនេះ ក្នុងបទថា **កាយទុច្ចរិតេន** ជាដើម ជាតតិយាវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ អធិប្បាយថា ខ្មាស រង្កៀសនូវកាយទុច្ចរិតជាដើម ដែលគួរខ្មាស ។ ក្នុងឱត្តប្បនិទ្ទេស ជាតតិយាវិភត្តិ ចុះក្នុងអត្ថថា ហេតុ អធិប្បាយថា ខ្លាចញញើត ព្រោះកាយទុច្ចរិតជាដើម ដែលជាហេតុនៃឱត្តប្បៈ។ បទថា **អារទ្ធវីរិយោ** បានដល់ ផ្គងសេចក្ដីព្យាយាម មានចិត្តមិនរួញរា ។ បទថា **បហានាយ** ប្រែថា ដើម្បីលះបង់ ។ បទថា **ឧបសម្បទាយ** ប្រែថា ដើម្បីបានចំពោះ ។ បទថា **ថាមវា** បានដល់ ប្រកបដោយកម្លាំង គឺសេចក្ដីព្យាយាម ។ បទថា **ទឡ្ហបរក្កមោ** បានដល់ មានសេចក្ដីព្យាយាមមាំទាំ ។ បទថា **អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ** បានដល់ មិនដាក់ធុរៈ ព្យាយាមមិនធូរថយ ក្នុងកុសលធម៌ទាំងឡាយ ។ បទថា **ឧទយត្ថគាមិនិយា** បានដល់ ដែលឲ្យដល់នូវការកើត ការរលត់ទៅនៃខន្ធទាំង ៥ អាចដឹងច្បាស់នូវការកើតនិងការវិនាសបាន ។ បទថា **បញ្ញាយ សមន្នាគតោ** បានដល់ ជាអ្នកដល់ព្រមដោយវិបស្សនាបញ្ញា និងមគ្គប្បញ្ញា ។ បទថា **អរិយាយ** បានដល់ តាំងនៅឆ្ងាយអំពីកិលេសទាំងឡាយ ដោយការសង្កត់សង្កិន និងដោយការកាត់ផ្ដាច់ ឈ្មោះថា បរិសុទ្ធ ។ បទថា **និព្វេធិកាយ** សេចក្ដីថា បញ្ញានោះ លោកហៅថា **និព្វេធិកា** ព្រោះដឹងច្បាស់ អធិប្បាយថា

*ប្រកបដោយនិព្វេធិកបញ្ញានោះ ។ ក្នុងសេចក្តីនោះ មគ្គ ឈ្មោះថា* **និព្វេធិកា** *ព្រោះទម្លាយនូវគំនរលោភៈ គំនរទោសៈ និងគំនរមោហៈ ដែលមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយ ដោយអំណាចសមុច្ឆេទប្បហាន ។ វិបស្សនាបញ្ញា ឈ្មោះថា* **និព្វេធិកា** *ដោយអំណាចតទង្គប្បហាន ។ ម្យ៉ាងទៀត វិបស្សនាគួរហៅថា* **និព្វេធិកា** *ព្រោះប្រព្រឹត្តទៅដើម្បីបាននូវមគ្គបញ្ញា ។ ក្នុងបទថា* **សម្មាទុក្ខក្ខយគាមិនិយា** *នេះ មគ្គបញ្ញា ឈ្មោះថា* **សម្មាទុក្ខក្ខយគាមិនី** *ព្រោះធ្វើវដ្តទុក្ខ និងកិលេសទុក្ខឲ្យអស់ទៅដោយប្រពៃ ដោយហេតុ ដោយន័យ ។ វិបស្សនាបញ្ញា ឈ្មោះថា* **ទុក្ខក្ខយគាមិនី** *ព្រោះធ្វើវដ្តទុក្ខ និងកិលេសទុក្ខឲ្យអស់ទៅ ដោយអំណាចតទង្គប្បហាន ។ វិបស្សនាបញ្ញានោះគប្បីជ្រាបថាជា* **ទុក្ខក្ខយគាមិនី** *ព្រោះប្រព្រឹត្តទៅដោយការដល់នូវការអស់ទុក្ខ ឬដោយការបានចំពោះនូវមគ្គបញ្ញា ។ ក្នុងសូត្រនេះ លោកពោលពល ៥ លាយឡំគ្នា ដោយប្រការដូច្នេះ ៕*

## អដ្ឋកថាវិត្ថតសូត្រទី ២ ចប់

# សុត្តន្តបិដក

## ទុក្ខសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីតានតឹង ចង្អៀតចង្អល់ ក្រវល់ក្រវាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ជាអ្នកខ្ជិល ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីតានតឹង ចង្អៀតចង្អល់ ក្រវល់ក្រវាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តែងនៅជាសុខ មិនមានសេចក្តីតានតឹង មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយក្នុងបច្ចុប្បន្នឡើយ លុះបែកធ្លាយរាង កាយស្លាប់ទៅ សុគតិនឹងមានប្រាកដ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ មានវិរិយៈប្រារព្ធ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្តីតានតឹង មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្នឡើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ សុគតិនឹងមានប្រាកដ ។

## ភតសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ជាអ្នកខ្ជិល ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ មានវីរិយៈប្រារព្ធ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។

## សិក្ខសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុ ឬភិក្ខុនីលាសិក្ខា ត្រឡប់មកកាន់ភេទដ៏ថោកទាប ពាក្យតូចពាក្យធំ សមតាមហេតុ ៥ យ៉ាង រមែងមកកាន់ស្ថាន ដែលគួរតិះដៀលចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ពាក្យតូចពាក្យធំ ៥ យ៉ាង តើអ្វីខ្លះ ។ គឺសូម្បីតែសទ្ធាក្នុងកុសលធម៌ របស់អ្នកក៏មិនមាន ១ សូម្បីហិរិក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ សូម្បីឱត្តប្បៈក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ សូម្បីសេចក្តីខ្មីឃ្មាតក្នុងកុសលធម៌របស់

អ្នកក៏មិនមាន ១ សូមៀបញ្ញា ( ការចេះដឹង ) ក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ភិក្ខុ ឬភិក្ខុនីលាសិក្ខាមកកាន់ភេទដ៏ថោកទាប ពាក្យតូចពាក្យធំសមតាមហេតុ ៥ យ៉ាងនេះ រមែងមកកាន់ស្ថាន ដែលគួរតិះដៀលចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុ ឬភិក្ខុនី មានមុខជោកដោយទឹកភ្នែក យំយែក ទំប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ទាំងទុក្ខទាំងទោមនស្ស ពាក្យ ( សរសើរ ) សមតាមហេតុ ៥ យ៉ាង រមែងមកកាន់ស្ថាន ដែលគួរសរសើរចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ពាក្យ ( សរសើរ ) សមតាមហេតុ ៥ យ៉ាង តើអ្វីខ្លះ ។ គឺសទ្ធាក្នុងកុសលធម៌របស់អ្នកក៏មាន ១ ហិរិក្នុងកុសលធម៌របស់អ្នកក៏មាន ១ ឱត្តប្បៈក្នុងកុសលធម៌របស់អ្នកក៏មាន ១ សេចក្តីខ្មីឃ្មាតក្នុងកុសលធម៌ របស់អ្នកក៏មាន ១ បញ្ញា ( ការចេះដឹង ) ក្នុងកុសលធម៌របស់អ្នកក៏មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុ ឬភិក្ខុនី មានមុខជោកដោយទឹកភ្នែក យំយែក ទំប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ទាំងទុក្ខទាំងទោមនស្ស ពាក្យ ( សរសើរ ) សមតាមហេតុ ៥ យ៉ាងនេះឯង រមែងមកកាន់ស្ថានដែលគួរសរសើរ ចំពោះមុខបុគ្គលនោះ ក្នុងបច្ចុប្បន្ននេះ ។

## សមាបត្តិសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ ក្នុងកុសល-

ធម៌មានត្រឹមណា ការប៉ះពាល់នូវអកុសលធម៌ ក៏មិនមានត្រឹមណោះ ម្នាល ភិក្ខុទាំងឡាយ លុះសទ្ធាសាបសូន្យទៅ អស្សទ្ធិយៈ ( ការមិនជឿ ) រួបរឹត ក្នុងកាលណា ការប៉ះពាល់នូវអកុសលធម៌ មានក្នុងកាលណោះ ។ ម្នាលភិក្ខុ ទាំងឡាយ ហិរិដែលបុគ្គលតម្កល់ស៊ប់ ក្នុងកុសលធម៌មានត្រឹមណា ការប៉ះ ពាល់នូវអកុសលធម៌ ក៏មិនមានត្រឹមណោះ ម្នាលភិក្ខុទាំងឡាយ លុះហិរិសាប សូន្យទៅ អហិរិកៈ ( សេចក្ដីមិនអៀនខ្មាស ) រួបរឹតក្នុងកាលណា ការប៉ះ ពាល់នូវអកុសលធម៌ ក៏មានក្នុងកាលណោះ ។ ម្នាលភិក្ខុទាំងឡាយ ឱត្តប្បៈ ដែលបុគ្គលតម្កល់ស៊ប់ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុ-សលធម៌ក៏មិនមានត្រឹមណោះ ម្នាលភិក្ខុទាំងឡាយ លុះឱត្តប្បៈសាបសូន្យទៅ អនោត្តប្បៈ ( សេចក្ដីមិនតក់ស្លុត ) រួបរឹតក្នុងកាលណា ការប៉ះពាល់នូវ អកុសលធម៌ ក៏មានក្នុងកាលណោះ ។ ម្នាលភិក្ខុទាំងឡាយ វិរិយៈដែលបុគ្គល តម្កល់ស៊ប់ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសល ក៏មិនមាន ត្រឹមនោះ ម្នាលភិក្ខុទាំងឡាយ លុះវិរិយៈសាបសូន្យទៅ កោសជ្ជៈរួបរឹតក្នុង កាលណា ការប៉ះពាល់នូវអកុសល ក៏មានក្នុងកាលនោះ ។ ម្នាលភិក្ខុទាំង-ឡាយ បញ្ញាដែលបុគ្គលតម្កល់ស៊ប់ ក្នុងកុសលធម៌មានត្រឹមណា ការប៉ះពាល់ នូវអកុសល ក៏មិនមានត្រឹមនោះ ម្នាលភិក្ខុទាំងឡាយ លុះបញ្ញាសាបសូន្យ ទៅ ទុប្បញ្ញា ( ការអប្បបញ្ញា ) រួបរឹតក្នុងកាលណា ការប៉ះពាល់នូវអកុសល ក៏មានក្នុងកាលនោះ ។

# អដ្ឋកថា

## សមាបត្តិសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាបត្តិសូត្រទី ៦ ដូចតទៅនេះ បទថា **អកុសលស្ស សមាបត្តិ** បានដល់ ការដល់ព្រមដោយការចូលដល់អកុសលធម៌ ។ បទថា **បរិយុទ្ធាយ តិដ្ឋតិ** បានដល់ គ្របសង្កត់ ៕

**អដ្ឋកថា សមាបត្តិសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## កាមសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ច្រើនតែជាប់ចិត្តក្នុងកាម ម្នាលភិក្ខុទាំងឡាយ បើកុលបុត្រលះបង់កណ្ដៀវ និងអម្រែក ចេញចាកផ្ទះចូលទៅកាន់ផ្នួស គួរហៅថា កុលបុត្រអ្នកមានសទ្ធាចេញបួស ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា កុលបុត្រអ្នកមានវ័យគួរបាននូវកាមទាំងឡាយ តាមតែបែបណា ។ ម្នាលភិក្ខុទាំងឡាយ ទោះកាមទាំងឡាយណាថោកទាបក្តី កាមទាំងឡាយណាកណ្ដាលក្តី កាមទាំងឡាយណាឧត្តមក្តី កាមទាំងអស់នោះ ក៏រាប់ថាជាកាមដូចៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ ដូចកុមារតូចទន់ខ្ចីដេកផ្ងារ បៀមកំណាត់ឈើ ឬអំបែងក្នុងមាត់ ព្រោះអាស្រ័យ

សេចក្តីប្រហែសរបស់ស្រីមេដោះៗ ( នោះលុះឃើញហើយ ) ក៏យកចិត្ត ទុកដាក់ដោយប្រញាប់ប្រញាល់ លុះយកចិត្តទុកដាក់ដោយប្រញាប់ប្រញាល់ ហើយ ក៏នាំចេញនូវកំណាត់ឈើ ឬអំបែងនោះ ដោយប្រញាប់ប្រញាល់ ប្រសិនបើមិនអាចនឹងនាំចេញដោយប្រញាប់ប្រញាល់បានទេ ក៏យកដៃឆ្វេង ត្រកងដោយរហ័ស ហើយធ្វើម្រាមចង្អុលដៃខាងស្តាំឲ្យខុប ខ្វេះយកចេញ ដោយទាំងឈាមមកផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះ ( ខ្លាច ) សេចក្តីលំបាកនុ៎ះ នឹងមានដល់កុមារ តថាគតមិន ពោលថា សេចក្តីលំបាកនុ៎ះ មិនមានដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ស្រីមេ ដោះដែលមានប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គួរតែធ្វើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ លុះកាលណាកុមារនោះ ចម្រើនធំឡើង មានបញ្ញាសមគួរហើយ ម្នាលភិក្ខុ ទាំងឡាយ ទើបស្រីមេដោះ ក៏មិនសូវគយគន់មើលចំពោះកុមារនោះទេ ដោយនឹកសង្ឃឹមថា ឥឡូវនេះ កុមារចេះរក្សាខ្លួន លែងមានសេចក្តីប្រហែស ធ្វេសហើយ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មាន ឧបមេយ្យដូចភិក្ខុមិនធ្វើដោយសទ្ធាក្នុងកុសលធម៌ មិនធ្វើដោយហិរិក្នុង កុសលធម៌ មិនធ្វើដោយឱត្តប្បៈក្នុងកុសលធម៌ មិនធ្វើដោយវីរិយៈក្នុង កុសលធម៌ មិនធ្វើដោយបញ្ញាក្នុងកុសលធម៌ ដរាបណា ម្នាលភិក្ខុទាំង-ឡាយ តថាគតត្រូវតែតាមថែរក្សាភិក្ខុនោះ ដរាបនោះដែរ ។ ម្នាលភិក្ខុទាំង-

ឡាយ លុះកាលណា ភិក្ខុធ្វើដោយសទ្ធាក្នុងកុសលធម៌ ធ្វើដោយហិរិក្នុងកុសលធម៌ ធ្វើដោយឱត្តប្បៈក្នុងកុសលធម៌ ធ្វើដោយវីរិយៈក្នុងកុសលធម៌ ធ្វើដោយបញ្ញាក្នុងកុសលធម៌ហើយ ម្នាលភិក្ខុទាំងឡាយ ទើបតថាគត ក៏មិនសូវគយគន់មើលចំពោះភិក្ខុនោះទេ ដោយនឹកសង្ឃឹមថា ឥឡូវនេះ ភិក្ខុនេះចេះរក្សាខ្លួន លែងមានសេចក្ដីប្រហែសធ្វេសហើយ ។

# អដ្ឋកថា

## កាមសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាមសូត្រទី ៧ ដូចតទៅនេះ បទថា **កាមេសុ លឡិតា** បានដល់ ជប់ជ្រប់ក្រៃលែងក្នុងវត្ថុកាម និងកិលេស-កាម ។ បទថា **អសិតព្យាភង្គិ** បានដល់ កណ្ដៀវប្រូតស្មៅ និងដងរែកស្មៅ ។ បទថា **កុលបុត្តោ** បានដល់ កុលបុត្រមានមារយាទ ។ បទថា **ឱហាយ** ប្រែថា លះហើយ ។ បទថា **អលំ វចនាយ** បានដល់ គួរពោល ។ បទថា **លព្ភា** បានដល់ បានងាយ គឺអាចបាន ។ បទថា **ហីនា កាមា** បានដល់ កាមរបស់សត្វ មានត្រកូល ទាប ៥ ។ បទថា **មជ្ឈិមា កាមា** បានដល់ កាមរបស់សត្វថ្នាក់កណ្ដាល ។ បទថា **បណីតា កាមា**

បានដល់ កាមរបស់ព្រះរាជា និងអមាត្យរបស់ព្រះរាជា ។ បទថា **កាមា-តោវ សង្ខំ គច្ឆន្តិ** សេចក្តីថា រាប់បានថា កាមទាំងអស់ ព្រោះអំណាចការប្រាថ្នា និងព្រោះអំណាចអារម្មណ៍ដែលគប្បីប្រាថ្នា ។

បទថា **វុឌ្ឍោ ហោតិ** ប្រែថា ជាមនុស្សចាស់ ។ បទថា **អលំ បញ្ញោ** គឺមានបញ្ញាសមគួរហើយ ។ បទថា **អត្តគុត្តោ** បានដល់ ឃុំគ្រងរក្សាដោយខ្លួនឯងបាន ឬអាចរក្សាឃុំគ្រងបាន ។ បទថា **ឆាលំ សមាទាយ** ប្រែថា មិនគួរប្រមាទ ។ បទថា **សទ្ធាយ អកតំ ហោតិ** សេចក្តីថា កិច្ចណាដែលគួរធ្វើក្នុងកុសលធម៌ទាំងឡាយដោយសទ្ធា កិច្ចនោះ មិនទាន់បានធ្វើ ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ ដោយបទថា **អនបេក្ខោ បនាហំ ភិក្ខវេ តស្មឹ ហោមិ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតដាក់ចិត្តក្នុងបុគ្គលនោះ ជាអ្នកធ្វើកិច្ចដែលគួរធ្វើដោយសទ្ធាជាដើមយ៉ាងនេះហើយ តាំងនៅក្នុងសោតាបត្តិផល ក្នុងសូត្រនេះត្រាស់សោតាបត្តិមគ្គ ៕

**អដ្ឋកថា កាមសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ចវនសូត្រទី៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ( សាសនធម៌ ) ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានសទ្ធា រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានហិរិ រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានឱត្តប្បៈ រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលប្រអូស រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអប្បឥតបញ្ញា រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្មបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបមិនឃ្លាត រមែងតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានហិរិ រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា រមែងមិនឃ្លាត តាំង

នៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្មបាន ។

# អដ្ឋកថា

## ចវនសូត្រ

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចវនសូត្រទី ៨ ដូចតទៅនេះ បទថា **សទ្ធម្មេ** បានដល់ សាសនសទ្ធម្ម ។ បទថា **អស្សទ្ធោ** បានដល់ ដែលវៀរចាកសទ្ធា ២ យ៉ាង គឺឱកប្បនសទ្ធា សទ្ធាដែលចុះស៊ប់ និងបច្ចក្ខសទ្ធា គឺសទ្ធាដែលជាក់ច្បាស់ ។ បទថា **ចវតិ ន បតិដ្ឋាតិ** បានដល់ ឃ្លាតចាកគុណក្នុងសាសនានេះ មិនអាចតាំងនៅបាន ។ ក្នុងសូត្រនេះ ត្រាស់ទាំងការតាំងនៅមិនបាន ទាំងការតាំងនៅបាន ។

**អដ្ឋកថា ចវនសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមអគារវសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុអ្នកមិនមានហិរិ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានឱត្តប្បៈ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអប្បឥតបញ្ញា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានហិរិ មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ក្នុងព្រះសទ្ធម្មបាន ។

# អដ្ឋកថា

## បឋមអគារវសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអគារវសូត្រទី ៩ ដូចតទៅនេះ ភិក្ខុ ឈ្មោះថា **អគារវ** ព្រោះមិនមានការគោរព ។ ឈ្មោះថា **អប្បតិស្ស** ព្រោះមិនមានការកោតក្រែង គឺមិនមានអ្នកធំ មិនប្រព្រឹត្តឱនលំទោន ពាក្យដ៏សេសក្នុងសូត្រនេះ ដូចគ្នានឹងសូត្រមុននោះឯង ។

# សុត្តន្តបិដក

## ទុតិយអគារវសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានហិរិ ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានឱត្តប្បៈ ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអប្បឥតបញ្ញា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង គួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា មានសេចក្តីគោរព មានសេចក្តីកោតក្រែង គួរនឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ម្នាលភិក្ខុ

ទាំងឡាយ ភិក្ខុអ្នកមានហិរិ ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា មានសេចក្តីគោរព មានសេចក្តីកោតក្រែង គួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មានសេចក្តីគោរព មានសេចក្តីកោតក្រែង គួរនឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។

សេក្ខពលវគ្គទី ១ ចប់

## ឧទ្ទាននៃសេក្ខពលវគ្គនោះ គឺ

និយាយអំពីកម្លាំងរបស់សេក្ខបុគ្គលយ៉ាងសង្ខេប ១ កម្លាំងរបស់សេក្ខបុគ្គលយ៉ាងពិស្តារ ១ ភិក្ខុមានធម៌ ៥ យ៉ាង តែងនៅជាទុក្ខ ១ ភិក្ខុមានធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ១ ភិក្ខុ ឬភិក្ខុនីលាសិក្ខា ១ ជាគម្រប់ ៥ ការប៉ះពាល់អកុសល ១ សត្វតែងជាប់ចិត្តក្នុងកាម ១ ភិក្ខុឃ្លាតចាកព្រះសទ្ធម្ម ១ ភិក្ខុមិនមានសេចក្តីគោរព ២ លើក ។

# អដ្ឋកថា

## ទុតិយអគារវសូត្រ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអគារវសូត្រទី ១០ ដូចតទៅនេះ បទថា **អភព្វោ** គឺដល់នូវភាពជាបុគ្គលអភព្វ ។ បទថា **វុឌ្ឍឹ** ប្រែថា ចម្រើន ។ បទថា **វិរុឡ្ហឹ** បានដល់ សល់នូវភាពជាអ្នកមិនញាប់ញ័រ ព្រោះភាពជាបុគ្គលដុះដាល ។ បទថា **វេបុល្លំ** បានដល់ ភាពជាធំ ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថា ទុតិយអគារវសូត្រទី ១០ ចប់**

**សេក្ខពលវគ្គទី ១ ចប់**

# សុត្តន្តបិដក

# ពលវគ្គទី ២

## អននុស្សុតសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាថា ជាអ្នកដល់នូវអរហត្ត ជាទីបំផុតនៃអភិញ្ញា និងត្រើយនៃអភិញ្ញា ក្នុងធម៌ដែលមិនធ្លាប់ឮមកក្នុងកាលមុន ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយកម្លាំងទាំងឡាយណា ទើបប្តេជ្ញានូវតំណែងដ៏ប្រសើរ បន្លឺសីហនាទក្នុងកណ្តាលបរិស័ទ ញុំាងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ កម្លាំងរបស់តថាគតនោះ មាន ៥ យ៉ាងនេះ ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺ កម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតប្រកបដោយកម្លាំងទាំងឡាយណា ទើបប្តេជ្ញានូវតំណែងដ៏ប្រសើរ បន្លឺសីហនាទក្នុងកណ្តាលបរិស័ទ ញុំាងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ កម្លាំងតថាគតរបស់តថាគតនោះ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

# ពលវគ្គទី ២

## អននុស្សុតសូត្រ

[ ១១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងអននុស្សុតសូត្រទី ១ នៃពលវគ្គទី ២ ដូចតទៅនេះ បទថា* **បុព្វាហំ ភិក្ខវេ អននុស្សុតេសុ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតដឹងក្រៃលែងក្នុងធម៌ទាំងឡាយ គឺសច្ចធម៌ ៤ ដែលតថាគតមិនធ្លាប់ស្តាប់ក្នុងកាលមុន ។ បទថា* **អភិញ្ញាវោសានបារមិប្បត្តោ បដិជានាមិ** *ព្រះមានព្រះភាគទ្រង់សម្តែងដល់គុណដែលទ្រង់សម្រេច ក្នុងមហាពោធិបល្ល័ង្កថា តថាគតដឹងក្រៃលែងក្នុងសច្ចធម៌ ដោយការធ្វើកិច្ច ១៦ យ៉ាង សម្រេចដោយមគ្គ ៤ ហើយដល់នូវបារមីចុងក្រោយ គឺត្រើយនៃភាពជាអ្នកធ្វើកិច្ចស្រេចហើយ ព្រោះកិច្ចទាំងអស់ចប់ហើយ ទើបប្តេជ្ញា ។ បទថា* **តថាគតស្ស** *បានដល់ របស់ព្រះតថាគតដោយហេតុ ៨ យ៉ាង ។ បទថា* **តថាគតពលានិ** *បានដល់ កម្លាំងញាណដែលដល់ហើយ គឺប្រព្រឹត្តទៅហើយ ដោយអាការដែលគប្បីដល់បានដោយកម្លាំងទាំងនោះ ។ បទថា* **អាសភណ្ឋានំ** *គឺឋានៈដែលប្រសើរបំផុត ។ បទថា* **សីហនាទំ** *គឺដែលបន្លឺដ៏ក្លៀវក្លា ។ បទថា* **ព្រហ្មចក្កំ** *គឺចក្រដ៏ប្រសើរ ។ បទថា* **បវត្តេតិ** *គឺពោល ។l៚*

**អដ្ឋកថា អននុស្សុតសូត្រទី ១ ចប់**

# សុត្តន្តបិដក

## កូដសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវិរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្លាំងរបស់សេក្ខបុគ្គលទាំង ៥ នេះ កម្លាំងបញ្ញាជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបសួប ( នៃកម្លាំងទាំងពួង ) ម្នាលភិក្ខុទាំងឡាយ ដូចផ្ទះកំពូលមានកំពូលជារបស់ប្រសើរ ជាទីប្រជុំព្រម ជាទីអបសួប ( នៃទព្វសម្ភារៈទាំងពួង ) មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្លាំងរបស់សេក្ខបុគ្គលទាំង ៥ យ៉ាងនេះ កម្លាំងបញ្ញាជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបសួប ( នៃកម្លាំងទាំងពួង ) ក៏មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកបដោយកម្លាំងសទ្ធា ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងហិរិ ...កម្លាំងឱត្តប្បៈ ...កម្លាំងវិរិយៈ ...កម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## កូដសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកូដសូត្រទី ២ ដូចតទៅនេះ បទថា **សេក្ខពលានិ** បានដល់ កម្លាំងញាណរបស់ព្រះសេក្ខៈ ។ បទថា **អគ្គំ** គឺ ឧត្តម ។ សេក្ខពល ឈ្មោះថា **សង្គាហិក** ជាទីប្រជុំ ព្រោះប្រជុំពល ដ៏សេស ដូចផ្ទះកំពូលប្រជុំត្រង់កំពូល ដូច្នោះ ។ សេក្ខពល ឈ្មោះថា **សង្ឃាតនិយ** ជាទីប្រជុំ ព្រោះធ្វើពលទាំងនោះឲ្យប្រជុំគ្នា ។ល។

**អដ្ឋកថា កូដសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សង្ខិត្តសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវីរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះ ឯង ។

# អដ្ឋកថា

## សន្និត្តសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្និត្តសូត្រទី ៣ ដូចតទៅនេះ ក្នុងពលទាំងនោះ ឈ្មោះថា **សតិពល** ព្រោះមិនញាប់ញ័រ ដោយភាពជាអ្នកមិនមានស្មារតី ឈ្មោះថា **សមាធិពល** ព្រោះមិនញាប់ញ័រដោយការរាយមាយ ។ល។

**អដ្ឋកថា សន្និត្តសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## វិត្ថតសូត្រទី ៤

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវិរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយ

ស្មើគ្នា ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាគ្រូនៃទេវតា និងមនុស្ស ទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវីរិយៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ ដើម្បីញុំាងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំងចិត្ត មានសេចក្ដីប្រឹងប្រែងដ៏មុតមាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងវីរិយៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសតិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសតិប្រកបដោយបញ្ញា ដែលមានសតិជាជំនួយដ៏ប្រសើរ ជាអ្នករឭកនឹកឃើញជាក់នូវអំពើដែលធ្វើរួចយូរហើយខ្លះ នូវសម្ដីដែលពោលរួចយូរហើយខ្លះ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា កម្លាំងសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសមាធិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ បានដល់ បឋមជ្ឈានដែលប្រកបដោយវិតក្កវិចារ មានបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងាប់ស្ងាត់ ព្រោះរម្ងាប់វិតក្កវិចារ បានដល់ ទុតិយជ្ឈាន ជាគុណជាតមានក្នុងសន្ដាននៃខ្លួន មានសេចក្ដីជ្រះថ្លាមាំ គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះលះបង់បីតិ

ផង ជាអ្នកព្រងើយកន្តើយផង មានសតិសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ក៏បានដល់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសរសើរថា បុគ្គលដែលបានដល់តតិយជ្ឈាន រមែងជាអ្នកព្រងើយកន្តើយ មានសតិនៅជាសុខ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះអស់សោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ក៏បានដល់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាដែលអាចកំណត់ដឹងនូវការកើត និងការរលត់ ជាបញ្ញាដ៏ប្រសើរ សម្រាប់ទម្លុះទម្លាយ ( នូវគំនរកិលេស ) ជាបញ្ញាអាចញ៉ាំងវដ្តទុក្ខ ឲ្យអស់ទៅដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## វិត្ថតសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិត្ថតសូត្រទី ៤ ដូចតទៅនេះ បទថា **សតិនេបក្កេន** នេះ បញ្ញា លោកហៅថា **នេបក្កៈ** គឺបញ្ញារក្សាខ្លួន ។ លោក

កាន់យកបញ្ញានោះ ដោយភាពជាធម៌ឧបការៈដល់សតិ ។៤៤។

## អដ្ឋកថាវិត្ថតសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ទដ្ឋព្វសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវិរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងអង្គនៃសោតាបត្តិ ៤ ។ កម្លាំងសទ្ធាគួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវិរិយៈ គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងសម្មប្បធាន ៤ ។ កម្លាំងវិរិយៈគួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសតិគួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងសតិប្បដ្ឋាន ៤ ។ កម្លាំងសតិគួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសមាធិគួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងឈាន ៤ ។ កម្លាំងសមាធិគួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញាគួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងអរិយសច្ច ៤ ។ កម្លាំងបញ្ញាគួរឃើញក្នុងធម៌នេះ ។

ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទដ្ឋព្វសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទដ្ឋព្វសូត្រទី ៥ ដូចតទៅនេះ ព្រះមានព្រះភាគ ដើម្បីត្រាស់លោកុត្តរធម៌ក្នុងទីដែលមិនមែនវិស័យ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ គប្បីឃើញសទ្ធាពល ក្នុងធម៌ណាដូច្នេះ ។ ឧបមាដូចសម្លាញ់ គឺកូនសេដ្ឋី ៤ នាក់ មានព្រះរាជាជាគម្រប់ ៥ ព្រះរាជាយាងចុះកាន់ផ្លូវ ដោយគិតថា អញនឹងលេងនក្ខត្តឫក្ស ក្នុងពេលទៅកាន់ផ្ទះរបស់សេដ្ឋីបុត្រទី ១ ជន ៤ នាក់ទៀត ក៏អង្គុយស្ងៀម ម្ចាស់ផ្ទះពោលថា ពួកអ្នកចូរឲ្យរបស់ទំពា របស់បរិភោគ ផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងប្រដាប់ជាដើមដល់អ្នកជនទាំងនេះ ដូច្នេះហើយ ចាត់ចែងក្នុងផ្ទះ ។ ក្នុងគ្រាទៅផ្ទះរបស់សេដ្ឋីបុត្រទី ២-៣-៤ ជន ៤ នាក់ទៀតក៏អង្គុយស្ងៀម ម្ចាស់ផ្ទះពោលថា ពួកអ្នកចូរឲ្យរបស់ទំពា របស់បរិភោគ ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងប្រដាប់ដល់ជនទាំងនេះ ដូច្នេះហើយ ចាត់ចែងក្នុងផ្ទះ ។ ក្នុងកាលតមក ក្នុងវេលាទៅក្នុងព្រះរាជមន្ទីររបស់ព្រះរាជាក្រោយគេបង្អស់ សូម្បីព្រះរាជាទ្រង់ជាធំក្នុងជនទាំងអស់ក៏ពិត ក្នុងគ្រានេះ ក៏នៅតែត្រាស់ថា

ពួកអ្នកចូរឲ្យរបស់ទំពា របស់បរិភោគ ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងប្រដាប់ជាដើមដល់ជនទាំងនេះ ដូច្នេះ រួចទ្រង់ចាត់ចែងក្នុងព្រះរាជមន្ទីររបស់ព្រះអង្គ យ៉ាងណា កាលពល មានសទ្ធាជាគម្រប់ ៥ កើតឡើងក្នុងអារម្មណ៍តែមួយ ក៏ដូចសម្លាញ់ទាំងនោះ ចុះកាន់វិថីដើររួមគ្នា សម្លាញ់ ៤ នាក់ទៀត អង្គុយស្ងៀមក្នុងផ្ទះរបស់សម្លាញ់ទី ១ សម្លាញ់ដែលជាម្ចាស់ផ្ទះរមែងចាត់ចែងការងារ យ៉ាងណា សទ្ធាពលមានលក្ខណៈបង្អោនជឿ ព្រោះសម្រេចសោតាបត្តិយង្គ ទើបជាធំ ជាប្រធាន ពលដ៏សេស ក៏ស្រេបតាមសទ្ធាពលនោះ ដូច្នោះ ក្នុងផ្ទះរបស់កូនសេដ្ឋីទី ២ សម្លាញ់ ៤ នាក់ទៀតក៏អង្គុយស្ងៀម សម្លាញ់ដែលជាម្ចាស់ផ្ទះ ជាអ្នកត្រួតត្រា យ៉ាងណា វិរិយ-ពល មានលក្ខណៈផ្គង ព្រោះដល់នូវសម្មប្បធាន ពលដ៏សេស ក៏ស្រេបតាមវិរិយពលនោះ ដូច្នោះ ក្នុងផ្ទះរបស់កូនសេដ្ឋីទី ៣ សម្លាញ់ ៤ នាក់ទៀត ក៏អង្គុយស្ងៀម សម្លាញ់ដែលជាម្ចាស់ផ្ទះ ជាអ្នកចាត់ចែង យ៉ាងណា សតិពលមានលក្ខណៈចូលទៅតាំងទុក ព្រោះដល់នូវសតិប្បដ្ឋាន ទើបជាធំជាប្រធាន ពលដ៏សេស ក៏ស្រេបតាមសតិពលនោះ ដូច្នោះ ក្នុងផ្ទះរបស់កូនសេដ្ឋីទី ៤ សម្លាញ់ ៤ នាក់ទៀតក៏អង្គុយស្ងៀម សម្លាញ់ដែលជាម្ចាស់ផ្ទះជាអ្នកចាត់ចែង យ៉ាងណា សមាធិពល មានលក្ខណៈមិនរាយមាយ ព្រោះដល់នូវឈានវិមោក្ខ ពលដ៏សេស ក៏អនុលោមតាមសមាធិពលនោះ ដូច្នោះ ។ តែក្នុងវេលាទៅព្រះរាជមន្ទីររបស់ព្រះរាជាក្រោយគេបង្អស់ សម្លាញ់ ៤ នាក់

ទៀតក៏អន្តុយស្ងៀម ព្រះរាជាមួយអង្គប៉ុណ្ណោះ ទ្រង់ចាត់ចែងក្នុងព្រះរាជមន្ទីរ យ៉ាងណា បញ្ញាពល មានលក្ខណៈដឹងទូទៅ ព្រោះសម្រេចអរិយសច្ច ៤ ទើបជាធំ ជាប្រធាន ពលដ៏សេស ក៏ស្រេបតាមបញ្ញាពលនោះ ដូច្នោះ លោកពោលពល ៥ ក្នុងសូត្រនេះ លាយឡំគ្នាយ៉ាងនេះ ដោយប្រការដូច្នេះ ។l៚

**អដ្ឋកថា ឧដ្ឋព្វសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បុនក្កូដសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវិរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្លាំង ៥ យ៉ាងនេះ កម្លាំងបញ្ញាជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្ដម្ភ ( នៃកម្លាំងទាំងពួង ) ។ ម្នាលភិក្ខុទាំងឡាយ ដូចផ្ទះកំពូល មានកំពូលជារបស់ប្រសើរ ជាទីប្រជុំព្រម ជាទីអបស្ដម្ភ ( នៃទព្វសម្ភារៈទាំងពួង ) មានឧបមាយ៉ាងណាមិញ ម្នាល

ភិក្ខុទាំងឡាយ បណ្ដាកម្លាំង ៥ យ៉ាងនេះឯង កម្លាំងបញ្ញាជាគុណជាត ខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្មប ( នៃកម្លាំងទាំងពួង ) ក៏មាន ឧបមេយ្យយ៉ាងនោះឯង ។

# អដ្ឋកថា

## បុនក្កូដសូត្រ

[ ១៦ ] ក្នុងបុនកូដសូត្រទី ៦ មានអត្ថងាយយល់ហើយ ។ ទ្រង់ត្រាស់សេក្ខពលប៉ុណ្ណោះ ក្នុង ៨ សូត្រ ទាំងក្នុងវគ្គមុន និងក្នុងវគ្គនេះ ។ តែព្រះមហាទត្តត្ថេរ ដែលនៅក្នុងករណ្ឌកោលវិហារពោលថា ព្រះមានព្រះភាគត្រាស់សេក្ខពល ក្នុង ៤ សូត្រខាងក្រោម ត្រាស់អសេក្ខពល ក្នុង ៤ សូត្រជាខាងលើ ។ល។

**អដ្ឋកថា បុនក្កូដសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមហិតសូត្រទី ៧

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបំពេញសីលដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញសីល ១ ជាអ្នកបំពេញសមាធិដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញសមាធិ ១ ជាអ្នកបំពេញបញ្ញាដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញបញ្ញា ១ ជាអ្នកបំពេញវិមុត្តិធម៌ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញក្នុងវិមុត្តិធម៌ ១ ជាអ្នកបំពេញវិមុត្តិញាណទស្សនៈ ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

# អដ្ឋកថា

## បឋមហិតសូត្រ

[ ១៧ ] បឋមហិតសូត្រទី ៧ ត្រាស់សីលជាខាងដើមលាយគ្នា ។ បទថា **វិមុត្តិ** បានដល់ អរហត្តផលវិមុត្តិ ។ បច្ចវេក្ខណញាណដែលជាវិមុត្តិញាណទស្សនៈ នោះ ជាលោកិយពិត ។

# សុត្តន្តបិដក

## ទុតិយហិតសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯង ។ ប្រកបដោយធម៌ ៥ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនបំពេញសីលដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញសីល ១ ជាអ្នកមិនបំពេញសមាធិដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញសមាធិ ១ ជាអ្នកមិនបំពេញបញ្ញាដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញបញ្ញា ១ ជាអ្នកមិនបំពេញវិមុត្តិធម៌ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិធម៌ ១ ជាអ្នកមិនបំពេញវិមុត្តិញ្ញាណទស្សនៈដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញ្ញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង ។

# អដ្ឋកថា

## ទុតិយហិតសូត្រ

[ ១៨ ] ទុតិយហិតសូត្រទី ៨ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់ភិក្ខុទ្រុស្តសីល ដែលមានសុតៈច្រើន ។

# សុត្តន្តបិដក

## តតិយហិតសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ជាអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯង មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនបំពេញសីលដោយខ្លួនឯង មិនបបួលអ្នកដទៃក្នុងការបំពេញសីល ១ ជាអ្នកមិនបំពេញសមាធិដោយខ្លួនឯង មិនបបួលអ្នកដទៃក្នុងការបំពេញសមាធិ ១ ជាអ្នកមិនបំពេញបញ្ញាដោយខ្លួនឯង មិនបបួលអ្នកដទៃក្នុងការបំពេញបញ្ញា ១ ជាអ្នកមិនបំពេញវិមុត្តិធម៌ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិធម៌ ១ ជាអ្នកមិនបំពេញវិមុត្តិញាណទស្សនៈដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ជាអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

# អដ្ឋកថា

## តតិយហិតសូត្រ

[ ១៩ ] តតិយហិតសូត្រទី ៩ ត្រាស់ដល់ភិក្ខុទ្រុស្តសីល ដែលមានសុតៈតិច ។

# សុត្តន្តបិដក

## ចតុត្ថហិតសូត្រទី ១០

[ ២០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍អ្នកដទៃផង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបំពេញសីលដោយខ្លួនឯងផង បបួលអ្នកដទៃក្នុងការបំពេញសីលផង ១ ជាអ្នកបំពេញសមាធិដោយខ្លួនឯងផង បបួលអ្នកដទៃក្នុងការបំពេញសមាធិផង ១ ជាអ្នកបំពេញបញ្ញាដោយខ្លួនឯងផង បបួលអ្នកដទៃក្នុងការបំពេញបញ្ញាផង ១ ជាអ្នកបំពេញវិមុត្តិធម៌ដោយខ្លួនឯងផង បបួលអ្នកដទៃក្នុងការបំពេញវិមុត្តិធម៌ផង ១ ជាអ្នកបំពេញវិមុត្តិញាណទស្សនៈដោយខ្លួនឯងផង បបួលអ្នកដទៃក្នុងការបំពេញវិមុត្តិញាណទស្សនៈផង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍អ្នកដទៃផង ។

ពលវគ្គទី ២ ចប់

### ឧទ្ទាននៃពលវគ្គនោះគឺ

សម្តែងអំពីព្រះដ៏មានព្រះភាគ ត្រាស់ដឹងសច្ចៈ ៤ ដែល
មិនធ្លាប់ឮមក ១ អំពីកម្លាំងបញ្ញាប្រៀបដូចកំពូលផ្ទះ ១
អំពីកម្លាំង ៥ យ៉ាងដោយសង្ខេប ១ ដោយពិស្តារ ១
អំពីកម្លាំង ៥ គប្បីឃើញក្នុងទីដូចម្តេច ១ អំពីកម្លាំងបញ្ញា

ប្រៀបដូចកំពូលផ្ទះម្តងទៀត ១ អំពីភិក្ខុជាអ្នកប្រព្រឹត្តដើម្បីប្រយោជន៍ មាន ៤ លើក ។

# អដ្ឋកថា

## ចតុត្ថហិតសូត្រ

[ ២០ ] ក្នុងចតុត្ថហិតសូត្រទី ១០ លោកពោលដល់ព្រះខីណាស្រពដែលមានសុតៈច្រើន ។

**អដ្ឋកថា ចតុត្ថហិតសូត្រទី ១០ ចប់**

**ពលវគ្គទី ២ ចប់**

# បញ្ចង្គិកវគ្គ

## បឋមគារវសូត្រទី ១

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ជាអ្នកមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ប្រព្រឹត្តមិនស្មើ ក្នុងពួកសព្រហ្មចារីបុគ្គលសោះ នឹងបំពេញអភិសមាចារិកធម៌ គឺបញ្ញត្តសីលបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសីលហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះរមែងមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែង ប្រព្រឹត្តស្មើក្នុងពួកសព្រហ្មចារីបុគ្គល នឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះទើបមាន បើភិក្ខុបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះទើបមាន បើបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលបាន ហេតុនុ៎ះទើបមាន បើបានបំពេញសីលហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះទើបមាន បើបានបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះទើបមាន ។

# អដ្ឋកថា

# បញ្ចង្គិកវគ្គទី ៣

## បឋមគារវសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមគារវសូត្រទី ១ នៃបញ្ចង្គិកវគ្គទី ៣ ដូចតទៅនេះ បទថា **អសភាគវុត្តិកោ** បានដល់ ប្រកបដោយការធ្វើជីវិតឲ្យប្រព្រឹត្តទៅមិនប៉ុនគ្នា មិនស្មើគ្នា ។ បទថា **អភិសមាចារិកំ ធម្មំ** បានដល់ សីលដែលបញ្ញត្តជាវត្ត ដែលជាអភិសមាចារដ៏ខ្ពង់ខ្ពស់ ។ បទថា **សេក្ខំ ធម្មំ** បានដល់ សីលដែលជាបញ្ញត្តរបស់ព្រះសេក្ខៈ ។ បទថា **សីលានិ** បានដល់ មហាសីល ៤ ។ បទថា **សម្មាទិដ្ឋី** បានដល់ សម្មាទិដ្ឋិលំដាប់វិបស្សនា ។ បទថា **សម្មាសមាធឹ** បានដល់ មគ្គសមាធិ និងផលសមាធិ ។ ក្នុងសូត្រនេះ ត្រាស់សីលជាដើមលាយគ្នា ។៚

**អដ្ឋកថា បឋមគារវសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយគារវសូត្រទី ២

[ ២២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីគោរព

មិនមានសេចក្តីកោតក្រែង ប្រព្រឹត្តមិនស្មើ ក្នុងពួកសព្រហ្មចារីបុគ្គលសោះ នឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលក្ខន្ធបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសីលក្ខន្ធហើយ នឹងបំពេញសមាធិក្ខន្ធបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសមាធិក្ខន្ធហើយ នឹងបំពេញបញ្ញាក្ខន្ធបាន ហេតុនុ៎ះរមែងមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង ប្រព្រឹត្តស្មើ ក្នុងពួកសព្រហ្មចារីបុគ្គលហើយ នឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះទើបមាន បើបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះទើបមាន បើបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលក្ខន្ធបាន ហេតុនុ៎ះទើបមាន បើបានបំពេញសីលក្ខន្ធហើយ នឹងបំពេញសមាធិក្ខន្ធបាន ហេតុនុ៎ះទើបមាន បើបានបំពេញសមាធិក្ខន្ធហើយ នឹងបំពេញបញ្ញាក្ខន្ធបាន ហេតុនុ៎ះទើបមាន ។

# អដ្ឋកថា

## ទុតិយគារវសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយគារវសូត្រទី ២ ដូចតទៅនេះ

បទថា **សីលក្ខន្ធំ** បានដល់ គំនរសីល ។ ក្នុង ២ បទដ៏សេសក៏មាន ន័យនេះដូចគ្នា ។ តែត្រាស់ខន្ធទាំង ៣ នេះលាយឡំគ្នា ។

## អដ្ឋកថា ទុតិយគារវសូត្រទី ២ ចប់

# សុត្តន្តបិដក

## ឧបក្កិលេសសូត្រទី ៣

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ មាសសៅហ្មងដោយឧបក្កិលេសណា ជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានរស្មីផង ជារបស់ប្រេះធាផង មិនងាយនឹងប្រកបការដោយស្រួលផង ឯឧបក្កិលេសនៃមាសនេះ មាន ៥ យ៉ាង ។ ឧបក្កិលេសនៃមាស ៥ យ៉ាង តើអ្វីខ្លះ ។ គឺដែក ១ ស្ពាន់ ១ សំណាកក់ ១ សំណាប៉ាហាំង ១ ប្រាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ មាសដែលសៅហ្មងដោយឧបក្កិលេសណា ជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានរស្មីផង ជារបស់ប្រេះធាផង មិនងាយនឹងប្រកបការដោយស្រួលផង ឧបក្កិលេសនៃមាសមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ កាលណាបើមាសផុតស្រឡះចាកឧបក្កិលេសទាំង ៥ យ៉ាងនេះហើយ មាសនោះ ទើបជារបស់ទន់ផង គួរដល់ការងារផង មានរស្មីផង មិន

ប្រេះធាផង ឆាយនឹងប្រកបការដោយស្រួលផង បុគ្គលណាមួយ ប្រាថ្នាគ្រឿងប្រដាប់ប្លែក ទោះបីចិញ្ចៀន ទោះបីកុណ្ឌល ទោះបីខ្សែក ឬសង្វារមាស ក៏គ្រឿងប្រដាប់ប្លែកៗ នោះ តែងសម្រេចប្រយោជន៍ដល់បុគ្គលនោះ ( សេចក្តីនេះមានឧបមាដូចម្តេចមិញ ) ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចចិត្តដែលសៅហ្មងដោយឧបក្កិលេសណា ជាធម្មជាតមិនទន់ផង មិនគួរដល់ការនោកម្មផង មិនមានរស្មីផង ជាចិត្តប្រេះធាផង មិនឆាយនឹងតម្កល់មាំដើម្បីអស់អាសវៈផង ឯឧបក្កិលេសនៃចិត្តនេះ មាន ៥ យ៉ាង ។ ឧបក្កិ-លេសនៃចិត្ត ៥ តើអ្វីខ្លះ ។ គឺកាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលសៅហ្មងដោយឧបក្កិលេសណា ជាចិត្តមិនទន់ផង មិនគួរដល់ការនោកម្មផង មិនមានរស្មីផង ជាចិត្តប្រេះធាផង មិនឆាយនឹងតម្កល់មាំដើម្បីអស់អាសវៈផង ឧបក្កិលេសនៃចិត្ត មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្តផុតស្រឡះចាកឧបក្កិលេសទាំង ៥ យ៉ាងនេះហើយ ទើបចិត្តនោះជាធម្មជាតទន់ផង គួរដល់ការនោកម្មផង មានរស្មីផង ជាចិត្តមិនប្រេះធាផង ឆាយនឹងតម្កល់មាំដើម្បីអស់អាសវៈផង មួយទៀត បុគ្គលបង្អោនចិត្តទៅរកធម៌ណាៗដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញាបាន កាលបើមានហេតុ មានទំនងបុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញចង់បាននូវឥទ្ធិ-

វិធញ្ញាណច្រើនប្រការ គឺអាត្មាអញតែម្នាក់ឯង ចង់និម្មិតខ្លួនឲ្យបានទៅជាមនុស្សច្រើននាក់ក៏បាន មានគ្នាច្រើននាក់ចង់និម្មិតខ្លួនឲ្យទៅជាមនុស្សម្នាក់ឯងក៏បាន អាត្មាអញដើរទៅមិនជាប់ចំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន អាត្មាអញចង់ងើបឡើង និងមុជចុះក្នុងផែនដីដូចជាងើបមុជក្នុងទឹកក៏បាន អាត្មាអញចង់ដើរទៅលើទឹក ក៏មិនបែកធ្លាយទឹក ដូចដើរលើផែនដីក៏បាន អាត្មាអញចង់ទៅក្នុងអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន អាត្មាអញចង់យកដៃទៅស្ទាបអង្អែល ចាប់ពាល់ព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន អាត្មាអញចង់ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងឥទ្ធិវិធញ្ញាណនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ( ចង់ឲ្យ ) មានសោតធាតុជាទិព្វដ៏បរិសុទ្ធ កន្លងហួសនូវសោតធាតុរបស់មនុស្សធម្មតា ឮនូវសំឡេងពីរប្រការ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលជាសំឡេងឆ្ងាយក៏បាន ជិតក៏បាន កាលបើមានហេតុ មានទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងសោតធាតុនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញចង់កំណត់ដឹងចិត្តរបស់សត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួន គឺចិត្តប្រកបដោយរាគៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាស

ចាករាគៈក្តី ក៏អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកប ដោយទោសៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្ត ប្រាសចាកទោសៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្ត ប្រកបដោយមោហៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តរួញថយក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តរួញថយ ចិត្តរាយមាយក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តជាមហគ្គតៈ គឺរូបាវចរ និង អរូបាវចរក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តមិនមែនជា មហគ្គតៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តជា សឧត្តរៈ គឺលោកិយចិត្តក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្ត ជាអនុត្តរៈ គឺលោកុត្តរចិត្តក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តតាំងមាំក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តមិនតាំងមាំក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តមិនតាំងមាំ ចិត្តរួចចាកកិលេសក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តមិនទាន់រួចចាកកិលេសក្តី អាត្មា អញគប្បីដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស កាលបើមានហេតុ មាន ទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងបរចិត្តវិជ្ជានោះៗ ។ បើបុគ្គល នោះប៉ុនប៉ងថា អាត្មាអញចង់រឭកនូវបុព្វេនិវាស ( ជាតិដែលធ្លាប់អាស្រ័យ នៅក្នុងកាលមុន ) ច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិ

ខ្ទះ ៤ ជាតិខ្ទះ ៥ ជាតិខ្ទះ ១០ ជាតិខ្ទះ ២០ ជាតិខ្ទះ ៣០ ជាតិខ្ទះ ៤០ ជាតិខ្ទះ ៥០ ជាតិខ្ទះ ១០០ ជាតិខ្ទះ ១០០០ ជាតិខ្ទះ ១០០០០០ ជាតិខ្ទះ សំវដ្តកប្បដ៏ច្រើនខ្ទះ វិវដ្តកប្បដ៏ច្រើនខ្ទះ សំវដ្តវិវដ្តកប្បដ៏ច្រើនខ្ទះថា អាត្មាអញកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទៅកើតក្នុងទីឯណោះ អាត្មាអញទៅកើតក្នុងទីនោះ មានឈ្មោះយ៉ាង មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងទីនេះ អាត្មាអញគប្បីរឭកនូវបុព្វេនិវាសបានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ កាលបើមានហេតុ មានទំនងបុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងបុព្វេនិវាសញ្ញាណនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញចង់ឲ្យមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ចង់ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាសត្វតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវ

កម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកខាងសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសត្វមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកាន់សុគតិ សួគ៌ ទេវលោក អាត្មាអញចង់ឲ្យមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ អាត្មាអញចង់ដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងទិព្វចក្ខុញាណនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញចង់ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលជាធម៌មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រាន្តនៅ កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងអាសវក្ខយញ្ញាណនោះៗ ។

# អដ្ឋកថា

## ឧបក្កិលេសសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបក្កិលេសសូត្រទី ៣ ដូចតទៅនេះ បទថា **ឆ ច បភស្សរំ** គឺមិនភ្លឺស្វាង ។ បទថា **បភង្គុ ច** គឺមានសភាពបែកធ្លាយ ។ បទថា **អយោ** គឺលោហៈដែលមានពណ៌ខ្មៅ ( ដែក ) ។ បទថា **លោហំ** បានដល់ លោហៈដ៏សេស វៀរលោហៈ ៤ ដែលត្រាស់ហើយក្នុងទីនេះ ។ បទថា **សជ្ឈុំ** បានដល់ ប្រាក់ ។ បទថា **ចិត្តស្ស** បានដល់ កុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ សួរថា ឧបក្កិលេស រមែងមានដល់កុសលចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ស្មេះទុកសិនចុះ តែមានដល់លោកុត្តរភូមិបានដូចម្ដេច ។ ឆ្លើយថា ដោយមិនឲ្យកុសលចិត្តកើតឡើង ឧបក្កិលេសទាំងឡាយ មិនឲ្យកុសលចិត្តកើតឡើង ដោយចំណែកណា ឈ្មោះថា ឧបក្កិលេសទាំងឡាយ ក៏រមែងមានដល់លោកិយកុសលចិត្តផង ដល់លោកុត្តរកុសលចិត្តផង ដោយចំណែកនោះៗ ឯង ។ បទថា **បភង្គុ ច** បានដល់ មានសភាពបែកធ្លាយ ព្រោះបែកល្អិតទៅក្នុងអារម្មណ៍ ។ បទថា **សម្មាសមាធិយតិ អាសវានំ ខយាយ** បានដល់ រមែងតាំងមាំដោយហេតុការណ៍ ដើម្បីប្រយោជន៍ដល់អរហត្ត ពោល គឺការអស់ទៅនៃអាសវៈទាំងឡាយ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ទ្រង់សម្ដែងដល់ព្រះខីណាស្រពដែលជម្រះចិត្តឲ្យបរិសុទ្ធ ហើយតាំងនៅក្នុងអរហត្តផល ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអភិញ្ញាបដិវេធ គឺការចាក់ធ្លុះរបស់

ព្រះទីណាស្រេចនោះ ទើបត្រាស់ពាក្យថា **យស្ស យស្ស ច** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។ល។

## អដ្ឋកថា ឧបក្កិលេសសូត្រទី ៣ ចប់

# ទុស្សីលសូត្រទី ៤

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ឈ្មោះថាសមាធិមានឧបនិស្ស័យស្លាប់ កាលបើសម្មាសមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ មានឧបនិស្ស័យស្លាប់ កាលបើយថាភូតញ្ញាណទស្សនៈមិនមាន និព្វិទាវិរាគៈរបស់បុគ្គលដែលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈ មានឧបនិស្ស័យស្លាប់ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈមានឧបនិស្ស័យស្លាប់ ម្នាលភិក្ខុទាំងឡាយ ដើមឈើប្រាសចាកមែក និងស្លឹកហើយ ក្រមរនៃឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ក៏មិនសូវបរិបូណ៌ ស្រាយក្តី ក៏មិនសូវបរិបូណ៌ ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចសម្មាសមាធិរបស់បុគ្គលទ្រុស្តសីល វិបត្តិចាក

សីល ឈ្មោះថា សមាធិមានឧបនិស្ស័យស្លាប់ កាលបើសម្មាសមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈមានឧបនិស្ស័យស្លាប់ កាលបើយថា-ភូតញ្ញាណទស្សនៈមិនមាន និព្វិទាវិរាគៈរបស់បុគ្គលដែលវិបត្តិចាកយថា-ភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈមានឧបនិស្ស័យស្លាប់ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈមានឧបនិស្ស័យស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិរបស់បុគ្គលមានសីល ពេញលេញដោយសីល ឈ្មោះថា សមាធិបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានយថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលពេញលេញដោយសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈបរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈរបស់បុគ្គលដែលពេញដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈបរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គល ដែលពេញដោយនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈបរិបូណ៌ដោយឧបនិស្ស័យ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមានមែក និងស្លឹកបរិបូណ៌ ក្រមរនៃឈើនោះក្តីក៏បរិបូណ៌ សម្បកក្តីក៏បរិបូណ៌ ស្រាយក្តីក៏បរិបូណ៌ ខ្លឹមក្តីក៏បរិបូណ៌ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចសម្មា-

សមាធិរបស់បុគ្គលមានសីល ពេញលេញដោយសីល ឈ្មោះថា សមាធិបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលពេញលេញដោយសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈបរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈរបស់បុគ្គលដែលពេញលេញដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈបរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គល ដែលពេញលេញដោយនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈបរិបូណ៌ដោយឧបនិស្ស័យ ។

# អដ្ឋកថា

## ទុស្សីលសូត្រ

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុស្សីលសូត្រទី ៤ ដូចតទៅនេះ បទថា **ហតូបនិសោ** បានដល់ ដាច់ចាកឧបនិស្ស័យ គឺកម្ចាត់នូវហេតុ ។ បទថា **យថាភូតញាណទស្សនំ** បានដល់ វិបស្សនាទន់ខ្ចី តាំងអំពីនាមរូបបរិច្ឆេទញ្ញាណទៅ ។ បទថា **និព្វិទា វិរាគោ** បានដល់ និព្វិទា គឺការនឿយណាយ និងវិរាគៈ គឺប្រាសចាកតម្រេក ។ ក្នុង ២ យ៉ាងនោះ និព្វិទា

ជាវិបស្សនាមានកម្លាំង វិរាគៈ ជាមគ្គ ។ បទថា **វិមុត្តិញ្ញាណទស្សនំ** បានដល់ ផលវិមុត្តិ និងបច្ចវេក្ខណញ្ញាណ ។ល។

## អដ្ឋកថា ឧស្សីលសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនុគ្គហសូត្រទី ៥

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដែលមានអង្គ ៥ ជួយទំនុកបម្រុងហើយ រមែងមានចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផលជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានបញ្ញាវិមុត្តិជាអានិសង្សផង ។ អង្គ ៥ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ សម្មាទិដ្ឋិដែលសីលជួយទំនុកបម្រុង ១ សុតៈជួយទំនុកបម្រុង ១ សាកច្ឆាជួយទំនុកបម្រុង ១ សមថៈជួយទំនុកបម្រុង ១ វិបស្សនាជួយទំនុកបម្រុង ១ ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដែលអង្គ ៥ នេះឯង ជួយទំនុកបម្រុងហើយ រមែងមានចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផលជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានបញ្ញាវិមុត្តិផលជាអានិសង្សផង ។

# អដ្ឋកថា

## អនុគ្គហសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុគ្គហសូត្រទី ៥ ដូចតទៅនេះ បទថា **សម្មាទិដ្ឋិ** បានដល់ សម្មាទិដ្ឋិថ្នាក់វិបស្សនា ។ បទថា **ចេតោវិមុត្តិផលា** ជាដើម សមាធិលំដាប់មគ្គផល ឈ្មោះថា **ចេតោវិមុត្តិ** ។ ផលញ្ញាណ ឈ្មោះថា **បញ្ញាវិមុត្តិ** ។ បទថា **សីលានុគ្គហិតា** បានដល់ សម្មាទិដ្ឋិដែលសីលអនុគ្រោះតាមរក្សា ។ បទថា **សុតានុគ្គហិតា** បានដល់ សម្មាទិដ្ឋិដែលពាហុសច្ចឧបការៈ ។ បទថា **សាកច្ឆានុគ្គហិតា** បានដល់ សម្មាទិដ្ឋិដែលធម្មសាកច្ឆាឧបការៈ ។ បទថា **សមថានុគ្គហិតា** បានដល់ សម្មាសមាធិដែលឯកគ្គតាចិត្តឧបការៈ ។ តែដើម្បីឲ្យសេចក្ដីនេះជាក់ច្បាស់ គប្បីលើកឧបមាបុរសដាំគ្រាប់ស្វាយផ្អែម បោះព្រំដែនដោយជុំវិញ ស្រោចទឹកតាមកាល ជម្រះឫសតាមកាល នាំសត្វដែលធ្លាក់ចុះទៅ ចេញតាមកាល ទាញសម្បុកពីងពាងចេញតាមកាល ហើយថែរក្សាស្វាយនោះ ។ សម្មាទិដ្ឋិថ្នាក់វិបស្សនា គប្បីឃើញដូចការដាំគ្រាប់ស្វាយផ្អែមរបស់បុរសនោះ ។ សីលដែលឧបការៈ គប្បីឃើញដូចការបោះព្រំដែន សុតៈដែលឧបការៈ ដូចការស្រោចទឹក ការសន្ទនាធម៌ឧបការៈ ដូចការពូនគល់ សមថៈឧបការៈដោយការកម្ចាត់អន្តរាយនៃឈាន និងវិបស្សនា ដូចការនាំសត្វចេញ ការដែលវិបស្សនាមានកម្លាំងឧបការៈ ក៏ដូចការបោចសម្បុកពីងពាងចេញ ការដែលសម្មាទិដ្ឋិមានមូល ដែលគុណមានសីលជាដើមនេះឧបការៈហើយ ចម្រើន

ដោយទិដ្ឋិជាមគ្គហើយ ឲ្យនូវចេតោវិមុត្តិផល និងបញ្ញាវិមុត្តិផលដោយរួស រាន់ គប្បីឃើញដូចដើមឈើ ដែលបុរសថែទាំយ៉ាងនេះ ចម្រើនលូតលាស់ ហើយឲ្យផលឆាប់រហ័ស ។ល។

## អដ្ឋកថា អនុគ្គហសូត្រទី ៥ ចប់

# សុត្តន្តបិដក

## វិមុត្តិសូត្រទី ៦

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ វិមុត្តាយតនៈ ( ហេតុជាគ្រឿងរួចចាក កិលេស ) នេះមាន ៥ យ៉ាង ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ មាន ព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តស្ទុងទៅ ( កាន់ព្រះនិព្វាន ) ចិត្ត ដែលមិនទាន់រួចស្រឡះ ក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ ក៏ រមែងដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាក យោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។ វិមុត្តាយតនៈ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយក្នុងសាសនា នេះ ជាគរុដ្ឋានីយបុគ្គល ( បុគ្គលគួរគោរព ) សម្តែងធម៌ដល់ភិក្ខុ ម្នាលភិក្ខុ ទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយ-

បុគ្គល សម្តែងធម៌ដល់ភិក្ខុនោះយ៉ាងណាៗ ភិក្ខុនោះរមែងដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះយ៉ាងនោះៗ កាលបើភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជ ( សេចក្តីរីករាយ ) រមែងកើតឡើង កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្តីសុខ រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ១ ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តស្ទុងទៅ ( កាន់ព្រះនិព្វាន ) ចិត្តដែលមិនទាន់រួចស្រឡះក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ ក៏ដល់នូវការអស់ទៅផង ចិត្តដែលមិនដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសម្តែងធម៌ដល់ភិក្ខុ តែជាសម្តែងធម៌ដល់បុគ្គលដទៃតាមសមគួរ ដល់ការរេចរដឹង តាមសមគួរដល់ការសិក្សាដោយពិស្តារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្តែងធម៌ដល់បុគ្គលដទៃតាមសមគួរដល់ការរេចរដឹង សមគួរដល់ការសិក្សាដោយពិស្តារយ៉ាងណាៗ ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះយ៉ាងនោះៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជក៏កើតឡើង

កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្ដីសុខ រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ២ ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ ។បេ។ ចិត្តដែលមិនទាន់ដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្ដា ឬភិក្ខុជាសព្រហ្មចារីណាមួយ ជាគរុដ្ឋានីយបុគ្គលមិនបានសម្ដែងធម៌ដល់ភិក្ខុទេ ទាំងមិនបានសម្ដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការរេះដឹង តាមសមគួរដល់ការសិក្សាដោយពិស្ដារទេ គ្រាន់តែធ្វើការស្វាធ្យាយធម៌ តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើនូវការស្វាធ្យាយធម៌តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារយ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះៗ កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជក៏រមែងកើតឡើង កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្ដីសុខ តែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី៣ ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ

។បេ។ ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈ ក៏រមែងដល់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសម្តែងធម៌ដល់ភិក្ខុ ទាំងមិនបានសម្តែងធម៌ ដល់បុគ្គលដទៃតាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយ ពិស្តារទេ ទាំងមិនធ្វើនូវការស្វាធ្យាយធម៌តាមសមគួរដល់ការចេះដឹង សមគួរ ដល់ការសិក្សាដោយពិស្តារដែរ គ្រាន់តែត្រិះរិះពិចារណារំពឹងក្នុងចិត្ត ដោយ ចិត្តចំពោះធម៌តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុត្រិះរិះពិចារណារំពឹងក្នុងចិត្ត ដោយចិត្តចំពោះធម៌តាមសមគួរ ដល់ការចេះដឹង សមគួរដល់ការសិក្សាយ៉ាងណាៗ ភិក្ខុនោះក៏ដឹងច្បាស់នូវ អដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះៗ កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជរមែងកើតឡើង កាលបើ មានបាមោជ្ជ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ នាមកាយក៏ ស្ងប់រម្ងាប់ ភិក្ខុដែលមាននាមកាយស្ងប់រម្ងាប់ ក៏រមែងទទួលសេចក្តីសុខ ចិត្ត របស់ភិក្ខុដែលមានសេចក្តីសុខ ក៏រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះ ជាវិមុត្តាយតនៈទី ៤ ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ ។បេ។ ចិត្ត ដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈ ក៏រមែងដល់ ។ ម្នាល ភិក្ខុទាំងឡាយ មួយវិញទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនបានសម្តែងធម៌ដល់ភិក្ខុទេ ទាំងក៏មិនបាន

សម្តែងធម៌ដល់បុគ្គលដទៃតាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ដោយពិស្តារទេ ទាំងមិនបានធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្តារទេ ទាំងមិនបានត្រិះរិះពិចារណា រំពឹងក្នុងចិត្តដោយចិត្តចំពោះធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាទេ តែលោករៀនយកដោយល្អនូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀនយកដោយល្អនូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញាយ៉ាងណាៗ ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះ យ៉ាងនោះៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជក៏កើតឡើង កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលប្រកបសេចក្តីសុខ តែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ៥ ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ ។បេ។ ចិត្តដែលមិនទាន់ដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈក៏រមែងដល់ ។ ម្នាលភិក្ខុទាំងឡាយ វិមុត្តាយតនៈទាំង ៥ យ៉ាងនេះឯង ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តស្ទុងទៅ ( កាន់ព្រះនិព្វាន ) ចិត្តដែលមិនទាន់រួចស្រឡះ

ចាកកិលេស ក៏រួចស្រឡះផង អាសវៈដែលមិនទាន់អស់ទៅ ក៏ដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់បានដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។

# អដ្ឋកថា

## វិមុត្តិសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិមុត្តិសូត្រទី ៦ ដូចតទៅនេះ បទថា **វិមុត្តាយតនានិ** ប្រែថា ហេតុនៃការរួចផុត ។ បទថា **យត្ថ** បានដល់ ក្នុងវិមុត្តាយតនៈណា ។ បទថា **សត្ថា ធម្មំ ទេសេតិ** បានដល់ ព្រះសាស្ដាទ្រង់សម្ដែងសច្ចធម៌ ៤ ។ បទថា **អត្ថប្បដិសំវេទិនោ** បានដល់ ដឹងអត្ថនៃបាលី ។ បទថា **ធម្មប្បដិសំវេទិនោ** បានដល់ ដឹងបាលី ។ បទថា **បាមុជ្ជំ** បានដល់ បីតិយ៉ាងទន់ ។ បទថា **បីតិ** បានដល់ បីតិមានកម្លាំង ដែលជាអាការត្រេកអរ ។ បទថា **កាយោ** បានដល់ នាមកាយ ។ បទថា **បស្សម្ភតិ** គឺស្ងប់ស្ងៀម ។ បទថា **សុខំ វេទេតិ** បានដល់ សេចក្ដីសុខ ។ បទថា **ចិត្តំ សមាធិយតិ** បានដល់ ចិត្តតាំងមាំដោយសមាធិថ្នាក់អរហត្តផលពិតហើយ ភិក្ខុនេះ កាលស្ដាប់ធម៌នោះ រមែងស្គាល់ឈានវិបស្សនា មគ្គនិងផល ដែលឈានជាដើមមកហើយ កាលភិក្ខុនោះដឹងយ៉ាងនេះ បីតិក៏កើត

ក្នុងវេលាដែលបីតិនោះ ភិក្ខុនោះក៏មិនរួញរា បំពេញឧបចារកម្មដ្ឋាន ចម្រើនវិបស្សនា ហើយរមែងសម្រេចអរហត្ត ។ ទ្រង់សំដៅដល់អរហត្តនោះ ទើបត្រាស់ថា **ចិត្តំ សមាធិយតិ** ដូច្នេះ ។ ក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។ តែនេះជាការផ្សេងគ្នា ។ បទថា **សមាធិនិមិត្តំ** បានដល់ សមាធិក្នុងអារម្មណ៍ ៣៨ ណាមួយ ឈ្មោះថា សមាធិនិមិត្ត ក្នុងបទជាដើមថា **សុគ្គហិតំ ហោតិ** កម្មដ្ឋានដែលបុគ្គលរៀនក្នុងសម្នាក់អាចារ្យ ឈ្មោះថារៀនហើយដោយល្អ មនសិការដោយល្អ ចាំទុកដោយល្អ ។ បទថា **សុប្បដិវិទ្ធំ បញ្ញាយ** បានដល់ ធ្វើឲ្យប្រចក្សល្អ ដោយបញ្ញា ។ បទថា **តស្មឹ ធម្មេ** បានដល់ ក្នុងធម៌ គឺបាលីដែលមកនៃកម្មដ្ឋាននោះ ។ ក្នុងសូត្រនេះត្រាស់វិមុត្តាយតនៈទាំង ៥ ដល់អរហត្ត ៕

## អដ្ឋកថាវិមុត្តិសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សមាធិសូត្រទី ៧

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរជាអ្នកប្រកបដោយប្រាជ្ញាចាស់ក្លា និងសតិខ្ជាប់ខ្ជួន ចម្រើននូវសមាធិប្រមាណមិនបាន ( លោកុត្តរ ) ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រកបដោយ

ប្រាជ្ញាចាស់ក្លា និងសតិខ្ជាប់ខ្ជួន ចម្រើននូវសមាធិប្រមាណមិនបាន ញាណ ( ការដឹង ) ៥ យ៉ាង ក៏រមែងកើតឡើងចំពោះខ្លួនមិនខាន ។ ញាណ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺញាណរមែងកើតឡើងចំពោះខ្លួនថា សមាធិនេះជាសុខក្នុងបច្ចុប្បន្នផង មានផលជាសុខតទៅផង ១ ញាណរមែងកើតឡើងចំពោះខ្លួនថា សមាធិនេះប្រាសចាកអាមិសៈដ៏ប្រសើរ ១ ញាណរមែងកើតឡើងចំពោះខ្លួនថា សមាធិនេះបុរសល្អតែងសេពគប់ ១ ញាណរមែងកើតឡើងចំពោះខ្លួនថា សមាធិនេះល្អិតប្រណីតស្ងប់ ជាគុណនាំឲ្យបុគ្គលបាននូវបដិប្បស្សទ្ធិ ( សេចក្តីស្ងប់ ) បាននូវឯកគ្គតារម្មណ៍ តែមិនទាន់បានដល់នូវការសង្កត់សង្កិន ឃាត់ហាមកិលេសដោយសេចក្តីព្យាយាមទេ ១ ញាណរមែងកើតឡើងចំពោះខ្លួនថា អាត្មាអញនោះសោតនឹករឭករួច សឹមចូលកាន់សមាធិនេះ នឹករឭករួច សឹមចេញចាកសមាធិនេះ ១ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ គួរជាអ្នកប្រកបដោយប្រាជ្ញាចាស់ក្លា និងសតិខ្ជាប់ខ្ជួន ចម្រើននូវសមាធិប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំង-ឡាយប្រកបដោយប្រាជ្ញាចាស់ក្លា និងសតិខ្ជាប់ខ្ជួន ចម្រើនសមាធិប្រមាណមិនបាន ញាណទាំង ៥ ប្រការនេះឯងរមែងកើតឡើងចំពោះខ្លួនឯងមិនខាន ។

# អដ្ឋកថា

## សមាធិសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិសូត្រទី ៧ ដូចតទៅនេះ បទថា **អប្បមាណំ** បានដល់ លោកុត្តរសមាធិដែលវៀរចាកធម៌ ដែលកំណត់ប្រមាណបាន ។ បទថា **និបកា បតិស្សតា** បានដល់ ជាអ្នកប្រកបហើយដោយបញ្ញារក្សាខ្លួន និងសតិ ។ បទថា **បញ្ច ញាណានិ** បានដល់ បច្ចវេក្ខណញ្ញាណ ៥ ។ បទថា **បច្ចត្តញ្ញេវ ឧប្បជ្ជន្តិ** ប្រែថា រមែងកើតឡើងខាងដើមប៉ុណ្ណោះ ។ ក្នុងបទថា **អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ** ជាដើម លោកបំណងយកអរហត្តផលសមាធិ ។ អាចារ្យពួកខ្លះពោលថា មគ្គសមាធិដូច្នេះក៏មាន ។ ពិតហើយ សមាធិនោះ ឈ្មោះថា ជាសុខក្នុងបច្ចុប្បន្ន ព្រោះជាសុខក្នុងខណៈដែលចិត្តជាឯកគ្គតា ។ សមាធិខាងដើមៗ មានសុខជាវិបាកក្នុងអនាគត ព្រោះជាបច្ច័យដល់សមាធិសុខក្រោយៗ នោះឯង សមាធិ ឈ្មោះថា ជាអរិយៈ ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ។ ឈ្មោះថា **និរាមិសោ** ព្រោះមិនមានកាមាមិសៈ វដ្តាមិសៈ និងលោកាមិសៈ ។ ឈ្មោះថា **អកាបុរិសសេវិតោ** ព្រោះជាសមាធិដែលមហាបុរសមានព្រះពុទ្ធជាដើមសេពហើយ ។ ឈ្មោះថា **សន្តោ** ព្រោះស្ងប់អង្គអវយវៈ គឺកាយស្ងប់អារម្មណ៍ និងស្ងប់ចាកសេចក្តីក្រវល់ក្រវាយ ដោយអំណាចកិលេសទាំងពួង ។ ឈ្មោះថា **បណីតោ** ព្រោះអត្ថថា មិនក្តៅក្រហាយ ។ ឈ្មោះថា **បដិប្បស្សទ្ធលទ្ធោ** ព្រោះការរម្ងាប់កិលេសដែលខ្លួនបានហើយ ឬខ្លួន

បានរម្ងាប់កិលេស ។ បទថា **បដិប្បស្សទ្ធំ បដិប្បស្សទ្ធិ** នេះ ដោយសេចក្តីដូចគ្នាតែមួយនោះឯងម្យ៉ាងទៀត ឈ្មោះថា **បដិប្បស្សទ្ធិ** ព្រោះមានកិលេសដែលរម្ងាប់ ឬដែលធ្លាយអំពីកិលេសបានហើយ ។ ឈ្មោះថា **ឯកោទិភាវាធិគតោ** ព្រោះដល់ដោយការមានធម៌ឯកផុសឡើង ឈ្មោះថា **ន សសង្ខារនិគ្គយ្ហវារិតវតោ** ព្រោះមិនចាំបាច់ប្រើចិត្តដែលមានសង្ខារ គឺសេចក្តីព្យាយាមឃាត់នូវកិលេស ដែលជាសត្រូវដើម្បីសម្រេច ដូចសមាធិរបស់បុគ្គលដែលនៅមានវសីមិនទាន់ស្ទាត់ជំនាញ ភិក្ខុកាលចូលសមាធិនោះ ឬចេញអំពីសមាធិនោះ រមែងមានសតិចូល មានសតិចេញ ដោយកាលតាមដែលកំណត់ ព្រោះជាអ្នកបរិបូណ៌ដោយសតិ ព្រោះដូច្នោះ បច្ចវេក្ខណញ្ញាណ ការដឹង ការពិចារណាឃើញ ជាបច្ច័យក្នុងសមាធិនេះឯណា កើតឡើងចំពោះខ្លួនប៉ុណ្ណោះ ដល់ភិក្ខុដែលពិចារណាឃើញយ៉ាងនេះថា សមាធិនេះមានសុខក្នុងបច្ចុប្បន្ន និងមានសុខជាវិបាកក្នុងអនាគត បច្ចយបច្ចវេក្ខណញ្ញាណនោះ ក៏ជាញាណម្យ៉ាង ក្នុងបទដ៏សេស ក៏មានន័យដូច្នេះ ។ ញាណទាំង ៥ នេះ រមែងកើតចំពោះខ្លួនប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

## អដ្ឋកថា សមាធិសូត្រទី ៧ ចប់

# សុត្តន្តបិដក

## អង្គិកសូត្រទី ៨

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ចូរអ្នកទាំងឡាយប្រុងស្តាប់សម្មាសមាធិនោះចុះ ។បេ។ ម្នាលភិក្ខុទាំងឡាយ វិធីចម្រើនសម្មាសមាធិដ៏ប្រសើរប្រកបដោយអង្គ ៥ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះស្ងាត់ចាកកាម ។បេ។ បានដល់បឋមជ្ឈាន ។ ភិក្ខុនោះក៏ញ៉ាំងករជកាយនេះឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចអ្នកផ្ងូតទឹកក្តី បុគ្គលអ្នកជំនួយការនៃអ្នកផ្ងូតទឹកក្តី ដែលឈ្លាសវៃរោយលម្អិតសម្រាប់ងូតក្នុងភាជនៈសំរឹទ្ធ ហើយប្រោះព្រំដោយទឹក រួចហើយក៏សូនជាដុំ លុះដល់វេលាល្ងាចដុំលម្អិតសម្រាប់ងូត ( នោះ ) ក៏ស្អិតចាប់ចូលគ្នាស្អិតល្អតទាំងខាងក្នុងខាងក្រៅ មិនបានរាត់រាយខ្ចាយចេញឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលញ៉ាំងករជកាយនេះឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់មិនមានឡើយ ក៏យ៉ាងនោះឯង ។

ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះក៏ញុំាងករជកាយនេះ ឲ្យជ្រួតជ្រាបឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិមិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងកើតនៃអន្លង់ទឹកនោះក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងលិចក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងជើងក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងត្បូងក៏មិនមាន ទាំងភ្លៀងក៏មិនបានបង្អុរចុះនូវធារទឹកដោយស្រួល ក្នុងអន្លង់ទឹកនោះ តាមកាលវេលាឡើយ ឯធារទឹកដ៏ត្រជាក់ ក៏ស្រាប់តែជោរឡើងអំពីអន្លង់ទឹកនោះប៉ុណ្ណោះ ហើយក៏ញុំាងអន្លង់ទឹកនោះ ឲ្យជ្រួតជ្រាបឆ្អែតដ៏បរិបូណ៌ ផ្សព្វផ្សាយដោយទឹកដ៏ត្រជាក់ ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកទាំងអស់នោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយទឹកត្រជាក់ មិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងករជកាយនេះ ឲ្យជ្រួតជ្រាបឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិ និងសុខ

ដែលកើតអំពីសមាធិមិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតិ ។បេ។ បានដល់តតិយជ្ឈាន ។ ភិក្ខុនោះ ក៏ញ៉ាំងករជកាយនេះ ឲ្យជ្រួតជ្រាបខ្អួតស្កប់ស្កល់ បរិបូណ៌ផ្សព្វផ្សាយដោយសុខ ឥតមានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលគ្មានបីតិមិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាទីដែលដុះព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី មានព្រលិត ឬឈូកក្រហម ឬឈូកសពួកខ្លះ ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក មិនទាន់លូតឡើងផុតអំពីទឹក លិចនៅក្នុងទឹក រស់នៅអាស្រ័យទឹក បទុមជាតទាំងនោះ រមែងជ្រួតជ្រាបខ្អួតស្កប់ស្កល់ បរិបូណ៌ផ្សព្វផ្សាយ ដោយទឹកដ៏ត្រជាក់ តាំងអំពីឫស មើម រហូតដល់ចុង ប្រទេសបន្តិចបន្តួចនៃវារិជាតទាំងអស់ ដែលជាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ឈ្មោះថា មិនបានផ្សព្វផ្សាយដោយទឹកត្រជាក់ មិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឲ្យជ្រួតជ្រាប ខ្អួតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយសុខឥតមានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលគ្មានបីតិមិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ៣ ។ ម្នាលភិក្ខុទាំង-

ឡាយ មួយទៀត ភិក្ខុព្រោះលះបង់សុខផង លះបង់ទុក្ខផង ។បេ។ ក៏បាន ដល់ចតុត្ថជ្ឈាន ។ ភិក្ខុនោះ អង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សាយដោយចិត្តដ៏បរិសុទ្ធផង មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកសំពត់សស្អាត មកអង្គុយទទូរអស់ទាំងក្បាល ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់បុរសនោះ ឈ្មោះថា មិនផ្សាយដោយសំពត់សស្អាតមិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់មិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ៤ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត បច្ចវេក្ខណនិមិត្ត ភិក្ខុបានរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ ដូចជាមនុស្សដទៃ សម្លឹងមើលបុគ្គលដទៃ ឬអ្នកឈរសម្លឹងមើលអ្នកអង្គុយ ឬក៏អ្នកអង្គុយសម្លឹងមើលអ្នកដេក យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បច្ចវេក្ខណនិមិត្ត ភិក្ខុបានរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញា ក៏យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចម្រើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយ

អង្គ ៥ ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកប ដោយអង្គ ៥ ដែលភិក្ខុចម្រើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា កាល បើមានហេតុ មានទំនង រមែងដល់នូវសេចក្តីជាក់ច្បាស់ ក្នុងធម៌នោះៗ ដោយ ការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ម្នាលភិក្ខុទាំងឡាយ ដូចជាពាងទឹកដែល ពេញដោយទឹក ពេញស្មើ ( នឹងមាត់ ) ល្មមសត្វក្អែកឱនផឹកបាន ដែលគេ តម្កល់ទុកលើជើងទ្រ បុរសដែលមានកម្លាំង លើករំកិលពាងទឹកនោះ ទៅក្នុង ទីណាៗ តើទឹកគប្បីដោយតាមមកបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន គប្បី ដោយតាមមកបាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះក៏ដូច្នោះដែរ កាលបើ សម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ភិក្ខុបានចម្រើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ ច្បាស់ដោយអភិញ្ញា កាលបើមានហេតុ មានទំនង រមែងដល់នូវសេចក្តីជាក់ ច្បាស់ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ។ ម្នាលភិក្ខុ ទាំងឡាយ មួយទៀត ដូចជាស្រះបោក្ខរណី ក្នុងភូមិភាគដ៏ស្មើ មានជ្រុង ៤ មានភ្លឺព័ទ្ធជុំវិញ ជាស្រះពេញដោយទឹក ពេញស្មើ ( នឹងមាត់ ) ល្មមសត្វ ក្អែកឱនផឹកបាន បុរសអ្នកមានកម្លាំង នឹងបើកនូវភ្លឺនោះចេញត្រង់កន្លែងណាៗ តើទឹកគប្បីហូរចេញទៅបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន នឹងហូរចេញទៅ បាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះក៏ដូច្នោះដែរ កាលបើសម្មាសមាធិដ៏

ប្រសើរ ប្រកបដោយអង្គ ៥ ភិក្ខុបានចម្រើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា កាលបើមានហេតុ មានទំនង ក៏រមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ដូចជារថសេះអាជានេយ្យ ដែលគេទឹមបញ្ឈរទុកក្នុងផ្លូវធំ ៤ មានផែនដីរាបស្មើ តែងមានរំពាត់ដ្ឋងទុក នាយសារថីអ្នកទូន្មានសេះ ជាអាចារ្យអ្នកបង្ហាត់សេះ ស្ទាត់វាងវៃឡើងកាន់រថនោះ យកដៃឆ្វេងកាន់ខ្សែ ដៃស្តាំកាន់រំពាត់ហើយ បរទៅមុខក្តី បរបត់មកក្រោយក្តី តាមផ្លូវណាៗ ដែលគេប្រាថ្នា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ដែលភិក្ខុចម្រើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា កាលបើមានហេតុ មានទំនង រមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ក៏យ៉ាងនោះឯង ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញ បានសម្រេចឥទ្ធិវិធញ្ញាណច្រើនប្រការ គឺអាត្មាអញម្នាក់ឯង និម្មិតខ្លួនឲ្យបានច្រើននាក់ក៏បាន ។បេ។ អាត្មាអញគប្បីធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន កាលបើមានហេតុ មានទំនង ភិក្ខុនោះ រមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងឥទ្ធិ-វិធញ្ញាណនោះៗ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានសោតធាតុ

ជាទិព្វ ។បេ។ ឮសំឡេងឆ្ងាយក៏បាន ជិតក៏បាន កាលបើមានហេតុមានទំនង ភិក្ខុនោះ រមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងសោតធាតុនោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញកំណត់ដឹងចិត្តរបស់សត្វដទៃ បុគ្គលដទៃដោយចិត្ត ( របស់ខ្លួន ) គឺចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។បេ។ ចិត្តមិនទាន់រួចស្រឡះចាកកិលេសក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះចាកកិលេស កាលបើមានហេតុ មានទំនង ភិក្ខុនោះ រមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងបរចិត្តវិជ្ជានោះៗ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ គប្បីរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ កាលបើមានហេតុ មានទំនង ភិក្ខុនោះ រមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងបុព្វេនិវាសញ្ញាណនោះៗ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។បេ។ គប្បីដឹងច្បាស់នូវពពួកសត្វ ដែលអន្ទោលទៅតាមកម្ម កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ក្នុងទិព្វចក្ខុញ្ញាណនោះៗ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងអាសវក្ខយញ្ញាណនោះៗ ។

# អដ្ឋកថា

## អង្គិកសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអង្គិកសូត្រទី ៨ ដូចតទៅនេះ បទថា **អរិយស្ស** បានដល់ នៅឆ្ងាយអំពីកិលេសដែលលះបានហើយ ដោយវិក្ខម្ភនប្បហាន ។ បទថា **ភាវនំ ទេសេស្សាមិ** សេចក្ដីថា តថាគតនឹងប្រកាសការចម្រើន និងវឌ្ឍនា ។ បទថា **ឥមមេវ កាយំ** បានដល់ ករជកាយនេះ ។ បទថា **អភិសន្ទេតិ** បានដល់ ទទឹក គឺជ្រួតជ្រាប គឺធ្វើបីតិ និងសុខ ឲ្យប្រព្រឹត្តទៅពេញករជកាយ ។ បទថា **បរិសន្ទេតិ** បានដល់ ហូរទៅដោយជុំវិញ ។ បទថា **បរិបូរេតិ** បានដល់ ពេញដូចថង់ស្បែក ដែលពេញដោយខ្យល់ ។ បទថា **បរិប្ផរតិ** បានដល់ ជ្រួតជ្រាបទៅដោយជុំវិញ ។ បទថា **សព្ពាវតោ កាយស្ស** បានដល់ រាងកាយគ្រប់ចំណែកនៃភិក្ខុនោះ ។ ទីណាមួយសូម្បីតែបន្តិច ជ្រួតជ្រាបទៅតាមស្បែកសាច់ និងសរសៃក្នុងទីដែលប្រព្រឹត្តទៅនៃសន្តិរបស់ឧបាទិន្នក ឈ្មោះថា សុខដែលកើតអំពីបឋមជ្ឈានមិនពាល់ត្រូវ មិនមាន ។ បទថា **ទក្ខោ** បានដល់ ឈ្លាស គឺមានការអាចធ្វើ ប្រកប និងផ្សំលម្អិតសម្រាប់ងូត ។ បទថា **កំសថាលេ** បានដល់ ភាជនៈដែលធ្វើដោយលោហៈណាមួយ ។ តែភាជនៈធ្វើដោយដី មិនជាថាវរៈ កាលដាក់លម្អិតសម្រាប់ងូតរមែងបែកបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់មិនសម្ដែងភាជនៈដីនោះ ។ បទថា **បរិប្ផោសកំ បរិប្ផោសកំ** បានដល់ ស្រោចហើយស្រោចទៀត ។ បទថា **សន្នេយ្យ** បាន

ដល់ កាន់ថាសស៊ីទ្ធដោយដៃធ្វេង ស្រោចទឹកល្មមប្រមាណដោយដៃស្តាំ ហើយប្របាច់លម្អិតធ្វើឲ្យជាដុំ ។ បទថា **សិនេហានុគតា** បានដល់ ត្រូវទឹកជ្រួតជ្រាប ។ បទថា **សិនេហបរេតា** បានដល់ ត្រូវទឹកជ្រួតជ្រាបទៅដោយជុំវិញ ។ បទថា **សន្តរពាហិរា** សេចក្តីថា ត្រូវទឹកជ្រួតជ្រាបពេញសព្វាង្គកាយខាងក្នុងផង ខាងក្រៅផង ។ បទថា **ន ច បគ្ឃរតិ** សេចក្តីថា តំណក់ទឹកតែមួយតំណក់មិនហូរចេញ អាចចាប់ទាំងដៃក៏បាន ម្រាម ២ ក៏បាន ធ្វើឲ្យជារមូរក៏បាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាដោយសេចក្តីសុខក្នុងទុតិយជ្ឈាន ។ បទថា **ឧព្ភិទោទកោ** បានដល់ ទឹកពុះ គឺទឹកដែលមិនហូរចុះទៅខាងក្រោម តែហូរឡើង អធិប្បាយថា ទឹកកើតខាងក្នុងនោះឯង ។ បទថា **អាយមុខំ** បានដល់ ផ្លូវទឹកហូរមក ។ បទថា **ទេវោ** បានដល់ មេឃ ។ បទថា **កាលេន កាលំ** បានដល់ រាល់កន្លះខែ ឬរាល់ ១០ ថ្ងៃ ។ បទថា **ធារំ** បានដល់ ផ្ការទឹកភ្លៀង ។ បទថា **ធានុប្បវេច្ឆេយ្យ** សេចក្តីថា មិនគប្បីធ្លាក់ គឺមិនគប្បីធ្លាក់ចុះ ។ បទថា **សីតា វារិធារា ឧព្ភិជ្ជិត្វា** សេចក្តីថា តំណក់ទឹកភ្លៀងធ្វើបន្ទប់ទឹកត្រជាក់ឲ្យពេញ ទឹកដែលកើតឡើងហើយ ហូរចុះទៅខាងក្រោម រមែងធ្វើទឹកដែលហូរខ្ទាំងឲ្យកលឡើង ទឹកដែលហូរមកអំពីទិសទាំង ៤ រមែងធ្វើទឹកឲ្យកល ដោយស្លឹកឈើ ស្មៅឧស កំណាត់ ឈើចាស់ៗ ជាដើម ទឹកភ្លៀងរមែងធ្វើឲ្យទឹកកលដោយពពុះ ទឹកដែលហូរចុះអំពីខ្សែទឹកភ្លៀង តែទឹកស្ងប់ ដូចនិម្មិតដោយឫទ្ធិ ហូរទៅកាន់

ទឹកដីនេះ មិនហូរទៅកាន់ទឹកដីនេះ ដូច្នេះមិនមាន គឺឈ្មោះថា ឱកាសដែលទឹកមិនពាល់ត្រូវមិនមាន ។ ក្នុងឧបមានោះ ករជកាយ ដូចអន្លង់ទឹក សេចក្ដីសុខក្នុងទុតិយជ្ឈានដូចទឹក ។ បទដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាសេចក្ដីសុខ ក្នុងតតិយជ្ឈាន ។ ឈ្មោះថា **ឧប្បលិនី** ព្រោះថា មានផ្កាឧប្បល ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងឧបមានេះ បណ្ដាឈូកស ឈូកក្រហម ឈូកខៀវណាមួយ ឈ្មោះថាឧប្បលទាំងអស់ ឈូកមានស្រទាប់ ៩៩ ឈ្មោះថា បុណ្ឌរិក ឈូកមានស្រទាប់ ១០០ ឈ្មោះថា បទុម ។ម្យ៉ាងទៀត ឈូកដែលកំណត់ស្រទាប់ក្ដី មិនមានស្រទាប់ក្ដី ឈូកសក្ដី ឈ្មោះថា បទុម ឈូកក្រហម ឈ្មោះថាបុណ្ឌរិក នេះជាវិនិច្ឆ័យក្នុងឧបមានេះ ។ បទថា **ឧទកានុគ្គតានិ** បានដល់ឈូកដែលមិនផុតអំពីទឹក ។ បទថា **អន្តោនិមុគ្គបោសិនី** បានដល់ ឈូកដែលលិចខាងក្នុងផ្ទៃទឹក ទឹកចិញ្ចឹម គឺនៅចម្រើននៅឡើយ ។ បទដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧបមាសេចក្ដីសុខ ក្នុងចតុត្ថជ្ឈាន ក្នុងបទថា **បរិសុទ្ធេន ចេតសា បរិយោទាតេន** នេះ គប្បីជ្រាបថា ឈ្មោះថា បរិសុទ្ធព្រោះអត្ថថា មិនមានឧបក្កិលេស ឈ្មោះថា ផូរផង់ ព្រោះអត្ថថា ផូរផង់ ។ បទថា **ឱទាតេន វត្ថេន** នេះ ព្រះមានព្រះភាគត្រាស់ដល់ការផ្សាយទៅនៃឧណ្ហភូមិ ព្រោះសំពត់ស្អាតគ្រោក មិនមានការផ្សាយទៅនៃឧណ្ហភូមិ សំពត់

ស្អាតដែលបោកគក់ក្នុងខណៈនោះ ការផ្សាយទៅនៃខណ្ឌភូមិ រមែងមានកម្លាំង ។ ដោយឧបមានេះ ករជកាយដូចសំពត់ សុខក្នុងចតុត្ថជ្ឈាន ដូចការផ្សាយទៅនៃឧណ្ហភូមិ ព្រោះដូច្នោះ កាលបុរសងូតទឹក ជម្រះកាយល្អហើយ អង្គុយទទូរសំពត់ស្អាតជិតសរីរៈ ឧណ្ហភូមិរមែងផ្សាយទៅពេញសំពត់អំពីសរីរៈ មិនមានចន្លោះ ទីណាដែលសំពត់មិនពាល់ត្រូវយ៉ាងណា មិនមានឱកាសទទេណាមួយ ដែលករជកាយរបស់ភិក្ខុមិនពាល់ត្រូវដោយសុខក្នុងចតុត្ថជ្ឈាន ដូច្នោះ គប្បីឃើញអត្ថក្នុងឧបមានេះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ចិត្តក្នុងចតុត្ថជ្ឈានប៉ុណ្ណោះ ដូចសំពត់ រូបដែលមានចិត្តក្នុងចតុត្ថជ្ឈាននោះ ជាសមុដ្ឋាន ដូចការផ្សាយទៅនៃឧណ្ហភូមិ គប្បីឃើញអត្ថក្នុងឧបមានេះ យ៉ាងនេះថា ឧបមាដូចសំពត់ស សូម្បីមិនពាល់ត្រូវកាយក្នុងចំណែកណាមួយ ឧណ្ហភូមិដែលមានកាយនោះជាសមុដ្ឋាន ឈ្មោះថាពាល់ត្រូវកាយគ្រប់ទី យ៉ាងណា សុខុមរូបដែលមានចតុត្ថជ្ឈានជាសមុដ្ឋាន ឈ្មោះថា ពាល់ត្រូវកាយរបស់ភិក្ខុគ្រប់ទីកន្លែងដូច្នោះឯង ។

បទថា **បច្ចវេក្ខណនិមិត្តំ** បានដល់ បច្ចវេក្ខណញាណនោះឯង ។ បទថា **សុគ្គហិតំ ហោតិ** សេចក្តីថា ឈានវិបស្សនា និងមគ្គ ជាធម៌ដែលភិក្ខុនោះកាន់យកហើយដោយល្អ យ៉ាងណា បច្ចវេក្ខណនិមិត្ត ក៏ឈ្មោះថាភិក្ខុនោះកាន់យកហើយដោយល្អ ដោយបច្ចវេក្ខណនិមិត្តជាប់តគ្នានោះឯងយ៉ាងនោះ ។ បទថា **អញ្ញោវា អញ្ញំ** បានដល់ អ្នកដទៃណាមួយពិចារណា

មើលអ្នកដទៃណាមួយ ។ ព្រោះខ្លួនរមែងមិនប្រាកដដល់ខ្លួនឯង ។ បទថា **ឋិតោ វា និសិន្នំ** បានដល់ អ្នកអង្គុយរមែងប្រាកដដល់អ្នកឈរ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ឧទកមណិកោ** បានដល់ ពាងទឹកដែលមានខ្សែចង ។ បទថា **សមតិត្តិកោ** ប្រែថា ពេញ ។ បទថា **កាកបេយ្យោ** បានដល់ ក្អែកទំត្រង់កណ្តាប់មាត់ មិនចាំបាច់ឱន-កក៏ផឹកបាន ។ បទថា **សុភូមិយំ** បានដល់ ផ្ទៃដីដែលរាបស្មើ ។ ដីដែលស្អាត ឈ្មោះថា ដីដែលរាប មកក្នុងបាលីនេះថា បុគ្គលគប្បីដាំពូជទាំងឡាយត្រង់ដីដែលល្អ ត្រង់ស្រែល្អ ដែលប្រាសចាកជង្គត់ ។ បទថា **ចាតុម្មហាបថេ** បានដល់ ក្នុងផ្លូវធំ ២ ខ្សែដែលជួបគ្នា។ បទថា **អាជញ្ញរថោ** បានដល់ រថដែលទឹមដោយសេះដែលបង្ហឹកហើយ ។ បទថា **ឱធស្តបតោទោ** សេចក្តីថា ជន្ទញដែលសំយុងខាងស្តាំ ដោយអាការដែលសារថីឡើងឈរលើរថ អាចកាន់យកបាន ។ បទថា **យោគ្គាចរិយោ** ប្រែថា អាចារ្យបង្ហឹកសេះ ។ ឈ្មោះថា **អស្សទម្មសារថិ** ព្រោះអាចារ្យទូន្មានសេះនោះឯង ញ៉ាំងសេះដែលបង្ហឹកឲ្យរត់ទៅ ។ បទថា **យេនិច្ឆកំ** បានដល់ ប្រាថ្នានឹងទៅដោយផ្លូវណា ។ បទថា **យទិច្ឆកំ** បានដល់ បំណងការទៅណាមួយ ។ បទថា **សារេយ្យ** បានដល់ ដេញទៅខាងមុខ ។ បទថា **បច្ចាសារេយ្យ** បានដល់ គប្បីដេញត្រឡប់ ។ ព្រះមាន

ព្រះភាគ កាលត្រាស់សមាបត្តិបរិកម្មដោយអង្គ ៥ ខាងក្រោយយ៉ាងនេះហើយ ទ្រង់សំដែងអានិសង្សនៃសមាបត្តិដែលស្ទាត់ហើយដោយឧបមាទាំង ៣ នេះ ឥឡូវនេះ ដើម្បីទ្រង់សំដែងលំដាប់នៃអភិញ្ញារបស់ព្រះខីណាស្រព ទើបត្រាស់ពាក្យជាដើមថា **សោ សចេ អាកង្ខតិ** ដូច្នេះ ។ ពាក្យនោះមានអត្ថងាយយល់ទាំងអស់ហើយ ។ល។

**អដ្ឋកថា អង្គិកសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ចង្កមសូត្រទី ៩

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្រ្កមនេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ ១ អត់ធន់ក្នុងការព្យាយាម ១ មិនមានជំងឺ ១ភោជនដែលបរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្សហើយ រមែងរលួយដោយស្រួល ១ សមាធិដែលកើតអំពីការចង្រ្កម រមែងតាំងនៅអស់កាលយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្រ្កមមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ចង្កមសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចង្កមសូត្រទី ៩ ដូចតទៅនេះ បទថា **អទ្ធានក្ខមោ ហោតិ** បានដល់ កាលដើរផ្លូវឆ្ងាយ ក៏ដើរបាន គឺអត់ធន់បាន ។ បទថា **បធានក្ខមោ** បានដល់ ព្យាយាមអត់ធន់បាន ។ បទថា **ចង្កមាធិគតោ សមាធិ** បានដល់ សមាធិនៃសមាបត្តិ ៨ ណាមួយ ដែលបុគ្គលអធិដ្ឋានចង្រ្កមដល់ហើយ ។ បទថា **ចិរដ្ឋិតិកោ ហោតិ** ប្រែថា តាំងនៅបានយូរ ។ ដ្បិតថា និមិត្តដែលបុគ្គលឈរកាន់យក កាលអង្គុយក៏បាត់ទៅ និមិត្តដែលបុគ្គលអង្គុយកាន់យក កាលដេកក៏បាត់ទៅ ឯនិមិត្តដែលបុគ្គលអធិដ្ឋានចង្រ្កមកាន់យកក្នុងអារម្មណ៍ដែលញាប់ញ័រហើយ កាលឈរក្តី អង្គុយក្តី ដេកក្តី រមែងមិនបាត់ទៅ ៕៚

**អដ្ឋកថា ចង្កមសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ឆាតិតសូត្រទី ១០

[ ៣០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនអង្គ ក៏បានស្តេចទៅដល់ព្រាហ្មណ-

គ្រាម ឈ្មោះឥច្ឆានង្គលៈ របស់អ្នកដែនកោសល ។ តាមដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈនោះ ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវនេះ ស្តេចមកដល់ស្រុកឥច្ឆានង្គលៈ គង់នៅក្នុងដងព្រៃឥច្ឆា-នង្គលៈ ជិតស្រុកឥច្ឆានង្គលៈ ។ កិត្តិសព្ទដ៏ពីរោះ ឮខ្ទរខ្ទាយសុសសាយចំពោះព្រះគោតមដ៏ចម្រើននោះ យ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់កពថ្មីទៀត ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ ( នូវព្រះនិព្វាន ) ដោយប្រាជ្ញាដ៏ឧត្តម ដោយព្រះអង្គ ហើយញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងព្រះអង្គសម្តែងធម៌ មានលម្អបទដើម បទកណ្តាល និងបទចុង ព្រមទាំងអត្ថនិងព្យញ្ជនៈ ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ពេញលេញទាំងអស់ ក៏ដំណើរដែលបានជួបប្រទះនឹងព្រះអរហន្តទាំងឡាយ មានសភាព

យ៉ាងនោះ ជាការប្រពៃពេកណាស់ ។ គ្រាកាលកន្លងរាត្រីនោះទៅ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ នាំយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រៃល ចូលសំដៅទៅឯដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ក៏ឈរស្រែកហ៊ោ និយាយខ្លាំងនៅនាខាងក្រៅខ្លោងទ្វារ ។ គាប់ជួនសម័យនោះ ព្រះនាគិតៈដ៏មានអាយុ លោកនៅជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈដ៏មានអាយុថា ម្នាលនាគិតៈ ចុះពួកណាស្រែកហ៊ោ និយាយពួខ្លាំងម៉្លេះ ហាក់ដូចជាព្រានត្រីដណ្តើមត្រីគ្នា ។ ព្រះនាគិតៈដ៏មានអាយុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈនុ៎ះ នាំយកខាទនីយភោជនីយាហារ ដ៏ក្រាស់ក្រៃល មកឧទ្ទិសចំពោះព្រះអង្គផង ចំពោះភិក្ខុសង្ឃផង ឈរចាំនាខាងក្រៅខ្លោងទ្វារ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាគិតៈ តថាគតសូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគត ម្នាលនាគិតៈ បុគ្គលណាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួលនូវនេក្ខម្មសុខ ( សុខក្នុងផ្នួស ) បវិវេកសុខ ( សុខក្នុងសេចក្តីស្ងប់ស្ងាត់ ) ឧបសមសុខ ( សុខក្នុងសេចក្តីស្ងប់រម្ងាប់ ) សម្ពោធសុខ ( សុខក្នុងការត្រាស់ដឹង ) ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតធ្លាប់បានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល បុគ្គលនោះឯង រមែងត្រេកអរ

ចំពោះសេចក្តីកខ្វក់ សុខក្នុងការដេកលក់ សុខក្នុងលាភសក្ការៈ និងសេចក្តីសរសើរ ។ ព្រះនាគិតៈក្រាបបង្គំទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគ ទទួលនិមន្តន៍ សូមព្រះសុគត ទទួលនិមន្តន៍ចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលនេះ ជាកាលគួរព្រះអង្គនឹងទទួលហើយ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគ នឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍ និងគហបតី នៅក្នុងនិគមក្តី នៅក្នុងជនបទក្តី នឹងនាំគ្នាតាមទៅក្នុងទីនោះៗ មិនខាន បពិត្រព្រះអង្គដ៏ចម្រើន ដូចជាភ្លៀងមានតំណក់ទឹកដ៏ថ្លោស កាលបង្អុរចុះមក ទឹកទាំងឡាយតែងហូរចាក់ទៅរកទីទំនាប យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគ នឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍ និងគហបតី នៅក្នុងនិគមក្តី នៅក្នុងជនបទក្តី នឹងនាំគ្នាតាមទៅក្នុងទីនោះមិនខាន ក៏យ៉ាងនោះឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះអង្គមានសីល និងប្រាជ្ញា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទៀតថា ម្នាលនាគិតៈ តថាគតសូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគត ម្នាលនាគិតៈ បុគ្គលណាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួលនូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតធ្លាប់បានដូចប្រាថ្នា បានដោយងាយ បានដោយ

ស្រួល បុគ្គលនោះឯង រមែងត្រេកអរចំពោះសេចក្តីសុខកខ្វក់ សុខក្នុងការដេកលក់ សុខក្នុងលាភសក្ការៈ និងសេចក្តីសរសើរ ។ ម្នាលនាគិតៈ បុគ្គលដែលស៊ី ផឹក ទំពាស៊ី លិទ្ធភក្សរ រមែងមានឧច្ចារបស្សាវៈ នេះជាអានិសង្សនៃការជ្រោកជ្រាកនោះ ម្នាលនាគិតៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្តតែងកើតឡើងព្រោះប្រែប្រួល ព្រាត់ប្រាស និរាសចាកសត្វសង្ខារជាទីស្រឡាញ់ នេះជាអានិសង្សនៃសេចក្តីស្រឡាញ់នោះ ម្នាលនាគិតៈ ការខ្ពើមរអើមក្នុងអសុភនិមិត្ត តែងតាំងឡើងដល់បុគ្គលអ្នកប្រព្រឹត្តព្យាយាមក្នុងអសុភនិមិត្ត នេះជាអានិសង្សនៃសេចក្តីព្យាយាមនោះ ម្នាលនាគិតៈ ការខ្ពើមរអើមក្នុងផស្សៈ តែងតាំងឡើងដល់បុគ្គលអ្នកពិចារណារឿយៗ ថា មិនទៀងក្នុងផស្សាយតនៈទាំង ៦ នេះជាអានិសង្សនៃការពិចារណាថាមិនទៀងនោះ ម្នាលនាគិតៈ ការខ្ពើមរអើមក្នុងឧបាទានក្ខន្ធ តែងតាំងឡើងដល់បុគ្គលអ្នកពិចារណានូវការកើតឡើង និងការវិនាសទៅ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះជាអានិសង្សនៃការពិចារណាឧបាទានក្ខន្ធនោះ ។

**បញ្ចង្គិកវគ្គទី ៣ ចប់**

## ឧទ្ទាននៃបញ្ចង្គិកវគ្គនោះ គឺ

និយាយអំពីសេចក្តីមិនគោរពមាន ២ លើក អំពីឧបក្កិលេស ១ អំពីសម្មាសមាធិរបស់បុគ្គលទ្រុស្តសីល ១ អំពីធម៌សម្រាប់ជ្រោមជ្រែងសម្មាទិដ្ឋិ ១ អំពីវិមុត្តាយតនៈ

១ អំពីបុគ្គលអ្នកចម្រើនសមាធិ ១ អំពីការចម្រើនទូវសម្មាសមាធិ ប្រកបដោយអង្គប្រាំ ១ អំពីអានិសង្សក្នុងការចង្ក្រម ១ អំពីនាគិតត្ថេរ ១ ។

# អដ្ឋកថា

## នាគិតសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាគិតសូត្រទី ១០ ដូចតទៅនេះ ឈ្មោះថា **ឧច្ចាសទ្ទាមហាសទ្ទា** ព្រោះឈ្មោះថា មានសំឡេងខ្ពស់ ព្រោះសំឡេងឡើងទៅខាងលើ និងឈ្មោះថា មានសំឡេងខ្លាំង ព្រោះសំឡេងផ្គុំគ្នា ។ ពិតហើយ កាលជនទាំងឡាយ មានក្សត្រមហាសាល និងព្រាហ្មណមហាសាលជាដើម ដែលមានឈ្មោះបោះសំឡេងល្បីរន្ទឺ កាន់យកសក្ការៈដ៏ច្រើន នាំគ្នាដើរមក កាលពួកបុគ្គលទាំងនោះពោលថា អ្នកចូរឲ្យឱកាសដល់បុគ្គលនោះ ចូរឲ្យឱកាសដល់បុគ្គលនោះ ដូច្នេះ កាលបុគ្គលទាំងនោះពោលយ៉ាងនេះថា ខ្ញុំមិនមានឱកាសមុន ដូច្នេះ សំឡេងក៏ខ្ពស់ និងខ្លាំង ។ បទថា **កេវដ្ដា មញ្ញេ មច្ឆេ វិលោបេន្តិ** ប្រែថា ដូចគ្នានឹងអ្នកប្រមង់ ។ ពិតហើយ កាលអ្នកប្រមង់ទាំងនោះ កាន់កញ្ច្រែងដាក់ត្រីដើរមកក្នុងផ្សារលក់ត្រី រមែងមានសំឡេង ដូច្នេះ របស់មហាជន ដែលនិយាយគ្នាថា លក់ឲ្យខ្ញុំ

លក់ឲ្យខ្ញុំ ដូច្នេះ ។

បទថា **មិឡ្ហសុខំ** បានដល់ សុខមិនស្អាត ។ បទថា **មិទ្ធសុខំ** បានដល់ សុខក្នុងការដេកលក់ ។ បទថា **លាភសក្ការសិលោកសុខំ** បានដល់ សុខដែលកើតឡើងព្រោះអាស្រ័យលាភសក្ការៈ និងការសរសើរ ។ បទថា **តន្និន្នាវ ភវិស្សន្តិ** លោកអធិប្បាយថា ជនទាំងឡាយនឹងទៅ គឺនឹងជាប់តាម ទៅកាន់ទីដែលព្រះមានព្រះភាគយាងទៅហើយនោះឯង ។ បទថា **តថា ហិ ភន្តេ ភគវតោ សីលបញ្ញាណំ** សេចក្តីថា ព្រោះហេតុដែលសីល និងការមានឈ្មោះបោះសំឡេងរបស់ព្រះអង្គមានយ៉ាងនោះ ។

បទថា **មា ច មយា យសោ** សេចក្តីថា សូម្បីយសក៏កុំទៅរួមជាមួយតថាគតឡើយ ។ បទថា **ឯសោ តស្ស និស្សន្ទោ** បានដល់ នេះជាផលសម្រេចនៃភាពជារបស់មិនស្អាត ។ បទថា **បិយានំ** បានដល់ ដែលឲ្យកើតសេចក្តីស្រឡាញ់ ។ បទថា **ឯសោ តស្ស និស្សន្ទោ** បានដល់ នេះជាផលសម្រេចនៃភាពជារបស់គួរស្រឡាញ់ ។ បទថា **អសុភនិមិត្តានុយោគំ** បានដល់ ប្រកបរឿយៗ នូវអសុភកម្មដ្ឋាន ។ បទថា **អសុភនិមិត្តេ** បានដល់ ឥដ្ឋារម្មណ៍ដែលជាទីតាំងនៃរាគៈ ។ បទថា **ឯសោ តស្ស និស្សន្ទោ** បានដល់ នេះជាផលសម្រេចនៃការប្រកបរឿយៗ នូវអសុភនិមិត្តនោះ ។ ក្នុងសូត្រនេះ ត្រាស់វិបស្សនាក្នុងឋានៈ ៥ នេះ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា នាគិតសូត្រទី ១០ ចប់**

**បញ្ចង្គិកវគ្គទី ៣ ចប់**

# សុត្តន្តបិដក
# សុមនវគ្គទី ៤

## សុមនសូត្រទី ១

[ ៣១ ] គ្រានោះ នាងសុមនារាជកុមារី មានរថ ៥០០ និងរាជកុមារី ៥០០ អង្គ ហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។ លុះនាងសុមនារាជកុមារីប្រថាប់ក្នុងទីសមគួរហើយ បានទូលសួរព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សាវកពីររូប របស់ព្រះដ៏មានព្រះភាគ ក្នុងសាសនានេះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានបញ្ញាស្មើគ្នា ប៉ុន្តែមួយអង្គជាទាយក មួយអង្គមិនមែនជាទាយក សាវកទាំងនោះ ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក បពិត្រព្រះអង្គដ៏ចម្រើន សាវកទាំងពីរដែលកើតជាទេវតានោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនាមានដែរ ម្នាលនាងសុមនា សាវកណាជាទាយក សាវកនោះដល់កើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាង គឺអាយុទិព្វ ១ សម្បុរទិព្វ ១ សុខទិព្វ ១ យសទិព្វ ១ អធិបតេយ្យទិព្វ ១ ។ ម្នាលនាងសុមនា សាវកណាជាទាយក សាវកនោះដល់ទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើទេវតាទាំងពីរនោះ ច្យុតអំពីទេវលោកនោះ មកកើតក្នុងមនុស្សលោក

នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំងពីរនោះ ដែលកើតជាមនុស្សហើយ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់មកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាង គឺអាយុជារបស់មនុស្ស ១ សម្បុរជារបស់មនុស្ស ១ សុខជារបស់មនុស្ស ១ យសជារបស់មនុស្ស ១ អធិបតេយ្យជារបស់មនុស្ស ១ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះ ដល់មកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើអ្នកទាំងពីរនោះ ចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចម្រើន បព្វជិតទាំងនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះ លុះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាង គឺបើគេអង្វរ រមែងប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរ ប្រើប្រាស់ចីវរតិច ១ បើគេអង្វរ រមែងបរិភោគបិណ្ឌបាតច្រើន បើគេមិនអង្វរ ក៏បរិភោគបិណ្ឌបាតតិច ១ បើគេអង្វរ រមែងប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់សេនាសនៈតិច ១ បើគេអង្វរ រមែងប្រើប្រាស់គិលានប្បច្ចយ-ភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់គិលានប្បច្ចយភេសជ្ជបរិក្ខារ

តិច ១ បើប្រសិនជានៅជាមួយ ពួកសព្រហ្មចារីណា ពួកសព្រហ្មចារីនោះ រមែងរាប់អានភិក្ខុនោះ ដោយកាយកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច រាប់អានដោយវចីកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច រាប់អានដោយមនោកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ខ្វល់ខ្វាយបម្រើជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ១ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះ ដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើបព្វជិតទាំងពីររូបនោះ បានសម្រេចព្រះអរហត្ត បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបព្វជិតទាំងពីររូប ដែលបានសម្រេចព្រះអរហត្តហើយនុ៎ះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ម្នាលនាងសុមនា ត្រង់រឿងនុ៎ះ តថាគតមិនសម្តែងហេតុផ្សេងគ្នា ត្រង់ចិត្តដែលរួចស្រឡះដោយវិមុត្តិនេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលគួរឲ្យទានទាំងឡាយមែន គួរធ្វើបុណ្យទាំងឡាយមែន ព្រោះថា បុណ្យទាំងឡាយជាឧបការៈ ដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយជាឧបការៈ ដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយជាឧបការៈ ដល់អ្នកបួស ( បាននៅយូរ ) ផង ។ ម្នាលនាងសុមនា ហេតុនុ៎ះយ៉ាងនេះហើយ ម្នាលនាងសុមនា ហេតុនុ៎ះយ៉ាងនេះហើយ ម្នាលនាងសុមនា បុគ្គលគួរឲ្យទានទាំងឡាយ គួរធ្វើបុណ្យទាំងឡាយ ( ព្រោះ ) បុណ្យទាំង-

ឡាយជាឧបការៈ ដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយជាឧបការៈ ដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកបួសផង ។ ព្រះដ៏មានព្រះភាគបានត្រាស់ពាក្យនេះ លុះព្រះសុគតបានត្រាស់ពាក្យនេះហើយ ព្រះសាស្ដាបានត្រាស់ពាក្យជាគាថានេះ តទៅទៀតថា

ព្រះចន្ទ្រមិនមានមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿង
លើសជាងពួកផ្កាយទាំងអស់លើអាកាស ដោយពន្លឺ ( របស់
ខ្លួន ) យ៉ាងណាមិញ បុរសបុគ្គលមានសទ្ធា បរិបូណ៌ដោយ
សីល រមែងរុងរឿងជាង ពួកបុគ្គលកំណាញ់ទាំងអស់ក្នុង
លោក ដោយចាគៈក៏យ៉ាងនោះដែរ ។ កាលភ្លៀងប្រកបដោយ
ផ្គរបន្ទោរ ដ៏ធៀលធ្លាត់បរិបូណ៌ ដោយភ្នំទឹកដ៏ច្រើន បង្អុរចុះ
មកបំពេញផែនដី ដែលខ្ពស់ទាបឲ្យពោរពេញ យ៉ាងណាមិញ
សាវករបស់ព្រះសម្មាសម្ពុទ្ធ ដែលបរិបូណ៌ដោយទស្សនៈ ជា
បណ្ឌិត រមែងគ្របសង្កត់បុគ្គល អ្នកមានសេចក្ដីកំណាញ់ដោយ
ហេតុ ៥ យ៉ាង គឺអាយុ យស សម្បុរ សុខ និងអធិបតេយ្យ
បណ្ឌិតនោះឯង បរិបូណ៌ដោយភោគៈ ដល់ទៅលោកខាងមុខ
រមែងរីករាយក្នុងស្ថានសួគ៌ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

# សុមនវគ្គទី ៤

## សុមនសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុមនសូត្រទី ១ នៃសុមនវគ្គទី ៤ ដូចតទៅនេះ បទថា **សុមនា រាជកុមារី** បានដល់ រាជកញ្ញាដែលបាន ឈ្មោះយ៉ាងនោះ ព្រោះព្រះនាងធ្វើមហាសក្ការៈហើយ តាំងសេចក្តីប្រាថ្នា ។ សេចក្តីពិស្តារមានដូច្នេះថា ក្នុងពុទ្ធកាលនៃព្រះវិបស្សីសម្មាសម្ពុទ្ធ កាលពួក អ្នកស្រុកគិតគ្នាថា ពួកយើងនឹងធ្វើការប្រឡាំងស្រេចហើយ ទាញយកព្រះ សាស្តារបស់ពួកយើង ទើបរិះរកឧបាយដែលនឹងបានព្រះសង្ឃ មានព្រះពុទ្ធ ជាប្រធាន អាស្រ័យសេនាបតីហើយ ធ្វើបុណ្យតាមលំដាប់ ក្នុងថ្ងៃទី ១ នៃ ថ្ងៃទាំងអស់ ជាភារៈរបស់សេនាបតី ។ ក្នុងថ្ងៃនោះ សេនាបតីត្រៀមមហាទាន ដាក់មនុស្សអ្នកយាម ដោយប្រាប់ថា ថ្ងៃនេះ ពួកអ្នកចូរឃ្លាំរក្សាការណ៍ដោយ មិនឲ្យអ្នកដទៃណាមួយថ្វាយកិក្ខាសូម្បីតែម្យ៉ាង ។ ថ្ងៃនោះ ភរិយាសេដ្ឋី ទ្រហោយំ ពោលនឹងធីតាដែលលេងជាមួយស្រី ៥០០ នាក់ ដែលត្រឡប់ មកហើយថា នែកូន បើបិតារបស់កូននៅមានជីវិត ថ្ងៃនេះ ម៉ែត្រូវនិមន្តព្រះ ទសពលឆាន់ជាដំបូង ។ កូនស្រីពោលនឹងម្តាយថា បពិត្រអ្នកម៉ែ សូមអ្នក ម៉ែកុំគិតថ្វីឡើយ កូននឹងរកវិធីឲ្យព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ឆាន់កិក្ខា របស់យើងជាដំបូង បន្ទាប់អំពីនោះ ទើបធីតាដាក់បាយាសដែលមានទឹកតិច

ក្នុងថាសមាសមានតម្លៃមួយសែនរហូតពេញ ហើយចម្អិនដោយសប្បិ ទឹកឃ្មុំ និងស្ករផែនជាដើម យកថាសមួយទៀតគ្រប យកកម្រងមាលិយម៉្វិះព័ទ្ធ ភាជនៈនោះ ធ្វើឲ្យដូចជាកម្រងផ្កា កាលបានឱកាស ដែលព្រះមានព្រះភាគ យាងចូលទៅកាន់ស្រុក នាងលើកភាជនៈខ្លួនឯង មានពួកទាសីចោមរោម ចេញអំពីផ្ទះទៅ ។ កាលដល់រវាងផ្លូវ អ្នកបម្រើរបស់សេនាបតីពោលថា នែនាង កុំមកផ្លូវនេះ ។ ធម្មតាអ្នកមានបុណ្យច្រើន រមែងមានពាក្យត្រូវចិត្ត មនុស្ស ពាក្យសម្ដីរបស់អ្នកបម្រើសេនាបតីទាំងនោះ ដែលពោលហើយ ពោលទៀត ក៏មិនអាចឃាត់បាន នាងពោលថា លោកមា លោកអុំ អ្នកមីង ហេតុអ្វី មិនឲ្យខ្ញុំចូលទៅ ។ អ្នកបម្រើពោលថា នែនាង លោកសេនាបតី តាំងពួកខ្ញុំឲ្យឃ្លាំរក្សាការណ៍ ដោយប្រាប់ថា ពួកអ្នក ចូរកុំឲ្យបុគ្គលណាម្នាក់ នាំរបស់ទំពា និងរបស់បរិភោគចូលមកដាច់ខាត ។ នាងពោលថា ពួកលោក ឃើញរបស់ទំពា របស់បរិភោគនៅក្នុងដៃរបស់ខ្ញុំឬ ។ អ្នកបម្រើពោលថា ឃើញតែកម្រងផ្កា ។ នាងសួរថា លោកសេនាបតីរបស់ពួកលោក មិនឲ្យ ធ្វើសូម្បីការបូជាដោយផ្កាឬ ។ អ្នកបម្រើពោលថា ឲ្យ នាង ។ នាងពោលថា បើដូច្នោះ សូមពួកលោកចៀសចេញទៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ទទួលកម្រងផ្កាចុះព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់សម្លឹងមើលអ្នកបម្រើរបស់សេនាបតីម្នាក់ ហើយឲ្យ ទទួលកម្រងផ្កា នាងថ្វាយបង្គំព្រះមានព្រះភាគ ហើយតាំងសេចក្ដីប្រាថ្នា

ថា បើខ្ញុំម្ចាស់កើតក្នុងភពតូចភពធំ សូមកុំមានជីវិតដោយការភ័យខ្លាចឡើយ ក្នុងភពដែលខ្ញុំម្ចាស់កើត សូមឲ្យជាទីស្រឡាញ់ដូចកម្រងផ្កានេះ ។ និងសូមឲ្យមានឈ្មោះថា សុមនាចុះ ។ ព្រះមានព្រះភាគត្រាស់ថា ចូរនាងមានសេចក្ដីសុខចុះ ដូច្នេះ នាងថ្វាយបង្គំហើយ ធ្វើប្រទក្សិណ ក្រាបទូលលាត្រឡប់ទៅ ។ ព្រះមានព្រះភាគយាងទៅកាន់ផ្ទះសេនាបតី ប្រថាប់គង់លើអាសនៈដែលគេក្រាល សេនាបតីកាន់យកបបរបង្អែមចូលទៅថ្វាយ ព្រះសាស្ដាទ្រង់យកព្រះហស្តបិទបាត្រ ។ សេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុគង់ហើយ ព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា តថាគតបានបិណ្ឌបាតក្នុងរវាងផ្លូវ ។ សេនាបតីនាំកម្រងផ្កាចេញ បានឃើញបិណ្ឌបាត ។ ចូឡុបដ្ឋាកជិតស្និទ្ធពោលថា បពិត្រលោកម្ចាស់ ស្រីពោលបញ្ឆោតខ្ញុំថាជាផ្កា ។ បាយាសគ្រប់គ្រាន់ដល់ភិក្ខុទាំងអស់ រាប់តាំងអំពីព្រះមានព្រះភាគជាដើមទៅ សេនាបតីបានថ្វាយទេយ្យធម៌របស់ខ្លួន ។ ព្រះសាស្ដាសោយស្រេចហើយ ត្រាស់មង្គលកថា ហើយទ្រង់យាងត្រឡប់ ។ សេនាបតីសួរថា ស្រីដែលថ្វាយបិណ្ឌបាតឈ្មោះអ្វី ។ អ្នកបម្រើពោលថា ជាកូនស្រីសេដ្ឋីលោកម្ចាស់ ។ សេនាបតីគិតថា ស្រីនេះ មានបញ្ញាច្រើន កាលមកនៅក្នុងផ្ទះ ឈ្មោះថា សគ្គសម្បត្តិរបស់បុរស មិនមែនរកបានលំបាកឡើយ ដូច្នេះ ទើបនាំនាងនោះមកតាំងទុកក្នុងតំណែងជាប្រធាន ។ នាងក៏ចាយទ្រព្យក្នុងផ្ទះរបស់មាតា និងក្នុងផ្ទះរបស់សេនាបតី ថ្វាយទានដល់ព្រះតថាគត បំពេញ

បុណ្យដរាបដល់អស់អាយុ កាលចុតិអំពីនោះ ក៏ទៅកើតក្នុងទេវលោកខាងកាមាវចរ ។ ក្នុងខណៈដែលនាងកើតនោះឯង ភ្លៀងផ្កាម្លិះធ្លាក់ពេញទេវលោកប្រមាណស្មើជង្គង់ ។ ស្តេចទេវតាគិតថា ទេពធីតានេះ កាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមក ទើបដាក់ឈ្មោះទេពធីតានោះថា សុមនា ។ ទេពធីតានោះអន្ទោលទៅក្នុងទេវលោក និងមនុស្សលោកអស់ ៨៩ កប្ប ។ ក្នុងទីដែលនាងកើតហើយ ភ្លៀងផ្កាម្លិះក៏ធ្លាក់មិនដាច់ ទើបឈ្មោះថាសុមនាដូចមុន ។ ក្នុងកាលនេះ នាងបានបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះបាទកោសល ក្នុងថ្ងៃនោះឯង កុមារិកា ៥០០ បដិសន្ធិក្នុងត្រកូលនោះៗ ហើយប្រសូតចាកគភ៌មាតាទាំងអស់ក្នុងថ្ងៃតែមួយ ក្នុងខណៈនោះឯង ភ្លៀងផ្កាម្លិះប្រមាណស្មើក្បាលជង្គង់ក៏ធ្លាក់ចុះមក ។

ព្រះរាជាទតឃើញព្រះរាជធីតានោះ ទ្រង់ត្រេកអរក្នុងព្រះហឫទ័យគិតថា ព្រះរាជធីតាជាអ្នកសាងបុណ្យកុសលមកអំពីមុន ទ្រង់ត្រិះរិះថា រាជធីតាអញ កាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមក ទើបព្រះរាជទានព្រះនាមរបស់ធីតានោះថា សុមនា ហើយទ្រង់ឲ្យស្វែងរកពេញព្រះនគរ ដោយទ្រង់ព្រះតម្រិះថា រាជធីតារបស់អញ មិនកើតម្នាក់ឯងប៉ុណ្ណោះឡើយ ទ្រង់បានដំណឹងថា មានទារិកា ៥០០ កើត ទើបទ្រង់ឲ្យចិញ្ចឹមទាំងអស់ដោយព្រះអង្គឯងត្រាស់ថា ក្នុងមួយខែៗ ពួកនាងចូរនាំមកបង្ហាញដល់រាជធីតារបស់យើង ដូច្នេះ ។ គប្បីជ្រាបថា ព្រះរាជធីតាធ្វើមហាសក្ការៈ ហើយតាំងសេចក្តី

ប្រាថ្នា ទើបបានព្រះនាមយ៉ាងនេះ ។ ពេលព្រះរាជធីតាមានព្រះជន្មបាន ៧ វស្សា កាលអនាថបិណ្ឌិកសេដ្ឋីសាងវិហារស្រេច ទើបបញ្ជូនទូតទៅក្រាបទូលដល់ព្រះតថាគត ព្រះសាស្តាមានពួកភិក្ខុជាបរិវារ បានយាងចូលទៅកាន់ក្រុងសាវត្ថី ។

អនាថបិណ្ឌិកសេដ្ឋីបានទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ការយាងមកក្នុងទីនេះរបស់ព្រះសាស្តា ជាមង្គលដល់ខ្ញុំព្រះអង្គផង ដល់ទ្រង់ផង សូមទ្រង់ឲ្យព្រះនាងសុមនារាជកុមារី មួយអន្លើដោយទារិកា ៥០០ កាន់ក្អមទឹក គ្រឿងក្រអូប និងផ្កាជាដើម ទទួលព្រះទសពលចុះ ។ ព្រះរាជាត្រាស់ថា ល្អហើយ លោកសេដ្ឋី ហើយទ្រង់ធ្វើតាមនោះ ។ ព្រះរាជធីតាក៏យាងទៅតាមព្រះរាជាណែនាំ ថ្វាយបង្គំព្រះសាស្តា ហើយព្រះនាងបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ហើយប្រថាប់នៅនាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះរាជធីតា ។ ព្រះរាជធីតា មួយអន្លើដោយកុមារី ៥០០ តាំងនៅក្នុងសោតាបត្តិផល ។ ទារិកា ៥០០ មាតុគ្រាម ៥០០ ឧបាសក ៥០០ ដទៃ ក៏តាំងនៅក្នុងសោតាបត្តិផល ក្នុងខណៈនោះដូចគ្នា ។ ក្នុងថ្ងៃនោះ មានព្រះសោតាបន្ន ២០០០ ក្នុងរវាងផ្លូវនោះឯង ។

បទថា **យេន ភគវា តេនុបសង្កមិ** សួរថា ព្រោះហេតុអ្វី ទើបចូលទៅគាល់ ។ ឆ្លើយថា ព្រោះត្រូវការសួរបញ្ហា ។ បានឮថា កាលព្រះ-កស្សបសម្មាសម្ពុទ្ធ មានភិក្ខុ ២ រូបជាសម្លាញ់នឹងគ្នា ក្នុងភិក្ខុ ២ រូបនោះ

មួយរូបបំពេញសារាណីយធម៌ មួយរូបបំពេញភត្តគ្គវត្ត ។ មួយរូបដែលបំពេញសារាណីយធម៌ ពោលនឹងភិក្ខុដែលបំពេញភត្តគ្គវត្តថា អ្នកមានអាយុ ឈ្មោះថា ទានដែលមិនឲ្យផល រមែងមិនមាន ការឲ្យរបស់ដែលខ្លួនបានដល់អ្នកដទៃ ហើយបរិភោគ ទើបគួរដូច្នេះ តែភិក្ខុដែលបំពេញភត្តគ្គវត្តពោលថា អ្នកមានអាយុ លោកមិនដឹងឬ ការឲ្យទេយ្យធម៌ធ្លាក់ទៅមិនគួរ បុគ្គលដែលកាន់យកត្រឹមតែអាហារ ញ៉ាំងជីវិតរបស់ខ្លួន ឲ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ បំពេញវត្តក្នុងរោងភត្ត ទើបគួរ ។ ក្នុងភិក្ខុ ២ រូបនោះ មួយរូបក៏មិនអាចឲ្យមួយរូបទៀត នៅក្នុងឱវាទរបស់ខ្លួនបាន ។ ទាំង ២ រូបបំពេញបដិបទារបស់ខ្លួន កាលចុតិអំពីភពនោះ ក៏កើតក្នុងកាមាវចរទេវលោក ។ បណ្ដាភិក្ខុ ២ រូបនោះ ភិក្ខុដែលបំពេញសារាណីយធម៌ ប្រសើរជាងភិក្ខុមួយរូបទៀតដោយធម៌ ៥ យ៉ាង ភិក្ខុទាំងនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ទើបកើតក្នុងក្រុងសាវត្ថី ក្នុងកាលឥឡូវនេះ ។ ភិក្ខុដែលបំពេញសារាណីយធម៌ បដិសន្ធិក្នុងព្រះគភ៌របស់អគ្គមហេសីរបស់ព្រះបាទកោសល មួយរូបទៀត បដិសន្ធិក្នុងផ្ទៃរបស់ស្រីបម្រើនៃអគ្គមហេសីនោះដូចគ្នា ។ ជនទាំង ២ នោះ កើតក្នុងថ្ងៃតែមួយនោះឯង ។ ក្នុងថ្ងៃដាក់ឈ្មោះមាតាឲ្យជនទាំងពីរងូតទឹកហើយ ឲ្យដេកក្នុងបន្ទប់ប្រកបដោយសិរី រៀបចំរបស់ល្អៗ ខាងក្រៅទុកឲ្យដល់ជនទាំង ២ ។ បណ្ដាមនុស្សទាំងនោះ ជនដែលបំពេញសារាណីយធម៌ គ្រាន់តែបើកភ្នែក ក៏ឃើញស្វេតច្ឆត្រធំ ទីដេក

ប្រកបដោយសិរី ដែលគេរៀបចំយ៉ាងល្អ និងនិវេសន៍ប្រដាប់ដោយគ្រឿងអលង្ការ ទើបបានដឹងថា អាត្មាអញកើតក្នុងរាជត្រកូល ដូច្នេះ ៗ ជននោះអាវជ្ជនះថា អាត្មាអញធ្វើកម្មអ្វីហ្ន៎ ទើបបានកើតក្នុងទីនេះ ដូច្នេះ ក៏ដឹងថា ដោយផលនៃការបំពេញសារាណីយធម៌ ដូច្នេះ ទើបពិចារណាថា សម្លាញ់របស់អញកើតក្នុងទីណាហ្ន៎ ក៏បានឃើញសម្លាញ់នោះ ដេកលើទីដែលទាប គិតថា សម្លាញ់អញនេះ បំពេញវត្តក្នុងភេទបាយ មិនជឿពាក្យរបស់អញ គ្រានេះ អញនឹងសង្កត់សង្កិនសម្លាញ់អញក្នុងឋានៈនេះ ក៏គួរ ទើបពោលថា នៃសម្លាញ់ អ្នកមិនជឿពាក្យរបស់ខ្ញុំ សម្លាញ់នោះឆ្លើយថា បើយ៉ាងនោះ នឹងកើតអ្វី សម្លាញ់នោះប្រាប់ថា អ្នកមើលសម្បត្តិរបស់ខ្ញុំចុះ ខ្ញុំដេកត្រង់ទីដេកដ៏មានសិរី នៅខាងក្រោមស្វេតច្ឆត្រ អ្នកដេកលើគ្រែទាប ដែលក្រាលដោយរបស់រឹង សម្លាញ់នោះពោលថា អើ អ្នកអាស្រ័យវត្ថុនោះ ហើយធ្វើមានះឬ វត្ថុទាំងអស់នោះ គេយកចម្រៀកឫស្សី នាំយកសំពត់ចាស់ៗ រុំទុក ត្រឹមតែជាបឋវីធាតុប៉ុណ្ណោះមិនមែនឬ ដូច្នោះ ៗ

ព្រះរាជធីតាសុមនា ស្តាប់ពាក្យរបស់ជនទាំងពីរហើយ គិតថា ក្នុងទីក្បែរប្អូនប្រុសទាំង ២ របស់អញ ក៏មិនមានបុគ្គលណា ដូច្នេះ ដើរទៅក្បែរជនទាំងនោះ ឈរផ្អែកទ្វារ បានឮពាក្យថា ធាតុ ហើយក៏គិតថា ពាក្យថា ធាតុនេះ ខាងក្រៅក៏មិនមាន ប្អូនប្រុសរបស់អញពិតជាសមណទេវបុត្រ បើអញប្រាប់ដល់មាតាបិតាថា ជនទាំងនេះនិយាយគ្នាយ៉ាងនេះ លោកក៏នឹង

ឲ្យយកចេញទៅ ដោយយល់ថា ជនទាំងនោះ ជាអមនុស្សដូច្នេះ ។ អញមិនប្រាប់ហេតុនេះដល់អ្នកដទៃ នឹងទូលសួរចំពោះព្រះទសពល ដែលជាមហាគោតមពុទ្ធបិតារបស់អញ ដែលជាហេរញ្ញិកបុរស ដែលកាត់សេចក្តីសង្ស័យបាន ដូច្នេះ ។ សោយព្រះក្រយាហារព្រឹកស្រេចហើយ ក៏ចូលទៅគាល់ព្រះរាជា ទូលសូមអនុញ្ញាតទៅគាល់ព្រះទសពល ។ ព្រះរាជាត្រាស់ថា ចូររៀបចំរថ ៥០០ ។ សេចក្តីពិត ក្នុងផ្ទៃជម្ពូទ្វីប កុមារី ៣ នាក់ប៉ុណ្ណោះ ដែលបានរថ ៥០០ ក្នុងសម្នាក់របស់បិតាទាំងឡាយ គឺព្រះនាងចុន្ទីរាជធីតារបស់ព្រះបាទពិម្ពិសារ នាងវិសាខាធីតារបស់ធនញ្ជ័យសេដ្ឋី និងព្រះនាងសុមនានេះ ។ នាងកាន់យកគ្រឿងក្រអូប និងផ្កា ហើយឈរនៅក្នុងរថដែលមានរថ ៥០០ ជាបរិវារ ទើបបានចូលទៅគាល់ព្រះមានព្រះភាគ ដោយគិតថា អញនឹងទូលសួរបញ្ហានេះ ដូច្នេះ ។

បទថា **ឥធស្សុ** ប្រែថា គប្បីមានក្នុងទីនេះ ។ បទថា **ឯកោ ទាយកោ** សេចក្តីថា បុគ្គលម្នាក់ ជាអ្នកចែករំលែកលាភដែលខ្លួនបានហើយ ឲ្យដល់អ្នកដទៃបរិភោគ ជាការបំពេញសារាណីយធម៌ ។ បទថា **ឯកោ អទាយកោ** សេចក្តីថា បុគ្គលម្នាក់ ជាអ្នកមិនចែករំលែកវត្ថុដែលខ្លួនបានហើយ ឲ្យដល់អ្នកដទៃបរិភោគ ជាអ្នកបំពេញវត្តក្នុងរោងភត្ត ។ បទថា **ទេវភូតានំ បន នេសំ** បានដល់ មនុស្សទាំង ២ នោះ ជាទេវតា ។ បទថា **អធិគណ្ហាតិ** បានដល់ គ្របសង្កត់ ។ បទថា **អធិបតេយ្យេន** បានដល់ ហេតុរបស់បុគ្គល

ដែលជាប្រធាន ។ បទថា **ឥមេហិ បញ្ចហិ ឋានេហិ** សេចក្តីថា គ្រប
សង្កត់បុគ្គលដែលមិនជាទាយកដោយហេតុ ៥ នេះ ដូចសក្កទេវរាជគ្រប
សង្កត់ពួកទេវតាដ៏សេស ដូច្នោះ ។

ក្នុងបទជាដើមថា **មានុសកេន** គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ជាប្រធាន
គ្របសង្កត់ដោយហេតុទាំង ៥ នេះ គឺដោយអាយុ ដូចព្រះមហាកស្សបត្ថេរ
ព្រះពកុលត្ថេរ និងព្រះអានន្ទត្ថេរ ។ ដោយពណ៌សម្បុរ ដូចព្រះមហា
គតិម្ពអភយត្ថេរ និងអមាត្យដែលជាភណ្ឌាគារិក គឺអ្នករក្សាឃ្លាំងដោយសុខ
ដូចរដ្ឋបាលកុលបុត្រ សោភណសេដ្ឋីបុត្រ និងយសកុលបុត្រ ដោយយស
ផង ដោយភាពជាធំផង ដូចព្រះបាទធម្មាសោក ។ បទថា **យាចិតោវ
ពហុលំ** សេចក្តីថា ជាប្រធានគ្របសង្កត់ដោយហេតុនេះថា ជាបុគ្គលដែល
គេអង្វរ ទើបបរិភោគចីវរជាដើម ដោយចំណែកច្រើន ដូចព្រះពកុលត្ថេរ
ព្រះសីវលិត្ថេរ និងព្រះអានន្ទត្ថេរជាដើម ។ បទថា **យទិទំ វិមុត្តិយា វិមុត្តំ**
សេចក្តីថា ហេតុផ្សេងៗ គ្នាឯណា ដែលគប្បីពោលប្រារព្ធវិមុត្តិរបស់បុគ្គល
ម្នាក់ទៀត និងវិមុត្តិរបស់បុគ្គលម្នាក់ទៀត តថាគតមិនពោលហេតុដែលផ្សេង
គ្នានោះ ។ ពិតហើយ កុមារអាយុ ៧ ឆ្នាំក្តី ព្រះថេរៈអាយុ ១០០ ឆ្នាំក្តី
ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ទេវតា ឬមារ ព្រហ្ម ក៏ចាក់
ធ្លុះនូវវិមុត្តិ ក្នុងលោកុត្តរមគ្គដែលចាក់ធ្លុះហើយ ឈ្មោះថា ផ្សេងគ្នាមិនមាន
ឡើយ ។ បទថា **អលមេវ** ប្រែថា គួរពិត ។ បទថា **យត្រ ហិ នាម** ស្មើ

គ្នានឹង **យានិ នាម** ប្រែថា ឈ្មោះឯណា ។

បទថា **គច្ឆំ អាកាសធាតុយា** គឺគោចរទៅតាមអាកាស ។ បទថា **សទ្ធោ** បានដល់ ជាអ្នកជឿគុណព្រះរតនត្រ័យ ។ បទថា **ថនយំ** ប្រែថា អណ្តែតទៅ ។ បទថា **វិជ្ជុមាលី** បានដល់ ប្រកបដោយផ្លេកបន្ទោរ ត្រង់អាកាស ដូចគ្នានឹងកម្រងផ្កា ។ បទថា **សតក្កកុ** គឺមានកំពូលរាប់រយ អធិប្បាយថា ប្រកបដោយពពករាប់រយកំពូល ដែលប្រាកដឡើងខាងនេះខាងនោះ ។ បទថា **ទស្សនសម្បន្នោ** គឺព្រះសោតាបន្ន ។ បទថា **ភោគ-បរិព្យូឡ្ហោ** បានដល់ ជាអ្នកដល់ព្រមដោយភោគៈដែលមាននាំទៅឲ្យដោយអំណាចទាន ដូចគ្នានឹងជំនន់ទឹក អធិប្បាយថា ឲ្យដល់ទេវលោក ។ បទថា **បេច្ច** គឺក្នុងបរលោក ។ បទថា **សគ្គេ បមោទតិ** សេចក្តីថា រមែងត្រេកអរដោយបាមោជ្ជក្នុងស្ថានសួគ៌ដែលបុគ្គលនោះកើតនោះឯង ។ល។

**អដ្ឋកថា សុមនសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ចុន្ទិសូត្រទី ២

[ ៣២ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជា

កលន្ទកនិវាបដ្ឋាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ នាងចុន្ទីរាជកុមារី មានរថ ៥០០ និងកុមារី ៥០០ ហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។ លុះនាងចុន្ទីរាជកុមារី ប្រថាប់ក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រាជកុមារឈ្មោះចុន្ទៈជាបងខ្ញុំព្រះអង្គនោះ និយាយយ៉ាងនេះថា តាមតែបុគ្គលណាក៏ដោយ ទោះស្ត្រីក្តី បុរសក្តី ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងហើយ វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមសួរ ព្រះដ៏មានព្រះភាគថា បុគ្គលជ្រះថ្លាក្នុងព្រះសាស្តា មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ ជ្រះថ្លាក្នុងព្រះធម៌ មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ ជ្រះថ្លាក្នុងព្រះសង្ឃ មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ បំពេញក្នុងសីលមានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។ ម្នាលនាងចុន្ទី រាប់តាំងពីពួកសត្វឥតជើងក្តី មានជើង ២ ក្តី ជើង ៤ ក្តី ជើង

ច្រើនក្តី មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជ្រះថ្លាក្នុងព្រះពុទ្ធ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លា ក្នុងបុគ្គលដ៏ប្រសើរ ។ ម្នាលនាងចុន្ទី ពួកសង្ខតធម៌ក្តី អសង្ខតធម៌ក្តីទាំងប៉ុន្មាន វិរាគធម៌ គឺធម៌ញុំាងសេចក្តីស្រវឹង ឲ្យស្រុតចុះ ឲ្យបាត់ទៅ (ឲ្យទ្រុឌទ្រោម) នាំបង់នូវសេចក្តីស្រេកឃ្លាន គាស់រម្លើងនូវសេចក្តីអាល័យ ផ្តាច់បង់នូវវដ្តៈ អស់តណ្ហាប្រាសចាកតម្រេក រលត់ទុក្ខ មិនមានគ្រឿងចាក់ដោត ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងវិរាគធម៌ ពួកបុគ្គលនោះ ឈ្មោះថាជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ផលដ៏ប្រសើររមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ។ ម្នាលនាងចុន្ទី សង្ឃក្តី គណៈក្តី ទាំងប៉ុន្មានសង្ឃសាវ័ករបស់តថាគត បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ សង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ជាអ្នកគួរទទួលចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះ ហើយនាំមកបូជា គួរទទួលអាគន្តុកទាន គួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងព្រះសង្ឃ ពួកបុគ្គលនោះ ឈ្មោះថាជ្រះថ្លាក្នុងព្រះសង្ឃ

ដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គល អ្នកជ្រះថ្លា ក្នុងព្រះសង្ឃដ៏ប្រសើរ ។ ម្នាលនាងចុន្ទី សីលដែលព្រះអរិយៈសរសើរទាំងអម្បាលមាន ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលអ្នកជា ដែលវិញ្ញូជនសរសើរហើយ មិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ប្រព្រឹត្តទៅ ដើម្បីសមាធិ នេះប្រាកដជាប្រសើរជាងសីលទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជាអ្នកបំពេញក្នុងពួកសីល ដែលព្រះអរិយៈសរសើរហើយ ពួកបុគ្គលទាំងនោះ ឈ្មោះថា បានបំពេញក្នុងសីលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកបំពេញក្នុងសីលដ៏ប្រសើរ ។

បុណ្យគឺអាយុដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើនដល់ពួកបុគ្គល អ្នកជ្រះថ្លានឹងវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ប្រសើរ ជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គល រកបុគ្គលដទៃក្រៃលែងជាងគ្មាន ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាករាគៈ ជាធម៌ស្ងប់រម្ងាប់ នាំមកនូវសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្ត រកខេត្តដទៃក្រៃលែងជាងគ្មាន ជាអ្នកឲ្យនូវទាន ចំពោះបុគ្គលដ៏ប្រសើរ បុគ្គលអ្នកមានប្រាជ្ញា មានចិត្តតម្កល់ក្នុងធម៌ដ៏ប្រសើរ ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ តែងបានទៅកើតជាទេវតា ឬមនុស្ស ដល់នូវសេចក្តីប្រសើរ រមែងរីករាយ ។

# អដ្ឋកថា

## ចុន្ទិសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចុន្ទិសូត្រទី ២ ដូចតទៅនេះ បទថា **បញ្ចហិ រថសតេហិ** សេចក្តីថា ព្រះនាងចុន្ទីសោយព្រះក្រយាហារព្រឹកហើយ ចូលគាល់ព្រះជនក ឲ្យរៀបចំរថ ៥០០ មានរថទាំងនោះចោមរោមហើយ ។ បទថា **ឧបសង្កមិ** សេចក្តីថា ព្រះនាងចុន្ទីត្រិះរិះថា អញនឹងទូលសួរការសន្ទនាបញ្ហា ដែលអាត្មាអញប្រព្រឹត្តទៅជាមួយព្រះជេដ្ឋភាតា គឺម្ចាស់បងចុន្ទះ ដូច្នេះ កាន់យកគ្រឿងក្រអូប ផ្កា និងលម្អិតជាដើម ហើយចូលទៅគាល់ ។ បទថា **យទេវ សោ ហោតិ** បានដល់ កាលណាបុគ្គលនោះ ។ ម្យ៉ាងទៀត បុគ្គលនោះណា ។ បទថា **អរិយកន្តានិ សីលានិ** បានដល់ សីលសម្បយុត្តដោយមគ្គ និងផល ។ សីលទាំងនោះ ជាសីលដែលគួរស្រឡាញ់របស់ព្រះអរិយៈទាំងឡាយ ព្រោះដូច្នោះ ទើបមិនលះក្នុងភពដទៃ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអគ្គប្បសាទសូត្រ ក្នុងចតុក្កនិបាត ។

### អដ្ឋកថា ចុន្ទិសូត្រទី ២ ចប់

# សុត្តន្តបិដក

## ឧគ្គហសូត្រទី ៣

[ ៣៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងជាតិយាវ័ន ទៀបក្រុងភទ្ទិយៈ ។ គ្រានោះ ឧគ្គហមេណ្ឌកនត្តា ( ជាចៅមេណ្ឌកសេដ្ឋី ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គហមេណ្ឌកនត្តា អង្គុយក្នុងទីសមគួររួចហើយ បានក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មានភិក្ខុជាគម្រប់ ៤ នឹងព្រះអង្គ ទទួលភត្តខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគ ទទួលដោយតុណ្ហីភាព ។ គ្រានោះ ឧគ្គហមេណ្ឌកនត្តាដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចេញទៅ ។ ដល់វេលារាត្រីកន្លងហើយ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅឯលំនៅរបស់ឧគ្គហមេណ្ឌកនត្តា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះឧគ្គហមេណ្ឌកនត្តា អង្គាសព្រះដ៏មានព្រះភាគឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ដោយដៃខ្លួនឯង ត្រាតែព្រះដ៏មានព្រះភាគទ្រង់ឃាត់ ។ លុះឧគ្គហមេណ្ឌកនត្តា ( ឃើញ ) ព្រះដ៏មានព្រះភាគឆាន់រួច លែងលូកព្រះហស្តក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧគ្គហមេណ្ឌកនត្តាអង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រ

ព្រះអង្គដ៏ចម្រើន ពួកកុមារីរបស់ខ្ញុំព្រះអង្គទាំងអម្បាលនេះ មុខជានឹងទៅកាន់ត្រកូលប្តី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទូន្មានពួកកុមារីទាំងនោះឲ្យទាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគប្រៀនប្រដៅពួកកុមារីទាំងនោះដោយឱវាទានុសាសនៈណា ដែលនាំឲ្យបានប្រយោជន៍និងសេចក្តីសុខអស់កាលដ៏វែងដល់កុមារីទាំងនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងពួកកុមារីទាំងនោះយ៉ាងនេះថា ម្នាលកុមារីទាំង-ឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា មាតានិងបិតាជាអ្នកប្រាថ្នាសេចក្តីចម្រើន ជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះអាស្រ័យសេចក្តីអនុគ្រោះហើយ ឲ្យដល់បុរសជាស្វាមីណា យើងទាំងឡាយជាស្រីក្រោកឡើងមុនគេ ដេកក្រោយគេ ប្រុងខ្លួននឹងទទួលកិច្ចការអ្វីៗ ប្រព្រឹត្តផ្គាប់ផ្គុន និយាយពាក្យផ្អែមល្ហែម ដល់ស្វាមីនោះ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា បុគ្គលណាជាទីគោរពនៃស្វាមី ទោះជាមាតាក្តី បិតាក្តី សមណព្រាហ្មណ៍ក្តី យើងទាំងឡាយនឹងធ្វើសក្ការៈ គោរពរាប់អានបូជាដល់បុគ្គលទាំងនោះ ទាំងទទួលគួរសម រៀបចំដោយអាសនៈនិងទឹកលាងជើង ចំពោះជនទាំងឡាយ ដែលមកដល់ហើយ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ការងារទាំងឡាយ

ណា ខាងក្នុងផ្ទះរបស់ប្តី ទោះរោមចៀមក្តី កប្បាសក្តី ពួកយើងនឹងជាស្រី ឈ្លាសវៃ ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស បរិបូណ៌ដោយឧបាយ និង ការត្រិះរិះក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ជនណាជាជនខាងក្នុងផ្ទះរបស់ស្វាមី ទោះខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី ពួកយើងដឹងការងារដែលជនទាំងនោះ ធ្វើហើយ ព្រោះការងារដែលជនទាំងនោះធ្វើហើយផង ដឹងការងារដែលជន ទាំងនោះមិនបានធ្វើ ព្រោះការងារដែលជនទាំងនោះមិនបានធ្វើផង ដឹងថា ឈឺធ្ងន់ ឈឺស្រាលផង ហើយចែករំលែកខាទនីយភោជនីយាហារជា ចំណែកៗ ដល់ជនទាំងនោះផង ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សា យ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ស្វាមីនាំរបស់ណាមក ទោះទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី យើងទាំងឡាយនឹងធ្វើរបស់នោះឲ្យសម្រេចដោយការរក្សា និងការ គ្រប់គ្រង មិនជាស្រីអ្នកលេង មិនជាស្រីអ្នកលួច មិនជាស្រីអ្នកផឹកសុរា មិនមែនជាស្រីអ្នកបំផ្លាញរបស់ទ្រព្យដែលខ្លួនគ្រប់គ្រងនោះ ម្នាលកុមារីទាំង-ឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលនាងកុមារីទាំងឡាយ មាតុគ្រាម ប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងពួកទេវតា មានកាយជាទីគាប់ចិត្ត ។

ស្វាមីណាចិញ្ចឹមករិយានោះសព្វកាល មានព្យាយាមខ្វល់ខ្វាយជានិច្ច ករិយាមិនត្រូវមើលងាយស្វាមីអ្នកចិញ្ចឹម អ្នកបំពេញសេចក្តីប្រាថ្នាទាំងពួង ( នោះ ) ឡើយ ស្ត្រីល្អមិនត្រូវក្រោធខឹងនឹងស្វាមី ដោយកិរិយាប្រព្រឹត្តឫស្យាផង ស្ត្រីអ្នកចេះដឹងរមែងគួរសមនឹងពួកជនទាំងពួង អ្នកជាទីគោរពរបស់ស្វាមីផង ករិយាជាស្ត្រីមានព្យាយាម មិនខ្ជិលច្រអូស សង្គ្រោះជនជាខាងក្នុងផ្ទះស្វាមី ប្រព្រឹត្តកិច្ចការជាទីគាប់ចិត្តរបស់ស្វាមី រក្សាទុកនូវសម្បត្តិ ដែលស្វាមីបានមកហើយដោយប្រពៃ ។ នារីណាបានប្រព្រឹត្តយ៉ាងនេះ លុះតាមអំណាចសេចក្តីប្រាថ្នារបស់ស្វាមី នារីនោះ រមែងទៅកើតក្នុងពួកទេវតាទាំងនោះ ដែលមានកាយជាទីពេញចិត្ត ។

# អដ្ឋកថា

## ឧគ្គហសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧគ្គហសូត្រទី ៣ ដូចតទៅនេះ បទថា **ភទ្ទិយេ** ប្រែថា ក្បែរភទ្ទិយនគរ ។ បទថា **ជាតិយាវនេ** បានដល់ ក្នុងព្រៃស្តុកដែលកើតឡើងឯង គេមិនបានដាំ ជាព្រៃជាប់គ្នានឹងព្រៃហិមពាន្ត

អធិប្បាយថា ព្រះមានព្រះភាគទ្រង់ចូលទៅអាស្រ័យនគរនោះ ប្រថាប់នៅក្នុងព្រៃនោះ ។ បទថា **អត្តចតុត្ថោ** បានដល់ មានព្រះអង្គជាគម្រប់ ៤ ។ សួរថា ព្រោះហេតុអ្វី ទើបឧគ្គហសេដ្ឋីជាចៅរបស់មេណ្ឌកសេដ្ឋីនោះ និមន្តព្រះមានព្រះភាគ មានទ្រង់ជាគម្រប់ ៤ មានភិក្ខុទៅ ៣ រូប ។ ឆ្លើយថា បានឮថា ក្នុងផ្ទះរបស់លោកសេដ្ឋីនោះ មានរៀបចំមង្គលធំ ដោយការងារធំ បុគ្គលជាច្រើន ក៏មកប្រជុំគ្នាក្នុងផ្ទះនោះ គាត់គិតថា អង្គាសភិក្ខុសង្ឃ គង់នឹងសង្គ្រោះទាញចិត្តជនទាំងនោះបានលំបាក ទើបនិមន្តព្រះមានព្រះភាគ មានទ្រង់ជាគម្រប់ ៤ ប៉ុណ្ណោះ ម្យ៉ាងទៀត គាត់មានការគិតយ៉ាងនេះថា កាលព្រះសាស្តាទ្រង់ឱវាទកណ្តាលមហាភិក្ខុសង្ឃ កុមារីទាំងឡាយ រវល់តែមើល ក៏មិនអាចទទួលយកព្រះឱវាទបាន ដោយហេតុដូចពោលមកនេះ ទើបគាត់និមន្តព្រះមានព្រះភាគជាគម្រប់ ៤ ប៉ុណ្ណោះ ។

បទថា **ឱវទតុ តាសំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគប្រទានឱវាទ គឺទូន្មានកុមារីទាំងនោះ ។ ពិតហើយ ពាក្យថា **តាសំ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **យំ តាសំ** បានដល់ ឱវាទានុសាសនៈសម្រាប់កុមារីទាំងនោះ ។ លោកសេដ្ឋីនោះ កាលក្រាបទូលហើយយ៉ាងនេះ គិតថា កុមារីទាំងនេះ កាលបានទទួលឱវាទក្នុងសម្នាក់នៃព្រះតថាគត គប្បីឲ្យនាំទៅត្រកូលស្វាមី ដូច្នេះ ។ ថ្វាយបង្គំព្រះមានព្រះភាគហើយចៀសចេញទៅ ។

បទថា **ភត្តុ** គឺប្តី ។ បទថា **អនុកម្បំ ឧបាទាយ** បានដល់ អាស្រ័យសេចក្តីអនុគ្រោះ ។ បទថា **បុព្វុដ្ឋាយិនិយោ** បានដល់ មានប្រក្រតីភ្ញាក់មុនគេទាំងអស់ ។ បទថា **បច្ឆានិបាតិនិយោ** បានដល់ មានប្រក្រតីដេកក្រោយគេបង្អស់ ។ ស្ត្រីបរិភោគហើយ ឡើងកាន់ដំណេក ដេកមុនមិនគួរ ។ តែឲ្យមនុស្សក្នុងផ្ទះទាំងអស់បរិភោគ ហើយរៀបចំរបស់របរដែលជាឧបករណ៍ដឹងថា គោជាដើមដែលមកហើយ និងមិនទាន់មក ចាត់ចែងការងារដែលគប្បីធ្វើក្នុងថ្ងៃស្អែក កាន់កូនសោទុកក្នុងដៃ បើអាហារមានក៏បរិភោគ បើមិនមានក៏ឲ្យអ្នកដទៃចម្អិន ហើយផ្គត់ផ្គង់មនុស្សទាំងអស់ឲ្យឆ្អែត ហើយដេកក្នុងកាលខាងក្រោយ ទើបគួរ ។ លុះដេកហើយ ទោះដេករហូតថ្ងៃរះក៏មិនគួរ តែក្រោកមុនគេហើយ ហៅទាសៈ និងកម្មករមក ហើយចាត់ចែងការងារថា អ្នកចូរធ្វើការងារនេះ អ្នកចូរធ្វើការងារនេះ ឲ្យរីតទឹកដោះមេគោ ធ្វើកិច្ចដែលគួរធ្វើទាំងអស់ក្នុងផ្ទះ ជាភារៈរបស់ខ្លួន ទើបគួរ ។ ព្រះមានព្រះភាគសំដៅដល់សេចក្តីនោះ ទើបត្រាស់ថា **បុព្វុដ្ឋាយិនិយោ បច្ឆានិបាតិនិយោ** ភ្ញាក់មុនដេកក្រោយ ដូច្នេះ ។

បទថា **កឹការបដិស្សាវិនិយោ** សេចក្តីថា មានប្រក្រតីសម្លឹងមើលមុខគ្នាហើយ ពិនិត្យមើលថា អញនឹងធ្វើអ្វី អញនឹងធ្វើអ្វី ដូច្នេះ ។ បទថា **មនាបចារិណិយោ** បានដល់ ប្រក្រតីធ្វើកិរិយាតែជាទីពេញចិត្ត ។ បទថា **បិយវាទិនិយោ** បានដល់ ពោលតែពាក្យដែលគួរស្រឡាញ់ ។ បទថា

**ប្ដូជេស្សាម** បានដល់ បូជាដោយបច្ច័យ ៤ ។ បទថា **អព្ភាគតេ** បានដល់ លោកមកដល់សម្នាក់របស់ខ្លួន ។ បទថា **អាសនោទកេន បដិប្ដូជេស្សាម** សេចក្ដីថា ទទួលដោយអាសនៈ និងទឹកលាងជើង ។ តែក្នុងសេចក្ដីនេះ គួរធ្វើសក្ការៈរាល់ថ្ងៃដល់មាតាបិតា ។ សម្រាប់សមណព្រាហ្មណ៍ដែលមកដល់ហើយ គួរប្រគេនអាសនៈ ទឹកលាងជើង និងគួរធ្វើសក្ការៈ ។

បទថា **ឧណ្ណា** គឺរោមចៀម ។ បទថា **តត្ថ ទក្ខា អនលសា** សេចក្ដីថា ជាអ្នកឈ្លាសក្នុងការត្រដោះ និងលាង ការជ្រលក់ និងរៀបចំឲ្យជាបន្ទះសម្រាប់រោមចៀមទាំងឡាយ និងក្នុងការប្រេះបាច់ ត្បេច ញី និងត្បាញជាដើមសម្រាប់សំឡី ។ បទថា **តត្រុបាយាយ** បានដល់ ជាអ្នកប្រកបដោយបញ្ញាដែលជាឧបាយក្នុងការរៀបចំរោមសត្វ និងសំឡីនោះ ដែលប្រព្រឹត្តទៅហើយ យ៉ាងនេះថា អាត្មាអញគួរធ្វើការងារនេះ ក្នុងវេលានោះ ដូច្នេះ ។ បទថា **អលំ កាតុំ អលំ សំវិធាតុំ** បានដល់ ធ្វើឯងក្ដី ប្រើអ្នកដទៃឲ្យធ្វើក្ដី ក៏គួរទាំងអស់ អធិប្បាយថា ឈ្មោះថា ជាអ្នកអាចបាន ដូច្នេះ ។ បទថា **កតញ្ច កតតោ ជានិស្សាម អកតញ្ច អកតតោ** សេចក្ដីថា អញនឹងដឹងយ៉ាងនេះថា អញគួរឲ្យវត្ថុនេះ និងធ្វើកិច្ចនេះ ដល់បុគ្គលដែលមកធ្វើការនេះអស់មួយថ្ងៃ ដែលមកធ្វើការនេះអស់កន្លះថ្ងៃ ដល់អ្នកដែលធ្វើការងារស្រេចដល់អ្នកអន្ដុយនៅក្នុងផ្ទះ ដូច្នេះ ។ ដោយបទថា **គិលានកានញ្ច ពលាពលំ** លោកសម្ដែងថា បើគេឲ្យថ្នាំ និងអាហារជាដើមដល់បុគ្គលទាំងនោះ ក្នុងគ្រា

មានជំងឺ នឹងធ្វើឲ្យស្វែងដល់ពេគ មនុស្សទាំងនេះ រមែងធ្វើវត្ថុដែលខ្លួនប្រាថ្នា ក្នុងពេលអាត្មាអញមិនមានពេគ ក្នុងពេលមានជំងឺ ក៏មិនដឹងថា អញមាន ដូច្នោះ បុគ្គលនោះ ជាអ្នកនឿយណាយ មិនធ្វើកិច្ចទាំងឡាយខាងក្រោយ ឬធ្វើ កិច្ចដែលគួរធ្វើ ព្រោះដូច្នោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីសិក្សាយ៉ាងនេះថា អញនឹងដឹងការមានកម្លាំង និងមិនមានកម្លាំងនៃបុគ្គលទាំងនោះ ហើយនឹងដឹង វត្ថុដែលគប្បីឲ្យ និងកិច្ចដែលគួរធ្វើ ។

បទថា **ខាទនីយំ ភោជនីយំ ចស្ស** បានដល់ នឹងចែកចាយរបស់ទំពា និងរបស់ស៊ីដល់មនុស្សខាងក្នុង ។ បទថា **បច្ចយំសេន** គឺតាមចំណែកដែល បុគ្គលគួរនឹងបាន អធិប្បាយថា តាមសមគួរដល់ចំណែកដែលខ្លួនគប្បីបាន ។ បទថា **សំវិភជិស្សាម** គឺនឹងឲ្យ ។ បទថា **សម្បាទេស្សាម** គឺនឹងឲ្យដល់ ព្រម ។ បទថា **អធុត្តី** បានដល់ មិនជាស្រីអ្នកលេង ដោយភាពជាអ្នកលេង ប្រុស និងលេងសុរា ។ បទថា **អថេនី** គឺមិនជាស្រីអ្នកលួច មិនជាស្រី ចោរ ។ បទថា **អសោណ្ឌី** មិនជាអ្នកលេង មានលេងស្រាជាដើម ។

ព្រះមានព្រះភាគ បញ្ចប់សូត្រយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ សរុបដោយគាថាទាំងឡាយ ទើបត្រាស់ពាក្យជាដើមថា **យោ នំ ភរតិ សព្វទា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ភរតិ** បានដល់ រកចិញ្ចឹម ទំនុកបម្រុង ។ បទថា **សព្វកាមហរំ** គឺឲ្យវត្ថុគួរប្រាថ្នាទាំងពួង ។ បទថា **សោត្ថិ** ប្រែថា ជាស្រីដែលល្អ ។ បទថា **ឯវំ វត្តតិ** បានដល់ ប្រព្រឹត្តវត្ត

*ប្រមាណប៉ុណ្ណោះឲ្យបរិបូណ៌ ។ បទថា* **មធាថា ធាម តេ ធេវា** *បានដល់ទេវតាជាន់និម្មានរតី ។ ពិតហើយ ទេវតាទាំងនោះ ហៅគ្នាថា និម្មានរតី និងមនាបា ព្រោះនិម្មិតរូបដែលខ្លួនប្រាថ្នា ហើយអភិរម្យ ៗ។*

**អដ្ឋកថា ឧគ្គហសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សីហសូត្រទី ៤

[ ៣៤ ] *សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ សីហសេនាបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសីហសេនាបតី អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលសួរ ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចនឹងបញ្ញត្តផលទានដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯងបានឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសីហៈ អាចបញ្ញត្តបាន ម្នាលសីហៈ ទាយកអ្នកម្ចាស់ទានជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ដោយហេតុណា*

ហេតុនេះឯងជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ពួកសប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកអ្នកម្ចាស់ទាន ម្នាលសីហៈ បើពួកសប្បុរសមានចិត្តស្ងប់រម្ងាប់ តែងរាប់រកទាយកអ្នកម្ចាស់ទាន ដោយហេតុណា ហេតុនេះជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត កិត្តិសព្ទដ៏ពីរោះរបស់ទាយកអ្នកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ ម្នាលសីហៈ ឯកិត្តិសព្ទដ៏ពីរោះរបស់ទាយកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅដោយហេតុណា ហេតុនេះឯងជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកម្ចាស់ទានចូលទៅកាន់បរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី រមែងក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ម្នាលសីហៈ បើទាយកម្ចាស់ទានចូលទៅកាន់បរិស័ទណាក៏ដោយ ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី ក៏ក្លៀវក្លា មិនមានសេចក្តីអៀនខ្មាសដោយហេតុណា ហេតុនេះជាផលទានដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវ-លោក ម្នាលសីហៈ បើទាយកម្ចាស់ទានបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោកដោយហេតុណា ហេតុនេះជាផលទានមានក្នុងលោកខាងមុខ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ សីហ-

សេនាបតីបានក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ផលទានទាំង ៤ ប្រការ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសម្តែងប្រាប់ហើយនេះ ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ខ្ញុំព្រះអង្គបានដឹងផលទានទាំងនុ៎ះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន ពួកសប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ តែងរាប់រកខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំក៏លាន់ឮថា សីហសេនាបតីជាអ្នកឲ្យទាន ជាអ្នកធ្វើបុណ្យ អ្នកឧបដ្ឋាកសង្ឃ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន ចូលទៅកាន់បរិស័ទណា ទោះជាខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតិបរិស័ទ សមណបរិស័ទ រមែងក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ។ បពិត្រព្រះអង្គដ៏ចម្រើន ផលទានទាំង ៤ ប្រការដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសម្តែងហើយនេះ ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគត្រង់ផលទានទាំងនោះទេ ដ្បិតខ្ញុំព្រះអង្គដឹងនូវផលទានទាំងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ដែលព្រះដ៏មានព្រះភាគ បានត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះរួចហើយថា ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ខ្ញុំព្រះអង្គ

មិនដឹងហេតុនុ៎ះមែន ក៏ប៉ុន្តែថា ខ្ញុំព្រះអង្គចេះតែជឿព្រះដ៏មានព្រះភាគក្នុងផល ទាននោះ ។ ម្នាលសីហៈ រឿងនុ៎ះ ពិតមែន ម្នាលសីហៈ រឿងនុ៎ះ ពិតមែន ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅ កើតក្នុងសុគតិសួគ៌ទេវលោក ។

នរជនមិនមានសេចក្តីកំណាញ់ ជាអ្នកឲ្យទាន ជាទីស្រឡាញ់ ( របស់ជនដ៏ច្រើន ) ផង ពួកសប្បុរសជាច្រើនតែងរាប់រក ទាយកនោះផង ( ទាយកនោះ ) ដល់នូវកិត្តិសព្ទផង យស រមែងចម្រើនដល់ទាយកនោះផង ទាយកនោះចូលទៅកាន់បរិ- ស័ទ មិនមានសេចក្តីអៀនខ្មាស មានតែសេចក្តីក្លៀវក្លាផង ហេតុដូច្នោះ បណ្ឌិតទាំងឡាយអ្នកស្វែងរកសេចក្តីសុខ ត្រូវ លះបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទានទាំងឡាយ បណ្ឌិតទាំងនោះស្ថិតនៅក្នុងស្ថានត្រៃត្រិង្សអស់កាលយូរអង្វែង បណ្ឌិតទាំងនោះ ទៅកើតក្នុងសហភាពនៃពួកទេវតា រីករាយ សប្បាយ បណ្ឌិតទាំងនោះមានឱកាសធ្វើហើយ មានកុសលធ្វើ ហើយ ច្យុតអំពីលោកនេះ មានរស្មីខ្លួនឯង អន្ទោលទៅក្នុងទី ជាទីត្រេកអរ បណ្ឌិតទាំងនោះស្កប់ស្កល់ដោយកាមគុណទាំង ៥ រីករាយសប្បាយក្នុងទីនោះ ។ ពួកសាវ័កទាំងអស់របស់ព្រះ សុគត ធ្វើតាមពាក្យរបស់ព្រះតថាគត ព្រះអង្គមិនជាប់ដោយ អកុសលធម៌ ប្រកបដោយតាទិគុណហើយ រមែងរីករាយ ។

# អដ្ឋកថា

## សីហសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ៤ ដូចតទៅនេះ បទថា **សន្ទិដ្ឋិកំ** បានដល់ ដែលគប្បីឃើញឯង ។ បទថា **ទាយកោ** គឺជាអ្នកអង់អាចក្នុងការឲ្យ ។ អធិប្បាយថា មិនមែនឈប់ ដោយហេតុត្រឹមតែជឿថា ទានជារបស់ល្អប៉ុណ្ណោះទេ នៅអាចបរិច្ចាគបានផងដែរ ។ បទថា **ទានបតិ** បានដល់ ឲ្យទានណា ក៏ជាម្ចាស់នៃទាននោះ ។ មិនមែនទាសទាន និងមិនមែនសហាយទាន ។ បុគ្គលណាបរិភោគរបស់ឆ្ងាញ់ តែឲ្យរបស់មិនឆ្ងាញ់ដល់បុគ្គលដទៃ បុគ្គលនោះជាទាសៈនៃទេយ្យធម៌ ពោល គឺទាន ។ ខ្លួនឯងបរិភោគរបស់ណា ឲ្យរបស់នោះឯង បុគ្គលនោះជាសម្លាញ់នៃទាន ។ បុគ្គលណាខ្លួនឯង ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់ធម្មតាៗ តែឲ្យរបស់ដែលឆ្ងាញ់ដល់អ្នកដទៃ បុគ្គលនោះ ឈ្មោះថា ជាម្ចាស់ ជាធំ ជាម្ចាស់នៃទាន ។ ព្រះមានព្រះភាគត្រាស់សំដៅដល់ទាយកនោះថា ជាទានបតី ដូច្នេះ ។

បទថា **អមង្កុភូតោ** បានដល់ មិនមែនជាអ្នកឥតអំណាចទេ ។ បទថា **វិសារទោ** គឺបានសោមនស្សប្រកបដោយញាណ ។ បទថា **សហព្យតតា** គឺដល់នូវការរួមគ្នាតែមួយ ។ បទថា **កតាវកាសា** សេចក្តីថា ឈ្មោះថា មានឱកាសដែលធ្វើហើយ ព្រោះខ្លួនធ្វើកម្មដែលមានឱកាសក្នុងស្ថានត្រៃត្រិង្សនោះ តែព្រោះហេតុដែលកម្មនោះជាកុសលតែម្យ៉ាង ព្រោះដូច្នោះ ទើបត្រាស់ថា **កតកុសលា** គឺសាងកុសល ។ បទថា **មោទរេ** គឺត្រេកអរ រីករាយ ។

បទថា **អសិតស្ស** បានដល់ ព្រះតថាគតដែលកិលេសមិនអាស្រ័យហើយ ។ បទថា **តាទិនោ** គឺជាអ្នកដល់នូវលក្ខណៈមាំទាំ ។ល។

## អដ្ឋកថា សីហសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ទានានិសង្សសូត្រទី ៥

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងទាននេះមាន ៥ យ៉ាង ។ ៥ យ៉ាងដូចម្តេចខ្លះ ។ គឺជាទីស្រឡាញ់ ជាទីគាប់ចិត្តជនច្រើន ១ ពួកសប្បុរសអ្នកស្ងប់ រមែងគប់រក ១ មានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ មិនបានប្រាសចាកធម៌របស់គ្រហស្ថ ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះអានិសង្សក្នុងទានទាំង ៥ យ៉ាង ។

បុគ្គលកាលឲ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូលទៅ
តាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារីអ្នកសង្រួម មាន
ចិត្តស្ងប់រម្ងាប់ រមែងរាប់រកបុគ្គលនោះសព្វកាល ពួកព្រហ្មចារី
នោះ រមែងសម្តែងធម៌ ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ដល់

បុគ្គលនោះ ទាំងបុគ្គលនោះដឹងនូវធម៌ ហើយជាអ្នកមិនមាន
អាសវៈ រមែងបរិនិព្វានក្នុងលោកនេះ ។

# អដ្ឋកថា

## នានានិសង្សសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនានានិសង្សសូត្រទី ៥ ដូចតទៅនេះ បទថា **គិហិធម្មា អនបគតោ ហោតិ** គឺជាអ្នកមានសីល ៥ មិនដាច់ ។ បទថា **សតំ ធម្មំ អនុក្កមំ** បានដល់ ជាអ្នកប្រព្រឹត្តតាមធម៌របស់សប្បុរស គឺមហាបុរស ។ បទថា **សន្តោ នំ ភជន្តិ** បានដល់ សប្បុរសទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកនៃព្រះតថាគត រមែងគប់រកបុគ្គលនោះ ។ល។

**អដ្ឋកថា នានានិសង្សសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## កាលទានសូត្រទី ៦

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ កាលទាននេះមាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដល់អ្នកមកថ្មី ១ ឲ្យទានដល់អ្នកមានដំណើរ ១ ឲ្យទានដល់អ្នកមានជំងឺ ១ ឲ្យទានក្នុងពេលអត់បាយ ១ បានតម្កល់ស្រូវថ្មី ផ្លែឈើដំបូងដល់បុគ្គលមានសីលទាំងឡាយជាដំបូង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាកាលទាន ៥ យ៉ាង ។

ពួកជនមានបញ្ញា ដឹងភាសិតរបស់អ្នកប្រាជ្ញ មានសេចក្តីកំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែងឲ្យទានក្នុងកាលគួរ ទានដែលបុគ្គលឲ្យតាមកាលគួរ ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយ និងចិត្តប្រកបដោយតាទិគុណ ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលបរិបូណ៌ ។ ពួកជនណា អនុមោទនា ឬធ្វើសេចក្តីខ្វល់ខ្វាយក្នុងទក្ខិណាទាននោះ ទក្ខិណាទានរបស់អ្នកទាំងនោះ នឹងបានឈ្មោះថាជាទានថយថោក ព្រោះតែអនុមោទនា ឬធ្វើការខ្វល់ខ្វាយនោះក៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែកបុណ្យដែរ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលណា ជាទានមានផលច្រើន បុគ្គលមានចិត្តមិនបានរួញរា គប្បីឲ្យទានចំពោះបុគ្គលនោះ ព្រោះថា បុណ្យទាំងឡាយ រមែងជាទីពឹងនៃពួក

*សត្វ ក្នុងលោកខាងមុខ ។*

# អដ្ឋកថា

## កាលទានសូត្រ

[ ៣៦ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងកាលទានសូត្រទី ៦ ដូចតទៅនេះ បទថា* **កាលទានានិ** *គឺទានដែលគួរ ទានដែលមកដល់ហើយ អធិប្បាយថា ទានដែលសមគួរ ។ បទថា* **ឧវសស្សានិ** *គឺស្រូវដែលល្អ ។ បទថា* **ឧវផលានិ** *បានដល់ ផ្លែឈើដែលល្អ ដែលចេញដំបូងអំពីចម្ការ ។ បទថា* **បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ** *សេចក្តីថា បុគ្គលនោះប្រគេនដល់បុគ្គលដែលមានសីលមុនហើយ ខ្លួនឯងបរិភោគឯងក្រោយ ។ បទថា* **វទញ្ញូ** *គឺជាអ្នកដឹងភាសិត ។ បទថា* **កាលេន ទិន្នំ** *បានដល់ ទានដែលគេឲ្យដ៏សមគួរ ដែលមកដល់ ។ បទថា* **អនុមោទន្តិ** *បានដល់ ជនដែលឈរអនុមោទនាក្នុងទីសមគួរ នាចំណែកម្ខាង ។ បទថា* **វេយ្យាវច្ចំ** *បានដល់ ធ្វើការដែលជាការងារខ្វល់ខ្វាយផ្លូវកាយ ។ បទថា* **អប្បដិវានចិត្តោ** *បានដល់ ជាអ្នកមានចិត្តមិនធុញទ្រាន់ ។ បទថា* **យត្ថ ទិន្នំ មហប្ផលំ** *បានដល់ គប្បីឲ្យក្នុងទីដែលឲ្យហើយមានផលច្រើន ។*

**អដ្ឋកថា កាលទានសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ភោជនទានសូត្រទី ៧

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យភោជនីយាហារ ឈ្មោះថា ឲ្យស្ថាន ៥ យ៉ាងដល់បដិគ្គាហកទាំងឡាយ ។ ស្ថាន ៥ យ៉ាងដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យពណ៌សម្បុរ ១ ឲ្យសុខ ១ ឲ្យកម្លាំង ១ ឲ្យបដិភាណ គឺប្រាជ្ញាវាងវៃ ១ ។ បុគ្គលដែលបានឲ្យអាយុហើយ រមែងបានចំណែកអាយុទិព្វ ឬអាយុជារបស់មនុស្ស ឲ្យពណ៌សម្បុរ រមែងបានចំណែកពណ៌សម្បុរទិព្វ ឬសម្បុររបស់មនុស្ស ឲ្យសុខ រមែងបានចំណែកសុខទិព្វ ឬសុខជារបស់មនុស្ស ឲ្យកម្លាំង រមែងបានចំណែកកម្លាំងទិព្វ ឬកម្លាំងជារបស់មនុស្ស ឲ្យបដិភាណ រមែងបានចំណែកបដិភាណជារបស់ទិព្វ ឬបដិភាណជារបស់មនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យភោជនីយាហារ ឈ្មោះថា ឲ្យស្ថាន ៥ យ៉ាងនេះដល់បដិគ្គាហកទាំងឡាយ ។

ធីរជនអ្នកមានប្រាជ្ញា ជាអ្នកឲ្យអាយុ ឲ្យកម្លាំង ឲ្យពណ៌សម្បុរ
ឲ្យបដិភាណ ឲ្យសុខ ( ដល់គេ ) ហើយធីរជននោះរមែងបាន
សុខ ។ អ្នកប្រាជ្ញឲ្យអាយុ ពណ៌សម្បុរ សេចក្តីសុខ ទាំង
បដិភាណ ទៅកើតក្នុងទីណាៗ រមែងមានអាយុវែង មានយស
បរិវារ ។

# អដ្ឋកថា

## ភោជនទានសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភោជនទានសូត្រទី ៧ ដូចតទៅនេះ បទថា **អាយុំ ទេតិ** បានដល់ ឈ្មោះថា រមែងឲ្យអាយុ ។ បទថា **វណ្ណំ** គឺពណ៌សម្បុរនៃរាងកាយ ។ បទថា **សុខំ** គឺសុខផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ពលំ** គឺកម្លាំងនៃរាងកាយ ។ បទថា **បដិភាណំ** គឺឈ្លាសក្នុងការចងបញ្ហា និងស្រាយបញ្ហា ។

អដ្ឋកថា ភោជនទានសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សទ្ធានិសំសសូត្រទី ៨

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងកុលបុត្រ អ្នកមានសទ្ធានេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសប្បុរសដែលមានចិត្តស្ងប់ក្នុងលោក សប្បុរសទាំងនោះ កាលអនុគ្រោះ រមែងអនុគ្រោះតែបុគ្គលដែលមានសទ្ធាជាដំបូង មិនអនុគ្រោះបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលចូលទៅជិត រមែងចូលទៅជិតតែបុគ្គលមានសទ្ធាជាដំបូង មិនចូលទៅជិតបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលទទួល រមែង

ទទួលតែបុគ្គលមានសទ្ធាជាដំបូង មិនទទួលបុគ្គលមិនមានសទ្ធាដូច្នេះទេ ១ កាលសម្តែងធម៌ ក៏សម្តែងចំពោះតែបុគ្គលមានសទ្ធាជាដំបូង មិនសម្តែងធម៌ចំពោះបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កុលបុត្រមានសទ្ធា លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ៥ ក្នុងកុលបុត្រអ្នកមានសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ដើមជ្រៃធំដុះលើផែនដីដ៏ល្អត្រង់ផ្លូវធំបែកជា ៤ រមែងជាទីពួនសម្ងំនៃពួកបក្សីជុំវិញយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កុលបុត្រដែលមានសទ្ធារមែងជាទីពឹងពាក់អាស្រ័យនៃជនដ៏ច្រើន គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក៏យ៉ាងនោះដែរ ។

ដើមឈើធំ បរិបូណ៌ដោយមែក ស្លឹក ផ្លែ ដើម ឫស បរិបូណ៌ដោយផ្លែ ជាទីពឹងរបស់សត្វបក្សីទាំងឡាយ ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ដែលនៅក្នុងព្រៃរំលោង ជាទីរីករាយចិត្ត ពួកសត្វដែលត្រូវការម្លប់ ក៏ទៅជ្រកម្លប់ ពួកសត្វដែលត្រូវការផ្លែ ក៏បរិភោគផ្លែ យ៉ាងណាមិញ បុរសបុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីលប្រព្រឹត្តឱនលំទោន មិនរឹងរូស ស្លូតត្រង់ ទន់ភ្លន់ ពួកព្រះសង្ឃដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាបុញ្ញក្ខេត្តក្នុងលោក រមែងរាប់រកនរជនប្រាកដដូច្នោះ ពួកព្រះសង្ឃទាំង

នោះ រមែងសម្តែងធម៌ ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ដល់ នរៈនោះ នរៈនោះដឹងនូវធម៌ច្បាស់ហើយ ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វានក្នុងលោកនេះ ។

# អដ្ឋកថា

## សទ្ធានិសំសសូត្រ

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសទ្ធានិសំសសូត្រទី ៦ ដូចតទៅនេះ បទថា **អនុកម្បន្តិ** គឺអនុគ្រោះ ។ បទថា **ខន្ធិមាវ មហាទុមោ** គឺដូចដើមឈើធំសម្បូរដោយដើមដង ។ បទថា **មនោរមេ អាយតនេ** បានដល់ ក្នុងទីប្រជុំដែលគួរត្រេកអរ ។ បទថា **ឆាយំ ឆាយត្ថិកា យន្តិ** បានដល់ ជាអ្នកត្រូវការម្លប់ ក៏ចូលទៅអាស្រ័យម្លប់ ។ បទថា **និវាតវុត្តឹ** គឺប្រព្រឹត្តឱនលំទោន ។ បទថា **អត្ថទ្ធំ** គឺវៀរកាពជាបុគ្គលរឹងត្អឹង ព្រោះក្រោធ និងមានះ ។ បទថា **សោរតំ** បានដល់ ជាអ្នកប្រកបដោយសេចក្តីស្ងប់ មានសីលស្អាត ។ បទថា **សខិលំ** គឺគួរត្រេកអរ ។ល។

**អដ្ឋកថា សទ្ធានិសំសសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បុត្តសូត្រទី ៩

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ មាតាបិតាពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។ ហេតុ ៥ យ៉ាងដូចម្តេចខ្លះ ។ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ បុត្រនឹងជួយធ្វើកិច្ចយើង ១ វង្សត្រកូលនឹងស្ថិតនៅយូរ ១ បុត្រប្រតិបត្តិទទួលយកមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសទក្ខិណាទានឲ្យដល់យើងដែលធ្វើមរណកាលទៅកាន់លោកខាងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតាកាលពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។

អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ យ៉ាង រមែងចង់បានបុត្រ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ នឹងធ្វើកិច្ចការដល់យើង វង្សត្រកូលនឹងស្ថិតនៅយូរ ប្រតិបត្តិគួរដើម្បីទទួលយកមត៌ក មួយទៀត នឹងឧទ្ទិសទក្ខិណា-ទានឲ្យដល់យើងដែលទៅកាន់លោកខាងមុខ អ្នកប្រាជ្ញទាំង-ឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ យ៉ាងនេះហើយ រមែងចង់បានបុត្រ ហេតុដូច្នោះ ពួកសប្បុរសអ្នកស្ងប់រម្ងាប់ជាកតញ្ញូកតវេទិបុគ្គល កាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើហើយក្នុងកាលមុន រមែងចិញ្ចឹមមាតាបិតា រមែងជួយធ្វើកិច្ចការរបស់បុព្វការីទាំងនុ៎ះតាមសមគួរ បុត្រអ្នកធ្វើតាមឪវាទ

អ្នកចិញ្ចឹមមាតាបិតា ដែលលោកចិញ្ចឹមហើយ មិនញ៉ាំងវង្ស-ត្រកូលឲ្យសាបសូន្យ ជាអ្នកមានសទ្ធាបរិបូណ៌ ដោយសីល ដែលអ្នកផងគប្បីសរសើរ ។

# អដ្ឋកថា

## បុត្តសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុត្តសូត្រទី ៩ ដូចតទៅនេះ បទថា **ភតោ វា នោ ភរិស្សតិ** សេចក្តីថា កូនដែលខ្ញុំចិញ្ចឹមមកហើយ បីបាច់មកហើយ ឲ្យបៅដោះ និងញ៉ាំងដៃ និងជើងឲ្យធំធាត់ជាដើម ក្នុងកាលខ្ញុំចាស់ កូននោះនឹងចិញ្ចឹមខ្ញុំ ដោយការលាងដៃ និងជើង ឲ្យងូតទឹក និងឲ្យបបរបាយជាដើម ។ បទថា **កិច្ចំ វា នោ ករិស្សតិ** សេចក្តីថា កូននោះ ផ្អាកការងាររបស់ខ្លួនហើយ នឹងទៅជួយធ្វើកិច្ចរបស់ខ្ញុំដែលកើតឡើងក្នុងរាជ-ត្រកូលជាដើម ។ បទថា **កុលវំសោ ចិរំ ឋស្សតិ** សេចក្តីថា កាលបុត្ររក្សា មិនធ្វើសម្បត្តិរបស់ខ្ញុំ មានស្រែ ចម្ការ ប្រាក់ និងមាសជាដើមឲ្យវិនាសទៅ វង្សត្រកូលក៏នឹងតាំងនៅយូរ ។ ម្យ៉ាងទៀត កូននោះមិនធ្វើសលាកភត្ត-ទានជាដើម ដែលខ្ញុំប្រព្រឹត្តមកហើយឲ្យដាច់ខ្សែ គង់ញ៉ាំងឲ្យប្រព្រឹត្តទៅ វង្សត្រកូលរបស់ខ្ញុំនឹងតាំងនៅយូរ ។ បទថា **ទាយជ្ជំ បដិបជ្ជតិ** សេចក្តីថា បុត្រ

កាលប្រព្រឹត្តខ្លួនសមគួរដល់មត្តិក ដោយបដិបត្តិសមគួរដល់វង្សត្រកូល និងគ្រប់គ្រងមត៌កដែលជាសម្បត្តិរបស់ខ្ញុំបាន ។ បទថា **ទក្ខិណំ អនុប្បទស្សតិ** សេចក្ដីថា បុត្រនឹងបន្ថែមទានឧទ្ទិសចំណែកបុណ្យឲ្យតាំងអំពីថ្ងៃទី ៣ រាប់អំពីថ្ងៃស្លាប់ ។ បទថា **សន្តោ សប្បុរិសា** សេចក្ដីថា គប្បីជ្រាបថា ជាសប្បុរស បុគ្គលល្អដោយបដិបត្តិប្រពៃក្នុងមាតាបិតា ក្នុងឋានៈនេះ ។ បទថា **បុព្វេកតមនុស្សរំ** សេចក្ដីថា កាលរឭកដល់គុណដែលមាតាបិតាធ្វើមុនហើយ ។ បទថា **ឱវាទការី** គឺជាអ្នកធ្វើតាមឱវាទដែលមាតាបិតាឲ្យហើយ ។ បទថា **ភតបោសី** បានដល់ បុត្រនឹងចិញ្ចឹមមាតាបិតាដែលលោកចិញ្ចឹមខ្លួនមក ។ បទថា **បសំសិយោ** សេចក្ដីថា ជាបុគ្គលដែលមហាជនគប្បីសរសើរក្នុងបច្ចុប្បន្ននេះឯង ៕

អដ្ឋកថា បុត្តសូត្រទី៩ចប់

# សុត្តន្តបិដក

## សាលសូត្រទី ១០

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ ដើមឈើធំចម្រើនឡើងដោយសេចក្ដីចម្រើន ៥ យ៉ាង ព្រោះអាស្រ័យស្ដេចភ្នំឈ្មោះហិមវន្ត ។ ៥ យ៉ាងដូចម្ដេច

ខ្ទះ ។ គឺចម្រើនដោយមែក ស្លឹក ត្រួយ ១ ចម្រើនដោយសម្បក ១ ចម្រើនដោយក្រមរ ១ ចម្រើនដោយស្រាយ ១ ចម្រើនដោយខ្លឹម ១ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើធំចម្រើនឡើងដោយសេចក្តីចម្រើន ៥ យ៉ាងនេះព្រោះអាស្រ័យស្តេចភ្នំឈ្មោះហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុងរមែងចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាង ព្រោះអាស្រ័យជនជាម្ចាស់ត្រកូលមានសទ្ធា ដូច្នោះដែរ ។ ៥ យ៉ាងដូចម្តេចខ្ទះ ។ គឺចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយសុតៈ ១ ចម្រើនដោយចាគៈ ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាងនេះ ព្រោះអាស្រ័យជនជាម្ចាស់ត្រកូលមានសទ្ធា ។

ភ្នំថ្មក្នុងជង្រៃធំ ដើមឈើធំៗ ទាំងនោះ រមែងចម្រើនឡើងព្រោះអាស្រ័យភ្នំថ្មនោះយ៉ាងណាមិញ កូនប្រពន្ធទាំងឡាយ ផៅពង្សទាំងឡាយ អាមាត្យទាំងឡាយ ពួកញាតិទាំងឡាយ ពួកជនអ្នកចិញ្ចឹមជីវិតដោយសារបុគ្គលនោះ រមែងចម្រើនឡើងព្រោះអាស្រ័យនឹងកុលបុត្រអ្នកមានសទ្ធា បរិបូណ៌ដោយសីលក្នុងលោកនេះ ពួកជនមានកូន និងប្រពន្ធជាដើមនោះ ឃើញសីលផង ចាគៈផង និងសុចរិតទាំងឡាយផងរបស់កុលបុត្រអ្នកមានសីលនោះហើយ រមែងធ្វើតាមយ៉ាងនោះដែរ ក្នុងលោកនេះ ពួកអ្នកប្រាជ្ញណាជាអ្នកប្រព្រឹត្តធម៌ ជាអ្នកមានដំណើរទៅកាន់

សុគតិសួគ៌ ពួកអ្នកប្រាជ្ញានោះជាអ្នកត្រេកអររីករាយ សម្រេច ដូចសេចក្ដីប្រាថ្នាក្នុងទេវលោក ។

សុមនវគ្គទី ៤ ចប់

## ឧទ្ទាននៃសុមនវគ្គនោះគឺ

រឿងទាំងនោះមាន ១០ គឺរឿងនាងសុមនារាជកុមារី ១ ចុន្ទីរាជ-កុមារី ១ ឧគ្គហមេណ្ឌកនត្តា ១ សីហសេនាបតី ១ អានិសង្ស-ទានទាំងឡាយ ១ កាលទាន ១ភោជនាហារ ១ កុលបុត្រ មានសទ្ធា ១ មាតាបិតាចង់បានកូន ១ ដើមឈើធំ ១ ។

# អដ្ឋកថា

## សាលសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាលសូត្រទី ១០ ដូចតទៅនេះ បទថា **មហាសាលា** គឺដើមឈើធំ ។ បទថា **សាខាបត្តបលាសេន វឌ្ឍន្តិ** គឺចម្រើនដោយមែក និងស្លឹក ដែលហៅថា បត្តៈ ។ បទថា **អរញ្ញស្មឹ** គឺ ក្នុងទីដែលមិនមែនស្រុក ។ បទថា **ព្រហាវនេ** បានដល់ ក្នុងព្រៃធំ គឺព្រៃ ជ្រៅ ។ បទដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា សាលសូត្រទី ១០ ចប់**

**សុមនវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## មុណ្ឌរាជវគ្គទី ៥

### អាទិយសូត្រទី ១

[ ៤១ ] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលគហបតី ការកាន់យកនូវភោគៈនេះមាន ៥ យ៉ាង ។ ៥ យ៉ាងដូចម្តេចខ្លះ ។ ម្នាលគហបតី អរិយសាវកក្នុងលោកនេះ មានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយសេចក្តីខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ហើយ ញុំាងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ ញុំាងមាតាបិតាឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ ញុំាងបុត្រភរិយា ទាសកម្មករ និងបុរសទាំងឡាយឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ នេះជាការកាន់យកនូវភោគៈទី ១ ។ ម្នាលគហបតី មួយទៀត អរិយសាវកមានភោគៈទាំងឡាយ ដែលខ្លួនបានដោយការខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ រមែងញុំាងមិត្តអាមាត្យឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ នេះជាការកាន់យកនូវភោគៈទាំងឡាយទី ២ ។ ម្នាលគហបតី មួយទៀត

អរិយសាវកមានភោគៈទាំងឡាយ ដែលខ្លួនបានមក ដោយការខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ទុកការពារនូវសេចក្តីអន្តរាយ ដែលកើតអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីជនមិនជាទីស្រឡាញ់ អំពីអ្នកទាមទារមត៌ក ហើយក៏ធ្វើខ្លួនឲ្យដល់សួស្តី ព្រោះភោគៈទាំងឡាយនោះ នេះជាការកាន់យកនូវភោគៈទាំងឡាយទី ៣ ។ ម្នាលគហបតី មួយទៀត អរិយសាវកមានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយការខ្នះខ្នែងព្យាយាម សន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ហើយជាអ្នកធ្វើនូវពលី ៥ ប្រការ គឺញាតិពលី ១ អតិថិពលី ១ បុព្វបេតពលី ១ រាជពលី ១ ទេវតាពលី ១ នេះជាការកាន់យកនូវភោគៈទាំងឡាយទី ៤ ។ ម្នាលគហបតី មួយទៀត អរិយសាវកមានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយការខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ពួកសមណព្រាហ្មណ៍ណា ប្រាសចាកសេចក្តីប្រមាទព្រោះស្រវឹង តាំងនៅក្នុងខន្តិ និងសោរច្ចៈ ទូន្មានតែខ្លួនឯងម្នាក់ រម្ងាប់តែខ្លួនឯងម្នាក់ រម្ងត់ ( កិលេស ) ចំពោះខ្លួនម្នាក់ ហើយតម្កល់ទុកនូវទក្ខិណាទានដ៏ខ្ពង់ខ្ពស់ ជាធម្មជាតឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ចំពោះពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ នេះជាការកាន់យកនូវភោគៈទាំងឡាយទី ៥ ។ ម្នាលគហបតី ទាំង ៥ នេះឯង

ជាការកាន់យកនូវភោគៈទាំងឡាយ ។ ម្នាលគហបតី បើភោគៈទាំង ៥ យ៉ាងនេះ របស់អរិយសាវ័កនោះ ដល់នូវកិរិយាអស់ទៅ ព្រោះហេតុដែលបុគ្គលគប្បីកាន់យក ចំពោះហេតុដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អរិយសាវ័កនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុទាំងឡាយណា ដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អាត្មាអញកាន់យកនូវហេតុទាំងឡាយនោះផង ភោគៈទាំងឡាយរបស់អាត្មាអញ ក៏ដល់នូវកិរិយាអស់ទៅផង ដូច្នោះ ហេតុនោះ អរិយសាវ័កនោះ មិនមានសេចក្តីស្តាយក្រោយសោះឡើយ ។ ម្នាលគហបតី បើភោគៈទាំង ៥ យ៉ាងនេះ អរិយសាវ័កនោះចម្រើនឡើង ព្រោះហេតុដែលគប្បីកាន់យក ចំពោះហេតុដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អរិយសាវ័កនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុទាំងឡាយណា ដែលអញគប្បីកាន់យកនូវភោគៈទាំងឡាយ អាត្មាអញនឹងកាន់យកនូវហេតុទាំងនោះផង ភោគៈទាំងឡាយរបស់អញ ចម្រើនឡើងផង ហេតុដូច្នោះនោះ អរិយសាវ័កនោះ ជាអ្នកឥតមានសេចក្តីស្តាយក្រោយសោះឡើយ ។ អរិយសាវ័កឥតមានសេចក្តីស្តាយក្រោយ ដោយហេតុទាំងពីរយ៉ាង ។

ភោគៈទាំងឡាយ ដែលអាត្មាអញបានបរិភោគហើយ មិត្តអាមាត្យ អាត្មាអញបានចិញ្ចឹមហើយ អាត្មាអញបានកន្លងផុតអំពីសេចក្តីអន្តរាយហើយ ទក្ខិណាដ៏ប្រសើរបំផុត អាត្មាអញបានឲ្យហើយ មួយទៀត ពលីទាំង ៥ អាត្មាអញបានធ្វើហើយ

ពួកព្រហ្មចារីអ្នកមានសីល ជាអ្នកសង្រួម អាត្មាអញបាន តម្កល់ទានទុកហើយ បណ្ឌិតអ្នកនៅគ្រប់គ្រងផ្ទះ ប្រាថ្នាភោគៈ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ អាត្មាអញបានសម្រេច ហើយ កម្មដែលមិនបានក្ដៅក្រហាយតាមក្រោយ អាត្មាអញ បានធ្វើហើយ សត្វ គឺនរជន កាលរឭកឃើញហេតុនុ៎ះ ឈ្មោះ ថា ជាអ្នកឋិតនៅក្នុងអរិយធម៌ ពួកបណ្ឌិតតែងសរសើរបុគ្គល នុ៎ះនាលោកិយនេះ បុគ្គលនោះ ដល់ទៅបរលោក រមែង រីករាយក្នុងស្ថានសួគ៌ ។

# អដ្ឋកថា

# មុណ្ឌរាជវគ្គទី ៥

## អាទិយសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាទិយសូត្រទី ១ នៃមុណ្ឌរាជវគ្គទី ៥ ដូចតទៅនេះ បទថា **ភោគានំ អាទិយា** បានដល់ ហេតុនៃភោគៈទាំងឡាយ ដែលគប្បីកាន់យកប្រយោជន៍ ។ បទថា **ឧដ្ឋានវីរិយាធិគតេហិ** បានដល់ ដែលបានមកដោយការឧស្សាហ៍ព្យាយាម ។ បទថា **ពាហាពលបរិចិតេហិ** បានដល់ ដែលសន្សំដោយកម្លាំងស្មន ។ បទថា **សេទាវក្ខិត្តេហិ** បានដល់ បានមកដោយបែកញើស ។ បទថា **ធម្មិកេហិ** គឺប្រកបដោយធម៌ ។ បទថា **ធម្មលទ្ធេហិ** បានដល់ មិនខូចនូវកុសលធម៌ បានមកដោយធម៌ ។ បទថា **បីណេតិ** បានដល់ ធ្វើឲ្យឆ្អែតស្កប់ស្កល់ ។ បទដ៏សេស ក្នុងសូត្រនេះ គប្បីជ្រាបដោយន័យ ដែលពោលហើយ ក្នុងចតុក្កនិបាត ។

**អដ្ឋកថា អាទិយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សប្បុរិសសូត្រទី ២

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ បើសប្បុរសកើតក្នុងត្រកូល រមែងកើត ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើនគ្នា ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់មាតាបិតាទាំងឡាយ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់កូនប្រពន្ធ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកមិត្តអាមាត្យ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកសមណ-ព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភ្លៀងធំញុំាងសម្ទូងទាំងអស់ ឲ្យលូតលាស់ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសប្បុរសកើតក្នុងត្រកូល ( នីមួយៗ ) រមែងកើតដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់មាតាបិតាទាំងឡាយ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់កូនប្រពន្ធ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់បុរសជាទាសកម្មករ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកមិត្តអាមាត្យ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកសមណព្រាហ្មណ៍ ក៏យ៉ាងនោះដែរ ។

សប្បុរស មានប្រយោជន៍ដល់ពួកជនច្រើន ប្រើប្រាស់ភោគៈទាំងឡាយ ទេវតារមែងរក្សានូវសប្បុរស ជាអ្នកគ្រប់គ្រងធម៌នោះ ជាពហុស្សូត បរិបូណ៌ដោយសីល និងវត្ត កិត្តិសព្ទមិនលះបង់ នូវសប្បុរសអ្នកតាំងនៅក្នុងធម៌ ។ អ្នកណាមួយអាចដើម្បីនិន្ទាបុគ្គល ដែលឋិតនៅក្នុងធម៌ បរិបូណ៌ដោយសីល ពោលពាក្យសច្ចៈ មានចិត្តប្រកបដោយហិរិ បីដូចជាមាសជម្ពូនទនោះបាន សូម្បីតែពួកទេវតា ក៏រមែងសរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរបុគ្គលនោះដែរ ។

## ឥដ្ឋសូត្រទី ៣

[ ៤៣ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ធម៌ ៥ យ៉ាង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ។ ធម៌ ៥ យ៉ាងដូចម្តេចខ្លះ ។ ម្នាលគហបតី អាយុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ពណ៌សម្បុរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ សុខជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ យសជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រក

បានដោយក្រក្នុងលោក ១ ស្ថានសួគ៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ។ ម្នាលគហបតី ធម៌ទាំង ៥ យ៉ាងនេះឯង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ។ ម្នាលគហបតី តថាគតមិនពោលនូវការបាន ចំពោះធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ ព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នាទេ ។ ម្នាលគហបតី បើការបានចំពោះនូវធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ នេះ នឹងមានហើយ ព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នា នរណាមួយក្នុងលោកនេះ អាចញ៉ាំងនរណាឲ្យសាបសូន្យបាន ។ ម្នាលគហបតី អរិយសាវ័ក អ្នកប្រាថ្នានូវអាយុ មិនគួរបន់ស្រន់ ឬមិនគួរត្រេកអរនឹងអាយុ ឬក៏ព្រោះហេតុនៃអាយុឡើយ ។ ម្នាលគហបតី បដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវអាយុ ដែលអរិយសាវ័កអ្នកប្រាថ្នានូវអាយុ គប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបាននូវអាយុ អរិយសាវ័កនោះបានប្រតិបត្តិហើយ ប្រព្រឹត្តទៅដើម្បីបាននូវអាយុ ។ អរិយសាវ័កនោះ ជាអ្នកបានអាយុជាទិព្វ ឬអាយុជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវ័កអ្នកប្រាថ្នាពណ៌សម្បុរ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងពណ៌សម្បុរ ឬក៏ព្រោះហេតុតែពណ៌សម្បុរទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានពណ៌សម្បុរ ដែលអរិយសាវ័ក អ្នកប្រាថ្នាពណ៌សម្បុរគប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបាន

ពណ៌សម្បុរ អរិយសាវកនោះប្រតិបត្តិហើយ ប្រព្រឹត្តទៅដើម្បីបានពណ៌សម្បុរមែន ។ អរិយសាវកនោះ ជាអ្នកបានពណ៌សម្បុរវិញ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវកជាអ្នកប្រាថ្នានូវសេចក្តីសុខ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងសេចក្តីសុខ ឬក៏ហេតុតែសេចក្តីសុខទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានសេចក្តីសុខ ដែលអរិយសាវកអ្នកប្រាថ្នាសេចក្តីសុខ គប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានសេចក្តីសុខ អរិយសាវកនោះប្រតិបត្តិហើយ ប្រព្រឹត្តទៅដើម្បីបានសេចក្តីសុខមែន ។ អរិយសាវកនោះ ជាអ្នកបានសេចក្តីសុខវិញ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវក អ្នកប្រាថ្នាយសសក្តិ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងយសសក្តិ ឬក៏ហេតុតែយសសក្តិទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានយសសក្តិ ដែលអរិយសាវកអ្នកប្រាថ្នាយសសក្តិ គប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីយសសក្តិ ដែលអរិយសាវកនោះប្រតិបត្តិហើយ ប្រព្រឹត្តទៅដើម្បីបានយសសក្តិមែន ។ អរិយសាវកនោះ ជាអ្នកបានយសសក្តិវិញ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវកអ្នកប្រាថ្នាស្ថានសួគ៌ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងស្ថានសួគ៌ ឬក៏ហេតុតែស្ថានសួគ៌ទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅដើម្បីបានទៅកើតក្នុងស្ថានសួគ៌ អរិយសាវក អ្នកប្រាថ្នាស្ថានសួគ៌ គប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានស្ថានសួគ៌

អរិយសាវកនោះប្រតិបត្តិហើយ ប្រព្រឹត្តទៅដើម្បីបានស្ថានសួគ៌មែន ។ អរិយសាវកនោះ ជាអ្នកបានទៅកើតស្ថានសួគ៌ ។

អ្នកប្រាជ្ញទាំងឡាយ តែងសរសើរសេចក្ដីមិនប្រមាទ ក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ ព្រោះប្រាថ្នានូវសេចក្ដីត្រេកអរ គឺ អាយុ ពណ៌សម្បុរ យសសក្តិ កិត្តិសព្ទ ស្ថានសួគ៌ ត្រកូលខ្ពស់ដ៏លើសលុបតៗ ទៅ ។ អ្នកប្រាជ្ញមិនមានសេចក្ដីប្រមាទ រមែងបានសម្រេចប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ១ ប្រយោជន៍ក្នុងបរលោក ១ អ្នកមានប្រាជ្ញាដែលហៅថា បណ្ឌិត ព្រោះបាននូវប្រយោជន៍ ។

# អដ្ឋកថា

## ឥដ្ឋសូត្រ

[ ៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥដ្ឋសូត្រទី ៣ ដូចតទៅនេះ បទថា **អាយុសំវត្តនិកា បដិបទា** បានដល់ បុញ្ញបដិបទា មានទាន និងសីលជាដើម ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **អត្ថាភិសមយា** បានដល់ សម្រេចប្រយោជន៍ លោកអធិប្បាយថា ព្រោះបានប្រយោជន៍ ។៚

**អដ្ឋកថា ឥដ្ឋសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មនាបទាយិសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងកូដាគារ-សាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃឧគ្គ-គហបតី អ្នកក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ ឧគ្គគហបតី អ្នកក្រុងវេសាលី ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកក្រុងវេសាលី អង្គុយក្នុងទីសមគួរហើយបានក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគថា អ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ខាទនីយាហារ ប្រាកដស្មើដោយផ្កាសាលព្រឹក្ស ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទទួលនូវខាទនីយាហារនោះដើម្បីសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន សូករមំសៈដ៏ប្រសើរ ស្អាតជាទីគាប់ចិត្ត របស់ខ្ញុំព្រះអង្គមាន សូមព្រះដ៏មាន

ព្រះភាគ ទ្រង់ទទួលសូករមំសៈនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មាន ព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន នាលិយសាក ដែលប្រឡាក់ដោយប្រេង ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនាលិយសាកនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន បាយស្រូវសាលីឥតមានវេទុក មានសម្លប្រើនមុខ មានម្ហូបគ្រឿងច្រើនមុខ ជាទីគាប់ចិត្តខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវភោជននោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគថា បុគ្គលអ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន សំពត់ទាំងឡាយនៅក្នុងដែនកាសី ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទទួលសំពត់ទាំងនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន

ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន បល្ល័ង្កដែលក្រាលដោយព្រំ មានរោមវែង ( ជាង ៤ ធ្នាប់ ) កម្រាលពណ៌សដែលធ្វើដោយរោមសត្វ កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម កម្រាលដ៏ឧត្តម ដែលធ្វើដោយស្បែកសត្វឈ្លូស មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតានមានពណ៌ក្រហម ជាទីគាប់ចិត្តនៃខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត យើងខ្ញុំដឹងរបស់នុ៎ះថា របស់នុ៎ះមិនគួរដល់ព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ផែនក្តារខ្លឹមចន្ទន៍របស់ខ្ញុំព្រះអង្គនេះ ថ្លៃជាងមួយសែន សូមព្រះដ៏មានព្រះភាគទទួលផែនក្តារនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ អនុមោទនាដោយអនុមោទនីយគាថានេះ ចំពោះឧគ្គគហបតី អ្នកក្រុងវេសាលីថា

បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ
សប្បុរសណា ដឹងនូវពួកព្រះអរហន្ត ឧបមាដូចជាស្រែហើយ
ប្រគេនសំពត់ស្លៀក ដណ្តប់ ដំណេក បាយ ទឹក និងបច្ច័យ
ទាំងឡាយមានប្រការផ្សេងៗ ដែលខ្លួនបរិច្ចាគហើយផង លះ-
បង់ហើយផង មិនមានស្តាយផង ចំពោះលោកអ្នកមានកាយ
វាចា ចិត្តត្រង់ សប្បុរសនោះ ឈ្មោះថា លះបង់ហើយ នូវវត្ថុ

ដែលគេលះបង់បានដោយកម្រ បុគ្គលអ្នកឲ្យរបស់ជាទីគាប់
ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគអនុមោទនា ដោយអនុមោទនីយគាថានេះ ចំពោះឧគ្គគហបតី អ្នកក្រុងវេសាលី ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ លំដាប់នោះ ឧគ្គគហបតីអ្នកក្រុងវេសាលី ក៏ធ្វើមរណ-កាល ក្នុងសម័យក្រោយមក លុះឧគ្គគហបតីអ្នកក្រុងវេសាលី ធ្វើមរណ-កាលហើយ ក៏ទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ ។ សម័យនោះសោត ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ឧគ្គទេវបុត្ត កាលរាត្រីកន្លងទៅហើយ មានរស្មីដ៏រុងរឿង បំភ្លឺវត្តជេតពនទាំងអស់ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ ។ លុះឧគ្គទេវបុត្ត ឈរក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលឧគ្គៈ សេចក្តីសមតាមបំណងរបស់អ្នក មានដែរឬទេ ។ បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់ជ្រាបសេចក្តីសមប្រកបតាមបំណងរបស់ខ្ញុំព្រះអង្គមានដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានត្រាស់នឹងឧគ្គទេវបុត្តដោយគាថាទាំងឡាយថា

បុគ្គលអ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្ត
វិញ បុគ្គលអ្នកឲ្យរបស់ខ្ពង់ខ្ពស់ រមែងបានរបស់ខ្ពង់ខ្ពស់វិញ

បុគ្គលអ្នកឲ្យរបស់ប្រសើរ រមែងបានរបស់ដ៏ប្រសើរវិញ បុគ្គលអ្នកឲ្យរបស់ដ៏ថ្លៃថ្លា រមែងបាននូវឋានៈដ៏ថ្លៃថ្លាវិញ នរៈណាអ្នកឲ្យរបស់ខ្ពង់ខ្ពស់ផង អ្នកឲ្យរបស់ប្រសើរផង អ្នកឲ្យរបស់ថ្លៃថ្លាផង នរៈនោះ កើតក្នុងទីណា ជាអ្នកមានអាយុវែង មានយសសក្តិក្នុងទីនោះៗ ។

# អដ្ឋកថា

## មនាបទាយិសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមនាបទាយិសូត្រទី ៤ ដូចតទៅនេះ បទថា **ឧគ្គោ** បានដល់ ដែលបានឈ្មោះយ៉ាងនេះ ព្រោះជាអ្នកខ្ពស់ដោយគុណទាំងឡាយ ។ បទថា **សាលបុប្ផកំ ខាទនីយំ** បានដល់ របស់ទំពាដូចគ្នានឹងផ្កាសាលព្រឹក្ស ធ្វើដោយម្សៅស្រូវសាលី ផ្សំដោយមធុរស ៤ ប្រភេទ ពិតហើយ មធុរសប្រភេទនោះ គេផ្សំឲ្យមានពណ៌ ត្របក និង កេសរ ហើយចៀនដោយសប្បិ ដែលផ្សំដោយគ្រឿងទេស មានថ្លៃម្ចាក់ជាដើម ឆ្អិនហើយ សម្រស់ឲ្យស្រស់សប្បិ ដាក់ក្នុងភាជនៈដែលមានគម្រប អប់ក្លិនឲ្យឈ្ងុយ ។ ឧគ្គគហបតី បំណងនឹងថ្វាយក្នុងវេលាអាហារ

ទើបក្រាបទូលយ៉ាងនេះ ដល់ព្រះមានព្រះភាគអង្គនោះ ដែលប្រថាប់គង់ផាន់បបរ ។ បទថា **បដិគ្គហេសិ ភគវា** នុ៎ះ ត្រឹមតែជាទេសនា ។ ឧបាសកបានថ្វាយខាទនីយនោះដល់ព្រះមានព្រះភាគ និងភិក្ខុ ៥០០ រូប ថ្វាយមំសសូករៈជាដើម ក៏ដូចគ្នានឹងខាទនីយនោះ ដូច្នោះ ។ ក្នុងបទទាំងនោះ បទថា **សម្បន្នវរសូករមំសំ** សេចក្តីថា សាច់ជ្រូកដែលចម្អិនដោយគ្រឿងទេសមានផ្លែម្នាក់ជាដើម និងផ្លែពុទ្រាដែលមានរសល្អ ធ្វើឲ្យឆ្អិនហើយ រក្សាមួយឆ្នាំ ទើបបរិភោគ ។ បទថា **និព្វត្តតេលកំ** គឺខាញ់ដែលក្តៅហើយ ។ បទថា **នាលិយសាកំ** បានដល់ បន្លែឈ្មោះនាលិកដែលលាយជាមួយម្សៅខ្សាយ ហើយចៀនដោយសប្បិ ផ្សំដោយមធុរស ៤ ប្រភេទ ហើយរក្សា ។ ក្នុងបទថា **នេតំ ភគវតោ កប្បតិ** នេះ លោកសំដៅដល់របស់ជាអកប្បិយថា សូម្បីកប្បិយ ក៏មិនគួរ ។

សេដ្ឋីឲ្យនាំរបស់ទាំងអស់នោះមក ហើយធ្វើឲ្យជាគំនរ របស់ណាមួយជាអកប្បិយ ក៏បញ្ជូនរបស់នោះៗ ទៅកាន់ទីផ្សារ ហើយទើបប្រគេនរបស់ដែលជាគ្រឿងឧបភោគ និងបរិភោគ ដែលជាកប្បិយ បន្ទះដើមចន្ទន៍ មិនធំពេក ប្រវែងប្រមាណ ២ ហត្ថ ១ ចំអាម ទទឹងប្រមាណ ១ ហត្ថ ១ ចំអាម តែជារបស់មានតម្លៃច្រើន ព្រោះជារបស់មានសារៈយ៉ាងល្អ ។ ព្រះមានព្រះភាគ ទ្រង់ទទួលបន្ទះដើមចន្ទន៍នោះហើយ ឲ្យជ្រៀកជាចម្រៀកតូចៗ ឲ្យប្រគេនដល់ភិក្ខុទាំងឡាយ ដើម្បីបុកជាថ្នាំបន្តក់ភ្នែក ។

បទថា **ឧជុភូតេសុ** បានដល់ ក្នុងបុគ្គលដែលបដិបត្តិត្រង់ដោយកាយ វាចា ចិត្ត ។ បទថា **ចាគំ** បានដល់ សេចក្ដីស្រឡាញ់ ។ ក្នុងបទថា **ចត្តំ** ជាដើម ឈ្មោះថា លះបង់ហើយ ដោយអំណាចបរិច្ចាគ ឈ្មោះថា លែងហើយ ដោយការលះបង់ គឺមិនកាន់យកមកវិញ ឈ្មោះថា **អនគ្គហិតំ** ព្រោះចិត្តមិនគិតយកមកវិញ ព្រោះមានចិត្តមិនស្ដាយ ។ បទថា **ខេត្តូបមេ** គឺដូចស្រែ ព្រោះជាទីដុះឡើង ។ បទថា **អញ្ញតរំ មនោមយំ** បានដល់ ពួកទេវតាដែលកើតដោយចិត្តដែលនៅក្នុងឈានណាមួយ ក្នុងជាន់សុទ្ធាវាស ។ បទថា **យថាធិប្បាយោ** គឺតាមអធ្យាស្រ័យ ។ សួរថា ព្រះមានព្រះភាគ ទ្រង់សួរអ្វី ដោយបទនេះ ។ ឆ្លើយថា បានឮថា លោកមានអធ្យាស្រ័យកាន់យកអរហត្ត កាលជាមនុស្ស ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់សួរថា តថាគតនឹងសួរសេចក្ដីនោះ ។ ទេវបុត្របានក្រាបទូលថា **តស្ស មេ ភគវា យថាធិប្បាយោ** ដូច្នេះ ព្រោះលោកសម្រេចអរហត្តហើយ ។ បទថា **យត្ថ យត្ថូបបជ្ជតិ** សេចក្ដីថា បុគ្គលនោះរមែងកើតក្នុងកុសលសម្បត្តិ ៣ ឬក្នុងស្ថានសួគ៌ជាន់កាមាវចរ ៦ ជាន់ ក្នុងភពណាមួយ ក៏ជាអ្នកមានអាយុវែងមានយសក្នុងភពនោះៗ ។

## អដ្ឋកថា មនាបទាយិសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អភិសន្ទសូត្រទី ៥

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ នេះមាន ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសុខ ។ ៥ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់ចីវររបស់គហបតីណា បានសម្រេចចេតោសមាធិ មានប្រមាណមិនបាន គំនរបុណ្យ គំនរកុសលប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ របស់គហបតីនោះ ប្រព្រឹត្តទៅដើម្បីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ មានប្រមាណមិនបានទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុបរិភោគបិណ្ឌបាតរបស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់វិហារ របស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់គ្រែ និងតាំងរបស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុបរិភោគនូវគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ របស់គហបតីណា ហើយបានសម្រេចចេតោសមាធិ មានប្រមាណមិនបាន គំនរបុណ្យ គំនរកុសលប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ របស់គហបតីនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ មានប្រមាណមិនបានទេ ។ ម្នាលភិក្ខុទាំងឡាយ គំនរបុណ្យ

គំនរកុសល ៥ យ៉ាងនេះឯង ជាធម៌ប្រមូលមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក ដែលបរិបូណ៌ដោយគំនរបុណ្យ គំនរកុសល ៥ យ៉ាងនេះហើយ បុគ្គលមិនងាយប្រមាណបុណ្យថា គំនរបុណ្យ គំនរកុសល ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ មានប្រមាណប៉ុណ្ណេះបានឡើយ គំនរបុណ្យរាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា គំនរបុណ្យច្រើនប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយនឹងកំណត់ នូវប្រមាណនៃទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណេះអាឡ្ហកក្តី ទឹកប៉ុណ្ណេះរយអាឡ្ហកក្តី ទឹកប៉ុណ្ណេះពាន់អាឡ្ហកក្តី ទឹកប៉ុណ្ណេះសែនអាឡ្ហកក្តី ដូច្នេះបានឡើយ ត្រឹមតែរាប់បានថា គំនរទឹកដ៏ធំប៉ុណ្ណោះ នឹងគប្បីរាប់មិនបាន ប្រមាណមិនកើត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលបរិបូណ៌ដោយគំនរបុណ្យ គំនរកុសលទាំង ៥ នេះហើយ បុគ្គលមិនងាយនឹងកំណត់ប្រមាណបុណ្យថា គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខប៉ុណ្ណេះបានឡើយ ត្រឹមតែរាប់ថា គំនរបុណ្យដ៏ធំ

ប៉ុណ្ណោះ នឹងគប្បីរាប់មិនបាន ប្រមាណមិនកើត ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ស្ទឹងទាំងឡាយដ៏ជ្រៅ ដែលហ្វូងត្រីអាស្រ័យនៅ រមែងហូរទៅជោរទៅកាន់សាគរ ដែលទ្រទ្រង់ទឹកដ៏ច្រើន ប្រមាណមិនបាន ជាស្រះធំមានភ័យច្រើន ជាទីកើតនៃគំនរកែវ យ៉ាងណាមិញ ធារបុណ្យរមែងជន់ជោរ ទៅរកនរៈជាបណ្ឌិត ដែលជាអ្នកឲ្យបាយ ទឹក សំពត់ អ្នកឲ្យទីដេក ទីអង្គុយ គ្រឿងកម្រាល យ៉ាងនោះដែរ ដូចជាទឹកក្នុងស្ទឹងទាំងឡាយ ហូរទៅកាន់សមុទ្ទសាគរ ។

# អដ្ឋកថា

## អភិសន្ទសូត្រ

[ ៤៥ ] អភិសន្ទសូត្រទី ៥ គប្បីជ្រាបដោយន័យដែលលោកពោលហើយ ក្នុងចតុក្កនិបាត ៕

### អដ្ឋកថា អភិសន្ទសូត្រទី ៥ ចប់

# សុត្តន្តបិដក

## សម្បទាសូត្រទី ៦

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ សុតសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសម្បទា ៥ យ៉ាង ។

# អដ្ឋកថា

## សម្បទាសូត្រ

[ ៤៦ ] ក្នុងសម្បទាសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសម្បទាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ធនសូត្រទី ៧

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ទ្រព្យគឺសទ្ធា ១ ទ្រព្យគឺសីល ១ ទ្រព្យគឺសុតៈ ១ ទ្រព្យគឺចាគៈ ១ ទ្រព្យគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺសទ្ធា តើដូច

ម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្ដីត្រាស់ដឹង របស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងអរិយសច្ច លែងវិលមកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យ គឺសីល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកសុរា និងមេរ័យជាគ្រឿងស្រវឹង ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសីល ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យ គឺសុតៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកស្ដាប់ច្រើន ។បេ។ ចាក់ធ្លុះដោយប្រពៃ ព្រោះសេចក្ដីឃើញ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសុតៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យ គឺចាគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានចិត្តដែលសេចក្ដីកំណាញ់ជាមន្ទិលទៅប្រាសហើយ នៅគ្រប់គ្រងផ្ទះ មានចាគៈរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូម បានត្រេកអរក្នុងទាន និងការចែករំលែក ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺចាគៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យ គឺបញ្ញា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបព្រមដោយប្រាជ្ញា ជាគ្រឿងយល់សេចក្ដីចម្រើន

និងវិនាស ប្រាជ្ញាដ៏មោះមុតប្រសើរ ជាបញ្ញាឲ្យដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទ្រព្យ ៥ យ៉ាង ។

សទ្ធារបស់បុគ្គលណា មិនញាប់ញ័រ បានតម្កល់ទុកប្រពៃក្នុងព្រះតថាគត មួយទៀត សីលរបស់បុគ្គលណា ជាសីលល្អ ជាទីត្រេកអររបស់ព្រះអរិយៈ ដែលព្រះអរិយៈសរសើរហើយ បុគ្គលណា មានសេចក្តីជ្រះថ្លាក្នុងព្រះសង្ឃ ទាំងមានកិរិយាឃើញត្រង់ អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រ ទាំងជីវិតរបស់បុគ្គលនោះ មិនឥតអំពើ ហេតុដូច្នោះ អ្នកប្រាជ្ញ កាលបើរឭកឃើញ នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង កិរិយាឃើញធម៌ផង ។

# អដ្ឋកថា

## ធនសូត្រ

[ ៤៧ ] ក្នុងធនសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាធនសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ឋានសូត្រទី ៨

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ អលព្ភនីយដ្ឋាន ៥ យ៉ាង ( ហេតុដែលមិនគប្បីបាន ) ដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក ( បានតាមប្រាថ្នា ) ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបាន ( តាមប្រាថ្នា ) ថា របស់ដែលមានជរាជាធម្មតា កុំជរាឡើយ ១ របស់ដែលមានព្យាធិជាធម្មតា កុំឈឺចាប់ឡើយ ... ១ របស់ដែលមានមរណៈជាធម្មតា កុំស្លាប់ឡើយ ... ១ របស់ដែលមានការអស់ទៅជាធម្មតា កុំអស់ទៅឡើយ ... ១ ហេតុដែលសមណ-ព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមប្រាថ្នាថា របស់ដែលមានសេចក្តីវិនាសជាធម្មតា កុំវិនាសឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ជរាធម៌របស់បុថុជ្ជនអ្នកមិនបានស្តាប់រមែងគ្រាំគ្រា បុថុជ្ជននោះមិនបានពិចារណាក្នុងជរាធម៌ ដែលគ្រាំគ្រាហើយថា មិនគ្រាំគ្រាចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ ការច្យុត ការកើតឡើងរបស់សត្វទាំងឡាយត្រឹមណា ជរាធម៌របស់សត្វទាំងអស់រមែងគ្រាំគ្រាត្រឹមនោះដែរ កាលបើជរាធម៌គ្រាំគ្រាហើយ អាត្មាអញត្រូវតែសោកសង្រេងលំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានកត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏ប្រព្រឹត្តទៅមិនបានផង ពួកជនជាសត្រូវក៏មានចិត្តរីករាយផង ពួកមិត្ត

សម្លាញ់តូចចិត្តផង ។ កាលបើជរាធម៌គ្រាំគ្រាហើយ បុថុជ្ជននោះក៏សោក សង្រេងលំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនបានស្តាប់ ត្រូវសរដែលសេចក្តីសោក លាបដោយថ្នាំពិសចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្យាធិធម៌របស់បុថុជ្ជនអ្នកមិនបានស្តាប់ រមែងឈឺចាប់ ... មរណធម៌រមែងស្លាប់ ... ខយធម៌ ( របស់សម្រាប់អស់ទៅ ) ជាធម្មតារមែងអស់ទៅ... នស្សនធម៌ ( របស់សម្រាប់វិនាស ) ជាធម្មតារមែងវិនាសទៅ បុថុជ្ជននោះមិនពិចារណាក្នុងនស្សនធម៌ដែលវិនាសទៅថា នស្សនធម៌មិនមែនវិនាសទៅ ចំពោះលើអាត្មាអញតែម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតនិងសេចក្តីកើតឡើងរបស់សត្វទាំងឡាយមាននៅត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមណោះ កាលបើនស្សនធម៌វិនាសទៅហើយ អាត្មាអញគប្បីសោក សង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានកត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារមិនប្រព្រឹត្តទៅបានផង ទាំងពួកជនជាសត្រូវក៏មានចិត្តត្រេកអរផង ពួកមិត្តសម្លាញ់ក៏តូចចិត្តផង ។ កាលបើនស្សនធម៌វិនាសទៅហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនបានស្តាប់ដែល

សរ គឺសោក លាបដោយថ្នាំពិសចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកជរាធម៌របស់អរិយសាវកអ្នកបានស្តាប់រមែងគ្រាំគ្រាទៅដែរ ប៉ុន្តែអរិយសាវកនោះ តែងពិចារណាឃើញក្នុងជរាធម៌ដែលគ្រាំគ្រាដូច្នេះថា ជរាធម៌រមែងមិនគ្រាំគ្រាទៅចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមកដំណើរទៅ សេចក្តីច្យុតសេចក្តីកើតឡើងរបស់សត្វទាំងឡាយមាននៅត្រឹមណា ជរាធម៌របស់សត្វទាំងអស់រមែងគ្រាំគ្រាទៅត្រឹមណោះ កាលបើជរាធម៌គ្រាំគ្រាទៅហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានកត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅបានផង ពួកជនជាសត្រូវមានចិត្តត្រេកអរផង ពួកមិត្តសម្លាញ់ ក៏តូចចិត្តផង ។ កាលបើជរាធម៌គ្រាំគ្រាទៅហើយ អរិយ-សាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេចឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរ គឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវកអ្នកបានស្តាប់ហើយ ដកហើយនូវសរ គឺសោកដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវកអ្នកមិនមានសរ គឺសោក រមែងញុំាងខ្លួនឯងឲ្យរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្យាធិធម៌របស់អរិយសាវក អ្នកបានស្តាប់

រមែងឈឺចាប់ ... មរណធម៌ រមែងស្លាប់ ... ខយធម៌រមែងអស់ទៅ ... នស្សនធម៌រមែងវិនាសទៅ អរិយសាវកនោះ ពិចារណាឃើញច្បាស់ក្នុង នស្សនធម៌ដែលវិនាសទៅហើយ ដូច្នេះថា នស្សនធម៌មិនវិនាសទៅចំពោះ លើអាត្មាអញតែម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុត សេចក្តីកើតឡើងនៃសត្វទាំងឡាយនៅមានត្រឹមណា នស្សនធម៌របស់សត្វទាំងអស់វិនាសទៅត្រឹមណោះ កាលបើនស្សនធម៌វិនាសទៅហើយ អាត្មាអញគប្បីសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានកត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅបានផង ពួកជនជាសត្រូវក៏ត្រេកអរផង ពួកមិត្តសម្លាញ់ក៏តូចចិត្តផង ។ កាលបើនស្សនធម៌វិនាសទៅហើយ អរិយ-សាវកនោះមិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់សេចក្តីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរ គឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវកអ្នកបានស្តាប់ ហើយដកនូវសរ គឺសោកដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវកអ្នកមិនមានសរ គឺសោក រមែងញុំាងខ្លួនឯងឲ្យរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ អលព្ភនីយដ្ឋាន ៥ យ៉ាងនេះឯង ជាហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបាន ( តាមប្រាថ្នា ) ។

ប្រយោជន៍ក្នុងលោកនេះ ទោះណាជាតិចតួច បុគ្គលមិនមែនបាន ព្រោះសេចក្ដីសោក ព្រោះសេចក្ដីខ្សឹកខ្សួលឡើយ ពួកជនជាសត្រូវឃើញជននោះកំពុងសោកសង្រេង ដល់នូវទុក្ខ ជាអ្នកមានចិត្តត្រេកអរ លុះណាតែបណ្ឌិតអ្នកឈ្វេងយល់ក្នុងការវិនិច្ឆ័យ នូវហេតុ និងផល ទើបមិនញាប់ញ័រក្នុងឧបទ្រពទាំង-ឡាយ ពួកជនជាសត្រូវឃើញមុខបណ្ឌិតនោះមិនប្រែប្រួល នៅដដែល ហើយខ្លួនឯងក៏ដល់នូវទុក្ខវិញ បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការណាៗ គប្បីព្យាយាមក្នុងទីនោះដោយប្រការនោះៗ គឺការនិយាយសរសើរក្ដី ការរាយមន្តក្ដី ការនិយាយជាសុភាសិតក្ដី បវេណី ( វង្សត្រកូល ) ក្ដី បើសិនជាបុគ្គលដឹងច្បាស់ថា ប្រយោជន៍នេះអាត្មាអញក្ដី បុគ្គលដទៃក្ដី មិនគប្បីបានទេ មិនសោកសៅ គប្បីអត់ធ្មត់ថា កម្មដ៏មាំ ( អាត្មាអញបានសន្សំទុកហើយ ) ឥឡូវនេះ អាត្មាអញធ្វើដូចម្ដេច ។

# អដ្ឋកថា

## ឋានសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ៨ ដូចតទៅនេះ បទថា **អលព្ភនីយានិ** បានដល់ ឋានៈណាមួយមិនគប្បីបាន គឺមិនអាចបាន ។ បទថា **ឋានានិ** គឺហេតុ ។ បទថា **ជរាធម្មំ មា ជីរិ** សេចក្ដីថា វត្ថុណារបស់ខ្ញុំ មានចាស់ជាសភាវៈ វត្ថុនោះ កុំចាស់ឡើយ ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **នច្ឆានេយ្យ** គឺមិនគាប់ចិត្ត ។ បទថា **អព្ពុហិ** គឺនាំចេញទៅ ។

បទថា **យតោ** គឺកាលណា ។ បទថា **អាបទាសុ** គឺក្នុងឧបទ្រវទាំងឡាយ ។ បទថា **ន វេធតិ** គឺមិនញាប់ញ័រ មិនសោយសោកដល់ ។ បទថា **អត្ថវិនិច្ឆយញ្ញូ** គឺជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យហេតុផល ។ បទថា **បុរាណំ** បានដល់ នៅតែចាស់នោះឯង ព្រោះមិនមានការផ្លាស់ប្ដូរ ។ បទថា **ជប្បេន** គឺដោយការសរសើរ ។ បទថា **មន្តេន** គឺដោយការរាយមន្តដែលមានអានុភាពច្រើន ។ បទថា **សុភាសិតេន** គឺដោយការពោលពាក្យសុភាសិត ។ បទថា **អនុប្បទានេន** បានដល់ ដោយការឲ្យទ្រព្យ ១០០ ឬ ១០០០ ។ បទថា **បវេណិយា វា** បានដល់ ដោយវង្សត្រកូល អធិប្បាយថា ដោយការពោលដល់បវេណីយ៉ាងនេះថា សេចក្ដីនេះ បវេណីរបស់អាត្មាអញ ប្រព្រឹត្តតមកហើយ វត្ថុនេះមិនប្រព្រឹត្តមកហើយ ដូច្នេះ ។ បទថា **យថា យថា យត្ថ លភេថ អត្ថំ** សេចក្ដីថា គប្បីបានប្រយោជន៍ មានការ

មិនចាស់ជាដើមនៃវត្ថុទាំងឡាយ ដែលមានការចាស់ជាធម្មតាជាដើមក្នុងទី ណាមួយ ដោយប្រការណាមួយ ព្រោះការសរសើរជាដើមនោះ ។ បទថា **តថា តថា តត្ថ បរក្កមេយ្យ** បានដល់ គប្បីធ្វើសេចក្តីព្យាយាមក្នុងទីនោះៗ ដោយប្រការនោះៗ ។ បទថា **កម្មំ ឧឡារំ** បានដល់ កម្មដែលញុំាងសត្វឲ្យ អន្ទោលក្នុងវដ្ដៈ ខ្ញុំធ្វើឲ្យមាំទាំសន្សំ ។ គួរពិចារណាយ៉ាងនេះ ឥឡូវនេះ ខ្ញុំនឹងធ្វើអ្វី ដូច្នេះហើយ ឈប់ស្ងៀម ។៙

**អដ្ឋកថា ឋានសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## កោសលសូត្រទី ៩

[ ៤៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់ អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះរាជាបសេនទិកោសល ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏ មានព្រះភាគ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ ក៏ក្នុងសម័យនោះ ព្រះនាង មល្លិកាទេវីទើបនឹងទិវង្គតទៅ ។ លំដាប់នោះ មានបុរសមួយនាក់ ចូលទៅ គាល់ព្រះរាជាបសេនទិកោសល លុះចូលទៅដល់ហើយ ក្រាបទូលជិតព្រះ កាណ៌នៃព្រះរាជាបសេនទិកោសលថា បពិត្រព្រះសម្មតិទេព ព្រះនាងមល្លិកា

ទៅវិទិវង្គតទៅហើយ ។ កាលរាជបុរសក្រាបទូលដូច្នេះហើយ ព្រះរាជាបសេនទិកោសល មានទុក្ខទោមនស្ស មានព្រះសុរេងឱនចុះ មានព្រះភក្ត្រជ្រប់ គង់សញ្ជប់សញ្ជឹងមិនមានបដិភាណ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះរាជាបសេនទិកោសល ទ្រង់មានទុក្ខទោមនស្ស មានព្រះសុរេងឱនចុះ មានព្រះភក្ត្រជ្រប់ សញ្ជប់សញ្ជឹងមិនមានបដិភាណហើយ បានត្រាស់នឹងព្រះរាជាបសេនទិកោសលយ៉ាងនេះថា បពិត្រមហារាជ អលព្ភនីយដ្ឋាន គឺហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោកមិនគប្បីបានតាមសេចក្តីប្រាថ្នានេះមាន ៥ យ៉ាង ។ ៥ យ៉ាងដូចម្តេចខ្លះ ។ ហេតុមិនគប្បីបានតាមសេចក្តីប្រាថ្នាថា ជរាធម៌កុំគ្រាំគ្រាឡើយដូច្នេះ ។បេ។

មិនមានបានព្រោះសោក ព្រោះខ្សឹកខ្សួលឡើយ ។បេ។ កម្មដ៏មាំ ( អាត្មាអញបានសន្សំទុកហើយ ) ឥឡូវនេះ អាត្មាអញធ្វើដូចម្តេចហ្ន៎ ។

# អដ្ឋកថា

## កោសលសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោសលសូត្រទី ៩ ដូចតទៅនេះ បទថា **ឧបកណ្ណកេ** ប្រែថា ទីជិតព្រះកាណ៌ ។ បទថា **ទុម្មនោ** ប្រែថា ទោមនស្ស

ក្នុងព្រះហឫទ័យ ។ បទថា **បត្តក្ខន្ធោ** ប្រែថា មានព្រះសុរង្គឱនចុះ ។ បទថា **បជ្ឈាយន្តោ** ប្រែថា ទ្រង់ពិចារណា ។ បទថា **អប្បដិភាណោ** ប្រែថា ទ្រង់គិតមិនចេញ ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។៚

**អដ្ឋកថាកោសលសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## នារទសូត្រទី ១០

[ ៥០ ] សម័យមួយ នារទៈដ៏មានអាយុ គង់នៅក្នុងកុក្កុដារាម ទៀបក្រុងបាតលិបុត្ត ។ ក៏សម័យនោះ ព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យនៃព្រះរាជាមុណ្ឌៈទិវង្គតទៅ ។ កាលព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យទិវង្គតទៅហើយ ទ្រង់មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងាររសោះ ទ្រង់ជាប់ព្រះហឫទ័យតែនឹងសរីរៈព្រះនាងភទ្ទាទេវីទាំងយប់ទាំងថ្ងៃ ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈទ្រង់ត្រាស់ហៅសោការក្ខមាត្យ ដែលគាប់ព្រះហឫទ័យមកថា ម្នាលសម្មាញ់ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរដាក់នូវសរីរៈនាងភទ្ទាទេវីទៅក្នុងស្នូកប្រេង

ជាវិការនៃដែកហើយ គ្របដោយស្នូកដែកដទៃទៀត ទុកឲ្យយើងគ្រាន់ឃើញសរីរៈនាងភទ្ទាទេវីយូរក្រែលបន្តិច ។ សោការក្ខាមាត្យ ជាទីគាប់ព្រះហឫទ័យទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយដាក់សរីរៈព្រះនាងភទ្ទាទេវីក្នុងស្នូកប្រេងជាវិការនៃដែកហើយ គ្របដោយស្នូកដែកដទៃទៀត ។ លំដាប់នោះ សោការក្ខាមាត្យជាទីស្រឡាញ់ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យនៃព្រះរាជាមុណ្ឌៈនេះ ទិវង្គតទៅហើយ កាលព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យទិវង្គតទៅហើយ ព្រះរាជានោះ មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងាររសោះ ទ្រង់ជ្រប់ទៅក្នុងសរីរៈព្រះនាងភទ្ទាទេវីទាំងយប់ទាំងថ្ងៃ ។ ព្រះរាជាមុណ្ឌៈចូលទៅជិតសមណព្រាហ្មណ៍ណាហ្ន៎ ហើយស្តាប់ធម៌របស់សមណព្រាហ្មណ៍ណា ទើបនឹងគប្បីលះបង់នូវសរ គឺសេចក្តីសោកចេញបាន ។ លំដាប់នោះ សោការក្ខាមាត្យជាទីគាប់ព្រះហឫទ័យ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះនារទៈដ៏មានអាយុនេះ គង់នៅក្នុងកុក្កុដារាម ទៀបក្រុងបាតលិបុត្ត ។ ព្រះនារទៈដ៏មានអាយុនោះ មានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅយ៉ាងនេះថា ជាបណ្ឌិត វាងវៃ ជាអ្នកប្រាជ្ញ បានស្តាប់ច្រើន មានវាចាដ៏វិចិត្រ មានបដិភាណល្អ មានវ័យចម្រើនផង ជាព្រះអរហន្តផង បើដូច្នោះ គួរតែព្រះរាជាមុណ្ឌៈចូលទៅរកព្រះនារទៈដ៏មានអាយុធ្វើដូចម្តេចហ្ន៎ ឲ្យព្រះរាជាមុណ្ឌៈទ្រង់ព្រះសណ្តាប់ធម៌ព្រះនារទៈដ៏មានអាយុ

ហើយ លះបង់នូវសរ គឺសោកចេញបាន ។ លំដាប់នោះ សោភារក្ខាមាត្យ ជាទីគាប់ព្រះហឫទ័យក៏ចូលគាល់ព្រះរាជាមុណ្ឌៈ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះរាជាមុណ្ឌៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ព្រះនារទៈដ៏មានអាយុនេះ គង់នៅក្នុងកុក្កុដារាម ទៀបក្រុងបាតលិបុត្ត ព្រះនារទៈដ៏មានអាយុនោះ មានកិត្តិសព្ទដ៏ពីរោះខ្ទរខ្ទាយទៅយ៉ាងនេះថា ជាបណ្ឌិត វាងវៃ ជាអ្នកប្រាជ្ញបានស្តាប់ច្រើន មានវាចាដ៏វិចិត្រ មានបដិភាណល្អ ហើយមានវ័យចម្រើនផង ជាព្រះអរហន្តផង បើព្រះសម្មតិទេពចូលទៅរក ព្រះនារទៈដ៏មានអាយុ ធ្វើដូចម្តេចហ្ន៎ ឲ្យព្រះសម្មតិទេពទ្រង់ព្រះសណ្តាប់ធម៌ព្រះនារទៈដ៏មានអាយុ ហើយលះបង់នូវសរ គឺសោកបាន ។ ម្នាលសម្លាញ់ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរទៅផ្ទៀងព្រះនារទៈដ៏មានអាយុចុះ ។ ដ្បិតថាបុគ្គលប្រាកដដូចជាយើង មិនសមបើនឹងចូលទៅរកសមណព្រាហ្មណ៍នៅក្នុងដែនដែលមិនទាន់បានផ្ទៀងជាមុនទេ ។ សោភារក្ខាមាត្យ ជាទីគាប់ព្រះហឫទ័យទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅរកព្រះនារទៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោភារក្ខាមាត្យ ជាទីគាប់ព្រះទ័យអង្គុយ ក្នុងទីដ៏សមគួរហើយ បានទូលព្រះនារទៈដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចម្រើន ព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យរបស់ព្រះរាជាមុណ្ឌៈនេះ ទិវង្គតទៅហើយ ។ កាលព្រះ

នាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះហឫទ័យ ទិវង្គតទៅហើយ ព្រះរាជានោះទ្រង់មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងារទ្រង់ជ្រប់ព្រះហឫទ័យតែក្នុងសរីរៈព្រះនាងភទ្ទាទេវីទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះនារទៈដ៏មានអាយុ មេត្តាសំដែងធម៌ដល់ព្រះរាជាមុណ្ឌៈឲ្យទាន ឲ្យព្រះរាជាមុណ្ឌៈ ទ្រង់ព្រះសណ្តាប់ធម៌នៃព្រះនារទៈដ៏មានអាយុហើយ លះបង់នូវសរ គឺសោកបាន ។ ម្នាលបុរសជាទីស្រឡាញ់ព្រះរាជាមុណ្ឌៈសម្គាល់កាលគួរ ដែលស្តេចមកក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ សោការក្ខមាត្យជាទីគាប់ព្រះហឫទ័យ ក្រោកចាកអាសនៈថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយធ្វើប្រទក្សិណ ចូលទៅគាល់ព្រះរាជាមុណ្ឌៈ លុះចូលទៅដល់ហើយ ក៏បានក្រាបទូលព្រះរាជាមុណ្ឌៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ព្រះនារទៈដ៏មានអាយុ បើកឱកាសថ្វាយហើយ ។ ព្រះសម្មតិទេពសម្គាល់កាលគួរនឹងស្តេចទៅឥឡូវនេះចុះ ។ ម្នាលសម្លាញ់ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរប្រើនាយសារថីឲ្យរៀបយានល្អៗ ។ សោកា-រក្ខមាត្យជាទីគាប់ព្រះហឫទ័យ ទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយប្រើនាយសារថីឲ្យរៀបយានល្អៗ ហើយក្រាបទូលព្រះរាជាមុណ្ឌៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព យានល្អៗ សម្រាប់ព្រះអង្គរៀបចំរួចស្រេចហើយ ។ ព្រះសម្មតិទេពសម្គាល់កាលគួរដែលព្រះអង្គ នឹងស្តេចទៅក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈស្តេចឡើង

គន់យានល្អៗ ចូលទៅឯកុក្កុដារាមដោយយានល្អៗ ដោយអានុភាពធំដើម្បីជួបព្រះនារទៈដ៏មានអាយុ ។ ទីដែលយានទៅបានត្រឹមណា ព្រះរាជាក៏ស្ដេចទៅដោយយានត្រឹមនោះ ហើយស្ដេចចុះអំពីយាន ទ្រង់ព្រះដំណើរដោយព្រះបាទ ចូលទៅអារាម ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈចូលទៅរកព្រះនារទៈដ៏មានអាយុ លុះស្ដេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ លុះព្រះរាជាមុណ្ឌៈគង់ក្នុងទីដ៏សមគួរហើយ ព្រះនារទៈដ៏មានអាយុថ្វាយព្រះពរយ៉ាងនេះថា ថ្វាយព្រះពរមហារាជ អលព្ភនីយដ្ឋាន គឺហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមប្រាថ្នានេះមាន ៥ យ៉ាង ។ ៥ យ៉ាងដូចម្ដេចខ្លះ ។ គឺហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមសេចក្ដីប្រាថ្នាថា ជរាធម៌កុំគ្រាំគ្រាឡើយ ព្យាធិធម៌ កុំឈឺចាប់ដូច្នេះឡើយ ... មរណធម៌កុំស្លាប់ដូច្នេះឡើយ ... ខយធម៌កុំអស់ទៅដូច្នេះឡើយ ... ហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្មណ៍ ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមសេចក្ដីប្រាថ្នាថា នស្សនធម៌ កុំវិនាសទៅដូច្នេះ ។ បពិត្រមហារាជ ជរាធម៌របស់បុថុជ្ជនអ្នកមិនបានស្ដាប់រមែងគ្រាំគ្រាទៅ បុថុជ្ជននោះមិនពិចារណាក្នុងជរាធម៌ដែលគ្រាំគ្រាទៅដូច្នេះថា ជរាធម៌មិនគ្រាំគ្រាចំពោះលើអាត្មាអញតែម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្ដីច្យុត សេចក្ដីកើតឡើងនៃសត្វទាំងឡាយ នៅមាន

ជរាបណា ជរាធម៌របស់សត្វទាំងឡាយទាំងអស់ រមែងគ្រាំគ្រាទៅជរាបនោះ កាលបើជរាធម៌គ្រាំគ្រាទៅហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនឃ្លានភត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅផង ពួកជនជាសត្រូវក៏មានចិត្តត្រេកអរផង មិត្តសម្លាញ់ក៏តូចចិត្តផង ដូច្នេះ ។ កាលបើជរាធម៌នោះគ្រាំគ្រាហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ នេះហៅថា បុថុជ្ជនអ្នកមិនបានស្តាប់ ត្រូវសរ គឺសោកដែលលាបដោយថ្នាំពិសចាក់ហើយ ញុំាងខ្លួនឯងឲ្យក្តៅក្រហាយ ។ បពិត្រមហារាជមួយទៀត ព្យាធិធម៌របស់បុថុជ្ជនអ្នកមិនបានស្តាប់ តែងឈឺចាប់ ... មរណធម៌រមែងស្លាប់ ... ខយធម៌រមែងអស់ទៅ ... នស្សនធម៌រមែងវិនាសទៅ បុថុជ្ជននោះ មិនពិចារណាក្នុងនស្សនធម៌ដែលវិនាសទៅហើយ ដូច្នេះថា នស្សនធម៌មិនវិនាសទៅចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុត សេចក្តីកើតឡើងរបស់សត្វទាំងឡាយនៅមានត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមនោះ កាលបើនស្សនធម៌វិនាសទៅហើយ អាត្មាអញក៏គប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនឃ្លានភត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅ

ផង ពួកជនជាសត្រូវមានចិត្តត្រេកអរផង មិត្តសម្លាញ់តូចចិត្តផង កាលបើនស្សនធម៌វិនាសទៅហើយ បុថុជ្ជននោះក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ នេះហៅថា បុថុជ្ជនមិនបានស្តាប់ ដែលសរ គឺសោក លាបដោយថ្នាំពិសចាក់ហើយ ញុំាងខ្លួនឯងឲ្យក្តៅក្រហាយ ។ បពិត្រមហារាជ ជរាធម៌របស់អរិយសាវក អ្នកបានស្តាប់ហើយ គ្រាំគ្រាទៅ អរិយសាវកនោះ ពិចារណាក្នុងជរាធម៌ ដែលគ្រាំគ្រាទៅហើយដូច្នេះថា ជរាធម៌មិនគ្រាំគ្រាទៅ ចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុត សេចក្តីកើតឡើងរបស់សត្វទាំងឡាយ នៅមានត្រឹមណា ជរាធម៌របស់សត្វទាំងអស់រមែងគ្រាំគ្រាទៅត្រឹមនោះ កាលបើជរាធម៌គ្រាំគ្រាហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញគប្បីមិនឃ្លានភត្តផង សម្បុរអាក្រក់គប្បីក៏ធ្លាក់ចុះក្នុងកាយផង ការងាររមិនប្រព្រឹត្តទៅផង ពួកជនជាសត្រូវមានចិត្តត្រេកអរផង ពួកមិត្តសម្លាញ់តូចចិត្តផង ។ កាលបើជរាធម៌គ្រាំគ្រាហើយ អរិយសាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរ គឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវកអ្នកបានស្តាប់ បានដកនូវសរ

គឺសោក ដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវកដែលមិនមានសរ គឺសោក រមែងញ៉ាំងខ្លួនឯងឲ្យរលត់ទុក្ខបាន ។ បពិត្រមហារាជ មួយទៀត ព្យាធិធម៌របស់អរិយសាវកអ្នកបានស្តាប់ហើយ រមែងឈឺចាប់ ... មរណធម៌រមែងស្លាប់ ... ខយធម៌រមែងអស់ទៅ ... នស្សនធម៌រមែងវិនាសទៅ អរិយសាវកនោះ ពិចារណាក្នុងនស្សនធម៌ដែលវិនាសទៅដូច្នេះថា នស្សនធម៌មិនវិនាសទៅ ចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុត សេចក្តីកើតឡើងនៃសត្វទាំងឡាយ នៅត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមនោះ កាលបើនស្សនធម៌វិនាសទៅហើយ អាត្មាអញសោតគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនឃ្លានកត្តផង សម្បុរអាក្រក់ក៏ធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅផង ពួកជនជាសត្រូវមានចិត្តត្រេកអរផង ពួកមិត្តសម្លាញ់ក៏តូចចិត្តផង ។ កាលបើនស្សនធម៌វិនាសទៅហើយ អរិយសាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ បុថុជ្ជនអ្នកមិនបានស្តាប់ដែលសរ គឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញ៉ាំងខ្លួនឲ្យក្តៅក្រហាយ នេះហៅថាអរិយសាវកអ្នកបានស្តាប់ បានដកនូវសរ គឺសោកដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវកមិនមានសរ គឺសោក រមែងញ៉ាំងខ្លួនឲ្យរលត់ទុក្ខបាន ។ បពិត្រ

មហារាជ អលព្ភនីយដ្ឋាន ៥ យ៉ាងនេះឯង ដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមប្រាថ្នា ។

ប្រយោជន៍ក្នុងលោកនេះ សូម្បីបន្តិចបន្តួច បុគ្គលមិនបានព្រោះ
សេចក្តីសោកខ្សឹកខ្សួលឡើយ ពួកជនជាសត្រូវឃើញបុគ្គលនុ៎ះ
កំពុងសោកសៅដល់នូវទុក្ខ ក៏មានចិត្តត្រេកអរ លុះណាតែ
បណ្ឌិតអ្នកឈ្លៀសយល់នូវហេតុផល ទើបមិនញាប់ញ័រក្នុងឧប-
ទ្រពទាំងឡាយ ពួកជនជាសត្រូវឃើញ ( ទឹក ) មុខបណ្ឌិត
នោះមិនប្រែប្រួលប្លែកអំពីដើម ក៏កើតទុក្ខវិញ បុគ្គលគប្បីបាន
ប្រយោជន៍ក្នុងទីណា ដោយប្រការណាៗ គប្បីព្យាយាមក្នុងទី
នោះៗ ដោយប្រការដូច្នោះៗ គឺការនិយាយសរសើរក្តី ការរាយ
មន្តក្តី ការនិយាយជាសុភាសិតក្តី ការផ្តល់ឲ្យក្តី បវេណីក្តី បើ
បុគ្គលដឹងថា ប្រយោជន៍នុ៎ះ អាត្មាអញក្តី អ្នកដទៃក្តី មិនគប្បី
បានតាមសេចក្តីប្រាថ្នាទេ ហើយមិនសោកសៅ គប្បីអត់ធ្មត់ថា
កម្មដ៏មាំ ( អាត្មាអញបានសន្សំទុកហើយ ) ឥឡូវនេះ អាត្មា
អញធ្វើដូចម្តេចហ្ន៎ ។

កាលព្រះនារទៈសម្តែងយ៉ាងនេះហើយ ព្រះរាជាមុណ្ឌៈបានទូលព្រះនារទៈដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះអ្វី ។ បពិត្រមហារាជ ធម្មបរិយាយនេះឈ្មោះថាសោកសល្លហរណៈ

គឺឧបាយជាគ្រឿងដកនូវសរ គឺសោក ។ បពិត្រព្រះករុណាមែនហើយ ហៅថា សោកសល្លហរណធម៌ បពិត្រព្រះករុណាមែនហើយ ហៅថា សោកសល្ល-ហរណធម៌ បពិត្រព្រះករុណា ខ្ញុំព្រះករុណាបានស្តាប់ធម្មបរិយាយនេះហើយ ក៏លះបង់នូវសរ គឺសោកបាន ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈ ត្រាស់ហៅសោការក្ខមាត្យ ជាទីគាប់ព្រះហឫទ័យថា ម្នាលសម្លាញ់ជាទីស្រឡាញ់ បើដូច្នោះ ចូរអ្នករំលាយសរីរៈនាងភទ្ទាទេវី ហើយកសាងព្រះស្តូប ដើម្បីបញ្ចុះធាតុនាងភទ្ទាទេវីនោះ ។ ចាប់ដើមតាំងពីថ្ងៃនេះទៅ យើងនឹងងូតទឹកផង ប្រោះព្រំផង បរិភោគភត្តផង ប្រកបការងារទាំងឡាយផង ។

**មុណ្ឌរាជវគ្គទី ៥ ចប់**

## ឧទ្ទាននៃមុណ្ឌៈរាជវគ្គនោះគឺ

ហេតុទាំងឡាយ ដែលបុគ្គលគប្បីបាននូវទ្រព្យ ១ សប្បុរសកើតក្នុងត្រកូល ១ ធម៌ទាំងឡាយជាទីប្រាថ្នា ១ បុគ្គលអ្នកឲ្យនូវរបស់ជាទីគាប់ចិត្ត តែងបានរបស់ជាទីគាប់ចិត្តវិញ ១ គំនរបុណ្យ ១ សម្បទា ១ ទ្រព្យ ១ ហេតុដែលបុគ្គលមិនគប្បីបានតាមប្រាថ្នា ១ ព្រះរាជាបសេនទិកោសល ព្រួយព្រះហឫទ័យ ១ នារទៈសម្តែងធម៌ ១ ។

**បឋមបណ្ណាសក ចប់**

# អដ្ឋកថា

## នារទសូត្រ

[ ៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនារទសូត្រទី ១០ ដូចតទៅនេះ បទថា **អជ្ឈោមុច្ឆិតោ** ប្រែថា ទ្រង់សន្លប់ស្មៀម គឺទ្រង់ប្រកបដោយការស្រឡាញ់ដ៏ខ្លាំងក្លា មានសភាពក្រឡុកចិត្ត រហូតកើតខ្យល់ ។ បទថា **មហាច្ចរាជានុភាវេន** មានអត្ថថា ទ្រង់មានមេទ័ព ១៨ នាក់ចោមរោមហើយ ដោយរាជានុភាពធំ ទ្រង់យាងទៅដោយឫទ្ធិដ៏ធំក្រៃលែង ។ សព្ទថា **តគ្ឃ** ជានិបាត ចុះក្នុងអត្ថថា ពិតដោយចំណែកមួយ ។ អធិប្បាយថា ជាគ្រឿងនាំចេញនូវសេចក្ដីសោក ដោយចំណែកមួយ ព្រះរាជាទ្រង់ស្ដាប់ឱវាទនោះហើយ ទ្រង់តាំងនៅក្នុងឱវាទនោះ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ដោយប្រពៃ ហើយបានជាអ្នកមានស្ថានសួគ៌ ជាទីទៅខាងមុខហើយ ដោយប្រការដូច្នេះ ៕

**អដ្ឋកថានារទសូត្រទី ១០ ចប់**

**មុណ្ឌរាជវគ្គទី ៥ ចប់**

**បឋមបណ្ណាសក ចប់**

# សុត្តន្តបិដក
# ទុតិយបណ្ណាសក

## នីវរណវគ្គទី ១

### អាវរណសូត្រទី ១

[ ៥១ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ ទទួលព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះ ភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ជាគ្រឿង ទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺកាមច្ឆន្ទៈ ជាគ្រឿងទប់ រាំង គ្របសង្កត់ នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ ព្យាបាទជាគ្រឿង ទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំង-ឡាយ ថីនមិទ្ធៈជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំង ថយ ១ ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចៈជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាជាគ្រឿងទប់ រាំង*

គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសោត មិនបានលះបង់ធម៌ ៥ នេះ ដែលជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុប ជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមិនមានកម្លាំង និងមានកម្លាំងថយ ដូច្នេះនុ៎ះ មិនជាហេតុជាទីតាំងឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹង ហូរចុះអំពីភ្នំ ប្រព្រឹត្តទៅកាន់ទីឆ្ងាយ មានខ្សែទឹកដ៏រហ័ស ហូរនាំយកទាំងសំណាត់ទៅ មានបុរសបើកមាត់ប្រឡាយសងខាងស្ទឹងនោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ខ្សែទឹកត្រង់កណ្តាលស្ទឹងនោះ នឹងហូររាចសាច ព្រាចទៅផ្សេងៗ មិនប្រព្រឹត្តទៅកាន់ទីឆ្ងាយបាន មានខ្សែទឹកមិនបានរហ័ស ទាំងមិនបានហូរនាំយកសំណាត់ទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានលះនូវធម៌ ៥ យ៉ាងនេះ ដែលជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុប ជាងមនុស្ស-ធម៌តទៅ ដោយប្រាជ្ញាមិនមានកម្លាំង និងមានកម្លាំងថយ ដូច្នេះនុ៎ះ ក៏មិនជា

ហេតុជាទីតាំង យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះភិក្ខុនោះ បាន លះបង់នូវធម៌ ៥ យ៉ាងនេះ ដែលជាគ្រឿងទប់ រារាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុប ជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមានកម្លាំង ដូច្នេះ នេះទើបជាហេតុជាទីតាំងបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹងហូរចុះអំពីភ្នំ ប្រព្រឹត្តទៅកាន់ទីឆ្ងាយ មានខ្សែទឹកដ៏រហ័ស ហូរនាំយកទាំងសំណាត់ទៅ មានបុរសទប់មាត់ប្រឡាយ សងខាងស្ទឹងនោះ កាលបើយ៉ាងនេះ ខ្សែទឹកត្រង់កណ្តាលស្ទឹងនោះ មិនបានហូររាចសាចព្រាចទៅផ្សេងៗ ល្មមប្រព្រឹត្តទៅកាន់ទីឆ្ងាយ ជាខ្សែទឹកដ៏រហ័ស ទាំងហូរនាំយកសំណាត់ទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសោតបាន លះបង់នូវធម៌ទាំង ៥ យ៉ាងនេះ ដែលជាគ្រឿងទប់ រារាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់ ដោយនូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុប ជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមានកម្លាំង ដូច្នេះ នេះក៏ជាហេតុជាទីតាំង យ៉ាងនោះដែរ ។

# អដ្ឋកថា
# ទុតិយបណ្ណាសក

## នីវរណវគ្គទី ១

### អាវរណសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាវរណសូត្រទី ១ នៃទុតិយបណ្ណាសក ដូចតទៅនេះ កិលេសទាំងឡាយ ឈ្មោះថា **អាវរណា** ព្រោះអំណាចរាំង ។ ឈ្មោះថា **នីវរណា** ព្រោះមានអំណាចរារាំង ។ បទថា **ចេតសោ អជ្ឈារុហា** ប្រែថា ដែលគ្របសង្កត់ចិត្ត កិលេស ឈ្មោះថា ធ្វើឲ្យបញ្ញាទុព្វលកម្លាំង ព្រោះធ្វើវិបស្សនាបញ្ញា និងមគ្គបញ្ញាឲ្យអស់កម្លាំង ដោយអត្ថថារារាំងមិនឲ្យកើតឡើង ។ មួយប្រការទៀត ឈ្មោះថា ធ្វើបញ្ញាឲ្យខ្សោយកម្លាំង ព្រោះបញ្ញា ដែលលាយឡំដោយកិលេសទាំងនេះកើតឡើង កិលេសទាំងនោះ ធ្វើបញ្ញានោះឲ្យខ្សោយកម្លាំង ដូច្នេះក៏មាន ។ បទថា **អពលាយ** សេចក្ដីថា ឈ្មោះថា ប្រាសចាកកម្លាំង ព្រោះត្រូវនីវរណៈ ៥ រួបរឹត ។ បទថា **ឧត្តរឹ វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ** សេចក្ដីថា នូវញាណទស្សនៈដ៏វិសេស ដែលអាចធ្វើនូវភាពជាព្រះអរិយៈឲ្យបានក្រៃលែងជាងមនុស្សធម៌ ពោល គឺកុសលកម្មបថ ១០ យ៉ាង ។

បទថា **ហារហារិនី** គឺអាចបន្សាត់វត្ថុដែលល្មមបន្សាត់ទៅបាន ។

បទថា **ឆន្តលមុខានិ** ប្រែថា មាត់អូរ ព្រោះជនទាំងឡាយ ហៅមាត់អូរទាំងនោះថា **ឆន្តលមុខានិ** ព្រោះគេយកនង្គ័លភ្ជួរ ភ្ជួរចូលទៅ ធ្វើឲ្យដូចជាស្នាមភ្ជួរ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ វិបស្សនាញាណ គប្បីឃើញដូចក្រសែទឹក វេលាដែលភិក្ខុលះបង់សំវរៈក្នុងទ្វារទាំង ៦ គប្បីឃើញដូចវេលាដែលមាត់អូរទាំងសងខាង វេលាដែលភិក្ខុត្រូវនីវរណៈ ៥ រួបរឹត គប្បីឃើញដូចវេលា ដែលគេបោះបង្គោលកណ្ដាលស្ទឹង ហើយធ្វើទំនប់រាំងដោយស្លឹកឈើស្ងួត ស្មៅ និងដីឥដ្ឋ ទឹកក៏បោកបក់បែកបាក់ទៅ ពេលដែលភិក្ខុមិនអាចកម្ចាត់អកុសលទាំងពួង ដោយវិបស្សនាញាណ ហើយសម្រេចដល់សាគរ គឺផ្លូវនៃព្រះនិព្វានបាន គប្បីជ្រាបដូចពេលដែលគេធ្វើទំនប់រាំងយ៉ាងនេះ ទឹកដែលខ្សោយកម្លាំង មិនអាចបក់នាំយកស្មៅ និងស្លឹកឈើស្ងួតជាដើមទៅដល់សមុទ្របាន ។ ក្នុងធម៌ចំណែក-ស គប្បីប្រកបសេចក្ដីចូលដោយផ្ទុយគ្នាតាមដែលពោលហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ៕ ០៙០

**អដ្ឋកថាអាវរណសូត្រទី ១ ចប់**

# សុត្តន្តបិដក

## កាសិសូត្រទី ២

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា គំនរអកុសល ( បើ ) ពោលឲ្យត្រូវគួរហៅថា នីវរណៈ ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ គំនរអកុសលទាំងអស់ ក៏គឺនីវរណៈទាំង ៥ យ៉ាងនេះ ។ នីវរណៈ ៥ តើដូចម្តេច ។ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា គំនរអកុសល ( បើ ) ពោលឲ្យត្រូវគួរហៅថា នីវរណៈ ៥ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ គំនរអកុសលទាំងអស់ ក៏គឺនីវរណៈ ៥ យ៉ាងនេះ ។

# អដ្ឋកថា

## កាសិសូត្រ

[ ៥២ ] ក្នុងកាសិសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាកាសិសូត្រទី ២ ចប់

# សុត្តន្តបិដក

## អង្គសូត្រទី ៣

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្តីព្យាយាមនេះមាន ៥ យ៉ាង ។ អង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿញាណជាគ្រឿងត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ជាព្រះពុទ្ធ ល្អែងវិលមកកាន់ភពថ្មីទៀត ១ ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើងសម្រាប់ដុតកម្តៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរនឹងធ្វើព្យាយាមបាន ១ ជាអ្នកមិនអួតអាង មិនមានមាយាជាអ្នកធ្វើខ្លួនឲ្យប្រាកដតាមពិតក្នុងសម្នាក់គ្រូ និងពួកសព្រហ្មចារីជាវិញ្ញូជន ១ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ ធ្វើកុសលធម៌ឲ្យសម្រេច មានកម្លាំងប្រឹងសង្វាត មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ ១ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា អាចកំណត់នូវការកើត និងការរលត់ដ៏ប្រសើរជាគ្រឿងទម្លុះទម្លាយ ( កិលេស ) អាចកំណត់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃបាន ១ ។ ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្តីព្យាយាមមាន ៥ នេះឯង ។

# អដ្ឋកថា

## អង្គសូត្រ

[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអង្គសូត្រទី ៣ ដូចតទៅនេះ ក្នុងបទថា **បធានិយង្គានិ** ការៈ គឺការតាំងសេចក្តីព្យាយាម លោកហៅថា **បធាន** សេចក្តីព្យាយាមរបស់ភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា ជាអ្នកមានសេចក្តីព្យាយាម អង្គរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម ព្រោះហេតុនោះ ឈ្មោះថា **បធានិយង្គ**។

បទថា **សទ្ធោ** ប្រែថា ជាអ្នកប្រកបដោយសទ្ធា ។ សទ្ធានោះមាន ៤ យ៉ាង គឺអាគមសទ្ធា ១ អធិគមសទ្ធា ១ ឱកប្បនសទ្ធា ១ បសាទសទ្ធា ១ បណ្តាសទ្ធាទាំង ៤ នោះ សទ្ធារបស់ព្រះសព្វញ្ញូពោធិសត្វ ឈ្មោះថា អាគមសទ្ធា ព្រោះមានមកតាំងអំពីការបំពេញបារមី ដែលឈ្មោះថា អធិគម-សទ្ធា ព្រោះសម្រេចដោយការចាក់ធ្លុះ របស់ព្រះអរិយសាវកទាំងឡាយ ។ ការជឿដ៏មាំទាំ ព្រោះមិនញាប់ញ័រ កាលពោលថា **ពុទ្ធោ ធម្មោ សង្ឃោ** ដូច្នេះ ឈ្មោះថា **ឱកប្បនសទ្ធា** ការកើតឡើងនៃការជ្រះថ្លា ឈ្មោះថា **បសាទ-សទ្ធា** ក្នុងព្រះសូត្រនេះ លោកបំណងយកឱកប្បនសទ្ធា ។ បទថា **ពោធឹ** បានដល់ មគ្គញាណ ៤ ភិក្ខុរមែងជឿថា មគ្គញាណ ៤ នោះ ដែលព្រះ-តថាគតទ្រង់ចាក់ធ្លុះដោយល្អហើយ ។ ពាក្យនោះត្រឹមតែជាមាតិកានៃទេសនាប៉ុណ្ណោះ ។ សទ្ធាក្នុងរតនៈទាំង ៣ លោកបំណងយកដោយអង្គនេះ ព្រោះភិក្ខុណាមានសេចក្តីជ្រះថ្លា មានកម្លាំងខ្លាំងក្នុងព្រះពុទ្ធជាដើម សេចក្តីព្យាយាម

គឺបធាន រមែងសម្រេចដល់ភិក្ខុនោះ ។

បទថា **អប្បាពាធោ** គឺមិនមានរោគ ។ បទថា **អប្បាតង្កោ** គឺមិនមានទុក្ខ ។ បទថា **សមវេបាកិនិយា** ប្រែថា មានការរំលួយស្មើ ។ បទថា **គហាណិយា** ប្រែថា ដែលភ្លើងធាតុកើតអំពីកម្ម ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** សេចក្តីថា ពិតហើយ ភិក្ខុមានភ្លើងធាតុត្រជាក់ពេក រមែងខ្លាចរងា មានភ្លើងធាតុក្តៅពេក រមែងខ្លាចក្តៅ សេចក្តីព្យាយាមរមែងមិនសម្រេចផលដល់ភិក្ខុទាំងនោះ តែរមែងសម្រេចផលដល់ភិក្ខុ ដែលមានភ្លើងធាតុល្មមប្រមាណ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ល្មមប្រមាណសមគួរដល់សេចក្តីព្យាយាម ។ បទថា **យថាភូតំ អត្តានំ អាវិកត្តា** គឺប្រកាសគុណរបស់ខ្លួនតាមសេចក្តីពិត ។ បទថា **ឧទយត្ថគាមិនិយា** គឺដែលអាចដល់ គឺកំណត់ដឹងការកើត និងការរលត់ ព្រះមានព្រះភាគត្រាស់ឧទយព្វយញ្ញាណដែលកំណត់ដឹងលក្ខណៈ ៥០ ប្រការ ដោយបទនេះ ។ បទថា **អរិយាយ** គឺបរិសុទ្ធ ។ បទថា **និព្វេធិកាយ** គឺដែលអាចទម្លាយនូវគំនរកិលេស មានគំនរលោភៈជាដើម ដែលបុគ្គលមិនធ្លាប់ទម្លាយ ។ បទថា **សម្មាទុក្ខក្ខយគាមិនិយា** គឺដែលឲ្យដល់នូវការអស់ទុក្ខដែលអស់ទៅ ព្រោះកិលេសទាំងឡាយបានដោយអំណាចតទង្គប្បហាន ។ ដោយបទទាំងអស់នេះ ព្រះមានព្រះភាគត្រាស់ចំពោះវិបស្សនាបញ្ញាប៉ុណ្ណោះ ដោយប្រការដូច្នេះ ព្រោះសេចក្តីព្យាយាមរមែងមិនសម្រេចផលដល់អ្នកដែលមានបញ្ញាថោកថយ ៕

**អដ្ឋកថា អង្គសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សមយសូត្រទី ៨

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ អសម័យ ( សម័យមិនគួរ ) ៥ យ៉ាង នេះដើម្បីព្យាយាម ។ អសម័យ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្រាំគ្រា ត្រូវជរាគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ១ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ជាអ្នកមានព្យាធិ ត្រូវព្យាធិគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ២ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្រុកអំណត់អត់បាយ មានស្រូវមិនល្អ រកបិណ្ឌបាតបានដោយក្រ មិនងាយបុគ្គលព្យាយាមស្វែងរក អាហារបានឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ៣ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ( ស្រុក ) មានភ័យ មានការរំភើបកក្រើក ក្នុងដងព្រៃ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយាន ហើយបរទៅ ម្នាល ភិក្ខុទាំងឡាយ នេះជាអសម័យទី ៤ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃបែកគ្នា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការជេរគ្នានិងគ្នាក៏រមែងមាន ការប្រទេចគ្នានិងគ្នាក៏រមែងមាន ការនិយាយ បោះបោកគ្នានិងគ្នាក៏រមែងមាន ការបោះបង់ចោលគ្នានិងគ្នាក៏រមែងមាន ពួក ជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃនោះឯង ក៏នៅតែមិនជ្រះថ្លា ពួកជនខ្លះដែល ជ្រះថ្លាហើយ ក៏បែរចិត្តផ្សេងទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ៥ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ យ៉ាងនេះឯង ជាអសម័យ

ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ អសម័យ ( សម័យមិនគួរ ) ៥ យ៉ាងនេះឯង ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ សម័យ ៥ យ៉ាងនេះ ដើម្បីព្យាយាម ។ សម័យ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះនៅក្មេងកំលោះ ពេញកម្លាំង មានសក់ខ្មៅ ប្រកបដោយវ័យកំពុងចម្រើន គឺវ័យជាបឋម ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ១ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើង ជាគ្រឿងដុតកម្តៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដើម្បីព្យាយាមបាន ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ២ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្រុកសម្បូរភិក្ខា មានស្រូវល្អ រកបិណ្ឌបាតបានងាយ បុគ្គលងាយព្យាយាមស្វែងរកអាហារបាន ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៣ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកមនុស្សព្រមព្រៀងគ្នា រួសរាយរកគ្នា មិនវិវាទគ្នា រលាយចូលគ្នា ដូចទឹកដោះលាយនឹងទឹក សម្លឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៤ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃព្រមព្រៀងគ្នា រួសរាយរកគ្នា មិនវិវាទគ្នា មានបាលីសម្រាប់សម្តែងឡើងតែមួយ នៅជាសុខសប្បាយ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការជេរគ្នានិងគ្នាក៏មិនមាន ការប្រទេចគ្នានិងគ្នាក៏មិនមាន ការស្រដីបោះបោករកគ្នានិង

គ្នាក៏មិនមាន ការលះបង់ចោលគ្នានិងគ្នាក៏មិនមាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃនោះ ក៏ជ្រះថ្លាឡើយ ពួកជនដែលជ្រះថ្លាហើយ ក៏រឹតតែជ្រះថ្លាក្រៃពេក ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៥ គួរប្រព្រឹត្តដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ យ៉ាងនេះឯង ជាសម័យគួរប្រព្រឹត្តដើម្បីព្យាយាម ។

# អដ្ឋកថា

## សមយសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមយសូត្រទី ៤ ដូចតទៅនេះ បទថា **បធានាយ** គឺដើម្បីជាប្រយោជន៍ដល់ការធ្វើសេចក្តី ព្យាយាម ។ បទថា **ន សុករំ ឧញ្ឆេន បគ្គហេន យាបេតុំ** សេចក្តីថា ភិក្ខុទាំងឡាយមិនអាចញ៉ាំងជីវិតនៅបាន ដោយការឱបបាត្រត្រាច់សូមទៅមក ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វដ្ដៈផង វិវដ្ដៈផង ។

**អដ្ឋកថាសមយសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## មាតុបុត្តិកសូត្រទី ៥

[ ៥៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ជនពីរនាក់ គឺភិក្ខុ ១ ភិក្ខុនី ១ ជាមាតា និងបុត្រ បានចូលទៅនៅចាំវស្សាទៀបក្រុងសាវត្ថី ។ ជនទាំងពីរនោះ ជាអ្នកប្រាថ្នាឲ្យឃើញគ្នានិងគ្នាជារឿយៗ គឺមាតាក៏ជាអ្នកប្រាថ្នាឲ្យឃើញបុត្ររឿយៗ ចំណែកបុត្រក៏ជាអ្នកប្រាថ្នាឲ្យឃើញមាតារឿយៗ ។ ការនៅប្រឡូកប្រឡំកើតមាន ព្រោះជនទាំងនោះបានឃើញគ្នារឿយៗ កាលបើការនៅប្រឡូកប្រឡំមានហើយ សេចក្តីស្និទ្ធស្នាលក៏កើតមាន កាលបើមានសេចក្តីស្និទ្ធស្នាលហើយ សេចក្តីស៊ប់ចិត្តក៏កើតមាន ។ ជនទាំងពីរនោះ លុះមានចិត្តចុះស៊ប់រកគ្នាហើយ ក៏មិនបានលាសិក្ខា មិនបានធ្វើឲ្យជាក់ច្បាស់ នូវភាពនៃខ្លួនមានកម្លាំងថយ ស្រាប់តែសេពនូវមេថុនធម្ម ។ គ្រានោះ មានភិក្ខុច្រើនរូប បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស មានជនពីរនាក់ គឺភិក្ខុ ១ ភិក្ខុនី ១ ជាមាតា និងបុត្រ បានចូលមកនៅចាំវស្សាក្នុងក្រុងសាវត្ថីនេះ ។ ជនទាំងពីរនោះជាអ្នកប្រាថ្នាឲ្យឃើញគ្នានិងគ្នាជារឿយៗ គឺមាតាក៏ជាអ្នកប្រាថ្នាឲ្យឃើញបុត្ររឿយៗ ចំណែកបុត្រក៏ជាអ្នកប្រាថ្នាឲ្យឃើញមាតារឿយៗ ។ ការ

នៅប្រឡូកប្រឡំគ្នាកើតមាន ក៏ព្រោះជនទាំងពីរនោះ បានឃើញគ្នារឿយៗ កាលបើមានការនៅប្រឡូកប្រឡំហើយ សេចក្ដីស្និទ្ធស្នាលក៏កើតមាន កាលបើមានសេចក្ដីស្និទ្ធស្នាលហើយ សេចក្ដីស៊ប់ចិត្តក៏កើតមាន ។ ជនទាំងពីរនោះ លុះមានចិត្តចុះស៊ប់រកគ្នាហើយ ក៏មិនបានលាសិក្ខា មិនបានធ្វើឲ្យជាក់ច្បាស់ នូវភាពនៃខ្លួនមានកម្លាំងថយ ស្រាប់តែសេពមេថុនធម្ម ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មោឃបុរសនោះ ដឹងដែរឬមិនដឹងទេថា មាតារមែងត្រេកអរក្នុងបុត្រ ឬថាបុត្រក៏រមែងត្រេកអរក្នុងមាតា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណារកមិនឃើញនូវរូបដទៃ សូម្បីតែរូបមួយដែលជាទីតាំងនៃតម្រេកយ៉ាងនេះ ជាទីតាំងនៃសេចក្ដីប្រាថ្នាយ៉ាងនេះ ជាទីតាំងនៃសេចក្ដីស្រវឹងយ៉ាងនេះ ជាទីតាំងនៃចំណងយ៉ាងនេះ ជាទីតាំងនៃសេចក្ដីជ្រប់នៅយ៉ាងនេះ នឹងធ្វើឲ្យអន្តរាយដល់ការបានសេចក្ដីក្សេមចាកយោគៈដ៏ប្រសើរលើសយ៉ាងនេះ ដូចជារូបស្រីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វត្រេកអរជាប់ជំពាក់ សញ្ជប់ជ្រប់ស៊ប់នៅក្នុងរូបស្រីហើយ សត្វពួកនោះឈ្មោះថា លុះក្នុងអំណាចនៃរូបស្រី រមែងសោកស្ដាយអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញនូវសំឡេងដទៃ សូម្បីតែសំឡេងមួយ ... នូវក្លិនដទៃ សូម្បីតែក្លិនមួយ ... នូវរសដទៃ សូម្បីតែរសមួយ ... នូវផស្សដទៃ សូម្បីតែផស្សមួយ ដែលជាទីតាំងនៃតម្រេកយ៉ាងនេះ ជាទីតាំងនៃសេចក្ដីប្រាថ្នាយ៉ាងនេះ ជាទីតាំងនៃសេចក្ដីស្រវឹងយ៉ាងនេះ ជាទីតាំងនៃចំណង

យ៉ាងនេះ ជាទីតាំងនៃសេចក្ដីជ្រប់នៅយ៉ាងនេះ នឹងធ្វើឲ្យអន្តរាយដល់ការបាន សេចក្ដីក្សេមចាកយោគៈដ៏ប្រសើរលើសយ៉ាងនេះ ដូចជាផ្សព្វនៃស្រីនេះទេ ។ ម្នាលភិក្ខុទាំងឡាយ សត្វត្រេកអរ ជាប់ជំពាក់ សញ្ជប់ជ្រប់ស៊ប់នៅក្នុងផ្សព្វនៃស្រីហើយ សត្វពួកនោះ ឈ្មោះថា លុះក្នុងអំណាចនៃផ្សព្វស្រី រមែងសោកស្ដាយអស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ស្រីទោះកំពុងដើរក្ដី ក៏រមែងគ្របសង្កត់ចិត្តបុរសបាន ទោះឈរក្ដី អង្គុយក្ដី ដេកក្ដី ក្រាបចុះក្ដី ការនិយាយក្ដី ច្រៀងក្ដី យំក្ដី ហើមប៉ោងក្ដី ស្លាប់ក្ដី ក៏រមែងគ្របសង្កត់នូវចិត្តនៃបុរសបាន ។ ម្នាលភិក្ខុទាំងឡាយ តាមពិតថា បុគ្គលកាលបើហៅមាតុគ្រាមនោះឲ្យត្រូវ គួរហៅថាជាអន្ទាក់ ( សម្រាប់ទាក់ ) ដោយជុំវិញរបស់មារ ដូច្នេះ បុគ្គលកាលបើហៅមាតុគ្រាមឲ្យត្រូវ គួរហៅថាជាអន្ទាក់ដោយជុំវិញរបស់មារ ដូច្នេះ ។

> បុគ្គលចរចាជាមួយនឹងជន ដែលមានដាវក្នុងដៃក្ដី ចរចាជាមួយ
> នឹងបិសាចក្ដី ប៉ះពាល់នឹងអាសិរពិស ហើយត្រូវអាសិរពិស
> ចឹកស្លាប់ក្ដី ( ប្រសើរជាង ) មិនគួរចរចាជាមួយនឹងមាតុ-
> គ្រាម តែមួយនឹងមួយឡើយ ។ ពួកមាតុគ្រាមនោះ រមែងចង
> បុរសដែលភ្លេចស្មារតី ដោយការសម្លឹងមើលផង ដោយកិរិយា
> ញញឹមផង មួយយ៉ាងទៀត ដោយការស្លៀកមិនស្រួលផង
> ដោយសម្ដីដ៏ពីរោះផង ជន គឺមាតុគ្រាមនុ៎ះ មិនមែនបៀតបៀន

បុរសតែ ( ត្រឹមរស់នៅ ) ប៉ុណ្ណោះទេ ទោះបីហើមប៉ោង ឬស្លាប់ហើយ ក៏ ( គង់នៅតែបៀតបៀនដែរ ) ។ កាមគុណទាំង ៥ នុ៎ះ គឺរូប សំឡេង ក្លិន រស ផស្សៈ ដែលជាតម្រេកនៃចិត្ត រមែងប្រាកដក្នុងរូបនៃស្ត្រី ។ កាលបុរសទាំងនោះ ដែលជំនន់គឺកាមក្ដួចនាំទៅ មិនបានកំណត់ដឹងនូវកាមទាំងឡាយ រមែងធ្វើនូវគតិ និងការកើតរឿយៗ អស់វដ្តកាលក្នុងសង្សារវដ្ត ទៅខាងមុខ ។ លុះតែបុរសទាំងឡាយណា កំណត់ដឹងនូវកាមទាំងឡាយបាន ទើបបុរសនោះ មិនមានភ័យអំពីទីណាឡើយ ឬបុរសទាំងឡាយណា បានដល់នូវការអស់ទៅ នៃអាសវៈក្នុងលោកហើយ បុរសទាំងនោះទើបឈ្មោះថា បានដល់នូវត្រើយ គឺព្រះនិព្វាន ។

# អដ្ឋកថា

## មាតុបុត្តិកសូត្រ

[ ៥៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមាតុបុត្តិកសូត្រទី ៥ ដូចតទៅនេះ បទថា **បរិយាទាយ តិដ្ឋតិ** សេចក្ដីថា រមែងគ្របសង្កត់ គឺទាញយក បានដល់ គប្បីឲ្យញាប់ញ័រទៅ តាំងនៅ ។ បទថា **ឧគ្ឃាតិតា** បានដល់ ប៉ោងឡើង ។ បទថា **អសិហត្ថេន** សេចក្ដីថា សូម្បីបុគ្គលកាន់ដាវមកបំណាំងនឹង

នឹងកាត់ក្បាល ។ បទថា **បិសាចេន** សេចក្តីថា សូម្បីយក្សដែលមកបំណាងនឹងស៊ី ។ បទថា **អាសជ្ជ** ប្រែថា គប្បីពាល់ត្រូវ ។ បទថា **មញ្ជុនា** ប្រែថា ដែលទន់ភ្លន់ ។ បទថា **កាមោឃវុឡ្ហានំ** គឺដែលឱឃៈ គឺដែលកាមោឃៈបក់ផាត់ឲ្យទៅ រុញច្រានទៅ ។ បទថា **កាលំ គតឹ ភវាភវំ** គឺដែលគតិ និងការមានរឿយៗ អស់កាលនៃវដ្ដៈ ។ បទថា **បុរក្ខតា** គឺដែលត្រាច់ទៅខាងមុខ បានដល់ ធ្វើទុកខាងមុខ ។ បទថា **យេ ច កាមេ បរិញ្ញាយ** សេចក្តីថា ជនទាំងឡាយណាដែលជាបណ្ឌិតកំណត់ដឹងកាមទាំង ២ យ៉ាង ដោយបរិញ្ញា ៣ ។ បទថា **ចរន្តិ អកុតោភយា** សេចក្តីថា ឈ្មោះថា ការមានភ័យអំពីទីណា មិនមានដល់ព្រះខីណាស្រពទាំងឡាយ ព្រោះដូច្នោះ ទើបព្រះខីណាស្រពទាំងនោះ មិនមានភ័យអំពីទីណា ត្រាច់ទៅ ។ បទថា **ពារគតា** សេចក្តីថា និព្វាន លោកហៅថា ត្រើយ ។ អធិប្បាយថា ចូលដល់និព្វាននោះ គឺធ្វើឲ្យជាក់ច្បាស់ ហើយតាំងនៅ ។ បទថា **អាសវក្ខយំ** បានដល់ អរហត្ត ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វដ្ដៈប៉ុណ្ណោះ ក្នុងគាថាទាំងឡាយ ត្រាស់វដ្ដៈផង វិវដ្ដៈផង ៕

## អដ្ឋកថា មាតុបុត្តិកសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ឧបជ្ឈាយសូត្រទី ៦

[ ៥៦ ] គ្រានោះឯង មានភិក្ខុមួយរូប បានចូលទៅរកឧបជ្ឈាយ៍របស់ខ្លួន លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងឧបជ្ឈាយ៍របស់ខ្លួនថា បពិត្រព្រះថេរៈដ៏ចម្រើន ឥឡូវនេះ កាយរបស់ខ្ញុំមានសភាពធ្ងន់ ទាំងទិសក៏មិនប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈ ទាំងសេចក្ដីអផ្សុក សេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយក៏មានដល់ខ្ញុំ ។ លំដាប់នោះឯង ភិក្ខុនោះ បាននាំភិក្ខុជាសទ្ធិវិហារិកនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ឥឡូវនេះកាយរបស់ខ្ញុំមានសភាពធ្ងន់ ទាំងទិសក៏មិនប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្ដីអផ្សុក សេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មានដល់ខ្ញុំ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ហេតុនុ៎ះរមែងមានយ៉ាងហ្នឹងឯង ។ កាលបើភិក្ខុមិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណក្នុងភោជន មិនបានប្រកបរឿយៗនូវការភ្ញាក់រឭក មិនពិចារណាភាវរកនូវពួកធម៌ជាកុសល អស់រាត្រីខាងដើម និងរាត្រីខាងចុង មិនបានប្រឹងប្រកបព្យាយាម ចម្រើននូវធម៌ទាំងឡាយ ជា

ចំណែកនៃពោធិញ្ញាណ កាយរបស់ភិក្ខុនោះ រមែងមានសភាពធូន់ ទាំងទិស ក៏មិនបានប្រាកដដល់ភិក្ខុនោះ ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ភិក្ខុនោះ ថីនមិទ្ធៈក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ភិក្ខុនោះ រមែងប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្តីអផ្សុក សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មានដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ ព្រោះហេតុនោះ អ្នកត្រូវសិក្សាក្នុងសាសនានេះ យ៉ាងនេះថា អាត្មាអញនឹងជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭក ពិចារណាភាវក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើម និងរាត្រីខាងចុង ប្រឹងប្រកបការព្យាយាម ចម្រើននូវធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ ។ ម្នាលភិក្ខុ អ្នកត្រូវសិក្សាយ៉ាងនេះឯង ។ លំដាប់នោះ ភិក្ខុនោះ លុះព្រះដ៏មានព្រះភាគទ្រង់ទូន្មាន ដោយឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចធ្វើប្រទក្សិណាចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះគេចចេញទៅតែម្នាក់ឯង ជាអ្នកមិនធ្វេសប្រហែស មានព្យាយាមដុតបំផ្លាញនូវកិលេស មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ពួកកុលបុត្រចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏បានធ្វើឲ្យជាក់ច្បាស់ បានដល់នូវគុណវិសេសដ៏លើសលុបនោះ ជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន អស់កាលមិនយូរ ហើយបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ

មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏ជាព្រះអរហន្តមួយអង្គដែរ ។ លុះភិក្ខុនោះបានសម្រេចអរហត្តហើយ ក៏ចូលទៅរកឧបជ្ឈាយ៍របស់ខ្លួន លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងឧបជ្ឈាយ៍របស់ខ្លួន យ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចម្រើន ឥឡូវនេះ កាយរបស់ខ្ញុំលែងធ្ងន់ហើយ ទិសទាំងឡាយក៏ប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈ ក៏លែងគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈ ដោយសេចក្តីត្រេកអរ សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយក៏មិនមានដល់ខ្ញុំឡើយ ។ លំដាប់នោះឯង ភិក្ខុនោះ បាននាំភិក្ខុជាសទ្ធិវិហារិកនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបាននិយាយយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចម្រើន ឥឡូវនេះកាយរបស់ខ្ញុំលែងធ្ងន់ហើយ ទិសទាំងឡាយក៏ប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈ ក៏លែងគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មិនមានដល់ខ្ញុំ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ហេតុនុ៎ះ រមែងមានយ៉ាងហ្នឹងឯង ។ កាលបើភិក្ខុបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭក ពិចារណាភាវរកនូវពួកធម៌ជាកុសល អស់

*រាត្រីខាងដើម និងរាត្រីខាងចុង ប្រឹងប្រែប្រកបការព្យាយាម ចម្រើនធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ កាយរបស់ភិក្ខុនោះ រមែងមិនធ្ងន់ ទិសទាំងឡាយ ក៏ប្រាកដដល់ភិក្ខុនោះ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ភិក្ខុនោះ ថីនមិទ្ធៈក៏មិនគ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ភិក្ខុនោះ ប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ ទាំងសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មិនមានដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវសិក្សាក្នុងសាសនានេះ យ៉ាងនេះថា ពួកយើងនឹងជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭកពិចារណាភាវរក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើម និងរាត្រីខាងចុង ប្រឹងប្រែប្រកបការព្យាយាម ចម្រើនធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។*

# អដ្ឋកថា

## ឧបជ្ឈាយសូត្រ

*[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបជ្ឈាយសូត្រទី ៦ ដូចតទៅនេះ បទថា* **មធុរកជាតោ** *ប្រែថា មានការធ្ងន់កើតឡើង ។ បទថា* **ទិសា ច មេ ន បក្ខាយន្តិ** *សេចក្តីថា ភិក្ខុពោលថា ទិសធំ ៤ និងទិសតូច ៤ មិន*

ប្រាកដដល់ខ្ញុំ ។ បទថា **ធម្មា ច មំ ធប្បដិភន្តិ** សេចក្តីថា ធម៌ គឺសមថៈ និងវិបស្សនា ក៏មិនប្រាកដដល់ខ្ញុំ ។ បទថា **អនភិរតោ ច ព្រហ្មចរិយំ ចរាមិ** សេចក្តីថា ខ្ញុំជាអ្នកអផ្សុក ហើយនៅប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ឧបជ្ឈាយ៍ស្តាប់ពាក្យរបស់ភិក្ខុនោះហើយ គិតថា ភិក្ខុនេះជាពុទ្ធវេនេយ្យបុគ្គល ទើបចូលទៅក្រាបទូលហេតុការណ៍នោះ ដល់ព្រះមានព្រះភាគ ។ បទថា **អវិបស្សកស្ស កុសលានំ ធម្មានំ** សេចក្តីថា ជាអ្នកមិនឃើញច្បាស់នូវធម៌ដែលជាកុសល គឺមិនស្វះស្វែងរក ។ បទថា **ពោធិបក្ខិកានំ** បានដល់ ធម៌ ៣៧ មានសតិប្បដ្ឋានជាដើម ។ល។

**អដ្ឋកថា ឧបជ្ឈាយសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ឋានសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះ ស្រ្តីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ។ ស្ថាន ៥ យ៉ាង តើដូចម្តេច ។ ស្រ្តីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ១ ។ ស្រ្តីក្តី បុរសក្តី គ្រហស្ថក្តី

បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លង ព្យាធិទៅបានឡើយ ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ ទៅបានឡើយ ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណា រឿយៗ ថា អាត្មាអញតែងមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វ និង សង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្ម ជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក អាត្មាអញ នឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាទៅបាន តើព្រោះ អាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែង មានសេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន ដែលជាហេតុនាំឲ្យពួកសត្វប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើ បុគ្គលនោះ ពិចារណាស្ថាននោះរឿយៗ ហើយ ក៏លះបង់យោព្វនមទៈ ( សេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន ) ដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានជរាជាធម្មតា មិនកន្លង

ជរាទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន តើព្រោះអាស្រ័យអំណាចប្រ-យោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងភាពនៃខ្លួនជាអ្នកមិនមានរោគ ដែលជាហេតុនាំឲ្យពួកសត្វប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗ ហើយ គង់លះបង់អារោគ្យមទៈ ( សេចក្តីស្រវឹងក្នុងភាវៈនៃខ្លួនមិនមានរោគ ) ដោយសព្វគ្រប់ ឬតុំនោះសោត គង់ស្រាលស្តើងទៅបាន ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងជីវិត ដែលជាហេតុនាំឲ្យពួកសត្វប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលពិចារណានូវស្ថាននោះរឿយៗ ហើយ គង់លះបង់ជីវិតមទៈ ( សេចក្តីស្រវឹងក្នុងជីវិត ) ដោយសព្វគ្រប់ ឬតុំនោះសោត គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំង-

ឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញតែងមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានតម្រេកក្រៃលែងក្នុងសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្ត ដែលជាហេតុនាំឲ្យសត្វប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗ ហើយ គង់លះបង់ឆន្ទរាគ ( តម្រេកក្រៃលែង ) ក្នុងសត្វ និងសង្ខារដោយសព្វគ្រប់ ឬតុំនោះសោត គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ តើព្រោះអាស្រ័យអំណាចប្រ-

យោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានកាយទុច្ចរិត វចី-ទុច្ចរិត មនោទុច្ចរិត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗហើយ គង់លះបង់ទុច្ចរិតដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមត៌កមានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក អាត្មាអញនឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវកនោះតែងពិចារណាថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានជរាជាធម្មតា មិនកន្លងជរាទៅបាន ទោះបីពួកសត្វដែលមានការវង្វាត់មកវង្វាត់ទៅច្យុត និងកើតអម្បាលម៉ាន ពួកសត្វទាំងអស់ក៏តែងមានជរាជាធម្មតា មិនកន្លងជរាទៅបានដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះរឿយៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះ រមែងសេពចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយកិលេសទាំងឡាយ ក៏វិនាសទៅ ។ ( អរិយសាវកនោះពិចារណា ) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ទោះពួកសត្វដែលមាន

ការវេស្តាត់មក វេស្តាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ក៏មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះរឿយៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។ ( អរិយសាវកនោះពិចារណា ) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ទោះពួកសត្វដែលមានការវេស្តាត់មក វេស្តាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ក៏មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានដែរ កាលបើអរិយសាវកនោះពិចារណានូវស្ថាននោះរឿយៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះ រមែងសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។ ( អរិយសាវកនោះពិចារណា ) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្តីព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ទោះពួកសត្វដែលមានការវេស្តាត់មក វេស្តាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់មាន

សេចក្ដីព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួងដែរ កាលបើអរិយសាវកនោះពិចារណានូវស្ថាននោះរឿយៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះរមែងសេព ចម្រើន ធ្វើ រឿយៗ នូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាប សូន្យទៅ អនុសយកិលេសទាំងឡាយក៏វិនាសទៅ ។ ( អរិយសាវកនោះ ពិចារណា ) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក អាត្មាអញនឹងធ្វើកម្មណា ទោះល្អក្ដី អាក្រក់ក្ដី នឹងជាអ្នកទទួលយកនូវផល នៃកម្មនោះ ទោះពួកសត្វដែលមានការវង្គាត់មក វង្គាត់ទៅ ច្យុត កើតអម្បាល ម៉ាន ពួកសត្វទាំងអស់ក៏មានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជា កំណើត មានកម្មផៅពង្ស មានកម្មជាទីរឭក ពួកសត្វនឹងធ្វើកម្មណា ទោះ ល្អក្ដី អាក្រក់ក្ដី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះដែរ កាលបើអរិយ-សាវកនោះពិចារណា នូវស្ថាននោះរឿយៗ ហើយ លោកុត្តរមគ្គក៏កើតឡើង ព្រម ។ អរិយសាវកនោះរមែងសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គ នោះ ។ កាលបើអរិយសាវកនោះសេព ចម្រើន ធ្វើរឿយៗ នូវលោកុត្តរ-មគ្គនោះហើយ សញ្ញោជនៈទាំងឡាយក៏រមែងសាបសូន្យទៅ អនុសយកិ-លេសទាំងឡាយ ក៏វិនាសទៅ ។

ធម៌ទាំងឡាយ គឺព្យាធិធម៌ ជរាធម៌ និងមរណធម៌ មានទៅយ៉ាងណា ពួកបុថុជ្ជនជាសប្បុរសរមែងស្អប់ខ្ពើមយ៉ាងនោះ ។ កាលបើពួកសត្វមានសភាវៈយ៉ាងនេះហើយ តថាគតក៏គួរធុញទ្រាន់នឹងសភាវៈនុ៎ះដែរ ហេតុនុ៎ះមិនមានដល់តថាគត មានសភាពដ៏សមគួរ មានវិហារធម៌យ៉ាងនេះ ។ តថាគតនោះកាលបើនៅយ៉ាងនេះ ក៏ដឹងនូវធម៌ដែលប្រាសចាកឧបធិ បានឃើញបព្វជ្ជាថាជាការក្សេម គ្របសង្កត់នូវសេចក្ដីស្រវឹងទាំងពួង គឺស្រវឹងក្នុងភាវៈនៃខ្លួនជាបុគ្គលមិនមានរោគ ក្នុងវ័យ ក្នុងជីវិតបាន ។ សេចក្ដីព្យាយាមក៏កើតមានដល់តថាគតនោះ កាលដែលឃើញច្បាស់នូវព្រះនិព្វាន តថាគត មិនគួរដើម្បីសេពកាមទាំងឡាយបានវិញ ក្នុងកាលឥឡូវនេះទេ តថាគតនឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌តទៅ មិនបានត្រឡប់វិញឡើយ ។

# អដ្ឋកថា

## ឋានសូត្រ

[ ៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ៧ ដូចតទៅនេះ បទថា **ជរាធម្មោម្ហិ** ប្រែថា អាត្មាអញ ជាអ្នកមានការចាស់ជាធម្មតា ។ បទថា **ជរំ**

**អនតីតោ** សេចក្តីថា មិនកន្លងផុតនូវការចាស់ទៅបានឡើយ រមែងត្រាច់ទៅក្នុងការចាស់នោះឯង ។ ក្នុងបទដ៏សេសទាំងឡាយ ក៏មានន័យនេះដូចគ្នា ។ ក្នុងបទទាំងឡាយថា **កម្មស្សកោ** ជាដើម កម្មជារបស់ខ្លួន គឺជារបស់មាននៃខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា មានកម្មជារបស់ខ្លួន ។ បទថា **កម្ម-ទាយាទោ** ប្រែថា អាត្មាអញជាទាយាទរបស់កម្ម អធិប្បាយថា មានកម្មជាមត៌ក គឺជាសម្បត្តិរបស់ខ្លួន កម្មជាកំណើត គឺជាហេតុកើតរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា មានកម្មជាកំណើត ។ កម្មជាផៅពង្សរបស់ខ្លួន ព្រោះដូច្នោះ ទើបអាត្មាអញ ឈ្មោះថា មានកម្មជាផៅពង្ស ។ អធិប្បាយថា មានកម្មជាញាតិ ។ កម្មជាទីអាស្រ័យ គឺជាទីពឹងរបស់ខ្លួន ព្រោះដូច្នោះ ទើបអាត្មាអញ ឈ្មោះថា មានកម្មជាទីអាស្រ័យ ។ បទថា **តស្ស ទាយាទោ ភវិស្សាមិ** ប្រែថា អាត្មាអញជាទាយាទនៃកម្មនោះ អធិប្បាយថា អាត្មាអញជាអ្នកទទួលផលដែលកម្មនោះឲ្យ ។

បទថា **យោព្វនមទោ** បានដល់ ការស្រវឹងកើតឡើងប្រារព្ធភាពជាកំលោះក្រមុំ ។ ក្នុងបទទាំងឡាយដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **មគ្គោ សញ្ជាយតិ** បានដល់ លោកុត្តរមគ្គ រមែងកើតឡើងព្រម ។ បទថា **សំយោជនានិ បហីយន្តិ** សេចក្តីថា សំយោជនៈ ១០ ប្រការ លោករមែងលះបានដោយប្រការទាំងពួង ។ បទថា **អនុសយា ព្យន្តី ហោន្តិ** សេចក្តីថា អនុស័យ ៧ ប្រការអស់ហើយ គឺមានផ្លូវជុំវិញកាត់ផ្តាច់ហើយ ក្នុងសូត្រនេះ

*ព្រះមានព្រះភាគបានត្រាស់វិបស្សនាក្នុងឋានៈទាំង ៥ ខាងដើមហើយ ដោយប្រការដូច្នេះ ត្រាស់លោកុត្តរមគ្គក្នុងឋានៈទាំង ៥ នេះ ។*

*ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរុបដោយគាថាទាំងឡាយទើបត្រាស់ថា* **ញាណំ ចក្ខុំ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ញត្វា ធម្មំ និរូបធឹ** *សេចក្តីថា ដឹងធម៌ គឺព្រះអរហត្តដែលប្រាសចាកឧបធិហើយ ។ បទថា* **សព្វេ មនេ អភិភោស្មិ** *សេចក្តីថា តថាគតគ្របសង្កត់ការស្រើនទាំង ៣ យ៉ាងនេះបានទាំងអស់ អធិប្បាយថា តថាគតឈានកន្លង ហើយតាំងនៅ ។ បទថា* **នេក្ខម្មំ ទដ្ឋុ ខេមតោ** *សេចក្តីថា ឃើញការបួសជារបស់ក្សេម ។ បទថា* **តស្ស មេ អហុ ឧស្សាហោ និព្វានំ អភិបស្សតោ** *សេចក្តីថា សម្រាប់តថាគតដែលជាអ្នកឃើញច្បាស់នូវព្រះនិព្វានបាន មានសេចក្តីព្យាយាមហើយ ។ បទថា* **អនិវត្តិ ភវិស្សាមិ** *សេចក្តីថា តថាគតជាអ្នកមិនត្រឡប់ចេញអំពីបព្វជ្ជា នឹងមិនត្រឡប់អំពីការនៅប្រព្រឹត្តព្រហ្មចរិយៈ នឹងមិនត្រឡប់ទៅអំពីព្រះសព្វញ្ញុតញ្ញាណ ។ បទថា* **ព្រហ្មចរិយបរាយណោ** *គឺជាអ្នកមានមគ្គព្រហ្មចរិយៈជាខាងមុខ ។ បទនេះ ព្រះមានព្រះភាគត្រាស់មគ្គមានអង្គ ៨ ដែលជាលោកុត្តរ ដោយប្រការដូច្នេះ ។ល។*

**អដ្ឋកថា ឋានសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## កុមារលិច្ឆវីសូត្រទី ៨

[ ៥៨ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចទៅបិណ្ឌបាតក្នុងនគរ វេសាលី រួចត្រឡប់មកពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត ហើយ ស្តេចចូលទៅកាន់មហាវ័ន គង់សម្រាកក្នុងវេលាថ្ងៃក្រោមម្លប់ឈើមួយដើម ។ សម័យនោះឯង ពួកលិច្ឆវីកុមារច្រើនអង្គ កាន់យកនូវធ្នូដែលខ្វនជាំឡើង ហើយ មានពួកឆ្កែចោមរោម ដើរសញ្ចរទៅមកក្នុងមហាវ័ន បានឃើញព្រះ ដ៏មានព្រះភាគ ទ្រង់គង់ក្រោមម្លប់ឈើមួយដើម លុះឃើញហើយ ក៏ដាក់ធ្នូ ដែលខ្វនជាំឡើងចេញហើយ បញ្ជូនពួកឆ្កែទៅក្នុងទីសមគួរ រួចចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ មាន សភាពស្ងប់ស្ងៀម ផ្គងអញ្ជលី ចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ ។ សម័យនោះ មហានាមលិច្ឆវី ដើរសញ្ចរទៅមក សម្រួលស្មងក្នុងមហាវ័ន បានឃើញពួកលិច្ឆវីកុមារទាំងនោះ កំពុងមានភាពស្ងប់ស្ងៀម ផ្គងអញ្ជលី ចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ លុះបានឃើញហើយ ក៏ចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះស្តេចមហានាមលិច្ឆវី អង្គុយក្នុងទីសមគួរ

ហើយ ក៏បន្លឺឡើងនូវឧទានថា ពួកស្តេចវជ្ជីនឹងចម្រើន ពួកស្តេចវជ្ជីនឹងចម្រើន ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលមហានាម ថ្វីក៏បានជានិយាយថា ពួកស្តេចវជ្ជីនឹងចម្រើន ពួកស្តេចវជ្ជីនឹងចម្រើនយ៉ាងនេះ ។ ស្តេចមហានាមលិច្ឆវីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកលិច្ឆវីកុមារទាំងនេះធ្លាប់តែកាចអាក្រក់ រឹងរូស ( ពេកណាស់ ) ជំនូនទាំងឡាយណា ទោះជាអំពៅក្តី ផ្លែពុទ្រាក្តី នំក្តី ត្រប៉ែក្តី ទ្រាបល្វក្តី ដែលគេបញ្ជូនទៅចំពោះត្រកូលទាំងឡាយ ក៏ចេះតែប្លន់ដណ្តើមយកស៊ីនូវជំនូនទាំងនោះ ( មិនតែប៉ុណ្ណោះ ថែមទាំងទៅ ) ពីខាងក្រោយជាក់ខ្នងពួកស្រីក្នុងត្រកូលខ្លះ និងពួកកុមារីក្នុងត្រកូលខ្លះ ឥឡូវនេះ ពួកលិច្ឆវីកុមារទាំងនោះ ( បែរជា ) មានសភាពស្ងប់ស្ងៀម ផ្គងអញ្ជលីចូលមកអង្គុយជិតព្រះដ៏មានព្រះភាគវិញ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមហានាម ធម៌ទាំងឡាយ ៥ យ៉ាង មានដល់កុលបុត្រណាទីមួយ ទោះជាព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយក្តី ទោះជាអ្នកបរិភោគនូវដែនក្តី បរិភោគនូវសម្បត្តិដែលបិតាឲ្យក្តី ទោះជាសេនាបតីនៃសេនាក្តី ទោះជាម្ចាស់នៃស្រុកក្តី ទោះជាធំជាងពួកក្តីមួយទៀត ពួកជនណាឲ្យគេធ្វើនូវភាពនៃខ្លួនជាធំដោយឡែក ក្នុងត្រកូលទាំងឡាយ សេចក្តីចម្រើនមានប្រាកដដល់ ( ជនទាំងឡាយនោះ ) មិនបានសាបសូន្យឡើយ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលមហានាម កុលបុត្រក្នុងលោកនេះ ធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាមាតាបិតា

ដោយភោគៈ ដែលបានដោយការសន្សំតប្រឹងប្រែង ដែលសន្សំមកដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ មាតាបិតាដែលកុលបុត្របានធ្វើសក្ការៈ ធ្វើគារវៈ រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្រនោះ ដោយចិត្តដ៏ល្អថា ចូរអ្នករស់នៅអស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្រ ដែលមាតាបិតាអនុគ្រោះហើយ រមែងមានតែសេចក្តីចម្រើនប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្រធ្វើសក្ការៈ ធ្វើគារវៈ រាប់អាន បូជានូវកូនប្រពន្ធ និងបុរសជាទាសៈ និងកម្មករទាំងឡាយ ដោយភោគៈដែលបានមកដោយការសន្សំតប្រឹងប្រែង ដែលសន្សំមកដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ កូនប្រពន្ធ និងបុរសជាទាសៈ និងកម្មករទាំងឡាយដែលកុលបុត្របានធ្វើសក្ការៈ ធ្វើគារវៈ រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្រនោះ ដោយចិត្តដ៏ល្អថា ចូរអ្នករស់នៅអស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្រដែលកូនប្រពន្ធ និងបុរសជាទាសៈ និងកម្មករទាំងឡាយអនុគ្រោះហើយ សេចក្តីចម្រើនមានប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្រធ្វើសក្ការៈ ធ្វើគារវៈ រាប់អាន បូជានូវពួកជនជិតខាងស្រែ និងការងាររបស់ខ្លួន និងជនអ្នកវាស់ទីដីដោយភោគៈទាំងឡាយ ដែលបានដោយការសន្សំតប្រឹងប្រែង ដែល

សន្សំទុកដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួកជនជិតខាងស្រែ និងការងារ និងជនអ្នករាស់ទីដីដែលកុលបុត្របានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្រនោះដោយចិត្តដ៏ល្អថា អ្នកចូររស់នៅអស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្រដែលពួកជនជិតខាងស្រែ និងការងារ និងជនអ្នករាស់ទីដីបានអនុគ្រោះហើយ សេចក្តីចម្រើនក៏មានប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្រធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាពួកទេវតាដែល ជាអ្នកទទួលនូវគ្រឿងបូជាដោយភោគៈ ដែលបានមកដោយការសន្សំប្រឹងប្រែង ដែលសន្សំទុកដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួកទេវតាដែលជាអ្នកទទួលគ្រឿងបូជា ដែលកុលបុត្របានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះនូវកុលបុត្រនោះដោយចិត្តដ៏ល្អថា អ្នកចូររស់នៅអស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្រដែលទេវតាអនុគ្រោះហើយ សេចក្តីចម្រើនក៏មានប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្រធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាពួកសមណព្រាហ្មណ៍ដោយភោគៈ ដែលបានមក ដោយការសន្សំប្រឹងប្រែង ដែលសន្សំទុកដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួក

សមណព្រាហ្មណ៍ដែលកុលបុត្របានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្រនោះដោយចិត្តដ៏ល្អថា អ្នកចូររស់នៅអស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្រដែលពួកសមណព្រាហ្មណ៍អនុគ្រោះហើយ សេចក្ដីចម្រើន ក៏មានប្រាកដមិនបានសាបសូន្យឡើយ ។ ម្នាលមហានាម ធម៌ទាំង ៥ យ៉ាងនេះ មានដល់កុលបុត្រណាទីមួយ ទោះជាព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយក្ដី ទោះជាអ្នកបរិភោគនូវដែនក្ដី បរិភោគនូវសម្បត្តិដែលបិតាឲ្យក្ដី ទោះជាសេនាបតីនៃសេនាក្ដី ទោះជាម្ចាស់នៃស្រុកក្ដី ទោះជាធំជាងពួកក្ដី មួយវិញទៀត ពួកជនណាដែលឲ្យគេធ្វើនូវភាពនៃខ្លួនជាធំដោយឡែក ក្នុងត្រកូលទាំងឡាយ សេចក្ដីចម្រើនមានប្រាកដដល់ ( ជនទាំងឡាយនោះ ) មិនបានសាបសូន្យទៅឡើយ ។

កុលបុត្រអ្នកធ្វើកិច្ចជំនួសមាតាបិតា ទំនុកបម្រុងកូន និងប្រពន្ធសព្វៗ កាល ប្រតិបត្តិជាប្រយោជន៍ដល់ជនទាំង ២ ពួក គឺជាប្រយោជន៍ដល់ជនក្នុងផ្ទះ និងជនដែលចូលមកជ្រកអាស្រ័យចិញ្ចឹមជីវិត ជាអ្នកដឹងនូវពាក្យពេចន៍នៃស្នូម ជាអ្នកមានសីលជាបណ្ឌិតគ្រប់គ្រងផ្ទះប្រកបដោយធម៌ ធ្វើអំណរឲ្យកើតដល់ពួកញាតិដែលទៅកាន់បរលោក ពួកញាតិដែលកំពុងរស់នៅក្នុងបច្ចុប្បន្ន ពួកសមណៈ ពួកព្រាហ្មណ៍ និងពួកទេវតា កុល-

បុត្រនោះ លុះបានធ្វើអំពើល្អហើយ រមែងជាបុគ្គលគួរបូជា គួរសរសើរ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវកុលបុត្រនោះ ក្នុងលោកនេះឯង កុលបុត្រនោះ លុះលះលោកនេះទៅហើយ រមែងត្រេកអរក្នុងស្ថានសួគ៌ ។

# អដ្ឋកថា

## កុមារលិច្ឆវីសូត្រ

[ ៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុមារលិច្ឆវីសូត្រទី ៨ ដូចតទៅនេះ បទថា **សជ្ជានិ ធនូនិ** សេចក្តីថា កាន់យកធ្នូដែលដំឡើងខ្សែហើយ ។ បទថា **ភវិស្សន្តិ វឌ្ឍិ** បានដល់ សេចក្តីវឌ្ឍនីងចម្រើន ។ បទថា **អចាដុកា** សេចក្តីថា អាស្រ័យការមិនចម្រើន ជាអ្នករឹងត្អឹងព្រោះមានះ ។ បទថា **បច្ឆាលិយំ ខិបន្តិ** សេចក្តីថា ដើរទៅខាងក្រោយ ហើយធាក់កណ្តាលខ្នង ។ ក្នុងបទទាំងឡាយ មានបទថា **រដ្ឋិកស្ស** ជាដើម បុគ្គលឈ្មោះថា **រដ្ឋិក** ព្រោះបរិភោគ គឺគ្រប់គ្រងដែន ។ បុគ្គលឈ្មោះថា **បេត្តនិក** ព្រោះបរិភោគ គឺគ្រប់គ្រង ទ្រព្យមត៌កដែលបិតាឲ្យ ។ បុគ្គលឈ្មោះថា **សេនាបតី** ព្រោះជាម្ចាស់ គឺជាធំនៃកងទ័ព គឺមេទ័ព ។ បទថា **គាមគ្គាមិកស្ស** គឺជាប្រធាននៃអ្នកស្រុក អ្នកដែនទាំងឡាយ អធិប្បាយថា ជាអ្នកគ្រប់គ្រងស្រុក ។

បទថា **ប្ងគន្តាមណិកស្ស** គឺធំជាងពួក ។ បទថា **កុលេសុ** គឺក្នុងត្រកូលនោះ បទថា **បច្ចេកាធិបច្ចំ ការេន្តិ** គឺគ្រប់គ្រងអធិបតី គឺភាពជាធំម្នាក់ឯង ។

បទថា **កល្យាណេន មនសា អនុកម្បន្តិ** គឺអនុគ្រោះដោយចិត្តដែលល្អ ។ បទថា **ខេត្តកម្មន្តសាមន្តសព្យោហារេ** បានដល់ ជនដែលជាម្ចាស់ទ្រព្យត្រង់ស្រែជាប់គ្នានឹងរបស់ខ្លួនដោយជុំវិញរបស់អ្នកស្រែ និងភ្នាក់ងារវាស់វែងដែលកាន់យកខ្សែ និងឈើវាស់ដី ។ បទថា **ពលិប្បដិគ្គាហិកា ទេវតា** បានដល់ អារក្ខទេវតាដែលគោរពតគ្នាមកតាមបវេណីរបស់ត្រកូល ។ បទថា **តា សក្ការោតិ** បានដល់ ធ្វើសក្ការៈដល់ទេវតាទាំងនោះ ដោយបបរ និងបាយយ៉ាងល្អ ។

បទថា **កិច្ចករោ** គឺជាអ្នកជួយធ្វើកិច្ចដែលកើតឡើង ។ បទថា **យេ ចស្ស ឧបជីវិនោ** បានដល់ ជនដែលចូលទៅអាស្រ័យកិច្ចនោះចិញ្ចឹមជីវិត ។ បទថា **ឧភិន្នំយេវ អត្ថាយ** សេចក្តីថា ជាអ្នកបដិបត្តិដើម្បីជាប្រយោជន៍ដល់ជនទាំង ២ ។ បទថា **បុព្វបេតានំ** គឺជាអ្នកទៅកាន់បរលោកហើយ ។ បទថា **ទិដ្ឋធម្មេ ច ជីវិតំ** គឺញាតិដែលមានជីវិតក្នុងបច្ចុប្បន្ន ។ ព្រះមានព្រះភាគទ្រង់សម្តែងញាតិទាំងឡាយក្នុងអតីត និងបច្ចុប្បន្ន ដោយបទទាំង ២ នេះ ដោយប្រការដូច្នេះ ។ បទថា **បីតិសញ្ជននោ** គឺឲ្យកើតសេចក្តីត្រេកអរ ។ បទថា **ឃរមាវសំ** ប្រែថា ជាអ្នកគ្រប់គ្រងផ្ទះ ។ បទថា **បុជ្ជោ ហោតិ បសំសិយោ** សេចក្តីថា រមែងជាបុគ្គលដែលគេគប្បីបូជា និងគប្បីសរសើរ ។៚

# សុត្តន្តបិដក

## បឋមទុល្លភសូត្រទី ៩

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ( អ្នកបួសខាងឯចាស់ ) ប្រកបដោយធម៌ ៥ យ៉ាង រកបានដោយក្រ ។ វុឌ្ឍបព្វជិតប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិតជាអ្នកមានបញ្ញាល្អិតល្អ រកបានដោយក្រ ១ ជាអ្នកបរិបូណ៌ដោយមារយាទល្អ រកបានដោយក្រ ១ ជាអ្នកចេះដឹងច្រើន រកបានដោយក្រ ១ ជាអ្នកចេះសម្តែងធម៌ រកបានដោយក្រ ១ ជាអ្នកទ្រទ្រង់វិន័យ រកបានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ( អ្នកបួសខាងឯចាស់ ) ប្រកបដោយធម៌ ៥ យ៉ាង នេះឯង រកបានដោយក្រ ។

# អដ្ឋកថា

## បឋមទុល្លភសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមទុល្លភសូត្រទី ៩ ដូចតទៅនេះ បទថា **និបុណោ** គឺជាបុគ្គលល្អិត ដឹងហេតុការណ៍ដ៏សុខុម ។ បទថា **អាកប្បសម្បន្នោ** គឺជាអ្នកដល់ព្រមដោយមារយាទរបស់សមណៈ ។

**អដ្ឋកថា បឋមទុល្លភសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយទុល្លភសូត្រទី ១០

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ( អ្នកបួសឯចាស់ ) ប្រកបដោយធម៌ ៥ យ៉ាង រកបានដោយក្រ ។ វុឌ្ឍបព្វជិត ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិតដែលប្រដៅងាយ រកបានដោយក្រ ១ ជាអ្នកប្រកាន់ល្អរកបានដោយក្រ ១ ជាអ្នកទទួលយកឱវាទខាងស្ដាំរកបានដោយក្រ ១ ជាអ្នកចេះសម្ដែងធម៌រកបានដោយក្រ ១ ជាអ្នកទ្រទ្រង់វិន័យរកបានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រកបានដោយក្រ ។

**នីវរណវគ្គទី ១ ចប់**

## ឧទ្ទាននៃនីវរណវគ្គនោះ គឺ

និយាយអំពីអាវរណធម៌ ១ គំនរអកុសល ១ អង្គនៃបធាន ១ សម័យដើម្បីព្យាយាម ១ ភិក្ខុនីជាមាតា និងភិក្ខុជាបុត្រ ១ ភិក្ខុ ១ រូប អផ្សុកប្រាប់ហេតុដល់ឧបជ្ឈាយ៍ ១ ស្ថាន ៥ យ៉ាង ដែលគួរពិចារណារឿយៗ ១ លិច្ឆវីកុមារ ១ វុឌ្ឍបព្វជិត ប្រកបដោយធម៌ ៥ យ៉ាងដទៃទៀត ពីរលើក រកបានដោយក្រ ១ ។

# អដ្ឋកថា

## ទុតិយទុល្លភសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយទុល្លភសូត្រទី ១០ ដូចតទៅនេះ បទថា **បនត្កិណាគ្គាហី** ប្រែថា ជាអ្នកទទួលឱវាទដែលលោកឲ្យហើយ ដោយចំណែកខាងស្តាំ គឺដោយគោរព ។ ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ហើយ ៕

**អដ្ឋកថាទុតិយទុល្លភសូត្រទី ១០ ចប់**

**នីវរណវគ្គទី ១ ចប់**

# សុត្តន្តបិដក

# សញ្ញាវគ្គទី ២

## បឋមសញ្ញាសូត្រទី ១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះ ដែលបុគ្គលចម្រើន ធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៥ យ៉ាង តើដូចម្តេច ។ គឺអសុភសញ្ញា ( សេចក្តីសម្គាល់ថាមិនល្អ ) ១ មរណសញ្ញា ( សេចក្តីសម្គាល់ក្នុងសេចក្តីស្លាប់ ) ១ អាទីនវសញ្ញា ( សេចក្តីសម្គាល់ថាជាទោស ) ១ អាហារេបដិកូលសញ្ញា ( សេចក្តីសម្គាល់ក្នុងអាហារថាជាបដិកូល ) ១ សព្វលោកេ អនភិរតសញ្ញា ( សេចក្តីសម្គាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។

# អដ្ឋកថា

## សញ្ញាវគ្គទី ២

### បឋមសញ្ញាសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសញ្ញាសូត្រទី ១ នៃសញ្ញាវគ្គទី ២ ដូចតទៅនេះ បទថា **មហប្ផលា** គឺមានផលច្រើន ដោយផលដែលជាវិបាក ។ ឈ្មោះថា **មហានិសំសា** ព្រោះមានអានិសង្សច្រើន ដោយអានិសង្សដែលជាវិបាក ។ បទថា **អមតោគធា** គឺមានព្រះនិព្វានដែលជាទីពឹង ។ បទថា **សព្វលោកេ អនភិរតសញ្ញា** បានដល់ សញ្ញាដែលកើតឡើងដល់បុគ្គលដែលមិនត្រេកអរក្នុងលោក ដែលជាទីអាស្រ័យនៅនៃធាតុទាំង ៣ ។៚

**អដ្ឋកថា បឋមសញ្ញាសូត្រទី ១ ចប់**

# សុត្តន្តបិដក

### ទុតិយសញ្ញាសូត្រទី ២

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មាន

ព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៥ យ៉ាង តើដូចម្ដេច ។ គឺអនិច្ចសញ្ញា ( សេចក្ដីសម្គាល់ថាមិនទៀង ) ១ អនត្តសញ្ញា ( សេចក្ដីសម្គាល់ថាមិនមែនខ្លួន ) ១ មរណសញ្ញា ( សេចក្ដីសម្គាល់ក្នុងសេចក្ដីស្លាប់ ) ១ អាហារេបដិកូលសញ្ញា ( សេចក្ដីសម្គាល់ក្នុងអាហារថាជាបដិកូល ) ១ សព្វលោកេ អនភិរតសញ្ញា ( សេចក្ដីសម្គាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។

# អដ្ឋកថា

## ទុតិយសញ្ញាសូត្រ

[ ៦២ ] ក្នុងទុតិយសញ្ញាសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយសញ្ញាសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមវឌ្ឍិសូត្រទី ៣-៤

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវកកាលចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាង ឈ្មោះថា ចម្រើនដោយសេចក្តីចម្រើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់រាងកាយ ។ អរិយសាវកចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាង តើដូចម្តេច ។ គឺចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយសុតៈ ១ ចម្រើនដោយចាគៈ ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក កាលចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាងនេះឯង ឈ្មោះថា ចម្រើនដោយសេចក្តីចម្រើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់រាងកាយ ។

បុគ្គលណាចម្រើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ ដោយបញ្ញា បុគ្គលប្រាកដដូច្នោះនោះ ឈ្មោះថា ជាសប្បុរសមានប្រាជ្ញាជាគ្រឿងពិចារណា រមែងកាន់យកនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍មានខ្លឹម និងប្រយោជន៍ដ៏ឧត្តមដល់ខ្លួន ក្នុងលោកនេះបាន ។

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវិកា កាលចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាង ឈ្មោះថាចម្រើនដោយសេចក្តីចម្រើនដ៏ប្រសើរ ទាំងឈ្មោះ

ថាកាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់រាងកាយ ។ អរិយសាវិកាចម្រើនដោយសេចក្ដីចម្រើន ៥ យ៉ាងតើដូចម្ដេច ។ គឺចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយសុតៈ ១ ចម្រើនដោយចាគៈ ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវិកាចម្រើនដោយសេចក្ដីចម្រើន ៥ យ៉ាងនេះឯង ឈ្មោះថា ចម្រើនដោយសេចក្ដីចម្រើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្ដមដល់រាងកាយ ។

ស្ត្រីណាចម្រើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយ
ចាគៈ ដោយបញ្ញា ស្ត្រីប្រាកដដូច្នោះនោះ ឈ្មោះថាជាឧបាសិកា
មានសីល រមែងកាន់យកនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍
មានខ្លឹម និងប្រយោជន៍ដ៏ឧត្ដម ដល់ខ្លួនក្នុងលោកនេះបាន ។

# អដ្ឋកថា

## បឋមវឌ្ឍិសូត្រជាដើម

[ ៦៣-៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវឌ្ឍិសូត្រទី ៣ ជាដើមដូចតទៅនេះ បទថា **វរាទាយី** គឺជាអ្នកកាន់យកបាននូវសារៈដ៏ឧត្ដម ។ ពាក្យដ៏សេស ក្នុងសូត្រនេះ និងសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា បឋមវឌ្ឍិសូត្រទី ៣ ជាដើមចប់**

# សុត្តន្តបិដក

## សាកច្ចសូត្រទី ៥

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា គួរដល់ការសាកសួររបស់សព្រហ្មចារីទាំងឡាយ ។ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមកក្នុងសីលសម្បទា-កថា ១ បរិបូណ៌ដោយសមាធិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមកក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយប្រាជ្ញាដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមកក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែល មានមកក្នុងវិមុត្តិសម្បទា-កថា ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមកក្នុងវិមុត្តិញាណទស្សនសម្បទាកថា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា គួរដល់ការសាកសួររបស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា

## សាកច្ឆសូត្រទី ៥

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាកច្ឆសូត្រទី ៥ ដូចតទៅនេះ បទថា **អលំសាកច្ឆោ** ប្រែថា ជាអ្នកគួរសន្ទនាផង ។ បទថា **អាគតំ បញ្ហំ** គឺជាអ្នកដែលត្រូវសួរហើយ ។ បទថា **ព្យាកត្តា ហោតិ** គឺជាអ្នកឆ្លើយបញ្ហាបាន ៕

អដ្ឋកថា សាកច្ឆសូត្រទី ៥ ចប់

# សុត្តន្តបិដក

## សាជីវសូត្រទី ៦

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរដល់សាជីវៈ ( ការសួរប្រស្នា និងការដោះប្រស្នា ) របស់សព្រហ្មចារីទាំងឡាយបាន ។ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនតាក់តែងទុកក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិដោយខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលខ្លួនតាក់តែងទុកក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាដោយខ្លួនឯង ទាំងបានព្យាករ

នូវប្រស្នាដែលខ្លួនតាក់តែងទុកក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនតាក់តែងទុកក្នុងវិមុត្តិសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នា ដែលខ្លួនតាក់តែងទុកក្នុងវិមុត្តិញ្ញាណទស្សនសម្បទាកថា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរដល់សាជីវៈរបស់សព្រហ្មចារីទាំងឡាយបាន ។

# អដ្ឋកថា

## សាជីវសូត្រ

[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាជីវសូត្រទី ៦ ដូចតទៅនេះ បទថា **អលំសាជីវោ** ប្រែថា គួរដល់ការមានអាជីវៈរួមគ្នា ។ បទថា **សាជីវោ** បានដល់ ការសួរបញ្ហា និងការឆ្លើយបញ្ហា ។ ពិតហើយ សព្រហ្មចារីទាំងមូល រមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅរួមបញ្ហាជាមួយគ្នា ព្រោះហេតុនោះ ការសួរ និងការឆ្លើយបញ្ហានោះ ព្រះមានព្រះភាគត្រាស់ថា **សាជីវ** ព្រោះមានអាជីវៈរួមគ្នា ។ បទថា **កតំ បញ្ហំ** គឺបញ្ហាដែលតាំងសួរហើយ ៕

**អដ្ឋកថា សាជីវសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមឥទ្ធិបាទសូត្រទី ៧

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ចម្រើនធម៌ ៥ យ៉ាង ធ្វើឲ្យរឿយៗ នូវធម៌ ៥ យ៉ាង បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះ គឺថា នឹងបានសម្រេចនូវការៈជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទិសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវការៈជាអនាគាមិបុគ្គលពុំខានឡើយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទប្រកបដោយវីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ទាំងប្រឹងចម្រើននូវការព្យាយាម ដ៏លើសលុបជាគម្រប់ ៥ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលណាមួយទោះជាភិក្ខុក្តី ភិក្ខុនីក្តី ចម្រើនធម៌ ៥ យ៉ាងនេះ ធ្វើឲ្យរឿយៗ នូវធម៌ ៥ យ៉ាងនេះ បណ្តាផលទាំង ២ ផលណាមួយគង់នឹងបានសម្រេចដល់បុគ្គលនោះ គឺថា នឹងបានសម្រេចនូវការៈជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទិសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវការៈជាអនាគាមិបុគ្គលពុំខានឡើយ ។

# អដ្ឋកថា

## បឋមឥទ្ធិបាទសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឥទ្ធិបាទសូត្រទី ៧ ដូចតទៅនេះ បទថា **ឧស្សោឡ្ហី** ប្រែថា សេចក្ដីព្យាយាមមានប្រមាណក្រៃលែង ។ល។

**អដ្ឋកថា បឋមឥទ្ធិបាទសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយឥទ្ធិបាទសូត្រទី ៨

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន អំពីកាលត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ បានចម្រើននូវធម៌ ៥ យ៉ាង ធ្វើឲ្យរឿយៗ នូវធម៌ ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្ដេច ។ គឺតថាគតបានចម្រើននូវឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទប្រកបដោយវិរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ទាំងប្រឹងចម្រើននូវការព្យាយាមដ៏លើសលុប ជាគម្រប់ ៥ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតបានចម្រើន បានធ្វើឲ្យរឿយៗ នូវធម៌ដែលមានការព្យាយាមដ៏លើសលុបជាគម្រប់ ៥ នេះ ទើបតថាគតនោះ បានបង្អោនចិត្តទៅដើម្បីធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម កាលបើហេតុមាន ក៏បាន

ដល់នូវការៈជាបទ្ទាល់ ក្នុងការធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ក្នុងធម៌នោះៗ ឯង ។ បើតថាគតនោះប្រាថ្នាថា សូមឲ្យតថាគត បាននូវការតាក់តែងឫទ្ធិជាច្រើនប្រការ ។បេ។ ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក កាលបើហេតុមាន តថាគតក៏បានដល់នូវការៈជាបទ្ទាល់ ក្នុងការតាក់តែងឫទ្ធិនោះៗ ។ បើតថាគតនោះប្រាថ្នាថា ។បេ។ សូមឲ្យតថាគត បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ កាលបើហេតុមាន តថាគតក៏បានដល់នូវការៈជាបទ្ទាល់ ក្នុងការបានសម្រេចនូវគុណវិសេសនោះៗ ។

# អដ្ឋកថា

## ទុតិយឥទ្ធិបាទសូត្រ

[ ៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឥទ្ធិបាទសូត្រទី ៨ ដូចតទៅនេះ ព្រះមានព្រះភាគ ត្រាស់អាគមឥទ្ធិបាទរបស់ព្រះអង្គ ដែលទ្រង់ចាក់ធ្លុះហើយត្រង់មណ្ឌលពោធិព្រឹក្ស ហើយទើបត្រាស់អភិញ្ញា ៦ របស់ទ្រង់នោះឯងឲ្យក្រៃលែងឡើងទៅ ដោយប្រការដូច្នេះ ។៙

**អដ្ឋកថាទុតិយឥទ្ធិបាទសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## និព្វិទាសូត្រទី ៩ និងអាសវក្ខយសូត្រទី ១០

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់ដោយមិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ធម៌ ៥ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយៗ ថា មិនស្អាតក្នុងកាយ ១ សម្គាល់ថាគួរខ្ពើមក្នុងអាហារ ១ សម្គាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ១ ឃើញរឿយៗ ថា មិនទៀងក្នុងសង្ខារទាំងពួង ១ ទាំងមរណសញ្ញាក៏ប្រាកដឡើង ខាងក្នុងចិត្តរបស់ភិក្ខុនោះដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់មិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំង-ឡាយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយៗ ថា មិនស្អាតក្នុងកាយ ១ សម្គាល់ថា គួរខ្ពើមក្នុងអាហារ ១ សម្គាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង ១ ឃើញរឿយៗ

ថា មិនទៀងក្នុងសង្ខារទាំងពួង ១ ទាំងមរណសញ្ញាក៏ប្រាកដឡើង ខាងក្នុងចិត្តរបស់ភិក្ខុនោះដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលភិក្ខុបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

សញ្ញាវគ្គទី ២ ចប់

### ឧទ្ទាននៃសញ្ញាវគ្គនោះគឺ

និយាយអំពីសញ្ញាពីរលើក ១ សេចក្តីចម្រើនពីរលើក ១ ភិក្ខុគួរដល់ការសាកសួរ ១ ភិក្ខុគួរដល់សាជីវៈ ១ ឥទ្ធិបាទដែលបានពោលពីរលើក ១ ធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ១ ធម៌ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈ ១ ។

## អដ្ឋកថា

## និព្វិទាសូត្រទី ៩ ជាដើម

[ ៦៩-៧០ ] ក្នុងនិព្វិទាសូត្រទី ៩ និងអាសវក្ខយសូត្រទី ១០ ព្រះមានព្រះភាគត្រាស់វិបស្សនា ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ។

អដ្ឋកថា និព្វិទាសូត្រទី ៩-១០ ចប់

សញ្ញាវគ្គទី ២ ចប់

# សុត្តន្តបិដក

## យោធាជីវវគ្គទី ៣

### បឋមចេតោវិមុត្តិសូត្រទី ១

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ ដែលបុគ្គលបាន ចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងមានចេតោវិមុត្តិជាផលផង មាន ចេតោវិមុត្តិផលជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានបញ្ញាវិមុត្តិ-ផល ជាអានិសង្សផង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ ថា មិនស្អាត ( ក្នុង រូបកាយ ) ១ មានសេចក្តីសម្គាល់ថា ជាបដិកូលក្នុងអាហារ ១ មានសេចក្តី សម្គាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង ១ ពិចារណាឃើញរឿយៗ ថា មិនទៀងក្នុងសង្ខារទាំងពួង ១ សេចក្តីសម្គាល់ក្នុងមរណៈ ភិក្ខុនោះ ក៏បាន តម្កល់ទុកដោយប្រពៃខាងក្នុងសន្តាន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងមាន ចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផលជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផលជាអានិសង្សផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុបានចេតោវិមុត្តិ និងបញ្ញាវិមុត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ នេះ ហៅថា លើកឡើងនូវជើងគុល គឺអវិជ្ជាដូច្នេះខ្លះ ថាបំផ្លេចបំផ្លាញនូវគូ គឺសង្សារវដ្តដូច្នេះខ្លះ ថាដកឡើងនូវសសរ គឺតណ្ហាដូច្នេះខ្លះ ថាបើកនូវសន្ទះ

ទ្វារ គឺនីវរណៈដូច្នេះខ្លះ ថាប្រាសចាកសត្រូវ រម្លើងនូវទង់ គឺមានះ ទម្លាក់នូវភារៈ ប្រាសចាកវដ្តៈដូច្នេះខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលហៅថាលើកឡើងនូវជើងគុល គឺអវិជ្ជា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជាចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកលើកឡើងនូវជើងគុល គឺអវិជ្ជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិ និងសង្សារដែលសម្រាប់តាក់តែងនូវភពថ្មីទៀតចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្ត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដកឡើងនូវសសរ គឺតណ្ហា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់តណ្ហាចោលចេញអស់ហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដកឡើងនូវសសរ គឺតណ្ហា

យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសននេះ បានលះបង់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់ គឺមានះ ទម្លាក់ចោលនូវភារៈ ប្រាសចាកវដ្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអស្មិមានះចោលចេញអស់ហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់ គឺមានះ ទម្លាក់ចោលនូវភារៈ ប្រាសចាកវដ្តៈ យ៉ាងនេះឯង ។

# អដ្ឋកថា
# យោធាជីវវគ្គទី ៣

## បឋមចេតោវិមុត្តិសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមចេតោវិមុត្តិសូត្រទី ១ នៃយោធាជីវវគ្គទី ៣ ដូចតទៅនេះ ពាក្យថា **យតោ ខោ ភិក្ខវេ** ជាដើមនេះ ព្រះមានព្រះភាគ ទ្រង់ផ្ដើមក្នុងឥឡូវនេះ ដើម្បីទ្រង់សរសើរភិក្ខុដែលចម្រើនវិបស្សនាហើយ សម្រេចអរហត្ត តាមដែលបានត្រាស់ហើយខាងដើម ។ បណ្ដាបទទាំងនោះ បទថា **យតោ ខោ** ប្រែថា កាលណា ។ បទថា **ឧក្ខិត្តបលិឃោ** បានដល់ ដកនូវជើងគុល គឺអវិជ្ជាចេញទៅហើយ ។ បទថា **សង្កិណ្ណបរិក្ខោ** បានដល់ រើនូវគូ គឺសង្សារវដ្ដឲ្យខ្ទេចខ្ទីហើយ ។ បទថា **អព្ពុឡ្ហេសិកោ** បានដល់ ដកនូវសសរ គឺតណ្ហាចេញហើយ ។ បទថា **និរគ្គឡោ** បានដល់ បើកនូវសន្ទះទ្វារ គឺនីវរណៈចេញហើយ ។ បទថា **បន្នទ្ធជោ បន្នភារោ** បានដល់ ដាក់នូវទង់ គឺមានះ និងភារៈ គឺខន្ធ អភិសង្ខារ និងកិលេសចុះហើយ ។ បទថា **វិសំយុត្តោ** បានដល់ រួចផុតចាកវដ្ដៈ ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យនៃព្រះបាលីនោះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងកាលរបស់ព្រះខីណាស្រព ដែលធ្វើកិលេសឲ្យអស់ទៅដោយមគ្គ ហើយទៅកាន់ទីដេកដ៏ប្រសើរ គឺនិរោធ ចូលផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍ ដោយព្រះតម្រាស់មានប្រមាណ

ប៉ុណ្ណោះ ប្រៀបដូចនគរ ២ គឺនគរចោរ ១ នគរក្សេម ១ ។ គ្រានោះ អ្នកចម្បាំងធំម្នាក់ គិតថា ដរាបណានគរចោរនៅមាន ដរាបនោះ ខេមនគរក៏មិនផុតភ័យ អញនឹងធ្វើនគរចោរមិនឲ្យជានគរ ហើយទើបពាក់គ្រោះ កាន់យកព្រះខ័ន ចូលទៅកាន់នគរចោរ យកព្រះខ័នកាត់នូវសសរគោល ដែលគេបញ្ឈរត្រង់ទ្វារនគរ ពុះបំបែកនូវសន្ទះទ្វារ ព្រមទាំងក្របទ្វារ លើកនូវជើងគុល ទម្លាយនូវកំពែង រើនូវគូ ដាក់នូវទង់ដែលគេលើកឡើង ដើម្បីលម្អព្រះនគរ ហើយយកភ្លើងដុតកម្ទេច ចូលទៅកាន់ខេមនគរ ឡើងលើប្រាសាទមានពួកញាតិចោមរោម បរិភោគអាហារដ៏ឆ្ងាញ់ ឧបមានេះ យ៉ាងណា សូម្បីឧបមេយ្យក៏ដូច្នោះ សក្កាយ ដូចចោរនគរ ព្រះនិព្វាន ដូចខេមនគរ ព្រះយោគាវចរ ដូចអ្នកចម្បាំងធំ លោកមានការគិតយ៉ាងនេះថា ដរាបណាសក្កាយនៅប្រព្រឹត្តទៅ ដរាបនោះ ក៏មិនរួចផុតអំពីកម្មករណ៍ ៣២ រោគ ៩៨ មហាភ័យ ២៥ ទើបលោកដូចជាអ្នកចម្បាំងធំ ពាក់នូវគ្រោះ គឺសីល កាន់យកនូវដាវ គឺបញ្ញា យកអរហត្តមគ្គកាត់នូវសសរគោល គឺតណ្ហា ដូចយកដាវកាត់នូវសសរគោល ដកនូវជើងគុល គឺសំយោជនៈខាងក្រោម ៥ ដូចអ្នកចម្បាំង ពុះបំបែកនូវទ្វារនគរ ព្រមទាំងក្របទ្វារ លើកនូវជើងគុល គឺអវិជ្ជា ដូចអ្នកចម្បាំងលើកនូវជើងគុល បំផ្លិចបំផ្លាញនូវអភិសង្ខារ គឺកម្ម រើនូវគូ គឺជាតិសង្សារ ដូចអ្នកចម្បាំងទម្លាយនូវកំពែង រើនូវគូ ដាក់ចុះនូវទង់ គឺមានះ ដូចអ្នកចម្បាំងទម្លាក់ទង់ ដែលគេលើកឡើងក្នុងនគរចោរ ដើម្បី

លម្អ ដុតនគរចោរ គឺសក្កាយ ចូលកាន់នគរ គឺកិលេសប្បរិនិព្វាន ជាទីរម្ងាប់កិលេស សោយសុខកើតអំពីផលសមាបត្តិ ដែលមានអមតនិរោធជាអារម្មណ៍ ញុំាងកាលឲ្យកន្លងទៅ ដូចអ្នកចម្បាំងចូលទៅក្នុងនគរក្រុម ឡើងប្រាសាទជាន់លើ បរិភោគអាហារដែលឆ្ងាញ់ ដូច្នោះ ។ល។

## អដ្ឋកថា បឋមចេតោវិមុត្តិសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយចេតោវិមុត្តិសូត្រទី ២

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងមានចេតោវិមុត្តិជាផលផង មានចេតោ-វិមុត្តិផលជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានបញ្ញាវិមុត្តិផលជាអានិសង្សផង ។ ធម៌ទាំង ៥ យ៉ាងតើដូចម្តេចខ្លះ ។ គឺសេចក្តីសម្គាល់ថា ជារបស់មិនទៀង ១ សេចក្តីសម្គាល់ថាជាទុក្ខ ក្នុងរបស់ដែលមិនទៀង ១ សេចក្តីសម្គាល់ថាមិនមែនខ្លួន ក្នុងរបស់ដែលជាទុក្ខ ១ សេចក្តីសម្គាល់ក្នុងការលះបង់ ១ សេចក្តីសម្គាល់ក្នុងការប្រាសចាករាគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែង

មានចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផលជាអានិសង្សផង មានបញ្ញា-វិមុត្តិជាផលផង មានបញ្ញាវិមុត្តិផលជាអានិសង្សផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុ បានចេតោវិមុត្តិ និងបញ្ញាវិមុត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា លើកឡើងនូវជើងគុល គឺអវិជ្ជា ដូច្នេះខ្លះ ថាបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្ដដូច្នេះខ្លះ ថាដកឡើងនូវសសរ គឺតណ្ហាដូច្នេះខ្លះ ថាបើកនូវសន្ទះទ្វារ គឺនីវរណៈដូច្នេះខ្លះ ថាប្រាសចាកសត្រូវ ដាក់ចុះនូវទង់គឺ មានះ ទម្លាក់នូវភារៈប្រាសចាកវដ្ដៈដូច្នេះខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកលើកឡើងនូវជើងគុល គឺអវិជ្ជា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជាចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលើកឡើងនូវជើងគុល គឺអវិជ្ជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្ដ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិ និងសង្សារ ដែលសម្រាប់តាក់តែងនូវភពថ្មីទៀតចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្ដ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដកឡើងនូវ

សសរ គឺតណ្ហា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់តណ្ហាចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដកឡើងនូវសសរ គឺតណ្ហា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់ គឺមានះ ទម្លាក់នូវភារៈប្រាសចាកវដ្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអស្មិមានះ ចោលចេញអស់ហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់ គឺមានះ ទម្លាក់នូវភារៈ ប្រាសចាកវដ្តៈ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយចេតោវិមុត្តិសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយចេតោវិមុត្តិសូត្រទី ២ ដូចតទៅនេះ បទថា **អនិច្ចសញ្ញា** បានដល់ សញ្ញាដែលកើតឡើងថា បញ្ចក្ខន្ធមិនទៀង ដោយអាការ គឺមានហើយ ក៏ទៅជាមិនមាន ។ បទថា **អនិច្ចេ ទុក្ខសញ្ញា** បានដល់ សញ្ញាដែលកើតឡើងថា វត្ថុណាមិនទៀង វត្ថុនោះក៏ជាទុក្ខ គឺដោយការបៀតបៀន ។ បទថា **ទុក្ខេ អនត្តសញ្ញា** បានដល់ សញ្ញាដែលកើតឡើងថា វត្ថុណាជាទុក្ខ វត្ថុនោះក៏ជាអនត្តា ដោយអាការ គឺមិននៅក្នុងអំណាច ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយខាងដើមនោះឯង តែក្នុងព្រះសូត្រទាំង ២ នេះ ក៏ត្រាស់ហៅថា វិបស្សនាផល ។៙

**អដ្ឋកថា ទុតិយចេតោវិមុត្តិសូត្រទី ២ ចប់**

# សុត្តន្តបិដក

## បឋមធម្មវិហារិកសូត្រទី ៣

[ ៧៣ ] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មាន

ព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការរៀននូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកមានប្រក្រតីនៅដោយធម៌ទេ ។ មួយទៀត ភិក្ខុសម្តែងធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដល់បុគ្គលទាំងឡាយដទៃ ដោយសេចក្តីពិស្តារ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការបញ្ញត្តិនូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបញ្ញត្តិ មិនហៅថាជាអ្នកនៅដោយធម៌ទេ។ មួយទៀត ភិក្ខុធ្វើនូវការស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដោយសេចក្តីពិស្តារ ។ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការស្វាធ្យាយនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយការស្វាធ្យាយ មិនហៅថាជាអ្នកនៅដោយធម៌ទេ ។ មួយទៀត

ភិក្ខុត្រិះរិះពិចារណាដោយចិត្ត សញ្ជឹងដោយចិត្ត ចំពោះធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ។ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការត្រិះរិះនូវធម៌ទាំងនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះ ហៅថាជាអ្នកច្រើនដោយសេចក្តីត្រិះរិះនូវធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។ ភិក្ខុនោះ មិនបានញុំាងថ្ងៃឲ្យកន្លងទៅ ដោយការរៀននូវធម៌នោះ មិនលះបង់នូវការសម្ងំ នៅក្នុងទីស្ងាត់ ប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុជាអ្នកនៅដោយធម៌ យ៉ាងនេះឯង ។ ភិក្ខុជាអ្នកច្រើនដោយការរៀន តថាគតបានសម្តែងហើយ អ្នកច្រើនដោយការបញ្ញត្តិ តថាគតបានសម្តែងហើយ អ្នកច្រើនដោយការស្វាធ្យាយ តថាគតបានសម្តែងហើយ អ្នកច្រើនដោយការត្រិះរិះ តថាគតបានសម្តែងហើយ អ្នកមានប្រក្រតីនៅដោយធម៌ តថាគតបានសម្តែងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុ អំពើណា ដែលសាស្តាជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គួរធ្វើដល់សាវកទាំងឡាយ អំពើនោះតថាគត ក៏បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុ ទីនុ៎ះជារុក្ខមូលសេនាសនៈ ទីនុ៎ះជាសុញ្ញាគារសេនាសនៈ ។ អ្នកទាំងឡាយ ចូរចម្រើន ( នូវសមថៈ និងវិបស្សនា ) អ្នក

ទាំងឡាយ ចូរកុំប្រមាទ អ្នកទាំងឡាយ ចូរកុំមានសេចក្ដីក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។

# អដ្ឋកថា

## បឋមធម្មវិហារិកសូត្រ

[ ៧៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមធម្មវិហារិកសូត្រទី ៣ ដូចតទៅនេះ បទថា **ទិវសំ អតិនាមេតិ** បានដល់ ធ្វើកាលមួយថ្ងៃឲ្យកន្លងទៅ ។ បទថា **រិញ្ចតិ បដិសល្លានំ** បានដល់ លះបង់នូវការនៅម្នាក់ឯង ។ បទថា **ទេសេតិ** បានដល់ ពោលប្រកាស ។ បទថា **ធម្មប្បញ្ញត្តិយា** បានដល់ ដោយការបញ្ញត្តិធម៌ ។ បទថា **ធម្មំ បរិយាបុណាតិ** បានដល់ សូធ្យរៀនសិក្សា ពោលនូវធម៌ គឺសច្ចៈ ៤ ដោយនវង្គសត្ថុសាសនៈ ។ បទថា **ន រិញ្ចតិ បដិសល្លានំ** បានដល់ មិនលះបង់ការនៅតែឯង ។ បទថា **អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ** បានដល់ សេពចម្រើនចិត្តសមាធិខាងក្នុងខ្លួនឯង គឺប្រកបសេចក្ដីខ្វល់ខ្វាយ ក្នុងសមថកម្មដ្ឋាន ។ បទថា **ហិតេសិនា** ប្រែថា ជាអ្នកស្វែងរកប្រយោជន៍ ។ បទថា **អនុកម្បកេន** ប្រែថា ជាអ្នកអាណិតអាសូរ ។ បទថា **អនុកម្បំ ឧបាទាយ** បានដល់ កំណត់ លោក

អធិប្បាយថា អាស្រ័យនូវការអាណិតអាសូរដោយចិត្តក៏មាន ។ បទថា **កតំ វោ តំ មយា** សេចក្តីថា តថាគតនឹងសម្តែងបុគ្គល ៥ ប្រភេទនេះ ធ្វើករណីយកិច្ចនោះ ដល់អ្នកទាំងឡាយហើយ ។ ពិតហើយ ព្រះសាស្តា ទ្រង់ជាអ្នកមានករុណា ក៏មានកិច្ច គឺការសម្តែងធម៌ដែលមិនវិបរិត មានប្រមាណប៉ុណ្ណោះឯង ។

បន្ទាប់អំពីនេះទៅ ឈ្មោះថា បដិបត្តិ ជាកិច្ចនៃសាវកអ្នកស្តាប់ទាំងឡាយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះគល់ឈើ ។បេ។ ជាអនុសាសនី ដូច្នេះ ។ ក្នុងព្រះតម្រាស់នោះ ទ្រង់សម្តែងសេនាសនៈ គឺគល់ឈើ ដោយបទថា **រុក្ខមូលានិ** គល់ឈើ ដូច្នេះ ។ ទ្រង់សម្តែងទីស្ងាត់ចាកមនុស្ស ដោយបទថា **សុញ្ញាគារានិ** ប្រែថា ផ្ទះស្ងាត់ ដូច្នេះ ។ម្យ៉ាងទៀត ទ្រង់ប្រាប់សេនាសនៈដែលសមគួរដល់ការបំពេញព្យាយាម ដោយបទទាំង ២ ឈ្មោះថា ទ្រង់ប្រគល់មត៌កឲ្យ ។ បទថា **ឈាយថ** បានដល់ អ្នកទាំងឡាយ ចូរសម្លឹងពិនិត្យអារម្មណ៍ ៣៨ ដោយការសម្លឹងពិនិត្យដោយអារម្មណ៍ និងសម្លឹងពិនិត្យខន្ធ អាយតនៈជាដើម ថាជារបស់មិនទៀងជាដើម ដោយការសម្លឹងពិនិត្យលក្ខណៈ លោកអធិប្បាយថា ចូរចម្រើនសមថៈ និងវិបស្សនា ។ បទថា **មា បមាទត្ថ** ប្រែថា កុំប្រមាទឡើយ ។ បទថា **មា បច្ឆា វិប្បដិសារិនោ អហុវត្ថ** សេចក្តីថា កាលទ្រង់សម្តែងសេចក្តីនេះថា សាវកទាំងឡាយណា ពេលនៅ

ជាកំលោះ ពេលមិនមានរោគ ពេលសម្បូរដោយសប្បាយ មានអាហារជាទីសប្បាយជាដើម ពេលដែលនៅចំពោះព្រះភក្ត្រព្រះសាស្តា វៀរយោនិសោមនសិការ ឆប់ជ្រប់តែក្នុងសេចក្តីសុខ ក្នុងការដេកលក់ ជាចំណីរបស់សន្លឹច អស់ថ្ងៃ និងយប់ ប្រមាទមកអំពីមុន ខាងក្រោយ សាវ័កទាំងនោះដល់ពេលចាស់ កើតរោគ ជិតនឹងស្លាប់ កាលវិបត្តិ និងកាលព្រះសាស្តាបរិនិព្វានហើយ កាលនឹកដល់ ការនៅដោយសេចក្តីប្រមាទមកអំពីមុននោះសម្លឹងឃើញការធ្វើកាលកិរិយា ដោយមានបដិសន្ធិជាការៈ ក៏ក្តៅក្រហាយចិត្ត ចំណែកអ្នកទាំងឡាយ កុំបីដូច្នោះឡើយ ដូច្នេះ ទើបត្រាស់ថា ពួកអ្នកចូរកុំក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ បទថា **អយំ វោ អម្ហាកំ អនុសាសនី** សេចក្តីថា វាចានេះ ពួកអ្នកចូរពិនិត្យកុំប្រមាទ ជាអនុសាសនីលោកអធិប្បាយថា ជាឱវាទអំពីតថាគតសម្រាប់អ្នកទាំងឡាយ ដូច្នេះ ។ល។

**អដ្ឋកថា បឋមធម្មវិហារិកសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយធម្មវិហារិកសូត្រទី ៤

[ ៧៤ ] គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ ... វេទល្លៈ តែភិក្ខុនោះមិនដឹងច្បាស់នូវអត្ថដ៏លើសលុប របស់ធម៌នោះដោយបញ្ញាឡើយ ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថាជាអ្នកនៅដោយធម៌ទេ ។បេ។ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ ... វេទល្លៈ តែភិក្ខុនោះដឹងច្បាស់នូវអត្ថដ៏លើសលុប របស់ធម៌នោះដោយបញ្ញា ។ ភិក្ខុជាអ្នកមានប្រក្រតីនៅដោយធម៌ យ៉ាងនេះឯង ។ ភិក្ខុ ។បេ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ ។

# អដ្ឋកថា

## ទុតិយធម្មវិហារិកសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយធម្មវិហារិកសូត្រទី ៤ ដូចតទៅនេះ បទថា **ឧត្តរឹ ចស្ស បញ្ញាយ អត្ថំ នប្បជានាតិ** សេចក្តីថា មិនដឹងអត្ថនៃធម៌នោះ ដោយមគ្គប្បញ្ញា ព្រមទាំងវិបស្សនា ក្រៅលែងជាងបរិយត្តិ

នោះ ។ អធិប្បាយថា មិនឃើញ មិនចាក់ធ្លុះសច្ចៈ ៤ ។ ក្នុងវារៈក្រៅពីនោះ ក៏ន័យនេះដូចគ្នា ។ ជន ៦ ពួក គឺភិក្ខុ ពហុស្សូត ជាអ្នកបំពេញវិបស្សនាកម្មដ្ឋាន ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រព គប្បីជ្រាបថា ជាធម្មវិហារី គឺអ្នកនៅដោយធម៌ ក្នុងព្រះសូត្រទាំង ២ នេះ ដោយប្រការដូច្នេះ ។៚

## អដ្ឋកថា ទុតិយធម្មវិហារិកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមយោធាជីវសូត្រទី ៥

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ( អ្នករស់នៅដោយបាន់ៈជាទាហាន ) នេះមាន ៥ ពួក តែងមានប្រាកដក្នុងលោក ។ យោធាជីវៈទាំង ៥ ពួកតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ គ្រាន់តែបានឃើញនូវផង់ធូលី ដែលហុយឡើង ( អំពីផែនដី ) ប៉ុណ្ណោះ ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបាន ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ១ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលី

ដែលហុយឡើងបាន តែថា លុះបានឃើញចុងនៃទង់ជ័យប៉ុណ្ណោះ ក៏រួញរា ជច់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលីដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន តែថា លុះបានឮសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលប៉ុណ្ណោះ ក៏រួញរា ជច់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៣ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលី ដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវពួកពលបាន តែថាក័ន្ទកាំងស្រឡាំងកាំង ក្នុងការប្រយុទ្ធគ្នា ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៤ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលីដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះ

ហើយ ឈ្មោះថាជាអ្នកឈ្នះសង្គ្រាម តែងបាននៅគ្រប់គ្រង នៅជាប្រធានលើសង្គ្រាមនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈទាំង ៥ ពួកនេះឯងតែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈនេះមាន ៥ ពួក តែងមានប្រាកដក្នុងពួកភិក្ខុ ក៏យ៉ាងនោះដែរ ។ បុគ្គល ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះបានឃើញនូវផង់ធូលី គឺលម្អរបស់មាតុគ្រាម ក៏លិចចុះទៅក្នុងមិច្ឆាវិតក្ក ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ដើម្បីភេទថោកទាបវិញ ។ អ្វីជាផង់ធូលីរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះឮដំណឹងថា ស្ត្រី ឬកុមារីក្នុងស្រុក ឬនិគមឈ្មោះឯណោះ មានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេក ។ ភិក្ខុនោះ លុះឮដំណឹងនោះហើយ ក៏លិចចុះទៅក្នុងមិច្ឆាវិតក្ក ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ដើម្បីភេទថោកទាបវិញ ។ នេះជាផង់ធូលីរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះគ្រាន់ តែបានឃើញនូវផង់ធូលីប៉ុណ្ណោះ ហើយ

ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបាន មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ឧបមាដូចយោធាជីវៈទី ១ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអត់ទ្រាំនូវផង់ធូលីបាន ប៉ុន្តែលុះបានឃើញនូវចុងនៃទង់ជ័យប៉ុណ្ណោះ ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយ ចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ដើម្បីភេទថោកទាបវិញ ។ អ្វីជាទង់ជ័យរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានឮដំណឹងថា ស្ត្រី ឬកុមារីក្នុងស្រុក ឬនិគមឈ្មោះឯណោះ មានរូបល្អ គួរមើលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេកទេ ប៉ុន្តែបើឃើញនូវស្ត្រី ឬកុមារីដែលមានរូបល្អ គួរមើលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេកដោយខ្លួនឯង លុះភិក្ខុនោះ បានឃើញនូវស្ត្រីនោះហើយ ក៏លិចចុះទៅក្នុងមិច្ឆាវិតក្ក ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រង នូវព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់ដើម្បីភេទថោកទាបវិញ ។ នេះជាចុងនៃទង់ជ័យរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន ប៉ុន្តែលុះបាន

ឃើញនូវចុងនៃទង់ជ័យប៉ុណ្ណោះហើយ ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអត់ទ្រាំនូវផង់ធូលីបាន ជាអ្នកអត់ទ្រាំនូវចុងនៃទង់ជ័យបាន ប៉ុន្តែ លុះបានឮសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលមកដល់ប៉ុណ្ណោះហើយ ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ អ្វីជាសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលនៃបុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបានចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលជាអ្នកអាស្រ័យនៅក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ក៏ញញឹម និយាយរក សើចក្អាកក្អាយ ចំអកចំអន់លេង ។ ភិក្ខុនោះ កាលបើមាតុគ្រាមញញឹម និយាយរក សើចក្អាកក្អាយ ចំអកចំអន់លេង ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។

នេះជាសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលនៃបុគ្គលនោះ ។ ម្នាលភិក្ខុទាំង-ឡាយ យោធាជីវៈនោះអត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន ប៉ុន្តែថា លុះបានឮសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលមកដល់ប៉ុណ្ណោះហើយ ក៏រួញរា ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីចុះកាន់សង្គ្រាមបានឡើយ មាន ឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មាន ឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ឧបមាដូចជា យោធាជីវៈទី ៣ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអត់ទ្រាំនូវផង់ធូលី បានអត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំ នូវសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលបាន ទាស់តែទៅកាន់តាំងស្រឡាំងកាំង ក្នុងការប្រយុទ្ធគ្នា ។ អ្វីជាការប្រយុទ្ធគ្នារបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំង-ឡាយ មាតុគ្រាមបានចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលជាអ្នកនៅអា-ស្រ័យក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ចូលទៅអង្គុយជិត ដេក ជិត ឱបរឹត ។ ភិក្ខុនោះកាលបើមាតុគ្រាម អង្គុយជិត ដេកជិត ឱបរឹត ក៏ មិនបានពោលលានូវសិក្ខា មិនបានប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំង ថយ ហើយក៏សេពនូវមេថុនធម្ម ។ នេះជាការប្រយុទ្ធគ្នារបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុង នៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលបាន ទាស់តែ

នៅកាន់កាំងស្រឡាំងកាំងក្នុងការប្រយុទ្ធគ្នា មានឧបមាដូចម្ដេចមិញ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឧបមាដូចយោធាជីវៈទី ៤ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុអត់ទ្រាំនូវ ផង់ធូលីបាន អត់ទ្រាំនូវចុងទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន ភិក្ខុនោះ បានឈ្នះនូវ សង្គ្រាមនោះហើយ ឈ្មោះថា ជាអ្នកឈ្នះនូវសង្គ្រាម តែងនៅគ្រប់គ្រងនៅ ជាប្រធានលើកងទ័ពនោះឯង ។ អ្វីជាការឈ្នះសង្គ្រាមរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបានចូលទៅរកភិក្ខុក្នុងសាសនានេះ ដែល ជាអ្នកអាស្រ័យនៅក្នុងព្រៃក្ដី ក្រោមម្លប់ឈើក្ដី ក្នុងផ្ទះស្ងាត់ក្ដី អង្គុយជិត ដេកជិត ឱបរឹត ។ ភិក្ខុនោះ កាលបើមាតុគ្រាមទៅអង្គុយជិត ដេកជិត ឱប រឹត ក៏រំលៀកខ្លួនចេញបាន ដោះខ្លួនចេញរួចហើយ ក៏ចៀសចេញទៅតាម ប្រាថ្នា ។ ភិក្ខុនោះតែងគប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល និងគំនរចំបើង ។ ភិក្ខុនោះជាអ្នកនៅ អាស្រ័យក្នុងព្រៃក្ដី ក្រោមម្លប់ឈើក្ដី ក្នុងផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែនតម្រង់ កាយឲ្យត្រង់ ប្រុងស្មារតីឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។ ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា

លះបង់ព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្ដីអនុគ្រោះសត្វទាំងពួងដោយប្រយោជន៍ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទជាគ្រឿងប្រទូស្ត លះបង់ថីនមិទ្ធៈ មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្ដីសម្គាល់ច្បាស់ក្នុងពន្លឺ មានសតិ មានសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មានចិត្តមិនរវើរវាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុង ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា មានចិត្តឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្ដីងឿងឆ្ងល់ក្នុងកុសលធម៌ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះលះនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យថយកម្លាំង ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវចតុត្ថជ្ឈាន ។ កាលបើចិត្តតាំងនៅល្អបរិសុទ្ធផូរផង់ មិនមានទីទួល ពោល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវធម៌ ដែលធ្វើនូវអាសវៈឲ្យអស់ទៅ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់នៃអាសវៈ ។ កាល

បើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរួចចាកកាមាសវៈផង ចិត្តរួចចាកភវាសវៈផង ចិត្តរួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចផុតស្រឡះ ( ចាកកាមាសវៈជាដើមហើយ ) សេចក្តីដឹងក៏កើតឡើងប្រាកដថា ចិត្តរួចស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ នេះជាជ័យជម្នះក្នុងសង្គ្រាមរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះអត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន យោធាជីវៈនោះ បានឈ្នះនូវសង្គ្រាមនោះហើយ ឈ្មោះថាជាអ្នកឈ្នះនូវសង្គ្រាម តែងនៅគ្រប់គ្រងនៅជាប្រធានលើសង្គ្រាមនោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ មានឧបមាដូចជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយមានឧបមាដូចជាពួកយោធាជីវៈទាំង ៥ នេះឯង តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។

# អដ្ឋកថា

## បឋមយោធាជីវសូត្រ

[ ៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមយោធាជីវសូត្រទី ៥ ដូចតទៅនេះ បទថា **យោធាជីវា** បានដល់ អ្នកចម្បាំងអាជីព ។ បទថា **រជគ្គំ** បានដល់ ផង់ធូលីដែលហុយឡើងអំពីផែនដីដែលបែក ព្រោះការជាន់ដោយជើងដំរី សេះជាដើម ។ បទថា **ន សន្ថម្ភតិ** បានដល់ ឈរបោះបង្គោលមិនបាន ។ បទថា **សហតិ រជគ្គំ** បានដល់ ឃើញផង់ធូលី ក៏អត់ធន់បាន ។ បទថា **ធជគ្គំ** បានដល់ ចុងទង់ជ័យដែលគេលើកឡើងលើខ្នងដំរី ខ្នងសេះជាដើម និងលើរថទាំងឡាយ ។ បទថា **ឧស្សាទនំ** បានដល់ សំឡេងកងរំពងរបស់ ដំរី សេះ រថ និងរបស់ពួកទាហាន ។ បទថា **សម្បហារេ** បានដល់ ការប្រហារត្រឹមតែតិចតួចដែលមកដល់ ។ បទថា **ហញ្ញតិ** បានដល់ ក្តៅក្រហាយ ចង្អៀតចង្អល់ ។ បទថា **ព្យាបជ្ជតិ** បានដល់ ដល់នូវវិបត្តិ លះនូវប្រក្រតីភាព ។ បទថា **សហតិ សម្បហារំ** បានដល់ ប្រកបដោយការប្រហារ ២ ឬ ៣ ដង ក៏អត់ធន់បាន ។ បទថា **តមេវ សង្គាមសីសំ** បានដល់ ស្ថានទីដែលតាំងបន្ទាយជ័យភូមិនោះឯង ។ បទថា **អជ្ឈាវសតិ** បានដល់ គ្រប់គ្រងប្រមាណ ៧ ថ្ងៃ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះថា ដើម្បីឧបការៈទំនុកបម្រុងដល់បុគ្គល ដែលត្រូវអាវុធឈឺចាប់ដើម្បីដឹងការពេញចិត្ត នៃកិច្ចដែលបដិបត្តិមកហើយ នឹងបានបំពាក់តំណែង និងដើម្បីសោយសុខក្នុងកាមជាធំ ។

ព្រោះព្រះសាស្ដាទ្រង់មិនមានកិច្ច ដោយពួកអ្នកចម្បាំងទាំងឡាយ តែទ្រង់នាំឧបមានេះមក ដើម្បីសម្ដែងបុគ្គល ៥ ពួកបែបនោះ ក្នុងព្រះសាសនានេះ ដូច្នោះ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងបុគ្គលទាំងនោះ ទើបត្រាស់ថា **ឯវមេវ ខោ** ជាដើម ។ ក្នុងបទនោះ បទថា **សំសីទតិ** បានដល់ រួញរាចិត្តចូលទៅក្នុងមិច្ឆាវិតក្ក ។ បទថា **ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ** បានដល់ គ្រប់គ្រងព្រហ្មចរិយវាស គឺការនៅប្រព្រឹត្តព្រហ្មចរិយៈមិនឲ្យដាច់ខ្សែមិនបាន ។ បទថា **សិក្ខាទុព្វល្យំ អាវិកត្វា** បានដល់ ប្រកាសភាពជាអ្នកខ្សោយកម្លាំងក្នុងសិក្ខា ។ ដោយបទថា **កិមស្ស រជគ្គស្មឹ** ត្រាស់ថា អ្វីឈ្មោះថា ចុងធូលីរបស់បុគ្គលនោះ ។

បទថា **អភិរូបា** ប្រែថា ស្អាត ។ បទថា **ទស្សនីយា** បានដល់ គួរដល់ការសរសើរ ។ បទថា **បាសាទិកា** បានដល់ នាំនូវការជ្រះថ្លាមកឲ្យចិត្ត ដោយការឃើញប៉ុណ្ណោះ ។ បទថា **បរមាយ** បានដល់ ឧត្ដម ។ បទថា **វណ្ណបោក្ខរតាយ** បានដល់ ដោយពណ៌សម្បុរនៃសរីរៈ និងដោយទ្រង់ទ្រាយនៃអវយវៈ ។ បទថា **ឱហសតិ** ប្រែថា អត់ធន់ ។ បទថា **ឧល្លបតិ** ប្រែថា ពោល ។ បទថា **ឧជ្ជគ្ឃតិ** បានដល់ ទះដៃសើចលេង ។ បទថា **ឧប្បណ្ឌេតិ** បានដល់ ចំអកចំអន់ ។ បទថា **អភិនិសីទតិ** បានដល់ អង្គុយជិតគ្នា ឬអង្គុយរួមអាសនៈគ្នា ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។

បទថា **អជ្ឈោត្ថរតិ** ប្រែថា សង្កត់ គឺឱបរឹត ។ បទថា **វិនិវេឋេត្វា**

**វិធិមោចេត្វា** បានដល់ ដោះ គឺបេះដៃរបស់ស្រីនោះអំពីទីដែលចាប់ ។ ពាក្យដ៏សេសក្នុងសេចក្តីនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។ ព្រះសូត្រនេះត្រាស់ដល់វដ្តៈ និងវិវដ្តៈ ។

## អដ្ឋកថា បឋមយោធាជីវសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយយោធាជីវសូត្រទី ៦

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ៥ ពួកនេះ តែងមានប្រាកដក្នុងលោក ។ យោធាជីវៈ ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ហើយចុះកាន់សង្គ្រាមដែលកំពុងប្រយុទ្ធគៀកគ្នា ។ យោធាជីវៈនោះ ខំព្យា-យាម ខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏បៀតបៀនសង្កត់សង្កិននូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាមខ្នះខ្នែងបាន ។ ម្នាលភិក្ខុទាំង-ឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ១ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ កាន់ដាវ និងខែល

សៀតធ្នូ និងបំពង់ព្រួញ ហើយចុះកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា ។ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏ចាកនូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាមខ្នះខ្នែងចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ។ យោធាជីវៈនោះ កាលពួកញាតិដែលកំពុងនាំទៅ មិនទាន់ដល់ផ្ទះរបស់ខ្លួន ឬសម្នាក់របស់ពួកញាតិ ក៏ធ្វើនូវមរណកាលក្នុងពាក់កណ្តាលផ្លូវទៅ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ហើយចុះកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា ។ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្នះខ្នែង បានចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកនូវយោធាជីវៈនោះទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ពួកញាតិក៏ទំនុកបម្រុងបម្រើ ក៏ធ្វើនូវមរណកាលដោយអាពាធនោះទៅ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៣ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញហើយ ចុះ

កាន់សង្គ្រាមដែលប្រយុទ្ធគៀកគ្នា ។ យោធាជីវៈនោះខំព្យាយាម ខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះដែលកំពុងតែខំព្យាយាមខ្នះខ្នែង បានចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ពួកញាតិក៏ទំនុកបម្រុង បម្រើនូវយោធាជីវៈនោះ ។ យោធាជីវៈនោះកាលបើពួកញាតិទំនុកបម្រុងបម្រើ ក៏បានជាសះស្បើយចាកអាពាធនោះទៅ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៤ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត យោធាជីវៈពួកខ្លះក្នុងលោកនេះ កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ហើយ ចុះកាន់សង្គ្រាមដែលប្រយុទ្ធគៀកគ្នា ។ យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះហើយ ឈ្មោះថា ជាអ្នកឈ្នះសង្គ្រាម តែងបាននៅគ្រប់គ្រងនៅជាប្រធានលើសង្គ្រាមនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈទាំង ៥ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈនេះ មាន ៥ ពួក តែងមានប្រាកដក្នុងភិក្ខុទាំងឡាយក៏យ៉ាងនេះដែរ ។ បុគ្គល ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅពឹងពាក់អាស្រ័យនឹងស្រុក ឬ

និគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុក ឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនបានតម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះឃើញមាតុគ្រាម ក្នុងស្រុក ឬនិគមនោះដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាមដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ ។ ភិក្ខុនោះកាលបើមានចិត្តត្រូវរាគៈអុចអាលហើយ ក៏មិនបានពោលលានូវសិក្ខា មិនបានប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយ ហើយក៏សេពនូវមេថុនធម្ម ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះខំព្យាយាមខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏បៀតបៀនចាប់ទុកនូវយោធាជីវៈនោះ ដែលកំពុងខំព្យាយាមខ្នះខ្នែង មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ មានឧបមាដូចជាយោធាជីវៈទី ១ តែងមានប្រាកដក្នុងភិក្ខុទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនូវស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅកាន់ស្រុក ឬនិគមនោះឯង ដើម្បីបិណ្ឌបាត

មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនតម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះឃើញមាតុគ្រាមក្នុងស្រុក ឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាម ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ ។ ភិក្ខុនោះកាលបើមានចិត្តត្រូវរាគៈអុចអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាម ហើយគប្បីប្រាប់ ( សេចក្ដីនេះ ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណាត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងនៅគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ នឹងពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏ទៅកាន់អារាម តែទៅមិនទាន់ដល់អារាមនៅឡើយ ក៏ប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាប ក្នុងដំណើរពាក់កណ្ដាលផ្លូវ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះកាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាមដែលប្រយុទ្ធគៀកគ្នា យោធាជីវៈនោះខំព្យាយាមខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាមខ្នះខ្នែងបានហើយ ចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ

ក៏នាំយកទៅឲ្យដល់ពួកញាតិ យោធាជីវៈនោះ កាលបើពួកញាតិនាំយកទៅ មិនទាន់ដល់សម្នាក់ញាតិទាំងឡាយ ក៏ធ្វើនូវមរណកាល ក្នុងដំណើរពាក់កណ្ដាលផ្លូវទៅ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនូវស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុក ឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនតម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះបានឃើញមាតុគ្រាមក្នុងស្រុក ឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាមដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ ។ ភិក្ខុនោះមានចិត្តត្រូវរាគៈអុចអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះមានចិត្តត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាម ហើយគប្បីប្រាប់ ( សេចក្ដីនេះ ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណាត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងនៅគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវ

ភាពនៃខ្លួនជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះ ក៏បានទៅកាន់អារាមហើយប្រាប់ ( សេចក្តីនោះ ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណាត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងនៅគ្រប់គ្រងព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខាវិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ពួកសព្រហ្មចារីក៏ទូន្មានប្រៀនប្រដៅភិក្ខុនោះថា ម្នាលអាវុសោ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជារាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាដុំសាច់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំង-ឡាយ មានឧបមាដូចគប់ភ្លើងស្មៅ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាគំនររងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាម នេះមានប្រមាណច្រើន

ណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចការយល់សប្តិ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជារបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាផ្លែឈើ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាកាំបិត និងជ្រញ់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាចុងលំពែង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ លោកដ៏មានអាយុ ចូរត្រេកអរក្នុងព្រហ្មចរិយធម៌ចុះ លោកដ៏មានអាយុកុំប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបឡើយ ។ ភិក្ខុនោះ កាលសព្រហ្មចារីបុគ្គល

ទាំងឡាយ ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏ពោលយ៉ាងនេះថា ម្នាល អាវុសោ កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ក៏ពិតមែន តែថា ខ្ញុំករុណាមិនអាចដើម្បីគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះ ក៏បានប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះកាន់ដាវ និងខែលសៀតធ្នូ និងបំពង់ព្រួញ ហើយចូលកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះខំព្យាយាមខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាមខ្នះខ្នែង បានចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ញាតិទាំងឡាយក៏ទំនុកបម្រុង បម្រើនូវយោធាជីវៈនោះ យោធាជីវៈនោះ កាលបើពួកញាតិទំនុកបម្រុងបម្រើ ក៏ធ្វើនូវកាលកិរិយា ដោយអាពាធនោះទៅ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមាន

ឧបមាដូចជាយោធាជីវៈទី ៣ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យហើយចូលទៅកាន់ស្រុក ឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយមិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនតម្កល់ស្មារតី មិនបានសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះបានឃើញមាតុគ្រាមក្នុងស្រុក ឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាមដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ ។ ភិក្ខុនោះមានចិត្តត្រូវរាគៈអុចអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាមហើយគប្បីប្រាប់ ( សេចក្តីនេះ ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណាត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខាវិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏ទៅកាន់អារាម ហើយប្រាប់ ( សេចក្តីនោះ ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ខ្ញុំករុណាត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ ខ្ញុំករុណាមិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយ

ចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទដ៏ថោកទាបវិញ ។ សព្រហ្មចារីបុគ្គលទាំងឡាយ ក៏ទូន្មានប្រៀនប្រដៅនូវភិក្ខុនោះថា ម្នាលអាវុសោ កាមទាំងឡាយ មានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចរាងឆ្អឹង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំង-ឡាយ មានឧបមាដូចជាដុំសាច់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ...កាមទាំងឡាយ មានឧបមាដូចជាគប់ភ្លើងស្មៅ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាគំនររងើកភ្លើង ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាយល់សប្ដិ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជារបស់ខ្ចីគេ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាផ្លែឈើ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាកាំបិត និងជ្រញ់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាចុងលំពែង ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាក្បាលពស់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់

ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ លោកដ៏មានអាយុ ចូរត្រេកអរក្នុងព្រហ្មចរិយធម៌ចុះ លោកដ៏មានអាយុ កុំប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញឡើយ ។ ភិក្ខុនោះ កាលសព្រហ្មចារីបុគ្គលទាំងឡាយទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏ពោលយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ខ្ញុំករុណានឹងព្យាយាម ម្នាលអាវុសោ ខ្ញុំករុណានឹងទ្រទ្រង់ ម្នាលអាវុសោ ខ្ញុំករុណានឹងត្រេកអរ ម្នាលអាវុសោ ឥឡូវនេះ ខ្ញុំករុណាមិនទាន់ប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញទេ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះកាន់ដាវ និងខែល សៀតនូវធ្នូ និងបំពង់ព្រួញ ហើយចូលកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះ ខំព្យាយាមខ្នះខ្នែងក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏ចាក់នូវយោធាជីវៈនោះឯង ដែលកំពុងតែខំព្យាយាមខ្នះខ្នែងបាន ក៏ចាប់នូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ញាតិទាំងឡាយ ពួកញាតិក៏ទំនុកបម្រុងបម្រើនូវយោធា-ជីវៈនោះ យោធាជីវៈនោះ កាលបើពួកញាតិទំនុកបម្រុងបម្រើ ក៏បានសះស្បើយចាកអាពាធនោះទៅ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ

បុគ្គលនេះ ឧបមាដូចជាយោធាជីវៈទី ៤ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុក ឬនិគមនោះដើម្បីបិណ្ឌបាត បានរក្សាកាយ រក្សាវាចា រក្សាចិត្ត តម្កល់ស្មារតី សង្រួមឥន្ទ្រិយ ។ ភិក្ខុនោះឃើញនូវរូបដោយចក្ខុហើយ តែមិនបានក្តោបកាន់នូវនិមិត្ត មិនបានក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្សដែលជាអកុសលធម៌ដ៏លាមក តែងជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក ... បានធុំក្លិនដោយច្រមុះ ... បានទទួលរសដោយអណ្តាត ... បានពាល់ត្រូវនូវផ្សព្វដោយកាយ ... បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែមិនបានក្តោបកាន់នូវនិមិត្ត មិនបានក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ លុះត្រឡប់មកពីបិណ្ឌបាតក្នុងវេលាក្រោយភត្តហើយ តែងគប់រកនូវសេនាសនៈដ៏ស្ងាត់ គឺព្រៃម្រប់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃស្មសាន ជង្គព្រៃ ទីវាល ទីគំនរចំបើង ឬ

ស្ទឹកឈើ ។ ភិក្ខុនោះ ជាអ្នកអាស្រ័យនៅក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះដ៏ស្ងាត់ក្តី ក៏អង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះ ( ទៅកាន់ព្រះកម្មដ្ឋាន ) ភិក្ខុនោះ ក៏លះបង់នូវអភិជ្ឈាក្នុងលោក ។បេ។ ភិក្ខុនោះក៏លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសនៃចិត្ត អាចធ្វើបញ្ញាឲ្យមានកម្លាំងថយ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានចូលកាន់ចតុត្ថជ្ឈាន ។ កាលដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេសប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ។ ភិក្ខុនោះក៏ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ភិក្ខុនោះដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះកាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ហើយចូលកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះហើយ ក៏ឈ្មោះថាជាអ្នកឈ្នះសង្គ្រាម នៅគ្រប់គ្រង នៅជាប្រធានលើសង្គ្រាមនោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈទាំង ៥ នេះឯង តែងមាន

ប្រាកដក្នុងភិក្ខុទាំងឡាយ ។

# អដ្ឋកថា

## ទុតិយយោធាជីវសូត្រ

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយយោធាជីវសូត្រទី ៦ ដូចតទៅនេះ បទថា **អសិចម្មំ គហេត្វា** កាន់យកដាវ និងខែល ។ បទថា **ធនុកលាបំ សន្នយ្ហិត្វា** បានដល់ ស៊កធ្នូនឹងបន្ទោះធ្នូ ។ បទថា **វិយូឡ្ហំ** បានដល់ តាំងនៅដោយការប្រឈមមុខច្បាំង ។ បទថា **សង្គាមំ ឱតរតិ** បានដល់ ចូលកាន់សង្គ្រាមធំ ។ បទថា **ឧស្សហតិ វាយមតិ** បានដល់ ធ្វើឧស្សាហ៍ គឺព្យាយាម ។ បទថា **ហនន្តិ** ប្រែថា សម្លាប់ ។ បទថា **បរិយាទេន្តិ** បានដល់ ទន់ទាញ គឺសង្កត់សង្កិន ។ បទថា **ឧបលិក្ខន្តិ** បានដល់ ចាក់ ។ បទថា **អបនេន្តិ** បានដល់ នាំទាហានបក្ខពួកខ្លួនទៅ ។ បទថា **អបនេត្វា ញាតកានំ នេន្តិ** បានដល់ នាំទាហានខាងខ្លួនបញ្ជូនទៅឲ្យញាតិ ។ បទថា **នីយមានោ** បានដល់ នាំទៅកាន់ផ្ទះខ្លួន ឬសម្នាក់ញាតិដ៏សេស ។ បទថា **ឧបដ្ឋហន្តិ បរិចរន្តិ** បានដល់ ធ្វើនូវការសម្អាតគ្រឿងប្រហារ និងព្យាបាលរបួសជាដើម ទំនុកបម្រុងថែរក្សា ។

បទថា **អរក្ខិតេនេវ កាយេន** បានដល់ មានកាយទ្វារមិនបានរក្សា ។ បទថា **អរក្ខិតាយ វាចាយ** បានដល់ មានវចីទ្វារមិនបានរក្សា ។ បទថា **អរក្ខិតេន ចិត្តេន** បានដល់ មានមនោទ្វារដែលមិនបានរក្សា ។ បទថា **អនុបដ្ឋិតាយ សតិយា** បានដល់ មិនធ្វើសតិឲ្យតាំងទុកដោយល្អ ។ បទថា **អសំវុតេហិ ឥន្ទ្រិយេហិ** បានដល់ មានឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ មិនបានរាំង មិនបានគ្រប់គ្រងហើយ ។ បទថា **រាគោ ចិត្តំ អនុទ្ធំសេតិ** បានដល់ រាគៈកាលកើតឡើង រមែងកម្ចាត់ចិត្តក្នុងសមថៈ និងវិបស្សនា គឺគ្រវែងទៅឆ្ងាយ ។ បទថា **រាគាយិតោម្ហិ អាវុសោ រាគបរេតោ** សេចក្តីថា អាវុសោ ខ្ញុំត្រូវរាគៈជ្រលក់ហើយ ត្រូវរាគៈតាមដល់ហើយ ។

ក្នុងបទថា **អដ្ឋិកង្កលូបមា** ជាដើម កាមទាំងឡាយប្រៀបដូចកំណាត់ឆ្អឹង ព្រោះអត្ថថា មានការឆ្ងាញ់តិច ប្រៀបដូចដុំសាច់ ព្រោះអត្ថថា ទូទៅដល់មនុស្សចំនួនច្រើន ប្រៀបដូចគប់ស្មៅ ព្រោះអត្ថថា តាមដុតឲ្យក្តៅផ្សា ប្រៀបដូចរងើកភ្លើង ព្រោះអត្ថថា ធ្វើនូវការក្តៅច្រើន ប្រៀបដូចយល់សប្តិ ព្រោះអត្ថថា ប្រាកដឡើងតិចតួច ប្រៀបដូចរបស់ខ្ចីគេ ព្រោះអត្ថថា នៅបានមួងម្កាល ប្រៀបដូចផ្លែឈើ ព្រោះអត្ថថា បាក់អស់ទាំងដើម ប្រៀបដូចជ្រញ់ចិញ្ច្រាំសាច់ ព្រោះអត្ថថា ជាទីរងមុខកាំបិត ប្រៀបដូចចុងលំពែង ព្រោះអត្ថថា ចាក់ទម្លុះ ប្រៀបដូចក្បាលពស់ ព្រោះអត្ថថា គួររង្កៀស គួរមានភ័យ ។

បទថា **ឧស្សហិស្សាមិ** បានដល់ នឹងធ្វើឧស្សាហ៍ ។ បទថា **ធារ–**

**យិស្សាមិ** បានដល់ ទ្រទ្រង់នូវភាពជាសមណៈ ។ បទថា **អភិរមិស្សាមិ** បានដល់ ធ្វើនូវការត្រេកអរក្រៃលែងឲ្យកើតឡើង អធិប្បាយថា មិនអផ្សុកចង់សឹក ។ ពាក្យដ៏សេស ក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់វដ្ដៈផង វិវដ្ដៈផង ដូច្នេះ ។

**អដ្ឋកថា ទុតិយយោធាជីវសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអនាគតសូត្រទី ៧

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភ័យ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ពស់គប្បីចឹកអាត្មាអញក្ដី ខ្យាដំរីគប្បីទិចអាត្មាអញក្ដី

ក្អួបគប្បីខាំអាត្មាអញក្តី ដែលនៅក្នុងព្រៃតែម្នាក់ឯង កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ អន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ១ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាម ញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ក៏កាលដែលអាត្មាអញ នៅក្នុងព្រៃតែម្នាក់ឯង គប្បីភ្លាត់ជួលទៅក្តី កត្តដែលអាត្មាអញបរិភោគហើយ គប្បីឲ្យទោសក្តី ប្រមាត់របស់អាត្មាអញ គប្បីកម្រើកឡើងក្តី ស្លេស្មរបស់អាត្មាអញ គប្បីកម្រើកឡើងក្តី ខ្យល់ទាំងឡាយ ដែលមានមុខមុតដូចជាកាំបិត គប្បីកម្រើកឡើងក្តី កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណ

វិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ក៏កាលដែលអាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងម្រឹគសាហាវទាំងឡាយ គឺរាជសីហ៍ក្តី ខ្លាធំក្តី ខ្លាដំបងក្តី ខ្លាឃ្មុំក្តី ខ្លាត្រីក្តី ម្រឹគសាហាវទាំងនោះ គប្បីផ្តាច់បង់អាត្មាអញចាកជីវិត កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៣ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះ

និព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ក៏កាលដែលអាត្មាអញ នៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងពួកចោរ ដែលធ្វើចោរកម្មហើយក្តី ដែលមិនទាន់បានធ្វើចោរកម្មក្តី ចោរទាំងនោះ គប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៤ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ប្រសិនបើមានអមនុស្សកំណាច

នៅក្នុងព្រៃ អមនុស្សក្រំណាចទាំងនោះ គប្បីផ្តាច់បង់នូវអាត្មាអញ ចាកជីវិតទៅ កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៥ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទាំង ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ មានព្យាយាមញាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

# អដ្ឋកថា

## បឋមអនាគតសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអនាគតសូត្រទី ៧ ដូចតទៅនេះ បទថា **អារញ្ញកេន** ប្រែថា ជាអ្នកនៅព្រៃ ។ បទថា **អប្បត្តស្ស** បានដល់ ដើម្បីដល់នូវគុណវិសេស មានឈាន វិបស្សនា និងមគ្គផល ដែលមិនទាន់ដល់ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សោ មមស្ស អន្តរាយោ** សេចក្ដីថា អន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈនោះ គប្បីមានដល់អាត្មាអញ ។ អន្តរាយនៃសួគ៌ និងអន្តរាយនៃមគ្គ គប្បីមានដល់ភិក្ខុដែលធ្វើកាលកិរិយាទាំងបុថុជ្ជន ។ បទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថរបស់ខ្លួនឯង ។

បទថា **វិរិយំ អារភាមិ** បានដល់ អាត្មាអញនឹងធ្វើសេចក្ដីព្យាយាម ២ យ៉ាង ។ បទថា **សត្ថកា** បានដល់ ខ្យល់ដែលកាត់ទី-ត និងសរសៃដូចសស្ត្រា ។ បទថា **វាឡេហិ** ប្រែថា កាច ។ បទថា **មាណវេហិ** បានដល់ ចោរ ។ ក្នុងពាក្យថា **កតកម្មេហិ វា អកតកម្មេហិ វា** នេះ ចោរទាំងឡាយដែលធ្វើចោរកម្មហើយ ឈ្មោះថា ជាអ្នកធ្វើកម្មហើយ ជាអ្នកចេញទៅដើម្បីធ្វើចោរកម្ម ឈ្មោះថា ជាអ្នកមិនទាន់បានធ្វើកម្ម ។ បណ្ដាចោរ ២ ពួកនោះ ពួកចោរដែលកាន់យកឈាមក្នុងបំពង់ករបស់សត្វទាំងឡាយ ធ្វើពលិកម្មដល់ទេវតា ឈ្មោះថា ធ្វើកម្មហើយ ព្រោះកម្មសម្រេចហើយ ពួកចោរធ្វើនូវការបួងសួងជាមុន ដោយគិតថា កម្មរបស់យើង នឹងសម្រេចផល

ដោយវិធីយ៉ាងនេះ ឈ្មោះថា មិនទាន់ធ្វើកម្ម ។ ទ្រង់សំដៅយកសេចក្តីនេះ ទើបត្រាស់ថា ចោរទាំងនោះគប្បីផ្តាច់ជីវិតអាត្មាអញ ដូច្នេះ ។ បទថា **វាឡា អមនុស្សា** បានដល់ ពួកអមនុស្សក្រាច មានយក្ខជាដើមដែលកាចឃោរឃៅ ។ល។

**អដ្ឋកថាបឋមអនាគតសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយអនាគតសូត្រទី ៨

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញ នូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញដូច្នេះថា ឥឡូវនេះអាត្មាអញនៅក្មេងកំលោះ ជំទង់ មានសក់ខ្មៅស្រិលប្រកបដោយវ័យចម្រើន គឺបឋមវ័យនៅឡើយ សម័យដែលជរាមកប៉ះពាល់នូវរាងកាយនេះ រមែងមានដោយពិត ក៏កាយដែលចាស់គ្រាំគ្រា ត្រូវជរាមក

គ្របសង្កត់ហើយ មិនងាយនឹងធ្វើទុកក្នុងចិត្ត នូវពាក្យប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកនូវសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាម ឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញជាអ្នកប្រកបដោយធម៌ណា សូម្បីខ្លួនចាស់ជរាហើយ ក៏នឹងនៅជាសុខដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើពិចារណាឃើញនូវអនាគតភ័យទី ១ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញមានអាពាធតិច មានទុក្ខតិច ប្រកបដោយភ្លើងធាតុដែលដុតកម្តៅស្មើគ្នា មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម សម័យដែលព្យាធិមកប៉ះពាល់នូវរាងកាយនេះ រមែងមានដោយពិត ក៏កាយដែលមានព្យាធិ ត្រូវព្យាធិមក

គ្របសង្កត់ហើយ មិនងាយនឹងធ្វើទុកក្នុងចិត្ត នូវពាក្យប្រដៅនៃព្រះសម្មា-

សម្បូរបាន មិនងាយនឹងគប់រកនូវសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាម ឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីមានព្យាធិ ក៏នឹងនៅជាសុខដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើពិចារណាឃើញនូវអនាគតភ័យទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ សម្ទូងល្អ បិណ្ឌបាតបានងាយ ស្រួលដើម្បីនឹងព្យាយាមស្វែងរកមកចិញ្ចឹមជីវិតបានងាយ ក៏សម័យដែលមានទុរ្ភិក្ស សម្ទូងមិនល្អ បិណ្ឌបាតបានដោយក្រ មិនងាយដើម្បីនឹងព្យាយាម ស្វែងរកមកចិញ្ចឹមជីវិតបានឡើយ មនុស្សទាំងឡាយ ក៏តែងទៅកាន់ទីដែលមានភិក្ខាងាយ ក្នុងវេលាដែលស្រុកកើតមានទុរ្ភិក្ស ការនៅច្រឡូកច្រឡំ ការនៅដេរដាស ក្នុងទីដែលមានភិក្ខាងាយនោះ រមែងមាន កាលបើការនៅច្រឡូកច្រឡំ ការនៅដេរដាសមាន

ហើយ មិនងាយនឹងធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធ បានទេ មិនងាយនឹងគប់រកសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្ដីព្យាយាម ឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីក្នុងទុរ្ភិក្ស-សម័យ ក៏នឹងនៅសប្បាយដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៣ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ មនុស្សទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយដោយទឹក ក្រឡេកមើលគ្នានិងគ្នា ដោយចក្ខុជាទីស្រឡាញ់ ក៏សម័យដែលមានភ័យ គឺចោរកម្រើកក្នុងដងព្រៃហើយ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយាន ហើយបរទៅ ( កាន់ទិសផ្សេងៗ ) ក៏កាលបើភ័យមានហើយ មនុស្សទាំងឡាយ តែងទៅកាន់ទីដ៏ក្សេមក្សាន្ត ការ

នៅប្រទូ្បកប្រទ្បំ ការនៅដេរដាសក្នុងទីនោះ រមែងមាន កាលបើការនៅប្រទូ្បកប្រទ្បំគ្នា ការនៅដេរដាសមានហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាម ឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីក្នុងវេលាមានភ័យ ក៏នឹងនៅសប្បាយដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៤ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ សង្ឃជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅសប្បាយ សម័យដែលសង្ឃបែកបាក់គ្នា រមែងមានដោយពិត កាលបើសង្ឃបែកបាក់គ្នាហើយ មិនងាយនឹងធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធ

បាន មិនងាយនឹងគប់រកសេនាសនៈស្ងាត់ គឺជង្គព្រៃបានឡើយ ធម៌ដែល មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាម ឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា កាលបើសង្ឃបែកបាក់គ្នាហើយ ក៏នឹងនៅសប្បាយដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៥ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

# អដ្ឋកថា

## ទុតិយអនាគតសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអនាគតសូត្រទី ៨ ដូចតទៅនេះ បទថា **បុរា មំ សោ ធម្មោ អាគច្ឆតិ** សេចក្តីថា ធម៌នោះមិនទាន់មកដល់អាត្មាអញដរាបណា អាត្មាអញក៏នឹងផ្តើមសេចក្តីព្យាយាមមុនដរាបនោះ ។ បទថា **ខីរោទកីភូតា** បានដល់ ដល់នូវភាពតែមួយ ដូចគ្នានឹងទឹកជាមួយទឹកដោះ ។ បទថា **បិយចក្ខូហិ** បានដល់ ដោយភ្នែកពេញទៅដោយមេត្តា ។ល។

**អដ្ឋកថា ទុតិយអនាគតសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## តតិយអនាគតសូត្រទី ៩

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ អនាគតភ័យនេះមាន ៥ យ៉ាង មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់ នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់ នូវអនាគតភ័យទាំងនោះចេញ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយ

នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ បើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ នឹងញ៉ាំងបុគ្គលដទៃឲ្យឧប-សម្បទ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មាន ក្នុងអធិសីល អធិចិត្ត និងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ នឹងញ៉ាំងបុគ្គលដទៃឲ្យឧបសម្បទ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មានក្នុងអធិសីល អធិចិត្ត និងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះ មុខជានឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ១ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចោលចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ បើភិក្ខុទាំងនោះមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើន

ចិត្ត មិនបានចម្រើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯង ក៏មិនអាចដើម្បីនឹងទូន្មាន ក្នុងអធិសីល អធិចិត្ត និងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មានក្នុងអធិសីល អធិចិត្ត និងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះ មុខជានឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ២ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា ហើយសម្តែងនូវអភិធម្មកថា និងវេទល្លកថា ឈានចុះទៅកាន់ធម៌ខ្មៅ ក៏មិនដឹងខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌

ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៣ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់ នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ពួកព្រះសូត្រណា ដែលជាតថាគតភាសិត ជ្រាលជ្រៅ ( ដោយបាលី ) ជ្រាលជ្រៅដោយអត្ថជាលោកុត្តរធម៌ ប្រកបដោយការៈសោះសូន្យ កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល ( ជនដទៃ ) ក៏មិនប្រាថ្នាដើម្បីស្តាប់ មិនផ្ទៀងត្រចៀកប្រុងស្តាប់ មិនតាំងចិត្តដើម្បីចង់ដឹងសោះ ទាំងមិនសម្គាល់នូវកិច្ច ដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះឡើយ បើពួកព្រះសូត្រណា ដែលកវីតាក់តែងជាពាក្យកាព្យឃ្លោង មានអក្ខរៈដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រ ជាពាក្យខាងក្រៅ ជាភាសិតរបស់សាវកខាងក្រៅ កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល ( ទើបពួកជនដទៃ ) នឹងប្រាថ្នាចង់ស្តាប់ ផ្ទៀងត្រចៀកប្រុងស្តាប់ តាំងចិត្តដើម្បីចង់ដឹង ទាំងសម្គាល់នូវកិច្ចដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះ

ខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៤ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ភិក្ខុទាំងឡាយជាថេរៈ នឹងមានសេចក្តីល្មោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធានក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រាថ្នាសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ នឹងដល់នូវទិដ្ឋានុគតិតាមពួកភិក្ខុ ដែលជាអ្នកល្មោភច្រើននោះ សូម្បីប្រជុំជន ដែលកើតខាងក្រោយនោះទៀត ក៏នឹងមានសេចក្តីល្មោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធានក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រាថ្នាសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ

ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៥ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់ នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ អនាគតភ័យទាំង ៥ យ៉ាងនេះឯង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាម ដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។

# អដ្ឋកថា

## តតិយអនាគតសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអនាគតសូត្រទី ៩ ដូចតទៅនេះ បទថា **ធម្មសន្ទោសា វិនយសន្ទោសោ** បានដល់ ការកាត់បង់នូវវិន័យរមែងមាន ព្រោះខូចនូវធម៌ ។ សួរថា កាលធម៌ខូច វិន័យឈ្មោះថា ខូចដូចម្ដេច ។ ឆ្លើយថា កាលធម៌ គឺសមថវិបស្សនាមិនតាំងគត៌ វិន័យ ៥ យ៉ាងក៏មិនមាន ។ កាលធម៌ខូចយ៉ាងនេះ វិន័យក៏ឈ្មោះថា ខូច ចំណែកសម្រាប់ភិក្ខុទ្រុស្តសីល ឈ្មោះថា សំវរវិន័យមិនមាន កាលសំវរវិន័យនោះមិនមាន

សមថៈ និងវិបស្សនាក៏មិនតាំងគតិ ។ ការខូចធម៌ ព្រោះខូចវិន័យ ក៏គប្បីជ្រាបដោយន័យយ៉ាងនេះ ។

បទថា **អភិធម្មកថំ** បានដល់ កថាពោលដោយធម៌ដ៏ក្រៃលែង មានសីលជាដើម ។ បទថា **វេទល្លកថំ** បានដល់ កថាលាយដោយញាណដែលប្រកបដោយការដឹង ។ បទថា **កណ្ហំ ធម្មំ ឱក្កមមានា** បានដល់ ឈានចុះកាន់កម្មចំណែកខ្មៅ ដោយការស្វែងរក ដោយការប្រណាំងប្រជែង ព្រោះស្វែងរកខុស ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយ វាយបុគ្គលដោយចិត្តប្រទូស្តក្តី សាងកម្មចំណែកខ្មៅនោះសម្រាប់ខ្លួនក្តី ពោលដើម្បីលាភសក្ការៈក្តី ឈ្មោះថា ឈានចុះកាន់ធម៌ចំណែកខ្មៅដូចគ្នា ។

បទថា **គម្ភីរា** បានដល់ ជ្រៅដោយបាលី ។ បទថា **គម្ភីរត្ថា** បានដល់ ជ្រៅដោយអត្ថ ។ បទថា **លោកុត្តរា** បានដល់ សម្តែងលោកុត្តរធម៌ ។ បទថា **សុញ្ញតាបដិសំយុត្តា** បានដល់ ប្រកបដោយខន្ធ ធាតុ អាយតនៈ និងបច្ចយាការ ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋបេស្សន្តិ** ប្រែថា នឹងមិនតាំងចិត្តដើម្បីដឹង ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** បានដល់ គប្បីសិក្សា គប្បីរៀន ។ បទថា **កវិកតា** បានដល់ ដែលកវីតែងដោយចងជាពាក្យស្លោកជាដើម ។ បទថា **កាវេយ្យា** ជាវេវចនៈនៃពាក្យថា **កវិកតា** នោះឯង ។ បទថា **ពាហិរកា** បានដល់ ដែលតាំងនៅខាងក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** បានដល់ ដែលសាវកខាងក្រៅព្រះសាសនាពោល។

ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ ព្រោះមានន័យដែលបានពោលហើយខាងដើម និងព្រោះដឹងបានងាយ ៗ៚

## អដ្ឋកថា តតិយអនាគតសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ចតុត្ថអនាគតសូត្រទី ១០

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ អនាគតភ័យនេះមាន ៥ យ៉ាង មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យទាំងនោះចេញ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត នឹងមានពួកភិក្ខុ ជាអ្នកប្រាថ្នាល្អក្នុងចីវរ កាលបើភិក្ខុទាំងនោះ ប្រាថ្នាល្អក្នុងចីវរហើយ មុខជានឹងលះបង់នូវបង្សុកូលិកធុតង្គ នឹងលះបង់នូវសេនាសនៈស្ងាត់ គឺដងព្រៃ នឹងចូលទៅសម្រេចការនៅក្នុងស្រុក ក្នុងនិគម ឬក្នុងព្រះរាជធានីទាំង-ឡាយ មួយយ៉ាងទៀត នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗព្រោះហេតុតែចីវរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ១ មិនទាន់

កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បី លះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុង កាលដ៏យូរអង្វែងទៅក្នុងអនាគត នឹងមានពួកភិក្ខុ អ្នកប្រាថ្នាល្អក្នុងបិណ្ឌបាត កាលបើភិក្ខុទាំងនោះ ប្រាថ្នាល្អក្នុងបិណ្ឌបាតហើយ មុខជានឹងលះបង់បិណ្ឌ-បាតិកធុតង្គ នឹងលះបង់នូវសេនាសនៈស្ងាត់ គឺដងព្រៃចោលចេញ ហើយនឹង ចូលទៅសម្រេចការនៅក្នុងស្រុក ឬនិគម ឬក្នុងព្រះរាជធានីទាំងឡាយ មួយ យ៉ាងទៀត ( ភិក្ខុទាំងនោះ ) ស្វែងរកនូវរសទាំងឡាយដ៏ប្រសើរ ដោយ ចុងអណ្តាតហើយ នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗ ព្រោះហេតុតែបិណ្ឌបាត ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ២ មិន ទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំង-ឡាយគួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាម ដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុង កាលដ៏យូរអង្វែងទៅក្នុងអនាគត នឹងមានពួកភិក្ខុ អ្នកប្រាថ្នាល្អក្នុងសេនា-សនៈ កាលបើភិក្ខុទាំងនោះ ប្រាថ្នាល្អក្នុងសេនាសនៈហើយ មុខជានឹងលះបង់ អារញ្ញិកធុតង្គ នឹងលះបង់នូវសេនាសនៈស្ងាត់ គឺដងព្រៃ ហើយនឹងចូលទៅ សម្រេចការនៅក្នុងស្រុក ឬនិគម ឬក្នុងព្រះរាជធានីទាំងឡាយ មួយយ៉ាង ទៀត នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗ ព្រោះហេតុតែ

សេនាសនៈ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៣ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត នឹងមានពួកភិក្ខុ នៅប្រឡូកប្រឡំគ្នា ដោយពួកភិក្ខុនី សិក្ខមានា និងសមណុទ្ទេស ម្នាលភិក្ខុទាំងឡាយ កាលបើការនៅប្រឡូកប្រឡំ ដោយពួកភិក្ខុនី សិក្ខមានា និងសមណុទ្ទេសមានហើយ អំពើនេះនឹងប្រាកដឡើង គឺថា ពួកភិក្ខុ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈផង នឹងត្រូវអាបត្តិដែលសៅហ្មងឯណានីមួយផង នឹងពោលលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញផង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៤ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំង-ឡាយគួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត នឹងមានពួកភិក្ខុ នៅប្រឡូកប្រឡំដោយពួកអារាមិកជន និងសមណុទ្ទេស ម្នាលភិក្ខុទាំងឡាយ កាលបើការនៅប្រឡូកប្រឡំ ដោយពួកអារាមិកជន និងសមណុទ្ទេសមានហើយ អំពើនេះនឹងប្រាកដឡើង គឺថាពួកភិក្ខុនឹងប្រកបរឿយៗ នូវការបរិភោគនូវវត្ថុដែលខ្លួនសន្សំទុក មានប្រការផ្សេងៗ ទាំងធ្វើនូវនិមិត្តដ៏ជ្រោកជ្រាក ដោយផែនដីខ្លះ

ដោយចុងស្មៅខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៥ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់ នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ អនាគតភ័យ ៥ យ៉ាងនេះឯង មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យទាំងនោះចោលចេញ ។

យោធាជីវវគ្គទី ៣ ចប់

## ឧទ្ទាននៃយោធាជីវវគ្គនោះគឺ

និយាយអំពីចេតោវិមុត្តិ ២ លើក ធម្មវិហារិបុគ្គល ២ លើក
ពួកយោធាជីវៈ ២ លើក និងអនាគតភ័យ ៤ លើក ។

# អដ្ឋកថា

## ចតុត្ថអនាគតសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុត្ថអនាគតសូត្រទី ១០ ដូចតទៅនេះ បទថា **កល្យាណកាមា** ប្រែថា ជាអ្នកប្រាថ្នាល្អ ។ បទថា **រសគ្គានិ** បាន

*ដល់ រសដ៏កំពូល ។ បទថា* **សំសដ្ឋា វិហរិស្សន្តិ** *បានដល់ នៅលាយឡំដោយសំសគ្គៈ ៥ យ៉ាង ។ ក្នុងបទថា* **សន្និធិការបរិភោគំ** *បានដល់ បរិភោគរបស់ដែលជាសន្និធិ គឺសន្សំទុកខុសវិន័យ ។ ក្នុងបទថា* **ឱឡារិកំបិ និមិត្តំ** *នេះ ភិក្ខុជីកដីឯងក្តី ប្រើឲ្យគេជីកក្តី ឈ្មោះថា ធ្វើនិមិត្តគ្រោតគ្រាតក្នុងផែនដី ។ ភិក្ខុកាត់ឯងក្តី ប្រើឲ្យអ្នកដទៃកាត់ក្តីនូវស្មៅ ឈើ មែកឈើ ស្លឹកឈើ ឈ្មោះថា ធ្វើនិមិត្តដ៏គ្រោតគ្រាតក្នុងរបស់មានពណ៌ខៀវ ។ ភិក្ខុឲ្យគេកាន់យកស្លឹកឈើ និងបន្លែជាដើមទុកឯងក្តី ប្រើឲ្យអ្នកដទៃទុកក្តីនូវផ្លែឈើ ដើម្បីចិញ្ចឹមជីវិត ក៏មិនចាំបាច់ពោលឡើយ ។ ក្នុងសូត្រទាំង ៤ នេះ ព្រះសាស្តាត្រាស់នូវការចម្រើន និងការវិនាស ក្នុងព្រះសាសនា ៕*

**អដ្ឋកថាចតុត្ថអនាគតសូត្រទី ១០ ចប់**

**យោធាជីវវគ្គទី ៣ ចប់**

# សុត្តន្តបិដក

# ថេរវគ្គទី ៤

## វជនីយសូត្រទី ១

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើររបស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុត្រេកអរក្នុងអារម្មណ៍ជាទីត្រេកអរ ១ ប្រទូស្តក្នុងអារម្មណ៍ជាទីប្រទូស្ត ១ ភ័ន្តវង្វេងក្នុងអារម្មណ៍ជាទីភ័ន្តវង្វេង ១ ញាប់ញ័រក្នុងអារម្មណ៍ជាទីញាប់ញ័រ ១ស្រវឹងក្នុងអារម្មណ៍ជាទីស្រវឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុមិនត្រេកអរក្នុងអារម្មណ៍ជាទីត្រេកអរ ១ មិនប្រទូស្តក្នុងអារម្មណ៍ជាទីប្រទូស្ត ១ មិនភ័ន្តវង្វេងក្នុងអារម្មណ៍ជាទីភ័ន្តវង្វេង ១ មិនញាប់ញ័រក្នុងអារម្មណ៍ជាទីញាប់ញ័រ ១ មិនស្រវឹងក្នុងអារម្មណ៍ជាទីស្រវឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត

ជាទីគោរព ជាទីសរសើររបស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា

## ថេរវគ្គទី ៤

### រជនីយសូត្រ

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរជនីយសូត្រទី ១ នៃថេរវគ្គទី ៤ ដូច្នេះ បទថា **រជនីយេសុ** បានដល់ ក្នុងអារម្មណ៍ទាំងឡាយ ដែលជាបច្ច័យបន្ថែមនូវរាគៈ ។ ក្នុងបទដ៏សេស ក្នុងទីនេះក៏ដូចគ្នា ៕

**អដ្ឋកថា រជនីយសូត្រទី ១ ចប់**

# សុត្តន្តបិដក

### វីតរាគសូត្រទី ២

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ

របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនទាន់ប្រាសចាករាគៈ ១ មិនទាន់ប្រាសចាកទោសៈ ១ មិនទាន់ប្រាសចាកមោហៈ ១ ជាអ្នកលុបគុណគេ ១ ប្រណាំងប្រជែងវាសនា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកប្រាសចាករាគៈ ១ ប្រាសចាកទោសៈ ១ ប្រាសចាកមោហៈ ១ មិនលុបគុណគេ ១ មិនប្រណាំងប្រជែងវាសនា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## វីតរាគសូត្រ

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវីតរាគសូត្រទី ២ ដូចតទៅនេះ បទថា **មក្ខី** បានដល់ ជាអ្នកលុបគុណ ។ បទថា **បឡាសី** បានដល់ ជាអ្នកប្រកបដោយការវាយឫកស្មើ មានការប្រណាំងប្រជែងជាលក្ខណៈ ។ល។

**អដ្ឋកថាវីតរាគសូត្រទី ២ ចប់**

# សុត្តន្តបិដក

## កុហកសូត្រទី ៣

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកប្រើកិរិយាបំភ័ន្ត ១ ជាអ្នករួសរ៉ាវ ១ ជាអ្នកនិយាយឲ្យទំនង ១ ជាអ្នកមានកលល្បិច ១ ជាអ្នកស្វែងលាភដោយលាភ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកមិនប្រើកិរិយាបំភ័ន្ត ១ ជាអ្នកមិនរួសរ៉ាវ ១ ជាអ្នកមិននិយាយឲ្យទំនង ១ ជាអ្នកមិនមានកលល្បិច ១ ជាអ្នកមិនស្វែងលាភដោយលាភ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## កុហកសូត្រ

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុហកសូត្រទី ៣ ដូចតទៅនេះ បទថា **កុហកោ** បានដល់ ជាអ្នកប្រកបដោយកុហកវត្ថុ គឺរឿងបោកបញ្ឆោត ។

បទថា **លបកោ** បានដល់ ជាអ្នកប្រកបដោយពាក្យរាក់ទាក់អាស្រ័យលាភ ។ បទថា **នេមិត្តិកោ** បានដល់ ជាអ្នកធ្វើអាកប្បកិរិយានៃនិមិត្ត គឺធ្វើសញ្ញា ។ បទថា **និប្បេសិកោ** បានដល់ ជាអ្នកប្រកបដោយល្បិច ។ បទថា **លាភេន លាភំ និជិគីសិតា** បានដល់ ជាអ្នកស្វែងរកលាភ ដោយលាភ ។ សុក្កបក្ខ គឺធម៌ចំណែកល្អ គប្បីជ្រាបដោយការផ្ទុយគ្នា តាមដែលពោលហើយនេះ ៕

**អដ្ឋកថា កុហកសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អសទ្ធសូត្រទី ៤

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនជឿកម្ម និងផល ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ អាប់ឥតប្រាជ្ញា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកប ដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរពជាទីសរសើរ

របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកជឿកម្មផល ១ ខ្មាសបាប ១ ខ្លាចបាប ១ ប្រុងព្យាយាម ១ មានប្រាជ្ញា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## អសទ្ធសូត្រ

[ ៨៤ ] ក្នុងអសទ្ធសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអសទ្ធសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អក្ខមសូត្រទី ៥

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើររបស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹង

រស ១ មិនអត់ធន់នឹងផោដ្ឋព្វៈ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកអត់ទ្រាំនឹងរូប ១ អត់ទ្រាំនឹងសំឡេង ១ អត់ទ្រាំនឹងក្លិន ១ អត់ទ្រាំនឹងរស ១ អត់ទ្រាំនឹងផោដ្ឋព្វៈ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## អក្ខមសូត្រ

[ ៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្ខមសូត្រទី ៥ ដូចតទៅនេះ បទថា **អក្ខមោ ហោតិ រូបានំ** បានដល់ ជាអ្នកមិនអត់ធន់ចំពោះរូបារម្មណ៍ គឺរមែងត្រូវរាគៈជាដើម ដែលមានរូបនោះជាអារម្មណ៍គ្របសង្កត់ ។ ក្នុងបទទាំងពួងក៏ន័យនេះដូចគ្នា ។l៚

**អដ្ឋកថា អក្ខមសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បដិសម្ភិទាសូត្រទី ៦

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើររបស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកបានអត្ថប្បដិសម្ភិទា ១ បានធម្មប្បដិសម្ភិទា ១ បាននិរុត្តិប្បដិសម្ភិទា ១ បានបដិភាណប្បដិសម្ភិទា ១ ជាអ្នកឧស្សាហ៍មិនខ្ជិលក្នុងកិច្ចដែលត្រូវធ្វើអ្វីៗ ទោះបីតូចធំរបស់ពួកសព្រហ្មចារី ទាំងប្រកបដោយប្រាជ្ញាឈ្លាសវៃ ក្នុងកិច្ចការនោះល្មមធ្វើបាន ចាត់ចែងបាន ១ ។ ធម៌ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## បដិសម្ភិទាសូត្រ

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសម្ភិទាសូត្រទី ៦ ដូចតទៅនេះ បទថា **អត្ថប្បដិសម្ភិទាបត្តោ** បានដល់ ជាអ្នកបានញាណបែកធ្លាយក្នុងអត្ថ ៥ ។ បទថា **ធម្មប្បដិសម្ភិទាបត្តោ** បានដល់ ជាអ្នកបាននូវញាណបែកធ្លាយក្នុងធម៌ ៤ យ៉ាង ។ បទថា **និរុត្តិប្បដិសម្ភិទាបត្តោ** បានដល់ ជាអ្នកបាននូវញាណបែកធ្លាយក្នុងធម្មនិរុត្តិ ។ បទថា **បដិភាណប្បដិសម្ភិទាបត្តោ**

បានដល់ ជាអ្នកបានទូវញាណដែលបែកធ្លាយក្នុងញាណទាំងនោះ ។ តែភិក្ខុដែលសម្រេចបដិភាណប្បដិសម្ភិទានោះ រមែងដឹងញាណទាំង ៣ នោះប៉ុណ្ណោះ មិនធ្វើកិច្ចរបស់ញាណទាំងនោះឡើយ ។ បទថា **ឧច្ចាវចានិ** បានដល់ ធំតូច ។ បទថា **កឹករណីយានិ** បានដល់ កិច្ចដែលគួរធ្វើយ៉ាងនេះ ។៙

## អដ្ឋកថា បដិសម្ភិទាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សីលសូត្រទី ៧

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុមានសីល ជាអ្នកសង្រួមដោយការសង្រួមក្នុងបាតិមោក្ខ ប្រកបដោយអាចារៈ និងគោចរ តែងឃើញភ័យក្នុងទោសទាំងឡាយ ទោះបីតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកស្តាប់ច្រើន ចាំរបស់ដែលស្តាប់ហើយ ចេះចាំលែងភ្លេចនូវរបស់ដែលស្តាប់ហើយ ពួកធម៌ណាមានលម្អត្រង់ខាងដើម មានលម្អត្រង់

កណ្តាល មានលម្អត្រង់ខាងចុង ប្រកាសព្រហ្មចារ្យ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ បរិបូណ៌គ្រប់គ្រាន់ដ៏បរិសុទ្ធ ភិក្ខុនោះបានស្តាប់ធម៌ មានសភាពយ៉ាងនោះច្រើន ជាអ្នកស្ទាត់រត់មាត់ នឹកឃើញដោយចិត្តបាន ចាក់ធ្លុះល្អដោយប្រាជ្ញាបាន ១ ជាអ្នកមានសម្តីពីរោះគឺកកងល្អ ប្រកបដោយសម្តីអ្នកក្រុងហូរមិនទាក់ មិនខុស ច្បាស់ បានសេចក្តី ១ ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានទូលាយនូវឈានទាំង ៤ ជាឈានអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា

## សីលសូត្រ

[ ៨៧ ] សីលសូត្រទី ៧ មានអត្ថងាយយល់ទាំងអស់ហើយ ។ ក្នុងសូត្រនេះ សីល គឺសីលរបស់ព្រះខីណាស្រព សុម្បីពាហុសច្ចៈ ក៏ជាពាហុសច្ចៈរបស់ព្រះខីណាស្រព ។ សុម្បីវាចា ក៏ជាវាចាល្អរបស់ព្រះខីណាស្រពដូចគ្នា សុម្បីឈានក៏គប្បីជ្រាបថា លោកពោលថា ជាកិរិយាឈាន

ប៉ុណ្ណោះ ។៚

## អដ្ឋកថា សីលសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ថេរសូត្រទី ៨

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ជាអ្នកប្រតិបត្តិ មិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈដឹងរាត្រីបួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត ១ សម្បូរដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ។បេ។ ចាក់ធ្លុះល្អដោយប្រាជ្ញា ១ តែជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ដ៏វិបរិត ១ ភិក្ខុនោះញុំាងជនច្រើន ឲ្យឃ្លាតចាកព្រះសទ្ធម្ម ឲ្យតម្កល់នៅក្នុងអសទ្ធម្ម ភិក្ខុដទៃដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនោះជាថេរៈដឹងរាត្រីបួសយូរខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់ច្រើន ជាអ្នកមានយស មានបរិវារច្រើន

ទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកដឹងច្បាស់ ចាំរបស់ដែលធ្វើហើយ ចាំលែងភ្លេចនូវរបស់ដែលធ្វើហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិដើម្បីមិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនប្រយោជន៍ដល់ជនច្រើន មិនមែនជាគុណទេ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីគុណ និងសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រីបួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត ១ ជាអ្នកសម្បូរដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងច្បាស់ ចាំរបស់ដែលធ្វើហើយ ចាំលែងភ្លេចនូវរបស់ដែលធ្វើហើយ ។បេ។ ចាក់ធ្លុះដោយប្រាជ្ញា ១ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិត ១ ភិក្ខុនោះញ៉ាំងជនច្រើន ឲ្យឃ្លាតចាកអសទ្ធម្ម ឲ្យតម្កល់នៅក្នុងព្រះសទ្ធម្ម ពួកភិក្ខុដទៃដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ដឹងរាត្រីបួសយូរខ្លះ ដល់នូវ

ទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹង ស្គាល់ច្រើន មានយស មានជនជាបរិវារច្រើនទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ប្រតិបត្តិដើម្បីគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

# អដ្ឋកថា

## ថេរសូត្រ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងថេរសូត្រទី ៨ ដូចតទៅនេះ បទថា **ថេរោ** បានដល់ ជាអ្នកដល់នូវការមាំទាំ ។ បទថា **រត្តញ្ញូ** បានដល់ ជាអ្នកដឹងរាត្រីច្រើន ដែលកន្លងហើយ តាំងអំពីថ្ងៃបួសមក ។ បទថា **ញាតោ** បានដល់ ដែលគេស្គាល់ គឺប្រាកដហើយ ។ បទថា **យសស្សី** បានដល់ ជាអ្នកអាស្រ័យយស ។ បទថា **មិច្ឆាទិដ្ឋិកោ** បានដល់ ជាអ្នកឃើញ

ដោយមិនឃើញតាមសេចក្តីពិត ។ បទថា **សទ្ធម្មា វុដ្ឋាបេត្វា** បានដល់ បបួលឲ្យចេញចាកធម៌ គឺកុសលកម្មបថ ១០ ។ បទថា **អសទ្ធម្មេ បតិដ្ឋាបេតិ** បានដល់ ឲ្យតាំងនៅក្នុងអកុសលកម្មបថ ១០ ។

អដ្ឋកថា ចោរសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមសេក្ខសូត្រទី ៩

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីត្រេកអរនឹងការងារ ១ សេចក្តីត្រេកអរនឹងតិរច្ឆានកថា ១ សេចក្តីត្រេកអរនឹងកិរិយាដេកលក់ ១ សេចក្តីត្រេកអរនឹងការប្រឡូកប្រឡំដោយពួក ១ មិនពិចារណាចិត្តដែលផុត ( ចាកកិលេស ) យ៉ាងណា ១ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនត្រេកអរនឹងការងារ ១ សេចក្តីមិនត្រេកអរនឹងតិរច្ឆានកថា ១

សេចក្តីមិនត្រេកអរនឹងកិរិយា ដេកលក់ ១ សេចក្តីមិនត្រេកអរនឹងការនៅប្រឡូកប្រឡំដោយពួក ១ ពិចារណាចិត្តដែលផុត ( ចាកកិលេស ) យ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

# អដ្ឋកថា

## បឋមសេក្ខសូត្រ

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសេក្ខសូត្រទី ៩ ដូចតទៅនេះ បទថា **សេក្ខស្ស** បានដល់ ភិក្ខុដែលនៅសិក្សានៅឡើយ គឺនៅមានកិច្ចដែលត្រូវធ្វើ ។ បទថា **បរិហានាយ** បានដល់ ដើម្បីសាបសូន្យចាកគុណខាងលើ ។ សេចក្តីត្រេកអរក្នុងនវកម្ម គឺការកសាង ឈ្មោះថា **កម្មារាមតា** ។ សេចក្តីត្រេកអរក្នុងការសន្ទនាប្រាស្រ័យ ឈ្មោះថា **ភស្សារាមតា** សេចក្តីត្រេកអរក្នុងការដេកលក់ ឈ្មោះថា **និទ្ទារាមតា** ។ ការត្រេកអរក្នុងការប្រឡូកប្រឡំដោយពួក ឈ្មោះថា **សង្គណិការាមតា** ។ បទថា **យថា-វិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** សេចក្តីថា មិនពិចារណាចិត្តតាមដែលរួចផុតហើយ ពិចារណាដល់ទោសដែលខ្លួនលះបាន និងគុណដែលខ្លួនបានទាំងនោះហើយ រមែងមិនធ្វើសេចក្តីព្យាយាមដើម្បីបានគុណជាន់ខ្ពស់ទៀត ។ ក្នុងសូត្រ

នេះ ត្រាស់ហេតុនៃការវិនាស និងហេតុនៃការចម្រើនដោយគុណខាងលើរបស់ព្រះសេក្ខៈ ៧ ពួក ដោយប្រការយ៉ាងនេះ ។ ឯប្រការណាជាហេតុនៃការវិនាសរបស់ព្រះសេក្ខៈ ប្រការនោះ ជាប្រការទី ១ របស់បុថុជ្ជនដូចគ្នាដោយប្រការ ដូច្នេះ ។

## អដ្ឋកថា បឋមសេក្ខសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយសេក្ខសូត្រទី ១០

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅជាសេក្ខៈ តែមានកិច្ចច្រើន មានការងារច្រើន មិនឈ្លាសវៃក្នុងកិច្ចដែលត្រូវធ្វើអ្វីៗ វៀរចាកការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបដោយចេតោសមថៈ ( សេចក្តីរម្ងាប់ចិត្ត ) ខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ ញុំាងថ្ងៃឲ្យកន្លងទៅដោយការងារ

បន្តិចបន្តួច ។ បោះបង់ការព្យួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនៅជាសេក្ខៈ ហើយច្រឡូកច្រឡំដោយគ្រហស្ថ និងបព្វជិត ដោយការជាប់ជំពាក់នឹងគ្រហស្ថដ៏មិនសមគួរ បោះបង់ការព្យួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈចូលទៅកាន់ស្រុកពីព្រឹកពេក ចេញមកវិញថ្ងៃពេក បោះបង់ការព្យួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាសេក្ខៈមិនបានតាមសេចក្ដីប្រាថ្នា បានលំបាក បានដោយក្រនូវវាចាដែលជាគ្រឿងជុសខាត់កិលេស ជាទីសប្បាយដល់ធម៌ ជាគ្រឿងបើកចិត្ត គឺវាចានាំឲ្យកើតសេចក្ដីប្រាថ្នាតិច វាចានាំឲ្យកើតសន្ដោស វាចានាំឲ្យស្ងប់ស្ងាត់ វាចាមិននាំឲ្យច្រឡូកច្រឡំ ( ដោយពួកគណៈ ) វាចានាំឲ្យប្រារព្ធសេចក្ដីព្យាយាម វាចានាំឲ្យកើតសីល វាចានាំឲ្យកើតសមាធិ វាចានាំឲ្យកើតបញ្ញា វាចានាំឲ្យកើតវិមុត្តិ វាចានាំឲ្យកើតវិមុត្តិញាណទស្សនៈមានសភាពដូច្នោះ បោះបង់ការព្យួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ

ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅជាសេក្ខៈ មិនមានកិច្ចច្រើន មិនមានការងារច្រើន ឈ្លាសវៃក្នុងកិច្ចដែលត្រូវធ្វើអ្វីៗ មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន ប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិនញុំាងថ្ងៃឲ្យកន្លងទៅដោយការងារបន្តិចបន្តួច មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបធម៌ជាគ្រឿងស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិននៅច្រឡូកច្រឡំដោយពួកគ្រហស្ថ និងបព្វជិត ដោយការជាប់ជំពាក់នឹងគ្រហស្ថដ៏មិនសមគួរ មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបសេចក្តីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិនចូលទៅកាន់ស្រុកពីព្រឹកពេក មិនចេញមកវិញថ្ងៃពេក មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបសេចក្តីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្ត

ទៅដើម្បីសេចក្ដីមិនសាបសូន្យដល់ ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈបានតាមសេចក្ដីប្រាថ្នា មិនបានលំបាក បានទូលាយ នូវវាចាជាគ្រឿងជុសខាត់កិលេស ជាទីសប្បាយដល់ធម៌ ជាគ្រឿងបើកចិត្ត គឺវាចានាំឲ្យមានប្រាថ្នាតិច វាចានាំឲ្យសន្ដោស វាចានាំឲ្យស្ងប់ស្ងាត់ វាចាមិននាំឲ្យប្រឡូកប្រឡំ ដោយពួកវាចានាំឲ្យប្រារព្ធព្យាយាម វាចានាំឲ្យកើតសីល វាចានាំឲ្យកើតសមាធិ វាចានាំឲ្យកើតបញ្ញា វាចានាំឲ្យកើតវិមុត្តិ វាចានាំឲ្យកើតវិមុត្តិញាណទស្សនៈមានសភាពដូច្នោះ មិនលះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបសេចក្ដីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

ថេរវគ្គទី ៤ ចប់

## ឧទ្ទាននៃថេរវគ្គនោះគឺ

និយាយពីអារម្មណ៍ជាទីរីករាយ ១ ពីភិក្ខុប្រាសចាករាគៈ ១
ពីភិក្ខុប្រើកិរិយាបំភ័ន្ត ១ ពីភិក្ខុជឿកម្មផល ១ ពីភិក្ខុមិន
អត់ធន់ ១ ពីបដិសម្ភិទា ១ ពីសីល ១ ពីភិក្ខុជាថេរៈ ១
និងភិក្ខុជាសេក្ខៈ ដទៃពីរលើកទៀត ។

# អដ្ឋកថា

## ទុតិយសេក្ខសូត្រ

[ ៩០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសេក្ខសូត្រទី ១០ ដូចតទៅនេះថា បទថា **វិយត្តោ** បានដល់ ជាអ្នកអាច គឺឈ្លាស ។ បទថា **កិំករណីយេសុ** បានដល់ ក្នុងកិច្ចដែលគួរធ្វើយ៉ាងនេះ ។ បទថា **ចេតោសមថំ** បានដល់ សមាធិកម្មដ្ឋាន ។ បទថា **អននុលោមិកេន** បានដល់ ដែលមិនសមគួរដល់សាសនា ។ បទថា **អតិកាលេន** បានដល់ ព្រឹកពេក ។ បទថា **អតិទិវា** បានដល់ កន្លងកាលថ្ងៃត្រង់ ដែលហៅថា ពេលថ្ងៃទៅហើយ ។ បទថា **អភិសល្លេខិកា** បានដល់ ជាបដិបទាដុសខាត់កិលេសក្រៃលែង ។ បទថា **ចេតោវិវរណសប្បាយា** បានដល់ ជាសប្បាយដល់សមថៈ និងវិបស្សនា ពោល គឺធម៌ជាគ្រឿងបើកចិត្ត ។ បទថា **អប្បិច្ឆកថា** បានដល់ ពាក្យដែលពោលថា លោកទាំងឡាយ ជាអ្នកប្រាថ្នាតិច ។ បទថា **សន្តុដ្ឋិកថា** បានដល់ ពាក្យដែលពោលថា លោកទាំងឡាយជាអ្នកសន្តោសដោយបច្ច័យ ៤ ។ បទថា **បវិវេកកថា** បានដល់ ពាក្យដែលពោលថា លោកទាំងឡាយជាអ្នកស្ងាត់ដោយវិវេក ៣ ។ បទថា **អសំសគ្គកថា** បានដល់ ពាក្យដែលពោលថា លោកទាំងឡាយជាអ្នកមិនច្រឡូកច្រឡំដោយការច្រឡូកច្រឡំ ៥ យ៉ាង ។ បទថា **វីរិយារម្ភកថា** បានដល់ ពាក្យដែលពោលថា លោកទាំងឡាយប្រារព្ធសេចក្តីព្យាយាម ២ យ៉ាង ។ ក្នុងបទថា **សីលកថា** ជាដើម បានដល់ ពាក្យប្រារព្ធសីល សមាធិ បញ្ញា វិមុត្តិ ៥ យ៉ាង កថា

*ប្រាវត្តវិមុត្តិញាណទស្សនៈ ពោល គឺបច្ចវេក្ខណៈ ១៩ ឈ្មោះថា វិមុត្តិ-ញាណទស្សនកថា ។ ក្នុងបទជាដើមថា* **ន និកាមលាភី** *សេចក្តីថា មិនបានតាមដែលខ្លួនប្រាថ្នា បានដោយលំបាក បានមិនបរិបូណ៌ ។ បទដ៏សេសងាយយល់ទាំងអស់ហើយនោះឯង ។ល។*

**អដ្ឋកថាទុតិយសេក្ខសូត្រទី ១០ ចប់**

**ថេរវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## កកុធវគ្គទី ៥

### បឋមសម្បទាសូត្រទី ១

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៥ យ៉ាង ។ សម្បទា ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ សុតសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា សម្បទា ៥ យ៉ាង ។

# អដ្ឋកថា

## កកុធវគ្គទី ៥

### បឋមសម្បទាសូត្រ

[ ៩១ ] បឋមសម្បទាសូត្រទី ១ ក្នុងកកុធវគ្គទី ៥ លោកពោលសម្បទា ៥ លាយគ្នា ៕

អដ្ឋកថា បឋមសម្បទាសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយសម្បទាសូត្រទី ២

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៥ យ៉ាង ។ សម្បទា ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសីលសម្បទា ១ សមាធិសម្បទា ១ បញ្ញាសម្បទា ១ វិមុត្តិសម្បទា ១ វិមុត្តិញាណទស្សនសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សម្បទា ៥ យ៉ាង ។

# អដ្ឋកថា

## ទុតិយសម្បទាសូត្រ

[ ៩២ ] ក្នុងទុតិយសម្បទាសូត្រទី ២ លោកពោលសម្បទា ៤ ខាងដើមលាយគ្នា សម្បទាទី ៥ ជាលោកិយពិត ។៚

### អដ្ឋកថា ទុតិយសម្បទាសូត្រទី ២ ចប់

# សុត្តន្តបិដក

## ព្យាករណសូត្រទី ៣

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ការព្យាករណ៍ ( អួត ) អរហត្តផលនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុព្យាករអរហត្តផលព្រោះតែខ្លួនល្ងង់វង្វេង ១ ភិក្ខុអ្នកមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នាហើយព្យាករអរហត្តផល ១ ភិក្ខុព្យាករអរហត្តផលព្រោះតែឆ្កួត ព្រោះចិត្តរវើរវាយ ១ ភិក្ខុព្យាករអរហត្តផល ដោយសម្គាល់ថាខ្លួនបាន ១ ភិក្ខុព្យាករអរហត្តផលតាមត្រឹមត្រូវមែន ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ការព្យាករណ៍អរហត្តផល ៥ យ៉ាង ។

# អដ្ឋកថា

## ព្យាករណសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្យាករណសូត្រទី ៣ ដូចតទៅនេះ បទថា **អញ្ញាព្យាករណានិ** បានដល់ ការព្យាករណ៍នូវអរហត្ត ។ បទថា **មន្ទត្តា** បានដល់ ព្រោះការល្ងង់ ព្រោះមិនដឹង ។ បទថា **មោមូហត្តា** បានដល់ ព្រោះការវង្វេង ។ បទថា **អញ្ញំ ព្យាករោតិ** សេចក្តីថា បុគ្គលនោះពោលថា អាត្មាអញសម្រេចអរហត្ត ។ បទថា **ឥច្ឆាបកតោ** បានដល់

*ត្រូវសេចក្តីចង់បានគ្របសង្កត់ ។ បទថា* **អធិមានេន** *បានដល់ ដោយសម្គាល់ថា បានសម្រេច ។ បទថា* **សម្មានេន** *បានដល់ ដោយហេតុ ដោយន័យ ដោយការណ៍ប៉ុណ្ណោះ ។*

**អដ្ឋកថា ព្យាករណសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ផាសុសូត្រទី ៤

*[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានការនៅសប្បាយនេះមាន ៥ ពួក ។ ភិក្ខុនៅសប្បាយ ៥ ពួក គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ១ ព្រោះរម្ងាប់វិតក្កវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ១ ព្រោះប្រាសចាកបីតិ ។បេ។ បានដល់តតិយជ្ឈាន ១ ព្រោះលះបង់សុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ១ បានសម្រេចចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យច្បាស់លាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ភិក្ខុមានការនៅសប្បាយ ៥ ពួក ។*

# អដ្ឋកថា

## ផាសុសូត្រ

[ ៩៤ ] ក្នុងផាសុសូត្រទី ៤ បទថា **ផាសុវិហារា** បានដល់ ធម៌ជាគ្រឿងនៅជាសុខ ។

អដ្ឋកថា ផាសុសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អកុប្បសូត្រទី ៥

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងត្រាស់ដឹងនូវធម៌មិនកម្រើក ( អរហត្ត ) យ៉ាងឆាប់រហ័ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបានដល់អត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ពិចារណាចិត្តដែលផុតហើយយ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងបានត្រាស់ដឹងធម៌មិនកម្រើកយ៉ាងឆាប់រហ័ស ។

# អដ្ឋកថា

## អកុប្បសូត្រ

[ ៩៥ ] ក្នុងអកុប្បសូត្រទី ៥ បទថា **អកុប្បំ** បានដល់ អរហត្ត ៗ។

**អដ្ឋកថា អកុប្បសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សុតសូត្រទី ៦

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងកាលបើធ្វើឲ្យច្រើន បានចម្រើននូវអានាបានស្សតិ រមែងបានត្រាស់ដឹងធម៌មិនកម្រើកយ៉ាងឆាប់រហ័ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ សន្តោសល្អក្នុងបរិក្ខារជាគ្រឿងចិញ្ចឹមជីវិតទាំងឡាយ ១ ជាអ្នកមានអាហារតិច ប្រកបរឿយៗ នូវភាពជាអ្នកមានអាហារតិចក្នុងពោះ ( មិនល្មោភតែស៊ី ) ១ ជាអ្នកដេកលក់តិច ប្រកបការភ្ញាក់រឭក ១ ជាអ្នកស្តាប់ច្រើន ចាំរបស់ដែលឮហើយ ចាំមិនភ្លេចនូវរបស់ដែលឮហើយ ពួកធម៌ណាមានលម្អត្រង់ខាងដើម មានលម្អត្រង់កណ្តាល មានលម្អត្រង់ខាងចុង ប្រកាសព្រហ្មចារ្យ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ បរិសុទ្ធពេញលេញអស់ជើង ធម៌មានសភាពដូច្នោះ

ភិក្ខុនោះបានស្តាប់ធម៌មានសភាពយ៉ាងនោះច្រើន ចាំស្ទាត់រត់មាត់ យល់ច្បាស់ដោយចិត្ត ចាក់ធ្លុះល្អដោយប្រាជ្ញា ១ បានពិចារណាចិត្ត ដែលផុតស្រឡះហើយយ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលបើធ្វើឲ្យច្រើននូវអានាបានស្សតិហើយ រមែងត្រាស់ដឹងនូវធម៌ មិនកម្រើកយ៉ាងឆាប់រហ័ស ។

# អដ្ឋកថា

## សុតសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុតសូត្រទី ៦ ដូចតទៅនេះ បទថា **អប្បដ្ឋោ** បានដល់ ជាអ្នកប្រារព្ធដល់ការងារតិច ។ បទថា **អប្បកិច្ចោ** បានដល់ ជាអ្នកមានកិច្ចដែលត្រូវធ្វើតិច ។ បទថា **សុភរោ** បានដល់ ជាបុគ្គលល្អ គឺចិញ្ចឹមបានងាយ ។ បទថា **សុសន្តោសោ** បានដល់ ជាអ្នកសន្តោសដោយល្អ ដោយសន្តោស ៣ ។ បទថា **ជីវិតបរិក្ខារេសុ** បានដល់ក្នុងវត្ថុដែលចាំបាច់ដល់ជីវិត ។ បទថា **អប្បាហារោ** បានដល់ ជាអ្នកមានអាហារតិច ។ បទថា **អនោទរិកត្តំ** បានដល់ ដល់នូវភាពជាអ្នកមិនយើញតែផ្ទៃ គឺមិនបរិភោគច្រើន ។ បទថា **អប្បមិទ្ធោ** បានដល់ ជាអ្នកមិនដេកលក់ច្រើនឡើយ ។ល។

# សុត្តន្តបិដក

## កថាសូត្រទី ៧

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង កាលបើធ្វើឲ្យច្បាស់នូវអានាបានស្សតិ រមែងត្រាស់ដឹងធម៌មិនកម្រើកយ៉ាងឆាប់រហ័ស។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ មានសន្តោសល្អ ក្នុងបរិក្ខារគ្រឿងចិញ្ចឹមជីវិត ១ ជាអ្នកមានអាហារតិច ប្រកបរឿយៗ នូវភាពជាអ្នកមានអាហារតិចក្នុងពោះ ១ ជាអ្នកដេកលក់តិច ប្រកបរឿយៗ នូវសេចក្ដីភ្ញាក់រឭក ១ បានតាមសេចក្ដីប្រាថ្នា បានមិនលំបាក បានទូលាយនូវវាចា ដែលជាគ្រឿងជុសខាត់កិលេសដ៏ប្រសើរ ជាទីសប្បាយដល់ធម៌ជាគ្រឿងបើកចិត្ត គឺវាចានាំឲ្យប្រាថ្នាតិច វាចានាំឲ្យសន្តោស វាចានាំឲ្យស្ងប់ស្ងាត់ វាចាមិននាំឲ្យច្រឡូកច្រឡំដោយពួក ( គណៈ ) វាចានាំឲ្យប្រារព្ធសេចក្ដីព្យាយាម វាចានាំឲ្យកើតសីល វាចានាំឲ្យកើតសមាធិ វាចានាំឲ្យកើតបញ្ញា វាចានាំឲ្យកើតវិមុត្តិ វាចានាំឲ្យកើតវិមុត្តិញាណទស្សនៈ មានសភាពដូច្នោះ ១ ពិចារណានូវចិត្ត ដែលផុតស្រឡះហើយយ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលបើច្បាស់នូវអានាបានស្សតិ រមែងបានត្រាស់ដឹងនូវធម៌មិនកម្រើក យ៉ាងឆាប់រហ័ស ។

# អដ្ឋកថា

## កថាសូត្រទី ៧

[ ៩៧ ] ក្នុងកថាសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាកថាសូត្រទី ៧ ចប់

## អារញ្ញសូត្រទី ៨

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង កាលបើបានធ្វើអានាបានស្សតិឲ្យច្រើន រមែងបានត្រាស់ដឹងធម៌មិនកម្រើក យ៉ាងឆាប់រហ័ស ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ មានសន្តោសល្អ ក្នុងបរិក្ខារជាគ្រឿងចិញ្ចឹមជីវិត ១ ជាអ្នកមានអាហារតិច ប្រកបរឿយៗ នូវភាពជាអ្នកមានអាហារតិចក្នុងពោះ ១ ជាអ្នកដេកលក់តិច ប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក ១ ជាអ្នកនៅក្នុងព្រៃ មានសេនាសនៈដ៏ស្ងាត់ ១ ពិចារណាចិត្ត ដែលផុតស្រឡះហើយយ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលបើបានធ្វើអានាបានស្សតិឲ្យច្រើន រមែងបានត្រាស់ដឹងធម៌មិនកម្រើក យ៉ាងឆាប់រហ័ស ។

# អដ្ឋកថា

## អារញ្ញសូត្រទី ៨

[ ៩៨ ] ក្នុងអារញ្ញសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអារញ្ញសូត្រទី ៨ ចប់

# សុត្តន្តបិដក

## សីហសូត្រទី ៩

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចម្រឹគ តែងចេញអំពីទីអាស្រ័យក្នុងសម័យរសៀល លុះចេញពីទីអាស្រ័យហើយ ក៏មីគពត់ខ្លួន លុះមីគពត់ខ្លួនរួចហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទៅទិសទាំង ៤ ជុំវិញខ្លួនហើយ ក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងរួចហើយ ក៏ដើរចេញទៅស្វែងរកចំណី ។ សត្វសីហៈនោះ កាលបើប្រហារដំរី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារក្របី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារគោ ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារខ្លាដំបង ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារពួកសត្វតូចៗ ដូចទន្សាយ និងឆ្មាជាទីបំផុត ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះសត្វសីហៈគិតថា ផ្លូវព្យាយាមរបស់អញ ចូរកុំវិនាសឡើយ ។

ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថាសត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត សម្តែងធម៌ចំពោះបរិស័ទដោយពាក្យណា នេះជាសីហនាទរបស់ព្រះតថាគតនោះ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកភិក្ខុ តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកភិក្ខុនី ក៏តថាគតតែងសម្តែងធម៌ ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកឧបាសក ក៏តថាគតតែងសម្តែងធម៌ ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកឧបាសិកា ក៏តថាគតតែងសម្តែងធម៌ ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ ចំពោះពួកបុថុជ្ជន ដោយហោចទៅ សូម្បីពួកអ្នកនាំបាយ និងពួកអ្នកនេសាទ ក៏តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិជ្ជាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគត មានធម៌ជាទីគោរព ជាអ្នកគោរពធម៌ ។

# អដ្ឋកថា

## សីហសូត្រ

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ៩ ដូចតទៅនេះ បទថា **សក្កច្ចញ្ញោវ បហារំ ទេតិ នោ អសក្កច្ចំ** សេចក្តីថា មិនឲ្យក្ឋាំងក្ឋាត់ដោយមិនវ័ិញ្ញូ ។ បទថា **មា មេ យោគ្គបថោ ឆស្ស** សេចក្តីថា ប្ដីដៃចាប់សត្វ ដែលអញជំនាញហើយ របស់អញ ចូរកុំសាបសូន្យទៅឡើយ ។ អធិប្បាយថា មនុស្សទាំងឡាយ ចូរកុំពោលយ៉ាងនេះថា សីហមិគរាជ ១ កាលក្រោកឡើងចាប់នូវសត្វធ្វា ក៏ចាប់មិនបាន ដូច្នេះ ។ ក្នុងបទថា **អន្ន-ភារនេសាទានំ** នេះ បាយជំណើប ហៅថា **អន្ន** បាយជំណើបនោះជារបស់ចាំបាច់សម្រាប់មនុស្សទាំងនោះ ព្រោះហេតុនោះ ទើបមនុស្សទាំងនោះ ឈ្មោះថា **អន្នភារា** ពាក្យនោះ ជាឈ្មោះរបស់អ្នកសុំទាន ។ ព្រានបក្សី ហៅថា **នេសាទ** គឺជាគតទ្រង់សម្ដែងយ៉ាងធ្ងន់ដល់អ្នកសុំទាន ឬព្រានបក្សីទាំងនោះដោយហោចបុគ្គលដែលនៅក្រោយគេបង្អស់ ដោយប្រការដូច្នេះ ៕ល៚

**អដ្ឋកថា សីហសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## កកុធសូត្រទី ១០

[ ១០០ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង កូនអ្នកស្រុកកោឡិយៈម្នាក់ ឈ្មោះកកុធៈ ជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ទើបនឹងស្លាប់ក្លាម បានទៅកើតក្នុងពួកទេវតាមួយរូប ដែលសម្រេចដោយចិត្ត ទេវបុត្តនោះបានអត្តភាពមានសភាពយ៉ាងនេះ ប្រហែលប៉ុនគាមក្ខេត្ត របស់អ្នកស្រុកមគធៈពីរឬបី ។ ទេវបុត្តនោះមិនទើសខ្លួនឯង មិនទើសអ្នកដទៃ ព្រោះតែការបានអត្តភាពនោះឡើយ ។ គ្រានោះ កកុធទេវបុត្រចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឈរក្នុងទីសមគួរ ។ លុះកកុធទេវបុត្ត ឈរក្នុងទីសមគួរហើយ បានទូលព្រះមហាមោគ្គល្លានដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ទេវទត្តកើតចិត្តលុះក្នុងសេចក្តីប្រាថ្នា មានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ បពិត្រលោកម្ចាស់ ទេវទត្តក៏សាបសូន្យចាកឫទ្ធិនោះ ដំណាលគ្នានឹងចិត្តដែលកើតឡើង ។ កកុធទេវបុត្តបានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំលា ព្រះមហាមោគ្គល្លានដ៏មានអាយុ ធ្វើប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះឯង ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយក្នុងទីដ៏

សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន មានកូនអ្នកស្រុកកោឡិយៈម្នាក់ ឈ្មោះកកុធៈ ជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គ ទើបនឹងស្លាប់ថ្មីៗ បានទៅកើតក្នុងពួកទេវតាមួយរូប ដែលសម្រេចដោយចិត្ត ទេវបុត្រនោះបានអត្តភាពយ៉ាងនេះ ប្រហែលប៉ុនគាមក្ខេត្ត របស់អ្នកស្រុកមគធៈពីរឬបី ។ ទេវបុត្រនោះមិនទើសខ្លួនឯង និងទើសអ្នកដទៃព្រោះការបានអត្តភាពនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ កកុធទេវបុត្តចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ ថ្វាយបង្គំខ្ញុំព្រះអង្គ រួចឈរក្នុងទីដ៏សមគួរ ។ លុះកកុធទេវបុត្តនោះ ឈរក្នុងទីដ៏សមគួរហើយ បានថ្លែងពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រលោកម្ចាស់ ទេវទត្តកើតចិត្ត លុះក្នុងសេចក្តីប្រាថ្នាមានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ដំណាលគ្នានឹងចិត្តដែលកើតឡើង បពិត្រព្រះអង្គដ៏ចម្រើន កកុធទេវបុត្តបានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ក្រាបថ្វាយបង្គំលាខ្ញុំព្រះអង្គ ធ្វើប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះឯង ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលមោគ្គល្លាន អ្នកបានកំណត់ដឹងច្បាស់ នូវចិត្តរបស់កកុធទេវបុត្រ ដោយចិត្តហើយថា កកុធទេវបុត្រនិយាយពាក្យណាមួយ ពាក្យទាំងនោះជាពាក្យពិត មិនមែនផ្តេសផ្តាសទេ ដែរឬ ។ ព្រះមហាមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកំណត់ដឹងចិត្ត ដោយចិត្តច្បាស់ថា កកុធទេវបុត្រនិយាយពាក្យណាមួយ ពាក្យទាំង

នោះ ជាពាក្យពិត មិនមែនផ្តេសផ្តាសទេ ។ ព្រះអង្គត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នករក្សាទុកនូវសម្តីនេះ ដ្បិតឥឡូវនេះ មោឃបុរសនោះ ធ្វើខ្លួនឲ្យល្បីដោយខ្លួនឯង ។ ម្នាលមោគ្គល្លាន គ្រូក្នុងលោកនេះមាន ៥ ពួក ។ គ្រូ ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលមោគ្គល្លាន គ្រូពួកមួយក្នុងលោកនេះ មានសីលមិនបរិសុទ្ធទេ តែប្តេជ្ញាថាអញមានសីលបរិសុទ្ធ សីលរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ។ សាវកទាំងឡាយ តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចម្រើននេះ មានសីលមិនបរិសុទ្ធទេ តែប្តេជ្ញាថាអញមានសីលបរិសុទ្ធ សីលរបស់អញបរិសុទ្ធផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថា បើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក វល់អ្វីយើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងតែទំនុកបម្រុងដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា លោកគង់នឹងឮខ្ចរខ្ចាយ ព្រោះតែកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវកទាំងឡាយ តែងរក្សាទុកនូវគ្រូបែបនេះដោយសីល ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថា នឹកសង្ឃឹមនូវការរក្សាអំពីពួកសាវកដោយសីល ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធ អាជីវៈរបស់អញបរិសុទ្ធផូរផង់ មិនសៅហ្មង ។ ពួកសាវកដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចម្រើនមានអាជីវៈមិនបរិសុទ្ធទេ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធ អាជីវៈរបស់អញ

បរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថា បើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ បើរឿងណាមិនគាប់ចិត្តដល់លោក វល់អ្វីយើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងតែរាប់អានដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងពួខ្វខ្វាយ ព្រោះតែកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវកទាំងឡាយ តែងរក្សាទុកនូវគ្រូបែបនេះដោយអាជីវៈ ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថា នឹកសង្ឃឹមនូវការរក្សា អំពីពួកសាវកដោយអាជីវៈ ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញថា អញមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់អញបរិសុទ្ធផូរផង់ មិនសៅហ្មងទេ ។ ពួកសាវកតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចម្រើននេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថា បើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្ត បើរឿងណាមិនគាប់ចិត្តដល់លោក វល់អ្វីយើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងរាប់អានយើងដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងពួខ្វខ្វាយ ព្រោះតែកម្មនោះមិនខានទេ ។ ម្នាលមោគ្គល្លាន ពួកសាវកតែងរក្សាទុកនូវគ្រូបែបនេះ ដោយធម្មទេសនា ឯគ្រូបែបនេះសោតឈ្មោះថា នឹកសង្ឃឹមនូវការរក្សា អំពីពួកសាវកដោយធម្ម-

ទេសនា ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយក្នុងលោកនេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធ វេយ្យាករណ៍របស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ។ ពួកសាវក តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចម្រើននេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធ វេយ្យាករណ៍របស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ដូច្នេះ បើយើងប្រាប់ដល់គ្រហស្ថ គង់លោកមិនគាប់ចិត្តទេ បើរឿងណាមិនគាប់ចិត្តដល់លោក វល់អ្វីយើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងរាប់អាន ( យើង ) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកធ្វើអំពើណា គង់គេដឹង ៗ រឿងលោកនោះមិនខានឡើយ ។ ម្នាលមោគ្គល្លាន ពួកសាវក តែងរក្សាទុកនូវគ្រូបែបនេះដោយវេយ្យាករណ៍ ចំណែកគ្រូមានសភាពយ៉ាងនោះ ឈ្មោះថា នឹកសង្ឃឹមនូវការរក្សាអំពីពួកសាវកដោយវេយ្យាករណ៍ ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវកតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចម្រើននេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ដូច្នេះ បើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ បើរឿងណាមិនគាប់ចិត្តដល់

លោក រវល់អ្វីយើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងរាប់អាន ( យើង ) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកធ្វើអំពើណា គង់លោកឮល្បី ព្រោះអំពើនោះមិនខានឡើយ ។ ម្នាលមោគ្គល្លាន ពួកសាវកតែងរក្សាទុកនូវគ្រូបែបនេះ ដោយញាណទស្សនៈ ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថានឹកសង្ឃឹមនូវការរក្សាអំពីពួកសាវក ដោយញាណទស្សនៈ ។ ម្នាលមោគ្គល្លាន គ្រូ ៥ ពួកនេះឯង តែងមានក្នុងលោក ។ ម្នាលមោគ្គល្លាន ចំណែកតថាគត ជាបុគ្គលមានសីលបរិសុទ្ធ ប្តេជ្ញាថាតថាគតមានសីលបរិសុទ្ធ សីលរបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវកមិនបាច់រក្សាទុក នូវតថាគតដោយសីលទេ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវកដោយសីលទេ ។ តថាគតជាបុគ្គលមានអាជីវៈបរិសុទ្ធ ប្តេជ្ញាថា តថាគតមានអាជីវៈបរិសុទ្ធ អាជីវៈរបស់តថាគត បរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវកមិនបាច់រក្សាតថាគត ដោយអាជីវៈទេ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សា អំពីពួកសាវកដោយអាជីវៈទេ ។ តថាគត ជាបុគ្គលមានធម្មទេសនាបរិសុទ្ធ ប្តេជ្ញាថា តថាគតមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់តថាគត បរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវកមិនបាច់រក្សាតថាគត ដោយធម្មទេសនាឡើយ តថាគតសោតក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយធម្មទេសនាទេ ។ តថាគត ជាបុគ្គលមានវេយ្យាករណ៍បរិសុទ្ធ ប្តេជ្ញាថា តថាគតមានវេយ្យាករណ៍បរិសុទ្ធ វេយ្យា-

ករណ៍របស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវ័កមិនបាច់រក្សាតថាគត ដោយវេយ្យាករណ៍ឡើយ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវ័កដោយវេយ្យាករណ៍ទេ ។ តថាគត ជាបុគ្គលមានញាណទស្សនៈបរិសុទ្ធ ប្តេជ្ញាថា តថាគតមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវ័ក មិនបាច់រក្សាតថាគត ដោយញាណទស្សនៈឡើយ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវ័ក ដោយញាណទស្សនៈទេ ។

**កកុធវគ្គទី ៥ ចប់**

## ឧទ្ទាននៃកកុធវគ្គនោះគឺ

សម្បទា ២ លើក ការព្យាករណ៍អរហត្តផល ១ ការនៅ
សប្បាយ ១ ជាគម្រប់ ៥ និងអកុប្បធម៌ រឿងភិក្ខុបាន
ស្តាប់ច្រើន ១ កថាវត្ថុ ១ ភិក្ខុនៅព្រៃ ១ សត្វសីហៈ ១
ជាគម្រប់ ១០ និងរឿងកកុធទេវបុត្រ ។

**បណ្ណាសកៈទី ២ ចប់**

# អដ្ឋកថា

## កក្កុជសូត្រ

[ ១០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកកុជសូត្រទី ១០ ដូចតទៅនេះ បទថា **អត្តភាវប្បដិលាភោ** គឺបាននូវរាងកាយ ។ ក្នុងបទថា **ទ្វេ វា តីណិ វា មាគធកានិ គាមក្ខេត្តានិ** នេះ ព្រំដែនស្រុកអ្នកមគធៈ មានទំហំតូច ទំហំកណ្ដាល ទំហំធំ គាមខេត្តខាងតូចអំពីនេះទៅ ៤០ ឧសភៈ អំពីនោះមក ៤០ ឧសភៈ រួមជា ១ គាវុត គាមខេត្តខាងកណ្ដាលអំពីនេះទៅ ១ គាវុត អំពីនោះមក ១ គាវុត រួមជាកន្លះយោជន៍ គាមខេត្តខាងធំអំពីនេះទៅ មួយគាវុតកន្លះ អំពីនោះមក មួយគាវុតកន្លះ រួមជា ៣ គាវុត ។ គាមក្ខេត្ត ទាំងនោះ គាមក្ខេត្តខាងតូច ក៏ ៣ គាមក្ខេត្ត គាមក្ខេត្តខាងកណ្ដាល ក៏ ២ គាមក្ខេត្ត ជាទំហំអត្តភាពរបស់ទេវបុត្រនោះ ដូច្នោះ ទើបទេវបុត្រនោះ មានរាងកាយទំហំ ៣ គាវុត ។

បទថា **បរិហាយិស្សាមិ** បានដល់ អញនឹងទំនុកបម្រុងរក្សា ។ បទថា **រក្ខស្សេតំ** បានដល់ អ្នកចូររក្សាវាចានោះ ។ បទថា **មោឃបុរិសោ** បាន ដល់ ជាមនុស្សទទេ ។ បទថា **នាស្សស្ស** បានដល់ មិនគប្បីជាទីពេញចិត្ត របស់លោក ។ បទថា **សមុទាចរេយ្យាម** បានដល់ គប្បីពោល ។ បទថា **កម្មន្តិ** បានដល់ ធ្វើការលើកតម្កើង ។ បទថា **យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតិ** សេចក្ដីថា សាស្ដានេះនឹងធ្វើកម្មណា លោកក៏នឹងប្រាកដ ដោយកម្មនោះ ។ បទដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ហើយ ៕

# អដ្ឋកថា កកុធសូត្រទី ១០ ចប់

# កកុធវគ្គទី ៥ ចប់

# ទុតិយបណ្ណាសក ចប់

# ក្បាលទី ២៨
# សុត្តន្តបិដក បាលីប្រែ -៤២
## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| **បុញ្ញាភិសន្ទវគ្គ** | | |
| បឋមបុញ្ញាភិសន្ទសូត្រ | ...... ...... ...... ...... | ២ |
| អដ្ឋកថាបឋមបុញ្ញាភិសន្ទសូត្រ | ...... ...... ...... ...... | ៥ |
| ទុតិយបុញ្ញាភិសន្ទសូត្រ | ...... ...... ...... ...... | ៧ |
| អដ្ឋកថាទុតិយបុញ្ញាភិសន្ទសូត្រ | ...... ...... ...... ...... | ១០ |
| បឋមសង្វាសសូត្រ | ...... ...... ...... ...... | ១១ |
| អដ្ឋកថាបឋមសង្វាសសូត្រ | ...... ...... ...... ...... | ១៦ |
| ទុតិយសង្វាសសូត្រ | ...... ...... ...... ...... | ១៧ |
| អដ្ឋកថាទុតិយសង្វាសសូត្រ | ...... ...... ...... ...... | ២១ |
| បឋមសមជីវិសូត្រ | ...... ...... ...... ...... | ២១ |
| អដ្ឋកថាបឋមសមជីវិសូត្រ | ...... ...... ...... ...... | ២៣ |
| ទុតិយសមជីវិសូត្រ | ...... ...... ...... ...... | ២៤ |
| អដ្ឋកថាទុតិយសមជីវិសូត្រ | ...... ...... ...... ...... | ២៥ |
| សុប្បវាសសូត្រ | ...... ...... ...... ...... | ២៦ |
| អដ្ឋកថាសុប្បវាសសូត្រ | ...... ...... ...... ...... | ២៨ |
| សុទត្តសូត្រ | ...... ...... ...... ...... | ២៩ |
| អដ្ឋកថាសុទត្តសូត្រ | ...... ...... ...... ...... | ៣០ |

កោជនសូត្រ ...... ...... ...... ...... ៣១

អដ្ឋកថាកោជនសូត្រ ...... ...... ...... ...... ៣២

គិហិសាមិចិសូត្រ ...... ...... ...... ...... ៣២

អដ្ឋកថាគិហិសាមិចិសូត្រ ...... ...... ...... ...... ៣៤

## បត្តកម្មវគ្គ

បត្តកម្មសូត្រ ...... ...... ...... ...... ៣៥

អដ្ឋកថា បត្តកម្មសូត្រ ...... ...... ...... ...... ៤៣

អនុនាថសូត្រ ...... ...... ...... ...... ៤៦

អដ្ឋកថា អនុនាថសូត្រ ...... ...... ...... ...... ៤៩

សព្រហ្មសូត្រ ...... ...... ...... ...... ៥០

អដ្ឋកថា សព្រហ្មសូត្រ ...... ...... ...... ...... ៥២

និរយសូត្រ ...... ...... ...... ...... ៥២

អដ្ឋកថា និរយសូត្រ ...... ...... ...... ...... ៥៣

រូបសូត្រ ...... ...... ...... ...... ៥៣

អដ្ឋកថា រូបសូត្រ ...... ...... ...... ...... ៥៤

សរាគសូត្រ ...... ...... ...... ...... ៥៦

អដ្ឋកថាសរាគសូត្រ ...... ...... ...... ...... ៥៧

អហិសូត្រ ...... ...... ...... ...... ៥៨

អដ្ឋកថាអហិសូត្រ ...... ...... ...... ...... ៦១

ទេវទត្តសូត្រ ...... ...... ...... ...... ៦២

អដ្ឋកថាទេវទត្តសូត្រ ...... ...... ...... ...... ៦៤

បធានសូត្រ ...... ...... ...... ...... ៦៥

អដ្ឋកថាបធានសូត្រ ...... ...... ...... ...... ៦៧

ធម្មិកសូត្រ ...... ...... ...... ...... ៦៧
អដ្ឋកថាធម្មិកសូត្រ ...... ...... ...... ...... ៧០

អបណ្ណកវគ្គ

បធានសូត្រ ...... ...... ...... ...... ៧៣
អដ្ឋកថាបធានសូត្រ ...... ...... ...... ...... ៧៤
ទិដ្ឋិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧៤
សប្បុរិសសូត្រ ...... ...... ...... ...... ៧៥
អដ្ឋកថាសប្បុរិសសូត្រ ...... ...... ...... ...... ៧៩
បឋមអគ្គសូត្រ ...... ...... ...... ...... ៨០
អដ្ឋកថាបឋមអគ្គសូត្រ ...... ...... ...... ...... ៨១
ទុតិយអគ្គសូត្រ ...... ...... ...... ...... ៨១
អដ្ឋកថាទុតិយអគ្គសូត្រ ...... ...... ...... ...... ៨២
កុសិនារាសូត្រ ...... ...... ...... ...... ៨២
អដ្ឋកថាកុសិនារាសូត្រ ...... ...... ...... ...... ៨៤
អចិន្តេយ្យសូត្រ ...... ...... ...... ...... ៨៦
អដ្ឋកថាអចិន្តេយ្យសូត្រ ...... ...... ...... ...... ៨៧
ទក្ខិណាសូត្រ ...... ...... ...... ...... ៨៨
អដ្ឋកថាទក្ខិណាសូត្រ ...... ...... ...... ...... ៩០
វណិជសូត្រ ...... ...... ...... ...... ៩១
អដ្ឋកថាវណិជសូត្រ ...... ...... ...... ...... ៩៤
កម្ពោជសូត្រ ...... ...... ...... ...... ៩៥
អដ្ឋកថាកម្ពោជសូត្រ ...... ...... ...... ...... ៩៦

មចលវគ្គ

បាណាតិបាតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៩៨

មុសាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៩៩

វណ្ណសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០០

កោធសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០២

តមសូត្រ ...... ...... ...... ...... ១០៣

អដ្ឋកថាតមសូត្រ ...... ...... ...... ...... ១០៧

ឱណតសូត្រ ...... ...... ...... ...... ១១០

អដ្ឋកថាឱណតសូត្រ ...... ...... ...... ...... ១១២

បុត្តសូត្រ ...... ...... ...... ...... ១១២

អដ្ឋកថាបុត្តសូត្រ ...... ...... ...... ...... ១១៧

សំយោជនសូត្រ ...... ...... ...... ...... ១២០

អដ្ឋកថាសំយោជនសូត្រ ...... ...... ...... ...... ១២១

ទិដ្ឋិសូត្រ ...... ...... ...... ...... ១២២

អដ្ឋកថាទិដ្ឋិសូត្រ ...... ...... ...... ...... ១២៤

ខន្ធសូត្រ ...... ...... ...... ...... ១២៥

អដ្ឋកថាខន្ធសូត្រ ...... ...... ...... ...... ១២៧

អសុរវគ្គ

អសុរសូត្រ ...... ...... ...... ...... ១២៨

អដ្ឋកថាអសុរសូត្រ ...... ...... ...... ...... ១៣០

បឋមសមាធិសូត្រ ...... ...... ...... ...... ១៣០

អដ្ឋកថាបឋមសមាធិសូត្រ ...... ...... ...... ...... ១៣១

ទុតិយសមាធិសូត្រ ...... ...... ...... ...... ១៣២

អដ្ឋកថាទុតិយសមាធិសូត្រ ...... ...... ...... ...... ១៣៤

តតិយសមាធិសូត្រ ...... ...... ...... ...... ១៣៥
អដ្ឋកថាតតិយសមាធិសូត្រ ...... ...... ...... ...... ១៣៨
ឆវាលាតសូត្រ ...... ...... ...... ...... ១៣៩
អដ្ឋកថាឆវាលាតសូត្រ ...... ...... ...... ...... ១៤០
រាគសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៤២
និសន្តិសូត្រ ...... ...... ...... ...... ១៤៤
អដ្ឋកថានិសន្តិសូត្រ ...... ...... ...... ...... ១៤៧
អត្តហិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៤៨
សិក្ខាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៤៩
បោតលិយសូត្រ ...... ...... ...... ...... ១៥៣
អដ្ឋកថាបោតលិយសូត្រ ...... ...... ...... ...... ១៥៩

## តតិយបណ្ណាសក

### វលាហកវគ្គ

បឋមវលាហកសូត្រ ...... ...... ...... ...... ១៦០
អដ្ឋកថាបឋមវលាហកសូត្រ ...... ...... ...... ...... ១៦៣
ទុតិយវលាហកសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៦៣
កុម្ភសូត្រ ...... ...... ...... ...... ១៦៧
អដ្ឋកថាកុម្ភសូត្រ ...... ...... ...... ...... ១៧០
ឧទករហទសូត្រ ...... ...... ...... ...... ១៧០
អដ្ឋកថាឧទករហទសូត្រ ...... ...... ...... ...... ១៧៣
អម្ពសូត្រ ...... ...... ...... ...... ១៧៤
អដ្ឋកថាអម្ពសូត្រ ...... ...... ...... ...... ១៧៧

អដ្ឋកថាសូត្រទី ៦ ( បិដកមិនមានសូត្រនេះ )
មូសិកាសូត្រ ...... ...... ...... ...... ១៧៧
អដ្ឋកថាមូសិកាសូត្រ ...... ...... ...... ...... ១៨០
ពលិពទ្ទសូត្រ ...... ...... ...... ...... ១៨១
អដ្ឋកថាពលិពទ្ទសូត្រ ...... ...... ...... ...... ១៨៣
រុក្ខសូត្រ ...... ...... ...... ...... ១៨៤
អដ្ឋកថារុក្ខសូត្រ ...... ...... ...... ...... ១៨៦
អាសីវិសសូត្រ ...... ...... ...... ...... ១៨៦
អដ្ឋកថាអាសីវិសសូត្រ ...... ...... ...... ...... ១៨៩

**កេសិវគ្គ**

កេសិសូត្រ ...... ...... ...... ...... ១៩០
អដ្ឋកថាកេសីសូត្រ ...... ...... ...... ...... ១៩៤
ជវសូត្រ ...... ...... ...... ...... ១៩៥
អដ្ឋកថាជវសូត្រ ...... ...... ...... ...... ១៩៦
បតោទសូត្រ ...... ...... ...... ...... ១៩៦
អដ្ឋកថាបតោទសូត្រ ...... ...... ...... ...... ២០២
នាគសូត្រ ...... ...... ...... ...... ២០២
អដ្ឋកថានាគសូត្រ ...... ...... ...... ...... ២០៦
ឋានសូត្រ ...... ...... ...... ...... ២០៧
អដ្ឋកថាឋានសូត្រ ...... ...... ...... ...... ២១០
អប្បមាទសូត្រ ...... ...... ...... ...... ២១១
អដ្ឋកថាអប្បមាទសូត្រ ...... ...... ...... ...... ២១២

អារក្ខសូត្រ ...... ...... ...... ...... ២១៣
អដ្ឋកថាអារក្ខសូត្រ ...... ...... ...... ...... ២១៤
សំវេជនីយសូត្រ ...... ...... ...... ...... ២១៥
អដ្ឋកថាសំវេជនីយសូត្រ ...... ...... ...... ...... ២១៦
បឋមភយសូត្រ និងទុតិយភយសូត្រ ...... ...... ...... ...... ២១៦
អដ្ឋកថាបឋមភយសូត្រ និងទុតិយភយសូត្រ ..... ...... ...... ២១៧

ភយវគ្គ

បឋមភយសូត្រ ...... ...... ...... ...... ២១៨
អដ្ឋកថាបឋមភយសូត្រ ...... ...... ...... ...... ២២២
ទុតិយភយសូត្រ ...... ...... ...... ...... ២២៣
អដ្ឋកថាទុតិយភយសូត្រ ...... ...... ...... ...... ២២៩
បឋមជ្ឈានសូត្រ ...... ...... ...... ...... ២៣០
អដ្ឋកថាបឋមជ្ឈានសូត្រ ...... ...... ...... ...... ២៣៤
ទុតិយជ្ឈានសូត្រ ...... ...... ...... ...... ២៣៧
អដ្ឋកថាទុតិយជ្ឈានសូត្រ ...... ...... ...... ...... ២៣៨
បឋមមេត្តាសូត្រ ...... ...... ...... ...... ២៣៩
អដ្ឋកថាបឋមមេត្តាសូត្រ ...... ...... ...... ...... ២៤៤
ទុតិយមេត្តាសូត្រ ...... ...... ...... ...... ២៤៥
អដ្ឋកថាទុតិយមេត្តាសូត្រ ...... ...... ...... ...... ២៤៦
បឋមអច្ឆរិយសូត្រ ...... ...... ...... ...... ២៤៧
អដ្ឋកថាបឋមអច្ឆរិយសូត្រ ...... ...... ...... ...... ២៤៩
ទុតិយអច្ឆរិយសូត្រ ...... ...... ...... ...... ២៥២
អដ្ឋកថាទុតិយអច្ឆរិយសូត្រ ...... ...... ...... ...... ២៥៣

តតិយអច្ឆរិយសូត្រ ...... ...... ...... ...... ២៥៥
អដ្ឋកថាតតិយអច្ឆរិយសូត្រ ...... ...... ...... ...... ២៥៦
ចតុត្ថអច្ឆរិយសូត្រ ...... ...... ...... ...... ២៥៧
អដ្ឋកថាចតុត្ថអច្ឆរិយសូត្រ ...... ...... ...... ...... ២៦០

បុគ្គលវគ្គ

សំយោជនសូត្រ ...... ...... ...... ...... ២៦២
អដ្ឋកថាសំយោជនសូត្រ ...... ...... ...... ...... ២៦៤
បដិភាណសូត្រ ...... ...... ...... ...... ២៦៥
អដ្ឋកថាបដិភាណសូត្រ ...... ...... ...... ...... ២៦៦
ឧគ្ឃដិតញ្ញូសូត្រ ...... ...... ...... ...... ២៦៦
អដ្ឋកថាឧគ្ឃដិតញ្ញូសូត្រ ...... ...... ...... ...... ២៦៧
ឧដ្ឋានសូត្រ ...... ...... ...... ...... ២៦៨
អដ្ឋកថាឧដ្ឋានសូត្រ ...... ...... ...... ...... ២៦៨
សាវជ្ជសូត្រ ...... ...... ...... ...... ២៦៩
អដ្ឋកថាសាវជ្ជសូត្រ ...... ...... ...... ...... ២៧១
បឋមសីលសូត្រ ...... ...... ...... ...... ២៧១
អដ្ឋកថាបឋមសីលសូត្រ ...... ...... ...... ...... ២៧២
ទុតិយសីលសូត្រ ...... ...... ...... ...... ២៧៣
អដ្ឋកថាទុតិយសីលសូត្រ ...... ...... ...... ...... ២៧៣
និក្កដ្ឋសូត្រ ...... ...... ...... ...... ២៧៤
អដ្ឋកថានិក្កដ្ឋសូត្រ ...... ...... ...... ...... ២៧៥
ធម្មកថិកសូត្រ ...... ...... ...... ...... ២៧៦
អដ្ឋកថាធម្មកថិកសូត្រ ...... ...... ...... ...... ២៧៧

| | |
|---|---|
| ភាទីសូត្រ ...... ...... ...... ...... | ២៧៨ |
| អដ្ឋកថាភាទីសូត្រ ...... ...... ...... ...... | ២៧៩ |
| **អាភាវគ្គ** | |
| អាភាសូត្រ ...... ...... ...... ...... | ២៨០ |
| អដ្ឋកថាអាភាសូត្រ ...... ...... ...... ...... | ២៨១ |
| បភាសូត្រ ...... ...... ...... ...... | ២៨១ |
| អដ្ឋកថាបភាសូត្រ ...... ...... ...... ...... | ២៨២ |
| អាលោកសូត្រ ...... ...... ...... ...... | ២៨២ |
| អដ្ឋកថាអាលោកសូត្រ ...... ...... ...... ...... | ២៨៣ |
| ឱភាសសូត្រ ...... ...... ...... ...... | ២៨៣ |
| អដ្ឋកថាឱភាសសូត្រ ...... ...... ...... ...... | ២៨៤ |
| បជ្ជោតសូត្រ ...... ...... ...... ...... | ២៨៤ |
| អដ្ឋកថាបជ្ជោតសូត្រ ...... ...... ...... ...... | ២៨៥ |
| បឋមកាលសូត្រ ...... ...... ...... ...... | ២៨៥ |
| អដ្ឋកថាបឋមកាលសូត្រ ...... ...... ...... ...... | ២៨៦ |
| ទុតិយកាលសូត្រ ...... ...... ...... ...... | ២៨៦ |
| អដ្ឋកថាទុតិយកាលសូត្រ ...... ...... ...... ...... | ២៨៧ |
| បឋមចរិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... | ២៨៨ |
| ទុតិយចរិតសូត្រ ...... ...... ...... ...... | ២៨៨ |
| អដ្ឋកថាទុតិយចរិតសូត្រ ...... ...... ...... ...... | ២៨៩ |
| សារសូត្រ ...... ...... ...... ...... | ២៨៩ |
| អដ្ឋកថាសារសូត្រ ...... ...... ...... ...... | ២៩០ |

# សុត្តន្តបិដក បាលីប្រែ -៤៣

## ឥន្ទ្រិយវគ្គ


| | | |
|---|---|---|
| ឥន្ទ្រិយសូត្រ | ...... ...... ...... ...... | ២៩១ |
| អដ្ឋកថាឥន្ទ្រិយសូត្រ | ...... ...... ...... ...... | ២៩២ |
| បឋមពលសូត្រ | ...... ...... ...... ...... | ២៩២ |
| អដ្ឋកថាបឋមពលសូត្រ | ...... ...... ...... ...... | ២៩៣ |
| ទុតិយពលសូត្រ | ...... ...... ...... ...... | ២៩៣ |
| អដ្ឋកថាទុតិយពលសូត្រ | ...... ...... ...... ...... | ២៩៤ |
| តតិយពលសូត្រ និងអដ្ឋកថា | ...... ...... ...... ...... | ២៩៤ |
| ចតុត្ថពលសូត្រ និងអដ្ឋកថា | ...... ...... ...... ...... | ២៩៥ |
| កប្បសូត្រ | ...... ...... ...... ...... | ២៩៦ |
| អដ្ឋកថាកប្បសូត្រ | ...... ...... ...... ...... | ២៩៦ |
| រោគសូត្រ | ...... ...... ...... ...... | ២៩៧ |
| អដ្ឋកថារោគសូត្រ | ...... ...... ...... ...... | ៣០០ |
| បរិហានិសូត្រ | ...... ...... ...... ...... | ៣០០ |
| អដ្ឋកថាបរិហានសូត្រ | ...... ...... ...... ...... | ៣០២ |
| ភិក្ខុនីសូត្រ | ...... ...... ...... ...... | ៣០៣ |
| អដ្ឋកថាភិក្ខុនីសូត្រ | ...... ...... ...... ...... | ៣០៨ |
| សុគតសូត្រ | ...... ...... ...... ...... | ៣១០ |
| អដ្ឋកថាសុគតសូត្រ | ...... ...... ...... ...... | ៣១៥ |


## បដិបទាវគ្គ


| | | |
|---|---|---|
| សង្ខិត្តសូត្រ | ...... ...... ...... ...... | ៣១៧ |
| អដ្ឋកថាសង្ខិត្តសូត្រ | ...... ...... ...... ...... | ៣១៨ |

វិត្ថារសូត្រ ...... ...... ...... ...... ៣១៨
អដ្ឋកថាវិត្ថារសូត្រ ...... ...... ...... ...... ៣២១
អសុកសូត្រ ...... ...... ...... ...... ៣២៣
អដ្ឋកថាអសុកសូត្រ ...... ...... ...... ...... ៣២៧
បឋមខមសូត្រ ...... ...... ...... ...... ៣២៩
អដ្ឋកថាបឋមខមសូត្រ ...... ...... ...... ...... ៣៣១
ទុតិយខមសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៣២
ឧកយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៣៥
មហាមោគ្គល្លានសូត្រ ...... ...... ...... ...... ៣៣៦
អដ្ឋកថាមហាមោគ្គល្លានសូត្រ ...... ...... ...... ...... ៣៣៨
សារីបុត្តសូត្រ ...... ...... ...... ...... ៣៣៨
អដ្ឋកថាសារីបុត្តសូត្រ ...... ...... ...... ...... ៣៤០
សសង្ខារសូត្រ ...... ...... ...... ...... ៣៤០
អដ្ឋកថាសសង្ខារសូត្រ ...... ...... ...... ...... ៣៤៣
យុគនទ្ធសូត្រ ...... ...... ...... ...... ៣៤៥
អដ្ឋកថាយុគនទ្ធសូត្រ ...... ...... ...... ...... ៣៤៧

## សញ្ចេតនិយវគ្គ

ចេតនាសូត្រ ...... ...... ...... ...... ៣៥០
អដ្ឋកថាចេតនាសូត្រ ...... ...... ...... ...... ៣៥៥
វិភត្តិសូត្រ ...... ...... ...... ...... ៣៦២
អដ្ឋកថាវិភត្តិសូត្រ ...... ...... ...... ...... ៣៦៤
កោដ្ឋិកសូត្រ ...... ...... ...... ...... ៣៦៥
អដ្ឋកថាកោដ្ឋិកសូត្រ ...... ...... ...... ...... ៣៦៧

អានន្ទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៧០
ឧបវាណសូត្រ ...... ...... ...... ...... ៣៧២
អដ្ឋកថាឧបវាណសូត្រ ...... ...... ...... ...... ៣៧៤
អាយាចនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៧៥
រាហុលសូត្រ ...... ...... ...... ...... ៣៧៧
អដ្ឋកថារាហុលសូត្រ ...... ...... ...... ...... ៣៧៨
ជម្ពាលីសូត្រ ...... ...... ...... ...... ៣៨០
អដ្ឋកថាជម្ពាលីសូត្រ ...... ...... ...... ...... ៣៨៣
និព្វានសូត្រ ........ ......... .......... ៣៨៨
អដ្ឋកថានិព្វានសូត្រ ...... ...... ...... ...... ៣៩០
មហាបទេសសូត្រ ...... ...... ...... ...... ៣៩០
អដ្ឋកថាមហាបទេសសូត្រ ...... ...... ...... ...... ៣៩៧

### យោធាជីវវគ្គ

យោធសូត្រ ...... ...... ...... ...... ៤០២
អដ្ឋកថាយោធសូត្រ ...... ...... ...... ...... ៤០៤
បាដិភោគសូត្រ ...... ...... ...... ...... ៤០៥
អដ្ឋកថាបាដិភោគសូត្រ ...... ...... ...... ...... ៤០៦
សុតសូត្រ ...... ...... ...... ...... ៤០៦
អដ្ឋកថាសុតសូត្រ ...... ...... ...... ...... ៤១០
អភយសូត្រ ...... ...... ...... ...... ៤១០
អដ្ឋកថាអភយសូត្រ ...... ...... ...... ...... ៤១៥
ព្រាហ្មណសច្ចសូត្រ ...... ...... ...... ...... ៤១៧
អដ្ឋកថាព្រាហ្មណសច្ចសូត្រ ...... ...... ...... ...... ៤២០

ឧម្មង្គសូត្រ ...... ...... ...... ...... ៤២៣
អដ្ឋកថាឧម្មង្គសូត្រ ...... ...... ...... ...... ៤២៦
វស្សការសូត្រ ...... ...... ...... ...... ៤២៧
អដ្ឋកថាវស្សការសូត្រ ...... ...... ...... ...... ៤៣២
ឧបកសូត្រ ...... ...... ...... ...... ៤៣៤
អដ្ឋកថាឧបកសូត្រ ...... ...... ...... ...... ៤៣៧
សច្ឆិកិរិយសូត្រ ...... ...... ...... ...... ៤៣៩
អដ្ឋកថាសច្ឆិកិរិយសូត្រ ...... ...... ...... ...... ៤៤០
ឧបោសថសូត្រ ...... ...... ...... ...... ៤៤០
អដ្ឋកថាឧបោសថសូត្រ ...... ...... ...... ...... ៤៤៤

## មហាវគ្គ

សោតានុគតសូត្រ ...... ...... ...... ...... ៤៤៧
អដ្ឋកថាសោតានុគតសូត្រ ...... ...... ...... ...... ៤៥២
ឋានសូត្រ ...... ...... ...... ...... ៤៥៥
អដ្ឋកថាឋានសូត្រ ...... ...... ...... ...... ៤៦៣
ភទ្ទិយសូត្រ ...... ...... ...... ...... ៤៦៤
អដ្ឋកថាភទ្ទិយសូត្រ ...... ...... ...... ...... ៤៧៤
សាមុគិយសូត្រ ...... ...... ...... ...... ៤៧៥
អដ្ឋកថាសាមុគិយសូត្រ ...... ...... ...... ...... ៤៧៩
វប្បសូត្រ ...... ...... ...... ...... ៤៨១
អដ្ឋកថាវប្បសូត្រ ...... ...... ...... ...... ៤៩០
សាឡ្ហសូត្រ ...... ...... ...... ...... ៤៩៧
អដ្ឋកថាសាឡ្ហសូត្រ ...... ...... ...... ...... ៥០៣

មល្លិកសូត្រ ...... ...... ...... ...... ៥០៥
អដ្ឋកថាមល្លិកសូត្រ ...... ...... ...... ...... ៥១២
អត្តន្ទបសូត្រ ...... ...... ...... ...... ៥១៣
អដ្ឋកថាអត្តន្ទបសូត្រ ...... ...... ...... ...... ៥២៩
តណ្ហាសូត្រ ...... ...... ...... ...... ៥៥៦
អដ្ឋកថាតណ្ហាសូត្រ ...... ...... ...... ...... ៥៦០
បេមសូត្រ ...... ...... ...... ...... ៥៦៥
អដ្ឋកថាបេមសូត្រ ...... ...... ...... ...... ៥៧៧

# បណ្ណាសកាសង្គហិតវត្ថុ

## សប្បុរិសវគ្គ

សិក្ខាបទសូត្រទី ១ ជាដើម ...... ...... ...... ...... ៥៧៩
អដ្ឋកថាសិក្ខាបទសូត្រទី ១ ជាដើម ...... ...... ...... ...... ៥៩១
បឋមបាបធម្មសូត្រ ...... ...... ...... ...... ៥៩២
អដ្ឋកថាបឋមបាបធម្មសូត្រ ...... ...... ...... ...... ៥៩៣
ទុតិយបាបធម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៥៩៤
តតិយបាបធម្មសូត្រ ...... ...... ...... ...... ៥៩៥
អដ្ឋកថាតតិយបាបធម្មសូត្រ ...... ...... ...... ...... ៥៩៧
ចតុត្ថបាបធម្មសូត្រ ...... ...... ...... ...... ៥៩៧
អដ្ឋកថាចតុត្ថបាបធម្មសូត្រ ...... ...... ...... ...... ៥៩៩

## សោភនវគ្គ

បរិសាសូត្រ ...... ...... ...... ...... ៦០០
អដ្ឋកថាបរិសាសូត្រ ...... ...... ...... ...... ៦០១

ទិដ្ឋិសូត្រ ...... ...... ...... ...... ៦០១
អដ្ឋកថាទិដ្ឋិសូត្រ ...... ...... ...... ...... ៦០២
អកតញ្ញុតាសូត្រ ...... ...... ...... ...... ៦០២
អដ្ឋកថាអកតញ្ញុតាសូត្រ ...... ...... ...... ...... ៦០៣
បាណាតិបាតសូត្រ ...... ...... ...... ...... ៦០៤
អដ្ឋកថាបាណាតិបាតសូត្រ ...... ...... ...... ...... ៦០៥
បឋមមគ្គសូត្រ ...... ...... ...... ...... ៦០៥
អដ្ឋកថាបឋមមគ្គសូត្រ ...... ...... ...... ...... ៦០៥
ទុតិយមគ្គសូត្រ ...... ...... ...... ...... ៦០៦
អដ្ឋកថាទុតិយមគ្គសូត្រ ...... ...... ...... ...... ៦០៦
បឋមវោហារបថសូត្រ ...... ...... ...... ...... ៦០៦
អដ្ឋកថាបឋមវោហារបថសូត្រ ...... ...... ...... ...... ៦០៧
ទុតិយវោហារបថសូត្រទី ៨ ជាដើម ...... ...... ...... ...... ៦០៧
អដ្ឋកថាទុតិយវោហារបថសូត្រទី ៨ ជាដើម ...... ...... ...... ...... ៦០៩

## ទុច្ចរិតវគ្គ

ទុច្ចរិតសូត្រជាដើម ...... ...... ...... ...... ៦១០
អដ្ឋកថាទុច្ចរិតសូត្រទី ១ ជាដើម ...... ...... ...... ...... ៦១៦

## កម្មវគ្គ

សង្ខិត្តសូត្រ ...... ...... ...... ...... ៦១៧
អដ្ឋកថាសង្ខិត្តសូត្រ ...... ...... ...... ...... ៦១៨
វិត្ថារសូត្រ ...... ...... ...... ...... ៦១៩
អដ្ឋកថាវិត្ថារសូត្រ ...... ...... ...... ...... ៦២១

សោណកាយនសូត្រ ...... ...... ...... ...... ៦២៣
អដ្ឋកថាសោណកាយនសូត្រ ...... ...... ...... ...... ៦២៧
សិក្ខាបទសូត្រទី ៤ ជាដើម ...... ...... ...... ...... ៦២៨
អដ្ឋកថាសិក្ខាបទសូត្រទី ៤ ជាដើម ...... ...... ...... ...... ៦៣៤
សមណសូត្រ ...... ...... ...... ...... ៦៣៥
អដ្ឋកថាសមណសូត្រ ...... ...... ...... ...... ៦៣៧
អានិសង្សសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៣៩

## អាបត្តិភយវគ្គ

សង្ឃភេទសូត្រ ...... ...... ...... ...... ៦៤១
អដ្ឋកថាសង្ឃភេទសូត្រ ...... ...... ...... ...... ៦៤៤
អាបត្តិសូត្រ ...... ...... ...... ...... ៦៤៥
អដ្ឋកថាអាបត្តិសូត្រ ...... ...... ...... ...... ៦៤៩
សិក្ខានិសំសសូត្រ ...... ...... ...... ...... ៦៥១
អដ្ឋកថាសិក្ខានិសំសសូត្រ ...... ...... ...... ...... ៦៥៤
សេយ្យសូត្រ ...... ...... ...... ...... ៦៥៥
អដ្ឋកថាសេយ្យសូត្រ ...... ...... ...... ...... ៦៥៧
ថូបារហសូត្រ ...... ...... ...... ...... ៦៥៨
អដ្ឋកថាថូបារហសូត្រ ...... ...... ...... ...... ៦៥៨
បញ្ញាវុឌ្ឍិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៥៩
ពហុការសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៦០
បឋមវោហារសូត្រ ...... ...... ...... ...... ៦៦១
អដ្ឋកថាបឋមវោហារសូត្រ ...... ...... ...... ...... ៦៦១
ទុតិយវោហារសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៦២

តតិយវេហាសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៦៣
ចតុត្ថវេហាសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៦៣

## អភិញ្ញាវគ្គ

អភិញ្ញាសូត្រ ...... ...... ...... ...... ៦៦៥
អដ្ឋកថាអភិញ្ញាសូត្រ ...... ...... ...... ...... ៦៦៦
បរិយេសនាសូត្រ ...... ...... ...... ...... ៦៦៦
អដ្ឋកថាបរិយេសនាសូត្រ ...... ...... ...... ...... ៦៦៨
សង្គហសូត្រ ...... ...... ...... ...... ៦៦៨
អដ្ឋកថាសង្គហសូត្រ ...... ...... ...... ...... ៦៦៩
មាលុង្ក្យបុត្តសូត្រ ...... ...... ...... ...... ៦៦៩
អដ្ឋកថាមាលុង្ក្យបុត្តសូត្រ ...... ...... ...... ...... ៦៧១
កុលសូត្រ ...... ...... ...... ...... ៦៧២
អដ្ឋកថាកុលសូត្រ ...... ...... ...... ...... ៦៧៤
បឋមអាជានីយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៧៤
ទុតិយអាជានីយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៧៧
ពលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៧៩
អរញ្ញសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៨០
កម្មបថសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៨១

កម្មបថវគ្គ ...... ...... ...... ...... ៦៨៣
អដ្ឋកថាកម្មបថវគ្គ ...... ...... ...... ...... ៦៨៦
ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក ...... ...... ...... ...... ៦៨៧
អដ្ឋកថាពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក ...... ...... ៦៨៩

# សុត្តន្តបិដក បាលីប្រែ -៤៤

## សេក្ខពលវគ្គ


សន្ទិដ្ឋសូត្រ ...... ...... ...... ...... ៦៩០
អដ្ឋកថាសន្ទិដ្ឋសូត្រ ...... ...... ...... ...... ៦៩២
វិត្ថតសូត្រ ...... ...... ...... ...... ៦៩៣
អដ្ឋកថាវិត្ថតសូត្រ ...... ...... ...... ...... ៦៩៥
ទុក្ខសូត្រ មិនមានអដ្ឋកថា ...... ...... ...... ...... ៦៩៧
ភតសូត្រ មិនមានអដ្ឋកថា ...... ...... ...... ...... ៦៩៨
សិក្ខសូត្រ មិនមានអដ្ឋកថា ...... ...... ...... ...... ៦៩៨
សមាបត្តិសូត្រ ...... ...... ...... ...... ៦៩៩
អដ្ឋកថាសមាបត្តិសូត្រ ...... ...... ...... ...... ៧០១
កាមសូត្រ ...... ...... ...... ...... ៧០១
អដ្ឋកថាកាមសូត្រ ...... ...... ...... ...... ៧០៣
ចវនសូត្រ ...... ...... ...... ...... ៧០៥
អដ្ឋកថាចវនសូត្រ ...... ...... ...... ...... ៧០៦
បឋមអគារវសូត្រ ...... ...... ...... ...... ៧០៧
អដ្ឋកថាបឋមអគារវសូត្រ ...... ...... ...... ...... ៧០៨
ទុតិយអគារវសូត្រ ...... ...... ...... ...... ៧០៩
អដ្ឋកថាទុតិយអគារវសូត្រ ...... ...... ...... ...... ៧១១


## ពលវគ្គ


អននុស្សុតសូត្រ ...... ...... ...... ...... ៧១២
អដ្ឋកថាអននុស្សុតសូត្រ ...... ...... ...... ...... ៧១៣
កូដសូត្រ ...... ...... ...... ...... ៧១៤

អដ្ឋកថាកូដសូត្រ ...... ...... ...... ...... ៧១៥

សន្និត្តសូត្រ ...... ...... ...... ...... ៧១៥

អដ្ឋកថាសន្និត្តសូត្រ ...... ...... ...... ...... ៧១៦

វិត្ថតសូត្រ ...... ...... ...... ...... ៧១៦

អដ្ឋកថាវិត្ថតសូត្រ ...... ...... ...... ...... ៧១៨

ទដ្ឋព្វសូត្រ ...... ...... ...... ...... ៧១៩

អដ្ឋកថាទដ្ឋព្វសូត្រ ...... ...... ...... ...... ៧២០

បុនកូដសូត្រ ...... ...... ...... ...... ៧២២

អដ្ឋកថាបុនកូដសូត្រ ...... ...... ...... ...... ៧២៣

បឋមហិតសូត្រ ...... ...... ...... ...... ៧២៤

អដ្ឋកថាបឋមហិតសូត្រ ...... ...... ...... ...... ៧២៤

ទុតិយហិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧២៥

តតិយហិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧២៦

ចតុត្ថហិតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧២៧


## បញ្ចង្គិកវគ្គ


បឋមគារវសូត្រ ...... ...... ...... ...... ៧២៩

អដ្ឋកថាបឋមគារវសូត្រ ...... ...... ...... ...... ៧៣០

ទុតិយគារវសូត្រ ...... ...... ...... ...... ៧៣០

អដ្ឋកថាទុតិយគារវសូត្រ ...... ...... ...... ...... ៧៣១

ឧបក្កិលេសសូត្រ ...... ...... ...... ...... ៧៣២

អដ្ឋកថាឧបក្កិលេសសូត្រ ...... ...... ...... ...... ៧៣៨

ទុស្សីលសូត្រ ...... ...... ...... ...... ៧៣៩

អដ្ឋកថាទុស្សីលសូត្រ ...... ...... ...... ...... ៧៤១

អនុគ្គហសូត្រ .......... .......... ........ ៧៤២
អដ្ឋកថាអនុគ្គហសូត្រ ...... ...... ...... ...... ៧៤៣
វិមុត្តិសូត្រ ...... ...... ...... ...... ៧៤៤
អដ្ឋកថាវិមុត្តិសូត្រ ...... ...... ...... ...... ៧៤៩
សមាធិសូត្រ ...... ...... ...... ...... ៧៥០
អដ្ឋកថាសមាធិសូត្រ ...... ...... ...... ...... ៧៥២
អង្គិកសូត្រ ...... ...... ...... ...... ៧៥៤
អដ្ឋកថាអង្គិកសូត្រ ...... ...... ...... ...... ៧៦១
ចង្កមសូត្រ ...... ...... ...... ...... ៧៦៦
អដ្ឋកថាចង្កមសូត្រ ...... ...... ...... ...... ៧៦៧
នាគិតសូត្រ ...... ...... ...... ...... ៧៦៧
អដ្ឋកថានាគិតសូត្រ ...... ...... ...... ...... ៧៧២

## សុមនវគ្គ

សុមនសូត្រ ...... ...... ...... ...... ៧៧៤
អដ្ឋកថាសុមនសូត្រ ...... ...... ...... ...... ៧៧៨
ចុន្ទិសូត្រ ...... ...... ...... ...... ៧៨៧
អដ្ឋកថាចុន្ទិសូត្រ ...... ...... ...... ...... ៧៩១
ឧគ្គហសូត្រ ...... ...... ...... ...... ៧៩២
អដ្ឋកថាឧគ្គហសូត្រ ...... ...... ...... ...... ៧៩៥
សីហសូត្រ ...... ...... ...... ...... ៨០០
អដ្ឋកថាសីហសូត្រ ...... ...... ...... ...... ៨០៤
ទានានិសង្សសូត្រ ...... ...... ...... ...... ៨០៥
អដ្ឋកថាទានានិសង្សសូត្រ ...... ...... ...... ...... ៨០៦

| | | |
|---|---|---|
| កាលទានសូត្រ | ...... ...... ...... ...... | ៨០៧ |
| អដ្ឋកថាកាលទានសូត្រ | ...... ...... ...... ...... | ៨០៨ |
| ភោជនទានសូត្រ | ...... ...... ...... ...... | ៨០៩ |
| អដ្ឋកថាភោជនទានសូត្រ | ...... ...... ...... ...... | ៨១០ |
| សទ្ធានិសង្សសូត្រ | ...... ...... ...... ...... | ៨១០ |
| អដ្ឋកថាសទ្ធានិសង្សសូត្រ | ...... ...... ...... ...... | ៨១២ |
| បុត្តសូត្រ | ...... ...... ...... ...... | ៨១៣ |
| អដ្ឋកថាបុត្តសូត្រ | ...... ...... ...... ...... | ៨១៤ |
| សាលសូត្រ | ...... ...... ...... ...... | ៨១៥ |
| អដ្ឋកថាសាលសូត្រ | ...... ...... ...... ...... | ៨១៧ |
| **មុណ្ឌរាជវគ្គ** | | |
| អាទិយសូត្រ | ...... ...... ...... ...... | ៨១៨ |
| អដ្ឋកថាអាទិយសូត្រ | ...... ...... ...... ...... | ៨២២ |
| សប្បុរិសសូត្រ ( មិនមានអដ្ឋកថា ) | ...... ...... ...... ...... | ៨២៣ |
| ឥដ្ឋសូត្រ | ...... ...... ...... ...... | ៨២៤ |
| អដ្ឋកថាឥដ្ឋសូត្រ | ...... ...... ...... ...... | ៨២៧ |
| មនាបទាយិសូត្រ | ...... ...... ...... ...... | ៨២៨ |
| អដ្ឋកថាមនាបទាយិសូត្រ | ........ ......... .......... | ៨៣២ |
| អភិសន្ទសូត្រ និងអដ្ឋកថា | ...... ...... ...... ...... | ៨៣៥ |
| សម្បទាសូត្រ និងអដ្ឋកថា | ...... ...... ...... ...... | ៨៣៨ |
| ធនសូត្រ និងអដ្ឋកថា | ...... ...... ...... ...... | ៨៣៨ |
| ឋានសូត្រ | ...... ...... ...... ...... | ៨៤១ |
| អដ្ឋកថាឋានសូត្រ | ...... ...... ...... ...... | ៨៤៦ |

កោសលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៨៤៧
នារទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៨៤៩

# ទុតិយបណ្ណាសក

## នីវរណវគ្គ

អាវរណសូត្រ ...... ...... ...... ...... ៨៦០
អដ្ឋកថានីវរណសូត្រ ...... ...... ...... ...... ៨៦៣
រាសិសូត្រ ...... ...... ...... ...... ៨៦៥
អដ្ឋកថារាសិសូត្រ ...... ...... ...... ...... ៨៦៥
អង្គសូត្រ ...... ...... ...... ...... ៨៦៦
អដ្ឋកថាអង្គសូត្រ ...... ...... ...... ...... ៨៦៧
សមយសូត្រ ...... ...... ...... ...... ៨៦៩
អដ្ឋកថាសមយសូត្រ ...... ...... ...... ...... ៨៧១
មាតុបុត្តកសូត្រ ...... ...... ...... ...... ៨៧២
អដ្ឋកថាមាតុបុត្តកសូត្រ ...... ...... ...... ...... ៨៧៥
ឧបជ្ឈាយសូត្រ ...... ...... ...... ...... ៨៧៧
អដ្ឋកថាឧបជ្ឈាយសូត្រ ...... ...... ...... ...... ៨៨០
ឋានសូត្រ ...... ...... ...... ...... ៨៨១
អដ្ឋកថាឋានសូត្រ ...... ...... ...... ...... ៨៨៨
កុមារលិច្ឆវីសូត្រ ...... ...... ...... ...... ៨៩១
អដ្ឋកថាកុមារលិច្ឆវីសូត្រ ...... ...... ...... ...... ៨៩៦
បឋមទុល្លភសូត្រ ...... ...... ...... ...... ៨៩៨

អដ្ឋកថាបឋមទុល្លភសូត្រ ...... ...... ...... ...... ៨៩៨
ទុតិយទុល្លភសូត្រ ...... ...... ...... ...... ៨៩៩
អដ្ឋកថាទុតិយទុល្លភសូត្រ ...... ...... ...... ...... ៩០០

## សញ្ញាវគ្គ

បឋមសញ្ញាសូត្រ ...... ...... ...... ...... ៩០១
អដ្ឋកថាបឋមសញ្ញាសូត្រ ...... ...... ...... ...... ៩០២
ទុតិយសញ្ញាសូត្រ ...... ...... ...... ...... ៩០២
អដ្ឋកថាទុតិយសញ្ញាសូត្រ ...... ...... ...... ...... ៩០៣
បឋមវឌ្ឍិសូត្រ ...... ...... ...... ...... ៩០៤
អដ្ឋកថាបឋមវឌ្ឍិ និងទុតិយវឌ្ឍិសូត្រ ...... ...... ...... ...... ៩០៥
សាកច្ឆសូត្រ ...... ...... ...... ...... ៩០៦
អដ្ឋកថាសាកច្ឆសូត្រ ...... ...... ...... ...... ៩០៧
សាជីវសូត្រ ...... ...... ...... ...... ៩០៧
អដ្ឋកថាសាជីវសូត្រ ...... ...... ...... ...... ៩០៨
បឋមឥទ្ធិបាទសូត្រ ...... ...... ...... ...... ៩០៩
អដ្ឋកថាបឋមឥទ្ធិបាទសូត្រ ...... ...... ...... ...... ៩១០
ទុតិយឥទ្ធិបាទសូត្រ ...... ...... ...... ...... ៩១០
អដ្ឋកថាទុតិយឥទ្ធិបាទសូត្រ ...... ...... ...... ...... ៩១១
និព្វិទាសូត្រ និងអាសវក្ខយសូត្រ ...... ...... ...... ...... ៩១២
អដ្ឋកថានិព្វិទាសូត្រជាដើម ...... ...... ...... ...... ៩១៣

## យោធាជីវវគ្គ

បឋមចេតោវិមុត្តិសូត្រ ...... ...... ...... ...... ៩១៤
អដ្ឋកថាបឋមចេតោវិមុត្តិសូត្រ ...... ...... ...... ...... ៩១៧

ទុតិយវិមុត្តិសូត្រ ...... ...... ...... ...... ៩១៩
អដ្ឋកថាទុតិយវិមុត្តិសូត្រ ...... ...... ...... ...... ៩២២
បឋមធម្មវិហារិកសូត្រ ...... ...... ...... ...... ៩២២
អដ្ឋកថាបឋមធម្មវិហារិកសូត្រ ...... ...... ...... ...... ៩២៥
ទុតិយធម្មវិហារិកសូត្រ ...... ...... ...... ...... ៩២៧
អដ្ឋកថាទុតិយធម្មវិហារិកសូត្រ ...... ...... ...... ...... ៩២៨
បឋមយោធាជីវសូត្រ ...... ...... ...... ...... ៩២៩
អដ្ឋកថាបឋមយោធាជីវសូត្រ ...... ...... ...... ...... ៩៣៨
ទុតិយយោធាជីវសូត្រ ...... ...... ...... ...... ៩៤០
អដ្ឋកថាទុតិយយោធាជីវសូត្រ ...... ...... ...... ...... ៩៥៤
បឋមអនាគតសូត្រ ...... ...... ...... ...... ៩៥៦
អដ្ឋកថាបឋមអនាគតសូត្រ ...... ...... ...... ...... ៩៦១
ទុតិយអនាគតសូត្រ ...... ...... ...... ...... ៩៦២
អដ្ឋកថាទុតិយអនាគតសូត្រ ...... ...... ...... ...... ៩៦៨
តតិយអនាគតសូត្រ ...... ...... ...... ...... ៩៦៨
អដ្ឋកថាតតិយអនាគតសូត្រ ...... ...... ...... ...... ៩៧៣
ចតុត្ថអនាគតសូត្រ ...... ...... ...... ...... ៩៧៥
អដ្ឋកថាចតុត្ថអនាគតសូត្រ ...... ...... ...... ...... ៩៧៨

ថេរវគ្គ

វជនីយសូត្រ ...... ...... ...... ...... ៩៨០
អដ្ឋកថាវជនីយសូត្រ ...... ...... ...... ...... ៩៨១
វីតរាគសូត្រ ...... ...... ...... ...... ៩៨១
អដ្ឋកថាវីតរាគសូត្រ ...... ...... ...... ...... ៩៨២
កុហកសូត្រ ...... ...... ...... ...... ៩៨៣

អដ្ឋកថាកុហកសូត្រ ...... ...... ...... ...... ៩៨៣
អសទ្ធសូត្រ ...... ...... ...... ...... ៩៨៤
អដ្ឋកថាអសទ្ធសូត្រ ...... ...... ...... ...... ៩៨៥
អក្ខមសូត្រ ...... ...... ...... ...... ៩៨៥
អដ្ឋកថាអក្ខមសូត្រ ...... ...... ...... ...... ៩៨៦
បដិសម្ភិទាសូត្រ ...... ...... ...... ...... ៩៨៧
អដ្ឋកថាបដិសម្ភិទាសូត្រ ...... ...... ...... ...... ៩៨៧
សីលសូត្រ ...... ...... ...... ...... ៩៨៨
អដ្ឋកថាសីលសូត្រ ...... ...... ...... ...... ៩៨៩
ថេរសូត្រ ...... ...... ...... ...... ៩៩០
អដ្ឋកថាថេរសូត្រ ...... ...... ...... ...... ៩៩២
បឋមសេក្ខសូត្រ ...... ...... ...... ...... ៩៩៣
អដ្ឋកថាបឋមសេក្ខសូត្រ ...... ...... ...... ...... ៩៩៤
ទុតិយសេក្ខសូត្រ ...... ...... ...... ...... ៩៩៥
អដ្ឋកថាទុតិយសេក្ខសូត្រ ...... ...... ...... ...... ៩៩៩

កកុធវគ្គ

បឋមសម្បទាសូត្រ ...... ...... ...... ...... ១០០១
អដ្ឋកថាបឋមសម្បទាសូត្រ ...... ...... ...... ...... ១០០១
ទុតិយសម្បទាសូត្រ ...... ...... ...... ...... ១០០២
អដ្ឋកថាទុតិយសម្បទាសូត្រ ...... ...... ...... ...... ១០០២
ព្យាករណសូត្រ ...... ...... ...... ...... ១០០៣
អដ្ឋកថាព្យាករណសូត្រ ...... ...... ...... ...... ១០០៣
ផាសុសូត្រ ...... ...... ...... ...... ១០០៤

អដ្ឋកថាផាសុសូត្រ ...... ...... ...... ...... ១០០៥

អកុប្បសូត្រ ...... ...... ...... ...... ១០០៥

អដ្ឋកថាអកុប្បសូត្រ ...... ...... ...... ...... ១០០៦

សុតសូត្រ ...... ...... ...... ...... ១០០៦

អដ្ឋកថាសុតសូត្រ ...... ...... ...... ...... ១០០៧

កថាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០០៨

អារញ្ញសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០០៩

សីហសូត្រ ...... ...... ...... ...... ១០១០

អដ្ឋកថាសីហកថាសូត្រ ...... ...... ...... ...... ១០១២

កកុធសូត្រ ...... ...... ...... ...... ១០១៣

អដ្ឋកថាកកុធសូត្រ ...... ...... ...... ...... ១០២០